United Nations
Educational, Scientific and
Cultural Organization

KH/2010/CLT/RP/30
Phnom Penh, June 2010
Original: French

# Sixteenth Plenary Session – ICC-Angkor

Siem Reap – 15 December 2009 – Sokha Angkor Resort

Khmer version

COMITE INTERNATIONAL DE COORDINATION POUR LA SAUVEGARDE ET LE DEVELOPPEMENT DU SITE HISTORIQUE D'ANGKOR
INTERNATIONAL CO-ORDINATING COMMITTEE FOR THE SAFEGUARDING AND DEVELOPMENT OF THE HISTORIC SITE OF ANGKOR

**សម័យប្រជុំពេញអង្គ**

# សម័យប្រជុំពេញអង្គលើកទី១៦

## ក្រោមអធិបតីភាពរបស់សហប្រធាន

**លោក** Jean-François Desmazières
ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព
ស្ថានទូតបារាំង

**លោក** Masafumi Kuroki
ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព
ស្ថានទូតជប៉ុន

សៀមរាប – ថ្ងៃទី ១៥ ធ្នូ ២០០៩ – សណ្ឋាគារ Sokha Angkor Resort

# លេខាធិការដ្ឋាន

| | | |
|---|---|---|
| ការិយាល័យអង្គការ យូណេស្កូ | អាស័យដ្ឋាន | ៣៨ មហាវិថី សម្ដេច សុធារស<br>ប្រអប់សំបុត្រ លេខ ២៩<br>ភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា |
| | លេខទូរស័ព្ទ | (៨៥៥)(២៣)៤២៦ ៧២៦<br>(៨៥៥)(២៣)៧២៣ ០៥៤<br>(៨៥៥)(១២)៩១១ ៦៥១<br>(៨៥៥)(១២)៥៥៦ ២៧៧<br>(៨៥៥)(១៦)៨៣១ ៥២០ |
| | ទូរសារ | (៨៥៥)(២៣)៤២៦ ១៦៣/២១៧០២២ |
| | អ៊ីមែល | bh.lim@unesco.org<br>apsara.ddta@online.com.kh |
| លេខាធិការដ្ឋានអចិន្ត្រៃ | ក្រុងប៉ារីស | លោក Azedine Beschaouch<br>លេខាធិការវិទ្យាសាស្ត្រអចិន្ត្រៃ |
| | ក្រុងភ្នំពេញ | លោក លឹម ប៊ុនហុក<br>លោកស្រី ចៅ ស៊ុន គិរិយ៉ា<br>(អាជ្ញាធរអប្សរា) |

# មាតិកា

I- ពិធីបើកអង្គប្រជុំ ....7

I.1 សុន្ទរកថារបស់ ឯកឧត្តម Jean-François Desmazières ឯកអគ្គរដ្ឋទូតបារាំង....7

I.2 សុន្ទរកថារបស់ ឯកឧត្តម Masafumi Kuroki ឯកអគ្គរាជទូតជប៉ុន....8

I.3 សុន្ទរកថារបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា....10

I.4 សុន្ទរកថារបស់តំណាងអគ្គនាយអង្គការ យូណេស្កូ លោកស្រី François Rivière អគ្គនាយិការងផ្នែកវប្បធម៌....14

I.5 សាររបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងទំនាក់ទំនងនៃសាធារណរដ្ឋបារាំង លោក Frédéric Mitterrand អានដោយលោក Azedine Beschaouch....16

II. របាយការណ៍សកម្មភាពការងារ....17

II.1 របាយការណ៍សកម្មភាពទូទៅរបស់អាជ្ញាធរជាតិអប្សរា ដោយឯកឧត្តម ប៊ុន ណារិទ្ធ ជាអគ្គនាយក....17

II.2 របាយការណ៍សកម្មភាពរបស់ CIC និងការអនុវត្តអនុសាសន៍មុនៗ ដោយលោកសាស្ត្រាចារ្យ Azedine BESCHAOUCH ជាលេខាវិទ្យាសាស្ត្ររបស់ CIC....21

III. ការអភិវឌ្ឍប្រកបដោយចីរភាព....25

III.1 ការគ្រប់គ្រងទឹកនៅក្នុងឧទ្យានអង្គរ ក្នុងអំឡុងពេលខ្យល់ព្យុះ កេតសាណា ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ដោយឯកឧត្តម បណ្ឌិត ហង់ ពៅ ជាអគ្គនាយករងរបស់អាជ្ញាធរជាតិ....25

III.2 ការគ្រប់គ្រងទឹកនៅក្នុងអាកាសយានដ្ឋានសៀមរាប អំឡុងពេលខ្យល់ព្យុះកំបុតត្បូងកេតសាណា ថ្ងៃទី២៩-៣០ ខែកញ្ញា ឆ្នាំ២០០៩ ដោយលោក Georges Ramorasata អ្នកទទួលខុសត្រូវផ្នែកបច្ចេកទេស SCA....28

III.3 គម្រោងពង្រីកបណ្ដាញទឹកស្អាតនៅសៀមរាប ដោយលោក Yoshihiko Sato ប្រធានក្រុមការងារគម្រោង JICA....30

III.4 គម្រោងដាក់ប្រព័ន្ធលូនៅប៉ែកខាងកើតស្ទឹងសៀមរាប ដោយលោក Olivier Gilard អ្នកទទួលបន្ទុកបេសកកម្ម AFD....................................................................................................32

IV. ការស្រាវជ្រាវនិងការអភិរក្ស.........................................................34

IV.1 កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យបណ្តុះបណ្តាលស្តីពីការការពារនិងការអភិរក្សបេតិកភណ្ឌវប្បធម៌ រវាងព្រះរាជាណាចក្រកម្ពុជា និង ICCROM ដោយលោក Mounir Bouchenaki ជាអគ្គនាយក ICCROM ........................................................................34

IV.2 ឯកសារនិងបញ្ជីសារពើភណ្ឌនៃសារមន្ទីររបស់ប្រទេសកម្ពុជា ដោយលោកស្រី Nao Hayashi អ្នកទទួលខុសត្រូវសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ផ្នែកសារមន្ទីរនិងសម្បត្តិវប្បធម៌នៃអង្គការយូណេស្កូ និង ដោយលោក Gaël de Guichen ទីប្រឹក្សារបស់អគ្គនាយក ICCROM ........................................................................36

IV.3 លទ្ធផលគម្រោង "Living with Heritage" ដោយបណ្ឌិត Eleanor Bruce សាស្ត្រាចារ្យ សាកលវិទ្យាល័យ Sydney ........................................................................41

IV.4 ឆ្នាំទីមួយនៃគម្រោង JAYA Koh Ker - របាយការណ៍ឆ្នាំ២០០៩ ដោយលោក Janos Jelen នាយក RAF (Royal Angkor Foundation) ប្រទេសហុងគ្រី..........................................43

IV.5 ទិន្នន័យថ្មីៗស្តីពីប្រភពនៃរាជាធិបតេយ្យនៅអង្គរ ដោយបណ្ឌិត Christophe Pottier វិស្វករ សាលាបារាំងចុងបូព៌ាប្រទេស (EFEO) ប្រទេសបារាំង..........................................47

IV.6 របាយការណ៍របស់ក្រុមអ្នកជំនាញ អាដ ហុក សម្រាប់ការអភិរក្ស ដោយលោក សាស្ត្រាចារ្យ Mounir Bouchenaki, Giorgio Croci , Pierre-André Lablaude និង Kenichiro Hidaka ........................................................................50

IV.7 សំណួរ-ចម្លើយ ស្តីពីរបាយការណ៍សកម្មភាពទាក់ទងនឹងគម្រោងដែលអនុវត្តដោយក្រុមការងារអន្តរជាតិ (របាយការណ៍ត្រូវបានចែកជូន)..........................................60

V. ការអភិវឌ្ឍប្រកបដោយចីរភាព.........................................................64

V.1 កិច្ចសហប្រតិបត្តិការរបស់ក្រសួងវប្បធម៌បារាំង នាយកដ្ឋានស្ថាបត្យកម្មនិងបេតិកភណ្ឌ ដោយលោក Pierre André Lablaude ក្រសួងវប្បធម៌និងទំនាក់ទំនង ប្រទេសបារាំង..........65

V.2 កិច្ចសហប្រតិបត្តិការប្រទេសជប៉ុន៖ ស្ថានភាពនៅពេលបច្ចុប្បន្ននិងគម្រោងនាពេលអនាគតរបស់ JASA ដោយលោក Yosio Ando នាយកផ្នែកកិច្ចសហប្រតិបត្តិការវប្បធម៌ពហុភាគី ក្រសួងការបរទេស ប្រទេសជប៉ុន..........................................66

V.3 កិច្ចសហប្រតិបត្តិការរបស់ប្រទេសនូវែលហ្សេឡង់៖ ជំនួយរបស់ប្រទេសនូវែលហ្សេឡង់

សម្រាប់ការអភិវឌ្ឍសហគមន៍ ដើម្បីការពាររមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ដោយឯកឧត្តម អ៊ុក សុម៉េត ទីប្រឹក្សាប្រធានអាជ្ញាធរជាតិអប្សរា និងលោក Philip Hewitt លេខាធិការទីមួយនិងជាតំណាង ស្ថានទូតប្រទេសនូវែលហ្សេឡង់នៅទីក្រុងបាងកក....70

V.4 កិច្ចសហប្រតិបត្តិការរបស់ប្រទេសអូស្ត្រាលី៖ ធានានិរន្តរភាពបេតិកភណ្ឌកម្ពុជា តាមរយៈភាពជាដៃគូ ដោយលោកជំទាវ Margaret Adamson ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា....72

V.5 កិច្ចសហប្រតិបត្តិការរបស់ប្រទេសកូរ៉េ៖ បណ្តាញផ្លូវរវាងក្រុងសៀមរាប ដោយលោក ទិត សុផា អាជ្ញាធរជាតិអប្សរា និងលោក Lee Kyung-Soo ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ.....74

V.6 កិច្ចសហប្រតិបត្តិការបារាំង៖ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកបេតិកភណ្ឌប្រចាំតំបន់ (ឡាវ វៀតណាម កម្ពុជា)៖ តុល្យាការទីមួយ ដោយលោកស្រី ស៊ីសុវត្ថិ ចន្ទទេវី ជានាយិកា....79

V.7 ការពិចារណាកាលពីថ្ងៃទី ១៤ វិច្ឆិកា ២០០៩ លើទិសដៅការងាររបស់ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយលោក Philippe Delanghe អ្នកឯកទេសកម្មវិធីវប្បធម៌ប្រចាំការិយាល័យអង្គការយូណេស្កូនៅទីក្រុងភ្នំពេញ.............83

ការពិភាក្សាទូទៅ....85

VI. **ការលើកតម្លៃបេតិកភណ្ឌ**....86

VI.1 គម្រោងដាក់ភ្លើងបំភ្លឺអង្គរទៅតាមបទដ្ឋានរមណីយដ្ឋានបេតិកភណ្ឌពិភពលោក៖..........86

ក. សេចក្តីផ្តើម ដោយលោកសាស្ត្រាចារ្យ Azedine Beschaouch....86

ខ. បទបង្ហាញ ដោយលោក Alain Guilhot និងលោក Olivier Binst....88

កិច្ចពិភាក្សាទូទៅ....95

VII. **អនុសាសន៍របស់ សេ អ៊ី សេ**....98

VII.1 ការបង្ហាញជូននូវអនុសាសន៍ ដោយលេខារបស់ សេ អ៊ី សេ....98

VII.2 ការអនុម័តអនុសាសន៍ដោយ សេ អ៊ី សេ....98

VII.3 កាលបរិច្ឆេទនៃសម័យប្រជុំបច្ចេកទេសលើកក្រោយ....99

VII.4 អនុសាសន៍សម័យប្រជុំពេញអង្គលើកទី១៦....101

VIII. **ពិធីបិទអង្គប្រជុំ**....104

VIII.1 សុន្ទរកថាសហប្រធានបារាំង លោក Jean-François Desmazières ឯកអគ្គរដ្ឋទូត..........104

VIII.2 សន្ទរកថាតំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិអប្សរា....................106

**បញ្ជីអ្នកចូលរួមក្នុងអង្គប្រជុំ**....................109

**របាយការណ៍អាជ្ញាធរជាតិអប្សរាឆ្នាំ២០០៩**.................... 121

# I- ពិធីបើកអង្គប្រជុំ

## I.1 សុន្ទរកថារបស់ ឯកឧត្តម Jean-François Desmazières ឯកអគ្គរដ្ឋទូតបារាំង

សូមគោរពលោកឧបនាយករដ្ឋមន្ត្រីដែលជារៀងរាល់ឆ្នាំតែងតែផ្តល់កិត្តិយស ហើយបានមកចូលរួមជាមួយយើងនៅថ្ងៃនេះ នៅក្នុងគណៈកម្មាធិការសម្របសម្រួលអន្តរជាតិសម្រាប់កិច្ចការអភិរក្សនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ។

សូមគោរពឯកឧត្តម ព្រះរាជតំណាងផ្ទាល់របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី

លោក លោកស្រី ដែលជាឯកអគ្គរដ្ឋទូត រាជទូតមកពីទីក្រុងបាងកក ឬក៏មកពីទីក្រុងភ្នំពេញ លោក លោកស្រី

និងមិត្តភ័ក្តិទាំងអស់ជាទីស្រឡាញ់រាប់អាន!

ថ្ងៃនេះគឺជាសម័យប្រជុំលើកទីដប់ប្រាំមួយរបស់គណៈកម្មាធិការអន្តរជាតិរបស់យើង។ លោកស្រីជាតំណាងរបស់អគ្គនាយិការយូណេស្កូជាទីគោរព! នេះគឺជាសម័យប្រជុំពេញអង្គលើកទី១៦! យើងក៏ត្រូវស្វាគមន៍អគ្គនាយិការបស់យូណេស្កូផងដែរ មិនមែនជាអគ្គនាយកទៀតទេ។ សម័យប្រជុំលើកទី១៦នេះមានន័យថា ស្ថាប័ននេះពិតជាបានបង្ហាញឲ្យឃើញអំពីសារប្រយោជន៍របស់ខ្លួន ហើយស្ថាប័ននេះនឹងអាចធ្វើជាឧទាហរណ៍ចំពោះអ្នកទាំងឡាយណាដែលមានបំណងរៀបចំឲ្យបានប្រសើរជាងមុន នូវការការពារបេតិកភណ្ឌពិភពលោកនៅក្នុងប្រទេសរបស់ខ្លួន។

ទោះជាយ៉ាងណាក៏ដោយ សមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការ រាជរដ្ឋាភិបាលកម្ពុជា យូណេស្កូ ប្រទេសជប៉ុន និងប្រទេសបារាំង មានសេចក្តីរីករាយនឹងធ្វើការជាមួយគ្នាជារៀងរាល់ឆ្នាំដើម្បីបំពេញភារកិច្ចនេះ និងសូមបង្ហាញជូននូវរបៀបវារៈដែលលេខាធិការដ្ឋានបានរៀបរៀងឡើង ឲ្យត្រូវទៅតាមភាពជាក់ស្តែងបំផុតតាមដែលអាចធ្វើទៅបាន។

ខ្ញុំសូមស្វាគមន៍វត្តមានរបស់ឯកឧត្តម Masafumi Kuroki ជាឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមនឹងដឹកនាំសម័យប្រជុំនេះជាលើកទីមួយ ជាមួយនឹងរូបខ្ញុំ។

ខ្ញុំក៏សូមស្វាគមន៍ផងដែរវត្តមានរបស់លោកសាស្ត្រាចារ្យ Kenichiro Hidaka ដែលបានចូលរួមក្នុងក្រុមអ្នកជំនាញ អាដ ហុក សម្រាប់ការអភិរក្ស។ គ្រប់គ្នាសុទ្ធតែដឹងហើយថា អ្នកជំនាញ អាដ ហុក ខាងការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាព នឹងស្ថិតនៅក្នុងចំណោមមនុស្សសំខាន់នៃគណៈកម្មាធិការរបស់យើង ហើយពួកគាត់ផ្តល់នូវអព្យាក្រឹត្យភាព ភាពម៉ឺងម៉ាត់និងការធានាដែលយើងមានទំនុកចិត្តនិងក្តីសង្ឃឹមពីគណៈកម្មាធិការនេះ។

ដូចសព្វមួយដងដែរ យើងមានរបៀបវារៈមួយដែលមានបទអន្តរាគមន៍និងបទបង្ហាញច្រើន។

នៅក្នុងរបៀបវារៈនេះ យើងមានបំណងនិយាយអំពីបញ្ហាដែលអាចជាបញ្ហាបច្ចុប្បន្នភាពនិងបញ្ហាទាក់ទងនឹងការអភិវឌ្ឍ៖ ចំណុចទីបីស្តីពីអង្គរនិងទឹកនឹងនិយាយជាអាទិ៍អំពីផលវិបាកបណ្តាលមកពីខ្យល់ព្យុះកំបុតត្បូង *Ketsana* នៅសៀមរាប។ យើងទាំងអស់គ្នាដឹងហើយថា សៀមរាបត្រូវបានទឹកជន់លិច។ វាគឺជាការល្អដែលត្រូវពិនិត្យមើល

ព្រឹត្តិការណ៍ទាំងនេះ។

ក្រៅពីរបាយការណ៍ជាទម្លាប់ស្តីពីការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាព យើងនឹងមានការរិះគិតពិចារណាមួយអំពីរបៀបរៀបចំចាត់ចែងអ្នកជំនាញខាងការអភិវឌ្ឍប្រកបដោយចីរភាពរបស់យើង។ នេះគឺជាចំណុចសំខាន់មួយនៃការវិវត្តរបស់ CIC នេះ។

យើងក៏នឹងនិយាយឡើងវិញផងដែរអំពីបញ្ហានៃការដាក់ភ្លើងបំភ្លឺនៅពេលយប់។ វាគឺជាចំណុចដ៏លំបាកមួយ។ វាគឺជាចំណុចមួយដែលយើងត្រូវតែពិនិត្យពិភាក្សា។ វាគឺជាចំណុចមួយដែលត្រូវតែប្រុងប្រយ័ត្នបំផុត។ ហើយដោយហេតុដូច្នេះ យើងនឹងចំណាយពេលច្រើនបន្តិចនៅរសៀលនេះដើម្បីនិយាយអំពីបញ្ហានេះ។

នៅទីបញ្ចប់ យើងនឹងសាកល្បងប្រមើមើល និងពិចារណាដល់អនាគតនៃស្ថាប័នរបស់យើង។ ខ្ញុំនឹងមិននិយាយទៅកាន់លោក លោកស្រី លើសពីនេះទៀតទេ ព្រោះថា ដូចជារៀងរាល់ឆ្នាំដែរ របៀបវារៈមានបទបង្ហាញច្រើនគួរសម ដូច្នេះ ខ្ញុំសំណូមពរទៅសហប្រធានជប៉ុន គឺឯកឧត្តម Masafumi Kuroki មេត្តាមានប្រសាសន៍ទៅកាន់អង្គប្រជុំ។

## I.2 សុន្ទរកថារបស់ ឯកឧត្តម Masafumi Kuroki ឯកអគ្គរាជទូតជប៉ុន

សូមអរគុណ លោកសហប្រធាន។

ដោយហេតុថានេះជាលើកទី១ ដែលខ្ញុំចូលរួមក្នុងកិច្ចប្រជុំនេះ សូមអនុញ្ញាតឲ្យខ្ញុំថ្លែងសុន្ទរកថាវែងជាងសហប្រធានបន្តិចរបស់ខ្ញុំបន្តិច។

សូមគោរព ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី! ឯកឧត្តម អ៊ុំ វិជ្ជារាវុធ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា លោកស្រី Françoise Rivière អគ្គនាយករងនៃអង្គការយូណេស្កូដើម្បីវិស័យវប្បធម៌ ឯកឧត្តម ប៊ុន ណារិទ្ធ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរាជាទីគោរព! ឯកឧត្តមឯកអគ្គរដ្ឋទូត មិត្តរួមការងារអស់លោក លោកស្រី ជាទីមេត្រី !

ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដែលបានចូលរួមក្នុងនាមជាសហប្រធាននៃសម័យប្រជុំពេញអង្គលើកទី១៦ នៃគណៈធម្មាធិការសម្របសម្រួលអន្តរជាតិ ដើម្បីអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរ ដែលចាប់រៀបចំធ្វើឡើងតាំងពីឆ្នាំឆ្នាំ១៩៩៣មក។

ខ្ញុំសូមផ្តើមសុន្ទរកថា ដោយសម្តែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ ចំពោះវត្តមានរបស់ឯកឧត្តម សុខ អាន ចំពោះការចូលរួមរបស់ឯកឧត្តម អ៊ុំ វិជ្ជារាវុធ ដែលជាសក្ខីភាពនៃការគាំទ្រជាអចិន្ត្រៃយ៍របស់ព្រះមហាក្សត្រ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះ លោកស្រី Françoise Rivière។ វត្តមានរបស់លោកស្រីបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំងនៃអង្គការយូណេស្កូ ចំពោះ CIC។

ខ្ញុំក៏សូមអរគុណផងដែរចំពោះអ្នកទាំងអស់គ្នាដែលតែងតែចូលរួមជានិច្ចក្នុងសម័យប្រជុំ CIC ដែលចាប់តាំងពីពេលចាប់បដិសន្ធិរហូតដល់សព្វថ្ងៃ ត្រូវបានគេទទួលស្គាល់ថាជាគំរូជោគជ័យ ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិរក្សបេតិកភណ្ឌពិភពលោក។

ខ្ញុំសូមកោតសរសើរជាខ្លាំងដល់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានជ្រើសរើសជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ នៅខែតុលា នាឆ្នាំកន្លងទៅ។ នេះសបញ្ជាក់ឲ្យឃើញថា សមាជិកទាំងឡាយនៃអង្គការយូណេស្កូ បានវាយតម្លៃខ្ពស់ដល់កិច្ចខំប្រឹងប្រែងចូលរួមយ៉ាងសកម្មនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការស្តារ និងអភិរក្សបេតិកភណ្ឌពិភពលោក ព្រមជោគជ័យនៃសកម្មភាពកន្លងមក និងនាពេលបច្ចុប្បន្ននៃ CIC ។

ព្រះរាជាណាចក្រកម្ពុជា មិនត្រឹមតែត្រូវបន្តការខំប្រឹងប្រែងតែប៉ុណ្ណោះទេ ប៉ុន្តែនៅពេលនេះ កម្ពុជាជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដូច្នេះកម្ពុជាត្រូវតែបង្ហាញឲ្យឃើញនូវគំនិតផ្តួចផ្តើម ដើម្បីឲ្យបទពិសោធន៍ និងលទ្ធផលទទួលបានក្នុងក្របខ័ណ្ឌ សេ អ៊ី សេ បម្រើជាប្រយោជន៍ដល់ការជួសជុល និងអភិរក្សរមណីយដ្ឋានបេតិកភណ្ឌពិភពលោកដទៃទៀត។

ដើម្បីចាប់ផ្តើមសម័យប្រជុំពេញអង្គលើកទី១៦នេះ ខ្ញុំសូមលើកឡើងនូវកំណត់សម្គាល់ចំនួនបីចំណុច ៖

ចំណុចទី១ទាក់ទងទៅនឹងការជួសជុល និងការអភិរក្ស។ ការចូលរួមសហការពីក្រុមបច្ចេកទេស និងអង្គការអន្តរជាតិ គឺជាលទ្ធផលជាក់ស្តែងមិនអាចប្រកែកបានឡើយ តាមរយៈការងារ និងរបាយការណ៍របស់ខ្លួន រួមនឹងលទ្ធផលដែលត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិ។

មុននឹងបន្តជួយគាំទ្រការជួសជុល និងការអភិរក្សរមណីយដ្ឋានអង្គរ ខ្ញុំយល់ថា ចាំបាច់ត្រូវពង្រឹងការបណ្តុះបណ្តាលវិស្វករ និងអ្នកជំនាញជាតិ ពីព្រោះថា CIC ទទួលស្គាល់នូវអធិបតេយ្យភាពនៃប្រទេសកម្ពុជា ស្តីពីរមណីយដ្ឋានអង្គរ និងការទទួលខុសត្រូវចំពោះការអភិរក្សរមណីយដ្ឋាននេះ។

ចំណុចទី២ ខ្ញុំយល់ថាបច្ចុប្បន្ននេះ ការអភិវឌ្ឍប្រកបដោយចិរភាពក្លាយទៅជារឿងសំខាន់ ដែលយើងត្រូវលើកយកមកពិនិត្យឲ្យបានឆាប់រហ័ស។

ចំនួនទេសចរណ៍បានកើនឡើងយ៉ាងឆាប់រហ័ស នៅសៀមរាប ប៉ុន្មានឆ្នាំចុងក្រោយនេះ ចំនួននោះកើនឡើងលើសពី២លាននាក់ នៅឆ្នាំ២០០៧។ ទន្ទឹមនឹងនោះ សណ្ឋាគារ និងសំណង់ពាណិជ្ជកម្មជាច្រើនត្រូវបានសាងសង់ឡើងជាច្រើន។

ទាំងនោះបង្កឲ្យមានជាបញ្ហាបរិស្ថាន ជាពិសេសទាក់ទងនឹងទៅនឹងការផ្គត់ផ្គង់ស្បៀង និងគុណភាពទឹកស្អាត ការនាំទឹកកខ្វក់ចេញ ការបំពុលបរិយាកាស និងការកាប់ព្រៃឈើ។

ដល់ពេលវេលាដែលយើងត្រូវពិនិត្យមើលបញ្ហាទាំងនេះហើយ វាជាបញ្ហាដែលប៉ះពាល់ដល់រមណីយដ្ឋានអង្គរ។ លើសពីនោះទៀត ប្រជាជននៅក្នុងតំបន់នេះ មិនមែនសុទ្ធតែជាអ្នកទទួលបានអត្ថប្រយោជន៍ ពីផ្លែផ្កានៃអភិវឌ្ឍន៍សេដ្ឋកិច្ចជានិច្ចកាលនោះឡើយ។

មុននឹងដោះស្រាយបញ្ហាដ៏ច្រើននេះ អ្នកឯកទេស អាដ ហុក បីរូប ដើម្បីការអភិវឌ្ឍប្រកបដោយចិរភាព ត្រូវបានតែងតាំងឡើង នៅឆ្នាំ២០០៦ ហើយអ្នកជំនាញទាំងបីរូបធ្លាប់បានបង្ហាញការងាររបស់ខ្លួនរួចហើយ កាលពីកិច្ចប្រជុំ CIC លើកមុនៗ។ អាស្រ័យដោយបញ្ហាទាំងនេះមានលក្ខណៈបន្ទាន់ ការពិនិត្យមើលទៅលើអាណត្តិ និងបែបបទការងារនៃអ្នកជំនាញ អាដ ហុក ត្រូវបានធ្វើឡើងកាលពីម្សិលមិញ។ ខ្ញុំមានសេចក្តីរីករាយណាស់ ដោយបានដឹងថាមានការសម្រេចចិត្តផ្តល់អាទិភាពទៅលើអាណត្តិនៃអ្នកជំនាញ អាដ ហុក ទាំងនោះ។

ចំណុចចាប់អារម្មណ៍ចុងក្រោយរបស់ខ្ញុំ ទាក់ទងនឹងសារៈសំខាន់នៃការរក្សានូវភាពស៊ីសង្វាក់គ្នារវាង ទេសចរណ៍

និងការអភិរក្សបេតិកភណ្ឌពិភពលោក។ ថ្ងៃនេះ យើងនឹងបានស្តាប់បទបង្ហាញស្តីពីគម្រោងដាក់ភ្លើងបំភ្លឺឧទ្យានអង្គរ ដោយផ្អែកទៅលើគំរូដែលធ្លាប់ធ្វើឡើង នៅក្នុងរមណីយដ្ឋានដទៃទៀត នៃបេតិកភណ្ឌពិភពលោក។ ខ្ញុំសង្ឃឹមថាការពិភាក្សាគ្នានៅពេលខាងមុខបន្តិចទៀតនេះ នឹងផ្តល់នូវអនុសាសន៍មួយដ៏សមស្រប។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមថាការពិភាក្សារបស់យើងនឹងទទួលបាននូវផ្លែផ្កា ប្រកបដោយប្រសិទ្ធភាព ដើម្បីឲ្យសម័យប្រជុំពេញអង្គនេះ អាចបំពេញតួនាទីក្នុងការកំណត់ទិសដៅ នយោបាយអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរប្រកបដោយចិរភាព។ សូមអរគុណ។

## I.3 សុន្ទរកថារបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា

"សូមគោរពលោកសហប្រធាន
សូមគោរពឯកឧត្តម អ៊ុំ វិជ្ជារាវុធ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ
សូមគោរពលោកស្រី Françoise Rivière នាយិការងរបស់យូណេស្កូទទួលបន្ទុកផ្នែកវប្បធម៌
សូមគោរពឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី ទាំងអស់ជាទីគោរព
សម្រាប់រូបខ្ញុំ នេះគឺជាសេចក្តីសោមនស្សរីករាយដ៏ក្រៃលែងដែលបានមកជួប CIC អង្គរបស់យើងជាថ្មីម្តងទៀត។ បច្ចុប្បន្ននេះ CIC គឺជាស្ថាប័នល្បីល្បាញនិងមានគេគោរពដែលស័ក្តិសមនឹងមានមោនភាពចំពោះប្រវត្តិរបស់ខ្លួន គឺរយៈពេលដប់ប្រាំមួយឆ្នាំបន្ទាប់ពីសន្និសីទស្ថាបនិកនៅទីក្រុងតូក្យូ និងរយៈពេលប្រាំមួយឆ្នាំបន្ទាប់ពីសន្និសីទកែលម្អថ្មីនៅទីក្រុងប៉ារីស៍។ តាមពិតទៅ ការវាយតម្លៃជាវិជ្ជមានដែលពិភពបេតិកភណ្ឌសម្តែងឡើងចំពោះការងាររបស់ CIC ទើបនឹងត្រូវបានបញ្ជាក់សារជាថ្មីទៀតនៅក្នុងឱកាសនៃមហាសន្និបាតលើកទី១៧ របស់រដ្ឋភាគីនៃអនុសញ្ញាឆ្នាំ ១៩៧២ ស្តីពីការការពារបេតិកភណ្ឌពិភពលោក វប្បធម៌និងធម្មជាតិ។
ដូចដែលលោក លោកស្រី ជ្រាបស្រាប់ហើយ មហាសន្និបាតនេះបានប្រារព្ធឡើងកាលពីខែតុលាកន្លងទៅ និងបានកត់ត្រាទុកនៅក្នុងថ្ងៃដ៏សំខាន់នោះ នូវការបោះឆ្នោតជ្រើសតាំងព្រះរាជាណាចក្រកម្ពុជា ជាសមាជិករបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោករយៈពេលចំនួនបួនឆ្នាំ គឺពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៣។ បទពិសោធន៍ដ៏សម្បូរបែបដែលប្រទេសយើងទទួលបាននៅក្នុងវិស័យសហប្រតិបត្តិការអន្តរជាតិ ស្តីពីការអភិរក្សនិងការលើកតម្លៃបេតិកភណ្ឌប្រហែលជាមានសារសំខាន់មិនតិចទេ ដែលធ្វើអោយយើងទទួលបាននូវលទ្ធផលនៃការបោះឆ្នោតដ៏គួរជាទីពេញចិត្តនេះ។
ជាការពិតណាស់ យើងមានសេចក្តីសោមនស្សរីករាយចំពោះព្រឹត្តិការណ៍នេះ ហើយជាការពិតណាស់ដែលថា CIC របស់យើងក៏សប្បាយរីករាយខ្លាំងនឹងការជាប់ឆ្នោតនេះដែរ។ ព្រឹត្តិការណ៍ដ៏សប្បាយរីករាយនេះផ្តល់ឱកាសអោយខ្ញុំផ្តល់ព័ត៌មានជូនដល់លោក លោកស្រី ក្នុងនាមឲ្យរាជរដ្ឋាភិបាល ថា ជាមួយនឹងលេខាធិការដ្ឋានរបស់យូណេស្កូ (ផ្នែកវប្បធម៌) ប្រទេសកម្ពុជាបានឈរឈ្មោះជាបេក្ខជន សម្រាប់ការទទួលនិងការរៀបចំសម័យប្រជុំសាមញ្ញរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅខែកក្កដា ឆ្នាំ ២០១២ បន្ទាប់ពីសម័យប្រជុំនាពេលខាងមុខដែលនឹងត្រូវបានគ្រោងទុកជាបន្តបន្ទាប់នៅ Brasília និងនៅ Bahreïn។
លោកសហប្រធានជាទីគោរព សហសេវិកជាទីស្រឡាញ់រាប់អាន។ ខ្ញុំសូមរំឭកថា ឆ្នាំ២០១២ គឺជាឆ្នាំនៃខួបគម្រប់សែសិបឆ្នាំនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក ពោលគឺ គឺអនុសញ្ញាឆ្នាំ១៩៧២។

ឆ្នាំ២០១២ សម្រាប់ជនជាតិខ្មែរទាំងប្រុសទាំងស្រីគ្រប់រូប គឺជាឆ្នាំនៃខួបគម្រប់ម្ភៃឆ្នាំនៃការចុះឈ្មោះអង្គរវត្តទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នៅយូណេស្កូ។ លោក លោកស្រី តើនេះមិនមែនជាភាពគាប់ជួនគ្នាដ៏គួរឲ្យរីករាយនិងប្រកបដោយអត្ថន័យទេឬ?

យើងសង្ឃឹមយ៉ាងមុតមាំថា សមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនឹងសម្រេចផ្តល់អនុសាសន៍ឲ្យជ្រើសរើសទីក្រុងសៀមរាបអង្គរ សម្រាប់សម័យប្រជុំរបស់គណៈកម្មាធិការ និងសម្រាប់ពិធីរំឭកខួបសំខាន់ៗដែលបានគ្រោងទុកនៅឆ្នាំ២០១២។

នៅត្រង់ចំណុចនេះ ខ្ញុំសូមឲ្យលោក លោកស្រី កត់សម្គាល់ថា ការគាំទ្រប្រកបដោយហេតុផលរបស់បណ្តារដ្ឋដែលជាសមាជិកដូចគ្នារបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក និងរបស់ CIC របស់យើង គឺជាកត្តាកំណត់សម្រាប់ជម្រើសដែលយើងប្រាថ្នាចង់បាននេះ។

យើងនឹងត្រឡប់មកនិយាយអំពីរឿងនេះនៅក្នុងពេលវេលាដ៏សមគួរមួយ គឺក្នុងរយៈពេលមួយឆ្នាំទៀត នៅក្នុងឱកាសនៃសម័យប្រជុំរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅ Bahreïn។

ឯកឧត្តម លោក លោកស្រី ជាទីគោរពរាប់អាន! ដើម្បីត្រឡប់មកនិយាយពីសម័យប្រជុំរបស់យើងនៅថ្ងៃនេះវិញ ខ្ញុំសូមអនុញ្ញាតស្វាគមន៍ជាបឋមចំពោះសហប្រធានថ្មីនៃ CIC របស់យើង គឺឯកឧត្តមឯកអគ្គរាជទូតជប៉ុន លោក Masafumi Kuroki។ យើងសូមស្វាគមន៍ទទួលលោកយ៉ាងកក់ក្តៅ ហើយជូសមុខឲ្យគណៈប្រតិភូខ្មែរ ខ្ញុំសូមជូនពរលោកឲ្យប្រកបទៅដោយជោគជ័យ នៅក្នុងបន្ទុកការងារថ្មីៗរបស់លោក និងការស្នាក់នៅប្រកបដោយក្តីរីករាយនៅក្នុងប្រទេសរបស់យើង។ សូមអរគុណ។

របៀបវារៈរបស់យើងបានត្រៀមទុកពេលវេលាមួយ សម្រាប់វគ្គនិយាយអំពីទឹកនៅក្នុងរមណីយដ្ឋានអេកូប្រវត្តិសាស្ត្រអង្គរ។ ជាការពិតណាស់ នៅក្នុងសន្និសីទពិភពលោកនៅទីក្រុង Copenhague ឆ្នាំនេះ លក្ខខណ្ឌអាកាសធាតុធ្វើឲ្យយើងប្រុងប្រយ័ត្ននិងយកចិត្តទុកដាក់ជាពិសេសចំពោះផលប៉ះពាល់បណ្តាលមកពីខ្យល់ព្យុះកំបុតត្បូង *Katsana* ដែលបានបោកបក់មកលើប្រទេសកម្ពុជា នៅក្នុងអំឡុងថ្ងៃចុងក្រោយនៃខែកញ្ញា ឆ្នាំ២០០៩។

ជាភ័ព្វសំណាងល្អ អាជ្ញាធរជាតិអប្សរារួមជាមួយនឹងនាយកដ្ឋានគ្រប់គ្រងទឹករបស់ខ្លួន អាចប្រឈមមុខទប់ទល់នឹងផលប៉ះពាល់ទាំងនេះ និងអាចជៀសវាងការខូចខាតធ្ងន់ធ្ងរបាន។

ប៉ុន្តែក្រៅពីព្រឹត្តិការណ៍ឥតថៃ្ងដន្យនេះ វាគឺជាការសំខាន់ដែលយើងត្រូវត្រៀមខ្លួនចំពោះអ្វីដែលមានលក្ខណៈអាក្រក់បំផុត ដោយធ្វើការវាយតម្លៃជាមុនអំពីហានិភ័យ និងដោយចាត់វិធានការណ៍បង្ការជាមុន។ វាគឺពិតជាដោយសារហេតុផលនេះហើយដែលយើងបានបង្កើតនាយកដ្ឋានពិសេសមួយ នៅក្នុងរចនាសម្ព័ន្ធថ្មីរបស់អាជ្ញាធរជាតិអប្សរា។

អប្សរាមានរចនាសម្ព័ន្ធមួយដែលគេគ្រប់គ្នាកត់សម្គាល់ឃើញថា ចាប់ពីពេលនេះតទៅ គឺដំណើរការហើយ។

ខ្ញុំមានបំណងឲ្យការប្រុងប្រយ័ត្នឥតឈប់ឈររបស់រាជរដ្ឋាភិបាល ចំពោះអ្វីដែលទាក់ទងនឹងទឹកនៅសៀមរាបនិងនៅអង្គរ ទទួលបាននូវការយកចិត្តទុកដាក់ដែលគាំទ្រដោយ CIC ជាពិសេសនោះ សូមឲ្យអង្គការនិងស្ថាប័ននានារបស់បណ្តាប្រទេសផ្តល់ជំនួយ អាចអនុវត្តន៍តាមឧទាហរណ៍ដ៏ល្អដែលផ្តល់ឲ្យដោយ AFD និង JICA។

ជាការពិតណាស់ គឺមានតម្រូវការជាបន្ទាន់ដែលត្រូវជួយទាំងផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសដល់សកម្មភាពរបស់

អភិបាលខេត្តសៀមរាប និងជាអនុប្រធានអាជ្ញាធរជាតិអប្សរា គឺឯកឧត្តម ស៊ូ ភិរិន្ទ ដែលនៅក្នុងមុខងារទ្វេនេះ ឯកឧត្តមទទួលបន្ទុកធ្វើការសម្របសម្រួលសកម្មភាពនិងកម្មវិធីធារាសាស្ត្រទាំងអស់នៅសៀមរាបអង្គរ។

លោកសហប្រធានជាទីគោរព! យើងមិនមើលរំលងទេនូវកិច្ចការដ៏សំខាន់ទាក់ទងនឹងការសិក្សាស្រាវជ្រាវនិងការអភិរក្ស ប៉ុន្តែឥឡូវនេះ CIC របស់យើងនឹងផ្តោតជាសំខាន់ទៅលើជំពូកដែលនិយាយអំពីការអភិវឌ្ឍប្រកបដោយចីរភាព។ នៅត្រង់ចំណុចនេះ ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសដែលត្រូវបានអញ្ជើញឲ្យមកធ្វើបទអន្តរាគមន៍នៅក្នុងការជជែកពិភាក្សាគ្នាៈ គឺមានប្រទេសបារាំង នូវ៉ែលហ្សេឡង់ អូស្ត្រាលី សាធារណរដ្ឋកូរ៉េ និងប្រហែលជាប្រទេសអាល្លឺម៉ង់ផងដែរ។

បទអន្តរាគមន៍ទាំងនេះនឹងរំឭកប្រាប់យើងគ្រប់គ្នានូវវិភាគទានដ៏មានតម្លៃនៃដៃគូរបស់យើង។ ប៉ុន្តែជាពិសេសនោះ យើងនឹងអាចស្វែងយល់អំពីអ្វីដែលជាការគ្រប់គ្រងល្អលើរមណីយដ្ឋានបេតិកភណ្ឌពិភពលោក នៅពេលបច្ចុប្បន្ននេះ។ ការគ្រប់គ្រងល្អ ជាបឋមគឺធានាបាននូវការអភិរក្សតម្លៃដែលនាំឲ្យមានការចុះបញ្ជីអង្គរនៅយូណេស្កូ។

បន្ទាប់មកទៀត ការគ្រប់គ្រងល្អគឺបង្កើតប្លង់គ្រប់គ្រងរួមនិងស៊ីសង្វាក់គ្នា ព្រមទាំងកម្មវិធីសកម្មភាពដែលផ្អែកលើទិន្នន័យនៅនឹងកន្លែង។

ហើយនៅទីបញ្ចប់ ការគ្រប់គ្រងល្អគឺ (ហើយចំណុចនេះគឺជាបញ្ហាប្រឈមដ៏ធំ) ត្រូវគិតគូរជាប់ជានិច្ចដល់ប្រជាពលរដ្ឋដែលរស់នៅ និងធ្វើសកម្មភាពយ៉ាងរស់រវើកក្នុងរមណីយដ្ឋានអេកូប្រវត្តិសាស្ត្រ ក្នុងភូមិទាំង១១២ ដែលបច្ចុប្បន្ននេះមានមនុស្សរហូតដល់ជិត១២០០០០នាក់។ អាចថាជាទីក្រុងតូចមួយ។

ដូច្នេះ យើងនឹងយល់អំពីបញ្ហាប្រឈមដ៏ចម្បងនិងការលំបាកធំៗ ទាំងផ្នែកសង្គមវប្បធម៌ក៏ដូចជាផ្នែកសេដ្ឋកិច្ច។ ប្រជាពលរដ្ឋនេះដែលមានយុវជនក្មេងៗយ៉ាងច្រើន ខ្វះភាពអំណត់ហើយមានទំនាក់ទំនងជាមួយនឹងពិភពអភិវឌ្ឍន៍ដែលមានភាពជឿនលឿនផ្នែកបច្ចេកវិទ្យា ដោយសារបណ្តាញព័ត៌មាន។

ពួកគេចង់មានអ្វីៗទាំងអស់ ឬស្ទើរតែទាំងអស់និងដោយឆាប់រហ័សបំផុត។ ពួកគេចង់បាននូវភាពទំនើប ហើយភាពទំនើបនេះមានន័យស្មើនឹងលទ្ធភាពក្នុងការសាងសង់លំនៅឋានថ្មីៗ មិនខ្វល់នឹងពិតពបែបប្រពៃណី ទាំងសំណង់និងទំនៀមទម្លាប់នៃការរបស់នៅ។

ប៉ុន្តែ នយោបាយរបស់រាជរដ្ឋាភិបាលដែលស្ថិតនៅក្រោមការដឹកនាំប្រកបដោយការប្រុងប្រយ័ត្នរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន គឺមិនមែនផ្តល់សិទ្ធិផ្តាច់មុខទៅឲ្យសមាជិកដទៃទៀត ដោយបោះបង់ចោលនូវការការពារបេតិកភណ្ឌដ៏ចាំបាច់នោះទេ។

ទោះជាមានជនក្រីក្រ ភាពក្រីក្រ សម្ពាធប្រជាជនក៏ដោយ ក៏រាជរដ្ឋាភិបាលតែងតែធ្វើការរំឭកដល់គ្រប់ក្រសួងនាយកដ្ឋានបច្ចេកទេស រដ្ឋបាលនិងអ្នកទទួលខុសត្រូវដែលពាក់ព័ន្ធថា ត្រូវតែយកចិត្តទុកដាក់ធ្វើយ៉ាងណាធានាឲ្យបាននូវតុល្យភាពសមរម្យរវាងការការពារនិងការលើកតម្លៃ រវាងការអភិរក្សនិងការអភិវឌ្ឍ រវាងមនសិការដ៏ខ្ពង់ខ្ពស់លើតម្លៃបេតិកភណ្ឌនិងការយកចិត្តទុកដាក់ជាប្រចាំចំពោះស្ថានភាពសង្គម ព្រមទាំងបម្រែបម្រួលសេដ្ឋកិច្ច។ យើងពិតជាដឹងច្បាស់ថាៈ ក្រៅពីមាគ៌ានេះ គ្មានផ្លូវផ្សេងទេ។

ប៉ុន្តែ វាជាមាគ៌ាដ៏ចង្អៀតមួយដែលទាមទារឲ្យមានជាចាំបាច់នូវការខិតខំប្រឹងប្រែងធ្វើការពន្យល់ឲ្យបានច្រើន ក៏ដូចជាការប្រុងប្រយ័ត្នខ្លាំង។ ត្រូវបំផុសប្រជាពលរដ្ឋដែលច្រើនតែខ្វាយខ្វល់ចង់រស់នៅមានសម្ភារៈប្រសើរជាងមុន ឲ្យយល់តម្លៃបេតិកភណ្ឌវប្បធម៌ និងបរិបថប្រវត្តិសាស្ត្រអង្គរ។

ប៉ុន្តែវាជាការចាំបាច់ផងដែរដែលត្រូវធ្វើឲ្យអ្នកវាយតម្លៃលើបេតិកភណ្ឌពិភពលោក យល់អំពីលក្ខណៈពិសេសរបស់អង្គរ។ នៅអង្គរ ប្រជាពលរដ្ឋស្រឡាញ់ជាប់ចិត្តនឹងទឹកដីនិងដីស្រែចម្ការ ព្រមទាំងស្រឡាញ់ជាប់ចិត្តនឹងជីវិតរបស់ខ្លួន នៅមុនការចុះផ្ទៃដីចំនួន៤០០០០ហិចតា ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកទៅទៀត។

សម្រាប់ប្រជាពលរដ្ឋនេះ ការអភិវឌ្ឍសហគមន៍គឺជាការចាំបាច់ខានមិនបានដាច់ខាត។ ហើយការអភិវឌ្ឍនេះវាសមស្របទៅនឹងសីលធម៌នៃអនុសញ្ញាឆ្នាំ១៩៧២។

នៅក្នុងលក្ខខណ្ឌទាំងនេះ ភារកិច្ចរបស់យើងគឺត្រូវធ្វើអ្វីៗទាំងអស់ ដើម្បីជៀសវាងកុំឲ្យសម្ពាធផ្ទែកលំនៅឋានរបស់អ្នកស្រុកដែលស្ថិតនៅក្នុងឧទ្យានអង្គរ មកដាក់បន្ទុកបន្ថែមពីលើសម្ពាធទីក្រុងនៅក្រៅតំបន់អង្គរដែលកើតឡើងដោយការពង្រីកទីក្រុងសៀមរាប។

យើងគិតថា គឺមិនត្រូវឲ្យរមណីយដ្ឋានអេកូប្រវត្តិសាស្ត្រអេកូឡូហ្ស៊ីនិងទេសចរណ៍អង្គរ ស្ថិតនៅក្នុងគំនាបនោះទេ។ នេះគឺពិតជាអ្វីដែលរបាយការណ៍សរុបចង់បង្ហាញឲ្យឃើញ។ ហើយនៅក្រោមការដឹកនាំរបស់រូបខ្ញុំផ្ទាល់ អ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរាកំពុងតែធ្វើបញ្ចើយរបាយការណ៍សរុបនេះ ដែលនឹងត្រូវប្រគល់ជូនគណៈកម្មាធិការបេតិកភណ្ឌពិភពលោកពិនិត្យ នៅមុនថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១០។

នៅត្រង់ចំណុចនេះ យើងគិតដល់ការជួយគាំទ្ររបស់ CIC របស់យើង ដែលអស់រយៈពេលប្រមាណជាដប់ប្រាំឆ្នាំមក ហើយដែល CIC ធ្វើសកម្មភាពផ្ទាល់នៅនឹងកន្លែង។ ដូច្នេះ CIC យល់ច្បាស់ជាងគេអំពីភាពស្មុគស្មាញនៃស្ថានភាព។

យើងក៏គិតផងដែរដល់ការគាំទ្ររបស់យូណេស្កូ ដែលតំណាងរបស់ខ្លួននៅទីក្រុងភ្នំពេញធ្វើកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធិភាពនិងយ៉ាងទៀងទាត់ជាមួយអាជ្ញាធរជាតិអប្សរា នៅក្រោមការជួយជំរុញរបស់ឯកឧត្តម Teruo Jinnai។ ខ្ញុំសូមសម្តែងនូវការពេញចិត្តយ៉ាងខ្លាំងដោយឃើញឯកឧត្តមបន្តបេសកកម្មរបស់ឯកឧត្តមជាមួយយើងទាំងអស់គ្នា។

ចុងក្រោយ យើងគិតដល់ការយកចិត្តទុកដាក់ដ៏មុតមាំរបស់អគ្គនាយិការងយូណេស្កូ គឺលោកស្រី Françoise Rivière។ ការចូលរួមរបស់លោកស្រីនៅក្នុងការងាររបស់យើង អាចឲ្យលោកស្រីយល់យ៉ាងច្បាស់អំពីស្ថានភាពនិងបញ្ហាប្រឈមនៅអង្គរ។ ដូច្នេះ សូមឲ្យកិច្ចខិតខំប្រឹងប្រែងរបស់យើងត្រូវបានធ្វើការវាយតម្លៃអោយសមទៅនឹងភាពជាក់ស្តែង។

លោកសហប្រធាន ឯកឧត្តម លោក លោកស្រី ជាទីគោរពរាប់អាន! មុននឹងបញ្ចប់ ខ្ញុំសូមទាញអារម្មណ៍មកគិតលើសារៈសំខាន់នៃទស្សនាទានស្តីពីការលើកតម្លៃនៅក្នុងបរិបទអង្គរ។ វាពិតណាស់ថាយើងត្រូវធ្វើការអភិវឌ្ឍដោយធ្វើការអភិរក្សនៅក្នុងពេលដំណាលគ្នា នូវតម្លៃរមណីយដ្ឋានបេតិកភណ្ឌពិភពលោក។ អាជ្ញាធរជាតិអប្សរានឹងយកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យគ្រប់គម្រោងវិនិយោគទាំងអស់គោរពតាមគោលការណ៍នេះ។

ដូចគ្នាដែរ ខ្ញុំសូមអោយអ្នកជំនាញ អាដ ហុក ទាំងខាងអភិរក្សក៏ដូចជាខាងអភិវឌ្ឍន៍ប្រកបដោយចីរភាព មានមានការប្រមើលមើលអោយបានវែងឆ្ងាយបំផុតដែលអាចធ្វើទៅបាន និងជួយដល់អាជ្ញាធរជាតិអប្សរាឲ្យធ្វើការរៀបចំអនាគតរមណីយដ្ឋានអង្គរឲ្យបានល្អ។ នៅក្នុងបេសកកម្មលើកក្រោយរបស់ខ្លួន សូមអ្នកជំនាញ អាដ ហុក មេត្តាទុកពេលខ្លះនៃសកម្មភាពរបស់ខ្លួន ម្យ៉ាង សម្រាប់ពិចារណាអំពីមាគ៌ានិងមធ្យោបាយក្នុងការវាយតម្លៃលើបេតិកភណ្ឌ និងម្យ៉ាងទៀតសម្រាប់ធានានូវធនធានហិរញ្ញវត្ថុក្នុងការធ្វើអាជីវកម្មលើរមណីយដ្ឋានទេសចរណ៍ និងសក្តានុពល

រមណីយដ្ឋានផ្នែកវប្បធម៌និងការលម្អែកំសាន្ត។

លោកសហប្រធានជាទីគោរពរាប់អាន! ខ្ញុំសូមបញ្ចប់ត្រឹមនេះចុះ ហើយខ្ញុំសូមជូនពរឲ្យសម័យប្រជុំរបស់យើងប្រកបដោយជោគជ័យ នៅក្រោមការដឹកនាំប្រកបដោយប្រសិទ្ធិភាពរបស់លោកសហប្រធាន ដោយមិនភ្លេចសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះអ្នកដែលអញ្ជើញមកចូលរួមនៅក្នុងសម័យប្រជុំ CIC របស់យើងជាលើកទីមួយ ហើយជាពិសេសនោះ ចំពោះឯកឧត្តមឯកអគ្គរាជទូតព្រះរាជាណាចក្របែលហ្ស៊ិក លោកឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ លោកឯកអគ្គរដ្ឋទូតប្រទេសឥណ្ឌា លោកឯកអគ្គរដ្ឋទូតប្រទេសឥណ្ឌូណេស៊ី លោកឯកអគ្គរដ្ឋទូតប្រទេសហុល្លង់ លោកឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី ព្រមទាំងគណៈប្រតិភូជប៉ុនទាំងអស់។

ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។ សូមអរគុណ។

**បទអន្តរាគមន៍របស់សហប្រធានបារាំង៖** "សូមអរគុណច្រើនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ចំពោះបទបង្ហាញទូទៅនេះស្តីពីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនងការអភិរក្សនិងការអភិវឌ្ឍនៅរមណីយដ្ឋានអង្គរ។

ខ្ញុំជឿជាក់ថា សហសេវិកជាឯកអគ្គរដ្ឋទូតរបស់យើងទាំងអស់ ពិតជាបានចងចាំទុកនូវបេក្ខភាពរបស់សៀមរាបនៃរមណីយដ្ឋានអង្គរ សម្រាប់សម័យប្រជុំនៅឆ្នាំ២០១២ សម័យប្រជុំដែលជាខួបរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ រាជរដ្ឋាភិបាលបង្ហាញឲ្យឃើញនូវទឹកចិត្តស្រឡាញ់ជាតិ។ ខ្ញុំជឿជាក់ថា គឺពាក្យទេកចិត្តស្រឡាញ់ជាតិនេះហើយដែលជាពាក្យមានន័យល្អប្រសើរបំផុត ទាក់ទងនឹងការការពារបេតិកភណ្ឌពិភពលោក ហើយទឹកចិត្តស្រឡាញ់ជាតិ គឺត្រូវចេះទទួលស្គាល់ទឹកចិត្តនេះ។

សូមអញ្ជើញ លោកស្រី Françoise Rivière ដែលជាតំណាងរបស់អគ្គនាយិកាយូណេស្កូ ហើយដែលជាមិត្តភ័ក្តិចាស់របស់គណៈកម្មាធិការរបស់យើងដែរនោះ មានប្រសាសន៍ជូសមុខឲ្យអង្គការយូណេស្កូ។

## I.4 សុន្ទរកថារបស់តំណាងអគ្គនាយកអង្គការ យូណេស្កូ លោកស្រី François Rivière អគ្គនាយិការងផ្នែកវប្បធម៌

សូមអរគុណ លោកសហប្រធាន។

សូមគោរព លោកសហប្រធាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ ឯកឧត្តម អស់លោក លោកស្រី ជាទីគោរព ឯកឧត្តម អស់លោក សហការី ទាំងអស់ជាទីមេត្រី ! ខ្ញុំព្យាយាមនិយាយឲ្យខ្លី នៅថ្ងៃនេះ។ ខ្ញុំមកទីនេះ ដើម្បីបង្ហាញជូនអស់លោកពីផលប្រយោជន៍នៃស្ថាប័ន គឺមិនមែននិយាយក្នុងនាមខ្ញុំផ្ទាល់ឡើយ។ ព្រោះថា នេះប្រហែលជាលើកចុងក្រោយហើយ ដែលខ្ញុំមកចូលរួមក្នុងការងាររបស់អស់លោក ក្នុងនាមខ្ញុំជា អគ្គនាយករងទទួលបន្ទុកខាងវប្បធម៌។ មនុស្សម្នាក់តែងតែដល់អាយុចូលនិវត្តន៍ ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំចង់និយាយអំពីសារៈសំខាន់ណាស់ សារប្រយោជន៍ដែលស្ថាប័ន រួមទាំងអគ្គនាយកដ្ឋានថ្មីផងដែរ យើងបានដឹងហើយឥឡូវនេះ មានអគ្គនាយិកាថ្មីមួយរូប គិតចំពោះ សេ អ៊ី សេ ដែលយើងតែងតែនិយាយថាជា « ជោគជ័យ » របស់អង្គការ UNESCO។

កាលពីល្ងាចម្សិលមិញ យើងបានរំឭកពីអនុស្សាវរីយ៍ខ្លះៗ ៖ ជាការពិតណាស់ អស់រយៈកាលម្ភៃឆ្នាំហើយ ជិតម្ភៃឆ្នាំហើយ ដែលប្រាសាទអង្គរបានចូលជាបេតិកភណ្ឌពិភពលោក ហើយតាមពិតទៅ គឺរហូតដល់ខួងឆ្នាំ៩៥-៩៩ ពោល

គឺពេលដែលកន្លងទៅមិនយូរប៉ុន្មានសោះ កាលណោះ ទើបតែជាពេលចាប់ផ្តើមដំបូងនៃការងារនៅអង្គរប៉ុណ្ណោះ ហើយផ្លូវដែលយើងដើរក្នុងរយៈពេលដ៏ខ្លីនេះ ពិតជាអស្ចារ្យខ្លាំងណាស់។

សព្វថ្ងៃនេះ យើងកំពុងតែពិនិត្យមើលពីលទ្ធផល ពីកិច្ចការមួយដែលយើងទទួលបានជោគជ័យដ៏ប្រសើរ។ គឺចំណុចនេះហើយ ដែលខ្ញុំចង់លើកមកជម្រាប គឺសារៈសំខាន់ គឺអត្ថប្រយោជន៍ដែលអង្គការUNESCO ទាំងមូលមានចំពោះការងារ CIC។

ចំណុចទីពីរដែលខ្ញុំចង់លើកឡើងគឺការពេញចិត្តរបស់ខ្ញុំ ដោយឃើញថា ការងាររបស់អស់លោកបានជឿនទៅមុខដោយគិតទៅតាមតម្រូវការជាក់ស្តែង និងបន្ទាប់ពីកាលៈទេសៈមួយដែលយើងបានផ្តល់អាទិភាពទៅលើការអភិរក្សបេតិកភណ្ឌស្ថាបត្យកម្ម ហើយខ្ញុំជឿជាក់ថា នៅលើទស្សនៈនេះ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិពិតជាសម្រេចកិច្ចការចលនា បំផុសបំផុលនិងរៀបចំអោយមានកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិរក្សរមណីយដ្ឋានបុរាណវិទ្យាអង្គរដូចដែលបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដូច្នោះដែរ។ បច្ចុប្បន្ននេះ លទ្ធផលដែលកើតចេញពីភាពជោគជ័យនេះជាចំណុចក្តៅនៃការងាររបស់លោកអ្នក ដូច្នេះ វាជាការមានប្រយោជន៍ដែលត្រូវចាប់អារម្មណ៍ទៅលើការអភិវឌ្ឍ និងធ្វើយ៉ាងណាឲ្យការអភិវឌ្ឍតំបន់អង្គរ និងក្រុងសៀមរាបក្លាយទៅជាការអភិវឌ្ឍប្រកបដោយចិរភាព។ ដូច្នេះ ខ្ញុំមិនចាំបាច់លើករឿងនោះមកនិយាយឡើងវិញទេ។ ចំណាប់អារម្មណ៍ទៅលើការងារស្តីពីទឹក ពិតជាក្តីកង្វល់ដ៏ធំនាពេលបច្ចុប្បន្ន។ ខ្ញុំសូមបន្ថែមផងដែរពីការចាប់អារម្មណ៍ទៅលើ បេតិកភណ្ឌអរូបីនៃប្រាសាទអង្គរដ៏សម្បូរបែប ហើយដែលអាចដោះស្រាយបញ្ហាទេសចរណ៍វប្បធម៌ ដែលអស់លោកបានលើកឡើង ព្រោះថាបើគេនិយាយពីការអភិវឌ្ឍ គេត្រូវនិយាយពីទេសចរណ៍ ហើយទេសចរណ៍នោះទៀតសោតត្រូវតែប្លែកៗខុសពីគ្នា គឺមិនត្រឹមតែជាទេសចរណ៍ទៅកាន់រមណីយដ្ឋានបូរាណវិទ្យាប៉ុណ្ណោះទេ ប៉ុន្តែក៏គឺជាទេសចរណ៍ដែលគិតទៅដល់អ្វីដែលតំបន់អង្គរ និងក្រុងសៀមរាបអាចផ្តល់ជូនយើង គឺបេតិកភណ្ឌអរូបី ប៉ុន្តែក៏អាចជាបេតិកភណ្ឌក្រុងផងដែរ ព្រោះដូចអស់លោកបានលើកឡើងដូច្នោះដែរ តំបន់អង្គរគឺរួមទាំងក្រុងសៀមរាបដែរ គឺយើងត្រូវគិតគូរដល់ក្រុងទាំងមូល។ ដូច្នេះចំណុចទីពីរ គឺសេចក្តីពេញចិត្ត ដោយសារឃើញគណៈកម្មាធិការមានការវិវត្ត ទៅតាមតម្រូវការដែលស្តែងឡើង។

ចំណុចទីបី ខ្ញុំក៏ពេញចិត្តផងដែរ ព្រោះឃើញថាមានការបែងចែកកាន់តែច្បាស់បន្តិចម្តង រវាងវិស័យបច្ចេកទេស និងវិស័យនយោបាយ។ ពិតណាស់ កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំក្នុងវិស័យនយោបាយ ហើយខ្ញុំមានចំណាប់អារម្មណ៍ជាខ្លាំង ព្រោះថារសៀលនេះ ក្រៅពីការបំភ្លឺប្រាសាទអង្គរ គឺថាប្រទេសនីមួយមើលឃើញពីកិច្ចសហប្រតិបត្តិការរបស់ខ្លួននៅក្នុង CIC តាមរបៀបផ្សេងៗគ្នា ហើយកិច្ចសហប្រតិបត្តិការសម្រាប់តំបន់អង្គរនិងក្រុងសៀមរាបនេះ វាមានសភាពធំធេងណាស់ ចំពោះប្រទេសសមាជិក ចំពោះប្រទេសកម្ពុជា ដូចមានរៀបចំស្រាប់នៅក្នុង CIC។

គឺចំណុចទាំងអស់នោះហើយដែលខ្ញុំចង់ជម្រាបជូនអស់លោក។ ដូច្នេះ ខ្ញុំគិតថានៅមានកិច្ចការជាច្រើនទៀត ដែលត្រូវបំពេញ គឺនៅមានកំឡុងពេលដ៏យូរទៅមុខទៀត សម្រាប់ភារកិច្ចរបស់គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ ប៉ុន្តែអ្វីៗទាំងអស់ចាប់ផ្តើមដំណើរការល្អហើយ កំពុងតែជឿនទៅមុខហើយ ការងារដ៏ច្រើនត្រូវបានបំពេញរួចក្នុងរយៈពេលដ៏ខ្លី។ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ ដែលបំពេញកិច្ចការនៅអង្គរនេះតែមួយគត់ ដែលទទួលបានជោគជ័យដ៏ពិតប្រាកដ។ សរុបមក ជោគជ័យអាស្រ័យទៅនឹងឆន្ទៈនៃសហគមន៍អន្តរជាតិ និងប្រទេសសមាជិកក្នុងការសហការតាមរយៈយន្តការមួយ ហើយខ្ញុំជឿជាក់ថាអង្គប្រជុំនេះជាឧទាហរណ៍គំរូមួយនៃកិច្ចសហប្រតិបត្តិការនោះ។ ខ្ញុំសូមថ្លែងការកោតសរសើរចំពោះអស់លោកទាំងអស់គ្នា។ សូមអរគុណ។

**កំណត់សម្គាល់របស់សហប្រធានបារាំង ៖** សូមអរគុណលោកស្រីនាយកចំពោះពាក្យសម្តីកោតសរសើរទាំងនេះជូនចំពោះគណៈកម្មាធិការរបស់យើង។ ពេលនេះយើងមានសារមួយពីមិត្តភក្តិចាស់របស់ប្រទេសកម្ពុជា គឺសាររបស់ឯកឧត្តម Frédéric Mitterrand រដ្ឋមន្ត្រីក្រសួងវប្បធម៌នៃសាធារណរដ្ឋបារាំង។ លោកសូមអោយសមាជិកនៃបណ្ឌិតសភាអក្សរសាស្ត្របារាំងអានសាររបស់លោក។ ដូច្នេះ លោកសាស្ត្រាចារ្យ Beschaouch ដែលជាសមាជិកបណ្ឌិតសភាអក្សរសាស្ត្រ លោកអាចអានសាររបស់លោក Frédéric Mitterrand បាននាពេលឥឡូវនេះ។

## I.5 សាររបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងទំនាក់ទំនងនៃសាធារណរដ្ឋបារាំង លោក Frédéric Mitterrand អានដោយលោក Azedine Beschaouch

ខ្ញុំសូមអរគុណលោកសហប្រធាន ខ្ញុំបាទមានក្តីរំភើបជាខ្លាំង ចំពោះទឹកចិត្តរាប់អានដោយប្រកបដោយមិត្តភាពនេះ ព្រមទាំងការផ្តល់កិត្តិយសពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងវប្បធម៌ ទំនាក់ទំនងនៃសាធារណរដ្ឋបារាំង។

នេះគឺលិខិតរបស់លោក ៖

« ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដ៏មានតម្លៃជាទីបំផុត នៅក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំមានឱកាសបានមកទីនេះជាញឹកញាប់ ហើយរៀងរាល់ពេលដែលខ្ញុំមានវត្តមាននៅទីនេះ ខ្ញុំខិតខំធ្វើយ៉ាងណាឲ្យជនរួមជាតិរបស់ខ្ញុំ ស្គាល់កាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ ភាពស្មុគស្មាញ ព្រមទាំងវប្បធម៌នៃប្រទេសនេះ ដែលធ្វើឲ្យខ្ញុំមានការស្ញប់ស្ញែងយ៉ាងជ្រាលជ្រៅជាទីបំផុត។

មុននឹងចាប់ផ្តើម ខ្ញុំសូមអនុញ្ញាតក្រាបថ្វាយបង្គំ ព្រះករុណា ព្រះបាទនរោត្តម សីហមុនី, អតីតព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ និងព្រះមហាក្សត្រិយានី មុនីនាថ ម៉ូនិក ព្រមទាំងលោកនាយករដ្ឋមន្ត្រីហ៊ុន សែន។

ដប់ប្រាំឆ្នាំមកហើយ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ ដើម្បីអភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានអង្គរ និងអាជ្ញាធរអប្សរា បានចូលរួម ក្រោមការដឹកនាំយ៉ាងប្តេជ្ញាចិត្តនៃរាជរដ្ឋាភិបាលកម្ពុជា ជួយជួសជុល និងលើកស្ទួយតម្លៃនៃរមណីយដ្ឋានឯកមួយនេះ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃមនុស្សជាតិនេះ ។

ដំណើរផ្សងព្រេងដ៏អស្ចារ្យនេះ កើតមានឡើងអាស្រ័យដោយការអំពាវនាវរបស់ព្រះករុណា ព្រះបាទ នរោត្តម សីហនុ នៅខែវិច្ឆិកា ឆ្នាំ ១៩៩១ ក្នុងឱកាសសន្និសីទមួយនៅទីក្រុងប៉ារីស៍ និង ដោយការប្តេជ្ញាចិត្តរបស់អាជ្ញាធរនៃប្រទេសកម្ពុជា អង្គការយូណេស្កូ ប្រទេសជប៉ុន និងប្រទេសបារាំង ព្រមទាំងសហគមន៍អន្តរជាតិ ដើម្បីអភិរក្ស និងថែរក្សាប្រាង្គប្រាសាទ ប្រវត្តិសាស្ត្រនិងវប្បធម៌ដ៏សម្បូរបែបនៅអង្គរ សម្រាប់មនុស្សជំនាន់ក្រោយ។

តុល្យាការនៃការងាររយៈពេល១៥ឆ្នាំនេះ គឺពិតជាអស្ចារ្យណាស់ ចំពោះការការពារ ថែរក្សា និងការលើកស្ទួយ ព្រមទាំងការអភិវឌ្ឍផងដែរ។ រយៈពេលច្រើនឆ្នាំកន្លងទៅ គណៈកម្មាធិការសម្របសម្រួលអន្តរជាតិ បានដើរតួនាទីរួមសហការយ៉ាងសំខាន់ នៅក្នុងសហគមន៍អន្តរជាតិ ជាទីកន្លែងដ៏ពិតប្រាកដមួយ ក្នុងការពិភាក្សា ចែករំលែកចំណេះដឹង ផ្តួចផ្តើមវិធីសាស្ត្រនិងគំនិត ដើម្បីជាប្រយោជន៍ដល់វិធីសាស្ត្ររួម និងសមធម៌មួយនៃរមណីយដ្ឋានអង្គរ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ប្រទេសបារាំងបានចាប់អារម្មណ៍ជាខ្លាំង និងជួយគាំទ្រអភិក្រមនេះ ហើយបានចូលរួមសម្រេចបាននូវប្រតិបត្តិការជាច្រើន ដោយសហការយ៉ាងជិតស្និទ្ធជាមួយ ក្រសួងការបរទេសបារាំងនិងអឺរ៉ុប និង

ក្រសួងវប្បធម៌និងទំនាក់ទំនង។

ខ្ញុំសូមសម្តែងនូវការកោតសរសើរដល់ជនរួមជាតិទាំងអស់ ដែលបានចូលរួមសហការក្នុងកិច្ចការរួមគ្នា រួមជាមួយអស់លោកទាំងអស់ ព្រមទាំងជាមួយស្ថានទូតបារាំង ក្នុងនោះមានលោក Michel VERROT នាយកស្ថាបត្យករនគរោបនីយករ លោក Eric LIOPIS បុរាណវិទូនៃវិទ្យាស្ថានជាតិការស្រាវជ្រាវបុរាណវិទ្យាការពារ និងលោក Pascal ROYÈRE ស្ថាបត្យករ នៃសាលាបារាំងចុងបូព៌ាប្រទេស។

ខ្ញុំក៏មានមោទនភាពជាខ្លាំងផងដែរ ដែលថាក្រសួងរបស់ខ្ញុំបានចូលរួមក្នុងការបណ្តុះបណ្តាលស្ថាបត្យករ វិស្វករ និងបុរាណវិទូកម្ពុជាជាច្រើន ហើយមជ្ឈមណ្ឌលតំបន់សម្រាប់បេតិកភណ្ឌក៏បានបណ្តុះបណ្តាលស្ថាបត្យករ វិស្វករ និងបុរាណវិទូឡាវនិងវៀតណាម ព្រមទាំងទទួលអ្នកមានជំនាញវ័យក្មេងកម្ពុជាអោយមកសិក្សានៅប្រទេសបារាំងផងដែរ។
នៅពេលដ៏ខ្លីខាងមុខ ខ្សែភាពយន្តមួយរឿងដឹកនាំដោយលោក Didier FASSIO និងមានលោកស្រី Fabienne SERVAN-SCHREIBER ជាផលិតករ នឹងជាសក្ខីភាពនៃកិច្ចប្រឹងប្រែងនេះ។ ការប្រឹងប្រែងរួមគ្នា និងការបំពេញការងារដ៏គួរឲ្យកត់សម្គាល់ដោយសាលាបារាំងចុងបូព៌ាប្រទេស ដើម្បីជួសជុលប្រាសាទដ៏សំខាន់មួយនៅក្នុងឧទ្យានអង្គរ គឺប្រាសាទបាពួន។

ខ្ញុំសូមអនុញ្ញាតរំលឹកឡើងវិញថា ការងារជួសជុលប្រាសាទបាពួនបានចាប់ផ្តើមធ្វើឡើង នៅឆ្នាំ១៩៩៥ ហើយគ្រោងនឹងបញ្ចប់នៅ រដូវផ្ការីក នាឆ្នាំ២០១១ ខាងមុខនេះ។ ខ្សែភាពយន្តនេះនឹងបញ្ចាំងផ្សាយ នៅប្រទេសបារាំង ចាប់ពីខែមករា ឆ្នាំក្រោយ ហើយខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំង។

ប៉ុន្តែការប្តេជ្ញាសហការរបស់ប្រទេសបារាំងមិនបញ្ចប់ត្រឹមនេះឡើយ។ ក្រៅពីតំបន់អង្គរ គឺនៅមានវប្បធម៌ខ្មែរដ៏មហាធំធេង ទាំងរូបី ទាំងអរូបី ដែលខ្ញុំប្រាថ្នាចង់ផ្សព្វផ្សាយអោយគេស្គាល់ អោយល្បីចិញ្ចាចនៅក្នុងប្រទេសរបស់ខ្ញុំ។

ដូច្នេះ នៅឆ្នាំ២០១០ ប្រទេសបារាំងនឹងទទួលបដិសណ្ឋារកិច្ចមួយអោយមានការសម្តែងរបាំព្រះរាជទ្រព្យនៃប្រទេសកម្ពុជា នោះជាឱកាសតែមួយគត់សម្រាប់ជនរួមជាតិបារាំង ក្នុងការស្វែងយល់ពីវិញ្ញត្តិវប្បធម៌មួយក្នុងចំណោមវិញ្ញត្តិវប្បធម៌ខ្មែរដ៏អស្ចារ្យទាំងឡាយ។

ខ្ញុំសង្ឃឹមថានឹងអាចទៅប្រទេសកម្ពុជាក្នុងពេលឆាប់ៗនេះ។ នៅក្នុងកំឡុងពេលរង់ចាំនេះ ខ្ញុំសូមជូនពរសូមឲ្យអស់លោកទទួលបានជោគជ័យដ៏ថ្លៃថ្លាក្នុងការងារប្រជុំនេះ ហើយសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អស់លោកទាំងអស់គ្នា។

# II. របាយការណ៍សកម្មភាពការងារ

## II.1 របាយការណ៍សកម្មភាពទូទៅរបស់អាជ្ញាធរជាតិអប្សរា ដោយឯកឧត្តម ប៊ុន ណារិទ្ធ ជាអគ្គនាយក

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា

សូមគោរពលោកសហប្រធាន ឯកឧត្តម ភ្ញៀវកិត្តិយស លោក លោកស្រី ជាទីគោរព!

សម័យប្រជុំរបស់ CIC ប្រព្រឹត្តទៅជាបន្តបន្ទាប់គ្នា ប៉ុន្តែមិនដូចគ្នាទេ។ មានព្រឹត្តិការណ៍ថ្មីៗជាច្រើនបានកើតឡើង ចាប់តាំងពីសម័យប្រជុំចុងក្រោយរបស់គណៈកម្មាធិការបច្ចេកទេសនៅខែមិថុនា។ បទពិសោធន៍ដ៏វែងឆ្ងាយរបស់ខ្ញុំនៅក្នុង CIC មិនអាចទប់ខ្ញុំមិនឲ្យមានសេចក្តីរំភើបនោះទេ ដោយសារភ្ញៀវជាតិក៏ដូចជាភ្ញៀវអន្តរជាតិបានមកចូលរួមជាច្រើនកុះករ។

ជាបឋម ខ្ញុំសូមស្វាគមន៍សហប្រធានជប៉ុនថ្មី គឺឯកឧត្តម Masafumi Kuroki ជាឯកអគ្គរាជទូតជប៉ុន និងឯកឧត្តម Hiroshi Karamura ជារដ្ឋមន្ត្រី។

ជានិច្ចកាល នេះគឺជាកិត្តិយសនិងជាសេចក្តីសោមនស្សរីករាយដ៏ស្មោះស្ម័គ្រដោយបានទទួលលោកស្រី Françoise Rivière ជាអគ្គនាយិការងរបស់យូណេសស្កូទទួលបន្ទុកផ្នែកវប្បធម៌។ ហើយយើងសូមឆ្លៀតឱកាសនេះជូនពរអោយលោកស្រី Irina Bokova ដែលជាអគ្គនាយិកាថ្មីរបស់យូណេសស្កូ ទទួលបានជោគជ័យនៅក្នុងការបំពេញបេសកកម្មដ៏សំខាន់នេះ។

យើងសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណៈប្រតិភូបារាំងនិងមិត្តភ័ក្តិដ៏ស្មោះស្មោះស្ម័គ្ររបស់យើង គឺលោកស្រី Francine d'Orgeval លោក Pierre Lanapat និងលោកស្រី Mireille Grubert។ យើងក៏បានទទួលដំណឹងផងដែរថា លោក Bruno Favel មិនអាចមានវត្តមានជាមួយយើងបានទេនៅថ្ងៃនេះ ហើយលោកត្រូវលុបចោលនូវការចូលរួមរបស់លោក ដោយសារតែបញ្ហាសុខភាព។ យើងសូមជូនពរឲ្យលោកឆាប់ជាសះស្បើយឡើងវិញ។ យើងក៏សូមស្វាគមន៍ផងដែរចំពោះព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី និងចំពោះឯកអគ្គរដ្ឋទូតគ្រប់រូប។

យើងកត់សម្គាល់ឃើញដោយសេចក្តីពេញចិត្តនូវការមកដល់របស់អ្នកចូលរួមថ្មីៗ៖ គឺលោកស្រី Eleanor Bruce មកពីសាកលវិទ្យាល័យ Sidney ប្រទេសអូស្ត្រាលី និងលោក Philippe Hewitt ជានាយកទទួលបន្ទុកទ្វីបអាស៊ី សម្រាប់ NZAID របស់ប្រទេសនូវែលហ្សេឡង់។ គ្រួសារនៃអ្នកជំនាញ អាដ ហុក ខាងការអភិរក្ស កាន់តែពង្រឹងមួយកម្រិតទៀតដោយសារការមកដល់របស់លោកសាស្ត្រាចារ្យ Kenichiro Hidaka ដែលជាអ្នកបន្តវេនពីលោកសាស្ត្រាចារ្យ Suzuki។

ចាប់តាំងពីសម័យប្រជុំលើកទីដប់ប្រាំបីរបស់គណៈកម្មាធិការបច្ចេកទេសមក មានព្រឹត្តិការណ៍ជាច្រើនបានកើតមានឡើង បន្ថែមលើសកម្មភាពប្រចាំថ្ងៃរបស់អាជ្ញាធរជាតិអប្សរា។ ចំណុចមួយចំនួននឹងត្រូវបានបង្ហាញជូនដោយលម្អិតដោយអ្នកធ្វើបទបង្ហាញផ្សេងទៀតនៅថ្ងៃនេះ។

ខ្ញុំមិនអាចធ្វើរបាយការណ៍ទូទៅដោយមិនលើកឡើងអំពីព្រឹត្តិការណ៍ដ៏គួរឲ្យកត់សម្គាល់បំផុត ដែលបានកើតមានឡើងនៅចុងរដូវភ្លៀងដែលបង្កឡើងដោយការឆ្លងកាត់របស់ខ្យល់ព្យុះកំបត់ត្បូង *Ketsana* ហើយដែលបានបណ្តាលឲ្យមានទឹកជំនន់នៅក្នុងឧទ្យានអង្គរ។ ការគ្រប់គ្រងទឹកគឺជាក្តីបារម្ភជាប្រចាំសម្រាប់អាជ្ញាធរជាតិនានា ប៉ុន្តែការគ្រប់គ្រងទឹកក៏បានក្លាយជាប្រធានបទដ៏គួរឲ្យយកចិត្តទុកដាក់ជាចម្បងរបស់ CIC ដែរ ព្រោះថានឹងមានសម័យប្រជុំមួយដែលនឹងនិយាយអំពីអង្គរនិងទឹក។ ប្រធាននាយកដ្ឋានគ្រប់គ្រងទឹក គឺឯកឧត្តម ហង់ ៣៧ នឹងនិយាយលម្អិតអំពីការកើតឡើងនៃព្រឹត្តិការណ៍ទាំងនេះ។

## ទាក់ទងនឹងការសិក្សាស្រាវជ្រាវនិងការអភិរក្ស

### កំណាយបុរាណវិទ្យាបង្ការ

កិច្ចប្រតិបត្តិការកំណាយបុរាណវិទ្យានៅជុំវិញប្រាសាទបន្ទាយក្តីនិងស្រះស្រង់ត្រូវបានធ្វើឡើង ដើម្បីរៀបចំនៅពេលអនាគតនូវទីធ្លាមុខរមណីយដ្ឋាននេះ។

### ការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យា

នៅក្នុងក្របខណ្ឌនៃការរៀបចំរមណីយដ្ឋានស្រះស្រង់ ការសិក្សាផ្នែកបុរាណវិទ្យាត្រូវបានចាប់ផ្តើមធ្វើនៅម្តុំស្រះទឹក និងនៅតាមផ្លូវដែលនាំទៅកាន់រមណីយដ្ឋានបឹងមាលា ទៅកាន់ភូមិរហាល ដើម្បីស្វែងរកស្នាមផ្លូវបុរាណដែលស្ថិតនៅក្នុងគម្រោង "Angkor living road "។

### សារមន្ទីរ

សារមន្ទីរកុលាលភាជន៍អង្គរដែលបានសាងសង់នៅខាងត្បូងតានី នឹងត្រូវសម្ពោធន៍នៅពេលបន្តិចទៀតនេះ ហើយការបើកឲ្យសាធារណៈជនចូលទស្សនានឹងប្រព្រឹត្តទៅនៅពេលឆាប់ៗនេះ។ នៅពេលថ្មីៗនេះ អាជ្ញាធរជាតិអប្សរាបានរៀបចំទីកន្លែងមួយដែលស្ថិតនៅក្នុងសារមន្ទីរ នរោត្តម សីហនុ អង្គរ ដើម្បីធ្វើឲ្យមានសុវត្ថិភាពចំពោះរូបចម្លាក់ និងវត្ថុនានាដែលបានរកឃើញ ឬក៏ដែលបានធ្វើសមុច្ច័យនៅក្នុងអំឡុងពេលកំណាយ។

### ការលើកតម្លៃបេតិកភណ្ឌនិងការអភិវឌ្ឍប្រកបដោយចីរភាព

ការងារសាងសង់ទីស្នាក់ការរបស់អាជ្ញាធរជាតិអប្សរាមានដំណើរឈានទៅមុខយ៉ាងលឿន។ យើងសង្ឃឹមថាអាចប្រើប្រាស់អគាររបស់យើង នៅមុនដំណាច់ឆ្នាំក្រោយ។

### ការកែលម្អបណ្តាញផ្លូវថ្នល់នៅក្នុងឧទ្យានអង្គរ

របាយការណ៍មួយនឹងត្រូវបង្ហាញជូន ទាក់ទងនឹងបណ្តាញផ្លូវរវាងតំបន់ដែលមានប្រាង្គប្រាសាទនិងកណ្តាលទីក្រុងសៀមរាប។ យើងសូមស្វាគមន៍និងថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋកូរ៉េ គឺឯកឧត្តម Lee Kyung-Soo ដែលបានផ្តល់កិត្តិយសដល់យើង ដោយបានបង្ហាញជូនដោយផ្ទាល់ខ្លួនលោក នូវកិច្ចសហប្រតិបត្តិការរបស់ប្រទេសកូរ៉េនៅអង្គរ។

### ការងារអភិវឌ្ឍន៍សហគមន៍

ដំណាក់កាលទីមួយនៃគម្រោងជាលក្ខណៈទ្វេភាគីជាមួយប្រទេសនូវែលហ្សេឡង់ ស្តីពីការចូលរួមរបស់សហគមន៍បានបញ្ចប់ហើយ។ អ្នកសម្របសម្រួលត្រូវបានទទួលការបណ្តុះបណ្តាល និងឲ្យបម្រើការងារដើម្បីបង្កើតទំនាក់ទំនងជាប្រចាំជាមួយអ្នកភូមិដែលរស់នៅក្នុងឧទ្យាន មានជាអាទិ៍ដើម្បីធ្វើឲ្យពួកគាត់ចាប់អារម្មណ៍ចំពោះភាពចាំបាច់ក្នុងការការពារបេតិកភណ្ឌ។ ការបណ្តុះបណ្តាលក៏ត្រូវបានផ្តល់ជូនផងដែរ ដើម្បីជួយពួកគាត់អោយចេះលើក

តម្លៃវប្បធម៌និងប្រពៃណីរបស់ខ្លួន បែបនេះ ធ្វើអោយអ្នកទេសចរចាប់អារម្មណ៍ អាចឈប់និងទស្សនាភូមិឋានរបស់ពួកគាត់ ដើម្បីស្វែងយល់ឲ្យបានប្រសើរអំពីរបៀបរស់នៅរបស់ពួកគាត់។

ដូច្នេះ យើងបានកំណត់ភូមិ "សាកល្បង" មួយចំនួនដែលស្ថិតនៅម្តុំស្រះស្រង់ ដើម្បីអនុវត្តគម្រោងសាកល្បង។ ដើម្បីអោយពួកគាត់ប្រឡូកពេញដៃបេញជើងនៅក្នុងគម្រោង ជាអាទិ៍សម្រាប់ដំណាក់កាលទីពីរ អ្នកស្រុកក៏នឹងចូលរួមយ៉ាងសកម្មផងដែរនៅក្នុងការតាក់តែងបង្កើតប្លង់គ្រប់គ្រងដីនៃភូមិរបស់ពួកគាត់។

## ភូមិធម្មជាតិ រុន តា ឯក

ការសិក្សាលើប្លង់ដីត្រូវបានធ្វើឡើងនៅក្នុងដំណាក់កាលទីមួយ នៅលើផ្ទៃដីប្រមាណជាមួយរយឡូ ដើម្បីនឹងចែកដីឡូទាំងនោះជូនអ្នកភូមិដែលស្ម័គ្រចិត្តទៅតាំងទីលំនៅនៅក្នុងភូមិធម្មជាតិថ្មីនេះ។

## ការងាររៀបចំទីធ្លាមុខស្រះស្រង់

ដោយសារមូលនិធិដែលផ្តល់ឲ្យដោយក្រុមហ៊ុន Jet tours ក្រៅពីការងារកំណាយបុរាណវិទ្យានិងការងារធារាសាស្ត្រដែលកំពុងដំណើរការ ការងារលើកតម្លៃទីលានមុខរមណីយដ្ឋានស្រះស្រង់ - បន្ទាយក្តី ក៏ត្រូវបានអនុវត្តដែរ។ យើងបានបោះបង្គោលតាមកន្លែងដែលតភ្ជាប់ទំនាក់ទំនងរវាងប្រាសាទបន្ទាយក្តីនិងស្រះស្រង់។ យើងក៏បានបោះបង្គោលដូចគ្នាដែរសម្រាប់កំណត់ផ្លូវដើរកំសាន្តនៅជុំវិញស្រះស្រង់។ ការដាំរុក្ខជាតិនិងការសាងសង់ផ្ទះខ្មែរគំរូនឹងធ្វើជាបន្តទៀតនាពេលឆាប់ៗនេះ ក្នុងដំណាក់កាលថ្មីនៃការងារដែលបានគ្រោងទុក។ របាយការណ៍លម្អិតមួយត្រូវបានផ្ញើទៅគណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់យូណេស្កូ តាំងពីខែតុលាម្ល៉េះ។

## ការជួសជុលបារាយខាងជើងនិងបារាយទឹកថ្លាឡើងវិញ

ទោះជាមានបញ្ហាទឹកជំនន់ដែលបានលើកឡើងពីខាងលើរួចហើយក៏ដោយ ក៏សកម្មភាពជួសជុលបារាយទាំងពីរនេះឡើងវិញមិនត្រូវបានផ្អាកទេ។ នៅក្នុងពេលទស្សនាបារាយខាងជើងដែលត្រូវបានរៀបចំកាលពីម្សិលមិញ សម្រាប់អ្នកចូលរួមប្រជុំថ្ងៃនេះ អ្នកចូលរួមអាចទស្សនាស្រះទឹកនៅនាគព័ន្ធ ដែលមានទឹកពេញដូចជានៅសម័យអង្គរដ៏កំពូលដែរ។

## សួនដាំគ្រឿងទេស

ការងារសិក្សាដីនិងការងារចាក់ដីបំពេញដើម្បីបង្កើតភាពទាកទាញថ្មីសម្រាប់អ្នកទេសចរ កំពុងតែធ្វើបញ្ចប់។ បង្គន់អនាម័យថ្មីៗត្រូវបានធ្វើរួចនិងដាក់ឲ្យប្រើប្រាស់កាលពីម្សិលមិញ នៅក្នុងទីធ្លាមុខប្រាសាទបន្ទាយស្រី និងនៅផ្លូវចូលផ្នែកខាងកើតរបស់ប្រាសាទតាព្រហ្ម។ យើងកំពុងធ្វើបង្គន់អនាម័យនៅប្រសាទបាគង។

## ការដាក់ភ្លើងបំភ្លឺរមណីយដ្ឋានអង្គរ

យោងតាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ការសិក្សាមួយស្តីពីការដាក់ភ្លើងបំភ្លឺប្រាង្គប្រាសាទនៃរមណីយដ្ឋានអង្គរ អោយសមស្របទាំងស្រុងទៅនឹងបទដ្ឋានរបស់បេតិកភណ្ឌពិភពលោកនិងរបស់យូណេស្កូ កំពុងតែ

ដំណើរការ។ បេសកកម្មនេះត្រូវបានប្រគល់ជូនទៅអ្នកឯកទេស ដែលបានបំពេញបេសកកម្មនៅតាមរមណីយដ្ឋានវប្បធម៌ដ៏ល្បីៗបំផុតនៅក្នុងពិភពលោក។ គម្រោងទីមួយនឹងត្រូវបានបង្ហាញជូននៅក្នុងសម័យប្រជុំពេញអង្គនេះ។

ឥឡូវនេះ ខ្ញុំសូមសម្តែងសេចក្តីគោរពចំពោះមិត្តភ័ក្តិដ៏សំខាន់របស់ប្រទេសកម្ពុជា ហើយដែលបានលាចាកពីពួកយើងទៅ នៅថ្ងៃទី២ ខែធ្នូ កន្លងទៅនេះ គឺខ្ញុំចង់និយាយពីលោក Ikuo Hirayama ដែលជាវិចិត្រករជប៉ុនដ៏ល្បីល្បាញនិងជាឯកអគ្គរដ្ឋទូតសុឆន្ទៈរបស់យូណេស្កូ។ ហើយលោកក៏ជាអ្នកការពារបេតិកភណ្ឌនិងជាសកម្មជនដំបូងគេបំផុតដែរ។ ចាប់តាំងពីឆ្នាំ១៩៩១មក លោកបានចូលរួមនៅក្នុងការអភិរក្សអង្គរ។ ម្យ៉ាងទៀត លោកបានធ្វើឲ្យអង្គរមានលក្ខណៈកាន់តែអស្ចារ្យតាមរយៈរូបគំនូរជាច្រើន។ យើងសូមចូលរួមមរណទុក្ខជាមួយគ្រួសាររបស់លោកនិងប្រទេសជប៉ុន។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

## II.2 របាយការណ៍សកម្មភាពរបស់ CIC និងការអនុវត្តអនុសាសន៍មុនៗ ដោយលោកសាស្ត្រាចារ្យ Azedine BESCHAOUCH ជាលេខាធិការវិទ្យាសាស្ត្ររបស់ CIC

“សូមគោរពលោកសហប្រធាន សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ

ឯកឧត្តម លោក លោកស្រី ជាឯកអគ្គរដ្ឋទូត រាជទូត សហសេវិកទាំងអស់ជាទីស្រឡាញ់រាប់អាន!

វាជាទម្លាប់ទៅហើយដែលត្រូវរំឭកឡើងវិញអំពីបេសកកម្មរបស់លេខាធិការដ្ឋាន ដើម្បីបង្ហាញជូនឲ្យបានប្រសើរនូវគោលសំខាន់ៗនៃសកម្មភាពនានារបស់ខ្លួន។ ដូចដែលលោក លោកស្រីជ្រាបស្រាប់ហើយ ជាបឋម លេខាធិការដ្ឋានស្ថិតនៅជាមួយសហប្រធានទាំងពីររូបរបស់យើង ហើយនៅត្រង់ចំណុចនេះ បន្ទាប់ពីការមកដល់របស់សហប្រធានថ្មីរបស់យើងគឺឯកឧត្តមឯកអគ្គរាជទូត Kuroki ភ្លាមនោះ ក្នុងនាមលេខាធិការដ្ឋាន យើងបានធ្វើយ៉ាងណាឲ្យឯកឧត្តមបានដឹងអំពីបទបញ្ជាផ្ទៃក្នុងរបស់យើង អំពីរបៀបធ្វើការងាររបស់យើង ហើយនិងទទួលបានដំបូន្មាននិងការតំរែតម្រង់ទិសពីឯកឧត្តម។

ដោយហេតុដូច្នេះផងដែរដែលយើងបានរៀបចំការប្រជុំចតុភាគី។ យើងបានផ្តល់ព័ត៌មាន និងឆ្លៀតឱកាសពីការមកដល់របស់សហប្រធានថ្មីរបស់យើង ដើម្បីធ្វើឲ្យរបៀបធ្វើការងារកាន់តែល្អថែមទៀត និងដើម្បីធ្វើយ៉ាងណាឲ្យបទបញ្ជាផ្ទៃក្នុងអាចត្រូវបានរៀបចំអោយមានទម្រង់ល្អ និងជាពិសេសនោះអាចដាក់ឲ្យប្រើប្រាស់នៅក្នុងលក្ខខណ្ឌដ៏ប្រសើរបំផុត។

ខ្ញុំក៏សូមជម្រាបប្រាប់លោក លោកស្រីផងដែរថា សហប្រធានទាំងពីររូបរបស់យើងបានសង្កត់ធ្ងន់សូមឲ្យមាន មិនត្រឹមតែអ្វីដែលយើងហៅថាកិច្ចប្រជុំចតុភាគីធម្មតាប៉ុណ្ណោះទេ មានន័យថា នៅមុនកិច្ចប្រជុំរបស់យើងមួយថ្ងៃ យើងបានរៀបចំកិច្ចប្រជុំចតុភាគីដើម្បីពិនិត្យឡើងវិញលើខ្លឹមសារធំៗនៃរបៀបវីរៈ នេះគឺជាអ្វីដែលយើងបានធ្វើ ប៉ុន្តែគួរធ្វើការប្រជុំចតុភាគីវិសាមញ្ញនៅពេលណាដែលយើងចាំបាច់ត្រូវធ្វើ ហើយជាពិសេសនោះគឺដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់រាជរដ្ឋាភិបាល ដូចដែលឯកឧត្តម សុខ អាន បានលើកឡើងនៅពេលមុននេះបន្តិច មានន័យថាត្រូវស្តាប់អាជ្ញាធរអប្សរា និងរៀបចំអនាគតស្ថាប័នមួយនេះតាមរយៈការរិះគិតពិចារណាអោយបានវែងឆ្ងាយទៅថ្ងៃមុខ។

លេខាធិការដ្ឋាននេះក៏ជាលេខាធិការដ្ឋានរបស់អាជ្ញាធរជាតិអប្សរាផងដែរ ព្រោះថាវាជាការសំខាន់ណាស់ដែលត្រូវដាក់អនុសាសន៍ជូនលោក លោកស្រីពិនិត្យ ហើយនៅថ្ងៃនេះតែម្តង លោក លោកស្រីទទួលបានរបាយការណ៍សកម្មភាពមួយច្បាប់ថ្មីទៀត។ ជារៀងរាល់ឆ្នាំ លេខាធិការដ្ឋានព្យាយាមនឹងផ្តល់ជូនលោក លោកស្រីឲ្យទាន់ពេលវេលានូវរបាយការណ៍ស្តីពីសម័យប្រជុំលើកមុន។ យើងតាមដាននិងពិនិត្យមើលយ៉ាងទៀងទាត់លើការអនុវត្តរាល់អនុសាសន៍និងសេចក្តីសម្រេចនានា។ លោក លោកស្រីពិតជាយល់ច្បាស់ហើយថា ការងារនេះមិនមែនសាមញ្ញនោះទេ ព្រោះថាយើងមិនត្រឹមតែត្រូវធ្វើការតាមដានជាប់ជាប្រចាំផ្នែករដ្ឋបាលប៉ុណ្ណោះទេ ហើយខ្ញុំគិតថា ការតាមដានផ្នែករដ្ឋបាលនេះមានភាពងាយស្រួលតាមរយៈការក្រើនរំឭក ប៉ុន្តែក៏ត្រូវទំនាក់ទំនងជាប់ជាប្រចាំជាមួយអ្នកដែលធ្វើការងារ ហើយជាពិសេសនោះ គឺជាមួយអាជ្ញាធរជាតិអប្សរា។

នៅត្រង់ចំណុចនេះ ខ្ញុំចង់និយាយថា បើមិនមានការិយាល័យរបស់យូណេស្កូទេនោះ ក្នុងឋានៈជាលេខាធិការដ្ឋានយើងនឹងមិនអាចទទួលជោគជ័យនៅក្នុងភារកិច្ចរបស់យើងបានទេ។ ហើយនៅចំពោះមុខអគ្គនាយិការងទទួលបន្ទុកផ្នែកវប្បធម៌របស់យើង ខ្ញុំសូមអនុញ្ញាតជម្រាបជូនថា អនុសាសន៍របស់លោកស្រីពិតជាមានប្រសិទ្ធិភាព ព្រោះថារាល់លើកដែលយើងទាក់ទងទៅការិយាល័យរបស់យូណេស្កូ យើងទទួលបានការគាំទ្រ ហើយលើសពីការគាំទ្រនេះទៅទៀត យើងទទួលបានមធ្យោបាយដើម្បីធ្វើការងារ។ ហើយខ្ញុំថែមទាំងអាចនិយាយលើសពីនេះទៀតថា ជាញឹកញាប់ លោកនាយក Teruo Jinnai ចាត់ទុកខ្លួនលោកជាសមាជិករបស់លេខាធិការដ្ឋានទៀតផង។ ហើយខ្ញុំសូមថ្លែងអំណរគុណលោកចំពោះការធ្វើបែបនេះ។

លេខាធិការដ្ឋានក៏ទទួលបន្ទុកតាមដានមើលក្រុមការងារទាំងអស់ ក្នុងការអនុវត្តសេចក្តីសម្រេចនិងអនុសាសន៍នានា។ នៅឆ្នាំនេះ កិច្ចការនេះត្រូវបានធ្វើឡើងជាមួយអ្នកជំនាញ អាដ ហុក។ យើងរៀបចំការមកដល់របស់អ្នកជំនាញ អាដ ហុក។ ហើយនៅត្រង់ចំណុចនេះ ខ្ញុំសូមជម្រាបប្រាប់លោក លោកស្រីថា ស្របតាមបំណងប្រាថ្នាដែលសម្តែងឡើងដោយសហប្រធានទាំងពីររូប ស្របតាមការវិវត្តនៃកិច្ចការនានានៅក្នុងរមណីយដ្ឋានអេកូប្រវត្តិសាស្ត្រនិងបុរាណវិទ្យាអង្គរ និងស្របតាមភាពចាំបាច់ក្នុងការជួយអាជ្ញាធរអប្សរាដែលជាអ្នកគ្រប់គ្រងលើកិច្ចប្រតិបត្តិការទាំងមូលនេះឲ្យធ្វើការត្រួតពិនិត្យឲ្យបានប្រសើរលើរាល់អ្វីៗដែលគេធ្វើនៅក្នុងរមណីយដ្ឋាននោះ យើងបានធ្វើយ៉ាងណាឲ្យភារកិច្ចរបស់អ្នកជំនាញមានការវិវត្តទៅមុខ ស្របតាមបំណងប្រាថ្នារបស់សហប្រធានទាំងពីររូប។

កាលពីថ្ងៃម្សិលមិញនេះទៀត ហើយរឿងនេះត្រូវបានរំឭកដោយសហប្រធានទាំងពីររូបរួចហើយ យើងបានធ្វើការពិភាក្សាពិរះរកវិធីធ្វើយ៉ាងណាអោយការងាររបស់អ្នកជំនាញ អាដ ហុក កាន់តែមានលទ្ធផលល្អ ហើយខ្ញុំសូមជម្រាបលោក លោកស្រីថា យើងនឹងបង្ហាញរបាយការណ៍អំពីរឿងនេះជូនសហប្រធានទាំងពីររូបរបស់យើង ដើម្បីធ្វើយ៉ាងណាឲ្យអនុសាសន៍ស្តីពីការងារអ្នកជំនាញដែលខ្ញុំជម្រាបជូននៅថ្ងៃនេះ នឹងទទួលបានផ្លែផ្កា ប្រសិនបើសហប្រធានទាំងពីររូបរបស់យើងយល់ព្រមនិងជួយចង្អុលផ្លូវស្តីពីចំណុចនេះ។

ចាប់ពីពេលនេះតទៅ យើងកត់សម្គាល់ឃើញថា កិច្ចការទាំងនេះមានភាពចាំបាច់ ដោយឃើញការបណ្តុះបណ្តាលដែលត្រូវបានធ្វើឡើងនៅក្នុងក្រុមបច្ចេកទេស ឬក៏វគ្គបណ្តុះបណ្តាលដែលធ្វើឡើងយ៉ាងល្អដោយសាលា Chaillot តាមរយៈការចូលរួមរបស់រដ្ឋាភិបាលបារាំង។ ឥឡូវនេះ មជ្ឈមណ្ឌលបណ្តាលប្រចាំតំបន់អាចពង្រឹងនិងបំពេញបន្ថែមនូវចំណេះដឹងព្រមទាំងធ្វើឲ្យកាន់តែសុក្រឹត្យនូវការបណ្តុះបណ្តាលយុវជនខ្មែរ ឡាវនិងវៀតណាមទៀតផង។

ពិតមែនហើយ បច្ចុប្បន្ននេះ អាជ្ញាធរជាតិអប្សរាមានបុគ្គលិកច្រើនជាងមុន មានសមត្ថភាពជាងមុន ហើយថែមទាំងអាចធ្វើការអភិរក្សនិងការលើកតម្លៃរមណីយដ្ឋានបានប្រសើរជាងមុនទៀតផង។ យើងយល់ឃើញថា ចាប់ពីពេល

នេះតទៅ អ្នកជំនាញ អាដ ហុក គួរតែចំណាយពេលយ៉ាងហោចណាស់រយៈពេលមួយថ្ងៃឬក៏លើសពីនេះ នៅក្នុងបេសកកម្មរបស់ខ្លួនដើម្បីធ្វើការនៅតាមរមណីយដ្ឋានជាមួយអ្នកជំនាញជនជាតិខ្មែរ អ្នកជំនាញជនជាតិខ្មែរក្មេងៗ។ មានន័យថាយើងវិវត្តន៍ទៅភមុខ ដូចជាកិច្ចការផ្សេងទៀតដែរ រឿងនេះត្រូវបាននិយាយនៅក្នុងសន្និសីទស្តាបនិកទីក្រុងតូក្យូ និងនៅក្នុងសន្និសីទទីក្រុងប៉ារីសរួចហើយថា ការសំខាន់នោះ គឺព្រះរាជាណាចក្រកម្ពុជាមានសមត្ថភាពធ្វើការអភិរក្សនិងការលើកតម្លៃដោយអ្នកជំនាញផ្ទាល់របស់ខ្លួន។ ដូច្នេះ អំណឺះតទៅ នៅពេលដែលសហប្រធានទាំងពីររូបរបស់យើងផ្តល់ការយល់ព្រមលើរបាយការណ៍របស់យើងនោះ យើងនឹងធ្វើការរៀបចំធ្វើយ៉ាងណាឲ្យអាជ្ញាធរជាតិអប្សរា ជាមួយនឹងអ្នកជំនាញ អាដ ហុក ធ្វើការបន្ថែមរយៈពេលមួយថ្ងៃទៀត។ ហើយនេះគឺជាការសំខាន់ណាស់សម្រាប់ការវិវត្តនៃកិច្ចការរបស់លេខាធិការដ្ឋាន និងការវិវត្តនៃកិច្ចការរបស់គណៈកម្មាធិការយើង ព្រោះថា នៅចុងបញ្ចប់ គឺសម្រាប់លោក លោកស្រីទេដែលយើងជម្រាបជូនអំពីការងារទាំងអស់នេះ។

ប៉ុន្តែខ្ញុំគិតថា លោក លោកស្រីនឹងយល់ស្របចំពោះរឿងនេះ គឺនៅពេលដែលរបាយការណ៍ទាំងនេះត្រូវបានបង្ហាញជូន លោក លោកស្រីនឹងយល់ពីសារៈសំខាន់នៃការងារដែលសម្រេចបាន ហើយជាពិសេសនោះ ដូចដែលលោកស្រី Rivière អគ្គនាយិការងរបស់យើងបាននិយាយយ៉ាងត្រឹមត្រូវអំបាញ់មិញនេះរួចហើយ គឺនៅពេលនេះ យើងឃើញការរីកចម្រើនដ៏ច្រើនដែលយើងធ្វើបាន។ ហើយយើងនឹងឃើញការរីកចម្រើនដ៏ច្រើនទាំងនេះនៅពេលដែលគេធ្វើរបាយការណ៍ជូនលោក លោកស្រី មានន័យថា មិនមែនសម្រាប់តែលោក លោកស្រីប៉ុណ្ណោះទេ ប៉ុន្តែនៅពេលដែលរបាយការណ៍ទាំងនេះត្រូវបានធ្វើការផ្សព្វផ្សាយទៅតាមគណៈកម្មការជាតិនានានៅក្នុងពិភពលោក ទៅយូណេសស្កូទៅគ្រប់ភ្ញៀវទាំងអស់រួចហើយ យើងនឹងឃើញថាជំនួយរបស់លោក លោកស្រីសម្រាប់ការបណ្តុះបណ្តាលកំពុងតែផ្តល់ផល ហើយមានយុវជនខ្មែរកាន់តែច្រើនឡើងដែលទទួលបាននូវការបណ្តុះបណ្តាល។

នៅទីបញ្ចប់ លេខាធិការដ្ឋានក៏ជាលេខាធិការដ្ឋាននៃការគិតគូរពិចារណាដែរ មានន័យថាយើងព្យាយាមចូលរួមចំណែកជាមួយអ្នកជំនាញ។ យើងផ្តល់យោបល់ដល់ពួកគេ ហើយពួកគេមានសមានចិត្តទទួលយកយោបល់ទាំងនោះ យើងក៏ចូលរួមចំណែកជាមួយសហប្រធានទាំងពីររូបរបស់យើងនៅរាល់លើកដែលមានភាពចាំបាច់ ព្រមទាំងជាមួយអាជ្ញាធរជាតិអប្សរាផងដែរ។

ហើយនៅឆ្នាំនេះ ដោយសារមានរបាយការណ៍ដ៏ធំមួយនេះដែលត្រូវប្រគល់ជូន ដូចដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានរំឭករួចមកហើយ របាយការណ៍នេះមិនត្រឹមតែជារបាយការណ៍របស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ របាយការណ៍នេះត្រូវបានស្នើដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោកទៅរដ្ឋភាគី គឺព្រះរាជាណាចក្រកម្ពុជា។ ប៉ុន្តែតាមការពិត ដូចដែលលោក លោកស្រីជ្រាបស្រាប់ហើយ របាយការណ៍នេះក៏ជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យឃើញអំពីសកម្មភាពរបស់លោក លោកស្រីផងដែរ មានន័យថា គណៈកម្មាធិការបេតិកភណ្ឌនឹងមានលទ្ធភាពមើលឃើញថា CIC ដ៏ល្បីល្បាញនៅក្នុងពិភពលោកនេះក៏ជាស្ថាប័នមួយរួមជាមួយអាជ្ញាធរជាតិអប្សរា ដែលធ្វើអោយមានការរីកចម្រើនទាំងនេះ។

ដោយហេតុដូច្នេះហើយបានជាយើងមានបំណងជួយអាជ្ញាធរជាតិអប្សរានៅក្នុងសម័យប្រជុំជាច្រើន ហើយជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណការិយាល័យរបស់យូណេស្កូ។ នៅក្នុងកិច្ចការនេះ ខ្ញុំមិនបានធ្វើតែម្នាក់ឯងនោះទេ។ រៀងរាល់លើក សហសេវិកនៃការិយាល័យរបស់យូណេស្កូបានចូលរួមធ្វើការជាមួយខ្ញុំ ហើយអាជ្ញាធរជាតិអប្សរាបានឲ្យយើងចូលរួមពិចារណាជាមួយ ឲ្យយើងចូលរួមរៀបចំរបាយកាណ៍នេះ។ របាយការណ៍នេះនឹងមានសារៈសំខាន់ព្រោះថានៅទីបញ្ចប់ គេនឹងមើលឃើញពីការរីកចម្រើន។ មានល្អត្រូវតែមានអាក្រក់ ប៉ុន្តែខ្ញុំជឿជាក់ថាទិដ្ឋភាព

វិជ្ជមានគឺមានសារៈសំខាន់ខ្លាំងណាស់។ ការរីកចម្រើនពិតជាធំធេង ហើយរបាយកាណ៍នេះនឹងបង្ហាញឲ្យឃើញ។ ដោយហេតុដូច្នេះហើយបានជានៅឆ្នាំនេះ លេខាធិការដ្ឋានរបស់លោក លោកស្រីបានខិតខំយកចិត្តទុកដាក់ ហើយនឹងបន្តយកចិត្តទុកដាក់រហូតដល់ពេលដែលរបាយការណ៍នឹងត្រូវបានប្រគល់ជូនទៅមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោក ដែលបន្ទាប់មកនឹងត្រូវពិនិត្យដោយគណៈកម្មាធិការបេតិកភណ្ឌពិភពលោក បន្ទាប់ពីការវាយតម្លៃរបស់អង្គការ ICOMOS និង ICCROM។ លេខាធិការដ្ឋានរបស់លោក លោកស្រីនឹងធ្វើការរហូតដល់ទីបញ្ចប់នៃភារកិច្ចរបស់ខ្លួន មានន័យថានឹងយកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យរបាយការណ៍នេះមានលក្ខណៈល្អប្រសើរបំផុត ហើយនិងឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក។

ជាការពិតណាស់ រៀងរាល់ថ្ងៃ ជាពិសេសសហសេវិកដែលបំពេញការងារនៅនឹងកន្លែង ពោលគឺនៅសៀមរាបនេះ យើងមានទំនាក់ទំនងជាប់ជាប្រចាំជាមួយក្រុមបច្ចេកទេសទាំងអស់។ ខ្លួនខ្ញុំផ្ទាល់ រាល់លើកដែលខ្ញុំមកទីនេះ ខ្ញុំមានកិត្តិយសដោយបានចូលរួមក្នុងគ្រប់ការងាររបស់អប្សរា បានរាយការណ៍ជូនសហប្រធានទាំងពីររូបរបស់ខ្ញុំ។ ខ្ញុំមានសេចក្តីរីករាយនឹងជម្រាបជូនថា ភារកិច្ចទាំងនេះ ទោះជាវាមានច្រើនសន្ទឹកសន្ធាប់ក៏ដោយ ក៏ភារកិច្ចទាំងនេះត្រូវបានបំពេញនៅក្នុងលក្ខណៈជាមិត្តភាពបំផុត។ ហើយនេះជាអ្វីដែលធ្វើឲ្យយើងអាចនិយាយបានថា យើងកាន់តែព្យាយាមធ្វើការងារឲ្យបានប្រសើរឡើងជាលំដាប់ ហើយយើងសង្ឃឹមថានឹងអាចធ្វើបានប្រសើរជាងមុន។

សូមអរគុណ។

**សេចក្តីកត់សម្គាល់របស់សហប្រធានបារាំង៖** សូមអរគុណលោកសាស្ត្រាចារ្យ Beshcaouch។ ដូច្នេះ ដើម្បីបញ្ចប់ចំណុចបច្ចេកទេសស្តីពីរបាយការណ៍សកម្មភាពនេះ ខ្ញុំសូមរំឭកប្រាប់លោក លោកស្រីថា ឯកសារពីរប្រភេទត្រូវបានចែកជូននៅក្នុងពេលនេះ៖

- ឯកសារពណ៌ខៀវដែលខ្ញុំមាននៅនឹងដៃខ្ញុំជាភាសាបារាំងនិងអង់គ្លេស គឺជារបាយការណ៍នៃសម័យប្រជុំបច្ចេកទេសលើកទី១៨។ ប្រសិនបើអ្នកណាមិនទាន់មានទេ អាចទៅយកនៅខាងក្រៅបាន។ នៅក្នុងរបាយការណ៍នៃសម័យប្រជុំបច្ចេកទេសលើកទី១៨នេះ មានអនុសាសន៍នៃសម័យប្រជុំបច្ចេកទេសលើកទី ១៨ ដែលយើងនឹងធ្វើការអនុម័តនៅល្ងាចនេះ។ ដូច្នេះ ប្រសិនបើលោក លោកស្រីចង់អានអនុសាសន៍ទាំងនោះឡើងវិញ គឺមាននៅក្នុងរបាយការណ៍នេះ។ ហើយយើងនឹងអនុម័តអនុសាសន៍ទាំងនេះ នៅពេលរសៀលនេះ។
- ឯកសារមួយទៀតដែលកំពុងតែចែកជូន ក៏ជាភាសាបារាំងនិងអង់គ្លេសផងដែរ។ គឺជាឯកសារពណ៌សនៃសម័យប្រជុំពេញអង្គលើកទី១៦។ វាជារបាយការណ៍សកម្មភាពរបស់ក្រុមការងារវិទ្យាសាស្ត្រនិងបុរាណវិទ្យា ជាភាសាបារាំងនិងអង់គ្លេស។ ហើយឯកសារនេះប្រើជាគ្រឹះសម្រាប់ការពិភាក្សាដែលយើងនឹងធ្វើបន្ទាប់ពីការសម្រាក ទាក់ទងនឹងការងាររបស់ក្រុមការងារបច្ចេកទេស។

ឥឡូវនេះ យើងចូលដល់ស្តីពីអង្គរនិងទឹក។ អង្គរនិងទឹក និងព្រឹត្តិការណ៍ព្រមទាំងការខូចខាតដែលបណ្តាលមកពីខ្យល់ព្យុះកំបុតត្បូង កេតសាណា។ យើងមានបទបង្ហាញចំនួនបួន៖ បទបង្ហាញទីមួយរបស់លោកបណ្ឌិត ហាង់ ពៅ ជាអគ្គនាយករងរបស់អាជ្ញាធរអប្សរា ដែលនឹងនិយាយអំពីផលប៉ះពាល់របស់ខ្យល់ព្យុះកំបុតត្បូងនៅក្នុងឧទ្យានអង្គរ។ បន្ទាប់មក មានបទបង្ហាញខ្លីៗចំនួនបីទៀត ប៉ុន្តែក៏សុទ្ធតែជាបទបង្ហាញដែលធ្វើឲ្យយើងចាប់អារម្មណ៍ដែរ។ តើក្នុង

ពេលមានខ្យល់ព្យុះកំបុតត្បូងនេះ មានអ្វីកើតឡើងនៅអាកាសយានដ្ឋានសៀមរាប? តើទីភ្នាក់ងារសហប្រតិបត្តិការ JICA និង AFD បានធ្វើអ្វីខ្លះដើម្បីគ្រប់គ្រងទឹកនៅផ្នែកខាងស្តាំនិងផ្នែកខាងឆ្វេងនៃស្ទឹងសៀមរាប? ដូច្នេះ តទៅនេះ ជាបទបង្ហាញទីមួយដែលលោកបណ្ឌិត ហង់ ពៅ នឹងពន្យល់ប្រាប់យើងអំពីអ្វីដែលបានកើតមានឡើងកាលពីប៉ុន្មានខែមុន នៅសៀមរាប គឺនៅខែកញ្ញា។

## III. ការអភិវឌ្ឍប្រកបដោយចីរភាព

### III.1 ការគ្រប់គ្រងទឹកនៅក្នុងឧទ្យានអង្គរ ក្នុងអំឡុងពេលខ្យល់ព្យុះ កេតសាណា ពីថ្ងៃទី២៩ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ ដោយឯកឧត្តម បណ្ឌិត ហង់ ពៅ ជាអគ្គនាយករងរបស់អាជ្ញាធរជាតិ

សូមគោរពឯកឧត្តមសហប្រធាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានអាជ្ញាធរអប្សរា។ សូមគោរព ឯកឧត្តម លោក លោកស្រី!
ខ្ញុំមានកិត្តិយសសូមបង្ហាញជូនលោក លោកស្រីអំពីការគ្រប់គ្រងទឹកនៅក្នុងឧទ្យានអង្គរ នៅក្នុងអំឡុងពេលខ្យល់ព្យុះកំបុតត្បូង *Ketsana*។

[ស្លាយ] នេះជាផែនទីដែលមានតំបន់១និងតំបន់២នៃឧទ្យានអង្គរ និងអាងផ្ទុកទឹកចំនួនបី៖ អាងផ្ទុកទឹកសៀមរាប អាងផ្ទុកទឹកពួកនិងអាងផ្ទុកទឹករលួស។

[ស្លាយ] ហើយលោក លោកស្រីឃើញមានស្ថានីយឧតុនិយមរបស់យើងដើម្បីកត់ត្រាទុកនូវរាល់ទិន្នន័យដែលទាក់ទងនឹងអាកាសធាតុនៅក្នុងតំបន់។ ចំពោះអ្វីដែលទាក់ទងនឹងព្រឹត្តិការណ៍ខ្យល់ព្យុះកំបុតត្បូង *Ketsana* ខ្យល់ព្យុះនេះបានចាប់ផ្តើមបោកបក់នៅចន្លោះម៉ោង២០ម៉៣០នាទី នាថ្ងៃទី២៩ ខែកញ្ញា រហូតដល់ម៉ោង២២ម៉៣០នាទី ថ្ងៃទី៣០ ខែកញ្ញា។

[ស្លាយ] លោក លោកស្រីឃើញមានភ្លៀងធ្លាក់យ៉ាងខ្លាំងឥតដាច់នៅក្នុងរយៈពេលចំនួនពីរថ្ងៃ និងមានកម្លាំងខ្លាំងខ្លាំងរហូតដល់ជាង១៥០មិល្លីម៉ែត្រក្នុងមួយម៉ោង។
ហើយទឹកភ្លៀងនោះបង្កឲ្យមានការខូចខាតនៅក្នុងឧទ្យាន។

[ស្លាយ] ខ្ញុំសូមពង្រីករូបភាពកន្លែងទាំងអស់ដែលនៅកណ្តាលឧទ្យាន ដើម្បីឲ្យលោក លោកស្រីយល់អំពីរបៀបនៃការហូរទឹកនៅក្នុងផ្នែកនេះ។ លោក លោកស្រីឃើញស្ទឹងសៀមរាបហូរតម្រង់ទៅទិសនេះ។ ហើយប្រសិនបើយើងចង់បំពេញបារាយខាងលិច ទឹកត្រូវបានបញ្ជូនដោយស្ទឹងសៀមរាប ដោយឆ្លងកាត់តាមប្រឡាយបង្ហូរទឹកដែលស្ថិតនៅខាងក្នុងកសិណខាងជើងរបស់អង្គរធំ ហើយឆ្លងកាត់តាមផ្នែកនេះនៃអង្គរធំ តាមបារាយខាងលិច។ នៅក្នុងករណីដែលយើងចង់បំពេញកសិណអង្គរវត្ត យើងប្រើប្រាស់ប្រឡាយបង្ហូរទឹកនៅក្នុងផ្នែកនេះដើម្បីបំពេញ។

[ស្លាយ] នេះជាការហូរទឹករបស់អាងផ្ទុកទឹករលួស។ យើងបានផ្លាស់ប្តូរទិសនៃការហូរទឹកនេះដើម្បីយកទឹកទៅបំពេញស្រះស្រង់ ដោយបើកប្រឡាយបង្ហូរទឹកមួយដែលប្រើសម្រាប់ការស្រោចស្រព។ ហើយទឹករបស់អាងផ្ទុកទឹករលួសហូរចុះទៅកាន់ទន្លេសាប។

[ស្លាយ] នេះជាការហូរទឹករបស់អាងផ្ទុកទឹកពួក។ តាមធម្មតា ទឹកមួយផ្នែកហូរពីអាងនេះទៅស្ទឹងសៀមរាប កន្លែងនេះ តាមទិសនេះ។ ទឹកឯទៀតបានមកពីផ្នែកនេះដែលហូរទៅកាន់ប្រឡាយបង្ហូរទឹកនៅក្នុងកសិណខាងជើងអង្គរធំ។ ហើយលោក លោកស្រីនឹងយល់ថាហេតុអ្វីបានជាខ្ញុំចង់បង្ហាញលោក លោកស្រីអំពីទិសនៃការហូរទឹកនេះ។ ដូច្នេះ នៅថ្ងៃកើតមានខ្យល់ព្យុះកំបុតត្បូង *Ketsana* ចរន្តទឹកបានហូរបញ្ច្រាសទិស។ ផ្ទុយពីហូរទៅកាន់ស្ទឹងសៀមរាប គឺទឹកស្ទឹងសៀមរាបបានហៀរ ដោយទឹកហូរមកពីទិសនេះវិញ។ ហើយតាមធម្មតា នៅក្នុងផ្នែកនេះ យើងមានប្រឡាយបង្ហូរទឹកដែលភ្ជាប់ជាមួយកសិណអង្គរវត្តនិងជាមួយស្ទឹងសៀមរាប នៅក្នុងករណីដែលយើងមានទឹកពេញពេកនៅក្នុងកសិណអង្គរវត្ត។ ដូច្នេះ ប្រឡាយបង្ហូរទឹកនេះគឺសម្រាប់ទឹកដែលហូរពីកសិណទៅកាន់ស្ទឹងសៀមរាប។
ប៉ុន្តែនៅក្នុងករណីនេះ នៅក្នុងអំឡុងពេលខ្យល់ព្យុះកំបុតត្បូង ទឹកដែលមកពីស្ទឹងសៀមរាបបានហូរទៅបំពេញកសិណអង្គរវត្តវិញ ហើយប្រឡាយបង្ហូរទឹកដែលយើងតាមទម្លាប់ប្រើដើម្បីបំពេញទឹក យើងបានប្រើជាប្រព័ន្ធបង្ហូរទឹកដើម្បីបញ្ជូនទឹកទៅកាន់កសិណអង្គរវត្ត។

[ស្លាយ] ហើយដូចដែលលោក លោកស្រីឃើញនៅលើរូបភាពនេះស្រាប់ សញ្ញាព្រួញនេះគឺជាផ្លូវចូលដែលយើងទើបនឹងធ្វើចប់កាលពីពីរខែមុន គឺនៅមុនពេលខ្យល់ព្យុះនាំទឹកមកកាន់បារាយខាងជើងបន្តិច។ ដូចដែលសញ្ញាព្រួញបង្ហាញពីការហូរទឹកនេះបញ្ជាក់ស្រាប់ សំណាង់នោះអាចឲ្យយើងបញ្ចៀសការបំផ្លាញផ្លូវនេះដែលស្ថិតនៅខាងជើងអង្គរធំ និងភូមិចំនួនពីរនៅទីនេះដែលមិនត្រូវបានទឹកជន់លិចទេ។ ម្យ៉ាងទៀត បញ្ហាដ៏សំខាន់បំផុតនោះគឺ ធម្មតាទឹកនេះចូលមិនដល់ទ្វារទឹកបារាយខាងជើងទេ ប៉ុន្តែនៅពេលព្យុះ បារាយបានស្រូបយកទឹកបានជាងបីលានម៉ែត្រគីប គឺជាបរិមាណទឹកដែលអាចមកបំផ្លាញអង្គរធំទាំងមូលបាន នៅកម្ពស់នេះ។ នេះហើយជាចំណុចដែលអាចបង្កើតឲ្យមានបញ្ហា។ នៅក្នុងពេលជាមួយគ្នានោះ យើងបានធ្វើការសង្កេតនៅនឹងកន្លែង។ ខ្ញុំនឹងបង្ហាញជូនលោក លោកស្រីដោយលម្អិតនៅពេលក្រោយ ព្រមទាំងរូបថត ទាក់ទងនឹងទឹកដែលហូរមកតាមប្រឡាយបង្ហូរទឹកនេះ ដោយមានផារទឹក១,៥ម៉ែត្រគីបក្នុងមួយវិនាទី។

[ស្លាយ] នេះគឺជារូបថត។ នៅទីនេះ គឺជាផ្នែកនៃកសិណអង្គរវត្ត។ សូមកត់សម្គាល់ថា កសិណទាំងពីររបស់អង្គរវត្តខាងជើងនិងខាងត្បូង ត្រូវបានតភ្ជាប់គ្នាដោយលូតូចមួយស្ថិតនៅផ្នែកខាងក្រោមដែលមានវិជ្ជមាត្រទំហំមួយម៉ែត្រ។ ដូច្នេះ ដោយសារតែល្បឿនទឹកដែលហូរមកពីស្ទឹងសៀមរាបមានកម្លាំងខ្លាំងនោះ ក្នុងរយៈពេលមិនដល់បីម៉ោងផង កសិណអង្គរវត្តទាំងពីរមានកម្ពស់ទឹកខុសគ្នាចំនួន៧០សង់ទីម៉ែត្រ។ ដូច្នេះ បញ្ហាដែលធ្វើឲ្យយើងមានការព្រួយបារម្ភ គឺទាក់ទងនឹងសុវត្ថិភាពរបស់អង្គរវត្ត។

[ស្លាយ] នៅលើរូបភាពនេះ លោក លោកស្រីឃើញកម្រិតទឹកខុសគ្នា ហើយសម្ពាធទឹកនេះអាចបង្កគ្រោះថ្នាក់ដល់អង្គរវត្ត។ ដោយហេតុដូច្នេះហើយបានជាយើង នៅអប្សរា យើងបានសម្រេចជីកកន្លែងបើកឲ្យទឹកហូរមួយនៅផ្នែកខាងកើតអង្គរវត្ត ដើម្បីឲ្យទឹកអាចមានកម្ពស់ស្មើគ្នារវាងកសិណទាំងពីរ និងដើម្បីកុំឲ្យមានបញ្ហាសម្ពាធទឹកដែលអាច

បង្គគ្រោះថ្នាក់ដល់ផ្នែកខាងលិចអង្គរវត្ត។ កន្លែងបើកឲ្យទឹកហូរនៅផ្នែកនេះគឺមិនគ្រប់គ្រាន់ទេ។ ដូច្នេះ យើងក៏បានបញ្ចូលទឹកតាមប្រឡាយបង្ហូរទឹក ហើយប្រឡាយបង្ហូរទឹកនេះត្រូវបានធ្វើរួចរាល់ ជិតពីរខែមុនកើតមានខ្យល់ព្យុះ។

[ស្លាយ] បន្ទាប់មកទៀត យើងមានកន្លែងបង្ហូរទឹកចេញចំនួនពីរកន្លែងដែលមិនអាចទទួលបាននូវធារទឹកហូរចូលពីស្ទឹងសៀមរាបទេ។ ប៉ុន្តែយើងបានសម្រេចធ្វើកន្លែងបើកឲ្យទឹកហូរមួយឆ្ពោះទៅកាន់អង្គរធំ។ ខ្ញុំនឹងនិយាយលម្អិតអំពីចំនុចនេះជូនលោក លោកស្រី ព្រោះថាកសិណអង្គរធំនៅក្នុងផ្នែកនេះដែលមានប្រវែងបីគីឡូម៉ែត្រ មិនដែលបានទទួលទឹកទាល់តែសោះ លើកលែងតែទឹកភ្លៀងចេញ។ ប៉ុន្តែទឹកភ្លៀងបានហូតនិងជ្រាបរហូតទាល់តែស្ងួតថែសចាប់ពីខែតុលានិងពាក់កណ្តាលខែវិច្ឆិកាទៅ។ ប៉ុន្តែនៅពេលនេះ គឺមានទឹក ព្រោះយើងបានបញ្ជូនទឹកពីកសិណអង្គរវត្តទៅកាន់អង្គរធំ។

[ស្លាយ] នៅទីនេះ លោក លោកស្រីឃើញកន្លែងថ្មីៗដែលយើងបានសាងសង់សម្រាប់នាំទឹកមានកម្ពស់លើសពី៥០សង់ទីម៉ែត្រចេញ នៅប្រហែលជាម៉ោង១០ នាថ្ងៃទី១ ខែតុលា ឆ្នាំ២០០៩។ ដូច្នេះ ទឹកមានកម្ពស់ខ្ពស់ណាស់។

[ស្លាយ] ខ្ញុំនឹងបង្ហាញរូបថតជូនមើល។ ជាឧទាហរណ៍ រូបថតរបស់បារាយខាងជើង៖ នៅទីនេះ បារាយខាងជើងមានទឹកពេញ ដោយមានចំណុះបីលានម៉ែត្រគីប។ ហើយលោក លោកស្រីឃើញស្នាមពណ៌ស ហើយនៅខាងចុងពណ៌សនេះ គឺកសិណអង្គរធំដែលមិនដែលមានទឹកបែបនេះទេ។ ជាទូទៅ ទឹកតែងតែហូតពីក្នុងប្រឡាយបង្ហូរទឹកនៃផ្នែកខាងជើងរបស់កសិណ។ ប៉ុន្តែនៅពេលនោះ គឺមានទឹកនៅគ្រប់ទីកន្លែង។

[ស្លាយ] ជាភ័ព្វសំណាងល្អ យើងមានបារាយខាងជើង។ លោក លោកស្រីឃើញទេ? នេះជាបារាយទាំងមូលដោយចេញពីចំណុចនេះដែលមានទឹកនៅផ្នែកខាងក្នុងនិងទឹករបស់នាគព័ន្ធ។ ខ្ញុំគិតថា ភាគច្រើនក្នុងចំណោមលោកលោកស្រីបានទស្សនាប្រាសាទរួចហើយកាលពីថ្ងៃម្សិលមិញ ហើយនេះគឺជាទិដ្ឋភាពរបស់បឹងឆ្ពោះទៅកាន់ប្រាសាទនាគព័ន្ធ។ នៅទីនេះ គឺការហូរទឹកឆ្ពោះទៅកាន់ស្ទឹងសៀមរាប នៅត្រង់ចំណុចនេះ ហើយធារទឹកត្រូវបានកាត់បន្ថយ។ ប៉ុន្តែ យើងនៅសល់ផលប៉ះពាល់ពីការហូរទឹកមួយទៀតដែលនឹងធ្វើឲ្យដាច់ផ្លូវតូចឆ្ពោះទៅកាន់ភាគខាងលិចអង្គរធំ។ ហើយកសិណទាំងនេះដែលមិនដែលទទួលទឹកទាល់តែសោះ នៅលើរូបភាពនេះវាមានទឹកនៅកណ្តាលរដូវតែម្តង។

[ស្លាយ] នេះជាផ្លូវចូលអង្គរវត្ត ហើយលោក លោកស្រីអាចវាយតម្លៃកម្ពស់ទឹកដែលចូលទៅក្នុងកសិណអង្គរវត្តដែលស្ទើរតែមានកម្ពស់ពីរម៉ែត្រកន្លះ។

[ស្លាយ] ហើយនេះគឺសុទ្ធសឹងជាការងារដែលត្រូវបានធ្វើរួចរាល់។ នេះជាកសិណអង្គរវត្ត ហើយនេះជាកសិណអង្គរធំ។ យើងមានស្នាមកសិណដែលកាលពីពេលមុន តភ្ជាប់ជាមួយភ្នំបាក់ខែងនិងប្រឡាយបង្ហូរទឹក ឬក៏គេបានជីកផ្នែកនេះដើម្បីឲ្យទឹកអាចហូរពីអង្គរវត្តទៅកាន់អង្គរធំ។

[ស្លាយ] ហើយនេះជាបុគ្គលិកដែលធ្វើការងារ ទោះជានៅពេលយប់ក៏ដោយ ដើម្បីគ្រប់គ្រងរមណីយដ្ឋានទាំងមូល។ សូមអរគុណ។"

**អត្ថាធិប្បាយរបស់សហប្រធានបារាំង៖** " សូមអរគុណលោកបណ្ឌិត ហាង់ ពៅ។ សម្រាប់យើង គឺពិតជាមាន

សារៈសំខាន់យ៉ាងខ្លាំងនិងប្រកបដោយការលើកទឹកចិត្តដោយឃើញថា អាជ្ញាធរអប្សរាធ្វើជាម្ចាស់លើប្រព័ន្ធធារាសាស្ត្រទាំងនេះ ស្គាល់អំពីដំណើរការនៃប្រព័ន្ធធារាសាស្ត្រទាំងនេះ។ យើងឃើញច្បាស់ហើយ វាជាកិច្ចអន្តរាគមន៍ដែលគួរតែធ្វើបន្ទាន់ដើម្បីជៀសវាងមហន្តរាយនៅត្រង់កន្លែងដែលងាយទទួលរងគ្រោះថ្នាក់ ហើយជាកន្លែងដែលមិនងាយនឹងរកឃើញនោះទេ ប៉ុន្តែលោកនិងក្រុមការងាររបស់លោកបានរកឃើញកន្លែងទាំងនោះ ហើយលោកក៏បានធ្វើកិច្ចអន្តរាគមន៍ដែលត្រូវធ្វើ។ ខ្ញុំជឿជាក់ថានេះជាការលើកទឹកចិត្តដ៏សំខាន់ណាស់ ហើយជាសេចក្តីពេញចិត្តដ៏ធំសម្បើមសម្រាប់យើងទាំងអស់គ្នាដោយឃើញថា នៅពេលបន្ទាន់ អប្សរាដំណើរការនិងដំណើរការបានយ៉ាងល្អទៀតផង។

ដូច្នេះ នៅក្នុងប្រធានបទនៃការគ្រប់គ្រងទឹកនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ខ្យល់ព្យុះកំបុតត្បូងដដែលនេះ ដើម្បីនឹង
ធ្វើឲ្យការពិចារណាកាន់តែមានលក្ខណៈស៊ីជម្រៅទៀតនោះ ខ្ញុំសូមជូនវេទិកាទៅក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន។ អ្នកធ្វើបទបង្ហាញគឺលោក Devillers ឬក៏លោក Georges Ramorasata? គឺលោក Georges Ramorasata ដែលនឹងឡើងមកនិយាយ។ ដូច្នេះ សូមលោកអញ្ជើញលោកមកកាន់មីក្រូ ហើយសូមលោកនិយាយត្រួសៗឲ្យបានឆាប់បន្តិច។ តាមរយៈរូបថតដែលថតពីលើអាកាស យើងបានឃើញអាកាសយានដ្ឋានស្ថិតនៅក្រោមបារាយខាងលិច។ តើព្រឹត្តិការណ៍នេះបានកើតឡើងយ៉ាងដូចម្តេចនៅអាកាសយានដ្ឋាន? ដោយសារបរិមាណទឹកភ្លៀងដ៏ច្រើនបែបនេះ តើលោកមានជួបបញ្ហាអីខ្លះ?

## III.2 **ការគ្រប់គ្រងទឹកនៅក្នុងអាកាសយានដ្ឋានសៀមរាប អំឡុងពេលខ្យល់ព្យុះកំបុតត្បូង កេតសាណា ថ្ងៃទី២៩-៣០ ខែកញ្ញា ឆ្នាំ២០០៩ ដោយលោក** Georges Ramorasata **អ្នកទទួលខុសត្រូវផ្នែកបច្ចេកទេស** SCA

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោក លោកស្រី ជាទីគោរព!
តាងនាមឲ្យអគ្គនាយករបស់យើង គឺលោក Nicolas Deviller ខ្ញុំនឹងបង្ហាញជូនលោក លោកស្រីអំពីការសិក្សាស្តីពីការបង្ហូរទឹកចេញដែលយើងបានធ្វើនៅអាកាសយានដ្ឋានសៀមរាប។ តាមយោបល់ខ្ញុំ ការសិក្សានេះគឺជាការសិក្សាបន្ថែមទៅលើការសិក្សាដែលលោកបណ្ឌិត ហាង់ ពៅ បានបង្ហាញជូននៅពេលអំបាញ់មិញនេះ។

[ស្លាយ] ដូច្នេះ ដូចដែលបង្ហាញនៅលើរូបនេះស្រាប់ ក្រុមហ៊ុនពិតជាយល់អំពីបញ្ហាប្រឈមនៃការផ្លាស់ប្តូរអាកាសធាតុ។ យើងបានចាប់ផ្តើមធ្វើការសិក្សានេះនៅឆ្នាំ២០០៩។ បន្ទាប់មកទៀត យើងបានផ្តោតការយកចិត្តទុកដាក់លើផលវិបាកដែលបង្កដោយខ្យល់ព្យុះ កេតសាណា។

[ស្លាយ] យើងក៏មានរូបថតមួយចំនួនរបស់អាកាសយានដ្ឋាននៅក្នុងអំឡុងពេលនៃខ្យល់ព្យុះផងដែរ។

[ស្លាយ] នេះជាទិសទូទៅរបស់អាកាសយានដ្ឋាន។ តាមការពិត អាកាសយានដ្ឋានស្ថិតនៅផ្នែកខាងត្បូងនៃបារាយខាងលិច។ អាកាសយានដ្ឋានមានលក្ខណៈពិសេសដោយស្ថិតនៅក្នុងតំបន់១និងតំបន់២របស់អប្សរា។

[ស្លាយ] យើងបានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើអាងផ្ទុកទឹកនៃតំបន់អាកាសយានដ្ឋាននេះ និង

បរិស្ថានជុំវិញវារួមទាំងផ្លូវធ្វើចរាចរណ៍នៅជុំវិញ ដែលជាតំបន់នៃការសិក្សារបស់យើង។ គ្រាន់តែជាការផ្តល់ព័ត៌មានជូនលោក លោកស្រី នៅក្នុងអំឡុងពេលខ្យល់ព្យុះ កេតសាណា អាកាសយានដ្ឋានមិនត្រូវបានទឹកជន់លិចទេ។ អាកាសយានដ្ឋាននៅតែបើកឲ្យដំណើរការនៅក្នុងរយៈពេលចំនួនពីរថ្ងៃដែលមានភ្លៀងធ្លាក់ ព្រោះថានៅពេលបច្ចុប្បន្ននេះ នៅក្នុងករណីមានភ្លៀងធ្លាក់ខ្លាំងនៅខាងក្នុងអាកាសយានដ្ឋាន យើងគ្រប់គ្រងស្ថានភាពបាន។ វាជាការពិតណាស់ដែលយើងត្រូវគិតដល់អ្វីៗដែលនៅជុំវិញអាកាសយានដ្ឋាន។

[ស្លាយ] នៅទីនេះ ពណ៌ក្រហម ជាប្រឡាយទឹក មានចំនួនបី។ លោក លោកស្រីឃើញមានផ្លូវជាតិលេខ៦ ដែលឆ្លងកាត់តាមទិសនិរតី។ តាមធម្មតាគឺមានប្រឡាយទឹកចំនួនបីភ្ជាប់ទៅអាងផ្ទុកទឹក។ មានមួយស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៦ ដែលលែងដំណើរការហើយ។ ប្រឡាយទីពីរនៅខាងត្បូងបន្តិច ហើយមិនដំណើរការដូចគ្នា។ ហើយចុងក្រោយ គឺប្រឡាយរបស់អាងផ្ទុកទឹកដែលស្ថិតនៅទីនេះ យើងឆ្ងល់ ព្រោះថាវាក៏មិនដំណើរការដែរ ទោះជាប្រឡាយនេះដើរតួនាទីជាអាងទឹកនៅតំបន់នេះក៏ដោយ។ នៅទីនេះ គឺមានតែទ្វារទឹកនេះទេដែលដំណើរការនៅពេលបច្ចុប្បន្ននេះ។ ដូច្នេះ នៅក្នុងអំឡុងពេលមានខ្យល់ព្យុះ កេតសាណា យើងឃើញថាទឹកបានហូរទៅតាមទិសនេះ។

ទាក់ទងនឹងអាកាសយានដ្ឋាន យើងដឹងថាវាដំណើរការដោយរបៀបណា ហើយយើងដឹងថាត្រូវបង្ហូរទឹកចេញដោយរបៀបណា។ ដូចដែលខ្ញុំបានជម្រាបរួចហើយ នៅកន្លែងរបស់យើង ការបង្ហូរទឹកចេញមានដំណើរការល្អ ហើយទឹកមិនបានជន់លិចទេ។ នៅក្នុងរយៈពេលចំនួនពីរថ្ងៃនៃខ្យល់ព្យុះ កេតសាណា អាកាសយានដ្ឋាននៅតែបើកឲ្យដំណើរការ។

[ស្លាយ] នៅអាកាសយានដ្ឋាន យើងត្រូវការធ្វើការចម្រាញ់ទឹក ព្រោះយើងត្រូវគិតគូរដល់បរិស្ថាន។ ដូច្នេះ យើងកំពុងតែធ្វើការសិក្សាលើការចម្រាញ់ទឹកដែលចេញមកពីអាកាសយានដ្ឋាន។

[ស្លាយ] ដូចដែលខ្ញុំបានជម្រាបជូនអំបាញ់មិញរួចហើយ តំបន់បរិស្ថានទាំងមូលដែលកំពុងតែធ្វើការសិក្សា គឺស្ថិតនៅទីនេះ។ យើងត្រូវការជំនួយនិងកិច្ចសហប្រតិបត្តិការពីអ្នកធ្វើអន្តរាគមន៍ទាំងអស់ ទាំងពីអប្បរាក៏ដូចជាពីសំណាក់ឯកឧត្តមអភិបាលខេត្តដែលមានវត្តមាននៅទីនេះ។

[ស្លាយ] កន្លែងនេះមានប្រឡាយបង្ហូរទឹកសម្រាប់ការស្រោចស្រព។ យើងបានពិពណ៌នារួចហើយអំពីសកម្មភាពកើតមាននៅពេលព្យុះ នៅពេលនោះ យើងបានដឹងច្បាស់ថាតើការសិក្សារបស់យើងឈានដល់ណាហើយ យើងក៏បានធ្វើការសិក្សាទាំងនេះឲ្យបានស៊ីជម្រៅថែមទៀត។

[ស្លាយ] ប្រឡាយបង្ហូរទឹកសម្រាប់ការស្រោចស្រពមានទឹកពេញយ៉ាងឆាប់រហ័ស។ នៅទីនេះ ប្រឡាយទឹកនៅសងខាង ដែលខ្ញុំបានជម្រាបជូនអំបាញ់មិញ ស្ទះ លែងបង្ហូរទឹកចេញហើយ មានតែប្រឡាយនេះទេ ដូចដែលបានបង្ហាញនៅក្នុងរបាយការណ៍អំបាញ់មិញហើយ ដែលអាចបង្ហូរទឹកចេញពីផ្នែកទាំងអស់ដែលនៅត្រង់នេះ។ ដូច្នេះ តាមការពិតទៅ យើងត្រូវការប្រឡាយមួយទៀត ព្រោះថាប្រឡាយតែមួយនេះមិនគ្រប់គ្រាន់ទេនៅពេលបច្ចុប្បន្ន។ វាបង្ហូរទឹកចេញពីកន្លែងដែលនៅត្រង់នេះទាំងអស់។

[ស្លាយ] នេះជាប្រឡាយបង្ហូរទឹកដែលស្ថិតនៅសងខាងផ្លូវជាតិលេខ៦ពេលបច្ចុប្បន្ន ដែលស្ទះទាំងស្រុង មិនអាច

អោយទឹកហូរបានទាល់តែសោះ។ ធម្មតា ទឹកនេះគួរតែហូរឆ្ពោះទៅទន្លេសាបដោយផ្ទាល់ដោយឆ្លងកាត់តាមកសិណា។ តាមធម្មតា ប្រឡាយទាំងពីរនេះនាំទឹកឆ្ពោះទៅកាន់ទន្លេសាប។ ប៉ុន្តែខ្យល់ព្យុះ កេតសាណា បានបង្ហាញប្រាប់យើងថា សមត្ថភាពនៃការបង្ហូរទឹកចេញពីតំបន់ទាំងមូលនេះ គឺមិនគ្រប់គ្រាន់ទេ។ ហើយសម្រាប់អាងផ្ទុកទឹកនេះ ប្រឡាយតែមួយគត់មិនគ្រប់គ្រាន់សម្រាប់បង្ហូរទឹកចេញពីតំបន់ខាងលើនេះបានទេ។
ដូចដែលខ្ញុំបានជម្រាបជូនរួចមកហើយ នៅអាកាសយានដ្ឋាន យើងអាចការពារខ្លួនយើងបាន។ ប៉ុន្តែជាការពិតណាស់ នៅក្នុងអំឡុងពេលខ្យល់ព្យុះ កេតសាណា ដើម្បីបង្ហូរទឹកចេញឲ្យបានច្រើន យើងបានបើកអោយទឹកហូរចូលពីខាងក្រៅ ដើម្បីកុំឲ្យទឹកលិចតំបន់នៅម្តុំនោះ។ ប៉ុន្តែយើងមិនអាចអោយទឹកហូរចូលច្រើនពេកទេ ព្រោះត្រូវរក្សាសុវត្ថិភាពរបស់យន្តហោះ និងចរាចរណ៍ផ្លូវអាកាស។ ដូច្នេះ នៅថ្ងៃទីពីរ យើងបានបិទលែងអោយទឹកហូរចូលទៀត ដោយរក្សាកម្រិតទឹកនៅខាងក្នុងកុំអោយឡើង ព្រោះថាយើងមិនអាចបង្ហូរទឹកចេញបានទៀតទេ។

ជាសេចក្តីសន្និដ្ឋាន ដើម្បីនិយាយឲ្យបានឆាប់ដូចដែលលោកសហប្រធានបានស្នើឡើង ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅប៉ែកខាងលិចសៀមរាប សុទ្ធតែយកចិត្តដាក់នឹងតំបន់នេះ។ ដូច្នេះ យើងទទូចសូមឲ្យមានកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរនានា ដូចដែលខ្ញុំបាននិយាយអំបាញ់មិញហើយ គឺជាមួយសាលាខេត្ត និងជាមួយអប្សរា។ យើងត្រូវដឹកនាំធ្វើសកម្មភាពឲ្យទាន់ពេលវេលា ព្រោះយើងដឹងថាមានសកម្មភាពដែលកំពុងតែប្រព្រឹត្តទៅ។ ជាឧទាហរណ៍ លោកបណ្ឌិត ហង់ ពៅ បានបង្ហាញអំបាញ់មិញនេះថាមានការសិក្សាដែលកំពុងតែធ្វើ ហើយយើងធ្វើការសិក្សានៅខាងយើងដែរ។ សំណាងល្អ ការសិក្សាទាំងពីរបំពេញឲ្យគ្នាទៅវិញទៅមក។

[ស្លាយ] ជាការពិតណាស់ បន្ទាប់មកទៀតគឺអាចមានហេដ្ឋារចនាសម្ព័ន្ធដែលទទួលរងការប៉ះពាល់ ទាំងផ្លូវនានាក៏ដូចជាអាកាសយានដ្ឋានដែរហើយថែមទាំងផ្លូវជាតិលេខ៦ផង ក៏អាចត្រូវទឹកជន់លិចទាំងស្រុងដែរ។ ជាការពិតណាស់ ទាក់ទងនឹងបរិស្ថាន ទឹកមិនស្ថិតនៅទីនេះទេ។ ដូច្នេះ ចំពោះយើង យើងអាចបង្ហូរទឹកភ្លៀងទាំងអស់ចេញបាន។ ប៉ុន្តែសម្រាប់ទាំងអស់ ដាច់ខាតត្រូវមានប្រឡាយមួយទៀតសម្រាប់បង្ហូរទឹកចេញពីតំបន់នេះ ព្រោះថាការខូចខាតនៅក្នុងករណីមានខ្យល់ព្យុះរយៈពេល៣-៤ថ្ងៃ ឬលើសពីនេះ អាចបង្កបញ្ហាផ្សេងៗទៀតដែលនឹងបង្កើនសម្ពាធមកពីទិសនិរតីឆ្ពោះទៅកាន់ប្រាសាទនានា ទាំងអង្គរវត្តក៏ដូចជាអង្គរធំដែរ។

បំណងប្រាថ្នារបស់យើងគឺបង្កើតគណៈកម្មាធិការមួយសម្រាប់ផ្នែកនេះដែលមានអាជ្ញាធរមូលដ្ឋាន ក្នុងនោះមានអប្សរា។ ហើយបន្ទាប់មកទៀត អាចមានក្រសួងសាធារណការដែលទទួលខុសត្រូវចំពោះផ្នែកជាតិ ដែលស្ថិតនៅផ្នែកនិរតីនៃអាងផ្ទុកទឹក។

សូមអរគុណលោកសហប្រធាន។

## III.3 គម្រោងពង្រីកបណ្តាញទឹកស្អាតនៅសៀមរាប ដោយលោក Yoshihiko Sato ប្រធានក្រុមការងារគម្រោង JICA

ឯកឧត្តម លោក លោកស្រី ជាទីគោរព!
នេះជាកិត្តិយសសម្រាប់រូបខ្ញុំដោយបានលើកយកការសិក្សារបស់យើងស្តីពី "គម្រោងរៀបចំការពង្រីកបណ្តាញទឹក

ស្អាតនៅសៀមរាប" មកបង្ហាញជូន។ គម្រោងនេះបានទទួលហិរញ្ញប្បទានពីរាជរដ្ឋាភិបាលជប៉ុននិងត្រួតពិនិត្យដោយ JICA (*Japan International Cooperation Agency* ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិរបស់ប្រទេសជប៉ុន)។ ដោយសារខ្ញុំមានពេលខ្លី ខ្ញុំនឹងសង្ខេបខ្លឹមសារនៃការសិក្សាដែលរួមមានប្រវត្តិ ទិសដៅ វិសាលភាព និងភ្នាក់ងារពាក់ព័ន្ធក្នុងការសិក្សា។ព

[ស្លាយ] តំបន់សិក្សាគ្របដណ្តប់លើឃុំទាំងអស់របស់ទីក្រុងសៀមរាបថ្មីនិងឃុំមួយដែលស្ថិតនៅក្បែរនោះ។

[ស្លាយ] ស្ថានីយផលិតទឹកស្អាតដែលបានសាងសង់នៅឆ្នាំ២០០៦ ដោយហិរញ្ញប្បទានរបស់ប្រទេសជប៉ុន មានសមត្ថភាពផលិតទឹកបានចំណុះ៨០០០ម៉ែត្រគីបក្នុងមួយថ្ងៃ។ ប៉ុន្តែតម្រូវការទឹកត្រូវបានវាយតម្លៃថាឡើងរហូតដល់ប្រហែល២០០០០ម៉ែត្រគីបក្នុងមួយថ្ងៃ នៅឆ្នាំ២០១៥។ នេះបើយើងអាចផ្គត់ផ្គង់ចំនួន៥៥%នៃតម្រូវការ នៅឆ្នាំ២០១៥។

[ស្លាយ] ប្រជាពលរដ្ឋស្ថិតនៅជាកត្តាចម្បងមួយក្នុងចំណោមកត្តាចម្បងៗដទៃទៀត ដែលជាកត្តាកំណត់វិសាលភាពនៃគម្រោងបណ្តាញទឹកស្អាត។ កំណើនប្រជាជនក្នុងសៀមរាបមានអត្រាតែ២,៥%ប៉ុណ្ណោះ រីឯអត្រាកំណើនប្រជាជនក្នុងក្រុងសៀមរាបវិញមានចំនួនរហូតដល់៥,២%។ ដូច្នេះ ក្រុងសៀមរាបជាក្រុងដែលមានកំណើនប្រជាជនមធ្យម។

តួលេខចុងក្រោយស្តីពីចំនួនអ្នកទេសចរដែលមកទស្សនាសៀមរាបមានកម្រិតខ្ពស់ ដោយមានភ្ញៀវទេសចរលើសពីពីរលាននាក់នៅឆ្នាំ២០០៨។ រយៈពេលនៃការស្នាក់នៅរបស់ពួកគេមានការកើនឡើង។ គេវាយតម្លៃថាការស្នាក់នៅមានពីរយៈពេលបីថ្ងៃទៅបីថ្ងៃកន្លះ។ ផលវិបាកគឺថា ដោយសារតែការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងក្រុងសៀមរាបមានកម្រិតទាប និងដោយសារការកើនឡើងនៃតម្រូវការនោះ គម្លាតរវាងការផ្គត់ផ្គង់និងតម្រូវការមានកាន់តែធំ។ យើងក៏ប្រឈមមុខផងដែរនឹងបញ្ហាមួយដែលលើកឡើងដោយអង្គការជាច្រើន ទាក់ទងនឹងការស្រុតដីដែលបង្កឡើងដោយការធ្វើអាជីវកម្មហួសហេតុលើទឹកក្រោមដី។

[ស្លាយ] ដូចឃើញក្នុងរូបនេះស្រាប់ ការសិក្សារបស់យើងចែកចេញជាបីដំណាក់កាល។ ដំណាក់កាលទីមួយបានបញ្ចប់កាលពីខែកន្លងទៅ ហើយដំណាក់កាលនេះមានការសិក្សាជាមូលដ្ឋាននិងការជ្រើសរើសយកប្រភពទឹកធម្មជាតិ។ ឥឡូវនេះ យើងស្ថិតនៅក្នុងដំណាក់កាលទីពីរដែលនឹងបញ្ចប់នៅខែមិថុនា ឆ្នាំ២០១០ ហើយដែលមានទិសដៅសិក្សាគម្រោងសាងសង់ស្ថានីយនិងការសិក្សាអំពីភាពអាចធ្វើបាន។ ដំណាក់កាលទីបីមានការវាយតម្លៃលើទឹកក្រោមដីដែលប្រើប្រាស់នៅពេលបច្ចុប្បន្ន រហូតដល់ខែកញ្ញា ឆ្នាំ២០១០។

គម្រោងរបស់យើងនឹងគ្របដណ្តប់៩០%នៃប្រជាជនក្នុងក្រុង និង១០០%នៃអ្នកទេសចរ នៅឆ្នាំ២០៣០ ដែលជាឆ្នាំគោលដៅ។ ដោយមានការយឺតយ៉ាវតែប៉ុន្មានឆ្នាំប៉ុណ្ណោះ គោលដៅនេះឆ្លើយតបនឹងទិសដៅដែលកំណត់នៅក្នុង SEDP ( *Social Economic Development Plan* ប្លង់អភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច) និង OMD (ទិសដៅសហវត្សដើម្បីការអភិវឌ្ឍ)។

[ស្លាយ] ដើម្បីអនុវត្តន៍គម្រោងអោយបានរលូនដើម្បីអាចឈានទៅដល់ទិសដៅដែលបានកំណត់ យើងបានសហការជាមួយអង្គការ ស្ថាប័នដែលពាក់ព័ន្ធនានាដែលមានបង្ហាញជូនលើតារាងនេះ រួមមាន រដ្ឋាករទឹកស្វយ័ត

សៀមរាប អាជ្ញាធរជាតិអប្សរា។ល។និង។ល។ យើងខ្ញុំនឹងធ្វើបទបង្ហាញស្តីពីលទ្ធផលនៃការងារបន្តបន្ទាប់ទៀត នៅក្នុងសម័យប្រជុំ CIC លើកក្រោយ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

## III.4 គម្រោងដាក់ប្រព័ន្ធលូនៅប៉ែកខាងកើតស្ទឹងសៀមរាប ដោយលោក Olivier Gilard អ្នកទទួលបន្ទុកបេសកកម្ម AFD

សូមគោរពលោកសហប្រធាន ឯកឧត្តម លោក លោកស្រី ជាទីគោរព!
ខ្ញុំសូមថ្លែងអំណរគុណដែលបានផ្តល់ឱកាសដល់រូបខ្ញុំដើម្បីនឹងបង្ហាញជូនដោយសង្ខេបអំពីគម្រោងដាក់ប្រព័ន្ធលូនៅប៉ែកខាងកើតស្ទឹងសៀមរាប ដែលយើងផ្តល់ហិរញ្ញវត្ថុនៅពេលបច្ចុប្បន្ននេះ។

[ស្លាយ] ដើម្បីបង្ហាញជូនលោក លោកស្រី ខ្ញុំបានយករូបថតតូចមួយពី *Google* ដែលបង្ហាញអំពីទីតាំងពាក់ព័ន្ធ។ នៅផ្នែកខាងឆ្វេងរូបថត លោក លោកស្រីអាចមើលឃើញស្ទឹងសៀមរាបនិងតំបន់ទាំងមូលស្ថិតនៅខាងកើតស្ទឹងសៀមរាប ដែលមានការអភិវឌ្ឍយ៉ាងខ្លាំងប៉ុន្មានឆ្នាំមកហើយ ប៉ុន្តែហេដ្ឋារចនាសម្ព័ន្ធនៅពេលនេះ មិនត្រូវបានអភិវឌ្ឍន៍ឲ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងទេ។

មុននឹងនិយាយអំពីគម្រោងផ្ទាល់ ខ្ញុំគ្រាន់តែចង់រំឭកបន្តិចអំពីគំនិតដែលស្ថិតនៅពីក្រោយគម្រោងប្រព័ន្ធលូនេះនិងការការពារទល់នឹងហានិភ័យទឹកជំនន់។ ខ្ញុំសូមរំឭកថា ហានិភ័យគឺជាកត្តាមិនទៀងទាត់ដែលអាចកើតមានឡើងដោយសារភ្លៀងធំផ្សាភ្ជាប់ទៅនឹងព្រឹត្តិការណ៍អាកាសធាតុ ប៉ុន្តែក៏ជាកត្តាមួយនៃភាពទន់ខ្សោយដែលជាសញ្ញាណសង្គមសេដ្ឋកិច្ចមួយផងដែរ។ មានន័យថា ប្រសិនបើលោក លោកស្រីមានស្ទឹងមួយ ឬក៏ភ្លៀងធំមួយដែលធ្លាក់មកលើតំបន់មួយដែលគ្មានតម្លៃ នោះ វាមិនមានបញ្ហាទេ។ ប៉ុន្តែការណ៍ដែលយើងអភិវឌ្ឍន៍តំបន់នេះហើយដែលធ្វើអោយហានិភ័យអាចស្តែងចេញបាន។ ហើយការគ្រប់គ្រងហានិភ័យ ដូចជាទឹកជំនន់ មិនអាចធ្វើឡើងដោយគ្រាន់តែដោះស្រាយកត្តាមិនទៀងទាត់ដូចជាការបង្ហូរទឹកចេញនោះទេ ប៉ុន្តែត្រូវធ្វើឡើងដោយលុបបំបាត់ហានិភ័យកុំអោយមាននៅក្នុងតំបន់អភិវឌ្ឍសេដ្ឋកិច្ច។

នៅពេលនេះ គម្រោងរបស់យើងផ្តោតការយកចិត្តទុកដាក់ទៅលើកត្តាមិនទៀងទាត់ គឺទាក់ទងនឹងការងារជាអាទិភាពដើម្បីជួយសម្រួលដល់ការបង្ហូរទឹកនិងការបង្កើនការបង្ហូរទឹកភ្លៀងចេញ។ គម្រោងក៏គិតគូរពិចារណាផងដែរអំពីគំនូសបំព្រួញស្តីពីការរៀបចំតំបន់ទាំងមូល ដើម្បីដាក់ការងារជាអាទិភាពទាំងនេះទៅក្នុងបរិបថនៃការគិតគូរពិចារណាមួយដែលមានលក្ខណៈទូលំទូលាយជាង។ ការរៀបចំគម្រោងមានបង្ហាញត្រួសៗនៅក្នុងតារាងមួយនេះ។ យើងឃើញមានភ្នាក់ងារអនុវត្តន៍គម្រោងដែលតំណាងដោយថ្នាក់ដឹកនាំខេត្តសៀមរាបនិងសាលាខេត្ត ដែលជួយពង្រឹងដោយអប្សរាព្រមទាំងការិយាល័យសិក្សាមួយនៅក្នុងស្រុក។ គណៈកម្មាធិការដឹកនាំគម្រោងរៀបចំប្រជុំផ្នែកដែលពាក់ព័ន្ធទាំងអស់ ដើម្បីផ្តល់ការតម្រង់ទិសទៅលើជម្រើសដែលត្រូវធ្វើឡើងដោយផ្នែកគ្រប់គ្រងគម្រោង។ បន្ទាប់មកទៀត ពាក់ព័ន្ធនឹងផ្នែកវិស្វកម្ម យើងបានរើសនិងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនមួយហើយ។ ម្យ៉ាងទៀតយើងក៏បានគិតគូរប៉ះប៉ូវដល់ប្រជាជនដែលប៉ះពាល់ដោយគម្រោងនិងគិតគូរអំពីវិធានការណ៍រំដោះដីផងដែរ។ ចំណែកឯក្រុមហ៊ុនទទួលបន្ទុកការងារនៅពេលនេះ មិនទាន់ត្រូវបានជ្រើសរើសនៅឡើយទេ ប៉ុន្តែប្រហែលជានឹងត្រូវជ្រើសរើសនៅក្នុងអំឡុងត្រីមាសទីមួយនៃឆ្នាំ២០១០។

[ស្លាយ] ដំណោះស្រាយដែលនឹងប្រកាន់យកមានបង្ហាញនៅលើគំនូសបំព្រួញនេះដែលលោក លោកស្រីឃើញអំពីសារៈសំខាន់នៃគោលការណ៍របស់គម្រោង ពោលគឺយើងសាកល្បងប្រើប្រាស់ប្រព័ន្ធដែលមានស្រាប់អោយបានច្រើនបំផុត ជៀសវាងការជីកលូថ្មី មានន័យថាកាត់បន្ថយផលប៉ះពាល់របស់គម្រោង។ យើងចង់ធ្វើអោយទឹកកខ្វក់ដែលបង្ហូរទៅក្នុងបណ្តាញនេះមានកម្រិតតិចបំផុត ព្រោះបណ្តាញលូមួយនេះទុកសម្រាប់តែសម្អាតទឹកភ្លៀងប៉ុណ្ណោះ មិនមែនសម្រាប់បង្ហូរទឹកកខ្វក់នោះទេ។ លូបង្ហូរទឹកកខ្វក់គឺជាកម្មវត្ថុនៃកិច្ចអន្តរាគមន៍មួយទៀត ដែលមាននៅក្នុងគម្រោងសម្រាប់នៃបណ្តាឆ្នាំខាងមុខ ជាអាទិ៍ជាមួយនឹងកិច្ចសហប្រតិបត្តិការរបស់ប្រទេសកូរ៉េ នេះបើយោងតាមព័ត៌មានដែលយើងដឹង។ គម្រោងត្រូវបានរៀបចំឡើងកុំអោយមានចំណាយខ្ពស់ពេក អោយនៅក្នុងកញ្ចប់ថវិកាដែលមានសម្រាប់កិច្ចប្រតិបត្តិការនេះ គឺទឹកប្រាក់ចំនួនបួនលានអឺរ៉ូ។

[ស្លាយ] ព្រំដែនការងារនៅក្នុងគម្រោងនេះ គឺយើងចាត់ការតែកត្តាហានិភ័យមិនទៀងទាត់ប៉ុណ្ណោះ។ ការសំខាន់គឺថាទន្ទឹមគ្នានឹងការងារអាទិភាពទាំងនេះ ផ្នែកដែលទទួលបន្ទុកខាងនគរោបនីយកម្ម ត្រូវបន្តចលនាអោយប្រជាជនយល់អំពីហានិភ័យដែលអាចកើតឡើងនៅពេលគេកសាងសំណង់របស់ពួកគេ។ ដូចយើងឃើញស្រាប់ហើយ គេមិនអាចបង្ហូរទឹកភ្លៀងអោយចេញលឿនបានទេនៅពេលមានព្យុះ កេតសាណា។ យើងដឹងថាទឹកជំនន់នឹងស្ថិតនៅជាការលំបាកមួយសម្រាប់តំបន់នេះ។ ផ្ទុយមកវិញ គម្រោងនានាដូចជាប្រភេទគម្រោងដែលយើងផ្តល់ហិរញ្ញប្បទាននឹងជួយធ្វើអោយទឹកហូរចេញលឿន ហើយអាចធ្វើអោយបញ្ហាដែលបណ្តាលមកពីទឹកជំនន់មានទំហំតូចអាចទទួលយកបាននៅក្នុងតំបន់ដែលមានការអភិវឌ្ឍក្រុងបែបនេះ។

[ស្លាយ] គេត្រូវរក្សាទុកនូវការដាក់សម្ពាធលើការអនុវត្តបទបញ្ញាស្តីពីទឹកកខ្វក់ ដើម្បីធ្វើយ៉ាងណាកុំឲ្យលូបង្ហូរទឹកដែលបានសាងសង់សម្រាប់ការបង្ហូរទឹកភ្លៀងចេញ ក្លាយទៅជាលូបង្ហូរទឹកកខ្វក់ និងបណ្តាលអោយមានបញ្ហានៃការបំពុលនៅពេលទឹកចេញទៅក្នុងអាងធម្មជាតិ។ ចំណុចចុងក្រោយមួយទៀតគឺគួរមានគម្រោងបន្ថែមផ្សេងៗទៀតដែលចាំបាច់សម្រាប់ពង្រឹងការការពារលូទឹកភ្លៀងនេះបន្ថែមទៀត មានជាអាទិ៍គម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនិងរដ្ឋាភិបាលកូរ៉េដែលត្រូវបានគ្រោងទុករួចហើយ ចំណែកឯគំនូសបំព្រួញមេនឹងត្រូវធ្វើការសិក្សានៅក្នុងក្របខណ្ឌនៃគម្រោងរបស់យើង។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** សូមអរគុណលោក Gilard។ ជាការពិតណាស់ នៅលើស្លាយចុងក្រោយគឺ BAD ជាភាសាបារាំង មានន័យថា ADB ជាភាសាអង់គ្លេស។ ខ្ញុំជឿជាក់ថាគ្រប់គ្នាសុទ្ធតែយល់អំពីភាពស៊ីសង្វាក់គ្នានៃបទបង្ហាញទាំងឡាយនៅក្នុងវគ្គស្តីពីទឹកនេះ។ បទបង្ហាញទីមួយរបស់លោកបណ្ឌិត ហាង់ ពៅ គឺការអភិរក្ស។ តើប្រាង្គប្រាសាទបានធន់នឹងទឹកជំនន់ដោយរបៀបណា? បទបង្ហាញបីបន្ទាប់ គឺការអភិវឌ្ឍប្រកបដោយចីរភាព។ តើត្រូវធ្វើរបៀបណាដើម្បីឲ្យទីក្រុងមានដំណើរការនិងអភិវឌ្ឍន៍? ហើយតាមពិតទៅ ខ្ញុំជឿជាក់ថានេះជាអ្វីមួយដែលយើងនឹងត្រូវដកស្រង់យកឬកត់ត្រាទុក។ យើងឃើញមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងរវាងភាពសមហេតុផលទាំងពីរនោះគឺទំនាក់ទំនងរវាងអប្សរានិងសាលាខេត្ត រវាងក្រុងនិងខេត្ត។ ជាការពិតណាស់ គឺមានការសម្របសម្រួលគ្នាមួយរវាងដៃគូផ្សេងៗដែលពាក់ព័ន្ធ គេត្រូវបន្តអភិវឌ្ឍន៍និងពង្រឹងកិច្ចការសម្របសម្រួលនេះ ដូចដែលបទបង្ហាញស្តីពីអាកាសយានដ្ឋានបានលើកឡើងរួចហើយ។
ឥឡូវនេះ សូមអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី សម្រាកពិសាភេសជ្ជៈសិន។ លោកសាស្ត្រាចារ្យ តើលោកមិនចង់សម្រាកពិសាកាហ្វេទេឬ?

**កំណត់សម្គាល់របស់លោក Azedine Beschaouch ៖** ការពិភាក្សាទូទៅត្រូវបានគ្រោងទុកនៅមុនការសម្រាកពិសារកាហ្វេ។ ប៉ុន្តែប្រសិនបើមិនមានសំណួរទេ តើសហប្រធានអនុញ្ញាតឲ្យលេខាធិការដ្ឋានផ្តល់ព័ត៌មានមួយនិងសំណួរមួយបានដែរឬទេ?

**ចម្លើយរបស់សហប្រធានបារាំង៖** អញ្ចឹង យើងអនុញ្ញាតឲ្យលេខាធិការដ្ឋានផ្តល់ព័ត៌មានមួយ។ យើងនឹងពន្យារពេលការពិភាក្សាទូទៅ។ ម្យ៉ាងទៀតមានការពិភាក្សាដល់ទៅពីរឯណោះ នៅក្នុងផ្នែកស្រាវជ្រាវនិងអភិរក្ស។

**កំណត់សម្គាល់របស់លោក Azedine Beschaouch ៖** លោកសហប្រធាន បន្ទាប់ពីបានស្តាប់បទបង្ហាញរួចមក លោកបានឃើញហើយថា តើនៅពេលបច្ចុប្បន្ននេះ អាដ្ឋាធរជាតិអប្សរាអាចប្រឈមមុខនឹងគ្រោះថ្នាក់ដោយរបៀបណា ហើយជាពិសេសនោះ អាចបញ្ចៀសការខូចខាតបានដោយរបៀបណា។
ប៉ុន្តែខ្ញុំសូមទាញការយកចិត្តទុកដាក់របស់លោក លោកស្រីលើហេតុការណ៍មួយ។ យើងបានទទួលព័ត៌មាន តាមរយៈខេត្តនិងប្រភពមកពីមជ្ឈិម ជាពិសេសគឺក្រសួងទេសចរណ៍ ដែលទទួលបន្ទុកខាងទេសចរណ៍នៅសៀមរាបដែរនោះ គឺថាគេបានចាត់វិធានការណ៍មួយចំនួន។ អង្គភាពអន្តរាគមន៍បន្ទាន់មួយត្រូវបានបង្កើតឡើង នោះគឺនាយករដ្ឋមន្ត្រី សម្តេច ហ៊ុន សែន រូបលោកផ្ទាល់ដែលបានសម្រេចបង្កើតអង្គភាពអន្តរាគមន៍បន្ទាន់នេះ។ សម្តេចបានផ្តល់ប្រាក់ចំនួនបួនលានដុល្លារ ហើយនៅពេលបន្តិចទៀតនេះ នៅពេលមានបទបង្ហាញទាក់ទងនឹងផ្លូវថ្នល់ លោកលោកស្រីនឹងឃើញថាប្រាក់ចំនួនបួនលានដុល្លារនេះត្រូវបានចំណាយដោយរបៀបណា ដោយហេតុថាឯកឧត្តមអភិបាលខេត្ត ស៊ូ ភិរិន្ទ រួមនឹងក្រុមជំនាញរបស់លោក បានធ្វើយ៉ាងណាឲ្យផ្លូវថ្នល់ទាំងអស់ដែលត្រូវបានបំផ្លាញដោយខ្យល់ព្យុះ កេតសាណា ត្រូវបានជួសជុលឡើងវិញ។ វាជាការសំខាន់ដែលត្រូវគូសបញ្ជាក់ថា បច្ចុប្បន្ននេះ មិនមែនតែអាដ្ឋាធរជាតិអប្សរាប៉ុណ្ណោះទេ គឺគ្រប់ផ្នែកទាំងអស់ដែលទទួលបន្ទុកទីក្រុងនេះ និងទាំងរមណីយដ្ឋាន ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក សុទ្ធតែចេះធ្វើអន្តរាគមន៍។ ហើយខ្ញុំគិតថាយើងត្រូវតែសំដែងនូវការកោតសរសើរ។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** "សូមអរគុណលោកសាស្ត្រាចារ្យ ។ ដូច្នេះ ខ្ញុំសូមស្នើឲ្យមសម្រាកពិសាកាហ្វេ។ ប៉ុន្តែខ្ញុំមិនមែនដាច់អហង្ការពេកទេ។ ប្រសិនបើមាននរណាម្នាក់ចង់សួរសំណួរទៅលោកបណ្ឌិត ហាង់ ពៅ គឺអាចសួរបាន។ តើសម្រាកពិសារកាហ្វេឬក៏អត់? បើគ្មានសំណួរទេ? មិនស្តាយក្រោយទេ? ប៉ុន្តែ យើងនៅតែអាចសួរសំណួរបាននាពេលរសៀល។ សូមអរគុណ។

# IV. ការស្រាវជ្រាវនិងការអភិរក្ស

## IV.1 កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យបណ្តុះបណ្តាលស្តីពីការការពារនិងការអភិរក្សបេតិកភណ្ឌវប្បធម៌ រវាងព្រះរាជាណាចក្រកម្ពុជា និង ICCROM ដោយលោក Mounir Bouchenaki ជាអគ្គនាយក ICCROM

សូមគោរពលោកសហប្រធានប្រធាន សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី សូមគោរពឯកឧត្តម លោក លោកស្រី!

ខ្ញុំសូមបង្ហាញជូនលោក លោកស្រី ត្រួសៗអំពីស្ថានភាពនៃកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និង ICCROM។

ICCROM គឺជាស្ថាប័នអន្តរជាតិអន្តររដ្ឋាភិបាលដែលត្រូវបានបង្កើតឡើងដោយយូណេស្កូ នៅឆ្នាំ១៩៥៦ ហើយដែលបច្ចុប្បន្ននេះមានរដ្ឋសមាជិកចំនួន ១២៨។ ប្រទេសកម្ពុជាជារដ្ឋសមាជិកដំបូងមួយក្នុងចំណោមរដ្ឋសមាជិកដំបូងៗដទៃទៀតរបស់ ICCROM។ ហើយស្ថាប័ននេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៦ នៅក្នុងឱកាសមហាសន្និបាតរបស់យូណេស្កូនៅទីក្រុង New Delhi និងមានទីស្នាក់ការនៅប្រទេសអ៊ីតាលី។ ទីស្នាក់ការរបស់ ICCROM គឺស្ថិតនៅទីក្រុង Rome។ ហើយខ្ញុំសូមរំឭកថា តំបន់អាស៊ីអាគ្នេយ៍ត្រូវបានតំណាងយ៉ាងឆាប់រហ័សនៅ ICCROM ដោយព្រះរាជាណាចក្រកម្ពុជា។

[ស្លាយ] ស្ថាប័ននេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៦ ដោយមានគោលបំណងទាក់ទងទៅនឹង ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាល ព័ត៌មាន និងការធ្វើចលនាអោយយល់ពីបេតិកភណ្ឌវប្បធម៌៖ បេតិកភណ្ឌវប្បធម៌រូបិយ បេតិកភណ្ឌវប្បធម៌អរូបិយ បេតិកភណ្ឌវប្បធម៌ដែលជាវត្ថុបុរាណ និងបេតិកភណ្ឌវប្បធម៌ដែលជាសំណង់បុរាណ។

អស់រយៈពេលចំនួន៥០ឆ្នាំមកហើយ ICCROM រៀបចំការសិក្សាជាលក្ខណៈអន្តរជាតិផ្នែកស្ថាបត្យកម្ម ផ្នែកអភិរក្សថ្ម ផ្នែកអភិរក្សនិងគ្រប់គ្រងសមុច្ច័យ។ ICCROM ក៏រៀបចំផងដែរនូវការសិក្សាជាលក្ខណៈតំបន់។

[ស្លាយ] នៅទីនេះ លោក លោកស្រី មើលឃើញថា ស្របគ្នានឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា យើងក៏មានការបណ្តុះបណ្តាលនៅទីក្រុងហាណូយ វៀងចន្ទន៍ ម៉ានីល ហ្សាការតា និង បាងកក ផងដែរ។

[ស្លាយ] ហើយមកទល់ពេលនេះគឺមានរយៈពេលបួនប្រាំឆ្នាំហើយ មានទាំងការបណ្តុះបណ្តាលថ្នាក់ជាតិនៅប្រទេសកម្ពុជា ជាពិសេសនោះគឺការបណ្តុះបណ្តាលដែលត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៩៩ និងឆ្នាំ២០០០ ដោយមានសិក្ខាកាមខ្មែរចំនួន២០រូប។ ហើយការបណ្តុះបណ្តាលនៅក្នុងគម្រោង *CollAsia* ដែលផ្តល់ហិរញ្ញប្បទានដោយមូលនិធិ Getty មានសិក្ខាកាមជាជនជាតិខ្មែរចំនួន២៥រូប។

ដូច្នេះ សរុបសេចក្តីមក យើងអាចនិយាយបានថា មានអ្នកជំនាញជនជាតិខ្មែរក្មេងៗចំនួន ៩៣ រូបហើយ ដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងផ្នែកផ្សេងៗនៃការអភិរក្សបេតិកភណ្ឌវប្បធម៌។

ខ្ញុំក៏សូមជម្រាបជូនលោក លោកស្រី ផងដែរថា ដោយមានទំនាក់ទំនងជាមួយអប្សរា និងតាមសំណើរបស់ឯកឧត្តម សុខ អាន យើងកំពុងរៀបចំកម្មវិធីបណ្តុះបណ្តាលមួយសម្រាប់រមណីយដ្ឋានព្រះវិហារ ដែលទើបនឹងត្រូវបានចុះទៅក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌។

នៅក្នុងក្របខណ្ឌគម្រោង *CollAsia* យើងក៏កំពុងតែដាក់បញ្ចូលនូវកម្មវិធីបណ្តុះបណ្តាលមួយសម្រាប់អ្នកជំនាញជនជាតិខ្មែរ ដែលផ្តោតជាសំខាន់ទៅលើការបណ្តុះបណ្តាលអ្នកអភិរក្សសារមន្ទីរនិងអ្នកគ្រប់គ្រងសមុច្ច័យ។ ហើយជាមួយមិត្តភ័ក្តិ World Monuments Fund របស់យើង យើងកំពុងតែរៀបចំគម្រោងមួយ គឺរោងជាងអភិរក្សស្តីពីប៉មធ្វើពីឥដ្ឋនៅភ្នំបាក់ខែង។

ខ្ញុំក៏សូមជម្រាបជូនលោក លោកស្រី ផងដែរថា តាមសំណើរបស់អាជ្ញាធរកម្ពុជា គឺចាប់តាំងពីសម័យប្រជុំចុងក្រោយរបស់គណៈធម្មាធិការបច្ចេកទេសនៅសៀមរាបនេះ យើងបានធ្វើសកម្មភាពវិភាគគម្រោងដាក់ភ្លើងបំភ្លឺប្រាង្គ

ប្រាសាទអង្គរ ហើយសកម្មភាពនេះបានប្រព្រឹត្តទៅនៅទីក្រុង Rome កាលពីខែវិច្ឆិកា ឆ្នាំ២០០៩។

ពិតប្រាកដណាស់ លោក លោកស្រី នឹងបានស្តាប់បទបង្ហាញមួយស្តីពីចំណុចនេះ។ យើងក៏បានធ្វើការលើប្រធានបទមួយដែលមានសារៈសំខាន់បំផុត ហើយដែលត្រូវបានគេពិភាក្សានៅប្រទេសអ៊ីតាលី គឺនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកមួយ គឺ Paestum។ នោះគឺអាហារូបករណ៍មេឌីទែរ៉ាណេផ្នែកទេសចរនិងបុរាណវិទ្យា។

[ស្លាយ] នោះគឺជាសម័យប្រជុំមួយដែលធ្វើឡើងជារៀងរាល់ឆ្នាំនៅ Paestum ដែលជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក។ ហើយយើងមានកិត្តិយសនិងក្តីសោមនស្សរីករាយដោយបានទទួលឯកឧត្តម សុខ សង្វារ ដែលជានាយកមួយរូបនៅក្រសួងទេសចរណ៍ ហើយដែលលោកបានឃើញផ្ទាល់នៅ Paestum នូវអាហារូបករណ៍ដ៏ពិសេសនេះដែលយើងនឹងដាក់ឈ្មោះថា អាហារូបករណ៍ពិភពលោកផ្នែកទេសចរណ៍និងបុរាណវិទ្យា ព្រោះថានៅពេលបច្ចុប្បន្ននេះ អាហារូបករណ៍នេះផ្តល់ជូនអ្នកតំណាងប្រទេស Pérou អ្នកតំណាងប្រទេស Mexique ព្រមទាំងដល់អ្នកតំណាងរបស់បណ្តាប្រទេសអឺរ៉ុបកណ្តាលនិងបណ្តាប្រទេសអាស៊ី។ ដូច្នេះ អាហារូបករណ៍នេះគឺជាកន្លែងតែមួយគត់ដែលមានកិច្ចសន្ទនាគ្នារវាងអ្នកឯកទេសផ្នែកបុរាណវិទ្យា សាស្ត្រាចារ្យសាកលវិទ្យាល័យដែលទទួលបន្ទុកផ្នែកការសិក្សានិងការអភិរក្សប្រាង្គប្រាសាទ និងអ្នកឯកទេសផ្នែកទេសចរណ៍ដែល នៅក្នុងរយៈពេល ៣ថ្ងៃ អាចសិក្សាអំពីយុទ្ធសាស្ត្រនានា និងរៀបចំទស្សនៈព្រមទាំងការអភិវឌ្ឍវិស័យទេសចរណ៍មួយដែលគោរពដល់បេតិកភណ្ឌវប្បធម៌។ ព្រោះថា ថ្វីត្បិតវាជាការសំខាន់ដែលត្រូវគិតគូរដល់ផ្នែកសេដ្ឋកិច្ចនៃវិស័យទេសចរណ៍ ប៉ុន្តែសម្រាប់យើងវាក៏សំខាន់ដែរដែលត្រូវគិតគូរដល់ការអភិរក្សបេតិកភណ្ឌ តាមរយៈភ្នាក់ងារដែលទទួលបន្ទុកផ្នែកអភិវឌ្ឍន៍វិស័យទេសចរណ៍។

លោកប្រធានជាទីគោរព ទាំងនេះហើយជាអ្វីដែលខ្ញុំចង់ជម្រាបជូនក្នុងរយៈពេលប៉ុន្មាននាទីនេះ ដើម្បីបង្ហាញថាតើនៅពេលបច្ចុប្បន្ននេះ អាជ្ញាធរកម្ពុជាគិតគូរយកចិត្តទុកដាក់ប៉ុនណាចំពោះបញ្ហាប្រឈមទាំងនេះ ដែលជាបញ្ហានៃការគ្រប់គ្រងបេតិកភណ្ឌនៅចំពោះមុខការអភិវឌ្ឍទេសចរណ៍។ សូមអរគុណ។

## IV.2 ឯកសារនិងបញ្ជីសារពើភណ្ឌនៃសារមន្ទីររបស់ប្រទេសកម្ពុជា ដោយលោកស្រី Nao Hayashi អ្នកទទួលខុសត្រូវសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ផ្នែកសារមន្ទីរនិងសម្បត្តិវប្បធម៌នៃអង្គការយូណេស្កូ និង ដោយលោក Gaël de Guichen ទីប្រឹក្សារបស់អគ្គនាយក ICCROM

**លោកស្រី** Nao Hayashi៖

សូមគោរពលោកសហប្រធាន! សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី! សូមគោរពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ! ឯកឧត្តម លោក លោកស្រី ជាទីគោរព!

ខ្ញុំមានកិត្តិយសបង្ហាញជូនលោក លោកស្រី នូវរបាយការណ៍សង្ខេបស្តីពីកិច្ចការដែលធ្វើដោយយូណេស្កូចាប់តាំងពីឆ្នាំ២០០៨មក ជាមួយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងការអភិវឌ្ឍសារមន្ទីរនិងអំពីទស្សនវិស័យនៃកិច្ចសហប្រតិបត្តិការ។

បន្ទាប់ពីអនុសាសន៍របស់លោកស្រី Françoise Rivière អគ្គនាយិការងរបស់យូណេស្កូទទួលបន្ទុកផ្នែកវប្បធម៌ ដែលត្រូវបានអនុម័តនៅក្នុងសម័យប្រជុំពេញអង្គរបស់ CIC នៅខែធ្នូ ឆ្នាំ២០០៦មក យូណេស្កូបានធ្វើកិច្ចការជាច្រើនដើម្បីពង្រឹងសារមន្ទីរនៅប្រទេសកម្ពុជា។

ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា គឺនាយកដ្ឋានដែលដឹកនាំដោយលោកស្រី ចៅ ស៊ុន កិរិយា នៅខែធ្នូ ឆ្នាំ២០០៨ យើងបានរៀបចំជាអាទិ៍នូវសិក្ខាសាលាមួយដើម្បីពិចារណាកំណត់អំពីអាទិភាពទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការចូលរួមពីសំណាក់អ្នកអភិរក្សសារមន្ទីរសំខាន់ៗក្នុងប្រទេសកម្ពុជា។

នេះគឺជាសញ្ញាមួយបញ្ជាក់ពីការយកចិត្តទុកដាក់និងភាពចាំបាច់ក្នុងការជួយពួកគេឲ្យធ្វើការកែលម្អឲ្យរឹតតែប្រសើរឡើងនូវប្រព័ន្ធឯកសារ និងបញ្ជីសារពើភណ្ឌ មិនត្រឹមតែដើម្បីធានាបាននូវកម្មសិទ្ធិនៃវត្ថុប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីបំពាក់សម្ភារៈដល់សារមន្ទីរដែលអាចឲ្យពួកគេបំពេញបេសកកម្មនៅក្នុងបរិបទថ្មីៗ។

គឺដោយផ្អែកលើការកត់សម្គាល់នេះហើយដែលពីថ្ងៃទី៤ ដល់ថ្ងៃទី៩ ខែធ្នូ នៅទីក្រុងភ្នំពេញ យូណេស្កូបានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមួយ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយលោក ហាប់ ទូច ដែលជានាយកសារមន្ទីរជាតិ។ យើងបានអញ្ជើញសមាជិកនានាដែលពាក់ព័ន្ធផ្ទាល់នឹងការងារផ្នែកឯកសារនិងបញ្ជីសារពើភណ្ឌឲ្យមកចូលរួម។

លោក Gaël de Guichen និងលោក Simon Warrack ដែលជាអ្នកជំនាញតែងតាំងដោយ ICCROM បានរៀបចំដឹកនាំវគ្គបណ្តុះបណ្តាលនេះ។ ឥឡូវនេះ ខ្ញុំសូមអញ្ជើញលោក Gaël de Guichen ឡើងមកបង្ហាញរបាយការណ៍នៃការបណ្តុះបណ្តាលនេះ ហើយបន្ទាប់មកទៀត ខ្ញុំនឹងឡើងមកនិយាយបន្ត។

**លោក** GUICHEN**៖**

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោកសហប្រធាន លោក លោកស្រី ជាទីគោរព!

[ស្លាយ] សិក្ខាសាលាបណ្តុះបណ្តាលផ្នែកឯកសារនិងបញ្ជីសារពើភណ្ឌសម្រាប់សារមន្ទីរប្រទេសកម្ពុជា បានប្រព្រឹត្តទៅពីថ្ងៃទី៤ ដល់ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ នៅក្នុងសារមន្ទីរជាតិទីក្រុងភ្នំពេញ ដោយមានការផ្តល់ហិរញ្ញប្បទានពីយូណេស្កូ។

សិក្ខាសាលានេះមានអ្នកចូលរួមចំនួន២៩រូប មកពីសារមន្ទីរចំនួន១៥ ដែលភាគច្រើននៃសារមន្ទីរទាំងនេះមានសមុច្ច័យបុរាណវិទ្យា។

ប៉ុន្តែសារមន្ទីរទាំងនោះមានលក្ខណៈខុសគ្នាច្រើន ពោលគឺចាប់ពីគ្រឹះស្ថានដែលមានបុគ្គលិកតែម្នាក់និងសមុច្ច័យដែលមានវត្ថុបុរាណចំនួនតែ៥ ទៅដល់សារមន្ទីរជាតិដែលមានបុគ្គលិកជាង១០០នាក់ និង វត្ថុបុរាណចំនួន ១៧ ៣១០។

[ស្លាយ] ជាសរុប គ្រឹះស្ថានទាំងនោះទទួលខុសត្រូវលើវត្ថុបុរាណចំនួន ៣៦ ១៧៨ ដែលនៅក្នុងចំណោមនេះ ៩០% ត្រូវបានរក្សាទុកនៅក្នុងឃ្លាំង ហើយ១០% ត្រូវបានដាក់តាំង។ គួរកត់សម្គាល់ថា អ្នកចូលរួមទាំងអស់គឺជាអ្នកទទួលខុសត្រូវផ្នែកឯកសារ ហើយនេះពិតជាធ្វើឲ្យពួកគេមានការយកចិត្តទុកដាក់យ៉ាងខ្លាំង។

[ស្លាយ] សិក្ខាសាលាបានប្រព្រឹត្តទៅនៅក្នុងសាលមួយរបស់សារមន្ទីរជាតិ ដែលមិនត្រឹមតែអាចធ្វើការងារអនុវត្តន៍ផ្ទាល់ដោយប្រើសមុច្ច័យជាក់ស្តែងប៉ុណ្ណោះទេ (ទាំងនៅក្នុងសាលដាក់តាំងក៏ដូចជានៅក្នុងឃ្លាំង) ប៉ុន្តែថែមទាំងអាច

ពន្យល់បន្ថែមលើការសិក្សាផ្នែកទ្រឹស្តីដោយប្រើឯកសារទាំងអស់ដែលត្រូវបានរៀបចំដោយសារមន្ទីរ អស់រយៈពេលជាច្រើនឆ្នាំមកហើយរហូតមកទល់ពេលនេះ។

[ស្លាយ] សរុបមក សិក្ខាសាលាមានការសិក្សាចំនួន៣៦ម៉ោង ដែលត្រូវបានបែងចែកដូចខាងក្រោមនេះៈ
ការសិក្សាផ្នែកទ្រឹស្តីចំនួន១២ម៉ោង
ការងារជាក្រុមចំនួន៩ម៉ោង
ការងារអនុវត្តន៍ចំនួន៩ម៉ោង
និងការទស្សនាចំនួន៦ម៉ោង

[ស្លាយ] នៅថ្ងៃទីមួយ អ្នកចូលរួមបានបង្ហាញឯកសារដែលមានស្រាប់នៅក្នុងគ្រឹះស្ថានរបស់ពួកគេ ហើយបានកំណត់បញ្ហាដែលពួកគេមានដូចគ្នា។ ការសិក្សានេះបានបង្ហាញឲ្យឃើញថា វត្ថុចំនួន៩៥% ត្រូវបានចុះលេខដោយប្រើប្រាស់វិធីផ្សេងៗគ្នា ហើយនេះគឺជាការសំខាន់ណាស់។

[ស្លាយ] ទីពីរ វត្ថុជាច្រើនត្រូវបានចុះបញ្ជី ប៉ុន្តែកម្រចុះទៅក្នុងបញ្ជីសារពើភណ្ឌណាស់។

[ស្លាយ] ទីបី លើកលែងតែសារមន្ទីរជាតិចេញ គ្មានប្រព័ន្ធកំណត់ទីកន្លែងរបស់វត្ថុទេ ឬ មានលក្ខណៈខុសប្លែកពីគ្នា។

ទីបួន គ្មានសលាកប័ត្រគោល គ្មានសលាកប័ត្រតាមប្រភេទ និងគ្មានសំណុំឯកសារមួយៗសម្រាប់វត្ថុដែលសំខាន់ៗទេ។

[ស្លាយ] ម្យ៉ាងទៀត នៅក្នុងសារមន្ទីរចំនួន១១ក្នុងចំណោមសារមន្ទីរទាំង១៥ វត្ថុដែលរក្សាទុកក្នុងឃ្លាំងត្រូវបានដាក់នៅនឹងដី ដោយសារតែគ្មានទូដាក់ត្រឹមត្រូវ។

[ស្លាយ] មានតែសារមន្ទីរចំនួន៣ប៉ុណ្ណោះដែលបានបញ្ចូលសំណុំសលាកប័ត្ររបស់ខ្លួនមួយផ្នែកទៅក្នុងកុំព្យូទ័រ។ ប៉ុន្តែជារួម ស្ថានភាពមិនជាអាក្រក់ទេ បើធ្វើកិច្ចការបន្ថែមបន្តិចបន្តួចទៀតគឺអាចបំពេញបន្ថែមសំណុំឯកសារនេះ។

[ស្លាយ] នៅថ្ងៃទីពីរ យើងបានពិពណ៌នាអំពីសមាសធាតុទាំងប្រាំបីដែលបង្កើតប្រព័ន្ធឯកសារ។

[ស្លាយ] បន្ទាប់មកទៀត ជាមួយនឹងវត្ថុប្រើប្រាស់ប្រចាំថ្ងៃដែលអ្នកចូលរួមបាននាំយកមកជាមួយ សមុច្ច័យមួយត្រូវបានបង្កើតឡើង។ សមុច្ច័យនេះបានក្លាយទៅជាសមុច្ច័យរបស់សារមន្ទីរមួយដែលគ្នាយើងហៅថា "សារមន្ទីរសិក្ខាសាលា"។ ផ្តើមចេញពីការប្រមូលផ្តុំវត្ថុទាំងអស់នេះ សមាសធាតុទាំងប្រាំបីដែលបង្កើតជាឯកសារពេញលេញត្រូវបានធ្វើឡើង។

[ស្លាយ] ថ្ងៃទីបីគឺជាការទស្សនាសារមន្ទីរខេត្តតាកែវ។ នាយកសារមន្ទីរបានបង្ហាញសមាសធាតុនៃប្រព័ន្ធឯកសារដែលខ្លួនប្រើប្រាស់។ ដូច្នេះ សិក្ខាកាមអាចមានលទ្ធភាពធ្វើការវាយតម្លៃជាលើកទីមួយ។

[ស្លាយ] នៅថ្ងៃទីបួន សិក្ខាកាមបានសិក្សាអំពីឯកសារនៃសារមន្ទីររបស់ពួកគេ និងបានបង្កើតគម្រោងកែលម្អសម្រាប់សារមន្ទីររៀងៗខ្លួន ព្រមទាំងបានវាយតម្លៃអំពីសម្ភារៈចាំបាច់និងពេលវេលាដែលពួកគេត្រូវការ។

[ស្លាយ] ថ្ងៃទីប្រាំ យើងបានសិក្សាលើវត្ថុនៅក្នុងឃ្លាំង ដោយធ្វើការអនុវត្តន៍ជាក់ស្តែងនៅក្នុងឃ្លាំងសារមន្ទីរផ្ទាល់ ដើម្បីឲ្យដឹងថាតើអ្វីទៅជាលក្ខខណ្ឌអប្បបរមាក្នុងការផ្ទុំបំណែកផ្សេងៗនៃវត្ថុមួយឡើងវិញ ពោលគឺចង់ដឹងថាតើវត្ថុអ្វីដែលខ្វះ វត្ថុអ្វីដែលមាន អាចផ្គុំជាមួយព័ត៌មាននៅក្នុងឯកសារ។

[ស្លាយ] នៅថ្ងៃចុងក្រោយ ការផ្គុំបំណែកនានានៃវត្ថុ "សារមន្ទីរសិក្ខាសាលា" ត្រូវបានធ្វើឡើង ដើម្បីសិក្សាអំពីការលំបាកនិងហានិភ័យដែលជួបប្រទះនៅក្នុងអំឡុងពេលនៃប្រតិបត្តិការបែបនេះ។

[ស្លាយ] នៅពេលនោះ នាយកសារមន្ទីរជាតិបានដឹកនាំវគ្គរៀនសូត្រមួយដ៏គួរឲ្យចាប់អារម្មណ៍ ដែលនៅក្នុងវគ្គនោះ សិក្ខាកាមបានសម្រេចអនុម័តយកប្រព័ន្ធចុះលេខថ្មីមួយដែលមានការឯកភាពគ្នា ហើយដែលអាចយកទៅប្រើបាននៅក្នុងគ្រប់សារមន្ទីរថ្នាក់ជាតិ។ សំណើនេះនឹងត្រូវដាក់ជូននិងស្នើសុំការយល់ព្រមពីសំណាក់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងវប្បធម៌នៅពេលឆាប់ៗនេះ។

[ស្លាយ] សិក្ខាសាលាបានបិទបញ្ចប់ដោយមានការប្រគល់វិញ្ញាបនបត្រ។ បន្ទាប់មកទៀត ការវាយតម្លៃមួយត្រូវបានធ្វើឡើងដោយមានសំណួរចំនួនប្រាំបីដែលបានផ្តល់លទ្ធផលដូចដែលលោក លោកស្រី អាចមើលឃើញនៅក្នុងតារាងនេះស្រាប់៖ ល្អចំនួន១៤% ល្អណាស់ចំនួន៧២% និងល្អប្រសើរចំនួន១៤%។

[ស្លាយ] ឯកសារគរុកោសល្យដែលយកមកប្រើក្នុងសិក្ខាសាលានេះ គឺជាផ្នែកមួយនៃសម្ភារៈដែលបានរៀបចំឡើងនៅក្នុងក្របខណ្ឌនៃភាពជាដៃគូរវាងយូណេស្កូនិង ICCROM។ ឯកសារនេះត្រូវបានប្រើសាកល្បងជាលើកទីមួយ ប៉ុន្តែយើងបានកែប្រែផ្នែកខ្លះៗរួចហើយ ចំណែកផ្នែកផ្សេងទៀត យើងអាចនិយាយបានថា វាពិតជាបានផ្តល់អោយយើងនូវការពេញចិត្តយ៉ាងខ្លាំង។
សូមអរគុណ។

**លោកស្រី** Hayahsi ៖
ខ្ញុំសូមអនុញ្ញាតត្រឡប់មកនិយាយអំពីរមណីយដ្ឋានអង្គរវិញ។ សម្រាប់រមណីយដ្ឋានអង្គរ វត្ថុដែលគេរកឃើញបង្កើតបានជារតនសម្បត្តិផ្នែកវប្បធម៌និងវិទ្យាសាស្រ្តមិនអាចកាត់ថ្លៃបាន សម្រាប់ការសិក្សាស្រាវជ្រាវនិងសកម្មភាពរបស់សារមន្ទីរ។ ការចុះបញ្ជីដ៏ល្អិតល្អន់នៃវត្ថុទាំងនោះ និងការអាចចូលមើលសមុច្ច័យទាំងនោះដោយសហគមន៍អ្នកវិទ្យាសាស្រ្តត្រូវតែធានាឲ្យបាន ដើម្បីធានានូវការអភិរក្សវត្ថុទាំងនោះ និងដើម្បីលើកស្ទួយការសិក្សាអំពីអារ្យធម៌ខ្មែរ។
ដូចដែលលោក លោកស្រី ជ្រាបស្រាប់ហើយ ជាគោលការណ៍ វត្ថុដែលបានមកពីរមណីយដ្ឋានត្រូវបានចាត់ទុកថាជាកម្មសិទ្ធិសាធារណៈរបស់ជាតិ។ ប៉ុន្តែស្ថាប័នដែលបានរកឃើញវត្ថុទាំងនោះរក្សាកម្មសិទ្ធិវិទ្យាសាស្រ្ត។
ប៉ុន្តែនៅចុងបញ្ចប់នៃរយៈពេលនៃការសិក្សានេះ យើងយល់ថាវាគឺជាការចាំបាច់ដែលវត្ថុទាំងអស់គួរតែទុកនៅអាជ្ញាធរជាតិអប្សរាដែលដើរតួនាទីជាអ្នកត្រួតពិនិត្យ ដោយមានប្រព័ន្ធបញ្ជីសារពើភណ្ឌសមស្របនិងមានលក្ខណៈប្រមូលផ្តុំ។

ម្យ៉ាងទៀត ខ្ញុំយល់ថាវាគឺជាការមានប្រយោជន៍ដែលត្រូវពិនិត្យជាមួយអាជ្ញាធរពាក់ព័ន្ធ នូវសេចក្តីសម្អាងផ្នែកច្បាប់ដែលមានស្រាប់ស្តីពីវត្ថុរកឃើញនៅនឹងរមណីយដ្ឋានបុរាណវិទ្យានានា។ ហើយប្រសិនបើយល់ឃើញថាចាំបាច់ ត្រូវពិនិត្យដោយអាជ្ញាធរជាតិដែលផ្តល់ជាអនុក្រឹត្យ ឬ ជាច្បាប់អាជីវកម្មសមធម៌ ទៅលើទ្រព្យសម្បត្តិវប្បធម៌ ហើយ

ដែលគេអាចយកទៅអនុវត្តន៍បានចំពោះគ្រប់ប្រតិបត្តិការទាំងអស់នៅតាមរមណីយដ្ឋានបុរាណវិទ្យាក្នុងប្រទេសកម្ពុជា។

យូណេស្កូក៏ចង់ជម្រាបផងដែរអំពីវត្តមានរបស់ពួកគេនៅព្រះរាជាណាចក្រកម្ពុជា ក្រៅពីបញ្ហាបច្ចេកទេស ព្រោះថាសិក្ខាកាមឆ្នាំ២០០៨ ក៏បានគូសបញ្ជាក់ផងដែរអំពីទំនាក់ទំនងរវាងសារមន្ទីរ និងបញ្ហានៃការអភិវឌ្ឍប្រកបដោយចីរភាព ជាអាទិ៍ទាក់ទងនឹងអ្វីដែលត្រូវតែធ្វើខាងវិស័យអប់រំនិងកម្មវិធីស្តីពីការចូលរួមរបស់សហគមន៍ក្នុងជីវិតសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការពង្រឹងការត្រួតពិនិត្យរបស់ពួកគេទៅលើតម្លៃវប្បធម៌។

យើងនឹងអាចរិះរកនៃការចូលរួមរបស់ប្រជាជនទាំងនោះ នៅក្នុងអភិក្រមនៃការកំណត់អត្តសញ្ញាណតម្លៃវប្បធម៌ពិសេសរបស់ពួកគេ ទៅតាមគំរូនៃគម្រោងផ្សេងទៀតរបស់យូណេស្កូដែលកំពុងបង្កើតនៅប្រទេសកម្ពុជានិងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍។

គោលការណ៍ទូទៅទាំងនេះពិតជាត្រូវទៅនឹងរមណីយដ្ឋានអង្គរ ចំពេលដែលសារមន្ទីរមួយអាចចូលរួមចំណែកក្នុងវិធីថ្មីនៃការអភិវឌ្ឍប្រកបដោយចីរភាពដែលត្រូវបានធ្វើការអនុម័តជាផ្លូវការនៅឆ្នាំ២០០៣។
ដូចដែលលោក លោកស្រី បានឃើញស្រាប់ហើយ វិធីនេះសំដៅទៅយកចិត្តទុកដាក់លើការគ្រប់គ្រងរមណីយដ្ឋាននៅក្នុងទស្សនវិស័យរួមមួយ ដើម្បីធានាអោយមានតុល្យភាពរវាងការការពារតម្លៃបេតិកភណ្ឌរបស់រមណីយដ្ឋាននិងការលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជនដែលរស់នៅជុំវិញរមណីយដ្ឋាន។ យោងតាមលទ្ធផលនៃការពិគ្រោះយោបល់ដែលធ្វើឡើងក្នុងនាម CIC ជាមួយស្ថាប័នវិទ្យាសាស្ត្រនៅសៀមរាប ទិសដៅនៃកិច្ចសហប្រតិបត្តិការមួយដែលមានរយៈពេលយូរអង្វែង ហាក់ដូចជាលេចរូបរាងឡើង។

សារមន្ទីរនិយាយអំពីជីវិតប្រជាជនអាចជាការបំពេញបន្ថែមដ៏ល្អមួយដល់សារមន្ទីរដែលមានស្រាប់នៅអង្គរ ដែលភាគច្រើនជាសារមន្ទីរបុរាណវិទ្យា។ សារមន្ទីរនេះអាចធ្វើឡើងនៅក្នុងផ្ទះបុរាណមួយដែលយើងយកមកជួសជុលហើយប្រហែលជាអាចជ្រើសរើសយកវិធីសាស្ត្រសារមន្ទីរវិទ្យាបែបអន្តរកម្មមួយ ដើម្បីលើកតម្លៃពិធីបុណ្យបែបសាសនានិងជំនឿផ្សេងៗ ព្រមទាំងសិល្បៈផ្នែកវាយនភណ្ឌ សិប្បកម្មបែបប្រពៃណីដូចជាការធ្វើកញ្ច្រែង ល្អី ឬក៏តួនាទីនៃម្ហូបអាហារនៅក្នុងវប្បធម៌ក្នុងស្រុក។ សារមន្ទីរបែបនេះមិនចាំបាច់ថាជាសារមន្ទីរធំពេកទេ។

លទ្ធភាពមួយទៀតគឺការបង្កើត *សារមន្ទីរចម្រុះ* មួយដែលជាគម្រោងធំ ដែលបង្ហាញអំពីរមណីយដ្ឋានអង្គរគ្រប់រូបភាពមានបង្ហាញទាំងបណ្តាញនិងវិស្វកម្មធារាសាស្ត្រ ព្រៃឈើនិងប្រវត្តិរុក្ខជាតិ ទំនាក់ទំនងអង្គរជាមួយបឹងទន្លេសាបព្រមទាំងបង្ហាញអំពីប្រវត្តិរបស់ប្រជាជនដែលរស់នៅជុំវិញរមណីយដ្ឋានផងដែរ។ សារមន្ទីរនេះត្រូវបញ្ចូលលក្ខណៈនៃសារមន្ទីរអំពីជីវិតប្រជាជនដែលបានរៀបរាប់ខាងលើ។

ជាសេចក្តីសន្និដ្ឋាន យូណេស្កូបន្តជួយអាជ្ញាធរជាតិនៅក្នុងការអនុវត្តគម្រោងផ្សេងៗ ដែលចូលរួមចំណែកដល់ការធ្វើឲ្យរឹតតែប្រសើរឡើងនូវការស្វែងយល់អំពីវត្ថុអភិរក្សនិងការអភិវឌ្ឍរមណីយដ្ឋានប្រកបដោយតុល្យភាព ដល់ការស្វែងយល់អោយបានកាន់តែច្បាស់អំពីប្រវត្តិសាស្ត្ររបស់ប្រទេស ជាប្រយោជន៍ដល់ការអប់រំប្រជាជន ព្រមទាំងពង្រឹងសារមន្ទីរដែលមានស្រាប់ដើម្បីលើកតម្កើងការសិក្សានិងបណ្តុះផ្នែកវិទ្យាសាស្ត្រ។

នៅទីបញ្ចប់ ផ្នែកវប្បធម៌របស់យូណេស្កូនិងដោយមានការយកចិត្តទុកដាក់ពីសំណាក់លោកស្រី Françoise Rivière

ដែលជាអគ្គនាយិការង យើងប្តេជ្ញាថាដើរទៅតាមទស្សនវិស័យនេះ។

សូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** ខ្ញុំសូមថ្លែងអំណរគុណលោកស្រី Hayashi និងលោក de Guichen ដែលបានរំឭកយើងទាំងបញ្ហានានាទាក់ទងនឹងសារមន្ទីរ ក៏ដូចជាទំនាក់ទំនងនៃសារមន្ទីរជាមួយការងារផ្នែកវិទ្យាសាស្ត្រ បុរាណវិទ្យានិងអភិរក្ស។ ជាអាទិ៍ លោក លោកស្រី បានលើកឡើងពីភាពចាំបាច់ដែលត្រូវមានក្របខណ្ឌគតិយុត្តិ ដើម្បីរៀបចំការងាររបស់ក្រុមការងារវិទ្យាសាស្ត្រនិងបុរាណវិទ្យា។

នៅពេលនេះ តើមាននរណាម្នាក់ចង់សួរសំណួរទៅក្រុមការងារយូណេស្កូស្តីពីសំណើទាក់ទងនឹងសារមន្ទីរទាំងនេះទេ? បើគ្មានសំណួរទេ ជាដំបូង យើងអាចស្តាប់បទបង្ហាញរបស់សាកលវិទ្យាល័យ Sydney បន្ទាប់មកទៀត បទបង្ហាញរបស់ក្រុមការងាររបស់ប្រទេសហុងគ្រី និងបទបង្ហាញរបស់ប្រទេសបារាំង មុននឹងផ្តល់យោបល់ទៅអ្នកជំនាញ អាដ ហុករបស់យើង។
អញ្ចឹង ខ្ញុំសូមអញ្ជើញលោកស្រីបណ្ឌិត Eleanor Bruce មកពីសាកលវិទ្យាល័យ Sydney ឡើងធ្វើបទបង្ហាញ។

## IV.3 **លទ្ធផលគម្រោង** "Living with Heritage" **ដោយបណ្ឌិត** Eleanor Bruce **សាស្ត្រាចារ្យសាកលវិទ្យាល័យ** Sydney

សូមគោរពឯកឧត្តមរដ្ឋមន្ត្រី ភ្ញៀវកិត្តិយសជាទីគោរពរាប់អាន!
គម្រោង *Living with heritage* ត្រូវបានផ្តល់ហិរញ្ញប្បទានដោយក្រុមប្រឹក្សាសិក្សាស្រាវជ្រាវប្រទេសអូស្ត្រាលី និងអង្គការមួយចំនួនទៀតដែលនៅក្នុងនោះមានយូណេស្កូនិងអប្សរា ទៅតាមគំនិតផ្តួចផ្តើមនិងសិក្សាស្រាវជ្រាវរបស់រដ្ឋាភិបាលអូស្ត្រាលី។

ចំណុចដ៏សំខាន់មួយនៃហិរញ្ញប្បទាននេះគឺ ជំរុញឲ្យមានកិច្ចសហប្រតិបត្តិការរវាងអ្នកស្រាវជ្រាវនិងអង្គការដែលចូលរួម ទាំងអស់ ជំរុញអោយមានការអនុវត្តល្អក្នុងការការគ្រប់គ្រងនិងការអភិរក្សធនធាននានានិងបេតិកភណ្ឌសម្រាប់មនុស្សជំនាន់ក្រោយ។

ប្រភេទនៃជំនាញដែលផ្តល់ដោយក្រុមស្រាវជ្រាវមានដូចជា ជំនាញខាងគ្រប់គ្រងបេតិកភណ្ឌ បុរាណវិទ្យា ទេសចរណ៍ ភូមិសាស្ត្រនិងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) បង្កើតជាវិធីសាស្ត្ររួមមួយដើម្បីដោះស្រាយបញ្ហាដ៏បន្ទាន់បំផុតក្នុងការគ្រប់គ្រងអង្គរ។

ខ្ញុំនឹងជម្រាបជូនត្រួសៗអំពីការសិក្សានៅក្នុងគម្រោងនេះ។ បន្ទាប់មកទៀត ខ្ញុំនឹងបង្ហាញជូននូវឧបករណ៍ពីរមាននៅក្នុងអីនធឺណែត ដែលយើងបានបង្កើតឡើងដើម្បីជួយដល់ការគ្រប់គ្រងបេតិកភណ្ឌ។ លទ្ធផលសំខាន់ៗនៃការងារស្រាវជ្រាវក្នុងគម្រោងនាបណ្តាឆ្នាំចុងក្រោយនេះដែលមានរយៈពេលចំនួនប្រាំឆ្នាំ អាចឲ្យយើងស្វែងយល់ផលប៉ះពាល់នៃការដែលបញ្ចូលឧទ្យានអង្គរទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ទៅលើសហគមន៍ដែលរស់នៅខាងក្នុងនិងជុំវិញឧទ្យាន។ លទ្ធផលទាំងនេះក៏ធ្វើឲ្យយើងគិតគូរដល់បេតិកភណ្ឌអរូបិយនិងចំណេះធ្វើនៅក្នុងស្រុក ទន្ទឹមនឹង

នោះ ក៏ត្រូវតាមដានមើលការវិវឌ្ឍនៃទេសភាពវប្បធម៌ និងបង្កើតវិធីសាស្ត្រគ្របដណ្តប់លើភូមិសាស្ត្រច្បាស់លាស់ ដើម្បីតាមដានមើលការវិវឌ្ឍទាំងនេះ និងពិនិត្យតួនាទីនៃការអនុវត្តការគ្រប់គ្រង។

ការសិក្សាមួយសំដៅទៅបង្កើតសៀវភៅផែនទីទេសភាពវប្បធម៌។ សៀវភៅនេះត្រូវបានបកប្រែជាភាសាខ្មែរ ហើយសៀវភៅណែនាំមួយក៏ត្រូវបានតាក់តែងឡើងផងដែរដើម្បីឲ្យអប្សរាអាចយកវាទៅប្រើប្រាស់បាននៅថ្ងៃក្រោយ។

ការសិក្សាមួយទៀតទាក់ទងនឹងទស្សនវិស័យរបស់អ្នកស្រុកចំពោះការគ្រប់គ្រងការកាន់កាប់ដីធ្លី។ ដោះស្រាយបញ្ហាប្រឈមដ៏សំខាន់នៃការគ្រប់គ្រង ឈានទៅដល់ការបង្កើតរបបរដ្ឋបាលដ៏មានប្រសិទ្ធិភាពមួយនៃការគ្រប់គ្រងដីធ្លី។

ការសិក្សាទីបី គឺសាកល្បងស្វែងយល់និងពិនិត្យទំនាក់ទំនងរវាងសហគមន៍ក្នុងស្រុកនិងកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ។

ការសិក្សាទីបួន គឺពិនិត្យមើលទំនាក់ទំនងរវាងឧទ្យានអង្គរនិងទេសភាពដែលស្ថិតនៅជុំវិញ ព្រមទាំងផលប៉ះពាល់នៃការអភិវឌ្ឍទៅលើតម្លៃសំខាន់ៗនៃបេតិកភណ្ឌនៅក្នុងឧទ្យាន។ ការសិក្សាក៏ផ្តោតផងដែរទៅលើការអនុវត្តការគ្រប់គ្រងដែលមានការចូលរួមពីអ្នកស្រុក ដែលអនុវត្តន៍ដោយអប្សរា វាមានសារៈសំខាន់សម្រាប់ធានាបាននូវតម្លៃនៃដៃគូចូលរួមនានា មានជាអាទិ៍ សហគមន៍ក្នុងស្រុក ភ្ញៀវអន្តរជាតិ និងអ្នកជំនាញខាងការគ្រប់គ្រងបេតិកភណ្ឌដែលត្រូវបានគិតបញ្ចូលទៅក្នុងការរៀបចំផែនការស្តីពីទេសភាពបេតិកភណ្ឌ។

ការសិក្សាចុងក្រោយ គឺទាក់ទងនឹងការតាមដានមើលការវិវឌ្ឍនៃទេសភាពរបស់រុក្ខជាតិនិងតំបន់ដែលមានដើមឈើដុះក្នុងនិងជុំវិញឧទ្យាន។ ដោយហេតុថាការចូលទៅតំបន់ដាច់ស្រយាលមានភាពងាយស្រួលជាងមុន វាជាការសំខាន់ដែលត្រូវបង្កើតវិធីសាស្ត្រសម្រាប់សិក្សាអំពីការវិវឌ្ឍនៃទេសភាពនៅលើដីដែលប៉ះពាល់ដោយផលវិបាកនៃការអភិវឌ្ឍ។ ចំណុចសំខាន់ គឺការបង្កើតវិធីសាស្ត្រដែលអាចអោយអ្នកដទៃប្រើបានដោយងាយស្រួល ហើយដែលអប្សរាអាចយកទៅប្រើប្រាស់បាន។ ការងារសិក្សាស្រាវជ្រាវនេះកំពុងតែដំណើរការ ដោយទទួលហិរញ្ញប្បទានតាមរយៈគម្រោង planet action project។

យើងបានបង្កើតគំរូទីកន្លែង-ពេលវេលាដើម្បីពិនិត្យមើលស្ថានភាពទីកន្លែងនិងពេលវេលា និងដើម្បីសាកល្បងបង្កើតរបៀបនិងសកម្មភាពរបស់ភ្ញៀវទេសចរទៅថ្ងៃអនាគតនៅក្នុងឧទ្យាន។
ដូច្នេះ ឧបករណ៍ទាំងពីរដែលមាននៅក្នុង អីនធឺណែត សម្រាប់ជួយដល់ការធ្វើសេចក្តីសម្រេចនៅក្នុងអប្សរា រួមមានទាំងការធ្វើបញ្ជីរមណីយដ្ឋានដែលយើងបានបង្កើតឡើង ដើម្បីឲ្យអ្នកគ្រប់គ្រងអាចធ្វើការសិក្សាស្រាវជ្រាវរកកន្លែងណាមួយនៅក្នុងរមណីយដ្ឋាន និងនៅក្នុងតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ព្រមទាំងដើម្បីរកមើលកន្លែងដែលទទួលរងការគំរាមកំហែងដោយការអភិវឌ្ឍជាយថាហេតុ ដើម្បីធ្វើបច្ចុប្បន្នកម្មមូលដ្ឋានទិន្នន័យ ស្គាល់រមណីយដ្ឋាន និងទទួលព័ត៌មានអំពីរមណីយដ្ឋានអោយបានប្រសើរជាងមុន និងដើម្បីផ្សព្វផ្សាយអំពីផលប្រយោជន៍នៃទីកន្លែងទាំងនេះ។

គំនិតផ្តួចផ្តើមទីពីរ គឺទាក់ទងនឹង ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនៅអង្គរ (ASIS) ព្រោះថា បង្កើតកិច្ចសហការស្តីពីការសិក្សានៅក្នុងឧទ្យានអង្គរសម្រាប់ការគ្រប់គ្រងបេតិកភណ្ឌនិងបុរាណវិទ្យា គឺអាស្រ័យនឹងការសិក្សាស្រាវជ្រាវនិងទិន្នន័យទាំងនេះឯង។ គំនិតផ្តួចផ្តើមនេះត្រូវបានប្រើជាគំរូ ដើម្បីលើកស្ទួយកិច្ចសហការព្រមទាំងការផ្លាស់ប្តូរព័ត៌មានផ្នែកផែនទីនិងភូមិសាស្ត្រ។

លទ្ធផលដ៏សំខាន់មួយទៀតនៃគម្រោងនេះ គឺរបាយការណ៍ដែលបានបោះពុម្ពផ្សាយកាលពីឆ្នាំទៅ ស្តីពីគុណតម្លៃ និងបញ្ហាទាក់ទងនឹងបេតិកភណ្ឌ ហើយខ្ញុំសូមគូសបញ្ជាក់ថា លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបង្កើតបានជាមូលដ្ឋានមួយសម្រាប់ការងារនាពេលអនាគតរបស់គម្រោង ក្របខណ្ឌការងារនៃបេតិកភណ្ឌអង្គរ និងអាចជួយដល់ការផ្តល់អនុសាសន៍និងការចង្អុលបង្ហាញនានាសម្រាប់ការគ្រប់គ្រងបេតិកភណ្ឌដែលស្ថិតនៅក្នុងរមណីយដ្ឋាន។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង ៖** សូមអរគុណច្រើនលោកស្រីបណ្ឌិត Bruce ចំពោះរបាយការណ៍សង្ខេបដ៏ពេញលេញនេះ ស្តីពីការងារដែលបានធ្វើទាក់ទងនឹងបេតិកភណ្ឌ និងស្តីពីអនាគតនៃការគ្រប់គ្រងបេតិកភណ្ឌ។ ទាក់ទងនឹងអ្វីដែលលោកស្រីបានលើកឡើង ខ្ញុំចងចាំថា មធ្យោបាយដ៏ប្រសើរបំផុតក្នុងការអភិរក្សរមណីយដ្ឋាន គឺត្រូវរំលឹកដល់លក្ខណៈពិសិដ្ឋរបស់រមណីយដ្ឋានចំពោះអ្នកស្រុក នេះ ប្រសិនបើយើងចង់រក្សានូវថាមភាពដ៏ខ្លាំងក្លាសម្រាប់ការអភិរក្សមរតកនិងបេតិកភណ្ឌពិភពលោក។ ត្រូវចងចាំថា រមណីយដ្ឋានអង្គរគឺជារមណីយដ្ឋានដ៏ពិសិដ្ឋ ហើយរមណីយដ្ឋាននេះត្រូវតែជារមណីយដ្ឋានពិសិដ្ឋសម្រាប់បុរាណវិទូបរទេស ភ្ញៀវទេសចរបរទេស ឲ្យដូចជារមណីយដ្ឋានមានលក្ខណៈពិសិដ្ឋសម្រាប់ប្រជាជនកម្ពុជានិងអ្នកដែលរស់នៅក្នុងរមណីយដ្ឋាននោះដែរ។

បទអន្តរាគមន៍ទីពីរ៖ លោកបណ្ឌិត Janos ដែលដឹកនាំគម្រោងរបស់ប្រទេសហុងគ្រីនៅកោះកេរ។

## IV.4 ឆ្នាំទីមួយនៃគម្រោង JAYA Koh Ker - របាយការណ៍ឆ្នាំ២០០៩ ដោយលោក Janos Jelen នាយក RAF ( Royal Angkor Foundation ) ប្រទេសហុងគ្រី

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី! ឯកឧត្តមជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ
ឯកឧត្តម លោក លោកស្រីជាទីគោរព!

គម្រោង Jaya Koh Ker (JKK) ដែលជាសំណើមួយរបស់ Royal Angkor Foundation (RAF) នៃទីក្រុង Budapest ប្រទេសហុងគ្រី ត្រូវបានបង្ហាញឲ្យស្គាល់លើកទីមួយនៅក្នុងសម័យប្រជុំលើកទី១៧របស់គណៈកម្មាធិការបច្ចេកទេសនៃគណៈកម្មាធិការសម្របសម្រួលអន្តរជាតិ (CIC) នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨។
ពិធីសារនៃកិច្ចព្រមព្រៀងមួយស្តីពីទិសដៅសំខាន់ៗនិងក្របខណ្ឌហិរញ្ញវត្ថុរបស់គម្រោង ត្រូវបានចុះហត្ថលេខារវាងអាជ្ញាធរជាតិអប្សរា RAF និង Hungarian Indochina Corporation (HUNINCOR) នៅក្នុងសម័យប្រជុំពេញអង្គលើកទី១៥របស់ CIC កាលពីឆ្នាំកន្លងទៅ។ HUNINCOR សន្យានឹងផ្តល់ប្រាក់ចំនួន ៩៨០០០០ដុល្លារ ដល់គម្រោង JKK សម្រាប់រយៈពេលចំនួនបីឆ្នាំ ដោយគិតចាប់ពីថ្ងៃទី១ ខែមករាឆ្នាំ២០០៩ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១១។

ការបង្ហាញលម្អិតអំពីគោលសំខាន់ៗរបស់គម្រោង JKK ត្រូវបានរៀបចំឡើងក្រោមគំនិតផ្តួចផ្តើមរបស់លេខាធិការដ្ឋាន CIC ដោយមានវត្តមាន RAF HUNINCOR និងអប្សរា ហើយបានប្រព្រឹត្តទៅនៅក្នុងការិយាល័យរបស់ JASA កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៩។
ការរៀបរាប់លម្អិតរបស់គម្រោង JKK ត្រូវបានបង្ហាញជូននៅក្នុងសម័យប្រជុំលើកទី១៨នៃគណៈកម្មាធិការបច្ចេកទេសរបស់ CIC នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៩។

បេសកកម្មសំខាន់របស់គម្រោង JKK គឺជួយគាំទ្រអាជ្ញាធរជាតិអប្សរានៅក្នុងសកម្មភាពរបស់ខ្លួន សម្រាប់ការអភិរក្ស និងការអភិវឌ្ឍតំបន់កោះកេរដែលមានសក្តានុពលនឹងអាចក្លាយទៅជារមណីយដ្ឋានបេតិកភណ្ឌពិភពលោក។ គន្លឹះជោគជ័យនៃសកម្មភាពទាំងនេះមានដូចតទៅៈ និរន្តរភាពនៃរបៀបរស់នៅដែលនឹងរស់ឡើងវិញ នៅពេលមានការរៀបចំអភិវឌ្ឍអតីតរាជធានីរបស់អាណាចក្រអង្គរនៅសតវត្សទីX ការពង្រឹងសមត្ថភាពនិងភាពជាដៃគូរវាងភ្នាក់ងារជាតិនិងអន្តរជាតិ ការបង្កើនទំនាក់ទំនងនិងការស្វែងយល់អំពីការវិវត្តសំខាន់ៗដែលមិនអាចចៀសវាងបានរវាងសហគមន៍ក្នុងស្រុក តំណាងរបស់រដ្ឋាភិបាលនិងអ្នកជំនាញបរទេស ភ្ញៀវទេសចរ ទាំងភ្ញៀវក្នុងស្រុកនិងភ្ញៀវអន្តរជាតិ។ និយាយឲ្យខ្លី គឺគុណភាពនៃជីវិតប្រកបដោយចិរភាពនិងគួរប្រាថ្នាចង់បានសម្រាប់បេតិកភណ្ឌ បរិស្ថានធម្មជាតិនិងសហគមន៍។

ហានិភ័យដ៏ធ្ងន់ធ្ងរបំផុតនោះគឺទាក់ទងនឹងការអភិវឌ្ឍដោយគ្មានការត្រួតពិនិត្យនិងមិនមានចិរភាព ដែលជាផលវិបាកនៃការអភិវឌ្ឍទេសចរណ៍លឿនជ្រុលពេក។ ដូច្នេះ គោលដៅសំខាន់នៃគម្រោងគឺចូលរួមចំណែកក្នុងការអភិវឌ្ឍតំបន់នេះប្រកបដោយចីរភាព ដោយកំណត់និងរក្សាសុវត្ថិភាពនៃការអភិរក្សតម្លៃប្រវត្តិសាស្ត្រនិងធម្មជាតិរបស់តំបន់កោះកេរ។ គោលដៅផ្ទាល់មួយក្នុងចំណោមគោលដៅផ្ទាល់ដទៃទៀតរបស់គម្រោងដើម្បីធ្វើការងារឲ្យបានល្អ គឺជួយអាជ្ញាធរជាតិអប្សរាក្នុងការពង្រាងប្លង់មេស្តីពីការអភិវឌ្ឍប្រកបដោយចិរភាព សម្រាប់តំបន់កោះកេរដែលអាចក្លាយទៅជាបេតិកភណ្ឌពិភពលោក។ ប្រសិនបើ និងនៅពេលណាដែលអ្នកចូលរួមផ្សេងៗព្រមព្រៀងគ្នាលើប្លង់មេនេះហើយ វាច្បាស់ជាមានបញ្ចូលទាំងសំណើកំណត់តំបន់ទទួលឥទ្ធិពល និងជួយសម្រួលដល់អន្តរកម្មដើម្បីបង្ការនូវរាល់ការខូចខាតបរិស្ថាន ការខូចខាតប្រាង្គប្រាសាទបច្ចុប្បន្ននៃបេតិកភណ្ឌវប្បធម៌ និងការរស់នៅបែបប្រពៃណីរបស់សហគមន៍។ ដូច្នេះ "ក្របខណ្ឌការងារដ៏សមស្រប" របស់គម្រោងត្រូវបានបង្ហាញនិងធ្វើការពិភាក្សារួចហើយ។

ចំពោះរឿងរៀបចំគម្រោងផែនការ ធាតុសំខាន់ៗរបស់គម្រោងមានឈ្មោះទាំងបីថា បេតិកភណ្ឌ ធម្មជាតិនិងសហគមន៍។ ធាតុទាំងបីនេះផ្អែកលើមុខងារពីររបស់គម្រោង ពោលគឺ "ភាពជាដៃគូនិងការពង្រឹងសមត្ថភាព" និង "ការចែករំលែកចំណេះដឹង"។ មុខងារទាំងនេះផ្តល់ដល់យើងនូវឧបករណ៍ចាំបាច់ដើម្បីផ្ទេររាល់លទ្ធផលរបស់គម្រោងដល់អ្នកចូលរួមសំខាន់ៗ និងជាអាទិភាព គឺផ្តល់ដល់អាជ្ញាធរជាតិអប្សរាដែលជាដៃគូរបស់យើង។

យើងបាននិយាយនៅខាងដើមហើយថា លទ្ធផលមួយក្នុងចំណោមលទ្ធផល "ផ្នែករដ្ឋបាល" របស់គម្រោងនេះ គឺការបង្កើតប្លង់អភិវឌ្ឍន៍ប្រកបដោយចិរភាព ដោយអាជ្ញាធរជាតិអប្សរា។ ប៉ុន្តែ ទោះជាអ្នកជំនាញអប្សរាអាចបង្កើតឯកសារបែបនេះបានក៏ដោយ (អប្សរាពិតជាអាចធ្វើបាន ប្រសិនបើយើងពិនិត្យទៅលើរចនាសម្ព័ន្ធដ៏ធំនិងធនធានបញ្ញាដែលមាននៅក្នុងអាជ្ញាធរជាតិ) ក៏ឯកសារនេះនឹងអាចមានតម្លៃស្មើគ្នាទៅនឹងឯកសារដែលអនុវត្តចេញពីប្លង់មេដែរ។

ដូច្នេះ ភារកិច្ចរបស់យើង គឺផ្តល់នូវក្របខណ្ឌធនធានបញ្ញាទូលំទូលាយ ប៉ុន្តែជាក់ស្តែងមួយ សម្រាប់លទ្ធផលចុងក្រោយដែលគ្រោងទុកដោយ JKK។ ដោយមានរយៈពេលខ្លី យើងសង្ឃឹមថា គម្រោងចាប់ផ្តើមដំណើរការមួយដែលនឹងឈានទៅសម្រេចគោលដៅដូចខាងក្រោមៈ

- ការស្វែងយល់ឲ្យបានច្បាស់លាស់អំពីបេតិកភណ្ឌរបស់តំបន់ប្រវត្តិសាស្ត្រកោះកេរ ដែលត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលភ្ញៀវជាតិនិងភ្ញៀវបរទេស និងរៀបចំកោះកេរឲ្យក្លាយទៅជារមណីយដ្ឋានបេតិកភណ្ឌ

ពិភពលោក។

- កែលម្អនិងការពារឲ្យបានល្អនូវធនធានធម្មជាតិដែលមាន សម្រាប់ការធ្វើអាជីវកម្មរយៈពេលយូរអង្វែង ដោយប្រជាពលរដ្ឋនិងភ្ញៀវដែលមកទស្សនា ដោយគិតគូរដល់តម្លៃប្រពៃណីនិងការវិវត្តបច្ចុប្បន្នផ្នែកអាកាសធាតុនិងធម្មជាតិ។
- ធ្វើឲ្យសហគមន៍មានជីវភាពសមរម្យមួយយ៉ាងឆាប់រហ័ស នៅក្នុងទិសដៅដែលមិនត្រឹមតែត្រូវបានពួកគេទទួលយកបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានស្នើឡើងដោយអ្នកដែលជាប់ពាក់ព័ន្ធទៀតផង។

នៅពេលដែលប្លង់លំអិតនៃគម្រោងត្រូវបានបង្ហាញជូននៅពាក់កណ្តាលទីមួយនៃនិទាឃៈរដូវរួចហើយ តំណាងផ្នែកនីមួយៗបានជួបតំណាងរបស់អាជ្ញាធរជាតិអប្សរា ហើយបានធ្វើដំណើរទៅកាន់រមណីយដ្ឋានដើម្បីវាយតម្លៃស្ថានភាព។

នៅពេលនោះ យើងឃើញថា មួយផ្នែកធំនៃតំបន់ដែលកំណត់ដោយព្រះរាជក្រឹត្យមិនទាន់បានធ្វើការបោសសម្អាតគ្រាប់មីននៅឡើយ។ ប៉ុន្តែ តំបន់កណ្តាលដែលត្រូវបានទស្សនាដោយភ្ញៀវទេសចរ គឺអាចចូលទៅបាន។ ដូច្នេះ ការសម្រេចនិងសកម្មភាពចាំបាច់នានាត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីជួយសម្រួលដល់ការងាររបស់អប្សរានិងអ្នកជំនាញអន្តរជាតិនៅក្នុងតំបន់ដែលមានគ្រាប់មីននៅឡើយ។

គេបានស្នើឲ្យធ្វើការពង្រីកតំបន់ដើម្បីអោយវាត្រូវនឹងទម្រង់ដែលអាចចាត់ចូលទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ ប៉ុន្តែ ការផ្លាស់ប្តូរព្រំដែនតំបន់នេះត្រូវធ្វើទៅតាមនីតិវិធីរដ្ឋបាលនិងគតិយុត្តិដូចដែលត្រូវបានបញ្ញត្តិដោយកថាខណ្ឌ ៨នៃព្រះរាជក្រឹត្យ។ បំណងរបស់យើងគឺគ្រាន់តែជួយសម្រួលដល់កិច្ចពិភាក្សាទាំងឡាយនៅក្នុងអាជ្ញាធរជាតិអប្សរា និងស្ថាប័ននានារបស់រដ្ឋាភិបាល ក្នុងការកំណត់តំបន់ទ្រនាប់និងតំបន់ការពារនៅក្នុងតំបន់ស្នូល។

ផែនទីកាន់កាប់ដីនិងប្រភេទព្រៃឈើមួយត្រូវបានរៀបចំឡើងដោយប្រើរូបភាពផ្កាយរណប ASTER។ ការងាររៀបរយជាបន្តទៀតត្រូវបានគ្រោងទុកនៅក្នុងក្របខណ្ឌនៃសម្រង់បរិស្ថានធម្មជាតិ។

ព្រំប្រទល់តំបន់ដែលត្រូវដោះគ្រាប់មីនត្រូវបានគូរនិងចុះក្នុងផែនទី។ ព្រំប្រទល់នេះមានសារៈសំខាន់បំផុតដើម្បីកំណត់តំបន់ដែលមានសុវត្ថិភាពសម្រាប់ចំណុចនិងមូលដ្ឋាននានានៃសម្រង់។ ការបែងចែកតំបន់ដីទាំងនេះជួយសម្រួលដល់ការកំណត់ប្រភេទដី ដើម្បីបង្កើតផែនទីស្តីពីដីធ្លី ធារាសាស្រ្ត និងជីវៈចម្រុះ។ ការបែងចែកតំបន់ដីធ្វើត្រឹមតំបន់ប្រាង្គប្រាសាទកោះកេរ ស្របទៅតាមព្រះរាជក្រឹត្យដែលកំណត់ប្រាសាទកោះកេរ។

តំបន់ដែលមានសក្តានុពលសម្រាប់សកម្មភាពអភិរក្សត្រូវបានកំណត់ គេក៏បានកំណត់ផងដែរនូវវិធីសាស្រ្តដើម្បីបង្កើតបញ្ជីសារពើភណ្ឌលំអិតនៃសិលាចារឹកទាំង៦៦ដែលគេបានធ្វើជំរឿនរួចហើយនៅកោះកេរ បង្កើតបញ្ជីសារពើភណ្ឌនៃផ្ទាំងថ្មនៅរាយប៉ាយជិតប្រាសាទនីមួយៗដែលគេដឹង កសាងប្រាង្គប្រាសាទឡើងវិញតាមស្ថាបត្យកម្មក្នុងកុំព្យូទ័រ កំណត់លក្ខន្តិកៈសម្រាប់ការរៀបចំផែនការនៃកិច្ចអន្តរាគមន៍បន្ទាន់ៗ សម្រង់រូបថតនៃក្បាច់រចនាស្ថាបត្យកម្មនិងប្រវត្តិសាស្រ្ត។

ការវាយតម្លៃបឋមមួយនិងការកំណត់អំពីការស្ទាបស្ទង់ផ្នែកបុរាណវិទ្យានាពេលអនាគតត្រូវបានបង្កើតឡើង ហើយការកំណត់តំបន់កំណាយប្រកបដោយក្តីសង្ឃឹមបំផុតបានចាប់ផ្តើមដំណើរការ។ នៅពេលធ្វើការរុករកនៅក្នុងតំបន់ដែលមានសុវត្ថិភាព បញ្ជីសារពើភណ្ឌមួយស្តីពីវត្ថុធ្វើអំពីកុលាលភាជន៍និងលោហធាតុត្រូវបានបង្កើតឡើង បន្ទាប់ពី

មានការយល់ព្រមពីអាជ្ញាធរជាតិអប្សរា។ សេចក្តីសន្និដ្ឋានត្រូវបានចុះទៅក្នុងបញ្ជីសារពើភណ្ឌនិងប្រគល់ជូនដល់តំណាងរបស់អប្សរា ដើម្បីអាចធ្វើការសិក្សាឲ្យបានស៊ីជម្រៅ។
ការងារផ្នែកឋានលេខាបុរាណវិទ្យាក៏បានចាប់ផ្តើមដំណើរការផងដែរ។ ការស្ទាបស្ទង់មួយត្រូវបានដឹកនាំធ្វើដើម្បីកំណត់អំពីពេលវេលាចាំបាច់ និងដើម្បីតាក់តែងនីតិវិធី។ លទ្ធផលនៃសកម្មភាពទាំងនេះត្រូវបានដាក់បញ្ចូលទៅក្នុងរបាយការណ៍ដែលបានប្រគល់ជូនលោក លោកស្រី ហើយដែលបង្ហាញឲ្យឃើញអំពីការងារសរុបនៃឆ្នាំទីមួយ។

ចំពោះអ្វីដែលទាក់ទងនឹងក្រុមសហគមន៍៖ ស្របតាមទិសដៅរបស់គម្រោងកោះកេរក្នុងការបង្កើតប្លង់មេដែលកំណត់វិធានការនិងសកម្មភាពសម្រាប់ការធ្វើអាជីវកម្មក្នុងតំបន់កោះកេរប្រកបដោយចិរភាពនោះ នៅពេលចាប់ផ្តើមគម្រោង ផ្នែកសហគមន៍យកចិត្តទុកដាក់ជាសំខាន់លើការស្វែងយល់អំពីបរិបទសង្គមសេដ្ឋកិច្ច ដើម្បីអាចបង្កើតកម្មវិធីរបស់ខ្លួន។ ការជួបសន្ទនាត្រូវបានដឹកនាំធ្វើជាមួយអ្នកស្រុក ដើម្បីវាយតម្លៃអំពីស្ថានភាពផ្នែកសង្គមសុខាភិបាល កសិកម្មនិងសេដ្ឋកិច្ច។ ការសិក្សាបឋមមួយស្តីពីសេចក្តីសន្និដ្ឋានទាំងនេះមាននៅក្នុងរបាយការណ៍នេះ។

ម៉ាស៊ីនមេអ៊ីនធឺណែតមួយត្រូវបានរៀបចំឡើងដើម្បីអោយសមាជិករបស់គម្រោងប្រើ។ ម៉ាស៊ីនមេនោះមានច្រើនភាសានិងអាចបង្កើតគណនេយ្យផ្ទាល់ផ្ទាល់ខ្លួនបាន។ មូលដ្ឋានទិន្នន័យមួយក៏ត្រូវបានបញ្ចូលទៅក្នុងម៉ាស៊ីនមេនោះដោយមានលក្ខខណ្ឌ SIG។ គេអាចចូលទៅកាន់ម៉ាស៊ីនមេបានតាមរយៈអាសយដ្ឋានរបស់គេហទំព័រ។ ម៉ាស៊ីនមេនោះមានសុវត្ថិភាពខ្ពស់និងមានច្រើនភាសា។ នៅក្នុងម៉ាស៊ីនមេនោះ គេអាចសរសេរជាភាសាខ្មែរ ភាសាសំស្ក្រឹតនិងភាសាទំនើបផ្សេងៗទៀត។ សកម្មភាពផ្សេងៗទៀតរបស់គម្រោងដែលបានអនុវត្តនៅនិទាឃៈរដូវឆ្នាំ២០០៩ ត្រូវបានរៀបរាប់ជូននៅក្នុងរបាយការណ៍។

នៅទីនេះ ខ្ញុំចង់បន្ថែមពាក្យពេចន៍ខ្លះស្តីពីបញ្ហាប្រឈមនៅឆ្នាំក្រោយ។ ដូចដែលយើងសង្កេតឃើញនៅពេលបច្ចុប្បន្ននេះ ការកំណត់និងការភ្ជាប់តំបន់កោះកេរទៅនឹងព្រះរាជវិថីនិងស្ទឹងគឺជាប្រធានបទដែលអាចឈានទៅកំណត់បណ្តាញថ្មីមួយនៃរមណីយដ្ឋាននានា ហើយកោះកេរស្ថិតនៅក្នុងបណ្តាញនេះទាំងស្រុង។ បញ្ហាមួយទៀតគឺការដោះមីន។ ការសម្រេចគួរតែត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីធានាដល់ការអភិរក្សប្រាង្គប្រាសាទនានា ព្រមទាំងធម្មជាតិនិងសហគមន៍ដែលរស់នៅជុំវិញរមណីយដ្ឋានដ៏អស្ចារ្យនេះ។

កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់យើងមានការរីកចម្រើនជាប់ជាប្រចាំ៖ ពិធីសារនៃកិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខាជាមួយសាលាបារាំងចុងបូព៌ាប្រទេស (EFEO) សាកលវិទ្យាល័យ Waseda មជ្ឈមណ្ឌលអភិរក្សអន្តរជាតិ Raymond Lemaire និងនាយកដ្ឋានបេតិកភណ្ឌនិងការអភិរក្សប្រទេសហុងគ្រី។ យើងធ្វើការដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអ្នកជំនាញរបស់សាកលវិទ្យាល័យ Sydney។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកជំនាញគ្រប់រូបដែលបានចែករំលែកប្រកបដោយចិត្តទូលំទូលាយ នូវចំណេះដឹងដ៏ច្រើនរបស់ខ្លួននៅក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** សូមអរគុណលោកបណ្ឌិត Jelen។ ខ្ញុំសូមរំឭកថា ក្រុមការងារ

ប្រទេសហុងគ្រីគឺជាក្រុមការងារដែលទើបមកដល់ថ្មីដើម្បីធ្វើការសិក្សាអំពីខ្មែរ ជាពិសេសនោះគឺនៅអង្គរនិងកោះកេរ ហើយយើងសូមជូនពរអោយការងាររបស់លោកកោះកេរបន្តយូរទៅមុខទៀត។ បន្ទាប់ពីមានវត្តមានអស់រយៈពេលមួយឆ្នាំមក RAF ក្លាយជាសមាជិកនៃគ្រួសារ CIC ទៅហើយ។
បទបង្ហាញចុងក្រោយ គឺជាបទបង្ហាញរបស់សាលាបារាំងចុងបូព៌ាប្រទេស ដែលតែងតែចាប់អារម្មណ៍ពង្សាវលីមែកធាងគ្រួសារព្រះមហាក្សត្រខ្មែរ។ ដូច្នេះ សូមអញ្ជើញលោក Pottier! តើលោកមានអ្វីថ្មីដែលត្រូវនិយាយប្រាប់យើងដោយសង្ខេបទេ?

## IV.5 ទិន្នន័យថ្មីៗស្តីពីប្រភពនៃរាជាធិបតេយ្យនៅអង្គរ ដោយបណ្ឌិត Christophe Pottier វិស្វករ សាលាបារាំងចុងបូព៌ាប្រទេស (EFEO) ប្រទេសបារាំង

សូមគោរព ឯកឧត្តម លោក លោកស្រី ជាទីគោរព!

កាលពី១០ឆ្នាំមុន មិនមែនជាអ្វីដែលថ្មីនោះទេ នៅក្នុងសាលប្រជុំដដែលនេះ ខ្ញុំបានធ្វើរបាយការណ៍ជូនលោក លោកស្រី រួចមកហើយអំពីការបញ្ចប់ការងារជួសជុលដែលបានចាប់ផ្តើមនៅឆ្នាំ១៩៩៣ នៅលើទីលានប្រាសាទដែលជាព្រះរាជវាំង ហើយក្នុងពេលជាមួយគ្នានោះ ក៏មានការបញ្ចប់ការធ្វើផែនទីបុរាណវិទ្យាដំណាក់កាលទីមួយនៃតំបន់អង្គរ ដែលចាប់ពីពេលនោះមក កិច្ចសហការមួយរវាងអាជ្ញាធរអប្សរានិងសាកលវិទ្យាល័យ Sydney ត្រូវបានអភិវឌ្ឍន៍នៅក្នុងក្របខណ្ឌរបស់គណៈកម្មាធិការ Angkor Project។ ខ្ញុំត្រូវនិយាយយឺតៗបន្តិច។

អញ្ចឹង កាលពីដប់ឆ្នាំមុន យើងបានចាប់ផ្តើមគម្រោងបុរាណវិទ្យាមួយដែលផ្តោតពិសេសទៅលើការសិក្សាអំពីរាជធានីអង្គរដំបូងៗ។ ខ្ញុំមានឱកាសធ្លាប់បានបង្ហាញជូនអង្គប្រជុំជាច្រើនលើកនូវការរីកចម្រើននៃកិច្ចការស្រាវជ្រាវនេះ ដែលខ្ញុំសូមបញ្ជាក់និងរំឭកឡើងវិញដោយរីករាយថា កិច្ចការស្រាវជ្រាវនេះត្រូវបានគាំទ្រជានិច្ចកាលដោយហិរញ្ញប្បទានរបស់ក្រសួងការបរទេសបារាំង។

ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃនេះខ្ញុំគ្រាន់តែទាញការចាប់អារម្មណ៍លើលទ្ធផលថ្មីៗមួយចំនួន ដែលមានទំនាក់ទំនងផ្ទាល់ជាមួយទស្សនៈរបស់យើងស្តីពីប្រភពនៃរាជាធិបតេយ្យនៅអង្គរ។
ដូច្នេះ សម្រាប់ការងាររយៈពេលចំនួនដប់ឆ្នាំដែលត្រូវនិយាយក្នុងរយៈពេលចំនួនប្រាំនាទី ខ្ញុំនឹងសាកល្បងនិយាយឲ្យខ្លីនិងច្បាស់លាស់។

[ស្លាយ] ដើម្បីឲ្យច្បាស់លាស់ ខ្ញុំសូមបង្ហាញតារាងសង្ខេបតូចមួយនៃកាលប្បវត្តិដែលត្រូវបានគេឯកភាពទាំងស្រុង ហើយដែលនៅផ្នែកខាងក្រោមនៃតារាងនេះ លោក លោកស្រី ឃើញមានឈ្មោះក្សត្របន្តបន្ទាប់ដែលមិនបានគ្រងរាជ្យជាប់គ្នាជាហូរហែមកនោះទេ។ ម្យ៉ាងទៀត ក្សត្រមួយចំនួននៅជាកម្មវត្ថុនៃការពិភាក្សានៅឡើយ។ ពណ៌ខៀវបង្ហាញអំពីរចនាបថសិល្បៈដែលមានលក្ខណៈមិនច្បាស់លាស់ ហើយកាលបរិច្ឆេទមួយចំនួនដែលលោក លោកស្រីឃើញនៅត្រង់នេះ និងត្រង់នោះ មិនប្រែប្រួលទេ ជាកាលបរិច្ឆេទកំណត់អំពីព្រឹត្តិការណ៍សំខាន់ៗនៅដើមសម័យអង្គរ មានជាអាទិ៍ កាលបរិច្ឆេទឆ្នាំ៨០២ ជាឆ្នាំឡើងគ្រងរាជ្យរបស់ព្រះបាទជ័យវរ្ម័នទីII។

អ្វីដែលខ្ញុំចង់លើកយកមកនិយាយនៅថ្ងៃនេះ គឺខ្ញុំចង់អោយលោក លោកស្រីប្រៀបធៀបបន្តិចរវាងទស្សនៈនេះ

ជាមួយទិន្នន័យដែលទទួលបានតាមរយៈកំណាយបុរាណវិទ្យា នៅក្នុងយុទ្ធនាការកំណាយបុរាណវិទ្យារយៈពេលដប់ឆ្នាំនេះជាអាទិ៍តាមរយៈលទ្ធផលនៃការកំណត់កាលបរិច្ឆេទជាបន្តបន្ទាប់ដោយប្រើកាំរស្មី ដែលមានលក្ខណៈពេញលេញជាងការកំណត់កាលបរិច្ឆេទនាពេលបច្ចុប្បន្ននេះ។

ខ្ញុំសូមរំឭកយ៉ាងខ្លីថា នៅក្នុងរយៈពេលដប់ឆ្នាំ យើងបានធ្វើកំណាយលើរមណីយដ្ឋានប្រមាណជាងដប់កន្លែង ក្នុងតំបន់ចំនួនពីរ។ តំបន់ទីមួយស្ថិតនៅជិតបារាយខាងលិច ហើយតំបន់ទីពីរស្ថិតនៅរលួសដែលជាអតីតរាជធានីហរិហរៈ។

[ស្លាយ] ខ្ញុំនឹងចាប់ផ្តើមនិយាយអំពីរាជធានីហរិហរៈដែលតាមពិតមានគេស្គាល់ច្រើន ហើយដែលស្ថិតនៅម្តុំប្រាសាទបាគង នៅចម្ងាយប្រមាណជាងដប់គីឡូម៉ែត្រ ប៉ែកអាគ្នេយ៍នៃក្រុងសៀមរាប។

យើងនឹងសាកល្បងត្រឡប់ថយទៅអតីតកាលវិញ។ ប៉ុន្តែ សូមចាប់ផ្តើមមើលពីប្រាសាទបាគងដែលជាប្រាសាទមានគេស្គាល់តាមរយៈអក្សរចារឹក។ ចាប់តាំងពីទសវត្សឆ្នាំ៣០ ឬទសវត្សឆ្នាំ២០ បាគងគឺជាប្រាសាទមួយដែលត្រូវបានគេកំណត់កាលបរិច្ឆេទច្បាស់លាស់ កសាងដោយព្រះបាទឥន្ទ្រវរ្ម័ន និងសម្ពោធនៅឆ្នាំ៨៨១។ តាមពិតទៅ ដូចដែលខ្ញុំបានបង្ហាញនៅទីនេះរួចហើយ ការស្ទាបស្ទង់ផ្សេងៗដែលបានធ្វើពីឆ្នាំ២០០៤ដល់ឆ្នាំ២០០៦ នៅក្នុងរមណីយដ្ឋានទាំងមូល ជាពិសេសនោះ គឺនៅក្នុងបរិវេណដ៏ធំរបស់ប្រាសាទរាងការ៉េ ដែលមួយជ្រុងៗមានប្រវែង១គីឡូម៉ែត្រ បានបង្ហាញអំពីការរស់នៅរបស់អ្នកស្រុកដែលមានដង់ស៊ីតេទាប នេះបញ្ជាក់ថា បរិវេណនោះមិនមែនជាទីក្រុងទេ។ ប៉ុន្តែបើត្រឡប់មកនិយាយអំពីកាលប្រវត្តិវិញនោះ យើងឃើញច្បាស់ណាស់ថា តួប្រាសាទមិនមែនត្រូវបានកសាងនៅឆ្នាំ៨៨១ដូចដែលបានកំណត់កាលពីមុននោះទេ ប៉ុន្តែយ៉ាងហោចណាស់ក៏មួយសតវត្ស ឬមួយសតវត្សកន្លះមុននោះផង។ ដូច្នេះ ប្រហែលជានៅកាលបរិច្ឆេទណាមួយក្នុងពាក់កណ្តាលទីពីរនៃសតវត្សទី៨ មុនការមកដល់ក្នុងតំបន់របស់មហាក្សត្រជ័យវរ្ម័នទីII ទៅទៀត។

[ស្លាយ] ប្រសិនបើយើងត្រឡប់ថយទៅអតីតកាលបន្តិចទៀត ហើយដែលជាការភ្ញាក់ផ្អើលបន្តិចនោះ គឺយើងក៏ត្រូវស្វែងរកព្រះរាជវាំងនៅរលួសផងដែរ។ ដូច្នេះ ខ្ញុំនឹងមិនត្រឡប់មកនិយាយអំពីរឿងនេះទេ ប៉ុន្តែរមណីយដ្ឋានដែលស័ក្តិសមនិងបំផុតល្អនោះ គឺរមណីយដ្ឋានព្រៃមន្ទីរដែលនៅទីនោះយើងបានរកឃើញរចនាសម្ព័ន្ធផ្សេងៗ ស្លាកស្នាមផ្នែកស្ថាបត្យកម្ម ការរៀបចំ ទីធ្លា ប្រព័ន្ធបង្ហូរទឹក រោងទង ទីលានប្រាសាទជាដើម។ល។និង។ល។ ហើយយើងក៏បានរកឃើញផងដែរនូវវត្ថុបុរាណដែលពិតជាមានលក្ខណៈពិសេស ហើយជាពិសេសនោះគឺវត្ថុដែលនាំចូលពីប្រទេសចិននិងពីមជ្ឈិមបូព៌ាប្រទេសសម្រាប់អ្នកជាន់ខ្ពស់ប្រើ នេះបញ្ជាក់ថាមានរាជវាំងមួយនៅតំបន់នោះ។ អ្វីដែលគួរឲ្យភ្ញាក់ផ្អើលជាងនេះទៅទៀតនោះ គឺកាលបរិច្ឆេទដែលយើងទទួលបានបន្ទាប់ពីការធ្វើកោសលវិច័យរួច។ តាមពិតទៅ គឺនៅមុនការសាងសង់ប្រាសាទបាគងទៅទៀត។ ដូច្នេះ ដូចលោកស្រី ឃើញនៅលើក្រាហ្វិកនេះស្រាប់ប្រហែលជានៅម្តុំឆ្នាំ៧០០ ឬអាចមុននេះបន្តិចទៀតផង។

[ស្លាយ] រមណីយដ្ឋានមួយទៀតអាចឲ្យយើងត្រឡប់ថយទៅអតីតកាលកាន់តែឆ្ងាយ នោះគឺរមណីយដ្ឋានត្រពាំងផុងដែលស្ថិតនៅជិតតំបន់លិចទឹក ខាងត្បូងតំបន់រលួស។ វាជារមណីយដ្ឋានដែលត្រូវបានគេស្គាល់ដោយសារស្លាកស្នាមស្ថាបត្យកម្ម ប៉ុន្តែកំណាយបុរាណវិទ្យាបានបង្ហាញអោយឃើញថា រមណីយដ្ឋាននេះត្រូវបានស្ថាបនាឡើងតាំងពីពេលដំបូងៗនៃឥណ្ឌាតូបនីយកម្មម្ល៉េះ។ យើងអាចនិយាយបានថា យ៉ាងហោចណាស់គឺនៅពេលមាន

ការលេចឡើងនូវវិហារព្រាហ្មណ៍សាសនាដំបូងៗនៅក្នុងតំបន់ ហើយដែលចាប់ពីពេលនេះតទៅ របកគំហើញទាំងនេះអាចឲ្យយើងចាត់ទុករមណីយដ្ឋានត្រពាំងផុងថា ប្រហែលជារមណីយដ្ឋានដើមដែលបានផ្តល់ឈ្មោះរបស់ខ្លួនដល់រាជធានីហរិហរៈ ដោយហេតុថា (មិនមែនខ្ញុំទេដែលគួររំឭកអំពីរឿងនេះនៅក្នុងកិច្ចប្រជុំនេះ នៅចំពោះមុខសាស្ត្រាចារ្យនិងអក្សរចារឹកវិទូនានា ដូចជាលោកសាស្ត្រាចារ្យ Claude Jacques ជាដើម) ហរិហរៈគ្រាន់តែមានន័យថាជាដំណាក់របស់អាទិទេព ហរិហរៈប៉ុណ្ណោះ។ ប៉ុន្តែតាមការពិត គឺពិតជានៅត្រពាំងផុងនេះឯងដែលយើងបានរកឃើញបដិមាករដ៏កម្រនៃអាទិទេពនេះ ដែលមានតែនៅក្នុងតំបន់អង្គរ។ ដូច្នេះ យើងប្រហែលជាមានភស្តុតាងដ៏ខ្លឹមនៃការចាប់កំណើតរាជធានីហរិហរៈដំបូង។

[ស្លាយ] ភស្តុតាងសំខាន់មួយទៀតដែលនាំឲ្យយើងត្រឡប់ថយក្រោយ រហូតទៅដល់ពេលដំបូងនៃការកសាងវិហារព្រាហ្មណ៍សាសនានៅក្នុងតំបន់អង្គរ ត្រូវបានផ្តល់ឲ្យយើងតាមរយៈការសិក្សាលើរមណីយដ្ឋានព្រៃក្មេង ដែលត្រូវបានគេស្គាល់យ៉ាងច្បាស់តាមរយៈផ្តែរមួយ ដែលបានផ្តល់ឈ្មោះរបស់ខ្លួនដល់រចនាបថមួយដែលមានកាលបរិច្ឆេទមិនច្បាស់លាស់។ ប៉ុន្តែនៅកន្លែងនោះ យើងបានរកឃើញស្លាកស្នាមនៃការតាំងទីរស់នៅជាហូរហែតាំងពីមុនសម័យអង្គរ ឬតាំងពីសម័យបុរេប្រវត្តិ រហូតដល់សតវត្សទីមួយមុនគ្រឹះសករាជ។ ហើយវិហារព្រាហ្មណ៍សាសនាចាប់មាននៅអំឡុងឆ្នាំ៥០០ ចន្លោះឆ្នាំ៥០០ និង ៦០០ គឺចាប់ពីសតវត្សទីVI មក។ នោះជាកាលបរិច្ឆេទនៃការចាប់ផ្តើមមានវិហារព្រាហ្មណ៍សាសនាក្នុងតំបន់អង្គរ។

[ស្លាយ] លើសពីនេះទៀត លោក លោកស្រី ពិតប្រហែលជានៅចាំផងដែរថា មានរបកគំហើញដ៏អស្ចារ្យមួយចំនួនជាពិសេសគឺនៅរមណីយដ្ឋានកោះតាមាសដែលស្ថិតនៅចំកណ្តាលបារាយខាងលិច ហើយដែលជាធម្មតាគឺស្ថិតនៅជម្រៅ២ម៉ែត្រក្រោមទឹក។ កំណាយនៅកន្លែងនោះបានបង្ហាញកន្លែងកប់ខ្មោចបុរាណមួយនៅយុគសំរឹទ្ធ និងបាននាំយើងទៅដល់ទីកន្លែងបុរេប្រវត្តិមួយដែលកកើតស្ទើរតែ៤០០០ឆ្នាំមុន។ នេះគឺពិតជាបង្ហាញអំពីការតាំងទីយ៉ាងយូររបស់មនុស្សនៅក្នុងតំបន់អង្គរ។

[ស្លាយ] ដូច្នេះ ខ្ញុំមិនអាចបញ្ចប់របាយការណ៍សង្ខេបនេះដោយមិននិយាយអំពីប្រាសាទមួយដ៏សំខាន់បានទេ។ វាពិតជាសំខាន់ទាក់ទងនឹងការចាប់បដិសន្ធិរបបក្សត្រនៅក្នុងតំបន់អង្គរ នោះគឺប្រាសាទអកយំ ដែលទម្រង់ពីរ៉ាមីតរបស់ប្រាសាទនេះបង្ហាញអំពីលក្ខណៈដ៏ពិសេសរបស់វាស្រេចទៅហើយ។

ខ្ញុំសូមរំឭកថា ប្រាសាទអកយំដែលបានប្រទះឃើញដោយចៃដន្យនៅឆ្នាំ១៩៣២ គឺជាពីរ៉ាមីតដែលគ្រឹះមួយជ្រុងៗមានប្រវែង១០០ម៉ែត្រ ហើយដែលនៅសតវត្សទីXI ត្រូវបានកប់បាត់ភាគច្រើន ឬទាំងស្រុងទៀតផងនៅក្រោមទំនប់ខាងត្បូងនៃបារាយខាងលិច។ បច្ចុប្បន្ន ភាគច្រើននៃរូបរាងប្រាសាទ គេមើលមិនឃើញឡើយ។

[ស្លាយ] កំណាយដែលបានធ្វើនៅឆ្នាំ២០០១ អាចឲ្យយើងប្រមូលវត្ថុសម្រង់ផ្សេងៗយកទៅស្រាវជ្រាវរកកាលបរិច្ឆេទរបស់ប្រាសាទអកយំឡើងវិញ ហើយយើងក៏បានដឹងថា ប្រាសាទនេះត្រូវបានសង់ឡើងម្តុំឆ្នាំ៦០០ គឺនៅដើមដំបូងនៃសតវត្សទីVII ឬអាចមុននេះបន្តិចផង។ ដូច្នេះ ចំណុចនេះបង្ហាញអំពីវត្តមានអំណាចដ៏សំខាន់មួយនៅក្នុងតំបន់អង្គរចាប់តាំងពីមានវត្តមានព្រះមហាក្សត្រនៅអង្គរដំបូង ដែលគេស្គាល់ប្រវត្តិមិនច្បាស់ឡើយ។

ជាកិច្ចបញ្ចប់របាយការណ៍សង្ខេបនេះ យើងអាចសន្និដ្ឋានបានអំពីរយៈពេលខ្លីដែលវិវត្តពីការកសាងប្រាសាទព្រាហ្មណ៍សាសនាដំបូងៗនៅក្នុងតំបន់អង្គរទៅរកការកសាងប្រាសាទរាងពីរ៉ាមីតដែលតំណាងអោយអំណាច

កំពូល។

ម្យ៉ាងទៀត យើងអាចកត់សម្គាល់អំពីចំណាស់អាយុកាលពីរ៉ាមីតនិងរាជវាំងនៅក្នុងតំបន់អង្គរ ជាអាទិ៍នៅហារិហារៈ។ នេះគឺពិតជាអ្វីដែលគួសបញ្ជាក់អំពីសារៈសំខាន់នៃសតវត្សដំបូងៗ ជាអាទិ៍គឺសតវត្សទីVII និងសតវត្សទីVIII ដោយមិនចាំបាច់និយាយដល់សតវត្សទីIX នៅក្នុងប្រវត្តិសាស្ត្រអង្គរផង ពោលគឺនៅអង្គរនេះតែម្តង និងដោយមិនភ្លេចអ្វីដែលកើតមាននៅកន្លែងផ្សេងទៀតក្នុងប្រទេសកម្ពុជានិងក្នុងប្រទេសខ្មែរទេ។
ដូច្នេះ នៅទីបញ្ចប់ បន្ទាប់ពីបំពេញការងារនៅនឹងកន្លែងអស់រយៈពេល១០ឆ្នាំមក ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់អំពីការចំអកនៃជោគវាសនាដែលធ្វើឲ្យយើងរកឃើញដោយចៃដន្យនូវសិលាចារឹកថ្មីមួយ ដែលហាក់ដូចជាបញ្ជាក់យ៉ាងច្បាស់អំពីបុរាណកាលដ៏វែងឆ្ងាយនៃប្រវត្តិរបស់អង្គរ។

[ស្លាយ] តាមការពិតទៅ វាមិនមានអ្វីគួរអោយភ្ញាក់ផ្អើលទេ ហើយរឹតតែមិនមែនជាភាពចៃដន្យទៅទៀតដែលសិលាចារឹកនេះ គួរឲ្យសោកស្តាយមិនមានកាលបរិច្ឆេទទេ ប៉ុន្តែយើងអាចប៉ាន់ស្មាននិងកំណត់កាលបរិច្ឆេទរបស់វានៅសតវត្សទីVII ហើយប្រហែលជាសិលាចារឹកដ៏ចំណាស់ជាងគេដែលមិនធ្លាប់ឃើញពីមុនទាល់តែសោះនៅក្នុងតំបន់អង្គរ។ ហើយវាចៃដន្យទៅទៀត សិលាចារឹកនេះមិនត្រឹមតែត្រូវបានរកឃើញនៅក្នុងតំបន់រលួសប៉ុណ្ណោះទេ ប៉ុន្តែគឺនៅប្រាសាទបាគងផ្ទាល់តែម្តង ដោយគេបានប្រើប្រាស់ឡើងវិញ។

ដូច្នេះ រយៈពេលដប់ឆ្នាំហើយ នៅទីបំផុត យើងអាចបញ្ជាក់បានតាមរយៈរបកគំហើញដ៏ចៃដន្យមួយ។

ខ្ញុំសូមអរគុណលោក លោកស្រី យ៉ាងជ្រាលជ្រៅ ដោយសូមរំឭកថា នេះគឺពិតជាការងារជាក្រុមដែលតម្រូវអោយយើងខិតខំប្រឹងប្រែងយ៉ាងខ្លាំង។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** អរគុណច្រើនលោក Pottier។ ការស្គាល់ពេលអនាគតអោយបានច្បាស់ក៏មានការលំបាកដូចជាការស្គាល់ពេលអតីតកាលដែរ។ យើងនឹងត្រូវទៅទស្សនាសារមន្ទីរកុលាលភាជន៍តានីនាពេលបន្តិចទៀតនេះ។ ដូច្នេះ ខ្ញុំសូមស្នើដល់លោក លោកស្រី ឲ្យផ្តល់វេទិកាជូនអ្នកជំនាញ អាដ ហុក ខាងការអភិរក្សរបស់យើងភ្លាម ហើយយើងនឹងសួររាល់សំណួរទាំងឡាយណាដែលយើងពេញចិត្តនឹងសួរ បន្ទាប់ពីបទបង្ហាញចុងក្រោយនាពេលព្រឹកនេះ។
ដូច្នេះ សូមអញ្ជើញលោកសាស្ត្រាចារ្យ Bouchenaki, Croci, Lablaude និងលោកសាស្ត្រាចារ្យ Hidaka ឡើងមានប្រសាសន៍។

## IV.6 របាយការណ៍របស់ក្រុមអ្នកជំនាញ អាដ ហុក សម្រាប់ការអភិរក្ស ដោយលោកសាស្ត្រាចារ្យ Mounir Bouchenaki, Giorgio Croci , Pierre-André Lablaude និង Kenichiro Hidaka

**លោក** Bouchenaki **៖**

សូមអរគុណលោកប្រធាន។ របាយការណ៍នេះធ្វើឡើងក្នុងនាមក្រុមអ្នកជំនាញនៅរមណីយដ្ឋានចំនួនពីរ៖ គឺ

កំណាយបុរាណវិទ្យានៅស្រះស្រង់និងការងារលើកតម្លៃស្រះស្រង់ និងកំណាយនៅព្រៃមន្ទីរដែលត្រូវបានធ្វើដោយលោក Christophe Pottier នៅក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយអប្សរា។

ការដ្ឋានទីមួយគឺការដ្ឋានស្រះស្រង់ដែលយើងបានចុះទៅមើលតាំងពីថ្ងៃមកដល់ដំបូងទី១២ធ្នូ។ ការដ្ឋាននេះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ឯកឧត្តម យួន យុន នាយ ជាអគ្គនាយករងទទួលបន្ទុកនាយកដ្ឋានរៀបចំដែនដីនិងការគ្រប់គ្រងលំនៅឋាននៅក្នុងឧទ្យានអង្គររបស់អាជ្ញាធរអប្សរា។

អ្នកទទួលខុសត្រូវជាច្រើនរូបរបស់គណៈកម្មាធិការអនុវត្តន៍គម្រោងលើកតម្លៃស្រះស្រង់នេះ បានចូលរួមក្នុងការទស្សនា ហើយនៅនឹងកន្លែង យើងមានកិច្ចពិភាក្សាដ៏គួរឲ្យចាប់អារម្មណ៍បំផុតស្តីពីគម្រោងនេះ។

- ជាមួយអ្នកស្រី ចៅ ស៊ុន កិរិយា ដែលជានាយិកានាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរនិងបទដ្ឋានបេតិកភណ្ឌ
- ឯកឧត្តម រស់ បូរ៉ាត់ ជាទីប្រឹក្សារបស់ឧបនាយករដ្ឋមន្ត្រី ឯកឧត្តម សុខ អាន និងប្រធានគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក
- ឯកឧត្តម ហង់ ពៅ អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងទឹក។

លើសពីនេះទៅទៀតនោះ បុរាណវិទូខ្មែរជាច្រើនរូបព្រមទាំងលោក Éric Llopis ក៏មានវត្តមានផងដែរ។ ពួកគេបានចូលរួមក្នុងការបង្ហាញអំពីកំណាយនិងកិច្ចពិភាក្សាដែលធ្វើឡើងបន្ទាប់ពីការចុះពិនិត្យកំណាយ។ ការងារកំណាយបានចាប់ធ្វើតាំងពីរដូវប្រាំងឆ្នាំ២០០៩ នៅក្នុងក្របខណ្ឌនៃគម្រោងធំស្តីពីការអភិរក្សនិងការលើកតម្លៃស្រះស្រង់ដែលទទួលហិរញ្ញប្បទានពីក្រុមហ៊ុន Jet Tours តាមរយៈមជ្ឈមណ្ឌលបេតិកភណ្ឌពិភពលោករបស់យូណេស្កូ។

ម្យ៉ាង គម្រោងនឹងធ្វើការវិភាគអំពីរចនាសម្ព័ន្ធបុរាណវិទ្យា ដែលស្ថិតនៅចន្លោះកំពែងប្រាសាទនិងផ្លូវចូលរបស់ប្រាសាទបន្ទាយក្តីនិងកំពង់ទឹកស្រះស្រង់។ ហើយម្យ៉ាងទៀត គឺការរៀបចំឡើងវិញនូវទីកន្លែងដែលមានឈ្មោះថា "ទីលាន" ដែលមានទីធ្លាខាងជើងនិងទីធ្លាខាងត្បូងស្រះស្រង់បច្ចុប្បន្ន។

រណ្តៅកំណាយខាងជើងឆៀងខាងត្បូង និង ខាងកើតឆៀងខាងលិច ដែលស្ថិតនៅជិតកំពង់ទឹកបានផ្តល់រួចហើយនូវព័ត៌មានដ៏មានតម្លៃស្តីពីដំណាក់កាលនៃការលើកទំនប់ស្រះស្រង់ និងស្តីពីការវិវត្តរបស់ទំនប់នេះ នៅចន្លោះសតវត្សទីX និងសតវត្សទីXII។

ការសិក្សាអំពីស្រទាប់ដីមានភាពច្បាស់លាស់និងមានឯកសារគាំទ្រគ្រប់គ្រាន់ នឹងជួយអោយគេស្គាល់អំពីប្រវត្តិនៃការសាងសង់កំពង់ទឹក អំពីកន្លែងនៅម្តុំកំពង់ទឹកនោះ និងជួយអោយការងារលើកតម្លៃរមណីយដ្ឋានស្រះស្រង់មានលក្ខណៈងាយស្រួល។ គម្រោងនឹងធ្វើការបិទកំណាត់ផ្លូវបច្ចុប្បន្នដែលស្ថិតនៅចន្លោះប្រាសាទបន្ទាយក្តីនិងស្រះស្រង់ ហើយកំណាយនឹងជួយអោយគេទទួលបានរាល់ព័ត៌មានសំខាន់ៗ ដែលសម្រួលដល់ការរៀបចំទីលានមុខស្រះស្រង់។

អ្នកជំនាញបានកត់ត្រាទុកអំពីឆន្ទៈរបស់អាជ្ញាធរជាតិអប្សរា ដែលចាត់ទុកការជីករណ្តៅធ្វើកំណាយបុរាណវិទ្យានេះទៅក្នុងទិសដៅមួយនៃការអនុវត្តគម្រោងធំ ក្នុងគោលបំណងការពារនិងលើកតម្លៃតំបន់ទាំងមូលដែលស្ថិតនៅជុំវិញស្រះស្រង់ រួមមានទាំងការគ្រប់គ្រងធនធានទឹកអោយបានយូរអង្វែង និងការលើកតម្លៃដីកសិកម្មផងដែរ។

គម្រោងនេះពិតជាឆ្លើយតបទៅនឹងយុទ្ធសាស្ត្រនៃវិធីសាស្ត្ររួម ដូចដែលត្រូវបានផ្តល់អនុសាសន៍ដោយស្ថាប័នអន្តរជាតិធំៗមានជាអាទិ៍ កតិកាសញ្ញារបស់អង្គការ ICOMOS ព្រមទាំងអនុសាសន៍របស់អង្គការយូណេស្កូជាដើម។

ដូច្នេះ គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនឹងត្រូវតាមដានដោយយកចិត្តទុកដាក់ នូវដំណាក់កាលនីមួយៗនៃកិច្ចប្រតិបត្តិការដែលធានាដល់ការអភិរក្សតំបន់ការពារ ដោយធ្វើអោយប្រជាជនទាំងបីភូមិនៅម្តុំស្រះស្រង់ចូលរួមយ៉ាងស្អិតល្មួត។

នៅក្នុងពេលជាមួយគ្នានេះ អ្នកជំនាញបានសំគាល់ឃើញថា កិច្ចប្រតិបត្តិការស្រាវជ្រាវផ្នែកបុរាណវិទ្យា ដែលបន្ទាប់មកមានការជួសជុលកំពង់ទឹក នឹងមានទាំងកិច្ចប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គម ដើម្បីជាប្រយោជន៍របស់ប្រជាជនក្នុងភូមិទាំងបីនេះ ដោយគិតដល់ដល់ការធ្វើគម្រោងទេសចរណ៍ប្រកបដោយចីរភាព។ ម្យ៉ាងទៀត ការបង្កើតភូមិថ្មីមួយហៅថា "ភូមិធម្មជាតិ" ដែលមានផ្ទៃដីចំនួន១០០០ហិចតាស្ថិតនៅខាងក្រៅឧទ្យានអង្គរ នឹងអាចឆ្លើយតបទៅនឹងសេចក្តីព្រួយបារម្ភដែលចង់រក្សាអោយប្រជាជននៅក្នុងតំបន់ការពារមានចំនួនថេរ និងជៀសវាងការរីកសុះសាយជាយថាហេតុនូវសំណង់លំនៅឋានថ្មីដោយគ្មានការត្រួតពិនិត្យ ដោយសារកំណើនធម្មតានៃចំនួនប្រជាជននៅក្នុងភូមិ។

ត្រង់ចំណុចនេះ ខ្ញុំចង់លើកឡើងអំពីបញ្ហាមួយដែលចោទឡើងនៅតាមរមណីយដ្ឋានបុរាណវិទ្យាជាច្រើននៅក្នុងពិភពលោកដែលមានលំនៅឋានអ្នកស្រុក។ ហេតុដូច្នេះ កិច្ចប្រតិបត្តិការនេះអាចជាការងារមួយដ៏គួរឲ្យចាប់អារម្មណ៍ ព្រោះគេអាចចាត់ទុកថាជាប្រតិបត្តិការសាកល្បងមួយ ហើយគេអាចយកបទពិសោធន៍ទៅអនុវត្តនៅក្នុងការគ្រប់គ្រងនិងការការពាររមណីយដ្ឋានដែលស្ថិតនៅតាមតំបន់ដទៃទៀតក្នុងពិភពលោក។

ដូច្នេះ អ្នកជំនាញបានចាត់ទុកថា វិធីសាស្រ្តរួមនៅក្នុងក្របខណ្ឌនៃគម្រោងរៀបចំស្រះស្រង់និងតំបន់ជុំវិញអាចធ្វើជាគំរូនៅក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកដទៃទៀត ដែលមានមនុស្សរស់នៅ។ វិធីសាស្រ្តដែលមានការចូលរួមពីអ្នកស្រុក យើងបានស្តាប់ដោយយកចិត្តទុកដាក់បំផុតនូវបទបង្ហាញរបស់សហសេវិកយើងមកពីសាកលវិទ្យាល័យ Sydney និងជាវិធីសាស្រ្តដែលអប្បរាយកមកអនុវត្ត គឺធ្វើឲ្យសហគមន៍ក្នុងស្រុកចូលរួមក្នុងសកម្មភាពការពារនិងអភិវឌ្ឍផ្សេងៗ មានជាអាទិ៍ការកែលម្អសិប្បកម្ម ការចូលរួមនៅក្នុងការលើកតម្លៃធនធានធម្មជាតិ ការរៀបចំបង្កើតគម្រោងអេកូទេសចរណ៍ ដែលទាំងនេះគ្រាន់តែជាឧទាហរណ៍ខ្លះៗប៉ុណ្ណោះ។ វិធីសាស្រ្តនេះមិនត្រឹមតែត្រូវបានគេកោតសរសើរយ៉ាងខ្លាំងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវបានគេលើកទឹកចិត្ត ជំរុញអោយយកមកអនុវត្តទៀតផង។

ដូច្នេះ អ្នកជំនាញសូមផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖

១.បន្តការងារកំណាយបុរាណវិទ្យា ដោយគិតដល់លទ្ធផលស្រាវជ្រាវដែលធ្វើរួចកាលពីពេលមុនៗ មានជាអាទិ៍នៅក្នុងបណ្តាឆ្នាំ៦០ ដោយលោក Groslier។

២.បន្តសិក្សាអំពីសម្ភារៈនានាដែលរកឃើញ មានជាអាទិ៍កុលាលភាជន៍ ដើម្បីកំណត់កាលប្បវត្តិឲ្យបានច្បាស់ជាងមុន។

៣.បង្កើតមូលដ្ឋានទិន្នន័យ ដែលអាចឲ្យមានការផ្លាស់ប្តូរព័ត៌មានខាងផ្នែកសិក្សា ស្រាវជ្រាវបុរាណវិទ្យាជាមួយគម្រោងស្រាវជ្រាវបុរាណវិទ្យាដទៃទៀតនៅក្នុងឧទ្យានអង្គរ។

៤.បន្តការសិក្សានិងការងារដែលសំដៅធានាឲ្យបាននូវការលើកតម្លៃធនធានក្នុងស្រុក តាមរយៈការគ្រប់គ្រងទឹកនៅក្នុងតំបន់ស្រះស្រង់។ ហើយយើងក៏បានស្តាប់នៅនឹងកន្លែងនូវបទបង្ហាញមួយរបស់សហសេវិកយើងដែលជានាយកផ្នែកគ្រប់គ្រងធនធានទឹកនៅអង្គរ។

ជាសេចក្តីសន្និដ្ឋាន ចំពោះអ្វីដែលទាក់ទងនឹងការដ្ឋានទីមួយនេះ យើងសូមគូសបញ្ជាក់ថាគម្រោងនេះមាន

សក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍទេសចរណ៍វប្បធម៌ ហើយអ្នកជំនាញខាងការអភិរក្សនិងអ្នកជំនាញខាងការអភិវឌ្ឍអាចតាមដានរួមគ្នាបាន។
ខ្ញុំជឿជាក់ថានៅក្នុងគម្រោងនេះ អ្នកជំនាញទាំងពីរក្រុមគួរធ្វើការជាមួយគ្នា ដើម្បីបន្តធានាបាននូវការតាមដាននិងការវិវត្តរបស់គម្រោងដ៏ធំនេះ ដែលខ្ញុំជឿជាក់ថាអាជ្ញាធរទាំងអស់ពិតជាផ្តល់ការយកចិត្តទុកដាក់បំផុត។

ការដ្ឋានទីពីរគឺជាការដ្ឋានដែលយើងបានចុះពិនិត្យជាមួយលោក Christophe Pottier។ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ក្រុមអ្នកជំនាញបានធ្វើដំណើរទៅកាន់ទីស្នាក់ការរបស់ EFEO (សាលាបារាំងចុងបូព៌ាប្រទេស) ហើយបានកត់ត្រាទុកនូវព័ត៌មានដ៏លម្អិតមួយដែលបុរាណវិទូ Christophe Pottier បានផ្តល់ឲ្យ ទាក់ទងនឹងការងារស្រាវជ្រាវដែលបានធ្វើជាមួយអប្សរា អស់រយៈពេលជាច្រើនឆ្នាំមកហើយ គឺអស់រយៈពេលចំនួនដប់ឆ្នាំមកហើយ នៅក្នុងតំបន់អង្គរ។

ខណៈដែលលោក Pottier ទើបនឹងបានបង្ហាញដោយរូបលោកផ្ទាល់អំពីលទ្ធផលនៃការងាររបស់លោកនៅក្នុងសម័យប្រជុំ CIC នេះ ក្រុមអ្នកជំនាញបានពិនិត្យពិចារណាថា ខ្លួនគ្រាន់តែទាញយកមេរៀនមួយចំនួនពីបទពិសោធន៍នេះ និងផ្តល់អនុសាសន៍ខ្លះៗប៉ុណ្ណោះ។
សេចក្តីកត់សម្គាល់ដ៏សំខាន់ទីមួយដែលគួរតែគូសបញ្ជាក់នោះ គឺទាក់ទងនឹងសារៈសំខាន់នៃការបង្កើតផែនទីបុរាណវិទ្យាមួយរបស់តំបន់អង្គរ ដែលម្យ៉ាង អាចឲ្យគេស្គាល់កាន់តែច្បាស់នូវការវិវត្តនៃប្រវត្តិសាស្ត្រតំបន់នេះ ដែលជាបេះដូងនៃអាណាចក្រខ្មែរ និងម្យ៉ាងទៀត គេអាចប្រើជាឧបករណ៍មួយ សម្រាប់ជាប្រយោជន៍ដល់ការអភិរក្សនិងការអភិវឌ្ឍ។

ក្រុមអ្នកជំនាញសូមកោតសរសើរចំពោះលទ្ធផលដែលទទួលបានរួចមកហើយដ៏គួរឲ្យកត់សម្គាល់និងថ្មីៗ ទាក់ទងនឹងបុរាណវិទ្យាប្រវត្តិសាស្ត្រ ដែលមិនត្រឹមតែអាចឲ្យគេស្គាល់ពីការងារមុនៗស្តីពីតំបន់អង្គរប៉ុណ្ណោះទេ ប៉ុន្តែក៏ធានាបានផងដែរនូវវិធីថ្មីនៃការស្រាវជ្រាវលើបុរីអង្គរនិងការរៀបចំទឹកដីអង្គរ ដោយសារវិធីសាស្ត្រស្រាវជ្រាវមួយដែលមានបច្ចេកវិទ្យាទំនើបសម្រាប់វិភាគនិងពិនិត្យ)។
ហើយខ្ញុំជឿជាក់ថា របកគំហើញថ្មីៗដែលត្រូវបានគូសបញ្ជាក់នៅពេលអំបាញ់មិញនេះរួចហើយដោយសហសេវិករបស់យើង គឺលោក Christophe Pottier អាចឲ្យយើងតាមដានដឹងអំពីការតាំងទីជាបន្តបន្ទាប់នៅក្នុងរមណីយដ្ឋាន និងអំពីការរៀបចំនគរោបនីយកម្មដែលផ្អែកលើគោលការណ៍ធរណីមាត្រ គោលការណ៍ប្រមូលផ្តុំអំណាច និងគោលការណ៍នៃការរៀបចំលំនៅឋានដែលមានទំនាក់ទំនងនឹងធារាសាស្ត្រ។

ដោយសារការងារដែលបានធ្វើនៅម្តុំរលួស គឺនៅព្រៃក្មេង កោះតាមាស ហរិហរៈ ត្រពាំងផុង បាគង ព្រះគោ និងនៅព្រៃមន្ទីរ យើងអាចមានចក្ខុវិស័យច្បាស់លាស់មួយស្តីពីតំបន់ទាំងនោះ។ ការពិនិត្យមើលដោយធ្វើការប្រៀបធៀបទៅលើស្រទាប់ដី និងទិន្នន័យសំខាន់ៗនានា គេអាចពិនិត្យមើលទិន្នន័យប្រវត្តិសាស្ត្រឡើងវិញ។

ដូច្នេះ ចំពោះរមណីយដ្ឋានព្រៃមន្ទីរ ដោយសារកំណាយដែលបានធ្វើឡើងនៅពេលថ្មីៗនេះ ដោយសារការវិភាគដ៏លម្អិតលើសម្ភារៈដែលគេបានបង្ហាញ មានជាអាទិ៍កុលាលភាជន៍ដែលនាំចូលពីប្រទេសចិននិងពីមជ្ឈិមបូព៌ាប្រទេសនោះ ប្លង់ទូទៅរបស់រមណីយដ្ឋាននេះក៏ត្រូវបានបង្កើតឡើង និងជាពិសេសនោះ គឺគេបានកំណត់កាលបរិច្ឆេទច្បាស់លាស់។
ទិន្នន័យអក្សរចារឹកបានបញ្ជាក់អំពីកាលបរិច្ឆេទឆ្នាំ៨៨១។ នៅពេលនេះយើងយល់ថា អ្វីដែលគេហៅថាព្រះរាជវាំង

នោះ ត្រូវបានបង្កើតនិងកសាងឡើងមុនកាលបរិច្ឆេទដែលគេទទួលស្គាល់បច្ចុប្បន្ន មានន័យថាប្រហែលជានៅពាក់កណ្តាលសតវត្សទីVIII នៃគ្រិស្តសករាជ គឺប្រហែលជា មួយសតវត្សកន្លះទៅពីរសតវត្ស មុនកាលបរិច្ឆេទដែលគេចាត់ទុករហូតមកទល់ពេលបច្ចុប្បន្ននេះ។

ដូច្នេះ ខ្ញុំសូមលើកឡើងឃ្លានេះ៖ "ពិចារណាឡើងវិញអំពីដើមកំណើតអង្គរ"។ នេះគឺជាអ្វីដែល Christophe Pottier ទើបអះអាងអម្បាញ់មិញនេះដោយពឹងផ្អែកលើទិន្នន័យបុរាណវិទ្យា។

ដូច្នេះ ក្រុមអ្នកជំនាញសូមកោតសរសើរលោក Christophe Pottier សហសេវិកជនជាតិខ្មែរក្មេងៗរបស់លោក ព្រមទាំងដៃគូជនជាតិអូស្ត្រាលីរបស់លោក ជាពិសេសគឺលោកសាស្ត្រាចារ្យ Roland Fletcher ចំពោះគុណភាពនៃការសិក្សាស្រាវជ្រាវដែលបានធ្វើ និងចំពោះលទ្ធផលដែលមានសារៈសំខាន់បំផុតដើម្បីស្គាល់អំពីប្រវត្តិសាស្ត្ររបស់អង្គរ។

ក្រុមអ្នកជំនាញសូមរំឭកឡើងវិញអំពីអនុសាសន៍ដែលបានបង្ហាញជូនរួចហើយ នៅក្នុងសម័យប្រជុំមុនៗរបស់ CIC និងជាពិសេសនោះគឺបន្ទាប់ពីមានការអំពាវនាវធ្វើឡើងនៅទីនេះផ្ទាល់ ដោយលោកសាស្ត្រាចារ្យ Claude Jacques។ អនុសាសន៍ទាំងនោះគឺមានដូចតទៅនេះ៖

១. ភាពចាំបាច់នៃការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យាដោយស្វ័យប្រវត្តិ នៅជុំវិញប្រាង្គប្រាសាទនិងរមណីយដ្ឋាននានា ដែលជាកម្មវត្ថុនៃកិច្ចអន្តរាគមន៍ពង្រឹង ឬជួសជុល។

២.យកចិត្តទុកដាក់ធ្វើយ៉ាងណាឲ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវផ្នែកបុរាណវិទ្យាត្រូវបានបោះពុម្ពផ្សាយ និងបញ្ចូលឲ្យបានឆាប់រហ័សទៅក្នុងមូលដ្ឋានទិន្នន័យ ដែលអាចឲ្យគេធ្វើការសិក្សានិងការវិភាគប្រៀបធៀបបាន។

៣. ធានាឲ្យបានថា ប្រាង្គប្រាសាទនិងរមណីយដ្ឋាននានានៅជិតកំណាយ ត្រូវបានទេសចរចូលទៅទស្សនា និងមានការដាក់ស្លាកសញ្ញាល្អ សមរម្យ។

៤.បញ្ចូលការរៀបចំប្រាង្គប្រាសាទនិងរមណីយដ្ឋាននានាដែលនៅជិតនោះមានការងារកំណាយ ទៅក្នុងគម្រោងរៀបចំទាំងមូល សម្រាប់ផ្តល់ព័ត៌មានទូទៅជូនដល់សាធារណៈជន។

សូមអរគុណលោកប្រធាន។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** តើមានសំណួរទេ? តើមានសំណើឬក៏សេចក្តីកត់សម្គាល់ទេ? ខ្ញុំទុកពេលបន្តិចជូន។ តើមាននរណាម្នាក់ចង់សួរសំណួរទាក់ទងនឹងការអភិរក្សប្រាង្គប្រាសាទនៅពេលមានខ្យល់ព្យុះកំបុតត្បូងទេ? បាទ សូមអញ្ជើញឯកឧត្តម។

**សំណួររបស់លោក តាន់ ប៊ុន សុយ៖** លោកសហប្រធានជាទីគោរព។ ខ្ញុំឈ្មោះ តាន់ ប៊ុន សួយ ជាអ្នកទទួលខុសត្រូវនាយកដ្ឋានអភិវឌ្ឍន៍កសិកម្មនិងសហគមន៍។ កិច្ចអន្តរាគមន៍របស់ខ្ញុំមិនទាក់ទងជាមួយភាពទទួលខុសត្រូវរបស់ខ្ញុំនោះទេ គឺវាទាក់ទងទៅនឹងបទបញ្ហាចំនួនពីរដែលយើងអនុវត្តន៍ នៅក្នុងករណីដែលបាននិយាយនៅព្រឹកនេះ។ យើងបាននិយាយអំពីខ្យល់ព្យុះកំបុតត្បូង កេតសាណា។ យើងបានលើកឡើងអំពីកត្តាទឹកភ្លៀង។ ប៉ុន្តែនៅពេល

ដែលយើងនិយាយអំពីខ្យល់ព្យុះកំបុតត្បូង វាក៏មានកត្តាខ្យល់ផងដែរដែលអាចបង្កមហន្តរាយដល់ប្រាសាទ។ ខ្ញុំសូមអំពាវនាវឲ្យមានការគិតគូរអំពីវិធានការណ៍ដែលអាចកាត់បន្ថយផលប៉ះពាល់ជាយថាហេតុ បណ្តាលមកពីខ្យល់ដែលមានកម្លាំងខ្លាំង។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** ទាក់ទងនឹងសេចក្តីព្រួយបារម្ភនេះ តើអ្នកជំនាញខាងការអភិរក្សរបស់យើងមានសេចក្តីកត់សម្គាល់ដែលត្រូវធ្វើឬទេ?

**ចម្លើយរបស់លោក** Bouchenaki៖ សូមអរគុណលោកប្រធាន និងសូមអរគុណចំពោះសំណួរនេះ។ ជាការពិតណាស់រៀងរាល់លើកដែលយើងធ្វើដំណើរមកកាន់ទឹកដីនៃឧទ្យានអង្គរ យើងតែងតែមានការប្រុងប្រយ័ត្ន។ ជាពិសេសនោះគឺយើងមកនៅក្នុងរដូវពីរខុសគ្នា។ ដូច្នេះ យើងប្រឈមមុខនឹងស្ថានភាពអាកាសធាតុខុសគ្នា។ ដោយហេតុថា នៅក្នុងឧទ្យាន មានព្រៃឈើច្រើន វាប្រាកដណាស់ដែលថាយើងត្រូវយកចិត្តទុកដាក់គិតគូរដល់បញ្ហាខ្យល់ផងដែរ ហើយបញ្ហាទាំងនេះនឹងត្រូវបានលើកយកមកនិយាយនៅក្នុងរបាយការណ៍ដែលលោកសាស្ត្រាចារ្យ Croci នឹងធ្វើនៅពេលបន្តិចទៀតនេះ នៅពេលដែលយើងនិយាយអំពីប្រាសាទតាព្រហ្ម និងអំពីកិច្ចប្រតិបត្តិការដែលធ្វើជាមួយសហសេវិកនៃក្រុមការងារឥណ្ឌារបស់យើងដែលធ្វើការនៅនឹងរមណីយដ្ឋាននោះ ហើយក្រុមឥណ្ឌាក៏ធ្វើការងារសាកល្បងផងដែរទាក់ទងនឹងការការពារដើមឈើ។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** សូមអរគុណ។ តើមានសេចក្តីកត់សម្គាល់អ្វីផ្សេងទៀតទេ? ប្រសិនបើមិនមានទេនោះ យើងមានកម្មវិធីជំមមាញឹកមួយទៀត ដោយហេតុថាសំណើដែលបានស្នើទៅលោក លោកស្រី គឺត្រូវធ្វើដំណើរទៅកាន់សារមន្ទីរកុលាលភាជន៍អង្គរ នៅតានី។ អ្ហា ! មានរបាយការណ៍ផ្សេងទៀត។ ដូច្នេះ លោកសាស្ត្រាចារ្យ Croci នឹងធ្វើរបាយការណ៍r របស់លោកភ្លាមនៅពេលនេះ ហើយ លោកសាស្ត្រាចារ្យ Lablaude និង Hidaka នឹងធ្វើជាបន្តបន្ទាប់ទៀត។

**លោក** Croci ៖

បទបង្ហាញរបស់ខ្ញុំទាក់ទងនឹងការចុះទៅមើលប្រាសាទតាព្រហ្ម។ គោលការណ៍ទូទៅនៃគម្រោង ត្រូវបានជជែកពិភាក្សាជាច្រើនដងរួចមកហើយ នៅនឹងប្រាសាទផ្ទាល់ ក៏ដូចជានៅក្នុងពេលប្រជុំ សេ អ៊ី សេ។ យើងបានសង្កត់ធ្ងន់ទៅលើតម្រូវការអោយមាន ទីមួយ តុល្យភាពរវាងវប្បធម៌និងធម្មជាតិ ពោលគឺអោយប្រាសាទនិងដើមឈើនៅជាមួយគ្នា និងទីពីរ គឺទុកអោយប្រាសាទទាំងមូលស្ថិតនៅក្នុងសភាពបាក់បែកដូចដើម ទោះបីជាផ្នែកខ្លះត្រូវជួសជុលឡើងវិញក៏ដោយ និងចុងក្រោយ គឺស្វែងយល់អំពីអត្ថន័យនៃប្រាសាទអោយបានស៊ីជម្រៅថែមទៀត តាមរយៈការធ្វើកំណាយបុរាណវិទ្យា។

គោលការណ៍ទូទៅនេះហាក់ដូចជាត្រូវបានក្រុម ASI គោរពតាមបានយ៉ាងល្អប្រសើរ។ នៅពេលចុះទៅពិនិត្យប្រាសាទនិងពេលពិភាក្សាជាមួយក្រុមឥណ្ឌា យើងបានពិភាក្សាគ្នាលើចំណុចខាងក្រោមនេះ៖

១. សុវត្ថិភាព៖ ទំនល់ទ្រធ្វើអំពីឈើបណ្តោះអាសន្ន ត្រូវបានជំនួសដោយទំនល់ទ្រធ្វើអំពីដែកដែលមានលក្ខណៈប្រសើរជាង។ ទន្ទឹមគ្នានោះដែរ នៅតាមផ្លូវដើរក្នុងប្រាសាទ មានការរៀបចំដាក់បន្ទះក្តារឈើដើម្បីអោយអ្នកទស្សនាស្រួលដើរ។ ការរៀបចំទាំងនេះផ្តល់នូវលទ្ធផលវិជ្ជមាន ទាំង៖

– ផ្នែកសុវត្ថិភាព មិនអោយមានអ្នកទេសចរចូលទៅកន្លែងចង្អៀត ងងឹត ដែលមានថ្មអាចធ្លាក់មកគ្រប់ពេល និងជាកន្លែងដែលគេទុកអោយស្ថិតនៅក្នុងស្ថានភាពដើម។

– ផ្នែកទេសភាព ពីព្រោះគេអាចទស្សនាភាពស៊ីគ្នារវាងដើមឈើនិងប្រាសាទ។ គេគ្រោងនឹងធ្វើកិច្ចការបន្ថែមទៀតលើចំណុចនេះ។

២. បន្ទប់អ្នករបាំះ នៅកន្លែងនេះ គេគ្រោងជួសជុលផ្នែកខ្លះ ហើយរក្សាទុកផ្នែកខ្លះដែលបាក់បែកធ្ងន់ធ្ងរ។ សំណើដែលលើកឡើងពិតជាគួរអោយយើងពិចារណាដែរ ប៉ុន្តែ គេត្រូវធ្វើការសិក្សាជំបូងសិន (គួរសិក្សាលើទំហំរបស់វា) ដើម្បីជៀសវាងលទ្ធផលដែលបង្ហាញថាផ្នែកទាំងពីរមានភាពខុសគ្នាដាច់ស្រឡះ ហើយអាចអោយគេយល់ថាផ្នែកដែលយើងទុកចោល មិនជួសជុល មិនមែនជាជម្រើសដោយចេតនាទេ ប៉ុន្តែគេបែរជាយល់ថា ជាផ្នែកដែលគេកំពុងបន្តជួសជុលទៅវិញ។ ការពិភាក្សាបានឈានទៅដល់ការព្រមព្រាងគ្នាថា ត្រូវយកថ្មដែលធ្លាក់គនៅខាងក្នុងបន្ទប់នេះចេញ ហើយទន្ទឹមនឹងនោះ ត្រូវដាក់ទ្រនល់ទ្រកន្លែងខ្លះដែលចាំបាច់។ ដូច្នេះ នៅពេលប្រជុំលើកក្រោយ យើងនឹងឃើញរូបរាងបន្ទប់ទាំងមូលច្បាស់ និងដឹងថាផ្នែកដែលត្រូវជួសជុលមានកម្រឹតណា ហើយផ្នែកដែលត្រូវទុកអោយនៅដដែលមានប៉ុណ្ណា។

៣. ក្លោងទ្វារចូលខាងលិចះ វាហាក់ដូចជាស្ថិតក្នុងស្ថានភាពអាក្រក់ និងគ្រោះថ្នាក់បន្តិច ប៉ុន្តែគេប្រហែលជាអាចទល់ទ្រអោយមាំបានដោយមិនចាំបាច់រុះរើថ្ម។ វិធានការជំបូងគឺត្រូវយកខ្សែចងផ្គោបក្លោងអោយបានច្រើនកន្លែងដើម្បីធ្វើអោយក្លោងមាំ។ ខ្សែយកមកចងនោះអាចជាខ្សែធ្វើពីដែកថែប មិនច្រេះ ដោតបញ្ចូលទៅតាមរន្ធបណ្តោយដែលមានស្រាប់ ធ្វើបែបនេះ គេមើលពីក្រៅមិនឃើញខ្សែនោះទេ។ ទាក់ទងនឹងក្លោងដែលមានផ្នែកខ្លះទ្រុឌទ្រោមពេក គេចាំបាច់ត្រូវចងភ្ជាប់ថ្មដែលឃ្លាតចេញពីគេ ហើយដាក់បញ្ចូលថ្មថ្មីត្រង់កន្លែងដែលចំហ បែបនេះគឺអាចធ្វើអោយរចនាសម្ព័ន្ធមានលំនឹង។ ក្រុមឥណ្ឌានឹងលើកសំណើឡើងពាក់ព័ន្ធនឹងការងារនេះក្នុងពេលប្រជុំលើកក្រោយ។

៤. ដើមឈើះ ដូចដែលយើងបាននិយាយលើកមុនៗដែរ វាមានប្រយោជន៍ធំធេងណាស់ចំពោះប្រាសាទ ដូច្នេះយើងត្រូវអភិរក្សវា។ ប៉ុន្តែដើមឈើខ្លះ គេក៏អាចកាប់ចេញបានដែរប្រសិនបើដើមឈើនោះអាចបង្កគ្រោះថ្នាក់ ហើយបើវាគ្មានប្រយោជន៍អ្វីសម្រាប់ទេសភាពទូទៅរបស់ប្រាសាទទេនោះ។ គេត្រូវផ្តោតទៅលើដើមឈើដែលមានជំងឺអាចបង្កគ្រោះថ្នាក់។ ឧទាហរណ៍ ដូចជាដើមឈើចាស់ៗ ពុកផុយទៅហើយ ក្នុងករណីនេះ គេចាំបាច់ត្រូវស្រាវជ្រាវរិះរកវិធានការដើម្បីព្យាបាលវា ឬវិភាគអំពីផលប៉ះពាល់ជាយថាហេតុរបស់វា ទាំងអស់នេះ គេត្រូវចងក្រងជាឯកសារអោយបានត្រឹមត្រូវ។ ចុងក្រោយ យើងបានពិភាក្សាគ្នាអំពីដើមឈើដែលទ្រេតខ្លាំង និងពីលទ្ធភាពទល់ទ្រវា។ ក្រុម ASI បានលើសំណើដំណោះស្រាយមួយ។ យើងបានឯកភាពលើសំណើនេះ ហើយយើងអាចចាត់ទុកថាជាដំណោះស្រាយសាកល្បង ដកបទពិសោធន៍។ កិច្ចការនេះនឹងធ្វើទៅដោយមានប្រព័ន្ធកុំព្យូទ័រតាមដានថាមពលខ្យល់។ នេះគឺដើម្បីវាយតម្លៃកម្លាំងខ្យល់ និងវិរូបកម្មព្រមទាំងរំញ័រដែលបណ្តាលមកពីកម្លាំងខ្យល់។ ព័តមានដែលទទួលបានពីការពិសោធន៍នេះនឹងមានប្រយោជន៍សម្រាប់ករណីស្រដៀងគ្នានេះទៅថ្ងៃអនាគត។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំងះ** សូមអរគុណច្រើនលោកសាស្ត្រាចារ្យ Croci។ ការជួសជុលប្រាសាទតាព្រហ្មដែលបានធ្វើដោយ Archaeological Survey of India គឺជាយុទ្ធនាការជួសជុលមួយក្នុងចំណោមយុទ្ធនាការជួសជុលធំៗបំផុតនៅអង្គរ។

**លោក Pierre-André Lablaude៖**

## ភ្នំបាខែង ៖

ក្រុមអ្នកអ្នកជំនាញ អាដ ហុក បានទៅទស្សនាភ្នំបាខែង ក្រោមការដឹកនាំរបស់លោក **Glenn Boornazian** និងសមាជិកផ្សេងៗ ទាំងខ្មែរ និងបរទេស នៃក្រុមការងាររបស់ **World Monuments Fund**។

បន្ទាប់ពីទស្សនកិច្ចនោះមក លោកមានបំណងគូសបញ្ជាក់ចំណុចសំខាន់ៗដូចតទៅ៖

១. រំឭកជាដំបូងពីសភាពកំពុងរងគ្រោះថ្នាក់ធ្ងន់ធ្ងរនៃប្រាសាទនេះ។ គ្រោះថ្នាក់នោះត្រូវបានជូនដំណឹងច្រើនឆ្នាំមកហើយ ជាគ្រោះថ្នាក់ទាក់ទងទៅនឹងការថែរក្សាប្រាសាទសុទ្ធសាធ ប៉ុន្តែក៏ជាគ្រោះថ្នាក់ដោយសារមនុស្សទៅទស្សនាច្រើន ឬអាចនិយាយថាក្នុងមួយថ្ងៃៗ មនុស្សចូលទស្សនាច្រើនលើសលុបពេក នៅម៉ោងពេលខ្លះ ហើយយើងក៏មិនភ្លេចលើកឡើងផងដែរអំពីហានិភ័យដែលអ្នកទស្សនាខ្លួនឯងអាចជួបប្រទះ។

២. ដូច្នេះ យើងមានសេចក្តីរីករាយជាខ្លាំងដោយឃើញក្រុមការងាររបស់ **World Monuments Fund** ប្រើប្រាស់អ្នកជំនាញ បុគ្គលិក និងសម្ភារៈ ព្រមទាំងថវិកាក្នុងកម្រិតខ្ពស់ មកចូលរួមជាថ្មីក្នុងការងារអភិរក្ស និងជួសជុលប្រាសាទនេះឡើងវិញ ដែលជាប្រាសាទមានសារសំខាន់បំផុតក្នុងប្រវត្តិសាស្រ្ត និងក្នុងទេសភាពវប្បធម៌អង្គរ។

៣. ប្រសិនបើយើងពិនិត្យ**ផ្នែកទី១**នៃប្រាសាទ ពោលគឺពីរ៉ាមីតកណ្តាលធ្វើពីថ្មភក់ និងការបារម្ភដែលពេលខ្លះមានភាពស្រពិចស្រពិលទាក់ទងទៅនឹងលំនឹងប្រាសាទទាំងមូល ការងារជួសជុលដំបូងធ្វើអោយពេលនេះយើងមានទស្សនៈសុទិដ្ឋិនិយម ចំពោះចំណោទបញ្ហាទាក់ទងទៅនឹងការអភិរក្ស ៖

-ផ្ទាំងថ្មគ្រឹះកណ្តាលតួប្រាសាទមើលទៅដូចជានៅល្អ មានលំនឹង ធន់ និងអាចទ្របន្ទុកសំណង់ទាំងមូលបាន។

-មូលហេតុបណ្តាលអោយមានភាពទ្រុឌទ្រោមចំពោះប្រាសាទ បានលេចឡើងយ៉ាងច្បាស់នាពេលនេះ៖

⇨ រុក្ខជាតិដុះចាក់ចូលញែកតាមចន្លោះផ្ទាំងថ្មប្រាសាទ។

⇨ ឫសឈើចាក់ចូលទៅក្នុងប្រាសាទធ្វើឲ្យរចនាសម្ព័ន្ធដើមប្រាសាទប្រែប្រួល។

⇨ និងចុងក្រោយ គឺទឹកភ្លៀងបានជ្រាបចូលទៅក្នុងរចនាសម្ព័ន្ធទ្រុឌទ្រោមនេះ រួមជាមួយបាតុភូតទឹកហូរច្រោះទម្លាក់ដីនិងថ្ម ព្រមទាំងសម្ពាធទឹកភ្លៀងដដែលនេះធាក់ចេញពីខាងក្នុងមកលើជញ្ជាំងថ្មភក់ខាងក្រៅ។

៤. គោលការណ៍ដែលលើកឡើងដោយសហសេវិករបស់យើងដែលមកពី World Monuments Fund ដើម្បីជួសជុលការខូចខាតនោះ មានលក្ខណៈសមហេតុសមផល ជាដំបូងដោយសារការថ្លឹងថ្លែងរវាង ៖

-ការពង្រឹងសំណង់ ត្រង់កន្លែងណាដែលអាចធ្វើទៅបាន និង

-ការរុះរើនិងរៀបឡើងវិញកន្លែងដែលទ្រុឌទ្រោមខ្លាំង ដើម្បីធ្វើយ៉ាងណាឲ្យកន្លែងដែលទ្រុឌទ្រោមនោះមានលំនឹងឡើងវិញ។

និងបន្ទាប់មក តាមរយៈការប្រើប្រាស់សម្ភារៈទំនើប ដើម្បីធ្វើឲ្យជញ្ជាំងប្រាសាទមិនជ្រាបទឹក ពោលគឺគេបានប្រើផ្ទាំងកៅស៊ូប្លាស្ទិកក្រាស់ យកទៅក្រាលពីក្រោម ហើយរៀបថ្មភក់ពីលើ។

ទោះបីជាក្នុងចំណោមយើងទាំងអស់គ្នា គ្មាននរណាម្នាក់ដឹងច្បាស់ថាសម្ភារៈនេះអាចជាប់យូរបានប៉ុណ្ណាក៏ដោយ ប៉ុន្តែការអភិរក្សប្រាសាទ មិនខុសអ្វីពីវេជ្ជសាស្ត្រនោះទេ ពោលគឺគេត្រូវព្យាបាលអ្នកជំងឺដោយប្រើមធ្យោបាយដែលមានស្រាប់។ ដូច្នេះ បើគិតទៅតាមសភាពនៃការអភិវឌ្ឍបច្ចេកទេសនាពេលបច្ចុប្បន្ន វិធីដែលគេប្រើនាពេលនេះ អាចចាត់ទុកថាជាដំណោះស្រាយមួយល្អហើយ។

៥. ប្រសិនបើយើងពិនិត្យ**ផ្នែកទី២** នៃប្រាសាទ ពោលគឺបណ្តាតួប៉មតូចៗសង់ពីឥដ្ឋដែលនៅជុំវិញប្រាសាទធំ គេសង្កេតឃើញមានបញ្ហាពីរ ៖

- បញ្ហារចនាសម្ព័ន្ធខាងលើកំពូល ដូចពីរ៉ាមីតធ្វើពីថ្មភក់ដែរ ធំបំផុតគឺបណ្តាលមកពីរុក្ខជាតិដុះពីលើ។
- ព្រមជាមួយគ្នានោះ ក៏មានបញ្ហារចនាសម្ព័ន្ធផ្នែកគ្រឹះក្រោមដែរ បណ្តាលមកពីៈ

⇨ ដីគ្រឹះផុងដោយសារសំណើម

⇨ គ្រឹះធ្វើពីថ្មបាយក្រៀមពុកផុយបន្តិចម្តងៗ។

ត្រង់ចំណុចនេះ ក្រុមការងារ WMF គ្រោងថានឹងមិនរុះរើនិងរៀបថ្មឡើងវិញទេ ព្រោះវាអាចជាការងារលំបាកនិងធ្វើអោយខូចខាតដល់សំណង់ធ្វើអំពីឥដ្ឋ ប៉ុន្តែចាប់យកដំណោះស្រាយដែលសមរម្យជាងការរុះរើថ្ម នោះគឺធ្វើពីគ្រឹះមកវិញ ដែលដំណោះស្រាយនេះមានគុណប្រយោជន៍ច្រើនដល់ការអភិរក្សសភាពដើមនៃសំណង់ ហើយម្យ៉ាងទៀតវាក៏ងាយធ្វើជាងដែរ។ ក៏ប៉ុន្តែ នៅមានការលំបាកដោយឡែកមួយ ដោយសារតែស្រទាប់បុរាណវិទ្យានៅពីក្រោមគ្រឹះសំណង់ទាំងនេះមានភាពសម្បូរបែប។

ចំពោះផ្នែកទីពីរនេះ ក្រុមអ្នកជំនាញ អាដ ហុកៈ

១. សូមកោតសរសើរដល់ក្រុមការងារ WMF ចំពោះការគិតគូរដល់សមាសភាគបុរាណវិទ្យា តាំងពីពេលដំបូងនៃគម្រោងនេះ ហើយកិច្ចការបុរាណវិទ្យានេះទទួលបានជំនួយដ៏វិសេសវិសាលពីក្រុមបុរាណវិទូខ្មែរ។

២. សូមជំរុញនិងលើកទឹកចិត្តដល់ក្រុម WMF ក្នុងគម្រោងរៀបចំសិក្ខាសាលាមួយ ដោយមានការគាំទ្រពី ICCROM អញ្ជើញអ្នកជំនាញ អ្នកមានឯកទេសផ្សេងៗមកចូលរួមពិភាក្សា ជុំវិញចំណោទបញ្ហាពិសេសនៃសំណង់ធ្វើពីឥដ្ឋនេះ ដើម្បីត្រិះរិះពិចារណា រកដំណោះស្រាយ ក្នុងកំឡុងពេលដែលមានគម្រោងការដ្ឋានជួសជុលនេះ រួចគេអាចយកលទ្ធផលនៃការពិភាក្សានេះទៅផ្សព្វផ្សាយជូនដល់ក្រុមបច្ចេកទេសនានា ទាំងខ្មែរ ទាំងអន្តរជាតិ ដែលនឹងត្រូវជួសជុលប្រាសាទផ្សេងទៀតស្រដៀងគ្នានឹងប្រាសាទនេះដែរ នៅក្នុងតំបន់អង្គរ។

៣. ចុងក្រោយ ក្រុមអ្នកជំនាញ អាដ ហុក សូមគូសបញ្ជាក់ថា ទំហំការងារជួសជុលប្រាសាទភ្នំបាខែង របស់ក្រុម WMF តម្រូវអោយពួកគេប្តេជ្ញាធ្វើបន្តកាន់តែខ្លាំងថែមទៀត ដោយគិតគូរដល់តំបន់ជុំវិញប្រាសាទទាំងមូល ហើយច្បាស់ណាស់ថា កាតព្វកិច្ចដែលពួកគេត្រូវបំពេញចំពោះមុខរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាចំពោះមុខសហគមន៍អន្តរជាតិទាំងមូល គឺពួកគេត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីអនុវត្តគម្រោងនេះឲ្យ

ដល់ទីបញ្ចប់ជាស្ថាពរ។

យើងសូមសំដែងនូវសេចក្តីរីករាយ និងការកោតសរសើរទុកជាមុនដល់សហាសេវិករបស់យើង។

**លោក** Hidaka ៖

មុននឹងចាប់ផ្តើមអានរបាយការណ៍របស់ខ្ញុំ ខ្ញុំសូមថ្លែងអំណរគុណសហាសេវិករបស់ខ្ញុំនិងអ្នកឯកទេសគ្រប់រូប ព្រោះថាខ្ញុំចូលចិត្តយ៉ាងខ្លាំងនូវបេសកកម្មទីមួយនេះ ក្នុងឋានៈជាសមាជិករបស់ក្រុមអ្នកជំនាញ ad hoc។

ភារកិច្ចរបស់ខ្ញុំគឺត្រូវធ្វើការសង្ខេបការងារចុះទៅពិនិត្យកំពែងប្រាសាទអង្គរធំ និងគម្រោងជួសជុលពង្រឹងផ្នែកខាងលើប្រាសាទអង្គរវត្ត។

លោកសាស្ត្រាចារ្យ Gaucher បានចាប់ផ្តើមនិយាយត្រួសៗអំពីប្រវត្តិនៃកំណាយនានាដែលបានធ្វើនៅប្រាសាទវិមានអាកាស ហើយបន្ទាប់មកបាននាំយើងទៅមើលស្លាកស្នាមបុរាណវិទ្យានៅក្នុងបរិវេណព្រះរាជវាំង។ ប្លង់កំពែងបុរាណត្រូវបានគូសឡើងវិញ ហើយផែនទីដ៏លម្អិតមួយត្រូវបានធ្វើដោយលោកសាស្ត្រាចារ្យ ដោយប្រើបច្ចេកទេសខ្ពស់និងច្បាស់លាស់។ ការសិក្សានិងការស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យ Gaucher ត្រូវមានការទទួលស្គាល់មិនត្រឹមតែក្នុងកម្រិតបុរាណវិទ្យាស្តីពីរចនាសម្ព័ន្ធរបស់ប្រាង្គប្រាសាទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការគិតគូរវែងឆ្ងាយរបស់លោកទៅលើគោលការណ៍នគរូបនីយកម្មខ្មែរ ដែលលោកសាកល្បងផ្គុំឡើងវិញ តាមរយៈសេចក្តីសំយោគលើការវិភាគប្រវត្តិសាស្ត្រ និមិត្តរូប សង្គម និងបច្ចេកទេសធរណីមាត្រ។

ដូច្នេះ កំពែងប្រាសាទដ៏ធំសម្បើមនឹងមានតម្លៃរបស់វាឡើងវិញ ដែលជាសមាសធាតុដ៏មានសារៈសំខាន់មួយរបស់ព្រះរាជវាំង។ ការសិក្សាបន្ថែមលើកំពែងអង្គរធំពិតជាអាចធ្វើអោយគេបើកផ្លូវទេសចរណ៍ថ្មីៗនៅតាមខ្នងកំពែងនេះ ដោយចេញដំណើរពីទិសខាងត្បូងឆ្ពោះទៅទិសខាងលិច បន្ទាប់មកឆ្ពោះទៅកាន់ទីលានស្តេចគម្លង់និងលានដំរី។ ដូច្នេះ ផ្លូវទស្សនាថ្មីដែលឆ្លងកាត់តាមព្រៃទាំងនេះ នឹងមានភាពផ្ទុយគ្នាស្រឡះគួរឲ្យចាប់អារម្មណ៍ជាមួយនឹងការងារជួសជុលប្រាសាទបាយ័ន ព្រមទាំងអាចឲ្យអ្នកទេសចរពេញចិត្តនឹងរមណីយដ្ឋានទាំងមូល។

ចំណុចទីពីរទាក់ទងនឹងរចនាសម្ព័ន្ធរបស់ប្រាសាទវិមានអាកាស។ សម្រង់និងការវិភាគនានានឹងអនុញ្ញាតឲ្យគេចាត់វិធានការណ៍បង្ការចំពោះជ្រុងទាំងអស់របស់ប្រាសាទដែលទ្រេតនិងមានផ្ទាំងថ្មគ្មានលំនឹង អាចធ្លាក់បង្កគ្រោះថ្នាក់។

យើងក៏បានចុះទៅពិនិត្យក្លោងទ្វារពីរក្នុងចំណោមទ្វារទាំងបួននៃអង្គរធំផងដែរ៖ គឺក្លោងទ្វារខាងត្បូងនិងក្លោងទ្វារខាងលិច។ ការដាក់ចន្ទល់ទ្រនោះឃើញថាមានប្រសិទ្ធិភាពហើយ ប៉ុន្តែផ្ទាំងថ្មមួយចំនួនដែលស្ថិតនៅផ្នែកខាងក្រៅនិងខាងលើ គួររៀបរយដាក់កន្លែងដើមវិញដើម្បីធានាបាននូវស្ថេរភាពរបស់រចនាសម្ព័ន្ធ។

បន្ទាប់ពីបទបង្ហាញរបស់លោកបណ្ឌិត ហាង់ ពៅ ស្តីពីទឹកមិនហូរ នៅផ្នែកខាងកើតកសិណអង្គរធំ យើងផ្តល់យោបល់ឲ្យពិនិត្យមើល ជាពិសេសប្រឡាយទាំងពីរនៅខាងកើត ដើម្បីរៀបចំគម្រោងសំដៅតភ្ជាប់កសិណខាងកើតទៅនឹងស្ទឹងសៀមរាប ការរៀបចំបែបនេះនឹងអាចឲ្យទឹកហូរទៅផ្នែកខាងក្រោម ឆ្ពោះទៅទិសខាងត្បូងនិងទៅកសិណអង្គរវត្ត។

បន្ទាប់មកទៀត យើងបានទៅមើលអង្គរវត្តមួយភ្លែតនៅពេលព្រលប់ថ្ងៃទី១៣ ខែធ្នូ។ លោកសាស្ត្រាចារ្យ Santoro បាននាំយើងទៅកាន់ខាងលើកំពូលនៃផ្នែកកណ្តាលរបស់ប្រាសាទ។ នៅផ្នែកខាងលិចរបស់ប៉មកណ្តាល យើងឃើញសសរទ្រហោជាងមានស្នាមប្រេះតាមបណ្តោយសសរ ហើយត្រូវបានគេគ្រឹបទប់ដោយកងធ្វើពីដែក អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ផ្នែកទទឹងសសរទាំងនេះរួមតូចដោយសារតែថ្មសឹក។ ដូច្នេះ ត្រូវចាត់វិធានការណ៍បង្ការដើម្បីទប់ស្កាត់រាល់ការដួលរលំ។ បាយអសម្រាប់បិទភ្ជិតស្នាមប្រេះហាក់ដូចជាមិនមានប្រសិទ្ធិភាពធ្វើអោយសាច់ថ្មដែលដាច់ចេញពីគ្នានោះស៊ីគ្នាវិញ។ ដូច្នេះ គេបានផ្គុំផ្នែកប្រេះទាំងពីរដោយប្រើដែកថែបស៊កបញ្ចូលទៅក្នុងថ្ម។ ការជួសជុលបែបនេះត្រូវបានចាត់ទុកថាមានលក្ខណៈសមស្របនិងមានប្រសិទ្ធិភាព។

ហោជាងខាងលិចរបស់ប៉មធំទ្រេតចេញក្រៅ ដែលត្រូវតម្រង់ឲ្យត្រង់មកវិញដោយកៀបជុំវិញប្រទាញទៅទិសផ្ទុយ។ គេសំគាល់ឃើញថ្មក្បាច់លំអដែលលយចេញមកខាងក្រៅរង្គោះរង្គើ។ ដំណោះស្រាយមួយក្នុងចំណោមដំណោះស្រាយដែលគេអាចយកមកអនុវត្ត ដើម្បីពង្រឹងលំនឹងប៉មទាំងមូលនេះ គឺការប្រើសរសៃដែកថែប ឬ សរសៃកញ្ចក់។ ការសិក្សាបន្ថែមទៀតចាំបាច់ត្រូវធ្វើដើម្បីកាត់បន្ថយតាមដែលអាចធ្វើទៅបាន នូវផលប៉ះពាល់ចំពោះសោភណភាពដោយសារការជួសជុលផ្នែកខាងមុខនេះ។

ចំពោះអ្វីដែលទាក់ទងនឹងគ្រឹះនៃផ្នែកខាងលើរបស់រោងទងទីបី ត្រូវគិតគូរដាក់ប្រព័ន្ធបង្ហូរទឹកចេញ និងធ្វើយ៉ាងណាអោយមានផលប៉ះពាល់តិចបំផុតទៅលើផ្ទៃមុខ។ យើងក៏អាចគិតគូរផងដែរអំពីលទ្ធភាពនៃការប្រើដុំថ្មសៀតភ្ជិត។ សូមអរគុណ។

**កំណត់សម្គាល់របស់សហប្រធានបារាំង៖** មីក្រូរបស់សហប្រធានអត់ឮទៀតទេ។ ប៉ុន្តែមិនជាអ្វីទេ។ យើងបានស្តាប់របាយការណ៍ទាំង៤ របស់អ្នកជំនាញខាងការអភិរក្ស។ យើងមានរបាយការណ៍ទាំង១៨ របស់ក្រុមការងារបច្ចេកទេស។ តើមាននរណាម្នាក់ចង់បញ្ចេញយោបល់ ឬក៏និយាយអ្វីដែរឬទេ? ប្រើមីក្រូក៏បាន អត់ក៏បាន។

## IV.7 សំណួរ-ចម្លើយ ស្តីពីរបាយការណ៍សកម្មភាពទាក់ទងនឹងគម្រោងដែលអនុវត្តដោយក្រុមការងារអន្តរជាតិ (របាយការណ៍ត្រូវបានចែកជូន)

**សំណួររបស់លោកសាស្ត្រាចារ្យ Nakagawa ៖** សំណួររបស់ខ្ញុំគឺទាក់ទងនឹងគម្រោងជួសជុលគោបុរៈខាងលិចរបស់ក្រុមអ៊ីតាលី។ ខ្ញុំចង់ឲ្យលោកពន្យល់អំពីការដាក់ទុយយោបង្ហូរទឹក។ តើការដាក់ទុយយោបង្ហូរទឹកភ្លៀងចេញពីដំបូលប៉មដូច្នេះមានប្រសិទ្ធិភាពបែបណាទៅ? ខ្ញុំក៏ចង់ដឹងផងដែរថាតើពេលដាក់ហើយងាយរុះរើចេញឬទេ និងចង់ដឹងអំពីលទ្ធភាពនៃការញែកថ្មដាក់ទុយយោ និងភាពយូរអង្វែងនៃ សម្ភារៈដែលយកមកប្រើ។ សូមលោកចែករំលែកបទពិសោធន៍របស់លោកអំពីកិច្ចអន្តរាគមន៍ប្រភេទនេះ និងអំពីបច្ចេកទេសដែលបានប្រើប្រាស់ប្រសិនបើលោកធ្លាប់បានប្រើបច្ចេកទេសនេះរួចហើយ។ ប្រសិនបើអាច សូមលោកផ្តល់ទស្សនៈរបស់លោក ទាក់ទងនឹងបច្ចេកទេសដែលWMF យកទៅប្រើដើម្បីជួសជុលដំបូលរោងទងកូរសមុទ្រទឹកដោះនៅអង្គរវត្ត។ ហើយនៅក្នុងករណីនេះ បើលោកយល់ឃើញថាវាអាចចោទជាបញ្ហា សូមលោកប្រាប់យើងឲ្យបានដឹងផង។

យើងមានសេចក្តីសោមនស្សរីករាយដោយឃើញថា រន្ធរបស់យើងអាចបម្រើដល់ការដ្ឋានរបស់រមណីយដ្ឋាន IGeS។ ក្រុមការងារទាំងអស់គួរតែធ្វើកិច្ចសហប្រតិបត្តិការ និងធ្វើការការចែករំលែក អោយគ្នាខ្ទីទៅវិញទៅមកនូវ

គ្រឿងបរិក្ខារនិងសម្ភារៈរបស់ខ្លួន។ ពីព្រោះវាច្បាស់ណាស់ថា យើងនៅទីនេះ គឺដើម្បីធ្វើកិច្ចសហប្រតិបត្តិការនិងនាំក្រុមការងារកម្ពុជាឆ្ពោះទៅកាន់ស្វ័យភាព។ នៅក្នុងទស្សនៈនេះ តម្រូវការចាំបាច់ដើម្បីឈានទៅរកស្វ័យភាព គឺត្រូវមានធនធានមនុស្សនិងគ្រឿងបរិក្ខារ។ នៅពេលអនាគតខ្លីខាងមុខនេះ យើងនឹងត្រូវការឈានទៅដល់កិច្ចព្រមព្រៀងមួយរវាងគ្រប់ក្រុមបច្ចេកទេសទាំងអស់។

នៅការដ្ឋានបាយ័ន រឿងមួយទៀតដែលយើងចងចាំទុក គឺមិនត្រូវរំខានអ្នកទេសចរដោយសារតែការងាររបស់យើងទេ។ ប៉ុន្តែនៅមានបញ្ហាដែលមានសារៈសំខាន់និងដែលទាក់ទងនឹងអង្គរទាំងមូល ហើយដែលយើងត្រូវតែយកចិត្តទុកដាក់ចំពោះបញ្ហាទាំងនោះ។ ខ្ញុំសង្កត់ធ្ងន់លើចំណុចនេះព្រោះថា គោបូរៈដែលជួសជុលនោះបែរមុខទៅរកទិសខាងលិច ដែលនៅទីនោះមានពន្លឺថ្ងៃដ៏ល្អបំផុតដែលអ្នកទេសចរចូលចិត្ត។ ដូច្នេះ ប្រហែលជាគួរប្រើពណ៌ប្រផេះលាបលើសំណង់ការដ្ឋាន ឬពណ៌ណាមួយដែលស៊ីគ្នានឹងប្រាសាទ។ ចំណុចចុងក្រោយ ខ្ញុំបានលើកឡើងរួមមកហើយ គឺគួរតែមានវត្តមានជនជាតិខ្មែរច្រើនជាងនេះនៅក្នុងកិច្ចប្រជុំរបស់ CIC ទោះជាខ្ញុំយល់ថាមានបញ្ហាទាក់ទងនឹងកន្លែងក៏ដោយ។ ប៉ុន្តែខ្ញុំសូមអរគុណ ប្រសិនបើអាចពិនិត្យមើលអំពីលទ្ធភាពផ្សាយបន្តផ្ទាល់នូវការប្រជុំនេះទៅកន្លែងណាមួយទៀតដើម្បីឲ្យជនជាតិខ្មែរក្មេងៗដែលចង់ចូលរួមក្នុងកិច្ចប្រជុំទាំងនេះ អាចចូលរួមបានតាមរយៈការមើលកញ្ចក់ទូរទស្សន៍។ លើសពីនេះទៅទៀតនោះ ខ្ញុំយល់ឃើញថាការពិសារអាហារថ្ងៃត្រង់មិនគួរមានទេ ហើយប្រាក់នេះគួរតែចំណាយសម្រាប់ការលើកតម្កើងអ្នកជំនាញជនជាតិខ្មែរវិញប្រសើរជាង។

**ចម្លើយរបស់លោក Azedine Beschaouch៖** វាពិតណាស់ថា បញ្ហាដែលលោកសាស្ត្រាចារ្យ Nakagawa ទើបលើកឡើងអំបាញ់មិញ មានសារៈសំខាន់បំផុត។ ខ្ញុំចង់និយាយថា នៅក្នុងអំឡុងពេលនៃការទស្សនាប៉មកណ្តាលអង្គរវត្តជាមួយលោកអគ្គវិស្វករ Santoro យើងបានចោទសួរសំណួរដូចគ្នា។ លោក Santoro ខ្លួនឯងមិនបានលាក់បាំងការលំបាកដែលលោកជួបប្រទះទេ ជាពិសេសនោះ ចំពោះបញ្ហាការបង្ហូរទឹកចេញ។ល។

ប្រសិនបើលោកសហប្រធានមិនជំទាស់ទេនោះ ខ្ញុំសូមស្នើដូច្នេះ ព្រោះថាបញ្ហាទាំងអស់នេះមានសារៈសំខាន់បំផុត ហើយក្រុមការងារជាច្រើនមានពាក្យរបស់ខ្លួនដែលត្រូវនិយាយ ឬក៏រង់ចាំដំណោះស្រាយរួមមួយ ដោយហេតុថាគឺមិនមែនម្នាក់ៗរកដំណោះស្រាយដោយខ្លួនឯងនោះទេ។ ដូច្នេះ ដោយសារតែវាមានលក្ខណៈបច្ចេកទេសខ្លាំង ហើយដោយសាររឿងនេះមិនអាចដោះស្រាយបានក្នុងរយៈពេលចំនួនប្រាំនាទីនោះ ខ្ញុំសូមស្នើឲ្យលេខាធិការដ្ឋានរបស់លោក លោកស្រី កត់ត្រាទុកនូវបញ្ហាទាំងអស់នេះ។ ហើយសម្រាប់សម័យប្រជុំបច្ចេកទេសលើកក្រោយ យើងនឹងរៀបចំឯកសារមួយដែលនឹងគិតដល់ទស្សនៈទើបនឹងលើកឡើងនេះ។ ហើយខ្ញុំសូមសង្កត់ធ្ងន់លើចំនុចនេះ គឺមិនត្រឹមតែទស្សនៈរបស់លោកសាស្ត្រាចារ្យ Nakagawa ប៉ុណ្ណោះទេ មានក្រុមការងារជាច្រើនទៀតយល់ស្របជាមួយលោក។ ហើយយើងនឹងដាក់ចំណុចនេះនៅក្នុងរបៀបវារៈប្រជុំលើកក្រោយ ព្រោះរឿងនេះទាក់ទងនឹងវិធីសាស្ត្រនិងអនាគតនៃការងារខ្លះៗទៀត។

ចំណុចចុងក្រោយគឺជាបញ្ហាលុយកាក់។ វាជាការជាក់ស្តែងណាស់ យើងទាំងអស់គ្នាមានចំនួន២៨០នាក់ទៅហើយ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំ ប្រសិនបើសាលប្រជុំអាចដាក់មនុស្សបានចំនួន៤០០នាក់ យើងនឹងមានគ្នាចំនួន៤០០នាក់បាត់ទៅហើយ។ ប្រសិនបើយើងបដិសេធមិនទទួលមនុស្ស គឺមិនមែនដោយសារពួកគេមានវ័យក្មេងឬចាស់នោះទេ។ ជាដំបូង ក្រុមបច្ចេកទេសត្រូវមានវត្តមាន។ មួយផ្នែកទាំងអស់នោះសុទ្ធតែជាជនជាតិខ្មែរ។ មិនត្រូវនិយាយថានៅទីនេះ គឺមានតែជនបរទេសនោះទេ។ យើងគ្រាន់តែគិតថា សម្រាប់សម័យប្រជុំបច្ចេកទេស គឺមិនមែន

សម្រាប់សម័យប្រជុំពេញអង្គទេ ព្រោះថាយើងបានរំឭករឿងនេះរួចហើយ សម័យប្រជុំពេញអង្គ ទាក់ទងជាបឋមទៅនឹងការតំរែតម្រង់ទិសផ្នែកនយោបាយ។ ប៉ុន្តែសម្រាប់សម័យប្រជុំបច្ចេកទេស ទំរាំដល់មានសាលប្រជុំធំជាងនេះ យើងគួរតែគិតដល់បញ្ហានៃការប្រើប្រាស់វីដេអូនេះ។ល។ ប៉ុន្តែរឿងនេះវាទាមទារលុយកាក់។ ប្រសិនបើខ្ញុំអាចនិយាយបាន យើងនឹងបង្ហាញវិក្កយបត្រជូន។ ហើយយើងនឹងពិនិត្យមើលថាតើយើងទទួលបានមធ្យោបាយដើម្បីធ្វើដូច្នេះដែរឬទេ។ សូមអរគុណលោកសាស្ត្រាចារ្យ Nakagawa ប៉ុន្តែយើងដែលជាលេខាធិការដ្ឋាន យើងមិនអាចសម្រេចរឿងនេះបានទេ។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់លោក Lablaude ៖** ខ្ញុំសូមលើកឡើងនូវចំណុចមួយដែលយើងមិនទាន់បាននិយាយទេរហូតមកទល់ពេលនេះ ប៉ុន្តែក៏ទាក់ទងផងដែរនឹងអង្គរវត្ត អត្ថន័យ របកគំហើញនិងថែមទាំងរូបភាពរបស់អង្គរវត្តផងដែរ។ នៅអង្គរវត្ត មានការដ្ឋានរបស់ក្រុមការងារផ្សេងៗដែលកំពុងតែដំណើរការ ហើយយើងគ្មានអ្វីក្រៅពីសម្តែងសេចក្តីសោមនស្សរីករាយចំពោះរឿងនេះទេ។ ប៉ុន្តែនៅក្នុងដំណើរការបច្ចុប្បន្នរបស់រមណីយដ្ឋាន មានអ្វីមួយដែលខ្ញុំយល់មិនសូវយល់សោះ។ កាលពីប៉ុន្មានឆ្នាំមុន យើងបានសង្កេតឃើញថាគឺពិតជាមានបញ្ហាសុវត្ថិភាព សម្រាប់ការឡើងទៅកាន់កំពូលបាកាន នៅផ្នែកខាងលើ។ ហើយដោយហេតុដូច្នេះ នៅក្នុងពេលជាមួយគ្នានោះ គេបានបង្ហាញនូវគម្រោងមួយចំនួនទាក់ទងនឹងការសាងសង់ជណ្តើរដែលគេបានធ្វើការជជែកពិភាក្សាគ្នា និងដែលអាចឲ្យគេឡើងរហូតដល់ផ្នែកខាងលើ។ គម្រោងទាំងនោះត្រូវបានពិនិត្យ ធ្វើការប្រៀបធៀបនិងផ្តល់ការយល់ព្រម។ ជណ្តើរមួយត្រូវបានសាងសង់ដោយអាជ្ញាធរអប្សរាដែលពិតជាឆ្លើយតបទៅនឹងលក្ខខណ្ឌសុវត្ថិភាពទាំងនេះបាន។ ការសាងសង់ជណ្តើរនៅកន្លែងនោះមិនប៉ះពាល់ដល់សោភណភាពរបស់ប្រាសាទទេ។ ប្រសិនបើខ្ញុំមិនយល់ច្រឡំទេនោះ ជណ្តើរនោះត្រូវបានសាងសង់រួចកាលពីពីរឬបីឆ្នាំមុន។ ហើយចាប់តាំងពីជណ្តើរនោះត្រូវបានសាងសង់រួចមក គេនៅតែមិនអាចឡើងទៅកាន់ផ្នែកខាងលើបាកានបានដដែល។ ដូច្នេះ ខ្ញុំគិតថានៅត្រង់ចំណុចនេះ គឺមានអ្វីមួយដែលពិបាកយល់បន្តិច បើគេមើលពីខាងក្រៅទៅ គឺថាភ្ញៀវម្នាក់ដែលមកកាន់អង្គរ តើធ្វើយ៉ាងម៉េច ទើបគាត់អាចយល់បានទៅ? គេមិនអាចឡើងទៅកាន់កន្លែងដ៏សំខាន់បំផុតនៃប្រាសាទមួយនោះ?

វាពិតជាដូចគ្នានឹងការដែលលោកទៅទស្សនាព្រះរាជវាំង Versailles ហើយគេប្រាប់លោកថាលោកមិនអាចចូលទៅមើលរោងទងអំពូលបានទេ។ ឬក៏ដូចគ្នានឹងការដែលលោកទៅមើលពីរ៉ាមីត Khéops ហើយគេប្រាប់លោកថាលោកមិនអាចចូលទៅមើលបន្ទប់រក្សាសាកសពបានទេ។ ឬដូចគ្នានឹងការដែលលោកទៅទស្សនា Saint-Pierre នៅទីក្រុងរ៉ូម ហើយគេប្រាប់លោកថា៖ "សូមមើលពីក្រៅទៅបានហើយ"។ ឬមួយក៏ទៅ Machu Picchu ហើយគេប្រាប់លោកថា ៖ "លោកត្រូវនៅខាងក្រោម" ត្រង់ Aguas Calientes ទៅ ហើយលោកសម្លឹងមើល Machu Picchu ពីខាងក្រោម។ ដូច្នេះ ខ្ញុំគិតថា នៅត្រង់ចំណុចនេះ គឺពិតជាមានបដិវាទកម្មមួយដែលត្រូវតែដោះស្រាយឲ្យបានឆាប់រហ័សបំផុត ព្រោះថានេះជាអ្វីមួយដែលអាចនាំឲ្យខូចប្រយោជន៍ដល់រូបភាពជាលក្ខណៈអន្តរជាតិរបស់អង្គរ ទាំងសម្រាប់ភ្ញៀវក៏ដូចជាសម្រាប់អ្នកទទួលខុសត្រូវនិងអ្នកឯកទេសទាំងអស់ខាងបេតិកភណ្ឌ។

**បទអន្តរាគន៍របស់សាស្ត្រាចារ្យ Hidaka ៖** ខ្ញុំសូមសារភាពអំពីការខ្វះខាតបទពិសោធន៍របស់ខ្ញុំ ចំពោះអ្វីដែលទាក់ទងនឹងកម្រិតទឹកភ្លៀងនៅសៀមរាបនេះ។ ដូច្នេះ រឿងទីមួយដែលខ្ញុំត្រូវធ្វើ គឺពិនិត្យមើលស្ថានភាពរបស់ប្រាង្គប្រាសាទនានានៅក្នុងរដូវភ្លៀង។ យើងពិតជាត្រូវការទិន្នន័យជាក់ស្តែងពិតប្រាកដ ហើយត្រូវពិនិត្យកម្រិតនៃការហូរទឹកភ្លៀងទៅផ្នែកខាងក្នុង។ ប្រហែលជានឹងមានការលំបាកផងដែរក្នុងការប្រើម៉ាស៊ីនវាស់ដោយពន្លឺ Infra Red។ ប៉ុន្តែខ្ញុំចង់

ប្រើសាកមើល។

បើខ្ញុំសង្កេតមើលប្រាសាទនៅពេលឥឡូវនេះដែលស្ថិតនៅក្នុងរដូវប្រាំងនោះ ខ្ញុំមិនមានអារម្មណ៍មិនល្អនោះទេ ជាអាទ៏ប្រសិនបើខ្ញុំធ្វើការប្រៀបធៀបជាមួយនឹងការលំបាកដែលខ្ញុំជួបប្រទះនៅរមណីយដ្ឋានរបស់ខ្ញុំនៅទីក្រុង Istanbul ស្ថិតក្នុងប្រទេសតួគី។ ដំបូលរបស់ Sainte Sophie ដែលត្រូវបានសាងសង់ឡើងនៅសតវត្សទីVI ដោយអធិរាជ មានការជ្រាបទឹកដ៏ធ្ងន់ធ្ងរ រួមជាមួយនឹងស្នាមសំណើមមួយឆ្នាំពេញមួយឆ្នាំ។ ដោយហេតុដូច្នេះហើយបានជាខ្ញុំចង់បន្តការសិក្សាស្រាវជ្រាវរបស់ខ្ញុំ ហើយលើកនេះគឺជាការស្រាវជ្រាវលើប្រាសាទមួយដែលមានទំហំធំទូលាយជាងមុន។ ខ្ញុំមានការសោកស្តាយដោយអាចផ្តល់តែចម្លើយមួយដែលមានលក្ខណៈទូទៅប៉ុណ្ណោះ។ យើងក៏អាចចាត់ទុកថា បញ្ហានៃការជ្រាបទឹកនេះគឺមាននៅគ្រប់ប្រាសាទធំៗក្នុងតំបន់នេះ។ ដូច្នេះ យើងត្រូវតែបើកចំហរចំពោះរាល់សំណើរៀបចំរោងជាងដើម្បីដោះស្រាយបញ្ហានេះ។

**ចម្លើយរបស់លោកសាស្ត្រាចារ្យ Croci ៖** ខ្ញុំសូមនិយាយខ្លីៗ ព្រោះពេលវេលាចេះតែរំកិលទៅមុខហើយ។ ដូចដែល WMF បានស្នើឡើងនៅក្នុងអំឡុងពេលនៃការទស្សនាប្រាសាទភ្នំបាខែង រោងជាងមួយនឹងត្រូវបានរៀបចំធ្វើឡើងដើម្បីពិភាក្សាអំពីបញ្ហារចនាសម្ព័ន្ធ ភាពរង្គោះរង្គើ ការរុះរើ ការជួសជុល។ល។ នៅបាខែង ក៏មានបញ្ហាទាក់ទងនឹងការជ្រាបទឹកដែរ ដែលប៉ះពាល់ដល់ប្រាសាទទាំងមូល។ លើសពីនេះទៅទៀតនោះ គឺមិនត្រឹមតែមានការលំបាកផ្នែកបច្ចេកទេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការលំបាកដែលទាក់ទងនឹងសោភណភាពផងដែរ ព្រោះថាយើងមិនចង់ឲ្យមានប្រហោងនៅតាមជញ្ជាំងទេ។ ដូច្នេះ ត្រូវតែរកឲ្យឃើញដំណោះស្រាយមួយ ដោយប្រហែលជាត្រូវបិទភ្ជិតមុខតំណា។ ដូច្នេះ ជាសេចក្តីសន្និដ្ឋាន ខ្ញុំសូមផ្តល់យោបល់ឲ្យឆ្លៀតឱកាសពីការអញ្ជើញរបស់ WMF ដើម្បីរៀបចំរោងជាងនេះ ដើម្បីនឹងនិយាយអំពីបញ្ហាជ្រាបទឹកនេះ យើងនឹងបានស្តាប់បទពិសោធន៍ខុសៗគ្នាដែលធ្លាប់បានជួប ហើយយើងត្រូវផ្តល់លទ្ធផលនៃរោងជាងនេះ ដល់គ្រប់មិត្តភ័ក្តិជនជាតិខ្មែរនិងអ្នកជំនាញរបស់យើង។ ខ្ញុំសូមអរគុណ។

**ចម្លើយរបស់លោក Santoro ៖** ខ្ញុំមិនមានសំណួរដែលត្រូវសួរនោះទេ ប៉ុន្តែខ្ញុំសូមឆ្លើយដោយខ្លីទៅនឹងសំណួររបស់លោកសាស្ត្រាចារ្យ Nakagawa។ យើងបានបង្ហាញនិងជម្រាបជូនជាច្រើនលើកច្រើនសារហើយ នៅក្នុងសម័យប្រជុំ CIC នេះ នូវកិច្ចអន្តរាគមន៍របស់យើងទាក់ទងនឹងការដាក់ទុយយោបង្ហូរទឹកចេញ ដែលអាចកាត់បន្ថយផលប៉ះពាល់លើប្រាសាទ ដោយដាក់ទុយយោនៅពីក្រោយថ្មភក់និងផ្ទាំងថ្មដែលស្ថិតនៅខាងក្រៅ ធ្វើយ៉ាងណាកាត់បន្ថយផលប៉ះពាល់និងនិងកុំអោយមើលឃើញ។ ចំពោះអ្វីដែលទាក់ទងនឹងភាពយូរអង្វែងរបស់ទុយយោ យើងបានដាក់ចម្រោះកុំអោយមានគ្រាប់ថ្មធំៗហូរកាត់ដែលអាចធ្វើអោយស្ទះ។ លទ្ធផលដែលទទួលបាន នៅពេលយើងជួសជុលផ្នែកខាងត្បូងនៃកសិណទិសខាងលិចអង្គរវត្ត បង្ហាញថា ប្រាំមួយឆ្នាំក្រោយមកគឺមិនមានសារធាតុរឹងហូរកាត់ចម្រោះ ធ្វើអោយស្ទះទេ ទោះជាមានទឹកហូរខ្លាំងអពីលើចុះមកក្រោមក៏ដោយ។ ដូច្នេះ បច្ចេកទេសនេះមិនត្រឹមតែទៅរួចនៅក្នុងការងារសាធារណៈធម្មតាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចប្រើសម្រាប់ការដ្ឋានជួសជុលនានាដូចជាករណីនៅទីនេះជាដើម។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង៖** ដូច្នេះ យើងបានកត់ត្រាទុកនូវបទអន្តរាគមន៍របស់អ្នកធ្វើបទបង្ហាញនានាមានជាអាទ៏សំណើរបស់លោកសាស្ត្រាចារ្យ Nakagawa។ ខ្ញុំសូមរំឭកថា បច្ចុប្បន្ននេះសម័យប្រជុំបច្ចេកទេសរបស់ CIC មានរយៈពេលចំនួន៤៨ម៉ោង គឺរយៈពេលចំនួនពីរថ្ងៃ គឺនៅជុំវិញការពន្យារពេលសម័យប្រជុំបច្ចេកទេស

នេះហើយ ដែលយើងអាចពន្យារកិច្ចដដែកពិភាក្សានិងកិច្ចសន្ទនាផ្សេងៗ។ ចំណែកឯសម័យប្រជុំពេញអង្គនៅខែធ្នូ គឺមានលក្ខណៈនយោបាយជាង។ ដោយសារតែសម័យប្រជុំពេញអង្គមានលក្ខណៈនយោយបាយជាង ទើបក្នុងសម័យប្រជុំនេះយើងបានគ្រោងបារពពិធីសម្ពធមួយ។ ហើយអ្វីដែលជាប្រភពនៃក្ដីកង្វល់ដ៏ធំសម្រាប់សហប្រធាន គឺសហប្រធានតែងតែគិតថា យើងនឹងមិនអាចធ្វើអ្វីៗទាំងអស់នៅថ្ងៃតែមួយបានទេ។ ពេលនោះ វាជំរុញឲ្យសហប្រធានធ្វើកិច្ចការមិនបានគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែមានកិច្ចប្រិតបត្តិការមួយរវាងប្រទេសជប៉ុននិងប្រទេសកម្ពុជានៅតានី ដែលយើងគួរតែគិតគូរ ទោះជាមានបញ្ហាពេលវេលាក៏ដោយ។ ដូច្នេះ ឥឡូវនេះ ខ្ញុំសូមស្នើលោក លោកស្រីអញ្ជើញទៅចូលរួមក្នុងការសម្ពោធន៍សារមន្ទីរកុលាលភាជន៍អង្គនេះ ដែលមានឈ្មោះជាភាសាអង់គ្លេសថា "the Angkor ceramic museum"។

ខ្ញុំក៏សូមស្នើឲ្យមានភាពប្រាកដនិយមផងដែរះ ដូច្នេះ ដើម្បីមានលក្ខណៈប្រាកដនិយមនោះ សម័យប្រជុំនៅពេលរសៀលនេះស្ដីពីការអភិវឌ្ឍប្រកបដោយចីរភាព នឹងចាប់ផ្ដើមនៅម៉ោងបីរសៀល។ គឺនៅម៉ោងបីរសៀល មិនមែននៅម៉ោងពីររសៀលទេ ព្រោះត្រូវតែមានភាពប្រាកដនិយម។ យើងមិនអាចធ្វើទៅរួចតាមរបៀបផ្សេងទៀតបានទេ។ ហើយអប្សរាបានគ្រោងទុកនូវរថយន្តធំៗចំនួនបីគ្រឿង។ ដូច្នេះ មានរថយន្តធំៗចំនួនបីគ្រឿងដែលនៅចាំដឹកលោក លោកស្រីទៅតានី ចាប់ពីពេលឥឡូវនេះទៅ។ សូមស្វាគមន៍ចំពោះអ្នកទាំងអស់គ្នា។ សូមអរគុណ។

## V. ការអភិវឌ្ឍប្រកបដោយចីរភាព

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង ៖** ហេតុអ្វីបានជាយើងមិនចាប់ផ្ដើមប្រជុំឡើងវិញនៅម៉ោង១៦ទៅ? បើចាប់ផ្ដើមប្រជុំនៅម៉ោង១៦ យើងនឹងឃាត់លោក Beschaouch មិនឲ្យនិយាយ ហើយនេះនឹងធ្វើឲ្យយើងចំណេញរយៈពេលមួយម៉ោង!

**ចម្លើយរបស់លោក Azedine Beschaouch ៖** ខ្ញុំនឹងធ្វើឲ្យលោកចំណេញពេលដល់ទៅមួយម៉ោងនិងម្ភៃនាទីឯណោះ។

**បទអត្ថាធិប្បាយរបស់សហប្រធានបារាំង ៖** ដូច្នេះ សូមអរគុណឯកឧត្តម សាស្ត្រាចារ្យហើយ ដែលធ្វើឲ្យយើងចំណេញពេលចំនួនមួយម៉ោងម្ភៃនាទី ដោយលោកមិននិយាយនៅពេលរសៀលនេះ។ នៅពេលនេះ គឺលោកឯកអគ្គរាជទូតជប៉ុនដែលត្រូវដឹកនាំសម័យប្រជុំបន្ត។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន ៖** យើងនឹងពិភាក្សាលើជំពូកទីបួនស្ដីពីការអភិវឌ្ឍប្រកបដោយចីរភាព។ ខ្ញុំជឿថាមានបទបង្ហាញរបស់ប្រទេសចំនួនបួន។ ជាបឋម ខ្ញុំសូមជូនវេទិកាទៅក្រសួងវប្បធម៌បារាំង គឺអ្នកតំណាងក្រសួងវប្បធម៌បារាំង លោក Lablaude។

## V.1 កិច្ចសហប្រតិបត្តិការរបស់ក្រសួងវប្បធម៌បារាំង នាយកដ្ឋានស្ថាបត្យកម្មនិងបេតិកភណ្ឌ (DAPA) ដោយលោក Pierre André Lablaude ក្រសួងវប្បធម៌និងទំនាក់ទំនង ប្រទេសបារាំង

សូមគោរពឯកឧត្តម លោកសហប្រធាន លោក លោកស្រី ជាទីគោរព!

ខ្ញុំសូមថ្លែងអំណរគុណដែលបានទុកពេលបួនប្រាំនាទីឲ្យខ្ញុំបានឡើងមកនិយាយ មិនមែនក្នុងនាមខ្លួនខ្ញុំផ្ទាល់ទេ ប៉ុន្តែខ្ញុំនឹងនាំសេចក្តីផ្តាំផ្ញើប្រកបដោយមិត្តភាពពីសំណាក់លោក Bruno FAVEL ប្រធាននាយកដ្ឋានកិច្ចការអឺរ៉ុប និងអន្តរជាតិ នៃអគ្គនាយកដ្ឋានបេតិកភណ្ឌ របស់ក្រសួងវប្បធម៌ និងគមនាគមន៍បារាំង ដែលលោកបានធ្លាក់ខ្លួនឈឺជាទម្ងន់ ភ្លាមៗ ពុំអាចមកចូលរួមជាមួយយើងទាំងអស់គ្នាបាននៅថ្ងៃនេះ ហើយលោកក៏សូម ឯកឧត្តម លោក លោកស្រីទាំងអស់គ្នាមេត្តាអភ័យទោសដល់រូបលោកផង។

លោកចង់រំឭក ចំពោះមុខអស់លោកអ្នកទាំងអស់គ្នា អំពីការចូលរួមនៃក្រសួងវប្បធម៌របស់យើងខ្ញុំ ដែលនៅជាប់ជាមួយសហការី និងមិត្តភក្តិទាំងឡាយ នៅក្រសួងការបរទេស ក្នុងគម្រោងផ្សេងៗ ដែលត្រូវបានបង្កើតឡើងដើម្បីអភិរក្សតំបន់ប្រាសាទអង្គរ និងពង្រីកកិច្ចសហប្រតិបត្តិការឲ្យបានទូលំទូលាយបំផុត ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

ជាមួយនឹងគោលដៅនោះ លោកក៏ចង់រំឭកផងដែរ ពីសកម្មភាពដែលដឹកនាំដោយក្រសួងវប្បធម៌និងគ្រឹះស្ថានសាធារណៈបារាំង ក្នុងការផ្តល់ភ្នាក់ងារ និងអ្នកជំនាញឯកទេសក្នុងវិស័យអភិរក្សបេតិកភណ្ឌ ឬបុរាណវិទ្យា។

លោកក៏ចង់ជម្រាបផងដែរអំពីមធ្យោបាយដែលត្រូវបានប្រមែប្រមូលជាញឹកញាប់ ដើម្បីទទួលស្វាគមន៍អ្នកជំនាញកម្ពុជាអោយទៅប្រទេសបារាំង ជាឧទាហរណ៍ យើងបានគ្រោងទុករួចហើយនូវការទទួលស្វាគមន៍ថ្នាក់ដឹកនាំជាន់ខ្ពស់នៃអាជ្ញាធរជាតិអប្សរាពីររូបនារដូវផ្ការីកខាងមុខនេះ។

លោកអាចនឹងជម្រាបជូនអស់លោកអំពីចំណុចទាំងនោះបានប្រសើរជាងខ្ញុំ ប្រសិនបើលោកមានវត្តមាននៅទីនេះ ៖ គឺអំពីអ្វីដែលបានធ្វើ អ្វីដែលកំពុងធ្វើ និងអ្វីដែលគ្រោងនឹងធ្វើ។

ខ្ញុំបានជួបលោកតាមទូរស័ព្ទ កាលពីល្ងាចម្សិលមិញ លោកក៏បានប្រាប់ខ្ញុំយ៉ាងច្បាស់ថា ចំណុចសំខាន់បំផុត ដែលត្រូវលើកឡើងនៅក្នុងកិច្ចប្រជុំនេះ គឺចំណុចទាក់ទងទៅនឹងការបណ្តុះបណ្តាល ពោល គឺការបណ្តុះបណ្តាល បណ្តុះបណ្តាលហើយ បណ្តុះបណ្តាលទៀត ព្រមទាំងការបន្ត និងការវិវត្តទៅមុខនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលតំបន់ផ្នែកបេតិកភណ្ឌបច្ចុប្បន្ន ដែល៖
–ឧបត្ថម្ភដោយក្រសួងការបរទេស ក្នុងក្របខណ្ឌនៃគម្រោង FSP
–ប្រតិបត្តិការដោយ École de Chaillot
–និងដែលការងារបូកសរុបនឹងមានបង្ហាញជូនអស់លោកអ្នក នៅពេលបន្តិចទៀតនេះ ដោយអ្នកស្រី ស៊ីសុវត្ថិ ចន្ទទេវី។

លើសពីលទ្ធផលសរុបដែលមានលក្ខណៈវិជ្ជមានគួរអោយទុកចិត្ត មានសំណួរមួយ ដែលត្រូវបានចោទ ឡើងសព្វថ្ងៃ

ដោយដៃគូសហការបារាំង ដែលបានចូលរួមក្នុងគម្រោងនេះ និងតាមរយៈសកម្មភាពនៃស្ថានទូតបារាំងប្រចាំនៅកម្ពុជា។ សំណួរនោះគឺថា ៖

តើត្រូវធ្វើបែបណាឲ្យជឿនលឿនទៅមុខកាន់តែខ្លាំងថែមទៀត នៅក្នុងការងារបណ្តុះបណ្តាលនេះ? តើត្រូវជួយ និងបំពេញបន្ថែមរបៀបដូចម្តេចទៀត ទៅលើលទ្ធផលជាច្រើនដែលទទួលបានរួចទៅហើយដោយសារមជ្ឈមណ្ឌលបណ្តុះបណ្តាលនេះ ក្នុងការជ្រើសរើស និងបង្រៀនជំនាញឯកទេសដល់យុវជន នៅក្នុងប្រទេសទាំងបីនៃអាស៊ីអាគ្នេយ៍ កម្ពុជា វៀតណាម ឡាវ ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលរួចហើយនោះ ?

តើត្រូវធ្វើយ៉ាងណាឲ្យការបណ្តុះបណ្តាល ស៊ីគ្នាកាន់តែខ្លាំងទៅនឹងសភាពជាក់ស្តែងនៃគម្រោង អនុវត្តនៅក្នុងប្រទេសទាំងបី? តើត្រូវធ្វើយ៉ាងណាជួយសម្រួលអោយសិស្សចាស់ៗអាចបំពេញការងារជាអាជីព? ដូចជាបញ្ជូននិស្សិតបារាំងនៅ École de Chaillot អោយមកចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈនេះ ក្នុងក្របខណ្ឌនៃការបង្កើតលំហាត់គម្រោងរួមគ្នាមួយ ក្រោមប្រធានបទណាមួយជាដើម ជាពិសេសនៅក្នុងតំបន់អង្គរ?

នេះហើយជាការត្រិះរិះពិចារណាដែលបើកចំហនាពេលបច្ចុប្បន្ន ហើយដែលក្រសួងវប្បធម៌បារាំងប្រាថ្នាចង់ចង់អោយដៃគូសហការរបស់ខ្លួនចូលរួមមតិយោបល់អោយបានកាន់តែច្រើននិងទូលំទូលាយបំផុត ។

កំណត់គម្រោងឲ្យបានច្បាស់ កំណត់លក្ខណៈសម្បត្តិនៃអ្នកដែលត្រូវបំពេញមុខងារក្នុងគម្រោង រៀបចំថវិកាជ្រើសរើសអ្នកដែលត្រូវបំពេញមុខងារក្នុងគម្រោងថ្មីនេះ ក្នុងរចនាសម្ព័ន្ធថ្មី នេះហើយជាដំណើរការដែលយើងត្រូវអនុវត្តចាប់ពីពេលនេះតទៅ។

ឯកឧត្តម សហប្រធាន អស់លោក លោកស្រី ជាទីគោរព!

មុននឹងបញ្ចប់ ខ្ញុំសូមបញ្ជាក់បន្ថែមពីលើសុន្ទរកថារបស់រដ្ឋមន្ត្រីយើងខ្ញុំ ដែលលោក BESCHAOUCH បានអានជូនកាលពីព្រឹកមិញនេះ ដោយជម្រាបជូនអ្នកទាំងអស់គ្នា អំពីការប្តេជ្ញាចិត្តរបស់លោក Bruno FAVEL និងភ្នាក់ងារទាំងអស់នៃក្រសួងវប្បធម៌បារាំងយើងខ្ញុំ ក្នុងន័យដូចបានជម្រាបជូនខាងលើនេះ។ សូមអរគុណ។

## V.2 កិច្ចសហប្រតិបត្តិការប្រទេសជប៉ុន៖ ស្ថានភាពនៅពេលបច្ចុប្បន្ននិងគម្រោងនាពេលអនាគតរបស់ JASA ដោយលោក Yosio Ando នាយកផ្នែកកិច្ចសហប្រតិបត្តិការវប្បធម៌ពហុភាគី ក្រសួងការបរទេស ប្រទេសជប៉ុន

សូមគោរពលោកសហប្រធាន! សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ! ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ លោកស្រី Rivière អគ្គនាយិការងរបស់យូណេស្កូ ឯកឧត្តម លោក លោកស្រីទាំងអស់ជាទីគោរពរាប់អាន!

ជាបឋម ខ្ញុំសូមថ្លែងអំណរគុណលោក លោកស្រីដែលបានផ្តល់ឱកាសឲ្យខ្ញុំធ្វើបទបង្ហាញដ៏ខ្លីស្តីពីសកម្មភាពនៃកិច្ចសហប្រតិបត្តិការរបស់ប្រទេសជប៉ុននៅអង្គរ។ នេះក៏ជាសេចក្តីរីករាយផងដែរដែលខ្ញុំបានមកតំណាងឲ្យក្រុមការងាររបស់រដ្ឋាភិបាលជប៉ុន ដែលទទួលខុសត្រូវលើការការពារអង្គរ សម្រាប់ CIC ដែលជាព្រឹត្តិការណ៍ដ៏ពិសេសនេះ។ អង្គរគឺជាបេតិកភណ្ឌដ៏មានប្រជាប្រិយបំផុតនៅប្រទេសជប៉ុន ក្នុងចំណោមបេតិកភណ្ឌដ៏មានប្រជាប្រិយភាពបំផុតនៅក្នុងពិភពលោក។ CIC បានដើរតួនាទីនិងបន្តដើរតួនាទីដ៏សំខាន់សម្រាប់ការសម្របសម្រួលកិច្ចសហ

ប្រតិបត្តិការអន្តរជាតិផ្សេងៗដែលធ្វើនៅអង្គរ។ ពិភពលោកទាំងមូលមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះរឿងនេះ។ យើងមានកិត្តិយសបំផុតដែលបានចូលរួមនៅក្នុងតួនាទីដ៏សំខាន់នេះ នៅក្នុងយន្តការរបស់ CIC នោះគឺតួនាទីសហប្រធាន។

លោកសហប្រធានជាទីគោរព។ ការអភិរក្សរមណីយដ្ឋាននិងប្រាង្គប្រាសាទអង្គរ ស្ថិតនៅជាកម្មវត្ថុដ៏មានតម្លៃបំផុតនៃគម្រោងសហប្រតិបត្តិការជប៉ុននានានៅក្នុងផ្នែកបេតិកភណ្ឌវប្បធម៌។ អស់រយៈពេលចំនួនដប់ប្រាំឆ្នាំមកហើយ យើងគាំទ្រអាជ្ញាធរកម្ពុជាតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដែលបានអនុវត្តន៍សម្រាប់ការពារនិងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌អង្គរ ដែលជាការងារដែលបានធ្វើឡើងដោយមានការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយដទៃទៀត នៅក្នុងក្របខណ្ឌរបស់ CIC។

ក្របខណ្ឌនៃការងារនេះត្រូវបានចាប់ផ្តើមធ្វើនៅឆ្នាំ១៩៩៣ បន្ទាប់ពី "សេចក្តីថ្លែងការណ៍ទីក្រុងតូក្យូ" ដែលត្រូវបានតាក់តែងឡើងនៅក្នុងសន្និសីទទីក្រុងតូក្យូនាឆ្នាំដដែលនោះ។ ប៉ុន្តែ សកម្មភាពរបស់ប្រទេសជប៉ុននៅក្នុងផ្នែកនេះមានជាអាទិ៍សកម្មភាពនៅក្នុងវិស័យឯកជនបានចាប់ផ្តើមតាំងពីមុនសម័យសង្គ្រាមស៊ីវិលទៅទៀត។ សកម្មភាពគាំទ្ររបស់ប្រទេសជប៉ុនដែលរួមចំណែកនៅក្នុងការអភិរក្សអង្គរ បានចាប់ផ្តើមនៅឆ្នាំ១៩៩៤ នៅក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយយូណេស្កូ។

សកម្មភាពទាំងនេះបានទទួលជំនួយពីយន្តការមួយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលជប៉ុន ហើយដែលត្រូវបានគេហៅថា JSA។ JSA គឺជាអក្សរកាត់ជាភាសាអង់គ្លេសនៃ "ក្រុមការងាររាជរដ្ឋាភិបាលជប៉ុនសម្រាប់ការអភិរក្សអង្គរ" (Japanese Government Team for Safeguarding Angkor) និងមានការចូលរួមពីសាកលវិទ្យាល័យ Waseda ដែលជាស្ថាប័នមួយក្នុងចំណោមស្ថាប័នមានបច្ចេកវិទ្យាទំនើបបំផុត នៅក្នុងវិស័យនេះ នៅប្រទេសជប៉ុន។

ដូច្នេះ សកម្មភាពទាំងនេះមានរយៈពេលចំនួនដប់ប្រាំឆ្នាំមកហើយ ហើយយើងចូលទៅក្នុងដំណាក់កាលទីបីនៃកិច្ចសហប្រតិបត្តិការ។ មានអ្នកជំនាញជនជាតិជប៉ុនចំនួនជាង៧០០នាក់ត្រូវបានបញ្ជូនមកប្រទេសកម្ពុជា ហើយពួកគេបានជួយពង្រឹងសមត្ថភាពរបស់សហសេវិកជនជាតិខ្មែរបានជាង២០០នាក់ នៅក្នុងផ្នែកជួសជុលនិងអភិរក្ស។ ថវិកាសរុបមានចំនួន 23 លាន8 សែនដុល្លារអាមេរិក។

ខ្ញុំសូមឆ្លៀតយកឱកាសនេះបង្ហាញជូនត្រួសៗអំពីអ្វីដែលក្រុម JSA សម្រេចបានកន្លងមក និងគម្រោងទៅថ្ងៃអនាគត។

[ស្លាយ] ដូចដែល លោក សោកស្រី ឃើញនៅលើអេក្រង់នេះស្រាប់ ដំណាក់កាលទីមួយនៃកិច្ចសហប្រតិបត្តិការរបស់ប្រទេសជប៉ុនបានចាប់ផ្តើមនៅឆ្នាំ១៩៩៤ ហើយបានបញ្ចប់នៅឆ្នាំ១៩៩៩។ ថវិកាមានចំនួន៩,៦លានដុល្លារអាមេរិក។

[ស្លាយ] ដំណាក់កាលទីមួយគឺការចាប់ផ្តើមការងារនៅរមណីយដ្ឋានបាយ័ន។ ដូច្នេះ សកម្មភាពជួសជុលនិងអភិរក្សត្រូវបានធ្វើនៅបណ្ណាល័យខាងត្បូងរបស់ប្រាសាទបាយ័ន ក្នុងអង្គរធំ។ កម្មវិធីរបស់យើងមិនមែនត្រឹមតែផ្តោតការយកចិត្តទុកដាក់ទៅលើផ្នែកជួសជុលនិងអភិរក្សប៉ុណ្ណោះទេ ប៉ុន្តែក៏មានទិសដៅធ្វើឲ្យធនធានមនុស្សមានការរីកចម្រើនផងដែរ។ ដូច្នេះ សកម្មភាពរបស់យើងក៏ផ្តោតទៅរកការពង្រឹងសមត្ថភាពរបស់អ្នកជំនាញខ្មែរនៅក្នុងជំនាញ

ទាំងនេះផងដែរ។

[ស្លាយ] គឺស្ថិតនៅក្នុងបរិបថនេះហើយដែលសិក្ខាសាលាមួយស្តីពីបាយ័ន ត្រូវបានរៀបចំឡើងនៅឆ្នាំ១៩៩៦ និងនៅឆ្នាំបន្តបន្ទាប់មកទៀត ដើម្បីធ្វើការជជែកពិភាក្សាលើក្របខណ្ឌការងារនៃគម្រោងមេផ្នែកអភិរក្សនិងជួសជុលប្រាសាទបាយ័នទាំងមូល។ ក្រុមការងារជប៉ុន ដោយមានកិច្ចសហប្រតិបត្តិការជាមួយយូណេស្កូ បានទទួលបន្ទុករៀបចំសិក្ខាសាលាទាំងនេះ។

[ស្លាយ] ដំណាក់កាលទីពីរនៃសកម្មភាពសហប្រតិបត្តិការរបស់ប្រទេសជប៉ុនបានចាប់ផ្តើមនៅឆ្នាំ១៩៩៩ ហើយបានបញ្ចប់នៅឆ្នាំ២០០៥។ សកម្មភាពទាំងនោះគឺជាសកម្មភាពជួសជុលនិងអភិរក្សរមណីយដ្ឋានប្រាសាទសួព្រ័ត្រ ដែលស្ថិតនៅទីលានមុខព្រះបរមរាជវាំងអង្គរធំ ព្រមទាំងបណ្ណាល័យខាងត្បូងរបស់អង្គរវត្ត។ ថវិកាសរុបមានចំនួនប្រហែល១១លានដុល្លារអាមេរិក។

ទន្ទឹមគ្នានេះ សកម្មភាពពង្រឹងសមត្ថភាពបានបន្តធ្វើ ហើយសិក្ខាសាលស្តីពីបាយ័ននៅបន្តរៀបចំរៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ២០០៤ ហើយយើងក៏បានបញ្ចប់ផងដែរនូវប្លង់មេសម្រាប់ការអភិរក្សនិងការជួសជុលបាយ័នទាំងមូល។

[ស្លាយ] តំណាក់កាលទីបីនៃគម្រោងជប៉ុនបានចាប់ផ្តើមនៅឆ្នាំ២០០៥ ហើយថវិកាមានចំនួន៣,៣លានដុល្លារអាមេរិក។គម្រោងនេះនៅកំពុងបន្តដំណើរការនៅឡើយ។

[ស្លាយ] នៅខែមិថុនា ឆ្នាំ២០០៦ គឺបន្ទាប់ពីការចាប់ផ្តើមដំណាក់កាលទីបីរបស់គម្រោងនៅខែឧសភា ឆ្នាំ២០០៥ បន្តិច ប្លង់មេស្តីពីការអភិរក្សនិងការជួសជុលប្រាសាទបាយ័នទាំងមូលត្រូវបានបោះពុម្ពផ្សាយ ដូចដែលបានពន្យល់ខាងលើរួចមកហើយ។

ផ្អែកលើប្លង់មេនេះ យើងបាននិងកំពុងអនុវត្តគម្រោងតំណាក់លាកទីបី គឺមានការជួសជុលបណ្ណាល័យខាងត្បូងរបស់បាយ័ន គម្រោងស្រាវជ្រាវស្តីពីវិធីអភិរក្សចម្លាក់នៅថែវផ្នែកខាងក្នុងបាយ័ន និងការស្រាវជ្រាវទៅលើស្ថេរភាពរបស់ប្រាសាទបាយ័នទាំងមូល។

[ស្លាយ] ចាប់តាំងពីឆ្នាំ១៩៩៤មក អ្នកជំនាញជប៉ុនចំនួនជាង៧០០នាក់បានធ្វើដំណើរមកកាន់រមណីយដ្ឋាន ហើយបានចូលរួមចំណែកនៅក្នុងគម្រោង។ ចាប់តាំងពីតំណាក់កាលទីបីរបស់គម្រោងមក ក្រុមការងារជប៉ុនបានសហការផ្ទាល់ជាមួយអាជ្ញាធរកម្ពុជានោះគឺអាជ្ញាធរអប្សរា។ ដូច្នេះ ដើម្បីអភិវឌ្ឍន៍ការពង្រឹងសមត្ថភាពរបស់អ្នកជំនាញខ្មែរ ក្រុមការងារចម្រុះថ្មីមួយត្រូវបានបង្កើតឡើងជាមួយអប្សរា។

[ស្លាយ] ក្រុមការងារថ្មីនេះត្រូវបានដាក់ឈ្មោះថា JASA ដែលជាក្រុមការងាររបស់ប្រទេសជប៉ុននិងអប្សរាសម្រាប់ការអភិរក្សអង្គរ (Japan-APSARA team for the Safeguarding of Angkor)។ គោលដៅរបស់គម្រោងនេះគឺពង្រឹងការអភិវឌ្ឍធនធានមនុស្សនៅប្រទេសកម្ពុជា និងធ្វើការផ្ទេរការងារជំនាញជប៉ុនទៅឲ្យអាជ្ញាធរអប្សរា។

ដោយសារតែបុគ្គលិកខ្មែរនិងជប៉ុនបានចូលរួមជាមួយគ្នានិងធ្វើការរួមគ្នានេះ យើងទទួលបានភាពជឿនលឿនជាច្រើននៅក្នុងវិស័យនេះ។

[ស្លាយ]   ប្រទេសជប៉ុនក៏បានជួយគាំទ្រផងដែរចំពោះគម្រោងបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈទីក្រុងភ្នំពេញ ហើយនិស្សិតជាង២០០នាក់បានទទួលសញ្ញាបត្រ នៅក្នុងវិស័យអភិរក្សនិងជួសជុល ពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៧។

អ្វីដែលខ្ញុំទើបបានបង្ហាញជូនលោក លោកស្រី គឺសកម្មភាពដែលក្រុមការងារជប៉ុនបានធ្វើរហូតដល់ពេលបច្ចុប្បន្ននេះនិងគម្រោងរហូតដល់ឆ្នាំ២០១១ ដែលមានការចូលរួមដោយផ្ទាល់ពីសំណាក់អាជ្ញាធរកម្ពុជា ព្រមទាំងមានកិច្ចសហប្រតិបត្តិការជាមួយយូណេស្កូ។

លោក លោកស្រីជាទីគោរព។ ឥឡូវនេះ ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីជម្រាបជូនលោក លោកស្រីអំពីគំនិតសម្រាប់តំណាក់កាលបន្តរបស់កិច្ចសហប្រតិបត្តិការជប៉ុននៅអង្គរ។

[ស្លាយ] នៅពេលដែលដំណាក់កាលទីបីរបស់គម្រោងត្រូវបានបញ្ចប់ ដូចដែលបានគ្រោងទុកនៅឆ្នាំ២០១១ហើយនោះប្រទេសជប៉ុននឹងបន្តគាំទ្រទៀត។ ប៉ុន្តែ យើងត្រូវធ្វើការពិភាក្សាជាមួយអាជ្ញាធរកម្ពុជាដែលមានសមត្ថកិច្ចនិងយូណេស្កូ ជាមុនសិន អំពីគម្រោងរបស់យើងសម្រាប់ដំណាក់កាលបន្តទៀត។ ប៉ុន្តែខ្ញុំអាចបញ្ជាក់ចាប់ពីពេលនេះតទៅថា នៅក្នុងតំណាក់កាលបន្ទាប់នៃកម្មវិធីរបស់យើងដែលនឹងមានរយៈពេលចំនួនប្រាំឆ្នាំដែលចាប់ផ្តើមនៅឆ្នាំ២០១១ យើងនឹងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើតម្រូវការនៃការបណ្តុះបណ្តាលអ្នកជំនាញខ្មែរ នៅក្នុងផ្នែកដែលបានលើកឡើងរួចមកហើយ។ ការងារជួសជុលប្រាសាទបាយ័ននឹងបន្តធ្វើតទៅទៀត ព្រមទាំងការងារនៅរមណីយដ្ឋានដទៃទៀតនៅអង្គរ។ ហើយទន្ទឹមគ្នានេះដែរ យើងក៏មានគំនិតមួយអំពីការងារបណ្តុះបណ្តាល។

នៅក្នុងផ្នែកជួសជុលនិងអភិរក្សរមណីយដ្ឋាន យើងគ្រោងនឹងបន្តការងារនៅក្នុងដំណាក់កាលបច្ចុប្បន្ននៃកម្មវិធីរបស់យើងទៀត។ ចំពោះអ្វីដែលទាក់ទងនឹងការអភិវឌ្ឍធនធានមនុស្ស យើងចង់គាំទ្រដល់សកម្មភាពអភិរក្សដោយឈរលើមូលដ្ឋានគ្រឹះយូរអង្វែង។ គំនិតរបស់យើងគឺថាចង់បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលមួយដែលមានបង្រៀនអំពីផ្នែកជួសជុលនិងអភិរក្ស។

ដោយសារហិរញ្ញប្បទានបន្ថែមរបស់រាជរដ្ឋាភិបាលរបស់យើង យើងមានបំណងផ្តល់គ្រឿងបរិក្ខារនិងសម្ភារៈដែលអាចជួយដល់ការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាលមួយនៅក្នុងការិយាល័យJASAបច្ចុប្បន្ន។ វិទ្យាស្ថាននេះនឹងផ្តល់លទ្ធភាពបណ្តុះបណ្តាលដល់អ្នកជំនាញខ្មែរនៅក្នុងផ្នែកផ្សេងៗនៃការអភិរក្សនិងជួសជុលសម្បត្តិវប្បធម៌។ យើងយល់ថាទាំងនេះគឺជាមូលដ្ឋានគ្រឹះយូរអង្វែងសម្រាប់អាជ្ញាធរកម្ពុជា ដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការអភិរក្សរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរដ៏អស្ចារ្យ។

តាំងពីពេលចាប់ផ្តើមដំបូងមក ក្រុមការងារជប៉ុនចាត់ទុកការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលអ្នកជំនាញនិងអ្នកបច្ចេកទេសជនជាតិខ្មែរជាគម្រោងសំខាន់មួយ ជាពិសេស ដោយមានការសហការជាមួយអាជ្ញាធរអប្សរា យើងបានធ្វើការផ្ទេរជំនាញ បច្ចេកទេសនិងចំណេះដឹងប្រកបដោយជោគជ័យគួរអោយកត់សម្គាល់។

យើងសង្ឃឹមថានាពេលអនាគត ចំណេះដឹងនិងធនធានមនុស្សដែលទទួលបាននៅក្នុងវិស័យនេះនឹងបម្រើមិនត្រឹមតែសម្រាប់គម្រោងការពារនានានៅអង្គរនិងនៅប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់គម្រោងប្រភេទដូចគ្នានេះនៅតាមបណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គផងដែរ។

ធ្វើរបៀបនេះ យើងនឹងសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព នៅក្នុងវិស័យអភិរក្សសម្បត្តិវប្បធម៌។

មុននឹងបញ្ចប់ ខ្ញុំសូមនិយាយដោយសង្ខេបអំពីសកម្មភាពដទៃទៀតរបស់ប្រទេសជប៉ុននៅអង្គរ។ លោក លោកស្រី មិនមែនមិនដឹងទេថា សាកលវិទ្យាល័យ Sophia កំពុងអនុវត្តកម្មវិធីមួយស្តីពីការអប់រំប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ហើយវិទ្យាស្ថាន Nara កំពុងត្រៀមចាប់ផ្តើមការជួសជុលប្រសាទប្រាសាទតុបខាងលិច។ វិទ្យាស្ថានតូក្យូធ្វើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រស្តីពីចម្លាក់នៅប្រាសាទតាណី រីឯ អ្នកជំនាញរបស់ JICA ធ្វើការងារអភិវឌ្ឍផ្នែកសង្គមសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាននៅក្នុងតំបន់។

លោកសហប្រធានជាទីគោរព! ជាទីបញ្ចប់ ខ្ញុំសូមគូសបញ្ជាក់ម្តងទៀតអំពីជំហររបស់រាជរដ្ឋាភិបាលជប៉ុនក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាសម្រាប់ការអភិរក្សបេតិកភណ្ឌវប្បធម៌នៅអង្គរ ព្រមទាំងសម្បត្តិវប្បធម៌រូបិយ ដើម្បីផ្ទេរដល់មនុស្សជំនាន់ក្រោយៗ ដោយមានការចូលរួមពីគ្រប់ដៃគូជប៉ុនទាំងអស់។ CIC ដើរតួនាទីដ៏ចម្បងក្នុងឋានៈជាអង្គការសម្របសម្រួល។ ខ្ញុំសង្ឃឹមថា CIC នឹងបន្តជួយដល់គ្រប់ភាគីទាំងអស់ដែលចូលរួមនៅក្នុងសកម្មភាពអភិរក្សដ៏មានតម្លៃនៅអង្គរនេះ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើនលោក Ando ចំពោះបទបង្ហាញរបស់លោកដែលងាយស្រួលយល់និងមានលក្ខណៈពេញលេញស្តីពីការងាររបស់រដ្ឋាភិបាលជប៉ុន។ បន្ទាប់មកទៀត ខ្ញុំសូមជូនវេទិកាទៅអ្នកតំណាងរបស់ប្រទេសនូវែលហ្សេឡង់ ដើម្បីនិយាយអំពីកិច្ចសហប្រតិបត្តិការរបស់ប្រទេសនូវែលហ្សេឡង់។ ជាបឋមគឺឯកឧត្តម អ៊ុក សុម៉េត ជាទីប្រឹក្សារបស់ប្រធានអាជ្ញាធរជាតិអប្សរា ហើយបន្ទាប់មកទៀតគឺលោក Philippe Hewitt អ្នកតំណាង NZAID។ សូមអញ្ជើញឯកឧត្តម អ៊ុក សុម៉េត ឡើងមានប្រសាសន៍។

## V.3 កិច្ចសហប្រតិបត្តិការរបស់ប្រទេសនូវែលហ្សេឡង់៖ ជំនួយរបស់ប្រទេសនូវែលហ្សេឡង់សម្រាប់ការអភិវឌ្ឍសហគមន៍ ដើម្បីការពាររមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ដោយឯកឧត្តម អ៊ុក សុម៉េត ទីប្រឹក្សាប្រធានអាជ្ញាធរជាតិអប្សរា និង លោក Philip Hewitt លេខាធិការទីមួយនិងជាតំណាង ស្ថានទូតប្រទេសនូវែលហ្សេឡង់ នៅទីក្រុងបាងកក

### លោក អ៊ុក សុម៉េត៖

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី សូមគោរពលោកសហប្រធាន!

ខ្ញុំមានកិត្តិយសជម្រាបជូនអំពីសភាពជឿនលឿនទៅមុខរបស់គម្រោងមួយដែលមានឈ្មោះថា គម្រោងអភិវឌ្ឍន៍សហគមន៍នៅក្នុងរមណីយដ្ឋានអង្គរ។ គម្រោងនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយប្រទេសនូវែលហ្សេឡង់។ដោយមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាពលរដ្ឋ ពីអាជ្ញាធរអប្សរា និងពីប្រទេសនូវែលហ្សេឡង់នោះ

ដំណាក់កាលទីមួយរបស់គម្រោងត្រូវបានវាយតម្លៃថាទទួលបានជោគជ័យ។

ហេតុអ្វីបានជាទទួលបានជោគជ័យ? គឺដោយសារតែទិសដៅទាំងអស់ត្រូវបានផ្សាភ្ជាប់គ្នានៅក្នុងគម្រោងទាំងមូល។ ទិសដៅទីមួយគឺធ្វើឲ្យប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរចូលរួមនៅក្នុងការអភិវឌ្ឍទេសចរណ៍។ នៅក្នុងន័យនេះកម្រៃដែលបានមកពីការអភិវឌ្ឍទេសចរណ៍ ឬក៏កំណើនដែលមានទំនាក់ទំនងនឹងការអភិវឌ្ឍត្រូវបានចែកជូនដោយស្មើភាពដល់ប្រជាពលរដ្ឋ។ ហេតុដូច្នេះ យើងសង្ឃឹមថាអាចកាត់បន្ថយគម្លាតនៃភាពក្រីក្រ ឬយ៉ាងហោចណាស់អាចធ្វើឲ្យជីវភាពរបស់ប្រជាជនមានលក្ខណៈល្អប្រសើរឡើង។

នៅក្នុងពេលជាមួយគ្នានេះដែរ យើងខិតខំពន្យល់អោយប្រជាពលរដ្ឋនៅតាមភូមិចូលរួមក្នុងការអភិវឌ្ឍរមណីយដ្ឋានអង្គរ និងក្នុងការអភិរក្សរមណីយដ្ឋានដោយចីរភាព។ ដំណាក់កាលទីមួយនៃគម្រោងទើបនឹងត្រូវបានបញ្ចប់ ភាគីទាំងបីដែលចូលរួមនៅក្នុងគម្រោងនេះសុទ្ធតែសំដែងសេចក្តីពេញចិត្ត។

ភាគីទីមួយគឺប្រជាពលរដ្ឋខ្លួនឯងផ្ទាល់ដែលចង់បានការបន្តគម្រោងទាំងនេះ ដូចដែលក្រុមការងាររបស់អាជ្ញាធរអប្សរានិងក្រុមការងារប្រទេសនូវែលហ្សេឡង់ចង់បានដែរ។

លើសពីនេះទៀត ដោយមានគម្រោងជួសជុលនិងលើកតម្លៃរមណីយដ្ឋានស្រះស្រង់ឡើងវិញនោះ គម្រោងរបស់យើងត្រូវបានពិនិត្យ កែសម្រួលឡើងវិញដើម្បីដាក់បញ្ចូលស្រះស្រង់ទាំងមូលទៅក្នុងគម្រោងធំរបស់យើងនាថ្ងៃអនាគត។ បែបនេះ គឺធ្វើអោយការបង្កើតគម្រោងមានគំនិតរួមទូទៅស៊ីសង្វាក់គ្នា នៅក្នុងទស្សនវិស័យនៃការអភិវឌ្ឍសេដ្ឋកិច្ចដែលនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋខ្លួនឯង។

គម្រោងនេះទាក់ទងនឹងភូមិចំនួនពីរដែលស្ថិតនៅខាងជើងស្រះស្រង់៖ គឺភូមិស្រះស្រង់និងភូមិរហាល។ ដោយសារតែខ្ញុំ មានពេលខ្លី ឥឡូវនេះខ្ញុំសូមជូនយោបល់ទៅអ្នកតំណាងជំនួយរបស់ប្រទេសនូវែលហ្សេឡង់ ដែលទទួលបន្ទុកគម្រោងនេះនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងជាពិសេសនៅប្រទេសកម្ពុជា គឺលោក Hewitt។

**លោក** Hewitt៖

សូមគោរពឯកឧត្តម
ភ្ញៀវកិត្តិយសដ៏ខ្ពង់ខ្ពស់
លោក លោកស្រីជាទីគោរពរាប់អាន
ខ្ញុំសូមអរគុណច្រើនដែលអនុញ្ញាតឲ្យរូបខ្ញុំបានចូលរួមនៅក្នុងសម័យប្រជុំ CIC នៅថ្ងៃនេះ ជាមួយនឹងអប្សរាដែលជាដៃគូរបស់យើង។ គឺជាកិត្តិយសមួយដែលបានធ្វើការជាមួយអប្សរានៅក្នុងគម្រោងនៅក្នុងឧទ្យាននេះ ដើម្បីជួយគាំទ្រដល់សហគមន៍។

**បទអន្តាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើនដែលបាននិយាយអំពីកិច្ចសហប្រតិបត្តិការរបស់ប្រទេសនូវែលហ្សេឡង់ ជាពិសេសគឺការចូលរួមរបស់ប្រជាពលរដ្ឋចំពោះការអភិវឌ្ឍសហគមន៍ ព្រមទាំងការការពាររមណីយដ្ឋាន។ តទៅនេះ ខ្ញុំសូមជូនយោបល់ទៅឯកឧត្តមលោកស្រី Margaret Adamson ជាឯកអគ្គរដ្ឋទូតប្រទេសអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា ដើម្បីជម្រាបជូនលោក លោកស្រីអំពីកិច្ចសហប្រតិបត្តិការរបស់ប្រទេសអូស្ត្រាលី។

## V.4 កិច្ចសហប្រតិបត្តិការរបស់ប្រទេសអូស្ត្រាលី៖ ធានានិរន្តរភាពបេតិកភណ្ឌកម្ពុជា តាមរយៈភាពជាដៃគូ ដោយលោកជំទាវ Margaret Adamson ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា

សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានអាជ្ញាធរអប្សរា។
សូមគោរព ឯកឧត្តមព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ សីហមុនី។
សូមគោរព តំណាងជាន់ខ្ពស់របស់អង្គការយូណេស្កូ ជាពិសេស លោកស្រី Françoise Riviere។
សូមគោរព ឯកឧត្តមសហប្រធាន។
ឯកឧត្តម អ្នកជំនាញ លោក លោកស្រីទាំងអស់ជាទីរាប់អាន។

ជាកិច្ចចាប់ផ្តើមនេះ ជូនសមុខឲ្យរដ្ឋាភិបាលប្រទេសអូស្ត្រាលី ខ្ញុំសូមសម្តែងនូវអំណរសាទរចំពោះរាជរដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងការបោះឆ្នោតនាពេលថ្មីៗ ដែលនេះជាលើកទីមួយហើយដែលប្រទេសកម្ពុជាបានក្លាយទៅជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។

កាលពីឆ្នាំទៅ ខ្ញុំមានសេក្តីសោមនស្សរីករាយដោយបានជំរាបជូនដល់សម័យប្រជុំ ICC ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលអូស្ត្រាលី តបតាមសំណើរបស់អង្គការយូណេស្កូ ក្នុងការធ្វើជាដៃគូជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយផ្តល់មូលនិធិសម្រាប់គម្រោងថ្មីមួយឈានទៅធ្វើការគ្រប់គ្រងរមណីយដ្ឋានបេតិកភណ្ឌ ដែលត្រូវការយកចិត្តទុកដាក់ និងផ្តោតទៅលើរមណីយដ្ឋានអង្គរ។ យើងបានឮចមកហើយពីសំណាក់ឯកឧត្តមអស់លោកដែលបានមានប្រសាសន៍លើកឡើងក្នុងថ្ងៃនេះពីបញ្ហាបន្ទាន់មួយចំនួន ដែលត្រូវធ្វើការដោះស្រាយតាមមធ្យោបាយសហការគ្នា គ្រប់គ្រងផលប៉ះពាល់បណ្តាលមកពីការអភិវឌ្ឍ និងវិស័យទេសចរណ៍ រួមជាមួយនឹងឥទ្ធិពលអវិជ្ជមានផ្សេងៗទៀតទៅ លើបរិស្ថាន និងឥទ្ធិពលអវិជ្ជមាននានាទៅលើការអភិរក្សប្រាង្គប្រាសាទ ព្រមទាំងទៅលើបេតិកភណ្ឌវប្បធម៌អរូបិយនានា។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសូមប្រកាសថា យើងបានឈានដល់កិច្ចព្រមព្រៀងលើរាល់ការរៀបចំឯកសារសម្រាប់ "គម្រោងក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌអង្គរ" ហៅកាត់ថា HMFដែលនឹងត្រូវចុះហត្ថលេខាជាផ្លូវការនៅចុងបញ្ចប់នៃកិច្ចប្រជុំនេះ។ នេះគឺជាវិធានការបង្ហាញអំពីវិធីសាស្ត្រ និងគោលបំណងនានារបស់គម្រោង និងការប្តេជ្ញាចិត្តរបស់កម្ពុជាដែលបានរួមចំណែកប្រហែល ១/៣ នៃមូលនិធិសរុប។ ខ្ញុំសូមថ្លែងអំណរគុណដល់អាជ្ញាធរជាតិអប្សរា និងតំណាងរបស់អង្គការយូណេស្កូប្រចាំនៅក្នុងទីក្រុងភ្នំពេញ ចំពោះការចូលរួមសហការដ៏វិសេសវិសាល ក្នុងការធ្វើឲ្យគម្រោងនេះលេចចេញជារូបរាងឡើង។

HMF នឹងចាប់ផ្តើមអនុវត្តក្របខណ្ឌគម្រោងជាក់ស្តែង ដោយធ្វើការសិក្សាទៅលើទីតាំងចំនួន ៣ ផ្សេងៗគ្នា រួមមាន អង្គរ បឹងមាលា និងកំពង់ភ្លុក ដោយផ្តោតទៅលើស្ថានភាពទេសចរណ៍ និងបញ្ហានានាពាក់ព័ន្ធការអភិវឌ្ឍ និងចំណុចអាទិភាពនាពេលបច្ចុប្បន្ន។

លទ្ធផលនិងបទពិសោធន៍ដែលយើងមានហើយ នឹងត្រូវយកមកប្រើប្រាស់ជាសមាសភាគដ៏សំខាន់ដើម្បីផ្តល់ជាអនុសាសន៍នានា សម្រាប់ធ្វើជាផែនការគ្រប់គ្រងផ្លូវការមួយចំពោះរមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌពិភពលោក។ ជាងនេះទៅទៀត គម្រោងនេះនឹងបំពេញបន្ថែមដោយផ្នែកមួយទៀតពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងដីធ្លីនៅក្នុងតំបន់អង្គរ ដែលអាជ្ញាធរជាតិអប្សរាត្រូវទទួលរ៉ាប់រង និងឆ្លើយតបទៅនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់ខ្លួនក្នុងទីក្រុងកេបិចក្នុងខែកក្កដា ឆ្នាំ២០០៨។ រាល់ដៃគូពាក់ព័ន្ធទាំងអស់ រាប់ចាប់តាំងពីរដ្ឋាភិបាលថ្នាក់ជាតិ ថ្នាក់ខេត្ត អាជ្ញាធរអប្សរា អង្គការយូណេស្កូរហូតដល់សហគមន៍ ICC ទាំងមូល នឹងមានផែនការមួយមានប្រសិទ្ធភាព ដោយក្នុងនោះមានការចងក្រងវិធីសាស្ត្រគោលនយោបាយនិងដំណោះស្រាយស៊ីសង្វាក់គ្នា។

ក្របខ័ណ្ឌនេះនឹងចូលរួមចំណែកក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងកាត់បន្ថយភាពក្រីក្រនៅក្នុងខេត្តសៀមរាប ដែលជាខេត្តមួយក្នុងចំណោមខេត្តក្រីក្របំផុតនៅក្នុងប្រទេសកម្ពុជា តាមរយៈការជួយសហគមន៍មូលដ្ឋានឲ្យចេះចែករំលែកផលប្រយោជន៍វប្បធម៌ និងសេដ្ឋកិច្ចដែលទទួលបានពីវិស័យទេសចរណ៍នៅតំបន់អង្គរ។

លើសពីនេះទៀត ក្របខ័ណ្ឌនេះត្រូវបានរៀបចំឡើងដើម្បីពង្រឹងជំនាញបច្ចេកទេស និងអភិបាលកិច្ចរបស់អាជ្ញាធរជាតិអប្សរា ដូច្នេះផលប្រយោជន៍ផ្សេងៗដែលបានមកពីវិស័យទេសចរណ៍ និងការអភិវឌ្ឍនៅតំបន់អង្គរនឹងត្រូវបានចែករំលែកស្មើៗគ្នា ក្នុងពេលទន្ទឹមនឹងគ្នានោះ ក៏ត្រូវធានាអោយត្រូវនឹងលក្ខខណ្ឌនៃការចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក រួមទាំងការការពារបរិស្ថានផងដែរ។

តំបន់អង្គរនឹងក្លាយទៅជារមណីយដ្ឋាននាំមុខគេ ក្រោមការខិតខំប្រឹងប្រែងរួមគ្នារបស់ក្រុមអ្នកជំនាញតាមវិស័យនីមួយៗ មានចាប់តាំងពីបុរាណវិទូរហូតដល់សង្គមវិទូ និងចាប់តាំងពីអ្នកជំនាញបរិស្ថាន ធនធានទឹក និងព្រៃឈើរហូតដល់អ្នកឯកទេសទេសចរណ៍ និងអ្នកឯកទេសខាងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ ដោយសារបរិបទសកលភាវូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ បង្កើតនូវរបៀបវារៈមួយ តម្រូវអោយយើងធ្វើការរួមគ្នាដើម្បីសន្តិភាពនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាព បេតិកភណ្ឌធម្មជាតិនិងបេតិកភណ្ឌវប្បធម៌ផ្សេងៗគ្នារបស់យើង ក៏ត្រូវស្ថិតក្នុងការយកចិត្តទុកដាក់ខ្ពស់បំផុត។ ដើម្បីឲ្យមានការការពារនិងថែរក្សាសុវត្ថិភាព សម្រាប់អ្នកជំនាន់ក្រោយនាពេលអនាគត បេតិកភណ្ឌរបស់យើងបានចូលរួមចំណែកក្នុងរបៀបវារៈរួមនេះ ដើម្បីជួយពង្រឹងអត្តសញ្ញាណជាតិ ការយោគយល់និងការគោរពគ្នាទៅវិញទៅមក ដើម្បីរួមចំណែកដល់ការអភិវឌ្ឍជាតិតាមរយៈការរកចំណូលពីវិស័យទេសចរណ៍។ នៅពេលទន្ទឹមគ្នានេះ បេតិកភណ្ឌធម្មជាតិរបស់យើងអាចបង្កើតជាផ្នែកមួយនៃការការពាររួមគ្នាប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

ផ្ទុយទៅវិញ សកម្មភាពទេសចរណ៍ដែលមិនគោរពច្បាប់ រួមទាំងការប៉ះពាល់មិនសំចៃទៅលើសំណង់និងសិលាចារិកដែលងាយខូចខាត និងការរំខានដល់ការគោរពប្រតិបត្តិវប្បធម៌ ឬ សាសនា សម្ពាធនៃការអភិវឌ្ឍផ្សេងៗទៀត ដែលបង្កឲ្យមានលទ្ធផលដែលគ្មាននិរន្តរភាពចំពោះបរិស្ថាន រួមជាមួយនឹងផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុ អាចនាំមកនូវមហន្តរាយសម្រាប់អនាគតនៃប្រាង្គប្រាសាទ និងបេតិកភណ្ឌអរូបិយ ព្រមទាំងបេតិកភណ្ឌធម្មជាតិផងដែរ។ នៅក្នុងប្រទេសកម្ពុជា យើងដឹងថា ការថែរក្សាប្រាង្គប្រាសាទតំបន់អង្គរនិងបេតិកភណ្ឌអរូបិយនៅក្នុងតំបន់នេះ ដែលបច្ចុប្បន្នស្ថិតនៅក្រោមការការពារជាបេតិកភណ្ឌពិភពលោក

គឺពឹងផ្អែកទៅលើលក្ខខណ្ឌជីវសាស្ត្រនៃបឹងទន្លេសាបនិងផលនេសាទរបស់វា ហើយវាពឹងផ្អែកផងដែរទៅលើភាពបន្តគង់វង្សនៃទន្លេមេគង្គ។

នេះគឺជាបរិបទមួយសម្រាប់ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌ ដែលវានឹងក្លាយជា ទម្រង់មួយសម្រាប់វិធានការជាសកលចំពោះរមណីយដ្ឋានបេតិកភណ្ឌដែលទាមទារការយកចិត្តទុកដាក់។ ប្រទេសអូស្ត្រាលីត្រូវបានស្នើឲ្យពិចារណាលើគម្រោងនេះដោយផ្អែកទៅលើការស្រាវជ្រាវរួមគ្នាអស់រយៈពេល១០ឆ្នាំនៅតំបន់អង្គរ ដែលដឹកនាំដោយសកលវិទ្យាល័យស៊ីដនីក្នុងភាពជាដៃគូជាមួយអាជ្ញាធរអប្សរា និងដៃគូអន្តរជាតិជាច្រើនទៀតតាមរយៈគម្រោងមហាអង្គរ (Greater Angkor) និងគម្រោង Living with Heritage ដែលលទ្ធផលនានាត្រូវបានបង្ហាញដោយបណ្ឌិត Eleanor Bruce មុននេះបន្តិច។

រដ្ឋាភិបាលអូស្ត្រាលីបន្តគាំទ្រកិច្ចសហការនេះ ដែលជាផ្នែកនៃភាពជាដៃគូទ្វេរភាគីរបស់យើង និងសាមគ្គីភាពជាមួយកម្ពុជាក្រោយពេលជម្លោះត្រូវបានបញ្ចប់។ ប្រទេសយើងទាំងពីរមានចំណាប់អារម្មណ៍រួមមួយ ពាក់ព័ន្ធនឹងសន្តិសុខនិងវិបុលភាពរបស់ប្រទេសកម្ពុជា និងការចូលរួមចំណែករបស់ខ្លួនក្នុងដំណើរការសន្តិភាពនិងស្ថេរភាពថ្នាក់តំបន់។ អាទិភាពខ្ពស់បំផុតរបស់កម្ពុជា គឺការថែរក្សាកេរ្តិ៍ដំណែលសិល្បៈល្អឯក និងសមិទ្ធផលប្រកបដោយគំនិតច្នៃប្រឌិតរបស់ខ្លួន ដែលត្រូវបានបង្ហាញឲ្យឃើញតាមរយៈការដាក់បញ្ចូលបេតិកភណ្ឌរបស់ខ្លួននៅលើទង់ជាតិ និងការខិតខំប្រឹងប្រែងស្វែងរកការទទួលបានសមាជិកភាពនៅក្នុងគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ វិធីសាស្ត្ររបស់ប្រទេសអូស្ត្រាលីចំពោះការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ត្រូវបានទទួលស្គាល់ថា ជាវិធីសាស្ត្រល្អបំផុតមួយដែលត្រូវបានគេអនុវត្តជាអន្តរជាតិ។

បន្ថែមពីលើការសហការទ្វេភាគីយ៉ាងជិតស្និទ្ធរបស់យើង ប្រទេសអូស្ត្រាលីរង់ចាំធ្វើការងារយ៉ាងជិតស្និទ្ធជាមួយប្រទេសកម្ពុជា លើបញ្ហាបេតិកភណ្ឌជាលក្ខណៈពហុភាគីក្នុងនាមជាសមាជិករបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក និងគាំទ្រដល់អាណត្តិជាសកលនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក។ នៅក្នុងនេះដែរ ក្របខ័ណ្ឌគ្រប់គ្រងបេតិកភណ្ឌនេះនឹងដើរតួជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងដ៏មានប្រយោជន៍។

សូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់ឯឧត្តម លោកជំទាវ អស់លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើនលោកស្រី Adamson ដែលបាននិយាយអំពីគម្រោងថ្មីរបស់លោកស្រីស្តីពី *management heritage framework*។ ហើយឥឡូវនេះ ខ្ញុំសូមជូនវេទិការទៅតំណាងប្រទេសកូរ៉េដើម្បីនិយាយអំពីគម្រោងដ៏ពិសេសស្តីពីបណ្តាញផ្លូវថ្នល់នៅសៀមរាប។ ជាបឋម គឺលោក ទិត សុផា មកពីអប្សរា និងបន្ទាប់មកទៀត គឺឯកឧត្តម Lee Kyung-Soo មកពីសាធារណរដ្ឋកូរ៉េ។

## V.5 កិច្ចសហប្រតិបត្តិការរបស់ប្រទេសកូរ៉េ៖ បណ្តាញផ្លូវខាងក្រុងសៀមរាប ដោយលោក ទិត សុផា អាជ្ញាធរជាតិអប្សរា និងលោក Lee Kyung-Soo ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ

## លោក ទិត សុផា៖

សូមគោរពឯកឧត្តមសហប្រធាន សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

[ស្លាយ] ខ្ញុំមានកិត្តិយសណាស់ដែលបានមកបង្ហាញត្រួសៗជូនឯកឧត្តម លោក លោកស្រី នូវការរីកចម្រើននៃការងារសាងសង់ផ្លូវនៅក្នុងឧទ្យានអង្គរ ដែលជាគម្រោងខ្មែរ កូរ៉េ។ បទបង្ហាញរបស់ខ្ញុំនឹងចែកជាប្រាំចំណុចសំខាន់ៗ ដូចដែលមានបង្ហាញនៅលើស្លាយនេះដែរ៖

១. នយោបាយនៃការអភិរក្សបេតិកភណ្ឌអង្គរ
២. ប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ
៣. ការសាងសង់ផ្លូវវាងឧទ្យានអង្គរ
៤. ផ្លូវវាងខាងត្បូងសៀមរាប
៥. ការគ្រប់គ្រងផ្លូវនៅក្នុងឧទ្យានអង្គរ

## ១. នយោបាយនៃការអភិរក្សបេតិកភណ្ឌអង្គរ

នៅឆ្នាំ២០០៤ អង្គរត្រូវបានដកចេញពីបញ្ជីបេតិកភណ្ឌស្ថិតក្នុងសភាពគ្រោះថ្នាក់។ អាជ្ញាធរអប្សរាបានចាប់ផ្តើមអភិរក្ស និងថែទាំបេតិកភណ្ឌវប្បធម៌អោយនៅគង់វង្ស និងលើកស្ទួយតម្លៃទេសចរវប្បធម៌ ដោយគោរពទៅតាមគោលការណ៍នៃការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

គឺបន្ទាប់ពីទទួលបានអនុសាសន៍ពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នោះហើយ ទើបអង្គភាពផ្លូវថ្នល់ត្រូវបានបង្កើតឡើង។ តួនាទីរបស់អង្គភាពនេះគឺ ថែទាំប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ ដោយធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន។

## ២. ប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ

[ស្លាយ] នៅក្នុងពេលនោះ ទន្ទឹមនឹងទីក្រុងសៀមរាបមានការអភិវឌ្ឍន៍ខ្លាំង និងការកើនឡើងនៃចំនួនទេសចរ ចរាចរនៅក្នុងក្រុងសៀមរាប ក៏ដូចជានៅក្នុងឧទ្យានអង្គរកាន់តែចង្អៀត។ ហេតុដូច្នេះហើយទើបផ្លូវជាច្រើននៅឧទ្យានអង្គរ ក៏ដូចជានៅក្នុងក្រុងសៀមរាបត្រូវបានជួសជុលឡើងវិញ។

[ស្លាយ] នេះគឺជាផែនទីប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ។ ពណ៌ក្រហមគឺជាផ្លូវក្រាលគ្រួសក្រហម ពណ៌បៃតងគឺជាផ្លូវក្រាលកៅស៊ូ ហើយពណ៌ខៀវគឺជាផ្លូវលំ។ នៅពេលបច្ចុប្បន្ន ផ្លូវនេះមានប្រវែង ២២០គម និងចែកជាបីកំណាត់ខុសៗគ្នា៖ ៩៨គម ចាក់កៅស៊ូ ៨២គម ក្រាលគ្រួសក្រហម និង៤០គម ជាផ្លូវលំនៅឡើយ។

## ៣. ការសាងសង់ផ្លូវវាងឧទ្យានអង្គរ

[ស្លាយ] នេះគឺផែនទីតំបន់ផ្សេងៗនៃឧទ្យាន។ ព័ណ៌ក្រហមគឺតំបន់២ ហើយព័ណ៌លឿងគឺតំបន់១។ នេះគឺផ្លូវជាតិលេខ៦ ក្រុងសៀមរាប និងប្រាង្គប្រាសាទអង្គរតំណាងដោយរូបទាំងនេះ។ រូបមានរង្វង់មូលគឺជាក្លោងទ្វារអង្គរធំ។

ពីមុន នៅពេលអ្នកស្រុកចង់ធ្វើដំណើរពីខាងជើងឧទ្យានទៅកាន់ក្រុងសៀមរាប ពួកគេធ្វើដំណើរតាមផ្លូវនៅតាមប្រាសាទនានា ដែលកាត់តាមក្លោងទ្វារតូចចង្អៀតរបស់អង្គរធំនេះ។ ដូច្នេះ នៅឆ្នាំ ២០០៤-២០០៥ ដើម្បីអភិរក្សបេតិកភណ្ឌអង្គរដែលមានតម្លៃមិនអាចកាត់ថ្លៃបាននេះ ផ្លូវក្រាលគ្រួសក្រហម មួយខ្សែប្រវែង ១៣គម ត្រូវបានសាងសង់ឡើង (ពី C ទៅ D) ដែលប្រើប្រាស់ថវិកាអាជ្ញាធរអប្សរា អស់ ៥៥៥ ០០០ ដុល្លារសហរដ្ឋអាមេរិក។

ទន្ទឹមនឹងគ្នានោះ រាជរដ្ឋាភិបាលកម្ពុជាបានអំពាវនាវដល់ដៃគូអភិវឌ្ឍន៍នានា ឲ្យជួយផ្តល់ហិរញ្ញប្បទានដើម្បីកសាងផ្លូវវាងឧទ្យានអង្គរ។ សាធារណរដ្ឋកូរ៉េបានឆ្លើយតបទៅនឹងការអំពាវនាវនោះនៅឆ្នាំ២០០៦ ដោយបានផ្តល់ប្រាក់កសាងផ្លូវវាងពីរខ្សែ (ពីA ទៅ B និងពីG ទៅ F )។ ខ្សែទីមួយយើងបានចំណាយប្រាក់អស់១.៦លានដុល្លារអាមេរិកដោយក្រាលគ្រួសក្រហម ចំណែកឯដំណាក់កាលទីពីរ ប្រាក់ចំនួន៤,៣លានដុល្លារអាមេរិក ត្រូវបានប្រើប្រាស់ដើម្បីចាក់កៅស៊ូ។ នៅក្នុងគម្រោងនេះដែរ មានផ្នែកពង្រឹងសមត្ថភាពបុគ្គលិកខ្មែរ ក្រុមទីមួយមានចំនួន៥នាក់ រយៈពេលពីរសប្តាហ៍ បន្ទាប់មកមានមួយក្រុមទៀត ចំនួន៥នាក់ដែរ បានទៅបំប៉នចំនួន៤សប្តាហ៍នៅប្រទេសកូរ៉េ។

គម្រោងទទួលបានជោគជ័យទាំងស្រុង ហើយនៅថ្ងៃទី៥ ឧសភា ២០០៩ ផ្លូវនេះត្រូវបានសម្ពោធអោយប្រើប្រាស់ក្រោមអធិបតីភាពរបស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា ព្រមទាំងក្រោមអធិបតីភាពរបស់ឯកឧត្តម Lee Kyung Soo ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា។

[ស្លាយ] បន្ថែមពីលើផ្លូវវាងនេះ សាធារណរដ្ឋកូរ៉េបានផ្តល់ជំនួយឲ្យកសាងកំណាត់ផ្លូវដែលនៅសល់ប្រវែង ២១គីឡូម៉ែត្រទៀត (ពី C ទៅ E ) ដែលជាគម្រោងមានរយៈពេលពីរឆ្នាំ ២០១០-២០១២។ ឆ្នាំទីមួយកំណាត់ផ្លូវ ១៦គីឡូម៉ែត្រនឹងត្រូវបានសាងសង់។

## ៤. ផ្លូវវាងខាងត្បូងសៀមរាប

បន្ថែមពីលើការសាងសង់ផ្លូវថ្មល់នៅក្នុងឧទ្យានអង្គរ អាជ្ញាធរអប្សរាក៏បានចូលរួមក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្រុងសៀមរាបផងដែរ។ ជាអាទិ៍ ទឹកប្រាក់ចំនួន៤លានដុល្លារអាមេរិក ត្រូវបានផ្តល់ជូនដើម្បីសាងសង់ផ្លូវក្រវ៉ាត់ក្រុងសៀមរាប ដើម្បីបន្ថយភាពកកស្ទះចរាចរនៅក្នុងក្រុង និងបញ្ចៀសយានយន្តធនធ្ងន់មិនឲ្យបើកកាត់ក្រុង។

## ៥. ការគ្រប់គ្រងផ្លូវនៅក្នុងឧទ្យានអង្គរ

ពាក់ព័ន្ធនឹងការគ្រប់គ្រងប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ ដំណាក់កាលទីមួយ អាជ្ញាធរអប្សរាបានបោះបង្គោលជារនាំងឃាំងកុំឲ្យឡានធំៗបើកកាត់ ហើយបានចាត់តាំងក្រុមមួយដែលមានគ្នា៦នាក់ ដើម្បីយាម២៤ម៉ោងលើ២៤ម៉ោង។ ធ្វើបែបនេះ យើងអាចបញ្ចៀសយានយន្តធនធ្ងន់មិនឲ្យបើកបរកាត់ឧទ្យានអង្គរ។ នៅពេលនេះ យានយន្តធនធ្ងន់អាចបើកកាត់ផ្លូវជាតិលេខ៦៧ មិនចាំបាច់បើកកាត់ផ្លូវនៅក្នុងឧទ្យានអង្គរឡើយ។

បន្ថែមពីលើបង្គោលរនាំងកាត់ផ្លូវ អាជ្ញាធរអប្សរាបានគ្រោងប្រើប្រាស់ថវិការបស់ខ្លួន ដើម្បីថែទាំប្រព័ន្ធផ្លូវនៅក្នុងឧទ្យានអង្គរ។ សូមអរគុណ!

**លោក Lee Kyung Soo៖**

សូមអរគុណ លោក ទិត សុផា ដែលបានបង្ហាញអំពីគម្រោងផ្លូវវាងក្រុងសៀមរាប។ ដោយសារបទបង្ហាញរបស់លោក បាននិយាយអំពីចំណុចជាច្រើនរួចមកហើយ ខ្ញុំនឹងនិយាយយ៉ាងខ្លីបំផុត។ មុននឹងចាប់ផ្តើមបទបង្ហាញរបស់ខ្ញុំ ខ្ញុំសូមអនុញ្ញាតថ្លែងអំណរគុណដល់សហប្រធានទាំងពីររូបរបស់ CIC ជាពិសេសខ្ញុំសូមសំដែងនូវការកោតសរសើរដល់ឯកឧត្តម Kuroki ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលឯកឧត្តមទើបចូលកាន់តំណែងថ្មី ហើយខ្ញុំក៏សូមសំដែងនូវការកោតសរសើរផងដែរចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលបានផ្តល់ការគាំទ្រដល់ការប្រជុំដ៏សំខាន់នេះ ដែលផ្តោតទៅលើការអភិរក្សនិងការអភិវឌ្ឍន៍បេតិកភណ្ឌដ៏មានតម្លៃ នោះគឺឧទ្យានអង្គរ។ នេះក៏ជាឱកាសមួយដើម្បីសម្តែងសេចក្តីអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូកាលពីខែតុលាកន្លងទៅ។ ខ្ញុំសង្ឃឹមថា ហើយខ្ញុំជឿជាក់ថានៅពេលនេះ កម្ពុជាជាសមាជិកនៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក កម្ពុជានឹងអាចចូលរួមជាមួយកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិរក្សនិងការពាររមណីយដ្ឋានអង្គរដែលជាបេតិកភណ្ឌពិភពលោក។

ឯកឧត្តម លោកជំទាវ លោក លោកស្រីជាទីរាប់អាន!

ថ្ងៃនេះខ្ញុំមានកិត្តិយសណាស់ដែលបានមកចូលរួមក្នុងកិច្ចប្រជុំ CIC នេះ ព្រមទាំងបង្ហាញជូននូវរបាយការណ៍ស្តីពីជំនួយកូរ៉េក្នុងគម្រោងកសាងផ្លូវនៅសៀមរាប ក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍន៍អង្គរប្រកបដោយចិរភាព។ ប្រទេសកូរ៉េ និងប្រជាជនកូរ៉េ ស្រឡាញ់ឧទ្យានអង្គរយ៉ាងខ្លាំង។ ប្រទេសកម្ពុជាក៏ដូចជាប្រទេសកូរ៉េមានរមណីយដ្ឋានជាច្រើនដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក។ នៅឆ្នាំ២០០៦ ប្រទេសកម្ពុជានិងប្រទេសកូរ៉េបានរៀបចំរួមគ្នានៅពិព័រណ៍វប្បធម៌មួយឈ្មោះអង្គរ-ឃ្យុងយុ នៅសៀមរាប។ ពិព័រណ៍នេះបានជួយពង្រឹងចំណងវប្បធម៌រវាងប្រទេសទាំងពីរ លើកស្ទួយតម្លៃវប្បធម៌បច្ចុប្បន្ននៅក្នុងបរិបទនៃទំនាក់ទំនងរវាងប្រជាជននិងប្រជាជន។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទេសចរជនជាតិកូរ៉េបានមកទស្សនាអង្គរច្រើនជាងគេ។ នេះជាហេតុផលមួយដែលប្រទេសកូរ៉េផ្តោតសំខាន់ទៅលើការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៃរមណីយដ្ឋាននេះ។

ពេលនេះខ្ញុំសូមចាប់ផ្តើមធ្វើបទបង្ហាញរបស់ខ្ញុំដែលចែកជាបីផ្នែក។

[ស្លាយ] សកម្មភាពរបស់យើងក្នុងការកសាងផ្លូវនៅសៀមរាបគឺផ្អែកទៅលើទស្សនាទាននិងនយោបាយនៃបេតិកភណ្ឌវប្បធម៌។ នយោបាយនោះផ្តោតទៅលើការអភិរក្សបេតិកភណ្ឌវប្បធម៌ឲ្យស្ថិតនៅក្នុងស្ថានភាពដើម ទៅលើការអភិវឌ្ឍន៍ធនធានទេសចរណ៍ ដោយទន្ទឹមនឹងនោះជួយលើកស្ទួយតម្លៃសម្បត្តិវប្បធម៌ ព្រមទាំងផ្តល់នូវលទ្ធភាពទស្សនាកម្សាន្តជាច្រើនផ្សេងទៀតដល់អ្នកទេសចរនៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការអភិរក្សបេតិកភណ្ឌរូបីនិងអរូបី។ តាមពិត ប្រទេសកូរ៉េបានចុះហត្ថលេខាលើអនុសញ្ញាជាច្រើននៅក្នុងក្របខ័ណ្ឌនៃការអភិរក្សវប្បធម៌។ នៅប្រទេសកូរ៉េមានរមណីយដ្ឋានចំនួន៩ ដែលត្រូវបានចុះនៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក និងមានស្មារតីចងចាំពិភពលោកចំនួន៧ ព្រមទាំងមានស្នាដៃឯកដែលជាសម្បត្តិវប្បធម៌អរូបីរបស់មនុស្សជាតិចំនួន៨។

ពេលនេះ ខ្ញុំសូមនិយាយអំពីប្រវត្តិគម្រោង។ [ស្លាយ] ដូចដែលរូបនេះបានបង្ហាញដូច្នោះដែរ ស្ថានភាពពិតជាធ្ងន់ធ្ងរខ្លាំងណាស់។ នេះគឺជាផ្លូវចូលអង្គរធំ និងផ្លូវនៅម្ខាងទៀតនៃរមណីយដ្ឋានបេតិកភណ្ឌ។ យានយន្តធនធ្ងន់អាចបង្កឲ្យមានមហន្តរាយធ្ងន់ធ្ងរ។ [ស្លាយ] នេះគឺជារូបភាពដែលបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃផ្លូវជុំវិញឧទ្យាន។

យើងបានសង្កេតឃើញមានបញ្ហាជាច្រើន ហើយបញ្ហាកាន់តែធ្ងន់ធ្ងរទៅៗ ដោយមូលហេតុចរាចរណ៍កាន់តែកើនឡើង។ បច្ចុប្បន្ននេះ អង្គរទទួលទេសចរណ៍បរទេសជាងមួយលាននាក់នៅសៀមរាប យានយន្តស្ទះនៅត្រង់តំបន់នេះ ខាងស្តាំ។ បញ្ហាទាំងអស់នេះ បានជះឥទ្ធិពលប៉ះពាល់ផ្ទាល់និងមិនផ្ទាល់ដល់ប្រាង្គប្រាសាទនានា៖ រំញ័រ បំពុលបរិយាកាស និងធូលីដី ដែលជាការរំខានសំខាន់ៗ។ គឺបន្ទាប់ពីបានសង្កេតឃើញដូច្នេះហើយ ទើបរដ្ឋាភិបាលកូរ៉េបានសម្រេចដោះស្រាយបញ្ហានេះ ដោយសហការយ៉ាងជិតស្និតជាមួយរាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសជាមួយអាជ្ញាធរអប្សរា។

ដូច្នេះ ការសិក្សាមួយត្រូវបានចាប់ផ្តើមធ្វើនៅឆ្នាំ២០០៥ ហើយយើងបានឈានទៅដល់សេចក្តីសន្និដ្ឋានមួយដែលថាការកសាងផ្លូវវាងឧទ្យានមួយ ត្រូវតែធ្វើបន្ថែមទៅលើគម្រោងសាងសង់ផ្លូវក្រវ៉ាត់ក្រុង។ [ស្លាយ] នេះគឺជាផែនទីផ្លូវក្រវ៉ាត់ក្រុង។ ដូចដែលយើងបានបង្ហាញជូនរួចមកហើយ ខ្សែពណ៌ក្រហមគឺជាផ្លូវបច្ចុប្បន្ន ហើយនេះគឺជាផ្លូវវាងប្រាសាទអង្គរ។ ខ្សែពណ៌ខៀវតំណាងឲ្យផ្លូវជាតិលេខ៦។ ផ្លូវនេះ គឺជាផ្លូវក្រាលគ្រួសក្រហមដែលនឹងត្រូវចាក់កៅស៊ូនៅពេលអនាគត ផែនទីនេះចែកចេញជាពីរផ្នែក ផ្នែកA ការងារបានធ្វើរួចរាល់អស់ហើយ និងមានបណ្តោយប្រវែង១៥គីឡូម៉ែត្រ ហើយខ្សែពណ៌លឿងនេះ តំណាងឲ្យកំណាត់ផ្លូវប្រវែង២០គីឡូម៉ែត្រ ដែលនឹងត្រូវកសាងនៅក្នុងដំណាក់កាលបន្តបន្ទាប់។ ខ្ញុំនឹងនិយាយលំអិតនៅពេលក្រោយ។

នៅពេលផ្លូវក្រវ៉ាត់ក្រុងត្រូវបានសាងសង់រួចរាល់ បំណងរបស់យើងគឺចង់បញ្ចៀសមិនអោយមានចរាចរយានយន្តធនធ្ងន់នៅក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរទេ នោះគឺដើម្បីកាត់បន្ថយជាតិពុលនិងលើកស្ទួយទេសចរណ៍ ព្រមទាំងទីផ្សារក្នុងស្រុកដោយបង្កើនការមកទស្សនាបេតិកភណ្ឌ។

ដូចដែលខ្ញុំបាននិយាយរួចមកហើយ ផ្នែកA ត្រូវបានធ្វើរួចរាល់ហើយ។ ចំណាយសរុបអស់៩លានដុល្លារអាមេរិកដោយយើងបានចាក់កៅស៊ូ។ ការបញ្ចប់ការងារនៅផ្នែកA អាចឲ្យយើងបញ្ឈប់ទាំងស្រុងមិនឲ្យមានចរាចរកាត់តាមឧទ្យាន គេអាចនឹងប្រើប្រាស់ផ្លូវវាងទៅវិញ។ យើងក៏សង្ឃឹមផងដែរថា វាអាចជួយការពារបានរយៈពេលយូរ ធ្វើឲ្យអ្នកបើកបរមិនសូវខុសច្បាប់ចរាចរ បន្ថយជាតិពុល និងធូលីដី។ ផ្លូវទាំងនេះ ប្រហែលជាអាចជួយអោយមានការអភិវឌ្ឍន៍ឧស្សាហកម្មទេសចរណ៍ ធ្វើឲ្យអ្នកទេសចរមានអារម្មណ៍ល្អនៅពេលពួកគេមកទស្សនា។ ប៉ុន្តែដោយសារការកសាងផ្លូវនេះ តម្រូវឲ្យមានការងារបន្ថែមមួយទៀត រដ្ឋាភិបាលកូរ៉េក៏បានសម្រេចបន្តការគាំទ្ររបស់ខ្លួន ដើម្បីឲ្យការងារកែលំអផ្លូវនេះកាន់តែប្រសើរឡើងថែមទៀត។ និងបានផ្តល់ជំនួយសាងសង់កំណាត់ផ្លូវ ដែលតភ្ជាប់ផ្លូវនេះទៅផ្លូវក្រវ៉ាត់ក្រុង។ ដូច្នេះយើងស្ថិតនៅក្នុងដំណើរបន្តការគាំទ្ររបស់យើងដល់បេតិកភណ្ឌខ្មែរ។ ប្រសិនបើយើងសាងសង់ផ្លូវនេះនៅឆ្នាំ២០១២ ដែលមានប្រវែងសរុប៣៦គីឡូម៉ែត្រ ផ្លូវនេះនឹងភ្ជាប់ទៅផ្លូវក្រវ៉ាត់ក្រុងទាំងមូលហើយចំណាយសរុប៥០,២លានដុល្លារអាមេរិក។ ការងារប្រហែលជានឹងរួចរាល់ចប់សព្វគ្រប់នៅឆមាសទី៤នៃឆ្នាំក្រោយ។ សូមអរគុណ!

**បទអន្តរាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណឯកឧត្តមដែលបានបង្ហាញប្រាប់យើងអំពីគម្រោងផ្លូវវាងក្រុងសៀមរាប ដែលនឹងជួយកាត់បន្ថយចំនួនរថយន្តដែលឆ្លងកាត់តាមរមណីយដ្ឋានប្រាង្គប្រាសាទប្រវត្តិសាស្ត្រ។ ឥឡូវនេះ ខ្ញុំសូមជូនវេទិកាទៅលោកស្រី ស៊ីសុវត្តិ ចន្ទទេវី ដើម្បីនិយាយអំពីមជ្ឈមណ្ឌលប្រចាំតំបន់ដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកបេតិកភណ្ឌ។

## V.6 កិច្ចសហប្រតិបត្តិការបារាំងៈ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកបេតិកភណ្ឌប្រចាំតំបន់ (ឡាវ វៀតណាម កម្ពុជា)៖ គុល្យាការទីមួយ ដោយលោកស្រី ស៊ីសុវត្ថិ ចន្ទទេវី ជានាយិកា

សូមគោរពឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា ឯកឧត្តម អ៊ុំ វិជ្ជារាវុធ ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី លោកសហប្រធាន ឯកឧត្តម លោក លោកស្រីជាទីគោរពរាប់អាន!

[ស្លាយ] ខ្ញុំសូមអនុញ្ញាតបង្ហាញជូនអំពីគុល្យាការទីមួយរបស់មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកបេតិកភណ្ឌប្រចាំតំបន់ ដែលបច្ចុប្បន្ននេះបានឈានដល់ឆ្នាំសិក្សាទីបីរបស់ខ្លួនហើយ។ ការបណ្តុះបណ្តាលនេះប្រព្រឹត្តិទៅក្នុងរយៈពេលមួយឆ្នាំសិក្សា សម្រាប់អ្នកជំនាញជនជាតិខ្មែរ ឡាវ និងវៀតណាម ដែលមានឯកទេសផ្នែកអភិរក្សនិងជួសជុលបេតិកភណ្ឌរូបិយ។
នៅក្នុងការបណ្តុះបណ្តាលនេះ គឺយើងចង់បានអ្នកឯកទេសខាងវិស័យជួសជុល ការពារនិងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌។ នៅក្នុងវិស័យទាំងនេះ ការបណ្តុះបណ្តាលនៅតែជាតម្រូវការដ៏សំខាន់បំផុតរបស់ប្រទេសទាំងបីនេះ។

[ស្លាយ] បន្ទាប់ពីទទួលការបណ្តុះបណ្តាលនេះទៅ និស្សិតភាគច្រើនត្រឡប់ទៅធ្វើការនៅតាមក្រសួងមន្ទីរនានានៅតាមខេត្ត ឬក៏នៅតាមទីក្រុងធំៗឬមធ្យមរបស់ប្រទេសទាំងបី។

សាលា Chaillot ដែលបណ្តុះបណ្តាលនៅប្រទេសបារាំង នូវស្ថាបត្យករផ្នែកប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ទទួលបន្ទុកខាងគរុកោសល្យនិងវិធីសាស្ត្រផ្នែកវិទ្យាសាស្ត្ររបស់មជ្ឈមណ្ឌល។

[ស្លាយ] គណៈកម្មាធិការចំនួនពីរត្រូវបានបង្កើតឡើងចាប់តាំងពីពេលមជ្ឈមណ្ឌលចាប់ផ្តើមមកៈ ទី១ គឺគណៈកម្មាធិការសម្របសម្រួលក្នុងស្រុកនៅក្នុងប្រទេសនីមួយៗក្នុងចំណោមប្រទេសពាក់ព័ន្ធទាំងបី។ គណៈកម្មាធិការនេះធ្វើការជ្រើសរើសនិស្សិតនិងធ្វើការតាមដាននិងសម្របសម្រួល។

[ស្លាយ] ទី២ គឺគណៈកម្មាធិការតម្រង់ទិសទូទៅដែលជួបប្រជុំគ្នាមួយដងក្នុងមួយឆ្នាំនៅទីក្រុងប៉ារីស៍ ធ្វើការជ្រើសរើសបេក្ខជនដោយផ្អែកលើសំណើដែលធ្វើឡើងទៅគណៈកម្មាធិការនីមួយៗនៃគណៈកម្មាធិការចម្រុះ។ គណៈកម្មាធិការនេះក៏ទទួលបន្ទុកផងដែរក្នុងការអនុម័តនិងតម្រង់ទិសកម្មវិធី ព្រមទាំងវាយតម្លៃលើការបន្តគម្រោង។

[ស្លាយ] ការបណ្តុះបណ្តាលផ្តោតទៅលើផ្នែកចំនួនពីរ។ ផ្នែកស្ថាបត្យកម្មទាក់ទងនឹងអគារឬប្រាង្គប្រាសាទ។ ចំណែកឯផ្នែកនគរោបនីយកម្មវិញ គឺទាក់ទងនឹងទីក្រុងបុរាណដែលមានសំណង់ឬគ្មាន នឹងទេសភាពនិងបញ្ហាដែលចោទឡើង។ សម្រាប់ផ្នែកនីមួយៗ ការសិក្សាមានការឆ្លាស់គ្នា សម្រាប់រយៈពេលចំនួនដប់សប្តាហ៍ក្នុងរយៈពេលមួយឆ្នាំសិក្សា។

[ស្លាយ] សាស្ត្រាចារ្យពីររូបដឹកនាំផ្នែកនីមួយៗនៃផ្នែកទាំងពីរ។ លោក Pierre André Lablaude ជាអ្នកត្រួតពិនិត្យប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ទទួលបន្ទុកផ្នែកស្ថាបត្យកម្ម និងលោក Alexandre Mélissnos ជាស្ថាបត្យករផ្នែក

នគរោបនីយកម្ម ទទួលបន្ទុកផ្នែកនគរោបនីយកម្ម។

[ស្លាយ] ការសិក្សាប្រព្រឹត្តទៅនៅសៀមរាប នៅក្នុងអគាររបស់អភិរក្សអង្គរសម្រាប់ផ្នែកស្ថាបត្យកម្ម និងនៅទីក្រុងភ្នំពេញ គឺនៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រាប់ផ្នែកនគរោបនីយកម្ម។

[ស្លាយ] ការបង្ហាត់បង្រៀនត្រូវបានធ្វើឡើងដោយសាស្ត្រាចារ្យដែលមកពីសាលា Chaillot ពី URBA ពី EFEO ពីយូណេស្កូ ។ល។និង។ល។ ក្រៅពីនេះមានបន្ថែមនូវសន្និសីទដែលធ្វើឡើងដោយអ្នកឯកទេសដែលធ្វើបទបង្ហាញអំពីបទពិសោធន៍នៅអាស៊ីអាគ្នេយ៍ និងជាពិសេសនៅរមណីយដ្ឋានអង្គរ។

[ស្លាយ] ការសិក្សាមានអមទៅដោយលំហាត់ខ្លីៗនិងគម្រោងដែលមានរយៈពេលវែងមួយ។ លំហាត់ខ្លីៗគឺជាការងារដែលមានការណែនាំ និងដឹកនាំធ្វើឡើងនៅនឹងរមណីយដ្ឋាន ដូចជាសំណង់មុំណាមួយ ឬក៏នៅប្រាង្គប្រាសាទណាមួយ។ ការសិក្សាទាំងនេះប្រព្រឹត្តទៅក្នុងរយៈពេលកន្លះថ្ងៃឬក៏មួយថ្ងៃពេញ សម្រាប់ផ្នែកនីមួយៗនៃផ្នែកទាំងពីរ។ ដូច្នេះ មានលំហាត់ចំនួនពីរឬបីត្រូវបានដាក់អោយនិស្សិតធ្វើសម្រាប់រយៈពេលចំនួនមួយឆ្នាំ ដើម្បីពង្រីកសមត្ថភាពវិភាគលើបញ្ហាដែលចោទឡើង។

[ស្លាយ] តទៅនេះជាឧទាហរណ៍ខ្លះៗនៃការងារដែលបានធ្វើឡើងដោយនិស្សិត៖ ការធ្វើសម្រង់ សំណើធ្វើការស្ទាបស្ទង់ ការធ្វើជំរឿនលើបេតិកភណ្ឌ ហើយក៏មានការវិភាគផ្នែកនគរោបនីយកម្មផងដែរ។

[ស្លាយ] គម្រោងរយៈពេលវែងត្រូវបានស្នើឡើងដោយសិក្ខាកាមចាប់តាំងពីខ្លួនបានដាក់ឯកសារបេក្ខភាពរបស់ខ្លួន ហើយនិស្សិតធ្វើការលើគម្រោងនោះពេញមួយឆ្នាំសិក្សា។

[ស្លាយ] ប្រធានបទដែលត្រូវបានផ្តល់សុពលភាពនិងដឹកនាំធ្វើដោយសាស្ត្រាចារ្យ មានផ្នែកពីរ៖ គឺការសិក្សាលើសំណង់ក្រុងចាស់ឬបុរាណ នៅតាមទីក្រុងឬតាមភូមិ។ ការសិក្សាលើប្រាង្គប្រាសាទមួយដែលស្ថិតនៅក្នុងដែនដីក្រុង ឬដែលមានទំនាក់ទំនងជាមួយនឹងក្រុងនោះ។

[ស្លាយ] ការងារស្តីពីគម្រោងរយៈពេលវែងចែកចេញជាបួនដំណាក់កាលសំខាន់ៗ ដែលមានរយៈពេលចំនួនបួនសប្តាហ៍សម្រាប់ផ្នែកនីមួយៗ៖ ការបង្កើតឯកសារ ការវិភាគ សំណើធ្វើការស្ទាបស្ទង់ និងការកំណត់ស្ថានភាពប្រឈម។ ហើយនៅទីបញ្ចប់ គឺសំណើសុំធ្វើកិច្ចអន្តរាគមន៍សម្រាប់ការការពារនិងការលើកតម្លៃ។

[ស្លាយ] តាំងពីពេលចាប់ផ្តើម យើងបានកំណត់ថាការបណ្តុះបណ្តាលនឹងមានសិក្ខាកាមយ៉ាងច្រើនបំផុតចំនួន២៥នាក់ក្នុងមួយឆ្នាំ គឺមានចំនួនប្រាំពីរឬប្រាំបីនាក់សម្រាប់ប្រទេសនីមួយៗ។ ការធ្វើការជ្រើសរើសចុងក្រោយត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនៃការប្រជុំរបស់គណៈកម្មាធិការតម្រង់ទិសទូទៅ។

[ស្លាយ] ជំនាន់ទីមួយមាននិស្សិតចំនួន២២នាក់ ដែលនៅក្នុងចំណោមនេះមានជនជាតិខ្មែរចំនួន៨នាក់ ជនជាតិឡាវ៥នាក់និងជនជាតិវៀតណាម៩នាក់។ នៅក្នុងចំណោមនិស្សិតទាំង២២នាក់នេះ មាននិស្សិតចំនួន១៨នាក់បានទទួលសញ្ញាប័ត្រ។

[ស្លាយ] ជំនាន់ទីពីរមាននិស្សិតចំនួន២១នាក់៖ ជនជាតិខ្មែរចំនួនប្រាំបួននាក់ ឡាវបីនាក់ វៀតណាមប្រាំបួននាក់

ហើយមាននិស្សិតចំនួន១៨នាក់បានទទួលសញ្ញាប័ត្រ។ ហើយនៅឆ្នាំនេះ មាននិស្សិតចំនួន១៩នាក់ត្រូវបានជ្រើសរើស៖ ជនជាតិខ្មែរប្រាំបីនាក់ ឡាវបួននាក់ និងវៀតណាមប្រាំពីរនាក់។ មុននឹងឆ្នាំសិក្សាទីបីរបស់មជ្ឈមណ្ឌលត្រូវបានបញ្ចប់ យើងយល់ថាគឺជាការសំខាន់ដែលត្រូវធ្វើការសរុបលទ្ធផលទីមួយទាក់ទងនឹងទិសដៅដែលយើងបានកំណត់។ យើងមិនទាន់មានព័ត៌មានពីប្រទេសវៀតណាម ឬក៏ពីប្រទេសឡាវនៅឡើយ។

[ស្លាយ] សម្រាប់ប្រទេសកម្ពុជា លទ្ធផលមានដូចតទៅនេះ៖ នៅក្នុងចំណោមសិស្សចំនួន២៥នាក់ សិស្ស២១នាក់មកពីវិទ្យាស្ថានជាតិនានា និងបួននាក់ជានិស្សិតឯករាជ្យមិនចំណុះឲ្យស្ថាប័នណាឡើយ។ ស្ថាប័នទាំងនោះមានអាជ្ញាធរជាតិអប្សរា (និស្សិតចំនួន១១នាក់) អាជ្ញាធរជាតិព្រះវិហារ (និស្សិតចំនួន២នាក់) ហើយក៏មាននិស្សិតមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈផងដែរ គឺនិស្សិ២នាក់មកពីបន្ទាយឆ្មារ និងនិស្សិត៦នាក់មកពីអង្គភាពមួយឈ្មោះថា បេសកកម្មបេតិកភណ្ឌ ដែលនៅក្រោមក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

[ស្លាយ] និស្សិតមកពីអប្សរាចំនួន១១នាក់ដែលមានបុរាណវិទូចំនួន៧នាក់និងស្ថាបត្យករចំនួន៤នាក់ មកពីនាយកដ្ឋានបច្ចេកទេសផ្សេងៗ។ គម្រោងសិក្សាមួយចំនួនជាគម្រោងបច្ចុប្បន្ន គម្រោងខ្លះកំពុងតែដំណើរការ។ ដូច្នេះ គម្រោងរៀបចំនិងជួសជុលស្រះស្រង់ ដែលជាកម្មវត្ថុនៃគម្រោងរយៈពេលវែងរបស់និស្សិតម្នាក់នៃជំនាន់ទីមួយ ត្រូវបានទទួលយក ហើយកំពុងតែប្រព្រឹត្តទៅនៅពេលបច្ចុប្បន្ននេះ។ គម្រោងនេះទទួលជំនួយពីក្រុមហ៊ុន Jet Tour។

ឧទាហរណ៍ដ៏គួរឲ្យចាប់អារម្មណ៍មួយទៀត គឺទាក់ទងនឹងនិស្សិតម្នាក់ក្នុងចំណោមនិស្សិតជំនាន់ទីពីរ ដែលជាស្ថាបត្យករឯករាជ្យ ត្រូវបានជ្រើសរើសដោយអប្សរានិងក្រុម Holcim ដើម្បីអោយត្រួតពិនិត្យការងារគម្រោងជួសជុលវត្តបាគង។

សិស្សចំនួនពីរនាក់នៃជំនាន់ទីបីស្ថិតនៅក្នុងក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរជាតិព្រះវិហារ៖ គឺស្ថាបត្យករម្នាក់និងបុរាណវិទូម្នាក់។ ប្រធានបទរបស់ក្រុមការងារបច្ចុប្បន្នគឺស្តីពី គោបុរៈទី៥។

[ស្លាយ] កាលពីពេលមុន អតីតនិស្សិតចំនួន២នាក់នៃជំនាន់ទីមួយត្រូវបានប្រគល់ទៅឲ្យអាជ្ញាធរព្រះវិហារដោយអប្សរា។ ពួកគេទទួលបន្ទុកដឹកនាំកម្មវិធីស្តីពីកិច្ចអន្តរាគមន៍បន្ទាន់នៅនឹងរមណីយដ្ឋាន។

[ស្លាយ] ទាក់ទងនឹងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សិស្សចំនួនប្រាំមួយនាក់របស់មជ្ឈមណ្ឌលដែលមកពីក្រសួងវប្បធម៌ ស្ថិតនៅក្នុងបេសកកម្មបេតិកភណ្ឌ។ បេសកកម្មបេតិកភណ្ឌត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៥។ ទិសដៅរបស់បេសកកម្មនេះមានដូចតទៅ៖ ការធ្វើបញ្ជីសារពើភណ្ឌលើបេតិកភណ្ឌ ការធ្វើអត្តសញ្ញាណកម្មបេតិកភណ្ឌនិងការធ្វើអោយគេទទួលស្គាល់បេតិកភណ្ឌ និងការបង្កើតឧបករណ៍សម្រាប់ធ្វើការអភិរក្សផងដែរ។

[ស្លាយ] នៅក្នុងផ្នែកបេតិកភណ្ឌអង្គរ សាលាផ្តោតទៅលើបេតិកភណ្ឌដែលមានការគំរាមកំហែងបំផុត៖ ដូចជាបេតិកភណ្ឌទីក្រុង បេតិកភណ្ឌសាសនា និងបេតិកភណ្ឌរបស់អ្នកស្រុកផងដែរ។ ការងារស្តីពីបញ្ជីសារពើភណ្ឌនិងការធ្វើអត្តសញ្ញាណកម្មបេតិកភណ្ឌទាក់ទងជាពិសេសទៅនឹងបេតិកភណ្ឌរបស់ទីក្រុងភ្នំពេញ។

[ស្លាយ] ប្រធានបទនៃគម្រោងរយៈពេលវែងរបស់និស្សិតម្នាក់ក្នុងជំនាន់ទីពីរទាក់ទងនឹងអគារមួយ ដែលសាងសង់ឡើងនៅឆ្នាំ១៩១៧។ ការជួសជុលអគារនេះឡើងវិញត្រូវបានធ្វើឡើងដោយមានជំនួយយ៉ាងសកម្មពីសំណាក់

បេសកកម្មបេតិកភណ្ឌ។ ប៉ុន្តែត្រូវកត់សម្គាល់ថា គ្រប់អនុសាសន៍ទាំងអស់មិនត្រូវបានគេអនុវត្តន៍តាមទាំងអស់នោះទេ។ នៅពេលបច្ចុប្បន្ននេះ បេសកកម្មមានតួនាទីត្រឹមតែផ្តល់ប្រឹក្សាប៉ុណ្ណោះ ជាអាទ៍ទាក់ទងនឹងពណ៌ថ្នាំលាប ជញ្ជាំងឬក៏វត្ថុធ្វើពីឈើ។
ដើម្បីពង្រីកចំណេះធ្វើរបស់សិប្បករឬសហគ្រាស បេសកកម្មអាចទទួលបន្ទុកជួសជុលអគារនានា។ បេសកកម្មបានធ្វើរឿងនេះជាច្រើនលើកមកហើយសម្រាប់ស្ថាប័នសាធារណៈនានា ដូចជាការជួសជុលនិងការរៀបចំសាលពិព័រណ៍សារមន្ទីរជាតិទីក្រុងភ្នំពេញ ព្រមទាំងការជួសជុលនិងការរៀបចំអគារមជ្ឈមណ្ឌលបុប្ផាណាជាដើម។

[ស្លាយ] អតីតនិស្សិតចំនួន៦នាក់របស់មជ្ឈមណ្ឌលដែលត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅបេសកកម្មបេតិកភណ្ឌ បានបង្កើតឧបករណ៍សម្រាប់ការអភិរក្សបេតិកភណ្ឌ ដោយអនុវត្តន៍តាមវិធីសាស្ត្រដែលបានរៀន។ ធ្វើការសិក្សា មុននឹងឈានដល់ការជួសជុល អាចនាំទៅដល់ការបង្កើតកម្មវិធីដែលមានរយៈពេលច្រើនឆ្នាំ ដូចជានៅសារមន្ទីរជាតិជាដើម។

[ស្លាយ] ការធ្វើប្លង់អភិរក្សសង្កាត់ប្រវត្តិសាស្ត្រល្បីៗនានានៅទីក្រុងភ្នំពេញ ជាបឋមគឺសង្កាត់នៅម្តុំប្រៃសណីយ៍។ ប្លង់អភិរក្សមានការវិភាគដោយស្វ័យប្រវត្តអំពីអគារនានា ប្លង់ប្រវត្តិសាស្ត្រនិងបុរាណវិទ្យា ប្លង់ស្ថាបត្យកម្ម ព្រមទាំងប្លង់អភិរក្សភ្ជាប់ជាមួយអនុសាសន៍ខាងស្ថាបត្យកម្មសម្រាប់អគារនីមួយៗ។

[ស្លាយ] ដូច្នេះ ដោយសរុបលទ្ធផលលើការសិក្សាទាំងបីឆ្នាំ នៅក្នុងចំណោមសិស្សជនជាតិខ្មែរចំនួន២៥នាក់ដែលទទួលបានការបណ្តុះបណ្តាលពីមជ្ឈមណ្ឌល មានសិស្សតែម្នាក់គត់ដែលមានការងារគ្មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការអភិរក្សបេតិកភណ្ឌ។ សិស្សចំនួនបីនាក់ទៅបន្តការសិក្សានៅបរទេសក្នុងវិស័យបេតិកភណ្ឌ ហើយសិស្សដទៃទៀតធ្វើការងារទាក់ទងនឹងការអភិរក្សនិងការលើកតម្លៃបេតិកភណ្ឌជាតិ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី។

**បទអន្តរាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើនចំពោះបទបង្ហាញរបស់លោកស្រីស្តីពីការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកបេតិកភណ្ឌ។ ខ្ញុំគិតថា ឥឡូវនេះបទបង្ហាញទាំងអស់ទាក់ទងនឹងកិច្ចសហប្រតិបត្តិការរបស់ប្រទេសនានាត្រូវបានធ្វើរួចហើយ។ នៅចុងបញ្ចប់នៃជំពូកស្តីពីការអភិវឌ្ឍប្រកបដោយចីរភាពនេះ ខ្ញុំសូមអញ្ជើញលោក Delanghe មកពីយូណេស្កូទីក្រុងភ្នំពេញ ឡើងមកធ្វើរបាយការណ៍ស្តីពីការពិភាក្សាដែលបានធ្វើកាលពីថ្ងៃម្សិលមិញ ទាក់ទងនឹងការងាររបស់ក្រុមអ្នកជំនាញ អាដ ហុក ផ្នែកការអភិវឌ្ឍប្រកបដោយចីរភាព។ដោយហេតុថាអាណត្តិនិងអាទិភាពការងាររបស់ក្រុមអ្នកជំនាញ អាដ ហុក សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពមិនទាន់មានលក្ខណៈច្បាស់លាស់និងមានក្របខ័ណ្ឌត្រឹមត្រូវនៅឡើយនោះ ទើបមានការពិភាក្សាគ្នាកាលពីថ្ងៃម្សិលមិញ។ ដូច្នេះ ខ្ញុំសូមជូនវេទិកាទៅលោក Delanghe។

## V.7 ការពិចារណាកាលពីថ្ងៃទី ១៤ វិច្ឆិកា ២០០៩ លើទិសដៅការងាររបស់ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដោយលោក Philippe Delanghe អ្នកឯកទេសកម្មវិធីវប្បធម៌ប្រចាំការិយាល័យអង្គការយូណេស្កូនៅទីក្រុងភ្នំពេញ

សូមគោរព ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិអប្សរា។ សូមគោរព ឯកឧត្តមសហប្រធាន។ សូមគោរព ឯកឧត្តមព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ។ ឯកឧត្តម លោក លោកស្រីជាទីរាប់អាន!

ដូចឯកឧត្តម អស់លោក លោកស្រី ដែលមានវត្តមាននៅទីនេះបានដឹងរួចមកហើយថា គណៈកម្មាធិការសម្របសម្រួលអន្តរជាតិដើម្បីកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៣ នៅឯ សន្និសីទទីក្រុងតូក្យូ។ យើងអាចសម្គាល់បានថា ជិត ២០ឆ្នាំកន្លងទៅហើយ ដែលទាំងទិដ្ឋភាពអភិរក្ស និងទិដ្ឋភាពអភិវឌ្ឍន៍ ត្រូវបានដាក់បញ្ចូលរួចទៅហើយទៅក្នុងការបង្កើតឈ្មោះនៃព្រឹត្តិការណ៍នេះ។

នៅព្រឹកនេះ ជំនួយការអគ្គនាយកផ្នែកវប្បធម៌របស់អង្គការយូណេស្កូ គឺ លោកស្រី Françoise Rivière បានចង្អុលបង្ហាញចំៗថា ទន្ទឹមនឹងគោលដៅចម្បងរបស់ ICC-Angkor ដែលផ្តោតភាគច្រើនទៅលើកិច្ចការអភិរក្សនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ទិដ្ឋភាពនៃការអភិវឌ្ឍកាន់តែសំខាន់ឡើងៗ ជាពិសេសដោយសារតែភាពជោគជ័យនៃយុទ្ធនាការអភិរក្សដែលមានអាយុកាល១៦ឆ្នាំហើយ បើគិតរហូតមកដល់ពេលបច្ចុប្បន្ននេះ។

ដោយសារសារៈសំខាន់ឬអាចនិយាយថាភាពចាំបាច់នៃទិដ្ឋភាពនៃការអភិវឌ្ឍ ទើបមានការលើកឡើងនិងបញ្ជាក់ពី "ការអភិវឌ្ឍប្រកបដោយនិរន្តភាព" នៅក្នុងសន្និសីទទីក្រុងប៉ារីស ឆ្នាំ២០០៣។ ដូចឯកឧត្តមអគ្គរាជទូតជប៉ុន លោក Masafumi Kuroki បានលើកឡើងរួចមកហើយថាក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព បានចូលរួមក្នុងការងារនេះដំបូងនៅឆ្នាំ២០០៧ ដោយមានការគាំទ្រពីរដ្ឋាភិបាលបារាំង ជប៉ុន និងអាជ្ញាធរជាតិអប្សរា។

នៅក្នុងដំណាក់កាលនៃការចាប់ផ្តើមនេះ វាមិនមានភាពងាយស្រួលឡើយ ជាពិសេសពាក់ព័ន្ធនឹងផ្នែកដ៏ធំដែលរួមបញ្ចូលនូវពាក្យថា "ការអភិវឌ្ឍប្រកបដោយនិរន្តភាព" បើប្រៀបធៀបជាមួយនឹងសហសេវិករបស់ពួកគេ ពោលគឺ ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិរក្ស ដែលវិសាលភាពការងាររបស់ពួកគេត្រូវបានបញ្ជាក់និងកំណត់យ៉ាងត្រឹមត្រូវ។

ការអភិវឌ្ឍប្រកបដោយនិរន្តរភាពរួមបញ្ចូលគ្រប់យ៉ាង ចាប់តាំងពីបញ្ហាបរិស្ថាន ទីក្រុង ទេសចរណ៍ ធនធានទឹក បញ្ហាសហគមន៍មូលដ្ឋាន រហូតដល់ទិដ្ឋភាពផ្សេងៗទៀតជាច្រើនដែលអាចនឹងរួមចំណែកដល់អនាគតដ៏យូរអង្វែងនៃរមណីយដ្ឋានអង្គរ។ ទាំងនេះពិតជាបង្ហាញនូវបញ្ហាប្រឈមយ៉ាងធំសម្រាប់ក្រុមអ្នកជំនាញ អាដ ហុក របស់

យើង។ វាជាបញ្ហាប្រឈមដែលធ្វើអោយយើងងាយដើរខុសទិសដៅណាមួយដែលត្រូវអនុវត្ត។ ទោះបីជាអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសនៅពេលចាប់ផ្តើមដំបូង បានបំពេញបេសកកម្មរួមគ្នាជាមួយសហសេវិករបស់ខ្លួន ដែលជាអ្នកជំនាញ អាដ ហុក ដើម្បីការអភិរក្ស និងមានការយល់ដឹងកាន់តែច្បាស់ពីយន្តការនិងដំណាក់កាលដែលពួកគេត្រូវធ្វើ ហើយទោះបីពួកគេធ្លាប់បានចុះទៅពិនិត្យនៅតាមរមណីយដ្ឋាននានាជាច្រើនលើកក៏ដោយ ដូចជាក្រុងសៀមរាបនិងតំបន់ជុំវិញ និងទោះបីជាពួកគេបានចូលរួមក្នុងសិក្ខាសាលាទាំងបួនស្តីពីបញ្ហាទឹក ដែលរៀបចំឡើងក្នុងក្របខ័ណ្ឌ ICC រវាងឆ្នាំ២០០៧-២០០៩ក៏ដោយ ក៏ពួកគេនៅតែត្រូវខិតខំស្វែងយល់នូវអ្វីៗគ្រប់យ៉ាងនៅក្នុងវិស័យដ៏ទូលំទូលាយជាអនេកដែលពោរពេញទៅដោយបញ្ហាប្រឈម និងកលានុវត្តភាព។

ក្នុងអំឡុងឆ្នាំ២០០៨ ការពិភាក្សាមួយចំនួនបានចាប់ផ្តើមធ្វើឡើងកាន់តែច្បាស់លាស់ជាមួយសហសេវិកទាំងពីររូបរបស់យើង គឺសាស្ត្រាចារ្យ Jean Marie Furt និងលោក Tetsuji Goto ស្តីពី វិធីដែលអាចធ្វើឲ្យការងារកាន់តែប្រសើរឡើង។ សំនួរដែលលើកឡើងរួមមាន៖

-តើក្រុមអ្នកជំនាញ អាដ ហុក គួរផ្តោតទៅលើវិស័យធំៗ ឬ ប្រធានបទពិសេសៗអ្វី?

-តើ ក្រុមអ្នកជំនាញ អាដ ហុក ចាំបាច់ត្រូវចូលរួមគ្រប់សម័យប្រជុំរបស់ ICC ឬ គួរមកចូលរួមប្រជុំតែមួយដងក្នុងមួយឆ្នាំ ដែលប៉េសកកម្មនីមួយៗអាចមានរយៈពេលយូរ?

-តើ ក្រុមអ្នកជំនាញ អាដ ហុក គួរមានជំនាញបំពេញអោយគ្នាទៅវិញទៅមកដែរឬទេ ខណៈដែលសហសេវិក របស់គេដើម្បីការអភិរក្សមានលក្ខណៈបែបនេះរួចទៅហើយនោះ?

តាមរយៈការពិភាក្សាទាំងឡាយ ចំណោទសួរទាំងនេះបង្កើតបានជាមូលដ្ឋានដើម្បីសម្រេចរៀបចំសម័យប្រជុំពិសេសមួយនៅក្នុងក្របខ័ណ្ឌនៃសម័យប្រជុំពេញអង្គលើកទី ១៦ របស់ ICC-Angkor រវាង ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព សហប្រធាន ICC និងលេខាធិការដ្ឋាន ICC ក្នុងបំណងរិះរកគំនិតឆ្ពោះទៅបង្កើតរូបមន្តថ្មីមួយដែលធ្វើឲ្យអ្នកជំនាញទាំងនោះអាចបំពេញប៉េសកកម្មរបស់ខ្លួនបានប្រសើរជាងមុន កំណត់គោលដៅរបស់ខ្លួននិងផ្តល់អនុសាសន៍បានល្អប្រសើរ។ សម័យប្រជុំនេះបានធ្វើឡើងកាលពីពេលរសៀលម្សិលមិញនេះ។

កិច្ចប្រជុំនេះបានផ្តល់នូវផ្លែផ្កាយ៉ាងច្រើន ដោយសារក្នុងអំឡុងពេលនោះ ភាគីនានាដែលពាក់ព័ន្ធបានធ្វើអន្តរាគមន៍ប្រកបដោយការស្តាបនា ដែលទីបំផុតបានឈានទៅដល់ការបង្កើតក្របខ័ណ្ឌដែលមានរចនាសម្ព័ន្ធមួយសម្រាប់ក្រុមអ្នកជំនាញ អាដ ហុក ។ ដូច្នេះហើយយើងបានដាក់ចេញនូវគោលការណ៍ណែនាំមួយគ្រប់គ្រាន់ ដែលគេអាចយកទៅអនុវត្តបាននៅក្នុងកិច្ចប្រជុំបច្ចេកទេសលើកក្រោយរបស់ ICC-Angkor។

គោលការណ៍ណែនាំទាំងនោះរួមមាន៖

១. ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តភាពគួរមកបំពេញប៉េសកកម្មយ៉ាងតិចម្តងក្នុងមួយឆ្នាំ។

២. វិស័យសំខាន់ៗដែលត្រូវសិក្សា រួមមាន ទេសចរណ៍ ធនធានទឹក និងបេតិកភណ្ឌវប្បធម៌ និងធម្មជាតិក្នុង

ទីក្រុងសៀមរាប ដោយយោងទៅតាមប្រព័ន្ធកំណត់តំបន់។

៣. នៅក្នុងវិស័យទាំងនេះ ប្រធានបទជាក់លាក់នៃការសិក្សាគួរធ្វើឡើងដោយមានកិច្ចសហការជាមួយអាជ្ញាធរជាតិអប្សរា

៤. ប្រធានបទជាក់លាក់ទាំងនេះគួរធ្វើការសិក្សាក្នុងរយៈពេលពី ២ ទៅ ៣ឆ្នាំដើម្បី សម្រួលឲ្យមានការវិភាគស៊ីជម្រៅនិងការប្រមូលផ្តុំនូវអនុសាសន៍ផ្សេងៗដែលពាក់ព័ន្ធ

៥. មុនសម័យប្រជុំបច្ចេកទេសលើកទី ១៩ របស់ ICC-Angkor (ខែមិថុនា ឆ្នាំ២០១០) ក្រុមអ្នកជំនាញ អាដហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តភាព ដោយមានរួមសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរជាតិអប្សរា នឹងកំណត់ប្រធានបទនៃការសិក្សាដើម្បីបញ្ជូនទៅឲ្យសហប្រធាន ICC តាមរយៈលេខាធិការដ្ឋានរបស់ ICC។

៦. ក្រុមអ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តភាព នឹងជួយសម្រួលដំណើរការនេះតាមរយៈបទពិសោធន៍របស់ពួកគេដែលមានកន្លងមក។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណចំពោះការពន្យល់បំភ្លឺរបស់លោកស្តីពីលទ្ធផលនៃការពិភាក្សាកាលពីថ្ងៃម្សិលមិញ។ ដូច្នេះ ខ្ញុំសូមជូនយោបល់សម្រាប់កិច្ចពិភាក្សាទូទៅ។ ហេតុដូច្នេះ តើលោក លោកស្រីមានការអត្ថាធិប្បាយឬក៏សំណួរអ្វីដែរឬទេ? តើមាននរណាម្នាក់ចង់មានយោបល់ដែរឬទេ?

## ការពិភាក្សាទូទៅ

**បទអត្ថាធិប្បាយរបស់លោក ប៊ុន ណារិទ្ធ៖** សូមអរគុណលោកសហប្រធាន។ ខ្ញុំសូមឆ្លើយទៅនឹងសំណួររបស់អ្នកជំនាញ អាដ ហុក ផ្នែកអភិរក្ស គឺលោក Pierre André Lablaude ដែលបានសួរកាលពីព្រឹកមិញនេះ ទាក់ទងនឹងការបើកប៉មកណ្តាលរបស់អង្គរវត្តឬហៅថាបាកាន ជូនសាធារណៈជនទស្សនា។ ជាការពិតណាស់ អាជ្ញាធរជាតិអប្សរាបានសាងសង់ជណ្តើរឈើចំនួនពីរនៅផ្នែកខាងកើត។ ប៉ុន្តែ ការងាររៀបចំថែរគឺជាការចាំបាច់ដើម្បីជួយសម្រួលដល់ការឆ្លងកាត់របស់ភ្ញៀវ។ យើងសង្ឃឹមថាការងារនឹងបញ្ចប់រួចរាល់នៅក្នុងរយៈពេលពីរខែទៀតយ៉ាងយូរ។ ការគ្រប់គ្រងលំហូរអ្នកទេសចរនឹងត្រូវអនុវត្តន៍។ យើងបានគ្រោងទុកថានឹងអនុញ្ញាតឲ្យភ្ញៀវចូលទស្សនាម្តងៗចំនួន១០០នាក់ និងផ្តល់អាទិភាពដល់ភ្ញៀវជាតិនៅក្នុងអំឡុងពេលថ្ងៃបុណ្យសាសនា។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើនចំពោះចម្លើយរបស់លោកទៅនឹងសំណួរដែលសួរកាលពីព្រឹកមិញនេះ ដែលទាក់ទងនឹងបាកាន ជណ្តើររបស់បាកាន ដែលនឹងត្រូវបើកជូនសាធារណៈជនចូលទស្សនានៅក្នុងរយៈពេលពីរខែទៀតយ៉ាងយូរ។ តើមានសំណួរផ្សេងទៀតទេ? សូមអញ្ជើញលោកឯកអគ្គរដ្ឋទូត។

**សេចក្តីបញ្ជាក់របស់ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់៖** សូមអរគុណច្រើនឯកឧត្តមសហប្រធានដែលបានផ្តល់ឱកាសដល់រូបខ្ញុំដើម្បីធ្វើកិច្ចអន្តរាគមន៍ដ៏ខ្លីនេះ។ បន្ទាប់ពីបទបង្ហាញនានានៅក្នុងវគ្គចុងក្រោយនេះ ខ្ញុំសូមបញ្ជាក់ជូនរាជរដ្ឋាភិបាល និងអាជ្ញាធរអប្សរាអំពីការគាំទ្រជាប្រចាំរបស់រដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់។ ការគាំទ្ររបស់យើងចំពោះការអភិរក្ស

អង្គរមានរយៈពេលជាងដប់ប្រាំឆ្នាំមកហើយ ដោយមានជាអាទិ៍ការពង្រឹងសមត្ថភាពនៅក្នុងផ្នែកអភិរក្សថ្ម ដែលស្ថិតនៅក្រោមការដឹកនាំរបស់ក្រុម GACP។ ហើយយើងមានសេចក្ដីរីករាយយ៉ាងខ្លាំងដោយឃើញថាមានអ្នកជំនាញជនជាតិខ្មែរកាន់តែច្រើនឡើងៗ មកចូលរួមនៅក្នុងអាជ្ញាធរអប្សរា។

គម្រោងបច្ចុប្បន្ននឹងបញ្ចប់នៅជំណាច់ឆ្នាំ២០១០ ហើយយើងពិតជាមានបំណងពន្យាររយៈពេលនេះទៀត។ DED ដែលជានាយកដ្ឋានផ្នែកអភិវឌ្ឍន៍របស់ប្រទេសអាល្លឺម៉ង់បានបញ្ជូនបុគ្គលិកមកអាជ្ញាធរអប្សរា ស្របតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការនៅក្រោមទម្រង់បច្ចុប្បន្ន ដែលនឹងបញ្ចប់នៅឆ្នាំ២០១៤។ សូមអរគុណ។

**សេចក្ដីកត់សម្គាល់របស់អ្នកតំណាងស្ថានទូតឡាវ៖** លោក លោកស្រីជាទីគោរព។ តាងនាមឲ្យស្ថានទូតឡាវ ខ្ញុំនឹងមានសំណួរជាច្រើនដែលត្រូវសួរទៅលោក លោកស្រី។ ប៉ុន្តែជាបឋម ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះអាជ្ញាធរអប្សរា មានជាអាទិ៍លោកសាស្ត្រាចារ្យ Azedine Beschaouch ព្រោះថាអាជ្ញាធរអប្សរាគ្រោងនឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលឡាវ ដើម្បីជួយប្រទេសឡាវឲ្យទទួលបានចំណេះដឹងឲ្យបានកាន់តែប្រសើរឡើងអំពីការអភិរក្សសម្រាប់កិច្ចសហប្រតិបត្តិការនាពេលអនាគត។ ដូច្នេះ យើងនឹងមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំងប្រសិនបើលោក លោកស្រីអាចធ្វើសហប្រតិបត្តិការជាមួយជនជាតិឡាវយើង ព្រោះថាយើងកំពុងតែជួសជុល Vat Phu ឡើងវិញ ដូចជាអង្គរវត្តរបស់លោក លោកស្រីដែរ គឺរមណីយដ្ឋាន Vat Phu Champassak។ ខ្ញុំសូមថ្លែងអំណរគុណឯកឧត្តម លោកជំទាវ លោក លោកស្រី។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើន។ ខ្ញុំសូមបញ្ចប់ជំពូកនេះហើយឆ្លងទៅជំពូកទីប្រាំមួយស្ដីពីការលើកតម្លៃបេតិកភណ្ឌ។ នោះគឺគម្រោងដាក់ភ្លើងបំភ្លឺអង្គរ ហើយខ្ញុំគិតថា នៅពេលកន្លងទៅមានការពិភាក្សាជាច្រើនរួចមកហើយលើចំណុចនេះ។ ដូច្នេះ ខ្ញុំនឹងស្នើទៅលោកសាស្ត្រាចារ្យ Beschaouch ឲ្យធ្វើការណែនាំឲ្យស្គាល់លោក Alain Guilhot និងលោក Olivier Binst ដែលនឹងបង្ហាញប្រាប់យើងអំពីគំរូនៃគម្រោងដាក់ភ្លើងបំភ្លឺ។

# VI. ការលើកតម្លៃបេតិកភណ្ឌ

## VI.1 គម្រោងដាក់ភ្លើងបំភ្លឺអង្គរនៅតាមបទដ្ឋានរមណីយដ្ឋានបេតិកភណ្ឌពិភពលោក៖

### ក. សេចក្ដីផ្ដើម ដោយលោកសាស្ត្រាចារ្យ Azedine Beschaouch

**លោក** Beschaouch ៖

សូមអរគុណលោកប្រធាន។ ខ្ញុំសូមរំឭកប្រាប់អ្នកចូលរួមសម័យប្រជុំរបស់យើងអំពីបញ្ហាទាក់ទងនឹងគម្រោងដាក់ភ្លើងបំភ្លឺ ដោយហេតុថាមានបទបង្ហាញជាច្រើនលើកច្រើនសារមកហើយទាក់ទងនឹងរឿងនេះ មានជាអាទិ៍នៅក្នុងសម័យប្រជុំបច្ចេកទេសលើកទី១៨កន្លងទៅនេះ។ ហើយចំពោះសេចក្ដីសន្និដ្ឋាន ខ្ញុំប្រហែលជាត្រូវជម្រាបជូនដោយរបៀបសង្កត់ធ្ងន់បន្តិច ប៉ុន្តែយើងត្រូវតែសង្កត់ធ្ងន់បែបនេះព្រោះវាទាក់ទងនឹងអង្គរ ដែលជារមណីយដ្ឋានដ៏ល្អបំផុតមួយក្នុងចំណោមរមណីយដ្ឋានដ៏ល្អបំផុតនានានៅក្នុងពិភពលោក ជារមណីយដ្ឋានដ៏ប្រណិតបំផុតមួយនៅក្នុងបញ្ជី

បេតិកភណ្ឌពិភពលោករបស់យូណេស្កូ។

របៀបបញ្ចាំងភ្លើងដែលគេបានបង្ហាញជូនយើងមិនត្រឹមតែជាការរំលោភលើរមណីយដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែជាការរំលោភលើបទដ្ឋានអន្តរជាតិថែមទៀត។ ដោយហេតុដូច្នេះហើយ និងជាភ័ព្វសំណាងល្អ រាជរដ្ឋាភិបាលនិងយើងទាំងអស់គ្នា យើងមានការចាប់អារម្មណ៍បំផុតចំពោះបញ្ហានេះ ហើយយើងសូមសម្តែងនូវការដឹងគុណចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងជាប្រធានអាជ្ញាធរជាតិអប្សរា ដែលបានសម្រេចចិត្តផ្លាស់ប្តូរវិធីសាស្រ្ត ហើយថែមទាំងផ្លាស់ប្តូរទិសដៅ ធ្វើការពិនិត្យពិចារណាលើគម្រោងទាំងមូលឡើងវិញ។

បន្ទាប់មកទៀត ឯកឧត្តមបានសំណូមពរដល់យើងឲ្យស្វែងរកលទ្ធភាពជ្រើសរើសអ្នកជំនាញនៅក្នុងចំណោមអ្នកជំនាញដ៏ឆ្នើមៗបំផុតនៅក្នុងបញ្ជីរបស់យូណេស្កូ ICCROM ICCOMOS។ល។និង។ល។ យើងក៏បានទាក់ទងជាពិសេសទៅលោកសាស្រ្តាចារ្យ Mounir Bouchenaki ដែលមានវត្តមាននៅទីនេះស្រាប់ គឺមិនមែនក្នុងឋានៈលោកជាអ្នកជំនាញទេ ប៉ុន្តែក្នុងឋានៈលោកជាអគ្គនាយករបស់ ICCROM។ ហើយចាប់ផ្តើមចេញពីចំណុចនេះ យើងបានធ្វើជម្រើសមួយដែលយើងបានដាក់ជូនឯកឧត្តមពិនិត្យ។ ក្រុមការងារដែលត្រូវបានស្នើទៅរាជរដ្ឋាភិបាល ហើយដែលឯកឧត្តមបានជ្រើសរើសយកនោះ គឺជាក្រុមការងារដែលដឹកនាំដោយអ្នកជំនាញម្នាក់ លោកបានដាក់ភ្លើងបំភ្លឺប្រាង្គប្រាសាទនានានៅក្នុងពិភពលោកទាំងមូលអស់រយៈពេលចំនួន៣០ឆ្នាំមកហើយ ចាប់ពីប្រទេសជប៉ុនរហូតដល់ប្រទេសកាណាដា។ មិនត្រឹមតែនៅប្រទេសបារាំងប៉ុណ្ណោះទេ ជាពិសេសនៅទីក្រុង Lyon ដោយហេតុថាឈ្មោះ Alain Guilhot ត្រូវបានគេស្គាល់ជាដំបូងនៅទីក្រុង Lyon ប៉ុន្តែលោកល្បីឈ្មោះគ្រប់ទីកន្លែង នៅទីក្រុង Séoul នៅ Tokyo នៅ Kyoto នៅប្រទេសអ៊ីតាលី នៅប្រទេសបារាំង។ល។និង។ល។

លោកបានចាត់ការរឿងនេះជាមួយនឹងក្រុមការងាររបស់លោក ហើយយើងរីករាយនឹងជម្រាបជូនថា ស្របតាមសេចក្តីណែនាំដែលបានផ្តល់ជូនអាជ្ញាធរជាតិអប្សរា និងតាមអនុសាសន៍របស់គណៈកម្មាធិការយើង លោកនឹងផ្តល់ជូន មិនមែនជាវិធីសាស្រ្តនោះទេ ប៉ុន្តែគឺសៀវភៅបន្ទុកមួយដែលឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់រដ្ឋាភិបាល។

កិច្ចការនេះត្រូវបានធ្វើ ហើយយើងសូមថ្លែងអំណរគុណជាពិសេសចំពោះអាជ្ញាធរប្រទេសបារាំងដែលបានជួយយើងចំពោះសាលាបារាំងផ្នែកបុរាណវិទ្យានិងប្រវត្តិសាស្រ្តនៅទីក្រុង Rome ដែលបានជួយយើង។ ប៉ុន្តែជាពិសេសជាងនេះទៅទៀតនោះ យើងសូមថ្លែងអំណរគុណចំពោះអគ្គនាយក ICCROM គឺលោក Bouchenaki ដែលជាមិត្តភ័ក្តិរបស់ខ្ញុំលោកបានស្វាគមន៍យើងនៅក្នុងកិច្ចប្រជុំអំពីរឿងនេះនាពេលនោះ។ តំណាងអាជ្ញាធរអប្សរាក៏មានវត្តមាននាពេលនោះ ព្រមទាំងរូបខ្ញុំផ្ទាល់ក្នុងឋានៈជាលេខាធិការរបស់លោក លោកស្រី ខ្ញុំបានធ្វើរបាយការណ៍ ហើយយើងបានរៀបចំឯកសារមួយ ដែលកំណត់យ៉ាងច្បាស់លាស់នូវលក្ខខណ្ឌនៃការរៀបចំការសិក្សាជាមុនស្តីពីភាពអាចធ្វើបាន ស្របតាមបទដ្ឋានអន្តរជាតិ។ អ្វីដែលលោក លោកស្រីនឹងឃើញនៅថ្ងៃនេះ ហើយនិងធ្វើការវាយតម្លៃដោយលោក លោកស្រីផ្ទាល់ គឺការសិក្សាស្តីពីភាពអាចធ្វើបានជាមុននេះ ហើយគឺលោក Alain Guilhot ដែលនឹងបង្ហាញការសិក្សាជាមុននេះជូនលោក លោកស្រី។

ប៉ុន្តែនៅក្នុងអំឡុងពេលបទបង្ហាញនេះ យើងបានសំណូមពរទៅលោក Olivier Binst ដែលស្ថិតនៅក្នុងក្រុមការងារនេះឲ្យធ្វើបទបង្ហាញ។ បើនិយាយឲ្យខ្លី តើលោក Olivier Binst ជានរណា? លោក Olivier Binst មានទំនាក់ទំនងជាមួយយូណេស្កូអស់រយៈពេលជាង២០ឆ្នាំមកហើយ ព្រោះគាត់បានមានទំនាក់ទំនងជាមួយស្ថាប័នបារាំងមួយដែល

ជាអកុសលបានបិទទ្វារទៅហើយ គឺជាស្ថាប័នដែលធ្វើអ្វីៗជាច្រើនសម្រាប់យើងនៅយូណេស្កូ ក្នុងពេលដែលលោក Bouchenaki ធ្វើជានាយកផ្នែកបេតិកភណ្ឌ និងបន្ទាប់មកទៀតជាអគ្គនាយករងទទួលបន្ទុកផ្នែកវប្បធម៌។ នៅពេលនោះមានរូបថតបេតិកភណ្ឌជាច្រើន ហើយរូបថតទាំងនោះមានរក្សាទុកនៅយូណេស្កូ។ នោះគឺគម្រោងមួយដែលមានឈ្មោះថា បេតិកភណ្ឌឆ្នាំ២០០១។ ខ្ញុំជឿថា ឥឡូវនេះលោក Olivier Binst នៅប្រទេសបារាំង លោកធ្វើការនៅក្នុងសហគ្រាសដ៏ធំមួយដែលទទួលបន្ទុកខាងបណ្តាញសារព័ត៌មាន ខាងការផ្សព្វផ្សាយព័ត៌មាន។ ហើយគឺនៅក្នុងតួនាទីនេះហើយដែលយើងបានស្នើឲ្យលោកផ្តល់ការចង្អុលបង្ហាញដល់យើង ដោយហេតុថាជាញឹកញាប់ លោកបានចូលរួមនៅក្នុងគម្រោងដាក់ភ្លើងបំភ្លឺទាំងនេះ។
ដូច្នេះ ដោយមានការអនុញ្ញាតពីលោកសហប្រធាន ជាពិសេសពីលោកសហប្រធានជប៉ុន យើងសូមផ្តល់វេទិកាទៅពួកគេទាំងពីរដើម្បីឲ្យពួកគេបង្ហាញអំពីការសិក្សាជាមុនស្តីពីភាពអាចធ្វើបាន។

## ខ. បទបង្ហាញ ដោយលោក Alain Guilhot និងលោក Olivier Binst

### លោក Guilhot ៖

សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ ឯកឧត្តមប្រធានលោកស្រីនាយិកាយូណេស្កូ លោក លោកស្រីជាអគ្គនាយក និងលោក លោកស្រីជាទីគោរពរាប់អាន!

សម្រាប់រូបខ្ញុំដែលជាស្ថាបត្យករផ្នែកពន្លឺ ធ្វើដំណើរមកកាន់អង្គរធ្វើអោយខ្ញុំសប្បាយ សប្បាយខ្លាំងណាស់ ប៉ុន្តែក៏ជាបញ្ហាប្រឈមដ៏ធំនិងជាការទទួលខុសត្រូវមួយដ៏ខ្ពស់ផងដែរ។ តាមពិតទៅ កាលពីប៉ុន្មានខែមុន នៅពេលដែល Olivier និងខ្ញុំបានមកលើកទីមួយតាមការអញ្ជើញ ដើម្បីធ្វើការវិភាគ ខ្ញុំបានចោទសួរខ្លួនឯងនៅពេលត្រឡប់ទៅវិញថា៖ "តើយើងអាចដាក់ភ្លើងបំភ្លឺបានដែរឬទេ? តើទៅរួចដែរឬទេ? តើពន្លឺព្រះចន្ទនិងពន្លឺផ្កាយមិនគ្រប់គ្រាន់ទេឬ?

ប៉ុន្តែព្រះចន្ទនិងផ្កាយមិនមែនចេះតែមាននៅពេលយប់នោះទេ ហើយខ្ញុំជឿជាក់យ៉ាងមុតមាំថា បច្ចេកទេសពន្លឺនាពេលបច្ចុប្បន្នអាចបញ្ចាំងពន្លឺស្រទន់ ដោយគោរពទាំងស្រុងចំពោះរមណីយដ្ឋានបេតិកភណ្ឌនេះដែលពោរពេញទៅដោយប្រវត្តិសាស្ត្រ ភាពអស្ចារ្យ និងជារមណីយដ្ឋានដ៏ពិសិដ្ឋជាទីគោរព។ ហើយនេះជាអ្វីដែលយើងនឹងបង្ហាញជូនលោក លោកស្រីក្នុងរយៈពេលប៉ុន្មាននាទីនេះ៖ គឺការវិភាគលើកទីមួយ ជាពង្រាងមួយដែលយើងខ្ញុំដាក់ជូនលោក លោកស្រីពិនិត្យ និងវិភាគអំពីលទ្ធភាព អំពីភាពអាចធ្វើបាននៃគម្រោងនេះ។

[ស្លាយ] នេះគឺជាសញ្ញាសំគាល់វប្បធម៌និងអន្តរជាតិថ្មីមួយរបស់ប្រទេសកម្ពុជា។ នេះមិនមែនជាការនិយាយអោយតែរួចពីមាត់នោះទេ។ យើងមានឆន្ទៈបម្រើអង្គរ សម្រាប់អនាគត បង្កើនចំនួនអ្នកទស្សនាដែលមានចំនួនច្រើនរួចស្រេចទៅហើយ រហូតដល់ចំនួនពីរលាននាក់នៅពេលថ្ងៃ។

ហើយតាមរយៈការទស្សនាពេលយប់នេះ ដោយហេតុថានេះគឺជាការទស្សនានៅពេលយប់ យើងចង់ផ្តល់លទ្ធភាពមួយអោយអ្នកទស្សនាស្គាល់អង្គរឲ្យបានកាន់តែប្រសើរឡើងថែមទៀត។

[ស្លាយ] ការដាក់ពន្លឺ អោយសមទៅនឹងភាពស្ងាត់ជ្រងំ ស្រគត់ស្រគំ គឺមិនអាចធ្វើខុសពីនេះឡើយ។ អង្គរមិនមែនជា

ប្រាង្គប្រាសាទដែលងាយស្រួលតម្រូវអោយត្រូវនឹងសីលធម៌នោះទេ អង្គរជាប្រាង្គប្រាសាទដ៏អស្ចារ្យមួយ ដែលយើងត្រូវប្រាកដថាពន្លឺបម្រើឲ្យរមណីយដ្ឋានពិសិដ្ឋជាទីគោរព ហើយត្រូវបំភ្លេចចោលនូវពន្លឺដែលភ្លឺខ្លាំងហួសហេតុពេក។

[ស្លាយ] រំលេចអោយឃើញនូវខ្សែបន្ទាត់និងសញ្ញាស្ថាបត្យកម្ម សោភណភាពដ៏ល្អត្រកាល ទេពកោសល្យនៃស្ថាបត្យករខ្មែរ ការចងចាំនិងសមត្ថភាពដ៏អស្ចារ្យ។

[ស្លាយ] ស្រមើស្រមៃនិងបញ្ចេញឲ្យឃើញ ទាំងពីរនេះគឺជាពាក្យពេចន៍របស់កវី "ពន្លឺ"។ ប៉ុន្តែវាក៏មានអត្ថន័យជ្រាលជ្រៅផងដែរ ព្រោះថាប្រវត្តិសាស្ត្រនិងជោគវាសនារបស់អារ្យធម៌មួយត្រូវបានចារឹកនៅទីនេះអស់រយៈពេលជាងមួយពាន់ឆ្នាំមកហើយសម្រាប់អ្នកខ្លះ ហើយខ្ញុំជឿជាក់ថា ប្រវត្តិសាស្ត្រនិងអារ្យធម៌នេះ ត្រូវតែបញ្ចេញឲ្យឃើញនៅលើឆាកវប្បធម៌និងលក្ខណៈអន្តរជាតិ ព្រោះវាស័ក្តិសមជាទីបំផុត។

ផ្តួចផ្តើមឲ្យមានសមសទ្ធាដែលកើតចេញពីសេចក្តីរំភើបនិងការគោរពដួងព្រលឹង ធ្វើអោយមានតុល្យភាពរវាងលទ្ធភាពនៃការទស្សនានិងការគោរពភាពដ៏ពិសិដ្ឋនៃរមណីយដ្ឋាន។

[ស្លាយ] ផ្តល់ ហើយពេលខ្លះផ្តល់ហើយផ្តល់ទៀត ផ្តល់អោយមុខទាំងនេះចេះនិយាយ មុខដែលមានស្នាមញញឹមប្រកបដោយភាពអាថ៌កំបាំង ស្នាមញញឹមដ៏ស្រទន់ ហើយក៏ជាស្នាមញញឹមដែលមានការផ្លាស់ប្តូរជាមួយនឹងអាទិទេពព្រះអាទិត្យដែលមានវត្តមានមួយពាន់ដងលើសយើង ហើយដែលយើងមិនអាចធ្វើបាន។ ទៅតាមដំណើរព្រះអាទិត្យ ទឹកមុខទាំងនេះអាចមានអត្ថន័យផ្សេងៗគ្នា ហើយប្រហែលជាមានសម្តីផ្សេងៗគ្នា។ ទាំងនេះហើយដែលយើងនឹងសាកល្បងបង្ហាញឲ្យឃើញដោយប្រើពន្លឺភ្លើង។

ម្យ៉ាងទៀត ខ្ញុំសូមអនុញ្ញាតជម្រាបជូនដូច្នេះ៖ ជាទូទៅគេថាពន្លឺដែលផ្ទុយនឹងពន្លឺធម្មជាតិ គឺពន្លឺសិប្បនិមិត្ត។ ខ្ញុំសូមកុំអោយគេប្រើពាក្យពន្លឺសិប្បនិមិត្តនេះទៀត។ នៅពេលខ្លះ ពន្លឺនេះជាពន្លឺអគ្គិសនីទៀតផង។ ប៉ុន្តែវាមិនមែនជាពន្លឺសិប្បនិមិត្តនោះទេ។ ហើយឥឡូវនេះ និងជាពិសេសនៅអង្គរ ខ្ញុំជឿថាពន្លឺគួរតែក្លាយទៅជាព្រះអាទិត្យនៅពេលយប់។ ពន្លឺព្រះអាទិត្យនៅពេលយប់អាចផ្តល់នូវការថ្នាក់ថ្នម នូវភាពស្រទន់ នូវការមើលឃើញចម្លាក់តូចឆ្មា។

[ស្លាយ] ពន្លឺត្រូវតែក្លាយទៅជាមគ្គុទ្ទេសក៍ម្នាក់។ ហើយដោយហេតុថាពន្លឺគឺជាមគ្គុទ្ទេសក៍ម្នាក់ មគ្គុទ្ទេសក៍នេះត្រូវនាំយើង ត្រូវដឹកដៃយើងដូចដែលសាស្ត្រាចារ្យមករកយើង ប៉ុន្តែដោយដឹងថាលោក លោកស្រីយល់ច្បាស់អំពីវប្បធម៌ មគ្គុទ្ទេសក៍អាចនិយាយថា៖ "មកមើលកន្លែងនេះ មកជាមួយខ្ញុំ។ មកមើលកន្លែងនេះ ស្អាតណាស់ អស្ចារ្យណាស់។ គឺជាប្រវត្តិសាស្ត្រមួយ ជាប្រវត្តិសាស្ត្ររបស់យើង"។

[ស្លាយ] រវាងការគោរពសាសនានិងអ្វីដែលមិនមែនសាសនា រវាងធម្មជាតិនិងវប្បធម៌ រវាងអតីតកាលនិងបច្ចុប្បន្នកាល បើនិយាយឲ្យខ្លី គឺជាបច្ចុប្បន្នកាលរបស់យើង បច្ចុប្បន្នកាលរបស់លោក លោកស្រី អនាគតកាលរបស់លោក លោកស្រី អនាគតកាលរបស់យើង សរុបទៅគឺនៅអង្គរ។

[ស្លាយ] យើងចង់ឲ្យពន្លឺនេះរំលេចនូវចម្លាក់ដ៏ល្អផូផង់ មិនខ្លាំងពេកមិនខ្សោយពេក ប្រកបដោយការគោរព ធ្វើយ៉ាងណាអាចផ្តល់លទ្ធភាពសម្រាប់ការទស្សនាថ្មីមួយ វិធីស្វែងយល់អំពីអង្គរថ្មីមួយ និងអាចបង្កើនលទ្ធភាពនៃការទស្សនាផ្សេងទៀតក្រៅពីការទស្សនានៅពេលថ្ងៃ។

[ស្លាយ] ប្រសិនបើយើងនិយាយពីការរៀបចំតែងលំអដោយប្រើពាក្យពេចន៍នោះ ព្រោះនេះមិនមែនជាទេសភាពធម្មជាតិនោះទេ គឺមិនមែនយើងនាំមកនូវអ្វីមួយដែលប្រាសចាកពីភាពបរិសុទ្ធនៃទីកន្លែងនោះទេ ប៉ុន្តែគ្រាន់តែនាំមកនូវសេចក្ដីរំភើបដែលជាសមាសធាតុមួយនៃអារ្យធម៌ខ្មែរ។ ហើយអារ្យធម៌នេះសមនឹងទទួលបាននូវការគោរព និងការផ្ដល់កិត្តិយស។
ដំណើរប្រព្រឹត្តិទៅនៃជីវិតមួយ យើងឃើញមាននៅក្នុងរចនាបថ នៅក្នុងកាយវិការដែលឆ្លាក់នៅលើថ្ម។ កាយវិការទាំងនេះមានចំនួនច្រើនអនេក ហើយខ្ញុំជឿជាក់ថាពន្លឺមានសមត្ថភាពគុកោសល្យនេះ តូចឆ្មារ ស្រទន់ ប៉ុន្តែប្រាកដជាអាចបង្ហាញឲ្យឃើញកាន់តែច្បាស់នូវធាតុទាំងប្រាំដែលអាចឲ្យគេកសាងអង្គរបាន។

រវាងវប្បធម៌និងស្មារតីចងចាំ ការអះអាងបង្កើតសញ្ញាសម្គាល់ថ្មីមួយ ដូចដែលយើងបាននិយាយរួចមកហើយចូលរួមចំណែកក្នុងការធ្វើអោយប្រទេសកម្ពុជាល្បីរន្ទឺគ្រប់ទិសទីនៅលើឆាកវប្បធម៌។

[ស្លាយ] តម្លៃនិងនិមិត្តរូបបេតិកភណ្ឌពិភពលោកដ៏ពិសេសនេះ គឺលោក លោកស្រីទាំងអស់គ្នាពិតជាមាន រួមជាមួយជំនាញនិងចំណេះដឹងវប្បធម៌ដ៏ខ្ពង់ខ្ពស់របស់លោក លោកស្រី ចំណែកខ្ញុំវិញ ខ្ញុំបានស្ដាប់លោក លោកស្រីដោយយកចិត្តទុកដាក់តាំងពីព្រឹកមកម្លេះ។ អ្នកជំនាញ "ពន្លឺ" និង អ្នកទំនាក់ទំនងដូចជាពួកខ្ញុំនេះ ពិតជានៅក្រោយលោក លោកស្រី នៅក្រោយឆ្ងាយណាស់ ប៉ុន្តែយើងខ្ញុំមានឆន្ទៈចូលរួមជាមួយអ្វីដែលលោក លោកស្រីកំពុងធ្វើ មានឆន្ទៈក្នុងការបម្រើនិងការបង្ហាញឲ្យឃើញ។

លទ្ធភាពមួយដែលអាចអោយគេរៀបចំពិធីវប្បធម៌ពិភពលោកដ៏ធំនៅអង្គរនោះ ប្រហែលជានៅទីលានដំរី យើងនឹងឃើញនៅក្នុងខ្សែទស្សនាដែលស្នើឡើង។ រមណីយដ្ឋាននេះ ស្មារតីចងចាំនេះ អតីតកាលនេះ ភាពសម្បូរណ៍បែបនេះអាចឲ្យគេធ្វើរឿងនេះបាន។ ហើយខ្ញុំជឿជាក់ថា នៅពេលអនាគត ពន្លឺនៃមហាទស្សនីយភាពវប្បធម៌នឹងអាចរកឃើញកន្លែងបង្ហាញខ្លួនមួយមហាធំនិងមហាអស្ចារ្យ។

[ស្លាយ] យើងនិយាយពីសភាពអស្ចារ្យ ភាពអស្ចារ្យនៃពន្លឺ ក៏ជាភាពរំជើបរំជួលរវាងស្នាដៃ សច្ចភាពរបស់មនុស្សខ្មែរនិងរបស់សិល្បៈខ្មែរដែរ។ ភាពអស្ចារ្យនៃពន្លឺគឺជាចំណងមួយ ជាទីកន្លែងសង្គមមួយ ដែលចូលរួមចំណែកក្នុងការផ្ដល់ជូនវិញនូវអារម្មណ៍មោទនៈភាពដ៏ត្រឹមត្រូវនេះ ដល់អ្នកដែលរស់នៅអង្គរនិងអ្នកដែលមកទស្សនាអង្គរ។

ចុងក្រោយ ភាពអស្ចារ្យនៃពន្លឺជាវិចទ័រទំនាក់ទំនងព័ត៌មានដ៏ខ្លាំងក្លា អាចនាំមកនូវសេចក្ដីរីករាយដូចគ្នាចំពោះអ្នកដែលរស់នៅនិងអ្នកដែលទស្សនា។ គ្មានបដិបក្ខភាពរវាងគ្នានោះទេ។ ខ្ញុំជឿជាក់ថាមានភាពបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមករវាងសកម្មភាពនិងភាពអស្ចារ្យដែលត្រូវរកឲ្យឃើញ។

**លោក Binst ៖**
មែនទែនទៅ តាមទស្សនៈរបស់យើង ហើយមិនមែននៅចំពោះមុខលោក លោកស្រីទេដែលខ្ញុំត្រូវគូសបញ្ជាក់បន្ថែមទៀតនោះ អង្គរ ត្រូវតែធ្វើអោយល្អឥតខ្ចោះ។ ជាការពិតណាស់ តាំងពីដំបូងម្លេះ លក្ខណៈសម្បត្តិនៃទីកន្លែងនេះបង្ខំនិងតម្រូវឲ្យយើងគិតគូរិះរកដំណោះស្រាយដ៏ថ្មីបំផុតនិងប្រកបដោយការគោរពបំផុតផងដែរ។

ដូច្នេះ យោងទៅតាមអនុសាសន៍នានាដែលយើងបានទទួល និងយោងទៅតាមបទពិសោធន៍របស់ Alain ផងនោះ យើងបានបង្កើតនូវវិធានចំនួនប្រាំស្ដីពីការដាក់ភ្លើងបំភ្លឺអង្គរ។ វិធានទាំងប្រាំដែលខ្ញុំនឹងបង្ហាញជូនលោក លោកស្រី

នៅពេលឥឡូវនេះ គឺជាសេចក្ដីសង្ខេបនៃការសិក្សាពេញលេញមួយដែលយើងនឹងប្រគល់ជូនអប្សរានៅពេលបន្តិចទៀតនេះ។

[ស្លាយ] **វិធានទីមួយ៖** លើកតម្លៃភាពដ៏សម្បើមអស្ចារ្យនៃរមណីយដ្ឋានទាំងមូល។ ការដាក់ភ្លើងបំភ្លឺត្រូវធ្វើឡើងនៅតាមប្រាង្គប្រាសាទនិងទេសភាព។ ជាការពិតណាស់ យើងឃើញថាទេសភាពវាសំខាន់ដល់កម្រិតណាចំពោះប្រាង្គប្រាសាទផ្ទាល់។ ទេសភាពទាំងនេះជួយឲ្យគេយល់អំពីរមណីយដ្ឋានទាំងមូល ហើយនេះគឺជាបេសកកម្មមួយក្នុងចំណោមបេសកកម្មទាំងអស់ដែលគម្រោងដាក់ភ្លើងបំភ្លឺនេះបានកំណត់ឡើង។ ការដាក់ភ្លើងបំភ្លឺនេះនាំមកនូវទស្សនៈថ្មីមួយដែលផ្អែកលើចំណេះដឹងនិងភាពរំជើបរំជួលផ្លូវចិត្ត។

[ស្លាយ] **វិធានទីពីរ៖** សង្កត់ធ្ងន់ទៅលើកម្លាំងនិងសោភណភាពរបស់រមណីយដ្ឋានដោយមិនធ្វើឲ្យប៉ះពាល់ដល់លក្ខណៈពិសិដ្ឋនិងបេតិកភណ្ឌរបស់រមណីយដ្ឋាន។ បើមិនមានការគោរពដ៏ម៉ឺងម៉ាត់ចំពោះរមណីយដ្ឋាននិងចំពោះអ្វីដែលតំណាងឲ្យរមណីយដ្ឋានទេ គឺមិនមានការដាក់ភ្លើងបំភ្លឺណាមួយអាចធ្វើបានឡើយនៅអង្គរក៏ដូចជានៅកន្លែងដ៏ទៃទៀត ជាពិសេសនោះគឺនៅអង្គរនេះតែម្ដង។ ការដាក់ភ្លើងបំភ្លឺអាចឲ្យទទួលបានការមើលឃើញប្រាង្គប្រាសាទពីខាងក្រៅ យើងមិនបានគ្រោងទុកឲ្យមើលឃើញប្រាង្គប្រាសាទពីខាងក្នុងទេ។ ការដាក់ភ្លើងបំភ្លឺមានលក្ខណៈអប្បបរមានិងមិនមានការបំភ្លឺចិញ្ចែងចិញ្ចាចទេ។ ជម្រើសសោភណភាពត្រូវគោរពដល់តម្លៃសាសនានិងតម្លៃជាសាកលនៃបេតិកភណ្ឌ។

[ស្លាយ] **វិធានទីបី៖** អនុម័តយកវិធានបច្ចេកទេសស្របតាមកំហិតដ៏ក្រិតក្រមស្ដីពីការគោរពនិងបូរណភាពរបស់រមណីយដ្ឋាន។ សម្ភារៈទាំងអស់ដែលយកទៅប្រើប្រាស់ត្រូវតែអាចដកចេញវិញបានដោយមិនធ្វើឲ្យខូចទ្រង់ទ្រាយដើមរបស់ទីកន្លែងឡើយ។ ការផ្គត់ផ្គង់ចរន្តអគ្គិសនី ខ្សែកាប ឧបករណ៍សម្រាប់បំភ្លឺ គឺមិនត្រូវឲ្យមើលឃើញទេនៅក្នុងផ្នែកនៃប្រាង្គប្រាសាទដែលស្ថិតនៅក្នុងការមើលឃើញជាទូទៅ និងពីផ្នែកដែលសារធារណៈជនអាចមើលឃើញ។ សម្ភារៈនានាដែលអាចមើលឃើញតិចតួចពីផ្នែកខ្លះ ត្រូវតែលាបពណ៌ដើម្បីឲ្យវាមានពណ៌ស៊ីគ្នាជាមួយនឹងបរិស្ថានដែលនៅជុំវិញ។

[ស្លាយ] **វិធានទីបួន៖** ត្រូវយកចិត្តទុកដាក់បំផុតចំពោះលក្ខណវិនិច្ឆ័យនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ការជ្រើសរើសសម្ភារៈក៏ដូចជាប្រភពថាមពលដែលគួរប្រើ គឺមានទិសដៅទទួលបាននូវតុល្យការបរិស្ថានដ៏ខ្លាំងបំផុត។ ជាការពិតណាស់ បច្ចេកវិទ្យានៅពេលបច្ចុប្បន្ននេះអាចឲ្យធ្វើឲ្យចំណុចនេះមានភាពប្រសើរបំផុតបាន។ ហើយយើងស្គាល់ច្បាស់អំពីបច្ចេកវិទ្យាទាំងនេះ។
គម្រោងស្ថិតនៅក្នុងទស្សនវិស័យនៃការគ្រប់គ្រងលំហូរអ្នកទេសចរប្រកបដោយសុខដុមនីយកម្ម។ ហើយនៅទីបញ្ចប់ ការផ្ទេរបច្ចេកវិទ្យា សមត្ថភាពនិងចំណេះធ្វើ ត្រូវរៀបចំឡើងតាមរយៈកម្មវិធីបណ្ដុះបណ្ដាលផ្នែកការថែទាំនិងការត្រួតពិនិត្យ។

[ស្លាយ] **វិធានទីប្រាំ៖** ខ្សែទស្សនានេះ ព្រោះថានេះគឺពិតជាខ្សែទស្សនាដែលមានពន្លឺ ផ្ដល់ឲ្យនូវការចាប់ផ្ដើមឬការបញ្ចប់ការទស្សនាមួយប្រកបដោយភាពអណ្ដែតអណ្ដូងនិងស្រមើស្រមៃសម្រាប់ការទស្សនានៅពេលថ្ងៃ។ ខ្សែទស្សនានេះនាំមកនូវទស្សនៈវិស័យដ៏ទូលំទូលាយនិងប្លែកៗគ្នាចំពោះរមណីយដ្ឋាន នៅក្នុងអំឡុងពេលនៃដំណើរទស្សនា ដែលនៅក្នុងដំណើរនោះ ប្រាសាទអង្គរវត្តគឺជាទិសដៅទស្សនាដ៏សំខាន់ជាងគេចុងក្រោយ។ ខ្សែទស្សនា

នេះមានចំងាយផ្លូវប្រវែង២៧គីឡូម៉ែត្រ សម្រាប់រយៈពេលទស្សនាសរុបតិចជាងមួយម៉ោងកន្លះ រួមទាំងពេលឈប់នៅមុខប្រាង្គប្រាសាទនីមួយៗដែលត្រូវបានដាក់ភ្លើងបំភ្លឺផង។ ខ្សែទស្សនានេះក៏មានគោលបំណងទាក់ទាញការយកចិត្តទុកដាក់របស់អ្នកទេសចរចំពោះប្រាសាទ ឬក៏ទិដ្ឋភាពមួយចំនួននៃរមណីយដ្ឋានដែលជាញឹកញាប់ត្រូវបានគេបំភ្លេចចោល។
ឥឡូវនេះ យើងនឹងបង្ហាញជូនលោក លោកស្រីអំពីខ្សែទស្សនានេះ។

**លោក Guilhot ៖**
ដូច្នេះ លោក លោកស្រីបានយល់ហើយ។ ដោយគោរពយ៉ាងម៉ឺងម៉ាត់តាមអនុសាសន៍នានានិងសៀវភៅបន្ទុកដែលត្រូវបានផ្តល់ឲ្យពួកយើង គឺមិនត្រូវមានពន្លឺនៅក្នុងប្រាសាទ មិនត្រូវមានពន្លឺដែលបង្កឲ្យមានការខូចខាត មិនត្រូវមានខ្សែកាប និងមិនត្រូវមានអំពូលហ្វារទេ។
ប៉ុន្តែត្រូវមានអ្វីដែលទាក់ទាញខ្លាំង មានភាពអស្ចារ្យ នៅក្នុងវង់ទស្សនានេះ ធ្វើយ៉ាងណាឲ្យអ្នកទស្សនានៅពេលយប់លាន់មាត់ថា៖ "នេះគឺពិតជាអស្ចារ្យមែន! យើងមិនបានយល់អញ្ចឹងសោះពីមុន! ថ្ងៃស្អែកយើងនឹងត្រឡប់មកទស្សនាម្តងទៀតជាមួយកូនរបស់យើង ជាមួយមិត្តភ័ក្តិយើង ជាមួយគ្រួសារយើង។

[មានការចាក់បញ្ចាំងវីដេអូ អមដោយបទភ្លេង]

នេះគឺជាខ្សែទស្សនាដែលយើងខ្ញុំបានស្នើឡើង។

កន្លែងឈប់ទីមួយនៅប្រាសាទនេះ គឺផ្លូវចូលទៅអង្គរវត្តនេះដែលមានលក្ខណៈសាមញ្ញ ប៉ុន្តែប្រហែលជាទីតាំងដែលតំណាងអោយជំនួបដំបូងជាមួយទឹកដែលជានិមិត្តរូបរបស់មហាសមុទ្រ។ ហើយចំណាំងពន្លឺនេះដែលយើងនឹងឃើញនៅពេលបន្តិចទៀតនៅក្នុងពន្លឺបង្កើតដោយកុំព្យូទ័រ អាចឲ្យយើងមើលឃើញនូវមហាកម្លាំង។ នេះគឺជាប្រាសាទដំបូងគេនិងជារបកគំហើញដំបូងបំផុតនៃបេតិកភណ្ឌដ៏អស្ចារ្យនេះ។

នេះជារូបភាពផ្ទៃមុខដែលខ្ញុំបាននិយាយរួចមកហើយ មុខដែលធ្វើឲ្យយើងស្ញប់ស្ញែងយ៉ាងខ្លាំង មុខដែលនាំមកឲ្យពិភពលោកទាំងមូលនូវឥទ្ធិពលនៃសេចក្តីរំភើប និងចម្ងល់។ ភាពអាថ៌កំបាំងបង្កប់នៅក្នុងទម្រង់មុខដែលឆ្លាក់បានល្អឥតខ្ចោះ ពោរពេញទៅដោយភាពស្រមើស្រមៃដែលយើងមានអារម្មណ៍ថាចាក់ឫសយ៉ាងជ្រៅទៅក្នុងវត្ថុដ៏ពិសិដ្ឋ។ យើងអាចធ្វើការងារកំណត់រមណីយដ្ឋាននៅក្នុងវង់ទស្សនានេះបាន គឺដោយសារមានជំនួយដ៏ច្រើនពីសំណាក់បណ្តាមន្ត្រីថ្នាក់ដឹកនាំរបស់អប្សរា ដែលបានជួយជ្រោមជ្រែងយើងខ្ញុំ ហើយដែលមន្ត្រីមួយចំនួនមានវត្តមាននៅទីនេះស្រាប់។ យើងធ្វើយ៉ាងណារៀបចំវង់ទស្សនាឲ្យមានទំនាក់ទំនងជាមួយប្រវត្តិសាស្ត្ររបស់រមណីយដ្ឋាននេះមិនអោយប្រាសចាកពីប្រវត្តិដើមឡើយ។

កំពង់ទឹកនេះដែលពន្លឺអាចបង្ហាញឲ្យឃើញ មានសោភណភាពដ៏ស្រស់ស្អាត ហើយក៏ជាទីកន្លែងមួយដែលលោកលោកស្រីក៏មានលទ្ធភាពពង្រីកការទស្សនាបន្ថែមដ៏ពិតប្រាកដផងដែរ។

ពេលខ្លះ កន្លែងឈប់ដើម្បីទស្សនាហាក់ដូចជាសាមញ្ញ ប៉ុន្តែខ្ញុំជឿជាក់ថាគោលបំណងរបស់យើងនៅចំពោះមុខភាពអស្ចារ្យនៃឧទ្យាននេះ គឺត្រូវបើកអោយមានការទស្សនាធំទូលាយ ជាជាងការបើកឲ្យទស្សនាតែប្រាសាទពីរឬបីដែលមានភ្ញៀវទស្សនាច្រើនជាងគេបំផុតនោះ។ បញ្ហានៃការកកស្ទះដែលបានលើកឡើងនៅក្នុងសន្និសីទនេះពិតជា

បង្ហាញច្បាស់ថា ត្រូវតែអាចបើកឲ្យមានលទ្ធភាពទស្សនានៅកន្លែងផ្សេងៗទៀត។

**ក្លោងទ្វារប្រាសាទតាព្រហ្មដ៏ស្រស់ស្អាត**

យើងមិនអាចស្នើឡើងនូវវង់ទស្សនាពេលយប់ដោយមិនឆ្លងកាត់ប្រាសាទតាកែវបានទេ គ្រាន់តែនៅប្រាសាទនេះមានកន្លែងគួរឈប់ដើម្បីទស្សនាចំនួនពីរកន្លែងទៅហើយ។ ទម្រង់របស់ប្រាសាទបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវឥទ្ធិពលនិងនិមិត្តរូបនៃប្រាសាទមួយនេះ។

វង់ទស្សនារបស់យើងខិតចូលទៅជិតផ្លូវចូលអង្គរធំ ដោយមានកន្លែងគួរឈប់ចំនួនពីរកន្លែងនៅមុខប្រាសាទដែលស្ថិតនៅទល់មុខគ្នា។

ខ្ញុំជឿថា សម្រាប់អ្នកដែលមិនធ្លាប់ចូលទៅក្នុងអង្គរធំ ពេលចូលទៅលើកដំបូង គេពិតជារំភើបអារម្មណ៍មិនខាន។ គេអាចចូលទៅក្នុងអង្គរធំរាប់ពាន់ដង ហើយគេនៅតែមានការរំភើបខ្លាំងដដែល។ គោលបំណងរបស់ពន្លឺគឺត្រូវរកឲ្យឃើញនិងបង្ហាញជូននូវភាពអស្ចារ្យរបស់រមណីយដ្ឋាន និងវត្តមានទឹកនៅក្នុងកសិណ។

យើងមកដល់ប្រាសាទសួព្រ័ត្រដែលមានកូនប្រាសាទតំរៀបជួរគ្នាទាំងដប់ពីរ ចំមុខលានដំរីដែលគេប្រើជាអាទិ៍សម្រាប់ពិធីដង្ហែក្បួនធំៗ។ *[កំណត់សម្គាល់របស់អ្នកចម្លង៖ ដោយសារការថតចម្លងមិនអាចស្តាប់បាន មានកន្លែងខ្លះមិនអាចចម្លងចេញបានទេ]* ការឆ្លងកាត់នៅមុខទីលានស្តេចគម្លង់នេះ និងនៅមុខចម្លាក់សត្វដំរីធំៗដ៏ច្រើនសន្ធឹកសន្ធាប់នេះ យើងគួរតែឈប់ដើម្បីទស្សនាអោយបានយូរ។

*[កំណត់សម្គាល់របស់អ្នកចម្លង៖ ដោយសារការថតចម្លងមិនអាចស្តាប់បាន មានកន្លែងខ្លះមិនអាចចម្លងចេញបានទេ]* ប្រាសាទនេះតំណាងអោយភពផែនដីដ៏អស្ចារ្យ ជាងនេះទៅទៀត មានផ្ទៃមុខជាច្រើនដ៏ស្ងប់ស្ងៀម មុខដែលយើងចង់ផ្តល់ជូននូវពាក្យសម្តី ហើយដែលជាសម្តីដ៏ស្រទន់និងប្រកបដោយការប្រុងប្រយ័ត្ន *[កំណត់សម្គាល់របស់អ្នកចម្លង៖ ដោយសារការថតចម្លងមិនអាចស្តាប់បាន មានកន្លែងខ្លះមិនអាចចម្លងចេញបានទេ]*។

ប្រាសាទផ្សេងត្រូវតែមានលក្ខណៈសាមញ្ញជាង បើប្រៀបធៀបនឹងផ្ទៃមុខធំៗដែលនៅជិតខ្លួន ជាមុខដែលប្រកបដោយភាពស្រទន់បំផុត និងរស់រវើក។

យើងមកដល់អង្គរវត្តដែលជាប្រាសាទចុងក្រោយ ព្រោះថានេះគឺជាគោលដៅរបស់កម្មវិធីទស្សនាដែលយើងបានស្នើឡើង និងព្រោះថាពិភពលោកទាំងមូលពិតជាស្គាល់អង្គរវត្ត ហើយពេលខ្លះស្គាល់ត្រឹមអង្គរវត្តប៉ុណ្ណោះ។ ខ្ញុំជឿជាក់ថា គេទើបបានទស្សនាសោភណភាពនៃរមណីយដ្ឋានដ៏អស្ចារ្យមួយ ហើយការទស្សនាពេលយប់នេះបញ្ចប់នៅអង្គរវត្ត គឺដើម្បីឲ្យអង្គរវត្តក្លាយទៅជាចំណុចទាក់ទាញសម្រាប់ការទស្សនាម្តងទៀតនៅពេលថ្ងៃ។

សម្រាប់វិធីសាស្រ្តនិងវង់ទស្សនាដែលយើងខ្ញុំបានស្នើឡើងនេះ យើងខ្ញុំចង់បង្ហាញជូននូវរូបភាពពន្លឺធ្វើចេញពីកុំព្យូទ័រចំនួនបួន។ សូមមេត្តាបិទភ្លើងម្តងទៀត។

តើអ្វីទៅជាពន្លឺធ្វើចេញពីកុំព្យូទ័រ? ពន្លឺធ្វើចេញពីកុំព្យូទ័រគឺជាវិធីបង្កើតពន្លឺដោយប្រើកុំព្យូទ័រដើម្បីបំភ្លឺប្រាសាទ។ នេះមិនមែនជាការបំភ្លើស ឬអ្វីដែលខុសពីការពិតនោះទេ។ តាមការពិត នេះគឺជាការបំភ្លឺដែលយើងបានគិតទុកមុន ហើយនឹងដូចសុទ្ធសាធនឹងពន្លឺពិតប្រាកដ។

ពន្លឺធ្វើចេញពីកុំព្យូទ័រមានផលប្រយោជន៍ច្រើនយ៉ាង។ វាអាចអោយយើងពិនិត្យវិធីសាស្រ្តបានគ្រប់ជ្រុងជ្រោយ អាច

ឲ្យយើងយល់ច្បាស់អំពីវិធីសាស្ត្រ ដោយសារថាពន្លឺគឺ បើតាមនិយមន័យ ជាវត្ថុអរូបិយ។ ប៉ុន្តែនៅក្នុងការវិភាគដែលយើងដាក់ជូនលោក លោកស្រីពិនិត្យ ពន្លឺនេះអនុញ្ញាតឲ្យលោក លោកស្រីអាចវិនិច្ឆ័យបានថាតើពន្លឺនេះឈានដល់កម្រិតដែលយើងចង់បានដែរឬទេ? ការពិសោធន៍របស់យើងធ្វើឲ្យយើងគិតថា គឺតាមសំណើនេះហើយដែលគួរធ្វើដើម្បីធ្វើយ៉ាងណាឲ្យភាពអស្ចារ្យលេចចេញឡើង ជាពិសេសនិមិត្តរូបនៃទឹក នៃមហាសមុទ្រ ដូចដែលខ្ញុំបាននិយាយរួចមកហើយ។ ប៉ុន្តែមុននឹងមើលឃើញនៅពេលព្រលឹម ពេលព្រះអាទិត្យរះ នូវទេសភាពចំណាំងពន្លឺដែលយើងបានថតយកមក រូបទេសភាពនាពេលព្រលឹមនេះស្អាតដូចផ្ទាំងគំនូរដ៏ពិតប្រាកដ ហើយខ្ញុំជឿជាក់ថា យើងអាចបង្កើតទេសភាពនេះបាននៅពេលយប់។

[ស្លាយ] ប្រាសាទតាកែវដែលខ្ញុំបាននិយាយនៅពេលអំបាញ់មិញ គឺជាប្រាសាទភ្នំដែលបង្ហាញខ្លួនឲ្យគេឃើញប្រកបដោយមោនភាពនិងមានគ្រឹះយ៉ាងរឹងមាំ ធ្វើឲ្យគេស្រម័យអំពីទេពកោសល្យនៃសិល្បៈខ្មែរ ហើយដែលរយៈពេលប៉ុន្មានសតវត្សក្រោយមក នៅតែមានភាពអស្ចារ្យនិងឥទ្ធិពលដដែល។ ពន្លឺស្ថិតនៅជាមួយប្រាសាទ ដើម្បីថ្លែងអំណរគុណដល់ទេពកោសល្យរបស់មនុស្ស។

[ស្លាយ] ក្លោងទ្វារនៅទិសខាងត្បូងនេះដែលខ្ញុំបានលើកឡើងនៅពេលអំបាញ់មិញ ក៏អាចឲ្យយើងរំលេចចេញនូវសោភណភាពដូចគ្នាដែរ ព្រោះថានៅពេលដែលយើងខ្ញុំបានជិះឡានឆ្លងកាត់ ទេសចរពេលថ្ងៃ ហើយទៅអនាគតប្រហែលជាមានទេសចរពេលយប់ ពួកគេពុំឃើញមានទឹក គ្មានចំណាំងពន្លឺឡើយ។ នេះគឺជាការគួរឲ្យសោកស្តាយព្រោះថានេះហើយដែលជាធាតុផ្សំដ៏សំខាន់មួយនៃស្ថាបត្យកម្មនេះ។ ហើយខ្ញុំក៏ជឿជាក់ដែរថា នៅទីកន្លែងនោះ ពន្លឺអាចរំលេចចេញនូវវត្តមានរុក្ខជាតិដែលជាផ្នែកមួយនៃស្នាដៃដ៏អស្ចារ្យនេះ។

[ស្លាយ] ហើយយើងសូមបញ្ចប់ការទស្សនានៅអង្គរវត្ត ព្រោះថានេះគោលដៅនៃគម្រោងដែលយើងបានដាក់ជូនលោក លោកស្រីពិនិត្យ ដោយធ្វើយ៉ាងណាកុំឲ្យភ្លេចថា អង្គរវត្តនៅតែប្រាសាទមួយដ៏សំខាន់បំផុត។ ប៉ុន្តែនៅក្នុងរមណីយដ្ឋានអង្គរនេះ មានប្រាសាទជាច្រើនដែលត្រូវទស្សនា។

[ស្លាយ] អង្គរវត្តក៏អាចឲ្យយើងលេងពន្លឺផងដែរ ជាការលេងពន្លឺពិតប្រាកដ ដោយមិនខ្លាំងពេក មិនហួសហេតុពេកអោយសមនឹងភាពស្រទន់ ភាពពិតដែលព្រះអាទិត្យអាចផ្តល់ឲ្យនៅពេលថ្ងៃ ដោយហេតុថានេះគឺកម្មវិធីទស្សនាមួយប្រកបដោយភាពស្រទន់និងល្អបំផុតដែលយើងស្នើឡើង។ ធ្វើយ៉ាងណាឲ្យគេចង់មកទស្សនាអង្គរនៅពេលយប់ជាមួយនឹងទស្សនៈវិស័យមួយផ្សេងទៀត ប្រកបដោយភាពអស្ចារ្យ និងឲ្យគេចង់ត្រឡប់មកទស្សនានៅពេលថ្ងៃវិញដើម្បីស្វែងយល់ឲ្យបានប្រសើរជាងមុននូវអ្វីដែលបុព្វបុរសខ្មែរបានកសាងឡើង។ សូមអរគុណ!

**បទអត្ថាធិប្បាយរបស់លោក Beschaouch ៖** ខ្ញុំសូមអរគុណ។ មិនមែនរូបខ្ញុំទេដែលត្រូវនិយាយ ដោយហេតុថាគម្រោងនេះត្រូវបានបង្ហាញជូនគណៈកម្មាធិការរបស់យើង។ ប៉ុន្តែខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះលោក Alain Guilhot ដោយលោកបានយល់ព្រមទទួលសំណើដែលខ្ញុំបានស្នើទៅលោកដោយខ្លួនខ្ញុំផ្ទាល់ ជួសមុខឲ្យអាជ្ញាធរជាតិអប្សរា យើងបានស្នើឲ្យលោកធ្វើការសិក្សាមួយស្តីពីភាពអាចធ្វើបាន។

បន្ទាប់មក ដូចដែលលោក លោកស្រីជ្រាបស្រាប់ហើយ ស្របតាមបំណងប្រាថ្នារបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន លោកតែងតែយកចិត្តទុកដាក់ចែករំលែកនូវគំនិត ចំណាប់អារម្មណ៍និងសេចក្តីរំភើបជាមួយនឹងគណៈកម្មាធិការរបស់យើង ហើយមិនធ្វើសេចក្តីសម្រេចដោយគ្មានយោបល់របស់យើងនោះទេ។ លោកក៏បានស្នើ

មកខ្ញុំឲ្យបង្ហាញនូវការសិក្សាមួយដូចដែលយើងបង្ហាញជូននៅថ្ងៃនេះ។

ខ្ញុំសូមថ្លែងអំណរគុណលោក ព្រោះខ្ញុំដឹងថាគម្រោងនេះធ្វើឲ្យលោកមានការងារដ៏ធំមួយ។ លោកបានទៅប្រទេស Bahreïn តាមសំណើរបស់ព្រះអង្គម្ចាស់ក្សត្រិយ៍។ ដូច្នេះ លោកឃើញហើយថាលោកក៏មានពិភពអារ៉ាប់នៅក្នុងផ្លូវធ្វើដំណើររបស់លោកផងដែរ ចាប់ពីបាងកក តូក្យូ សេអ៊ូល និងបាងកក កូឡាឡាំពួ។ល។ ខ្ញុំសូមអរគុណលោក ព្រោះថាគម្រោងនេះធ្វើឲ្យលោកមានការងារច្រើន ហើយខ្ញុំសូមនិយាយនៅចំពោះមុខអ្នកទាំងអស់គ្នាថា ខ្ញុំយល់ថាលោកពិតជាអស្ចារ្យខ្លាំងណាស់ ទោះបីជាខ្ញុំយល់ថាខ្លួនឯងធ្លាប់ធ្វើដំណើរច្រើនក៏ដោយ ប៉ុន្តែលោកធ្វើដំណើរលើសខ្ញុំទៅទៀត ព្រោះថានៅល្ងាចដែលលោកបានមកដល់ យើងបានអញ្ជើញលោកពិសារអាហារជាមួយយើងជាលក្ខណៈមិត្តភាពលោកបាននិយាយថា៖ "ខ្ញុំមិនទាន់ទម្លាប់តាមម៉ោងខ្មែរទេ" ដោយសារតែលោកបានធ្វើដំណើរឆ្លងកាត់តាមប្រទេសចំនួនបួន ដើម្បីមកបញ្ចប់នៅទីក្រុង Lyon ក្នុងរយៈពេលមួយសប្តាហ៍។ ដូច្នេះ ខ្ញុំសូមថ្លែងអំណរគុណលោកជាសាធារណៈដែលលោកបានយល់ព្រមមកធ្វើបទបង្ហាញជាបឋមអំពីការសិក្សានេះ។ ដូច្នេះ ប្រសិនបើសហប្រធានទាំងពីររូបរបស់ខ្ញុំអនុញ្ញាត ឥឡូវនេះ បើអ្នកណាមានចំណាប់អារម្មណ៍ សេចក្តីកត់សម្គាល់ ឬការផ្តល់យោបល់ដែលនឹងជួយកែលម្អវង់ទស្សនានេះ សូមមេត្តាមានយោបល់ ព្រោះថាពួកគេនឹងបង្ហាញជូននូវគម្រោងចុងក្រោយជាស្ថាពរ ហើយនេះគ្រាន់តែជាពង្រាងប៉ុណ្ណោះ។ ខ្ញុំសូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណច្រើន។ ហើយឥឡូវនេះ តើមានសេចក្តីកត់សម្គាល់ទាក់ទងនឹងបទបង្ហាញនេះដែរឬទេ? តើមានឬមិនមាន?

## កិច្ចពិភាក្សាទូទៅ

**សំណួររបស់លោក Michel Verrot ៖** ដោយហេតុតែយើងស្ថិតនៅក្នុងការស្រមើស្រម៉ៃ ខ្ញុំចង់ស្រមៃថា បើយើងនៅត្រង់ផ្លូវវាងថ្មីនៃទីធ្លាមុខអង្គរវត្ត យើងអាចមើលឃើញភ្លើងភ្លឺនៅពេលយប់នៅលើកំពូលភ្នំបាក់ខែង។ ប្រាសាទនេះជានិមិត្តរូបដ៏សំខាន់មួយនៃពិភពខ្មែរ។

**ចម្លើយរបស់លោក Alain Guilhot ៖** ខ្ញុំយល់អំពីសំណូមពររបស់លោក ប៉ុន្តែវង់ទស្សនារបស់យើងមិនមានលក្ខណៈលម្អិតនិងជាស្ថាពរនោះទេ។ នេះជាសំណើដំបូង ហើយខ្ញុំយល់ថាត្រូវតែធ្វើការបំពេញ កែលំអរបន្ថែមពីមួយឆ្នាំទៅមួយឆ្នាំ ព្រោះថាវង់ទស្សនាគឺជាអ្វីមួយដែលត្រូវពង្រីកពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយឆ្នាំទៅមួយឆ្នាំ ហើយរមណីយដ្ឋានទាំងមូលស័ក្តិសមនឹងបំភ្លឺភ្លើង វាជាការពិត។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** តើមានសេចក្តីកត់សម្គាល់ផ្សេងទៀតដែរឬទេ?

**បទអត្ថាធិប្បាយរបស់លោក Bouchenaki ៖** សូមអរគុណលោកប្រធាន។ ម្យ៉ាង ខ្ញុំសូមថ្លែងអំណរគុណហើយនិងកោតសរសើរចំពោះការងារដែលសម្រេចបានក្នុងរយៈពេលដ៏ខ្លីនេះ។ តើលោក លោកស្រីនៅចាំទេថា នៅពេលដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន បានសួរយើងនៅក្នុងសម័យប្រជុំចុងក្រោយថាតើអ្វីទៅជាប្រតិកម្មរបស់យើងចំពោះគម្រោងដាក់ភ្លើងបំភ្លឺ និងគម្រោងទស្សនានៅពេលយប់នៅប្រាសាទអង្គរ? ប្រតិកម្មរបស់សហសេវិកយើងទាំងអស់ដែលមានវត្តមាននៅទីនេះគឺដូច្នេះ៖ "ចូរប្រុងប្រយ័ត្ន! យើងស្ថិតនៅចំពោះមុខរមណីយដ្ឋានមួយដែល

មានសារៈសំខាន់ជាទីបំផុត ជារមណីយដ្ឋានមួយមិនសូវរឹងមាំ។ ចូរយើងកុំធ្វើកិច្ចប្រតិបត្តិការណាមួយដែលអាចនាំយើងទៅដល់ការវិនិច្ឆ័យរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលគួរឲ្យស្តាយ អាចជាការវិនិច្ឆ័យអវិជ្ជមាន"។ ហើយខ្ញុំអាចនិយាយបានថា នៅក្នុងអំឡុងពេលនៃកិច្ចពិភាក្សាជាមួយសហសេវិករបស់ខ្ញុំ គឺលោក Azédine Beschaouch លោក Pierre André Lablaude លោក Claude Jacques លោក Georgio Croci ដែលមិននៅទីនេះទេ លោកបានចាកចេញទៅហើយ លោកសាស្រ្តាចារ្យ Suzuki មុននឹងការមកដល់របស់លោក Hidaka ដែលជាមិត្តភ័ក្តិរបស់ខ្ញុំ គឺយើងពិតជាមានប្រតិកម្មដូចៗគ្នា។ តើយើងគ្មានដំណោះស្រាយអ្វីផ្សេងទៀត ក្រៅពីការទស្សនាជាក់ស្តែងនៅនឹងកន្លែងទេឬ? ហើយខ្ញុំក៏បានគិតទៅដល់លោក Alain Guilhot ។ តើមកពីហេតុអ្វី?

ម្យ៉ាង ព្រោះខ្ញុំបានឃើញការដាក់ភ្លើងបំភ្លឺប៉ម PETRONAS ដែលជាអាគារដ៏ទំនើបបំផុតមួយនៅទីក្រុង Kuala Lumpur។ ហើយនៅពេលថ្មីៗនេះទៀត ខ្ញុំបានទទួលបន្ទុកធ្វើការងារលើការចុះបញ្ជី និងបន្ទាប់មកទៀត ធ្វើការតាមដានមើលការងាររៀបចំ Qual'at al Barhein ដែលត្រូវបានដាក់ភ្លើងបំភ្លឺដែរ អ្នកដាក់ភ្លើងបំភ្លឺនោះគឺលោក Alain Guilhot។ នោះគឺជាអាគារទំនើបមួយនៅយុគសម័យកណ្តាល។ ហើយខ្ញុំបានគិតថា យើងប្រហែលជាអាចស្នើសុំយោបល់ពីលោក និងគិតគូររកវិធីសាស្រ្តដ៏ប្រសើរណាមួយសម្រាប់ការដាក់ភ្លើងបំភ្លឺរមណីយដ្ឋានអង្គរ។

ហើយបន្ទាប់មកទៀត យើងមានភ័ព្វសំណាងដោយទទួលបានជំនាញនិងបទពិសោធន៍របស់លោក នៅក្នុងអំឡុងពេលនៃការធ្វើវិភាគនិងការគិតគូរពិចារណាពេញមួយថ្ងៃ ដើម្បីឲ្យដឹងថា "តាមពិតទៅ តើយើងចង់បានអ្វី?" ហើយខ្ញុំជឿថាលោកបានផ្តល់ចម្លើយជូនយើងហើយ ចម្លើយនោះថែមទាំងសមស្របទៅនឹងការអភិរក្សទៀតផង។

ទីមួយ នៅក្នុងសំណើរបស់លោក លោកបានផាត់ចោលការចូលទស្សនា ការចូលទៅទស្សនានៅក្នុងប្រាង្គប្រាសាទនៅពេលរាត្រីចោទជាបញ្ហាច្រើន។

ទីពីរ លោកបានផ្តល់អាទិភាពដល់វង់ទស្សនាជាជាងប្រាសាទមួយ។

ទីបី ខ្ញុំជឿថាលោកបានបើកវង់ទស្សនាដែលមានការចែកប្រកបដោយសមតា ការទស្សនាប្រកបដោយសុខដុមនីយកម្មនៅក្នុងឧទ្យានអង្គរ។ លោកសហប្រធាន និងឯកឧត្តមឧបនាយករដ្ឋមន្រ្តីជាទីគោរព! តាងនាមឲ្យសហសេវិករបស់ខ្ញុំ ខ្ញុំសូមសំដែងនូវចំណាប់អារម្មណ៍ថា ពេលនេះ យើងមានសំណើមួយដែលអាចលើកតម្កើងតម្លៃរបស់រមណីយដ្ឋានអង្គរឲ្យកាន់តែខ្ពស់ថែមទៀត។ ហើយខ្ញុំជឿជាក់ថា តម្លៃអង្គរនៅលើឆាកអន្តរជាតិ រួមជាមួយនឹងការដាក់ភ្លើងបំភ្លឺនេះ នឹងអាចផ្តល់ឲ្យប្រជាជនកម្ពុជានិងប្រជាជនដែលរស់នៅក្នុងឧទ្យានរៀងរាល់ថ្ងៃ នូវលទ្ធភាពក្នុងការកោតសរសើរស្ញប់ស្ញែង ចំពោះលក្ខណៈសម្បត្តិស្ថាបត្យកម្មនិងសុខដុមនីយកម្មរវាងធម្មជាតិនិងវប្បធម៌របស់រមណីយដ្ឋានអង្គរ គឺមិនត្រឹមតែនៅក្នុងអំឡុងពេលថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងអំឡុងពេលយប់ផងដែរ។

ខ្ញុំក៏សូមអរគុណផងដែរចំពោះ Olivier Binst ដែលជាមិត្តភ័ក្តិចាស់ម្នាក់របស់ខ្ញុំ។ គឺជាមួយរូបលោកនេះហើយដែលយើងបានធ្វើប្រតិបត្តិការ "បេតិកភណ្ឌឆ្នាំ២០០១" នៅខណៈពេលមួយដែលយើងត្រូវធ្វើឲ្យគេស្គាល់រមណីយដ្ឋាននានានៃបេតិកភណ្ឌពិភពលោក។ គឺនៅឆ្នាំ១៩៩៤-៩៥ នៅពេលដែលយើងត្រូវធ្វើឲ្យប្រទេសជាសមាជិកអនុសញ្ញាឆ្នាំ១៩៧២ មានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងចំពោះសារៈសំខាន់របស់បេតិកភណ្ឌ និងចំពោះការអភិរក្ស។

ដោយសារតែរូបលោក យើងទទួលបានរូបថតពីបណ្តាជាងថតរូបដ៏ឆ្នើមនៅក្នុងពិភពលោក ដែលបានធ្វើដំណើរទៅ

កាន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកទាំងអស់។ ហើយនៅពេលបច្ចុប្បន្ននេះ យូណេស្កូមានបណ្ណាល័យរូបថតមួយដែលសិទ្ធិក្នុងការប្រើប្រាស់រូបថតទាំងនេះត្រូវបានជាងថតរូបទាំងអស់ប្រគល់ឲ្យយូណេស្កូ ជាទូទៅសិទ្ធិនេះមានតម្លៃថ្លៃណាស់។ ហើយខ្ញុំជឿថា Olivier Binst ពិតជាបានយល់ច្បាស់នូវអ្វីដែល Azédine Beschaouch និងខ្ញុំបានស្នើដល់រូបលោក នៅពេលដែលយើងបានជួបលោក យើងបានសួរថា៖ តើត្រូវធ្វើដូចម្តេចដើម្បីឲ្យវាជាប្រតិបត្តិការវប្បធម៌ មានវិធីសាស្រ្តវប្បធម៌?

ដូច្នេះ អ្វីដែលលោក លោកស្រីឃើញតាមរយៈបទបង្ហាញនេះ គឺមិនត្រឹមតែការដាក់ភ្លើងបំភ្លឺប៉ុណ្ណោះទេ ប៉ុន្តែជាពិសេសនោះ គឺការដាក់ភ្លើងបំភ្លឺនេះអាចនាំមកនូវចំណេះដឹងបន្ថែមនិងពេញចិត្តចំពោះរមណីយដ្ឋានដ៏មានសារៈសំខាន់បំផុតនេះ។ តាមយោបល់ខ្ញុំ អ្វីដែលយើងទើបនឹងបានឃើញអំបាញ់មិញនេះផ្តល់នូវចម្លើយដ៏ប្រសើរមួយចំពោះសេចក្តីព្រួយបារម្ភរបស់យើងក្នុងនាមជាអ្នកអភិរក្ស ព្រោះថាយើងមិនចង់ឃើញប្រាង្គប្រាសាទនានាទទួលរងនូវការខូចខាតទេ ទោះបីជាយើងចង់បង្កើនចំណេះដឹងរបស់យើងតាមរយៈការទស្សនានៅពេលយប់ក៏ដោយ។ ព្រោះដូចដែលលោក លោកស្រីជ្រាបស្រាប់ហើយ នៅទីនេះមានរាត្រីដ៏ស្រស់ត្រកាលជាច្រើន។ ហើយនៅពេលបន្តិចទៀត ក្នុងវេលាយប់នេះ លោកស្រីឯកអគ្គរដ្ឋទូតប្រទេសអូស្រ្តាលីនឹងបង្ហាញជូនយើងនូវរមណីយដ្ឋានមួយ។ សូមអរគុណលោកប្រធាន។

**សំណួររបស់សហប្រធានជប៉ុន៖** សូមអរគុណចំពោះសេចក្តីពន្យល់បន្ថែមរបស់លោក។ តើមានសំណួរឬសេចក្តីកត់សម្គាល់ផ្សេងទៀតដែរឬទេ?

**សំណួររបស់លោក អ៊ុក សុម៉េត ៖** ខ្ញុំមានសំណួរមួយសួរទៅលោក Guilhot។ ខ្ញុំឈ្មោះ អ៊ុក សុម៉េត មកពីអាជ្ញាធរជាតិអប្សរា។ ខ្ញុំមានសំណួរខ្លីមួយព្រោះលោកបានលើកឡើងនៅពេលអំបាញ់មិញនេះអំពីព្រះចន្ទនិងផ្កាយដែលមិនសុទ្ធតែមានរាល់យប់ទេ។ បើយើងសន្មត់ថា ថ្ងៃណាមួយមានព្រះចន្ទនិងផ្កាយនោះ នៅពេលនោះ តើអ្វីទៅជាទស្សនាទាននៃការដាក់ភ្លើងបំភ្លឺបេតិកភណ្ឌរបស់មនុស្សជាតិនេះ? លោកបាននិយាយអំពីអព្ភន្តរញ្ញាណ ហើយតើយើងមិនអាចដាក់បញ្ចូលអព្ភន្តរញ្ញាណនេះ ទៅក្នុងពន្លឺដែលមានលក្ខណៈជាសាកលនេះដែលនាំមកដោយព្រះចន្ទនិងផ្កាយទេឬ? តើមានការបន្ថយកម្លាំងពន្លឺនៃភ្លើងដែលលោកដាក់បំភ្លឺដែរឬទេ? ឬមួយក៏លោកបិទភ្លើងទាំងស្រុងហើយទុកឲ្យលេចឡើងនូវតម្លៃជាសាកលរបស់ព្រះចន្ទនិងផ្កាយវិញ?

**ចម្លើយរបស់លោក Alain Guilhot ៖** សូមអរគុណលោកអគ្គនាយកដែលបានសួរសំណួរនេះ ព្រោះថាខ្ញុំមិនអាចជំរាបជូននូវអ្វីៗទាំងអស់ក្នុងរយៈពេលប៉ុន្មាននាទីបានទេ។ ខ្ញុំជឿថាចម្លើយមាននៅក្នុងសំណុំឯកសារដែលយើងខ្ញុំនឹងប្រគល់ជូនលោក លោកស្រី។ ពិតប្រាកដណាស់ យើងបានគិតដល់ចំនុចនេះ។ ប្រាកដហើយ នៅយប់ដែលមានព្រះចន្ទពេញបូណ៌មីនិងផ្កាយ យើងចង់ស្នើឡើងនូវវង់ទស្សនាមួយដោយបិទភ្លើងបំភ្លឺទាំងស្រុង មានតែពន្លឺព្រះចន្ទនិងផ្កាយប៉ុណ្ណោះ ជាការទស្សនារមណីយដ្ឋានលំអដោយពន្លឺពណ៌ធម្មជាតិ ដែលមានម្តងឬពីរដងក្នុងមួយខែ។ ប៉ុន្តែយើងគិតថា នេះគឺជាសកម្មភាពមួយដែលត្រូវបង្កើតឡើង។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** ប្រសិនបើលោក លោកស្រីមានសំណួរផ្សេងទៀត តើលោក លោកស្រីអាចសួរសំណួរដោយផ្ទាល់ទៅលោក Guilhot នៅក្រោយសម័យប្រជុំបានទេ? ព្រោះយើងមានពេលវេលាតិច។ តើខ្ញុំអាចបញ្ចប់ជំពូកស្តីពីការលើកតម្លៃបេតិកភណ្ឌនេះបានដែរឬទេ? ខ្ញុំសូមឆ្លងទៅជំពូក អនុសាសន៍របស់ CIC ហើយខ្ញុំ

សូមជូនវេទិកាទៅលោកសាស្ត្រាចារ្យ Beschaouch ។

# VII. អនុសាសន៍របស់ សេ អ៊ី សេ

## VII.1 ការបង្ហាញជូននូវអនុសាសន៍ ដោយលេខារបស់ សេ អ៊ី សេ

**លោក Beschaouch៖** ខ្ញុំសូមអរគុណហើយដែលបានឯកភាពទៅលើរបៀបវារៈបំព្រួញ។ ខ្ញុំសូមរំលឹកថាមានចំណុចពីរទៀតមុននឹងចូលដល់កាលបរិច្ឆេទដែលជារឿងងាយដោះស្រាយ។ ចំណុចទាំងពីរនោះទាក់ទងនឹង អនុសាសន៍ថ្ងៃនេះ និងអនុសាសន៍ ដែលបើតាមនីតិវិធី យើងត្រូវអនុម័តថ្ងៃនេះ ប្រសិនបើគ្មានការជំទាស់ទេនោះ។

ឯកឧត្តមសហប្រធាន យើងខ្ញុំជាមួយសហការីកំពុងរៀបចំអនុសាសន៍ថ្ងៃនេះ ដែលទាំងអស់មានចំនួន៦។ យើងខ្ញុំនឹងតាក់តែងអនុសាសន៍ទាំងនេះ រួចដាក់ជូនសហប្រធាន នៅពេលដែលសហប្រធានឯកភាពហើយ យើងនឹងផ្ញើជូនអ្នកចូលរួមទាំងអស់។ ទោះបីជាម៉ោងកាន់តែខើចណាស់ទៅហើយក៏ដោយ យើងក៏ត្រូវធ្វើទៅតាមបទបញ្ជាដែរ។

ទាក់ទងនឹងអនុសាសន៍សម័យប្រជុំបច្ចេកទេសលើកទី១៨ ខ្ញុំបានសូមអោយសហការីរបស់ខ្ញុំចែកជូនហើយ ប៉ុន្តែអាចមានអ្នកខ្លះនិយាយថា ឯកសារចែកច្រើនពេក មិនដឹងមួយណាទេ។

ដូច្នេះ បញ្ហាដែលចោទឡើង ប្រសិនបើអស់លោក លោកស្រី អនុញ្ញាតអោយខ្ញុំនិយាយ គឺថា តើមានអ្នកណាចង់បន្ថែមអ្វីទេ ទៅលើអនុសាសន៍ទាំងនេះ ដែលជាអនុសាសន៍ចុងក្រោយនៃសម័យប្រជុំបច្ចេកទេសលើកទី១៨ និងដែលយើងកំពុងដាក់ជូនសម័យប្រជុំពេញអង្គពិនិត្យនិងអនុម័ត។

នីតិវិធីគឺបែបនេះឯង លើកលែងតែមានអ្នកណាម្នាក់ចង់បន្ថែមអ្វីមួយ ក្នុងករណីនេះ យើងនឹងពិភាក្សាបន្តទៀត បើមិនដូច្នោះទេ យើងអាចនិយាយបានថា "អនុម័ត" ដើម្បីអោយសហប្រធានរបស់យើងអនុញ្ញាតអោយយើងដាក់នៅក្នុងរបាយការណ៍ថាអនុសាសន៍ទាំងនេះត្រូវបានអនុម័តជាផ្លូវការ ហើយយើងអាចឈានទៅរកការអនុវត្តបាន។

## VII.2 ការអនុម័តអនុសាសន៍ដោយ សេ អ៊ី សេ

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** សូមអរគុណលោកសាស្ត្រាចារ្យ។ ទាក់ទងនឹងអនុសាសន៍សម័យប្រជុំបច្ចេកទេសលើកទី១៨ តើមានអ្នកណាមានយោបល់អ្វីទេ?

**បទអត្ថាធិប្បាយរបស់លោក Beschaouch៖** (ទាំងភាសាបារាំង ទាំងភាសាអង់គ្លេស) ហើយនៅក្នុងឯកសារដែលយើងបានចែកជូន គ្រប់គ្នាសុទ្ធតែមានអនុសាសន៍ទូទៅដែលបានធ្វើឡើងនៅថ្ងៃទី២ និងទី៣ មិថុនា ២០០៩។ ប្រសិនបើគ្មានការជំទាស់អ្វីទេ តើយើងអាចចាត់ទុកថាលោកអ្នកឯកភាពជាផ្លូវការទៅលើអនុសាសន៍ទាំងនេះហើយបានទេ? ដើម្បីអោយសហប្រធានរបស់យើងអនុញ្ញាតអោយយើងសរសេរនៅក្នុងរបាយការណ៍ថា "ការអនុម័ត

អនុសាសន៍ទូទៅនិងអនុសាសន៍ពិសេស"។ ប្រសិនបើអនុម័តហើយ សូមអរគុណច្រើន! យើងឈានទៅចំណុចមួយទៀតឯកឧត្តមសហប្រធាន។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** ដូច្នេះ សម្រេចថា អនុសាសន៍សម័យប្រជុំបច្ចេកទេសលើកទី១៨ ត្រូវបានអនុម័តជាផ្លូវការ។ ប្រធានបទបន្តគឺពាក់ព័ន្ធនឹងកាលបរិច្ឆេទសម័យប្រជុំបច្ចេកទេសលើកក្រោយ។ ខ្ញុំសូមជូនវេទិកាទៅលោកសាស្ត្រាចារ្យ។

## VII.3 កាលបរិច្ឆេទនៃសម័យប្រជុំបច្ចេកទេសលើកក្រោយ

**បទអត្ថាធិប្បាយរបស់លោក Beschaouch៖** សូមអរគុណច្រើនឯកឧត្តមសហប្រធាន។ កាលបរិច្ឆេទនៃសម័យប្រជុំបច្ចេកទេសតែងតែត្រូវបានកំណត់ដោយសម័យប្រជុំពេញអង្គ។ ហើយសម័យប្រជុំបច្ចេកទេសនឹងកំណត់កាលបរិច្ឆេទសម័យប្រជុំពេញអង្គវិញម្តង។ ដូចដែលលោក លោកស្រីដឹងស្រាប់ហើយ យើងតែងតែប្រជុំបច្ចេកទេសនៅទីនេះ ខែមិថុនា ដោយគិតទៅដល់កាលបរិច្ឆេទនៃការប្រជុំរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក មុនពេលដែលកម្ពុជាបានជាប់ឆ្នោតជាសមាជិករបស់គណៈកម្មាធិការនេះនៅឆ្នាំនេះទៅទៀត ពីព្រោះ តំណាងយូណេស្កូមួយចំនួន អ្នកខ្លះនៅក្នុងចំណោមយើងទាំងអស់គ្នា ត្រូវទៅចូលរួមក្នុងការប្រជុំរបស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ ដូច្នេះយើងតែងមិនប្រជុំនៅខែកក្កដាទេ ហើយយើងតែងតែប្រជុំនៅមុនថ្ងៃទី១៥ខែមិថុនា។ ឆ្នាំនេះយើងបានស៊ើបសួរមើលហើយ លោកនាយកការិយាល័យយូណេស្កូនៅភ្នំពេញសូមអោយយើងផ្ទៀងផ្ទាត់មើលអោយបានច្បាស់ព្រោះឮថាអាចមានការប្រជុំមួយរបស់គណៈកម្មាធិការអន្តរជាតិស្តីពីបេតិកភណ្ឌវប្បធម៌អរូបី នៅខែមិថុនា។ យើងបានផ្ទៀងផ្ទាត់មើលជាមួយប៉ារីស៍ហើយ ថាប្រជុំនេះនឹងធ្វើឡើងនៅខែតុលាទេ។

**បទអត្ថាធិប្បាយរបស់លោក ស្រី Rivière ៖** នៅក្នុងកូនសៀវភៅកំណត់ហេតុរបស់ខ្ញុំ មានកត់ត្រាថា នៅខែមិថុនា នឹងមានប្រជុំមួយពីចន្លោះថ្ងៃទី២១ដល់ថ្ងៃទី២៥ ប៉ុន្តែត្រូវបញ្ជាក់ម្តងទៀត។

**បទអត្ថាធិប្បាយរបស់លោក Beschaouch៖** ការប្រជុំនោះស្ថិតនៅក្រោមការទទួលខុសត្រូវរបស់លោកស្រីអគ្គនាយករង ដូច្នេះមានតែលោកស្រីទេដែលមានព័ត៌មានច្បាស់ជាងគេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំសូមចោទជាសំណួរឡើង។ នៅក្នុងការប្រជុំចតុភាគីម្សិលមិញ យើងបានស្នើដល់សហប្រធានទាំងពីររូបអោយមានការប្រជុំបច្ចេកទេសលើកក្រោយនៅថ្ងៃទី៨ និងទី៩ មិថុនា។ បើសិនជាខ្ញុំមិនច្រលំទេ គឺចំថ្ងៃអង្គារនិងថ្ងៃពុធ។ អញ្ចឹងគេអាចមកដល់ថ្ងៃអាទិត្យ ហើយសម្រាកថ្ងៃច័ន្ទបាន។ ចំណែកឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរអប្សរា លោកតែងតែផ្តល់កិត្តិយសមកចូលរួមក្នុងកិច្ចប្រជុំរបស់យើង។ យើងជៀសវាងថ្ងៃព្រហស្បតិ៍ ព្រោះថ្ងៃសុក្រ មានប្រជុំគណៈរដ្ឋមន្ត្រី។ ដូច្នេះ បើយើងយកថ្ងៃទី៨ និងថ្ងៃទី៩ ពិតជាល្អទាំងអស់គ្នា ចំពោះខាងថ្នាក់ដឹកនាំយូណេស្កូ ទោះបីជាថ្ងៃប្រជុំខែមិថុនាអាចប្រែប្រួលបន្តិចយ៉ាងណាក្តី ក៏ថ្ងៃទី៨និងទី៩នៅឆ្ងាយពីថ្ងៃទី២១ដែរ។

**បទអត្ថាធិប្បាយរបស់លោក ស្រី Rivière ៖** ខ្ញុំសូមជម្រាបបន្ថែមថា លើកនេះខុសពីលើកមុន គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនឹងប្រជុំចុងខែ៧ ដើមខែ៨ នៅទីក្រុង Brasilia។ ដូច្នេះ លោកអ្នកអាចយកខែ៧ក៏បាន។

**បទអត្ថាធិប្បាយរបស់លោក Beschaouch៖** អូហ៍ អរគុណណាស់។ អញ្ចឹង បើសិនជាគណៈកម្មាធិការ មកពី

មូលហេតុអាកាសធាតុ ខ្ញុំគិតថា...

**បទអត្ថាធិប្បាយរបស់លោក ស្រី** Rivière ៖ អត់ទេ មិនមែនមកពីមូលហេតុអាកាសធាតុទេ។ គឺមកពីមានការប្រកួតបាល់ទាត់នៅប្រេស៊ីល។ បើមានបាល់ទាត់ហើយ សូម្បីតែគណៈកម្មាធិការបេតិកភណ្ឌពិភពលោកក៏ត្រូវរៀបចំក្រោយដែរ។

**បទអត្ថាធិប្បាយរបស់លោក** Beschaouch៖ បាល់ទាត់ជាបេតិកភណ្ឌមួយផ្សេងទៀត! បើអញ្ចឹង យើងសូមជូនលទ្ធភាពមួយទៀតនេះទៅសហប្រធានរបស់យើង។ បើមិនយកថ្ងៃទី៨ ទី៩ មិថុនាទេ យើងអាចយកដើមខែ៧ក៏បាន នេះប្រសិនបើឯកឧត្តមឧបនាយរដ្ឋមន្រ្តី មិនមានជាប់រវល់អីទេ យើងក៏មានពេលច្រើនសម្រាប់ធ្វើរបាយការណ៍ផង។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** ដូច្នេះ លេខាធិការដ្ឋានស្នើសុំកាលបរិច្ឆេទដើមខែកក្កដា ដើម្បីរៀបចំសម័យប្រជុំបច្ចេកទេស សេ អ៊ី សេ លើកក្រោយ អញ្ចឹង យើងអាចកំណត់យកដើមខែ៦ ឬ ដើមខែ៧ បានទេ ហើយថ្ងៃណាពិតប្រាកដ យើងនឹងជម្រាបជូនតាមក្រោយ។

**បទអត្ថាធិប្បាយរបស់លោក** Beschaouch៖ សូមអរគុណឯកឧត្តមសហប្រធាន។ ដោយសារថា កម្រមានអ្នកណាមកតែពីរថ្ងៃណាស់ លើកលែងតែអ្នកបច្ចេកទេសដ៏តិចតួចប៉ុណ្ណោះ ជាទូទៅយើងមកស្ទើរតែមួយសប្តាហ៍តែម្តង។ អញ្ចឹង យើងនិយាយថាយកដើមខែមិថុនាទៅចុះ ហើយថ្ងៃពិតប្រាកដ យើងនឹងយកថ្ងៃ អង្គារ ពុធ ឬ ច័ន្ទ អង្គារ យើងនឹងជូនដំណឹងអោយបានមុន មួយខែ ឬ មួយខែកន្លះ។ អញ្ចឹងទៅបានទេ? សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** ដូច្នេះ យើងកំណត់យកដើមខែមិថុនាសម្រាប់ការប្រជុំបច្ចេកទេសលើកក្រោយ ថ្ងៃច័ន្ទ អង្គារ ឬ ថ្ងៃអង្គារ ពុធ នៃសប្តាហ៍ទីមួយ ខែមិថុនា។ ថ្ងៃណាពិតប្រាកដ យើងនឹងជម្រាបជូនតាមក្រោយ។

**បទអត្ថាធិប្បាយរបស់លោក** Beschaouch៖ ខ្ញុំសូមអនុញ្ញាតនិយាយមួយម៉ាត់មុននឹងចូលដល់កម្មវិធីបិទអង្គប្រជុំ។ យើងបានស្នើសុំអោយអាជ្ញាធរជាតិអប្សរាចែកឯកសារនេះដែលពាក់ព័ន្ធនឹងលោក អ្នក។ វាជាឯកសារដែលគេបានប្រើនៅពេលប្រជុំបោះឆ្នោតសមាជិកគណៈកម្មាធិការបេតិកភណ្ឌពិភពលោក។ វាជាឯកសារដែលយើងអាចប្រើបានយូរឆ្នាំទៀត ព្រោះវាបង្ហាញពីកិច្ចសហប្រតិបត្តិការអន្តរជាតិនៅអង្គរ។ មានឈ្មោះប្រទេសរបស់លោកអ្នក មានទាំងទង់ជាតិ មានឈ្មោះនិងរូបប្រាសាទដែលលោកអ្នកកំពុងជួសជុល ជាមួយអាជ្ញាធរជាតិអប្សរាទៀតផង។ ឯកសារនេះរៀបចំដោយលោកស្រី ចៅ ស៊ុន កិរិយា។ ខ្លឹមសារក៏ល្អ សោភណភាពក៏ល្អ ហើយឯកឧត្តម សុខ អាន បានចេញបញ្ជាអោយបោះពុម្ព។ យើងបានចែកជូនរួចហើយ យើងគិតថាវាត្រូវតែចែកជូនលោក អ្នក។ យូណេស្កូកំពុងតែធ្វើឯកសារមួយទៀត នោះគឺសៀវភៅនិយាយពី១៥នៃ សេ អ៊ី សេ របស់យើង។ ខ្ញុំកំពុងតែអានឡើងវិញ ដើម្បីជួយលោក Teruo Jinnai ជួយអានអត្ថបទដែលបានសំរិទ្ធសម្រាំងចុងក្រោយនេះ។ សៀវភៅនេះមានជាង១២០ទំព័រទៅហើយ។ នៅពេលបោះពុម្ពរួច សៀវភៅនេះនឹងនិយាយអំពីយូណេស្កូ អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ អំពី ការវិវត្តរបស់ សេ អ៊ី សេ អំពីប្រវត្តិនៃការងារដែលធ្វើនៅអង្គរក្នុងក្របខ័ណ្ឌ សេ អ៊ី សេ។ ខ្ញុំគិតថាវាជាសៀវភៅមួយដ៏ល្អ និងជាសៀវភៅមួយដែលមានប្រយោជន៍។

**បទអត្ថាធិប្បាយរបស់លោក ស្រី** Rivière ៖ សូមទោស ខ្ញុំសូមនិយាយ មកពីខ្ញុំគិតថាវាហាក់ដូចជាខ្វះចំណុចមួយនៅ

ក្នុងរបៀបវារៈនេះ។ ចំណុចនោះត្រូវបានលើកឡើងត្រួសៗដែរ នោះគឺអនុសាសន៍នៃសម័យប្រជុំពេញអង្គនេះ។ លោកលេខាធិការរបស់យើងបាននិយាយថា លោកកំពុងធ្វើការលើចំណុចនេះ មិនទាន់ធ្វើចប់ទេ យើងគ្មានពេល ប៉ុន្តែពេលធ្វើរួច នឹងចែកជូន។ យើងគ្រោងអ្វីខ្លះនៅក្នុងអនុសាសន៍នោះ?

**បទអន្តរាធិប្បាយរបស់លោក Beschaouch៖** គ្រោងអ្វីខ្លះ? យើងធ្លាប់ធ្វើម្តងកាលពី៧ឆ្នាំមុន ដែលកាលនោះ យើងស្ថិតនៅក្នុងស្ថានភាពដូចថ្ងៃនេះអញ្ចឹង។ តាមនិតិវិធី យើងធ្វើរួចហើយ អនុម័ត ប៉ុន្តែនៅពេលនោះ សហប្រធានរបស់យើងបានយល់ព្រមទុកពេលអោយយើងរៀបចំអនុសាសន៍។ សម្រាប់ថ្ងៃនេះ អនុសាសន៍ទាំងអស់មាន៧ចំណុច ដូចដែលខ្ញុំបានជម្រាបរួចហើយ។ យើងនឹងដាក់ជូនសហប្រធានពិនិត្យ រួចបញ្ជូនទៅអាជ្ញាធរជាតិអប្សរា ដើម្បីមើលក្រែងមានចំណុចខ្វះខាត ឬ មិនត្រឹមត្រូវនឹងកិច្ចការដែលគេកំពុងអនុវត្ត។ នៅពេលដែលយើងបានការយល់ព្រមពីសហប្រធានហើយ យូណេស្កូនឹងធ្វើជូនសមាជិកដែលចូលរួមទាំងអស់នៅថ្ងៃនេះ តាមរយៈអីមែល ឬ តាមប្រៃសណីយ៍ចំពោះអ្នកដែលគ្មានអ៊ីមែល។ ធ្វើបែបនេះ យើងជៀសវាង ម្យ៉ាង យើងមិនអនុម័ត យើងទទួលរងគ្រោះដោយសារបញ្ហាពេលវេលា។ ដូច្នេះ យើងនឹងធ្វើអោយបានដាច់ខាត។ នេះជាការប្តេជ្ញាចិត្តមួយ។ កាលពី៧ឆ្នាំមុន យើងធ្លាប់ជួបបញ្ហាដូចគ្នានេះដែរ ហើយយើងដោះស្រាយបានយ៉ាងល្អប្រសើរ។

## VII.4 អនុសាសន៍សម័យប្រជុំពេញអង្គលើកទី១៦

**សំណួររបស់សហប្រធានជប៉ុន៖** លោកសាស្ត្រាចារ្យ! តើលោកសាស្ត្រាចារ្យអាចលើកឡើងខ្លីៗអំពីគោលគំនិតទូទៅពាក់ព័ន្ធនឹងខ្លឹមសារអនុសាសន៍ដែលនឹងត្រូវធ្វើឡើងព្រមទាំងពេលវេលាដែលអាចធ្វើអនុសាសន៍នេះរួចទេ?

**ចម្លើយរបស់លោក Beschaouch ៖** ខ្ញុំសូមអរគុណលោកសហប្រធាន! ខ្ញុំសូមឆ្លើយលើចំណុចសំខាន់មុន គឺពេលវេលា។ អនុសាសន៍នឹងធ្វើរួចមុនចុងសប្តាហ៍ ពោលគឺថាថ្ងៃនេះទី១៥ ដូច្នេះយើងនឹងធ្វើរួចនៅថ្ងៃទី២០ ឬ២១។ ការបកប្រែអនុសាសន៍ជាភាសាអង់គ្លេសនឹងមិនត្រូវការពេលវេលាច្រើនទេព្រោះវាមិនវែងពេកទេ ដូច្នេះ ទាំងភាសាបារាំងនិងភាសាអង់គ្លេសនឹងធ្វើចប់មុនចុងសប្តាហ៍ រួចនឹងដាក់ជូនលោកសហប្រធាន។

ចំណែកខ្លឹមសារ នឹងមានដូចខាងក្រោមនេះ៖

អនុសាសន៍មួយសំខាន់ទាក់ទងនឹងទឹក។ ដូចយើងបានលើកឡើងកាលពីម្សិលមិញក្នុងកិច្ចប្រជុំចតុភាគី ក៏ដូចជាក្នុងកិច្ចប្រជុំថ្ងៃនេះ យើងឃើញថាអនុសាសន៍ពាក់ព័ន្ធនឹងទឹកនេះត្រូវធ្វើឡើងដើម្បីអោយមានសេចក្តីសម្រេចនានាអាចជួយដល់អាជ្ញាធរអប្សរា ដល់ឯកឧត្តមអភិបាលខេត្តដែលសម្របសម្រួលគ្រប់មន្ទីរ នាយកដ្ឋានខេត្ត តំបន់ និងអាជ្ញាធរដែនដីដែលទទួលបន្ទុកខាងទឹក។ យើងបានលើកសំណើអោយចេញជាសេចក្តីប្រកាសមួយ ដើម្បីបង្កើតអោយមានគណៈកម្មការអន្តរជំនាញ អន្តរនាយកដ្ឋាន មួយដែលនឹងតាមដានលើបញ្ហាទឹកជាមួយយូណេស្កូ។

ប្រកាសនោះ យើងបានធ្វើពង្រាង និងពិភាក្សារួចហើយ ពេលនេះយើងបានដាក់ជូនទៅថ្នាក់លើ ពោលគឺជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរអប្សរា។ ប្រកាសនេះបានដាក់ជូនឯកឧត្តមពិនិត្យ ក្នុងនាមឯកឧត្តមជាតំណាងដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល ដូច្នេះឯកឧត្តមត្រូវមើល ព្រោះមានក្រសួងច្រើនពាក់ព័ន្ធ ពាក់ព័ន្ធមិនមែនក្នុងឋានៈក្រសួងផ្ទាល់ទេ ប៉ុន្តែក្នុងនាមមន្ទីរដែលស្ថិតនៅក្រោមអធិបតីភាពរបស់ឯកឧត្តមអភិបាលខេត្ត ស៊ូ ភីរិន្ទ។ នេះ

ជាអនុសាសន៍ទីមួយដែលត្រូវអនុវត្តអោយបាន ពីព្រោះ ការសិក្សារយៈពេលបួនឆ្នាំមកហើយ យើងឈានមកដល់ត្រឹមនេះ។ យើងត្រូវឈានទៅជំហានបន្ទាប់ទៀត។ ពីព្រោះអ្វី? ពីព្រោះថ្ងៃនេះ យើងបានឃើញថាមានច្រកទ្វារទឹកហូរចេញចំនួន៣នៅប្រលានយន្តហោះ ដូចដែលលោក Devillers បានបង្ហាញ ហើយក្នុងនោះមានច្រកពីរស្ទះ។ លោក លោកស្រីបានឮដូចខ្ញុំដែរថាច្រកទីបីស្ទះដោយសារអ្នកស្រុកចោលសំរាម។ គេអាចធ្វើអោយវាលយន្តហោះស្ថិតក្នុងសភាពគ្រោះថ្នាក់ ដោយសារដែលអ្នកស្រុកចោលសំរាមអោយស្ទះទ្វារទឹក។ តើអ្នកណាអាចដឹងបាន? យើងមិនអាចស្នើសុំអោយឯកឧត្តមអភិបាលខេត្តដើរតួជាប៉ូលិសគ្រប់ពេលបាននោះទេ។ ដូច្នេះ មានតែគណៈកម្មការនេះឯងជាអ្នកតាមដាន ទាញអារម្មណ៍ ។ល។ នេះជាខ្លឹមសារនៃអនុសាសន៍ទីមួយ។

អនុសាសន៍ទីពីរពាក់ព័ន្ធនឹងបច្ចេកទេស មានន័យថាធ្វើយ៉ាងណាអោយដំណោះស្រាយដែលបានរកឃើញនៅថ្ងៃនេះ លោក លោកស្រីឃើញហើយនៅពេលលោក Nakagawa សួរសំណួរទៅលោក Santoro គឺដំណោះស្រាយដែលផ្តល់ជូនត្រូវមានការពិភាក្សាគ្នាខាងបច្ចេកទេសជាមុនសិន មុននឹងឈានមកដល់កន្លែងនេះ ព្រោះ វាមិនដែលធ្លាប់កើតឡើងទេ ប៉ុន្តែ ពេលខ្លះវាអាចបង្កអោយមានការជជែកគ្នាលើវិធីជួសជុល។ ដូច្នេះ យើងចង់ផ្តល់ជាអនុសាសន៍ថា ហើយខ្ញុំបានសួរយោបល់ទៅអ្នកជំនាញ អាដ ហុក ហើយ ពួកគេពេញចិត្តនឹងអនុសាសន៍នេះ គឺថាត្រូវការពិភាក្សា ពិគ្រោះយោបល់គ្នាជាមួយអ្នកជំនាញ អាដ ហុក ទៅលើបញ្ហាធំៗពាក់ព័ន្ធនឹងវិធីសាស្រ្តជួសជុលដែលកំពុងយកមកអនុវត្ត ជាពិសេសក្នុងការជួសជុល ប្រាសាទអង្គរវត្ត ដែលមានក្រុមបច្ចេកទេស៦ក្រុមកំពុងធ្វើការដើម្បីអោយមានការសម្របសម្រួលខាងផ្នែកវិធីសាស្រ្ត។ ដូច្នោះ យើងអាចបង្កើតជាឯកសារមួយដែលយើងនឹងផ្តល់ជូនក្រុមបច្ចេកទេសដទៃទៀត ថ្វីត្បិតថាវាមិនមែនជាគម្ពីរក្បួននៃការអភិរក្ស ប៉ុន្តែ យ៉ាងហោចណាស់ វាអាចជាគម្រូជាបទដ្ឋាននៃការអភិរក្សនៅអង្គរនេះ។

ពាក់ព័ន្ធនឹងទេសចរណ៍ ខ្ញុំមិនដឹងថាត្រូវលប់ចម្លើយចេញឬអត់ទេ៖ មានអនុសាសន៍មួយដែលអ្នកជំនាញ អាដ ហុក ស្នើឡើង ហើយផ្នែកទីពីរគឺសំខាន់ ពោលគឺស្នើអោយបង្កើតប្លង់ទូទៅមួយ ព្រោះថានៅតាមកន្លែងជាច្រើននៃប្រាង្គប្រាសាទនានា ហើយយើងបានដើរពិនិត្យត្រួសៗរួចហើយដែរ ដើម្បីរក្សាសុវត្ថិភាពអ្នកទេសចរ យើងមិនគួរអោយពួកគេប្រើប្រាស់ជណ្តើរប្រាសាទមួយចំនួនទៀតឡើយ ដែលនៅទីនេះយើងហៅថាជណ្តើរបុរាណ។ ដូច្នេះយើងគួរដាក់ជណ្តើរឈើថែមទៀត ប៉ុន្តែត្រូវធ្វើអោយមានសោភណភាពដែរ ហើយអ្នកជំនាញគិតថាជណ្តើរឈើមិនរំខានអ្វីនោះទេ ដូច្នេះ យើងត្រូវធ្វើការអោយបានលឿនទៅមុខលើចំណុចនេះ។

អនុសាសន៍មួយទៀតពាក់ព័ន្ធនឹងក្រុង ដើម្បីអោយគេចាប់អារម្មណ៍ខ្លាំងថែមទៀតលើក្រុងសៀមរាប ព្រោះថាបើយើងមើលលើប្លង់បែងចែកតំបន់ ក្រុងសៀមរាបនៅជាប់នឹងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក។ វានៅក្នុងតំបន់ចំនួនពីរ គឺតំបន់៤និង៥ ក្នុងប្លង់ចែកតំបន់ដែលសម្រេចដោយព្រះរាជក្រឹត្យ។ ហើយនៅសៀមរាបនេះ មានបេតិកភណ្ឌក្រុង ដែលមានអគារសល់តាំងពីសម័យអាណានិគមបារាំង មានសំណង់ធ្វើអំពីឈើ ព្រមទាំងវត្តអារាមបុរាណៗ ជាដើម។ យើងត្រូវប្រុងប្រយ័ត្ន ចាត់វិធានការ និងមានកម្មវិធីអភិរក្ស សំណង់បេតិកភណ្ឌទាំងនេះអោយដូចជាប្រាង្គប្រាសាទអង្គរដូច្នោះដែរ។

មួយទៀតគឺពាក់ព័ន្ធនឹងទេសភាពក្រុង។ យើងពិតជាមានសំណាងណាស់ ពីព្រោះ គ្រប់គ្នាសុទ្ធតែនិយាយថា៖ យើងចង់អោយជនបទនៅផ្សារភ្ជាប់នឹងទីក្រុង។ ខ្ញុំមិនដឹងថាលក្ខណៈនេះមាននៅកន្លែងណាទៀតទេក្នុងពិភពលោក សូម្បីតែនៅអាហ្វ្រិកខាងជើង ក៏លក្ខណៈបែបនេះកំពុងឈានទៅរកការបាត់បង់ដែរ។ នៅសៀមរាបនេះ យើងធ្លាប់

ឃើញជនបទនៅក្នុងក្រុង ហើយយើងមានជនបទដែលមានប្រឡាយទឹកខ្វាត់ខ្វែង។ AFD និង AIMF (សមាគមអន្តរជាតិនៃអភិបាលក្រុងនិយាយភាសាបារាំង) បានផ្តល់មូលនិធិ ដោយសារឯកឧត្តមអភិបាលខេត្ត ហើយខ្ញុំលើកឡើងចំណុចនេះ ពីព្រោះគេបានអញ្ជើញខ្ញុំអោយទៅចូលរួមសន្និសីទមួយនៅ Hué ស្តីអំពីរឿងនេះ។ កម្ពុជាបានទទួលថវិកា។ យើងនឹងផ្តល់អនុសាសន៍មួយដើម្បីអោយបេតិកភណ្ឌក្រុងត្រូវបានគេសិក្សា និងជួយអាជ្ញាធរអប្សរាព្រមទាំងធ្វើយ៉ាងណាអោយគេបង្ហាញការសិក្សានេះជូនដល់គណៈកម្មាធិការរបស់យើង។ នេះគឺជាគោលធំៗនៃអនុសាសន៍ដែលយើងនឹងរៀបចំឡើង។ សូមអរគុណ។

យោបល់សហប្រធានជប៉ុនៈ លោកសាស្ត្រាចារ្យ! ដូច្នេះ យើងនឹងរង់ចាំពង្រាងអនុសាសន៍ទាំងនេះ ដែលលោកនឹងដាក់ជូនមុនដំណាច់ចុងសប្តាហ៍។ ដូច្នេះ បើគ្មានប្រធានបទណាផ្សេងនឹងពិភាក្សាទេ យើងនឹងឈានទៅរកវគ្គចុងក្រោយនៃសម័យប្រជុំពេញអង្គនេះ ហើយខ្ញុំសូមអញ្ជើញ ជាបឋម សហប្រធានបារាំងរបស់ខ្ញុំ។

# អនុសាសន៍សម័យប្រជុំពេញអង្គរបស់ សេ អ៊ី សេ លើកទៅ១៦

ថ្ងៃទី ១៥ ធ្នូ ឆ្នាំ ២០០៩

## អនុសាសន៍ទូទៅ

ចាប់ពីពេលនេះតទៅ របៀបវារៈសម័យប្រជុំបច្ចេកទេសនិងរបៀបវារៈសម័យប្រជុំពេញអង្គត្រូវបានបែងចែកខុសពីគ្នាដាច់ស្រឡះ។ ដូច្នេះ អនុសាសន៍ត្រូវបានផ្តល់ជូនសមាជិកនៃគណៈកម្មាធិការ ជាពិសេស ប្រធានក្រុមបេសកកម្មបុរាណវិទ្យា សូមទុកបទបង្ហាញរបស់ខ្លួនធ្វើនៅក្នុងសម័យប្រជុំបច្ចេកទេស។

## អនុសាសន៍ពិសេស

១. បញ្ហាពាក់ព័ន្ធនឹងទឹក (ប្រភព ការស្តុកទុក ការចែកចាយ ទឹកក្រោមដី ល្ង) ត្រូវបានចាត់ទុកជាឯកច្ឆន្ទថាជាអាទិភាពដាច់ខាត។ ដើម្បីធានានូវការពិគ្រោះ ពិភាក្សាអន្តរនាយកដ្ឋាន និងអន្តរជំនាញ ស្តីពីបញ្ហានេះ និងដើម្បីអោយការតាមដានមានជាប់ជាប្រចាំនិងមានប្រសិទ្ធិភាព អនុសាសន៍ត្រូវបានផ្តល់ជូនអោយចេញសេចក្តីប្រកាស ឬអនុក្រឹត្យមួយ ដើម្បីអោយការបង្កើតគណៈកម្មាធិការស្នើឡើងដោយអាជ្ញាធរជាតិអប្សរា គាំទ្រដោយអង្គការយូណេស្កូ ក្លាយទៅជាផ្លូវការ និងមានការឯកភាពពីឯកឧត្តមអភិបាលខេត្តសៀមរាប។

២. នៅក្នុងវិស័យការពារបេតិកភណ្ឌ ជាមួយវិធានការអភិរក្ស ឬ កម្មវិធីជួសជុល ចាំបាច់ត្រូវមានការពិភាក្សាពិគ្រោះយោបល់រវាងក្រុមបច្ចេកទេសដែលធ្វើការនៅអង្គរ។ ដោយមានការឯកភាពពីអ្នកជំនាញ អាដ ហុក សេ អ៊ី សេ សូមផ្តល់អនុសាសន៍ អោយមានការពង្រឹងបន្ថែមលើការសម្របសម្រួលផ្នែកវិធីសាស្ត្រ រវាងក្រុមបច្ចេកទេសទាំងអស់ អោយមានការពិគ្រោះ ពិភាក្សាយ៉ាងទូលំទូលាយលើបច្ចេកទេសយកមកប្រើប្រាស់ និងដំណោះស្រាយដែលស្នើឡើង ដោយយោងទៅតាមបទដ្ឋានអន្តរជាតិ ហើយជាពិសេស សូមអោយព័ត៌មានបច្ចេកទេសត្រូវបានចែកចាយអោយបានច្រើនរវាងក្រុមបច្ចេកទេសទាំងអស់។

៣. នៅក្នុងវិស័យសុវត្ថិភាពអ្នកទេសចរ និងអ្នកទស្សនាជាទូទៅ សេ អ៊ី សេ សូមផ្តល់អនុសាសន៍ អោយអាជ្ញាធរ

ជាតិអប្សរា ដោយមានការពិគ្រោះ ពិភាក្សាជាមួយអ្នកជំនាញ អាដ ហុក ទាំងពីរក្រុម (អភិរក្សនិងអភិវឌ្ឍន៍) បង្កើតកម្មវិធីដាក់ជណ្តើរឈើនៅតាមកន្លែងដែលមានការពិបាកឡើង ឬកន្លែងដែលអាចមានគ្រោះថ្នាក់។ ការអនុវត្តកម្មវិធីនេះត្រូវមានការពិភាក្សានៅក្នុងសម័យប្រជុំ សេ អ៊ី សេ ជាមុនសិន។

៩. ក្រុងសៀមរាបមិនត្រឹមតែជាកន្លែងទទួលបដិសណ្ឋារកិច្ចភ្ញៀវទេសចរ ដែលមកទស្សនាអង្គរប៉ុណ្ណោះទេ។ សៀមរាបសំបូរទៅដោយបេតិកភណ្ឌក្រុងៈ **ស្ថាបត្យកម្ម** (ផ្សារជំនាន់ដើម ស្ថាបត្យកម្មជំនាន់អាណានិគម ផ្ទះឈើ វត្តអារាមសម័យបុរាណ) **ទេសភាព** (ជនបទជាប់នឹងក្រុង និងដងស្ទឹង) និង **ធម្មជាតិ** (តំបន់មានប្រឡាយទឹក)។ អនុសាសន៍ត្រូវបានផ្តល់ជូនអោយយកចិត្តទុកដាក់ជាប់ជាប្រចាំទៅលើក្រុងសៀមរាប ទៅលើការការពារ ព្រមទាំងការលើកតម្លៃបេតិកភណ្ឌនៅក្នុងក្រុងនេះ។

# VIII. **ពិធីបិទអង្គប្រជុំ**

## VIII.1 **សុន្ទរកថាសហប្រធានបារាំង លោក** Jean-François Desmazières **ឯកអគ្គរដ្ឋទូត**

សូមអរគុណលោកសហប្រធាន។ វាពិតជាដល់ពេលត្រូវបញ្ចប់ហើយ។ ប៉ុន្តែទោះបីជាយើងប្រញាប់យ៉ាងណាក្តី ក៏យើងគួរឆ្លៀតពេលបញ្ចប់អោយបានល្អដែរ បើមិនអញ្ចឹងទេ វាហាក់ដូចជាមិនសមទេ។

លោកស្រី Rivière បានមានប្រសាសន៍ហើយថា សេ អ៊ី សេ អង្គរជាបទពិសោធន៍គួរអោយចាប់អារម្មណ៍មួយ ហើយវាមានដំណើរការល្អទៀត។ លោកស្រីបានទទួលស្គាល់ថា សេ អ៊ី សេ នេះបានវិវត្តទៅមុខ។ ពិតណាស់ថា បើយើងមិនវិវត្តទៅមុខទេ យើងពិតជាក្រិននៅមួយកន្លែងមិនខាន។ យើងឃើញហើយថា ពេញមួយថ្ងៃនេះ មានចំណុចមួយចំនួនដែលបញ្ជាក់ថាយើងចាំបាច់ត្រូវតែបន្តវិវត្តទៅមុខទៀត។ ខ្ញុំសូមរំលឹកឡើងវិញថា កាលពីឆ្នាំទៅមិញ យើងបានអនុម័តបទបញ្ជាផ្ទៃក្នុង ក្នុងហេតុផលចង់អោយអ្វីៗមានសភាពច្បាស់លាស់សម្រាប់គ្រប់ក្រុមដែលមកចូលរួមទាំងអស់។

នៅឆ្នាំនេះ បើនិយាយអំពីការរៀបចំនិងការវិវត្តន៍ ការពិចារណាបានសង្កត់ធ្ងន់លើការងាររបស់អ្នកជំនាញ អាដ ហុក ដើម្បីការអភិវឌ្ឍន៍ប្រកបដោយចិរភាព។ យើងបានចាប់ផ្តើមដោយអោយពួកគេដើរតាមគន្លងអ្នកជំនាញ អាដ ហុក ដើម្បីការអភិរក្ស។ តាមពិត ការងាររបស់ពួកគេទាំងពីក្រុមមិនដូចគ្នាទេ។ ពេលវេលាការងារក៏មិនដូចគ្នាដែរ ហើយការគិតក៏រឹតតែមិនដូចគ្នាទៅទៀត មានន័យថាវាមិនមែនជាការគិតមួយបែបវិទ្យាសាស្ត្រជាមួយក្រុមសាកលវិទ្យាល័យនោះទេ ផ្ទុយទៅវិញ វាជាការបូកផ្សំគ្នារវាងអ្វីដែលអ្នកវិទ្យាសាស្ត្រនិងអ្នកជំនាញខាងការអភិរក្សយល់ឃើញ និងអ្វីដែលរដ្ឋាភិបាលនិងអាជ្ញាធរថ្នាក់ជាតិគួរធ្វើ ឬ គិតទុកមុនដើម្បីធ្វើយ៉ាងណាអោយអង្គរមានការអភិវឌ្ឍន៍ល្អផ្នែកទេសចរណ៍ដូចដែលយើងសុទ្ធតែចង់បានគ្រប់ៗគ្នា។

ដូច្នេះ ត្រូវមានការផ្លាស់ប្តូររបៀបធ្វើការរបស់អ្នកជំនាញផ្នែកអភិវឌ្ឍប្រកបដោយចិរភាព ដោយគិតដល់កម្មវិធីការងាររបស់ពួកគេដែលខុសពីមុន។

ទាំងនេះពិតជានាំយើងអោយគិតបន្តិចទៅលើ សេ អ៊ី សេ នេះ។ មានការពិចារណាពីរបែប។ វាដូចជាការកំណត់ដែនច្បាស់លាស់បន្តិច។ មានការពិចារណារវាងការអភិរក្សនិងការអភិវឌ្ឍន៍ និងការពិចារណារវាងការពិចារណារវាងការអភិរក្សនិងការអភិវឌ្ឍន៍នេះ ដែលគ្រប់ដៃគូទាំងអស់ទៅតាមកម្រិតខុសៗគ្នាអាចធ្វើទៅបាន។

មានអ្នកចូលរួមជាង៣០០រយនាក់នៅក្នុងបន្ទប់ប្រជុំនេះ លក្ខណៈមួយក្នុងចំណោមលក្ខណៈផ្សេងទៀតនៃអង្គប្រជុំដ៏ពិសេសនេះ នៃក្រុមអ្នកប្រាជ្ញនេះ គឺបានតំណាងរដ្ឋាភិបាលជាច្រើនមកចូលរួម មានឯកអគ្គរាជទូត រាជទូតជាងដប់ប្រាំប្រទេសមកចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងតំណាងជាច្រើនទៀតរបស់រាជរដ្ឋាភិបាល ព្រោះថាខាងកម្ពុជា មានការចូលរួមពីខាងអន្តរក្រសួង ហើយខាងរដ្ឋាភិបាលផ្សេងទៀត មានអ្នកប្រាជ្ញ អ្នកវិទ្យាសាស្ត្រ អ្នកសាកលវិទ្យាល័យ អ្នកស្រាវជ្រាវ ជាដើម។ នេះក៏ជាលក្ខណៈមួយរបស់គណៈកម្មាធិការនេះដែរ ហើយក៏ជារបៀបពិភាក្សាមួយដែលត្រូវចេះរៀបចំដែរ។

តាមពិត អារម្មណ៍ដែលយើងអាចមានគឺគួរតែជាពេលវេលានៃការពិភាក្សារវាងក្រុមអ្នកវិទ្យាសាស្ត្រខ្លួនឯងដែលគេគួរតែរៀបចំអោយបានប្រសើរជាងនេះ និងស៊ីជម្រៅ។ ប្រហែលជាក្នុងន័យនេះហើយដែលយោបល់លើកឡើងអម្បាញ់មិញចង់និយាយ។

ដូច្នេះ ខ្ញុំគិតថា ដោយសារយើងនៅក្នុងដំណាក់កាលគិតគូរ រៀបចំដែលយើងត្រូវធ្វើអោយមានភាពស៊ីសង្វាក់ល្អជាងនេះរវាងសម័យប្រជុំខែមិថុនា កក្កដា និងសម័យប្រជុំខែធ្នូ គឺថាសម័យប្រជុំខែធ្នូគួរនៅតែជាសម័យប្រជុំពេញអង្គ។ វាជាសម័យប្រជុំផ្តល់អនុសាសន៍។ បើនិយាយម្យ៉ាងទៀត វាហាក់ដូចជាសម័យប្រជុំរវាងតំណាងរដ្ឋាភិបាលនានា ប៉ុន្តែអមទៅដោយអ្នកវិទ្យាសាស្ត្រ ព្រោះថាសំដីរបស់អ្នកវិទ្យាសាស្ត្រពិតជាសំខាន់ណាស់សម្រាប់ពួកយើង ហើយយើងចង់ស្តាប់ពួកគេ។ ហើយសម័យប្រជុំខែ មិថុនា កក្កដា ដែលយើងហៅថាសម័យប្រជុំបច្ចេកទេស បានចាប់ផ្តើមរីកធំជាងមុន។ ឥឡូវនេះ យើងប្រជុំរហូតដល់៤៨ម៉ោង។ យើងចង់អោយសម័យប្រជុំបច្ចេកទេសនេះកាន់តែស៊ីជម្រៅថែមទៀត។ ប្រហែលជាយើងមិនគួរនឹងខ្មាសអៀនដែលត្រូវហៅសម័យប្រជុំនេះថាជា សម័យប្រជុំវិទ្យាសាស្ត្រ នោះទេ ហើយដែលយើងគួរចំណាយពេលវេលាអោយបានកាន់តែច្រើនដើម្បីពិចារណាលើប្រធានបទទាំងនេះ លើការរៀបចំ និងលើការរៀបចំអោយមានការពិគ្រោះយោបល់គ្នារវាងក្រុមបច្ចេកទេសទាំងអស់។

ដូច្នេះ លេខាធិការវិទ្យាសាស្ត្ររបស់យើង គឺលោកសាស្ត្រាចារ្យ Beschaouch បានអំពាវនាវសុំអោយមានចូលរួម ហើយខ្ញុំចង់បញ្ជាក់ថែមទៀតថា យើងពិតជាអំពាវនាវសុំអោយមានការចូលរួម។ លោក លោកស្រី ក្រុមវិទ្យាសាស្ត្រទាំងអស់ សូមអំពាវនាវអោយមានការចូលរួមទាំងអស់គ្នា ដើម្បីបន្តពិចារណាលើរបៀបដែលយើងរៀបចំ ដើម្បីអោយការពិគ្រោះយោបល់គ្នាដែលធ្វើឡើងនៅក្នុងក្របខណ្ឌ សេ អ៊ី សេ នេះអាចបន្តរីកលូតលាស់ទៅមុខប្រកបដោយលក្ខណៈសុខដុមរមនា។

ដូច្នេះ នេះជាអ្វីដែលខ្ញុំចង់និយាយដើម្បីបញ្ចប់។ ជាការបញ្ចប់លើនីតិវិធីដែលមានការវិវត្តជាប់ជានិច្ច ហើយបើយើងពិនិត្យមើលទៅវាដូចជាផ្ទុយបន្តិច ព្រោះថា ជាថ្មីម្តងទៀត នៅខែធ្នូ យើងគ្មានពេលវេលានឹងនិយាយអោយបានច្រើនទេ យើងបានកាត់ពេលវេលាសម្រាប់ការពិភាក្សាអស់ជាច្រើន គួរអោយសោកស្តាយណាស់។ ប៉ុន្តែដោយហេតុនេះហើយ យើងគួរតែរៀបចំឡើងវិញ។ ហើយទោះជាយ៉ាងណាក្តី មានការអំពាវនាវសូមអោយគ្រប់គ្នាជួយដល់លេខាធិការដ្ឋានវិទ្យាសាស្ត្រ រៀបចំសម័យប្រជុំខែ មិថុនា កក្កដា ២០១០ អោយមានរយៈពេលវែងជាងនេះ សុខដុមរមនាជាងនេះ និងបើកចំហដល់ការពិភាក្សាច្រើនជាងនេះ។ សូមអរគុណ។

## VIII.2 សន្ទរកថាតំណាងរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិអប្សរា

សូមគោរព សហប្រធានទាំងពីរជាទីគោរព។
សូមគោរព អ្នកស្រីអគ្គនាយករងនៃអង្គការយូណេស្កូ
ឯកឧត្តម លោក លោកស្រីជាទីរាប់អាន!

ដូចអស់លោកជ្រាបស្រាប់ហើយ របៀបវារៈនៃសម័យប្រជុំពេញអង្គលើកទី១៦ បានប្រើពេលវេលាដូចជាប្រផិតប្រផើយបន្តិច។

ពិតណាស់ថា រាល់ប្រធានបទដែលគ្រោងឡើងទាំងអស់ សុទ្ធតែមានសារៈសំខាន់ ទាំងចំពោះកិច្ចការអភិរក្សនិងលើកតម្លៃតំបន់អង្គរ ក៏ដូចជាចំពោះកិច្ចអភិវឌ្ឍជានិរន្តរភាព នៅសៀមរាប។ ប៉ុន្តែ បើទៅមិនរួចគេក៏មិនអាចបង្ខំបានដែរ។

ខ្ញុំសូមកោតសរសើរដល់លេខាធិការដ្ឋានដែលបានដាក់ជូននូវរបៀបវារៈថ្មី ដែលទទួលបាននូវការយល់ព្រមពីសហប្រធានទាំងពីររបស់យើង។ ខ្ញុំក៏សូមអរគុណផងដែរដល់អ្នកចូលរួមទាំងអស់ ដែលបានគោរពតាមម៉ោងកំណត់កាលពីពេលរសៀលនេះ។

ឯកឧត្តម លោក លោកស្រីជាទីរាប់អាន!

ខ្ញុំសូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ។

ជាដំបូង ខ្ញុំសូមសង្កត់ធ្ងន់ទៅលើអត្ថន័យនៃពិធីដែលប្រារព្ធឡើងនៅតានី ថ្ងៃនេះ។ បន្ទាប់ពីសារមន្ទីរ ព្រះសីហនុ អង្គរ ដែលឧទ្ទិសដល់សិល្បៈចម្លាក់ យើងក៏បានសម្ពោធសារមន្ទីរកុលាលភាជន៍ គឺឡកុលាលភាជន៍ ដែលអាជ្ញាធរអប្សរាខំប្រឹងប្រែងរៀបចំឡើងជាពិសេស នៅក្នុងឧទ្យានបុរាណវិទ្យាមួយ។

នោះគឺជាចំណុចថ្មីមួយទៀត ស្តីពីយុទ្ធសាស្ត្របង្កើតសារមន្ទីរ ដែលយើងចង់អនុវត្ត នៅខាងក្នុង និងនៅជុំវិញតំបន់អង្គរ ដោយអនុលោមទៅតាមនិយាមអន្តរជាតិ និងដោយប្រើប្រាស់ជាបណ្តើរៗ នូវបច្ចេកទេសថ្មីៗក្នុងការតាំងពិព័រណ៍ ក្នុងការផ្សព្វផ្សាយផ្នែកទេសចរណ៍ និងការបំផុសបញ្ញាបផ្នែកវប្បធម៌។

ចំពោះចំណុចនេះ យើងខ្ញុំសប្បាយរីករាយណាស់ ដោយមានការជួយជ្រោមជ្រែងពីអ្នកជំនាញនៃអង្គការយូណេស្កូ និងដៃគូសហការនៃប្រទេសដែលជាសមាជិកនៃ CIC ជាឧទាហរណ៍ ប្រទេសជប៉ុន ជាមួយនឹងវិទ្យាស្ថានជាតិណារ៉ា នៃសាកលវិទ្យាល័យ សូហ្វីយ៉ា។

ម្យ៉ាងវិញទៀត សារមន្ទីរនេះ ដែលស្ថិតនៅកណ្តាលស្រុកស្រែ បង្ហាញពីសុឆន្ទៈរបស់យើង ក្នុងការជួយបំផុសប្រជាជនជនបទ ឲ្យយល់ពីតម្លៃនៃបេតិកភណ្ឌ។

កំណត់សម្គាល់ទីពីរ ដែលសំខាន់ហើយត្រូវធ្វើនោះ គឺខ្ញុំចង់បញ្ជាក់អោយច្បាស់ពីចំណុចមួយ។ បន្ទាប់ពីព្យុះកេតសាណា កើតឡើងភ្លាម ឯកឧត្តម ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន, ឯកឧត្តម ថោង ខុន

រដ្ឋមន្ត្រីក្រសួងទេសចរណ៍, ឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាប បានជួបជុំគ្នាជាបន្ទាន់ ស្វែងរកដំណោះស្រាយ ដើម្បីស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធក្រុងសៀមរាប ដែលខូចខាតដោយសារព្យុះនេះ។

បន្ទាប់ពីមានគំនិតផ្តួចផ្តើមនេះ និងដោយផ្អែកទៅលើរបាយការណ៍ស្តីពីស្ថានការណ៍ជាក់ស្តែង សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន បានគាំទ្រគណៈកម្មាធិការនេះ ហើយបានផ្តល់ជូននូវទឹកប្រាក់ចំនួន៥លានដុល្លារ ដើម្បីស្តារហេដ្ឋារចនាសម្ព័ន្ធនៃទីក្រុងឡើងវិញ។ កិច្ចការទាំងនេះត្រូវបានធ្វើរួចរាល់អស់ហើយ។

ចំណាប់អារម្មណ៍ចុងក្រោយរបស់ខ្ញុំ គឺទាក់ទងទៅនឹងការដាក់ភ្លើងបំភ្លឺប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ។ ខ្ញុំសូមរំឭកអោយច្បាស់ពីការសម្រេចដែលយើងបានធ្វើឡើង។ ប្រាសាទទាំងអស់សុទ្ធតែស្ថិតនៅក្នុងបញ្ជីសម្បត្តិវប្បធម៌នៃមនុស្សជាតិ។ សម្បត្តិទាំងនេះ ត្រូវបានការពារដោយច្បាប់ជាតិ និងស្ថិតនៅក្រោមការការពាររបស់អង្គការយូណេស្កូ។

យើងអាចប្រើប្រាស់ប្រាង្គប្រាសាទដើម្បីអភិវឌ្ឍផ្នែកទេសចរណ៍។ ប៉ុន្តែ ក៏ត្រូវតែមានលក្ខណៈជាការលើកតម្លៃ ទៅតាមបទដ្ឋាន លក្ខណៈវិនិច្ឆ័យ និងបច្ចេកទេសដែលគេទទួលស្គាល់រួចមកហើយដែរ។

ឥឡូវ ផ្លូវបានត្រួសត្រាយហើយ រីឯគោលដៅរបស់យើង គឺនឹងធ្វើការបំភ្លឺប្រាង្គប្រាសាទអោយបានល្អអស្ចារ្យ ដែលយកតាមលំនាំនៃការបំភ្លឺភ្លើងនៅទីក្រុងប៉ារីស រ៉ូម ណារ៉ា ប្រាសាទពីរ៉ាមីត និងរមណីយដ្ឋានដទៃទៀតជាច្រើន។

សហប្រធានជាទីគោរព !

សរុបសេចក្តីមក ខ្ញុំសូមកោតសរសើរដោយក្តីសោមនស្ស ដែលលោកទាំងពីរបានដឹកនាំសកម្មភាពការងារដល់ទីបញ្ចប់។ គ្រប់គ្នាសុទ្ធតែពេញចិត្តនឹងភាពអត់ធ្មត់ និងទឹកចិត្តគួរជាទីស្រឡាញ់របស់លោកទាំងពីរ ដែលពេលខ្លះក៏ចាំបាច់ត្រូវប្រកាន់នូវភាពម៉ឺងម៉ាត់ផងដែរ។ ខ្ញុំសូមថ្លែងអំណរគុណជាថ្មីទៀត។

យើងនឹងបំពេញកិច្ចការរួមគ្នា ដើម្បីត្រៀមរៀបចំសម័យប្រជុំបច្ចេកទេស នៃCIC នៅដើមខែមិថុនា ឆ្នាំ២០១០ ខាងមុខនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសបិទសម័យប្រជុំពេញអង្គលើកទី១៦ នៃ CIC នាពេលនេះ។

**បទអត្ថាធិប្បាយរបស់លោក Beschaouch៖** លោកសហប្រធាន បើយោងតាមកម្មវិធី មុននឹងចាកចេញទៅពិសារអាហារពេលល្ងាចនៅប្រាសាទ បាយ័ន តាមការអញ្ជើញរបស់លោកជំទាវឯកអគ្គរដ្ឋទូត អូស្ត្រាលី យើងនឹងមានពិធីចុះហត្ថលេខាកិច្ចព្រមព្រៀងដ៏សំខាន់មួយ ដែលនឹងឆ្លៀតក្នុងឱកាសដែលមានវត្តមានរបស់លោកស្រីអគ្គនាយករងខាងវប្បធម៌ រាជរដ្ឋាភិបាលកម្ពុជាដែលតំណាងដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងរដ្ឋាភិបាលអូស្ត្រាលីដែលតំណាងដោយ លោកជំទាវឯកអគ្គរដ្ឋទូត។ ពិធីនេះនឹងប្រារព្ធទៅនៅបន្ទប់ជាន់ទី១ រយៈពេលប្រមាណ១០នាទីប៉ុណ្ណោះ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះចំពោះមុខវត្តមានរបស់លោក លោកស្រី សហប្រធាន និងអ្នកទាំងអស់គ្នាដែលមានសមានចិត្តចង់ចូលរួម ជាបឋម សហប្រធានសម័យប្រជុំបច្ចេកទេស និងតំណាងរដ្ឋដែលមាន

វត្តមាននៅទីនេះ មុននឹងចេញទៅពិសាអាហារពេលល្ងាច។ សូមអរគុណ។

**បទអត្ថាធិប្បាយរបស់សហប្រធានជប៉ុន៖** ពិធីនេះនឹងប្រព្រឹត្តទៅភ្លាមនេះ ហើយការពិសាអាហារពេលល្ងាចនេះនឹងចាប់ផ្តើមនៅម៉ោង៧កន្លះនៅបាយ័ន។ សម័យប្រជុំពេញអង្គត្រូវបានបញ្ចប់នាពេលនេះ។ សូមអរគុណ។

## *** ចប់សម័យប្រជុំពេញអង្គលើកទី១៦របស់ សេ អ៊ី សេ ***

## សម័យប្រជុំពេញអង្គ សេ អ៊ី សេ អង្គរ លើកទី ១៦
## ថ្ងៃទី ១៥ វិច្ឆិកា ២០០៩ នៅសណ្ឋាគារ Sokha Angkor Resort
# បញ្ជីឈ្មោះអ្នកចូលរួម

| ល.រ | ឈ្មោះ | ងារ: | អង្គការ | អ៊ីមែល ឬ លេខទូរស័ព្ទ |
|---|---|---|---|---|
| 1 | Alain Guilhot | Expert for Angkor illumination | | |
| 2 | Alexander Ignatov | Ambassador | Embassy of the Federation of Russia | |
| 3 | An Sopheap | Department of Conservation Monument of Angkor | APSARA Authority | sopheap_an@yahoo.com |
| 4 | Ang Sokun | Department of Administration | APSARA Authority | 012 81 76 16 |
| 5 | Azedine Beschaouch | ICC Scientific Secretary | UNESCO | azedinebeschaouch@hotmail.com |
| 6 | Be Sinoun | Department of Cultural Development and Museum Conservation | APSARA Authority | |
| 7 | Bertrand Porte | Archaeologist | EFEO | bertrandporte@yahoo.fr |
| 8 | Bi Sopheap | Department of Public Order and Cooperation | APSARA Authority | |
| 9 | Blaise Kilian | ICC Secretariat | UNESCO Phnom Penh | b.kilian@unesco.org |
| 10 | Bounlap Keokangna | Deputy Director | SAGV | |
| 11 | Bun Kanhara | Office of Director General | APSARA Authority | 017 69 69 27 |
| 12 | Bun Lim Heng | Secretary of State | Council of Minister | |
| 13 | Bun Narith | Director General | APSARA Authority | puch_002@yahoo.com |
| 14 | Carol A. Rodley | Ambassador | US Embassy | |
| 15 | Chan Samnoble | Interpreter French-Khmer | APSARA Authority | chan.somnoble@rupp.edu.kh |
| 16 | Chan Tani | Vice-President | National Committee of World Heritage | |
| 17 | Chan Vathana | Deputy Director of Department | APSARA Authority | 012 31 57 86 |
| 18 | Chau Sun Kérya | ICC Secretariat | APSARA Authority | apsara.ddta@online.com.kh |
| 19 | Chea Phally | Department of Conservation Monument of Angkor | APSARA Authority | phally-but@yahoo.com |
| 20 | Chea Sarith | Department of Conservation Monument of Angkor | APSARA Authority | 012 93 58 30 |

| | | | | |
|---|---|---|---|---|
| 21 | Chea Sophat | Deputy Commissioner | Heritage Police | 015 86 33 28 |
| 22 | Chea Sopheak | | APSARA Authority | sopheak_siemreap@yahoo.com |
| 23 | Cheam Phally | Senior Architect | WMF | phallysiemreap@yahoo.com |
| 24 | Chhay Siven | Department of Agriculture and Community Development | APSARA Authority | |
| 25 | Chhieu Nam | Deputy Director of Department | APSARA Authority | 016 87 77 07 |
| 26 | Chhit Boravuth | | Council of Minister | |
| 27 | Chhom Kunthea | | APSARA Authority | |
| 28 | Chhong Setha | Director of Department | NAPV | c_setha2003@hotmail.com |
| 29 | Chhong Vira | Deputy Director of Department | APSARA Authority | 017 97 67 97 |
| 30 | Chhor Thanat | Deputy Director General | APSARA Authority | |
| 31 | Chin Sopheap | Governor | Angkor Thom District | |
| 32 | Chou Radyna | Department of Water Management | APSARA Authority | radinachou@yahoo.com |
| 33 | Christiane Garnero Morena | Expert | ICOMOS | garneromorena@gmail.com |
| 34 | Christophe Pottier | Architect | EFEO | christophe.pottier@efeo.net |
| 35 | Chrun Sophal | Department Director | APSARA Authority | 098 60 77 77 |
| 36 | Chuch Phoeurn | President | National Authority of Preah Vihear | chuch_phoeun@yahoo.com |
| 37 | Chuon Bunnath | Department of Technical Support and Intersectorial Projects | APSARA Authority | chounbunnath@yahoo.com |
| 38 | Claude Jacques | Archeologist | | claude.jacques@sfr.fr |
| 39 | D.S. Sood | Team Leader | ASI | dssood2006@yahoo.com |
| 40 | David Rorke | Interpreter English-French | UNESCO | dgrorke@yahoo.com |
| 41 | Dom Hak | Deputy Director General | APSARA Authority | |
| 42 | Dominique Freslon | Conseiller culturel | Ambassade de France | Dominique.FRESLON@diplomatie.gouv.fr |
| 43 | Dominique Soutif | Archaeologist | EFEO | |
| 44 | Dougald O'Reilly | Director | Heritage Watch | |

| | | | | |
|---|---|---|---|---|
| 45 | Ea Darith | Deputy Director of Department | APSARA Authority | 092 97 57 57 |
| 46 | Eleanor Bruce | Senior Lecturer | University of Sydney | eleanor,bruce@sydney.edu.au |
| 47 | Elke Tigges | Expert | DED/APSARA | elke.tigges@ded-cambodia.org |
| 48 | Em Srey Peou | | APSARA Authority | sreypeou_em@yahoo.com |
| 49 | Emmeline Decker | Dipl.-Restorer | GACP | emmeline.decker@gmail.de |
| 50 | Engl Soewono | Secretary | Embassy of Indonesia | engelstlh@yahoo.com |
| 51 | Eric Bourdonneau | Archaeologist | EFEO | eric.bourdonneau@free.fr |
| 52 | Eric Lliopis | Archaeologist | FSP | eric.llopis@inrap.fr |
| 53 | Francine d'Orgeval | | Ministère des Affaires Etrangères | Francine.DORGEVAL@diplomatie.gouv.fr |
| 54 | Françoise Riviére | Deputy Director-General for Culture | UNESCO Paris | |
| 55 | Frank Marcus Mann | Ambassador | Embassy of Gemany | |
| 56 | Furukawa Hirokazu | Consultant | APSARA Authority | 012 75 17 86 |
| 57 | Gaël de Guichen | Advisor to the DG ICCROM | ICCROM | ask Makara? |
| 58 | Georges Ramorasata | Chief Technical Officer | SCA | Georges.RAMORASATA@cambodia-airports.aero |
| 59 | Gilles Angles | Attaché de mission | Ambassade de France | |
| 60 | Giorgio Croci | Ad hoc Expert for conservation | UNESCO | mail@giorgiocroci.com |
| 61 | Glenn Boornazian | Project Coordinator | WMF | gboornazian@icr-icc.com |
| 62 | Gu Yu Cai | Director General | Chinese Academy of cultural Heritage | |
| 63 | Hang Chansopheap | Department of Land and Housing Management | APSARA Authority | |
| 64 | Hang Peou | Department Director | APSARA Authority | |
| 65 | Hang Sot | Vice-President | National Authority of Preah Vihear | 097 88 8 27 27 |
| 66 | Hans Leisen | Project Director | GACP | l@phno.auswaertiges-amt.de |
| 67 | Hem Sinath | Director of Department | NAPV | 097 74 71 78 78 |
| 68 | Heng Bunlay | | Council of Ministers | 012 51 84 85 |
| 69 | Heng Bunlay | Photographer | Council of Minister | 012 518 485 |

| | | | | |
|---|---|---|---|---|
| 70 | Heng Jeudi | Department of Technical Support and Intersectorial Projects | APSARA Authority | hengjadi@yahoo.com |
| 71 | Heng Kim Leng | Deputy Director of Department | APSARA Authority | 012 72 82 21 |
| 72 | Hidaka Kenichiro | Ad hoc Expert for development | UNESCO | akadih@heritage.tsukuba.ac.jp |
| 73 | Hing Thoraxy | Secretary of State | Council of Minister | thoraxy@gmail.com |
| 74 | Hiroshi Kawamura | Minister | Embassy of Japan | hiroshi.kawamura-2@mofa.go.jp |
| 75 | Hiroshi Sugiyama | Researcher | Nara Institute | sugiyama@nabunken.org.jp |
| 76 | Hiroyuki Nonaka | Project Formulation Advisor | JICA | Hiroyuki@jica.go.jp |
| 77 | Hok Peng Sè | Department Director | APSARA Authority | 012 32 39 97 |
| 78 | Hok Reatha | | APSARA Authority | hokreatha@yahoo.com |
| 79 | Hong Makara | National Programme Officer | UNESCO Phnom Penh | m.hong@unesco.org |
| 80 | Hor Ritheanou | Office of Director General | APSARA Authority | h_nou@yahoo.com |
| 81 | Hy Mara | Financial Controller | APSARA Authority | 012 26 67 66 |
| 82 | I Gede Ngurah Swajaya | Ambassador | Embassy of Indonesia | |
| 83 | Ichita Shimoda | Technical Advisor | JASA | ichita731@hotmail.com |
| 84 | Iev Chanheng | National Project Coordinator | UNESCO Phnom Penh | c.iev_jasa@online.com.kh |
| 85 | Im Sokrithy | Deputy Director of Department | APSARA Authority | 016 88 81 73 |
| 86 | Ishimura Tomo | Researcher | Nara Institute | tomoishi@nabunken.go.jp |
| 87 | Istvan Zelnik | President and CEO | HUNINCOR | |
| 88 | It Peou | Deputy Director of Department | APSARA Authority | 016 93 93 31 |
| 89 | Ivan Chválny | Commercial Attaché | The Embassy of Czech Republic | ivan_chvaly@mzv.cz |
| 90 | Jacques Gaucher | Archaeologist | EFEO | jacques_gaucher@yahoo.com |
| 91 | Jady Smith | Project Facilitator | Embassy of New Zealand | jady.smith@yahoo.com |
| 92 | Janhwij Shrama | Director Conservation | ASI | dircon.asi@gmail.co |

| | | | | |
|---|---|---|---|---|
| 93 | Jean François Desmaziéres | Ambassadeur | Ambassade de France | |
| 94 | Jean-Baptiste Chevance | Archaeologist | Archaeology and Development Foundation | jbchevance@free.fr |
| 95 | Jean-Marie Furt | Ad hoc Expert for development | UNESCO | jmafurt@wanadoo.fr |
| 96 | Jelen Janos | Director | Royal Angkor Foundation | jelenjanos@gmail.com |
| 97 | Jérémy Berthelomeau | Consultant | APSARA Authority | berthelomeau@yahoo.com |
| 98 | Josephine Gillespie | | University of Sydney | j.gillespie@usyd.edu.au |
| 99 | Joyce Clark | | | jclark0323@aol.com |
| 100 | József Laszolovszky | Chief Scientific Advisor of the JKK Project, Leader of the Heritage Cluster | Royal Angkor Foundation | |
| 101 | Julia Estève | Archaeologist | EFEO | esteve.julia@yahoo.fr |
| 102 | K.P. Poonacha | Joint Director General | ASI | jdg1.asi@gmail.com |
| 103 | Karel Kranda | Czech National team at Angkor | CNTA | kranda@ujf.cas.cz |
| 104 | Karin Schinken | Expert | DED | |
| 105 | Katsuhiko Sato | Team Leader | JICA | njs-sato.y@inbj.nifty.com |
| 106 | Kem Reth Viseth | Secretary of State | Council of Minister | 012 80 44 41 |
| 107 | Kéngchay Sixanonh | First Secretary | Embassy of Lao P.D. R. | laoembpp@camintel.com |
| 108 | Kenneth Meyer | | U.S. Embassy | |
| 109 | Ket Sophan | Cambodian Permanent Delegation to UNESCO | Council of Minister | |
| 110 | Khankham Kenbouttha | Director | SAGV | |
| 111 | Kheav Marady | Journalist | Council of Minister | 017 534 625 |
| 112 | Khoy Kim Tour | Conseller of the President | APSARA Authority | 012 77 73 99 |
| 113 | Khuon Khun Neay | Department Director | APSARA Authority | 012 94 00 05 |

| | | | | |
|---|---|---|---|---|
| 114 | Kim Seong-do | Deputy Director | Modern Cultural Heritage Division, Cultural Heritage Administration, Korea | |
| 115 | Kong Kanthy | Staff chief | I.Ge.S. | igescamb@hotmail.com |
| 116 | Laurent Delfour | Architect and Planner | SAGV | laurent.delfour@yahoo.fr |
| 117 | Lay Poty | Department of Water Management | APSARA Authority | potylay@yahoo.com |
| 118 | Lee Kyung-Soo | Ambassador | Embassy of Republic of Korea | ksd@korea.kr |
| 119 | Lim Bun Hok | ICC Secretariat | UNESCO Phnom Penh | bh.lim@unesco.org |
| 120 | Lim Kannitha | Archaeologist | EFEO | kannithalim@yahoo.com |
| 121 | Lim Ourk | Deputy Director of Department | APSARA Authority | 012 94 32 02 |
| 122 | Lionel Courty | Interpreter English-French | UNESCO | lionelcourty@hotmail.com |
| 123 | Long Kosal | Director of Department | NAPV | 092 89 99 66 |
| 124 | Louk Sok Leng | Department of Tourism Development | APSARA Authority | |
| 125 | M.M. Kanade | Superintending Archaeological Engineer | ASI | mmkanade2002@yahoo.com |
| 126 | Mam Morakat | Department of Urbanism Development of Siem Reap | APSARA Authority | |
| 127 | Mang Dara | Cambodian Delegation to UNESCO Paris | APSARA Authority | |
| 128 | Mao Loâ | Department Director | APSARA Authority | 017 88 86 67 |
| 129 | Margaret Adamson | Ambassador | Embassy of Australia | |
| 130 | Mariko Kano | Cultural Attache | Embassy of Japan | mariko.kano@mofa.go.jp |
| 131 | Masafumi Kuroki | Ambassador | Embassy of Japan | masafumiknroki@motagqp |
| 132 | Meas Bunleab | Department of Forest Management | APSARA Authority | |
| 133 | Meas Samnang | Department of Communication | APSARA Authority | 016 30 66 00 |
| 134 | Meng Vanny | Department of Administration | APSARA Authority | 012 44 50 88 |
| 135 | Meung Vuthy | Governor | Banteay Srey District | 085 567 567 |
| 136 | Mey Marady | Deputy Director General | APSARA Authority | meyapsara@camintel.com |
| 137 | Michael Spence | Vice Chancellor | Embassy of Australia | m.spence@vcc.usyd.eud.au |

| | | | | |
|---|---|---|---|---|
| 138 | Michel Verrot | Project Coordinator | FSP | michelsien@camnet.com.kh |
| 139 | Miec Sopheap | Journalist | Council of Minister | 016 44 6310 |
| 140 | Mihály Rózsa | Country Director | Royal Angkor Foundation | rozsamihaly@gmail.com |
| 141 | Mireille Grubert | | Ecole de Chailot | npakker@citechaillot.fr |
| 142 | Mok Kunthy | Department of Administration | APSARA Authority | 012 98 68 17 |
| 143 | Monh Sameth | Secretary of State | Council of Minister | |
| 144 | Mot Lyna | Department of Administration | APSARA Authority | 012 44 50 88 |
| 145 | Mounir Bouchenaki | Ad hoc Expert for conservation | UNESCO | mbo@iccrom.org |
| 146 | N.S.K Harsh | Pathologist | ASI | nirmalharsh57@gmail.com |
| 147 | Nao Hayashi | Desk Officer for Asia and the Pacific | UNESCO Paris | n.hayashi@unesco.org |
| 148 | Nathalie Lancret | Director | IPRAUS | nathalie.lancret@wanadoo.fr |
| 149 | Neav Hak Leang | Department of Agriculture and Community Development | APSARA Authority | 012 39 31 35 |
| 150 | Negth Chhayly | Deputy Director of Department | APSARA Authority | 017 59 61 68 |
| 151 | Ngan Dany | Department Director | APSARA Authority | 012 30 30 30 |
| 152 | Ngeth Sothy | Deputy Director of Department | APSARA Authority | 015 99 72 27 |
| 153 | Nhem Bora | Interpreter English-Khmer | APSARA Authority | samrethsopha@hotmail.com |
| 154 | Nicolas Deviller | CEO | SCA | nicolas.deviller@cambodia-airports.aero |
| 155 | Nin Chansamean | Department Director | APSARA Authority | 012 98 55 56 |
| 156 | Nobuo Endo | Research fellow | Sophia University | n-endo@sophia.ac.jp |
| 157 | Nuon Mony | Department of Forest Management | APSARA Authority | |
| 158 | Nut Narang | Representative | Ministry of Land Management and Contruction | |
| 159 | Olivier Binst | Expert for Angkor illumination | | |

| | | | | |
|---|---|---|---|---|
| 160 | Olivier Cunin | Co-operator | Gopura Team | cunin@crai.archi.fr |
| 161 | Olivier Gilard | Programme Officer | AFD | |
| 162 | Oum Marady | | APSARA Authority | marady_oum@yahoo.com |
| 163 | Oum Sopha | Department of Forest Management | APSARA Authority | |
| 164 | Oum Weachiravuth | High Representative of H.M. the King | Royal Palace | weachiravuth@gmail.com |
| 165 | Pal Chan Dara | | Council of Minister | |
| 166 | Pao Sophal | Director of Department | NAPV | |
| 167 | Pascal Royere | Architect | EFEO | pascal.royere@efeo.net |
| 168 | Phai Sun Heng | Department of Finance | APSARA Authority | 017 44 55 81 |
| 169 | Phay Siphan | Secretary of State | Council of Ministers | |
| 170 | Philip Hewitt | Representative | Embassy of New Zealand | Philip.Hewitt@nzaid.govt.nz |
| 171 | Philippe Delanghe | Culture Programme Specialist | UNESCO Phnom Penh | p.delanghe@unesco.org |
| 172 | Phoeurn Revant | Deputy Director General | NAPV | 097 66 67 99 |
| 173 | Phou Sâm At | Governor | Prasat Bakong District | |
| 174 | Phuong Sopheak | Department of Tourism Development | APSARA Authority | phuongsopheak@yahoo.com |
| 175 | Pich Sokha Lay | Governor | Pouk District | |
| 176 | Pierre Clément | President | AAA | p.clement@arte-charpentier.com |
| 177 | Pierre Lanapats | Sous-Directeur De L'Archéologie et Des Sciences Sociales | MAE-France | pierre.lanapats@diplomatie.gouv.fr |
| 178 | Pierre-André Lablaude | Ad hoc Expert for conservation | UNESCO | lablaude.administration@orange.fr |
| 179 | Po Map | Interpreter French-Khmer | APSARA Authority | pomapdef@yahoo.fr |
| 180 | Ponn Dary | Department of Cultural Development and Museum Conservation | APSARA Authority | |
| 181 | Prim Virak | Deputy Director of Department | APSARA Authority | 012 30 33 08 |
| 182 | Prom Chak | ICC Secretariat | UNESCO Phnom Penh | c.prom@unesco.org |

| | | | | |
|---|---|---|---|---|
| 183 | Prom Karona | Deputy Director of Department | APSARA Authority | 012 26 77 07 |
| 184 | Prom Sam Ean | Deputy Director of Department | APSARA Authority | 012 84 56 07 |
| 185 | Rajesh K. Sachdeva | Ambassadeur | Embassy of India | |
| 186 | Ramesh C. Chadha | Second Secretary | Embassy of India | |
| 187 | Ro Sovandaroath | Department of Cultural Development and Museum Conservation | APSARA Authority | roath_ro@yahoo.com |
| 188 | Robert Mccarty | Chief experts | JASA | rmccarthy@yahoo.com |
| 189 | Roland Fletcher | Professor | University of Sydney | roland.fletcher@arts.usyd.edu.au |
| 190 | Romana Tedeschi | Project Manager | BSCP | bscp@online.com.kh |
| 191 | Ros Borath | President | Natiional Committee of World Heritage | apsara.dma@online.com.kh |
| 192 | Ros Dina | Photographer | Council of Minister | 089 885 757 |
| 193 | Ros Rotheany | Deputy Director of Department | APSARA Authority | 011 88 77 00 |
| 194 | Ros Savy | | Council of Ministers | 017 45 57 22 |
| 195 | Ros Savy | Photographer | Council of Minister | 017 453 722 |
| 196 | Rudi Veestraeten | Ambassador | Embassy of Belgium | rubi-veestracten@diplobel.fed.cb |
| 197 | S.S.Negi | Director of Forest Research Institute | ASI | negiiss@rcko.org |
| 198 | Sad Nady | Commissioner of Police | Siem Reap Province | 012 63 01 38 |
| 199 | Sahai Sacchidananh | | APSARA Authority | 085 78 44 53 |
| 200 | Saing Vattana | Department of Communication | APSARA Authority | 012 97 80 75 |
| 201 | Sâm Siyan | Chief of Unit | Tourism Police | |
| 202 | Samreth Socheat | | Council of Ministers | 012 44 46 26 |
| 203 | Samreth Socheat | Photographer | Council of Minister | 012 444 626 |
| 204 | San Chanthan | Department of Conservation Monument of Angkor | APSARA Authority | sorn_chanthorn@yahoo.com |
| 205 | San Setha | Department of Conservation Monument of Angkor | APSARA Authority | sithasam_hot@yahoo.com |

| | | | | |
|---|---|---|---|---|
| 206 | San Sophorn | | National Committee of World Heritage | 012 79 73 72 |
| 207 | Satoru Miwa | Project Manager | Sophia University | satoru@online.com.kh |
| 208 | Saum Sopharath | Department of Urbanism Development of Siem Reap | APSARA Authority | pharath_angkor@yahoo.com |
| 209 | Savitri Suwansathit | Advisor | Ministry of Culture of Thailand | |
| 210 | Say Samkhan | Secretary of State | Council of Minister | 016 812 830 |
| 211 | Seng Savong | | Council of Minister | |
| 212 | Seng Sometha | | Council of Minister | |
| 213 | Seng Sotheara | | APSARA Authority | |
| 214 | Seung Kong | Deputy Director General | APSARA Authority | 012 26 40 56 |
| 215 | Shinji Tsukawaki | Water Specialist | Kanazawa University | shinji@staff.kanazawa-u.ac.jp |
| 216 | Sim Than | Deputy Director of Department | APSARA Authority | |
| 217 | Simon Warrack | Stone Conservator | ICCROM | swarrack@gmail.com |
| 218 | Sisowath Chandevy | Directrice Ecole Patrimoine | FSP | chandevy@yahoo.com |
| 219 | So Chheng | Archaeologist | CSA | chheng.so@hotmail.com |
| 220 | Sok An | Deputy Prime Minister | Council of Ministers | |
| 221 | Sok Leakhena | Depty Governor | Siem Reap Provnce | |
| 222 | Sok Sangvar | | Council of Minister | |
| 223 | Sok Sokan | | Council of Minister | |
| 224 | Song Sopheakdei | Photographer | Council of Minister | 017 997 167 |
| 225 | Song Sopheakdey | | Council of Ministers | 017 99 71 67 |
| 226 | Sou Phirin | Governor | Siem Reap Provnince | souphirin@camnet.com.kh |
| 227 | Soun Sovann | | National Committee of World Heritage | 012 20 34 64 |
| 228 | Sum Map | | Council of Minister | 012 55 11 33 |

| | | | | |
|---|---|---|---|---|
| 229 | Suziki Takashi | Consultant | APSARA Authority | 012 95 16 95 |
| 230 | Svay Piseth | Deputy Director of Department | APSARA Authority | 012 97 62 57 |
| 231 | Sylvain Ulisse | Coordinateur de projet | FSP | sylvain.ulisse@free.fr |
| 232 | T. Lakshmipriya | Consultant | ASI | tlpriya@gmail.com |
| 233 | T.S. Maxwell | Professor | Univesity of Bonn | maxangkor@camnet.com.kh |
| 234 | Takeshi Nakagawa | Co-director | JASA | nakag@waseda.jp |
| 235 | Tan Boun Suy | Department Director | APSARA Authority | tanbounsuy@yahoo.com |
| 236 | Tan Sambon | Deputy Director General | APSARA Authority | 012 95 79 40 |
| 237 | Tan Sawathya | Deputy Director of Department | APSARA Authority | sawathya.tan@orange.fr |
| 238 | Tan Theany | Secretary General | Nat. Com. for UNESCO | camnac@hotmail.com |
| 239 | Tea Vann | Department of Conservation Monument of Angkor | APSARA Authority | 099 60 49 96 |
| 240 | Tekreth Somrach | Secretary of State | Council of Minister | |
| 241 | Tep Bun Chhay | Governor | Siem Reap District | 012 68 75 47 |
| 242 | Tep Tony | Deputy Director of Department | APSARA Authority | 012 63 04 18 |
| 243 | Tep Vannda | Representative | Ministry of Economic and Finance | tvnnda@yahoo.com |
| 244 | Tep Vattho | Department Director | APSARA Authority | 012 65 53 91 |
| 245 | Teruo Jinnai | UNESCO Representative in Cambodia | UNESCO Phnom Penh | t.jinnai@unesco.org |
| 246 | Test Sothy | Department of Tourism Development in Angkor | APSARA Authority | essothy@yahoo.com |
| 247 | Tetsuji Goto | Ad hoc Expert for development | UNESCO | bobgoto2006@yahoo.co.jp |
| 248 | Thai Piseth | | Council of Ministers | 017 84 49 80 |
| 249 | Tharapong Srisuchat | Director of Fine Arts Department | Ministry of Culture of Thailand | fadod5@yahoo.com |
| 250 | Thia Narak Piseth | Photographer | Council of Minister | 017 844 980 |

| | | | | |
|---|---|---|---|---|
| 251 | Thitiya Panmanee | Second Secretary | Royal Thai Embassy | |
| 252 | Thol Nachhovy | Department of Land and Housing Management | APSARA Authority | |
| 253 | Thong Khon | Minister | Ministry of Tourism | |
| 254 | Tieng Kanha Sothy | | APSARA Authority | |
| 255 | Tith Sopha | Deputy Director of Department | APSARA Authority | 092 97 57 57 |
| 256 | Tjaco van den Hout | Ambassador | Embassy of Netherlands | ban-cdp@minbuza.nl |
| 257 | Tous Sumneath | Department of Land and Housing Management | APSARA Authority | |
| 258 | Uhm Won-jae | First Secretary | Embassy of Republic of Korea | |
| 259 | Uk Someth | Deputy Director General | APSARA Authority | someth_uk@yahoo.com |
| 260 | Uk Topbottra | Deputy Director General | NAPV | 097 78 23 44 |
| 261 | Uth Sam Oeun | Director | Dpt. Urbanism | |
| 262 | Va Vuth | Department of Agriculture and Community Development | APSARA Authority | vavuth_agriculturecambodia @yahoo.com |
| 263 | Valter M. Santoro | Head of Project | I.Ge.S. | vm.santoro@igessnc.com |
| 264 | Weeraya Tepayayone | Culture Officer | Ministry of Culture of Thailand | jibbbb@hotmail.com |
| 265 | Wen Yuqing | Architect | CSA | yqwen@sina.com |
| 266 | Wolfgang Mőllers | Country Director | DED | ld@ded.org.kh |
| 267 | Yim Nolla | Senior Minister | Council of Ministers | |
| 268 | Yin Soeum | Interpreter English-Khmer | APSARA Authority | 12891301 |
| 269 | Yin Sovat | Deputy Director of Department | APSARA Authority | 016 95 57 77 |
| 270 | Yoko Futagami | Senior Researcher | NRICP Tokyo | futa@tobunken.go.jp |
| 271 | Yoshi Ando | Director | Ministry of Foreign Affairs | yoshio.ando@mofa.go.jp |
| 272 | You Chantha | | APSARA Authority | chanthayon@yahoo.com |
| 273 | Yuni Sato | Researcher | Nara Institute | |

# របាយការណ៍សកម្មភាពការងារ

# អាជ្ញាធរជាតិអប្សរា

## ឆ្នាំ ២០០៩

**របាយការណ៍សង្ខេប រៀបចំឡើងដោយលោកស្រី ចៅ ស៊ុន កិរិយា**
**យោងទៅតាមឯកសារដែលផ្ដល់ជូនដោយ**
**នាយកដ្ឋាននានារបស់អាជ្ញាធរជាតិអប្សរា**

# មាតិកា

សេចក្តីផ្តើម....................................................................................................4

I. នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ..........................................................6

II. នាយកដ្ឋានហិរញ្ញវត្ថុ និង គណនេយ្យ.............................................................9

III. នាយកដ្ឋានផ្សព្វផ្សាយ......................................................................................9

IV. នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ...............................................11

V. នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ.................13

VI. នាយកដ្ឋានអភិវឌ្ឍន៍កសិកម្មនិងសហគមន៍...................................................16

VII. នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន.......................20

VIII. នាយកដ្ឋានគ្រប់គ្រងទឹក................................................................................25

IX. នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបេតិកភណ្ឌ................................30

X. នាយកដ្ឋានអភិវឌ្ឍន៍ បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប............................41

XI. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ..............................................................44

XII. នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ.............................55

XIV. នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ..............................................66

# សេចក្តីផ្តើម

ចាប់តាំងពីអាជ្ញាធរជាតិអប្សរាបានរៀបចំរចនាសម្ពន្ធរបស់ឡើងវិញកាលពីឆ្នាំ២០០៨ និងការដាក់បញ្ចូលនាយកដ្ឋានទាំង១២អោយនៅក្នុងទីស្នាក់ការបណ្តោះអាសន្នតែមួយ ការងារសាងសង់ទីស្នាក់ការអចិន្ត្រៃយ៍របស់អាជ្ញាធរបានចាប់ផ្តើមនិងមានការរីកចម្រើនយ៉ាងខ្លាំង។ ការរើទៅកាន់ទីស្នាក់ការថ្មីនេះអាចនឹងប្រព្រឹត្តទៅនៅក្នុងអំឡុងឆ្នាំ២០១០។ ឆ្នាំ២០០៩ពោរពេញទៅដោយព្រឹត្តិការណ៍ ក៏ដូចជាការសម្រេចបាននូវសមិទ្ធផលនានាក្នុងវិស័យហេដ្ឋារចនាសម្ពន្ធ។ កិច្ចការលម្អិតនឹងមានបង្ហាញជូននៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់នាយកដ្ឋាននីមួយៗ ប៉ុន្តែខាងក្រោមនេះ គឺជាព្រឹត្តិការណ៍សំខាន់ៗមួយចំនួនមានដូចជា៖

## ១. ព្រឹត្តិការណ៍ទាក់ទងនឹងធនធានទឹក៖

ក. នៅចុងរដូវវស្សា ក្នុងអំឡុងខែវិច្ឆិកា ខ្យល់ព្យុះ កេតសាណា ដែលបានបំផ្លាញប្រទេសជិតខាងនៅជាប់សមុទ្រ ក៏បានធ្វើអោយខូចខាតតំបន់អង្គរដែរ ថ្វីត្បិតថាមិនច្រើនក៏ដោយ ប៉ុន្តែក៏ធ្វើអោយទឹកលិចរមណីយដ្ឋានដែរ។ ការចុះអន្តរាគមន៍ទាន់ពេលវេលាពីសំណាក់នាយកដ្ឋានគ្រប់គ្រងទឹក បានទប់ទឹកមិនអោយលិចភូមិដែលនៅទាបៗ។ ព័ត៌មានលំអិតទាក់ទងនឹងដំណើរការនៃ ការចាត់វិធានការបន្ទាន់ ព្រមទាំងការលើកទំនប់និងការបញ្ចៀសទឹកភ្លៀង នឹងមានបញ្ជាក់ជូននៅក្នុងរបាយការណ៍របស់នាយកដ្ឋានគ្រប់គ្រងទឹក។

ខ. សិក្ខាសាលាស្តីអំពីទឹកលើកទីបួនត្រូវបានរៀបចំឡើងដោយអង្គការយូណេស្កូនិងអាជ្ញាធរជាតិអប្សរា ដើម្បីអោយដៃគូរពាក់ព័ន្ធ ពិភាក្សាលើពង្រាងសេចក្តីប្រកាសបង្កើតគណៈកម្មការផ្តល់យោបល់លើការងារគ្រប់គ្រងទឹកតំបន់សៀមរាប។

គ. ការជួសជុលបារាយខាងជើងឡើងវិញគឺជាជោគជ័យមួយ ព្រោះថា នេះជាលើកទីមួយហើយតាំងពី១៦សតវត្សកន្លងមក បារាយខាងជើងមានទឹកពេញ ប្រមាណជា ៧០០ ០០០ ម៉ែត្រគូប នៅឆ្នាំ២០០៨ ហើយបរិមាណទឹកឡើងរហូតដល់ ២,៩៨ លានម៉ែត្រគូបនៅឆ្នាំ២០០៩។ បារាយដ៏ធំនេះបានដើរតួនាទីយ៉ាងសំខាន់នៅពេលមានព្យុះកេតសាណា ដោយសារវាស្រូបយកទឹកភ្លៀងធ្វើមិនអោយលិចនិងខូចខាងជញ្ជាំងខាងជើងដ៏ទ្រុឌទ្រោមនៃក្រុងអង្គរធំ ហើយទន្ទឹមគ្នានោះដែរ ក៏បានជៀសវាងមិនអោយលិចភូមិដែលនៅជិតៗនោះក្នុងពេលមានព្យុះភ្លៀងខ្លាំង។

ឃ. ទំនប់បារាយទឹកថ្លាដែលខូចខាតត្រូវបានជួសជុលឡើងវិញ ហើយគម្រោងជួសជុលនៅតែធ្វើបន្តទៀតសំដៅទៅបង្កើតអោយមានទេសភាពវប្បធម៌ប្រវត្តិសាស្ត្រឡើងវិញ និងរៀបចំខ្សែទស្សនាដើម្បីអោយអ្នកទេសចរទស្សនានិងយល់ច្បាស់អំពីស្នាដៃដ៏មហិមាមួយនេះរបស់ក្សត្រខ្មែរនាសម័យអង្គរ។

**២. ការលើកតម្លៃបេតិកភ័ណ្ឌ៖** ការអភិវឌ្ឍឧទ្យានអង្គរត្រូវតែធ្វើឡើងដោយផ្អែកលើការលើកតម្លៃប្រាង្គប្រាសាទដោយធ្វើអោយទីជុំវិញមានភាពស្រស់បំព្រងឡើង។ ការធ្វើបែបនេះ វាទាក់ទងនឹង៖

### ក. ធ្វើអោយហេដ្ឋារចនាសម្ព័ន្ធទេសចរមានភាពប្រសើរឡើង

- ជួសជុលផ្លូវធំៗនៅក្នុងឧទ្យាន និងសាងសង់ផ្លូវបញ្ចៀសថ្មីដើម្បីសម្រួលចរាចរណ៍

- បង្គន់អនាម័យថ្មីៗត្រូវបានសាងសង់រួចនិងដាក់អោយប្រើប្រាស់៖ បង្គន់អនាម័យទីពីរត្រូវបានដាក់អោយប្រើប្រាស់បន្ថែមទៀត ដោយសារបង្គន់អនាម័យទីមួយមិនអាចឆ្លើយតបទៅនឹងតម្រូវការទេសចរដែលមានចំនួនកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះនៅប្រាសាទបន្ទាយស្រី។ បង្គន់អនាម័យផ្សេងទៀតក៏ត្រូវបានដាក់អោយប្រើប្រាស់នៅផ្លូវចូលខាងកើតប្រាសាទតាព្រហ្ម និងប្រាសាទបាគង។

### ខ. លើកតម្លៃតំបន់ជុំវិញប្រាង្គប្រាសាទ

- ការកសាងនិងដាក់អោយប្រើប្រាស់ជាបណ្តើរៗនៃរចនាសម្ព័ន្ធបដិសណ្ឋារកិច្ចមុខប្រាសាទបន្ទាយស្រីបានទទួលការស្វាគមន៍យ៉ាងវិជ្ជមានពីសាធារណជននិងក្រុមហ៊ុនទេសចរណ៍ ហើយពួកគេបានលើកទឹកចិត្តអោយអាជ្ញាធរជាតិអប្សរាកសាងរចនាសម្ព័ន្ធដូចគ្នានេះនៅមុខទីលានប្រាសាទធំៗផ្សេងទៀតក្នុងឧទ្យានអង្គរ។

- ក្រុមហ៊ុន Jet Tours បានផ្តល់ជំនួយហិរញ្ញប្បទានចំនួន ៧០០០០ ដុល្លាអាមេរិក ដើម្បីជួសជុលនិងលើកតម្លៃស្រះស្រង់។ នេះគឺជាគម្រោងដែលត្រូវការអន្តរាគមន៍ពីនាយកដ្ឋានច្រើន ហើយក្នុងនោះនាយកដ្ឋានគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរទទួលបន្ទុកដឹកនាំការអនុវត្តគម្រោង។

- ការធ្វើអោយឧទ្យានអង្គរមានភាពស្រស់បំព្រង៖ ការធ្វើអោយសោភណភាពទូទៅរបស់ប្រាង្គប្រាសាទនិងទេសភាពជុំវិញមានភាពប្រសើរឡើង តាមរយៈការជំនួសរូបចម្លាក់ចាស់ៗដោយរូបចម្លាក់ចម្លងអោយដូចរូបដើម (នៅបន្ទាយស្រី ច្រកទ្វារខាងត្បូងអង្គរធំ និងបង្កាន់ដៃរូបនាគនៅអង្គរវត្ត)។

### គ. អភិវឌ្ឍន៍វប្បធម៌ដើម្បីអោយជម្រើសនៃការទស្សនាមានភាពសំបូរបែប

ក្រៅពីការកែលម្អហេដ្ឋារចនាសម្ព័ន្ធបដិសណ្ឋារកិច្ច យើងចាំបាច់ត្រូវត្រៀមរៀបចំទទួលការវិលត្រឡប់មកវិញរបស់ទេសចរបន្ទាប់ពីមានវិបត្តិហិរញ្ញវត្ថុពិភពលោក ដោយផ្តល់អោយពួកគេនូវការកំសាន្តផ្សេងៗទៀត។ ក្នុងគោលគំនិតនេះ អាជ្ញាធរជាតិអប្សរាបានផ្តួចផ្តើមបង្កើតគម្រោងដូចខាងក្រោម៖

- សារមន្ទីរ៖ បន្ទាប់ពីសារមន្ទីរ ព្រះនរោត្តម សីហនុ អង្គរ ដែលត្រូវបានសាងសង់រួចជាស្ថាពរដើម្បីដាក់តាំងរូបចម្លាក់ដែលគេរកឃើញក្នុងពេលធ្វើកំណាយ ឬរូបចម្លាក់ដែលគេប្រទះឃើញដោយចៃដន្យ ក៏ដូចជាទុករូបចម្លាក់ទាំងនោះអោយមានសុវត្ថិភាពទម្រាំដល់ពេលមានឃ្លាំងស្តុកត្រឹមត្រូវ សារមន្ទីរមួយទៀតត្រូវបានសម្ពោធនិងដាក់អោយប្រើប្រាស់ក្នុងពេលឆាប់ៗនេះ នោះគឺសារមន្ទីរនៅក្នុងរមនីយដ្ឋាន តានី ដែលយើងអោយឈ្មោះថា សារមន្ទីរកុលាលភាជន៍អង្គរ ដែលនៅក្នុងនោះ មានដាក់តាំងរបស់របរកុលាលភាជន៍រកឃើញកាលពីឆ្នាំ១៩៩៧ដោយក្រុមអ្នកស្រាវជ្រាវអាជ្ញាធរជាតិអប្សរា និងវិទ្យាស្ថាន ណារ៉ា របស់ប្រទេសជប៉ុន។

- ការដាក់ភ្លើងលំអរឧទ្យានអង្គរ៖ ក្រោមការស្នើសុំរបស់រាជរដ្ឋាភិបាល ការសិក្សាមួយស្តីពីការដាក់ភ្លើងលំអរឧទ្យានអង្គរអោយត្រូវនឹងបទដ្ឋានបេតិកភណ្ឌពិភពលោកនិងអង្គការយូណេស្កូ កំពុងត្រូវបានធ្វើឡើង។ ប៉េសកកម្មនេះត្រូវបានប្រគល់ជូនអ្នកជំនាញដែលធ្លាប់រៀបចំបំភ្លឺរមណីដ្ឋានវប្បធម៌ធំៗនានានៅក្នុងពិភពលោក។ គម្រោងដាក់

ភ្លើងលំអរឧទ្យានលើកទីមួយត្រូវបានបង្ហាញជូន សេ អ៊ី សេ ក្នុងសម័យប្រជុំពេញអង្គកាលពីថ្ងៃទី១៥ ធ្នូ ២០០៩។ គម្រោងនេះទទួលបានការយល់ព្រមពីអ្នកជំនាញនិងអាជ្ញាធររដ្ឋាភិបាលហើយ។ យើងបានគិតគូរពីជំហ៊ានបន្តទៀតរបស់គម្រោង។

- សួនគ្រឿងទេសៈ គោលបំណងនៃការបង្កើតសួនគ្រឿងទេសគឺយើងចង់ផ្តល់ជូនអ្នកទេសចរនូវការទស្សនាកំសាន្តមួយទៀតក្រៅពីការទស្សនាប្រាង្គប្រាសាទ ជាពិសេសសម្រាប់អ្នកទេសចរដែលចូលចិត្តធម្មជាតិ និងចង់ស្វែងយល់អំពីការធ្វើម្ហូបនៅក្នុងប្រទេសតំបន់ត្រូពិក ដូចជានៅកម្ពុជាដែលគេច្រើនប្រើគ្រឿងទេសច្រើនបែបយ៉ាង។

**៣. ការអភិវឌ្ឍសង្គមៈ** ដោយសារក្នុងឧទ្យានអង្គរមានប្រជាជនរស់នៅ ភូមិដែលនៅក្នុងតំបន់ការពារត្រូវតែគោរពតាមបទបញ្ញាដែលកំណត់ដោយក្រឹត្យ នស ០០១ ស្តីពីការបែងចែកតំបន់ការពារ ដែលនៅក្នុងនោះ ហាមមិនអោយកសាងសំណង់ថ្មី ឬហាមមិនអោយប្រកបរបរអាជីវកម្មមួយចំនួន។ អាជ្ញាធរជាតិអប្សរាក៏បានបង្កើតគម្រោងអភិវឌ្ឍន៍មួយចំនួនដើម្បីជួយប្រជាជនដែលរស់នៅក្នុងភូមិទាំងនេះអោយមានលទ្ធភាពបន្តរស់នៅក្នុងភូមិរបស់ខ្លួនបាន។

**ក. ភូមិធម្មជាតិ រុន តាឯក**

ភូមិរុនតាឯកនៅក្រៅតំបន់ការពារនៃឧទ្យានអង្គរ។ អាជ្ញាធរបានត្រៀមដី ១០០០ហិកតា ដើម្បីទទួលប្រជាជនដែលមានសមាជិកគ្រួសារកាន់តែច្រើនឡើងអោយទៅរស់នៅ។ យើងបានគ្រោងបង្កើតគម្រោងទេសចរណ៍ធម្មជាតិនៅតំបន់នេះ ដើម្បីជួយអោយប្រជាជនដែលមតតាំងលំនៅដ្ឋានថ្មីអាចរកចំណូលបាន និងដើម្បីភ្ជាប់ភូមិរបស់ពួកគេទៅនឹងតំបន់មានឡបុរាណ ពោលគឺតានី ដែលនៅទីនោះ យើងទើបបានបង្កើតសារមន្ទីរកុលាលភាជន៍មួយ។

**ខ. ការអនុវត្តគម្រោងទ្វេរភាគីជាមួយប្រទេស នូវែល ហ្សេឡង់**

តំណាក់កាលទីមួយនៃគម្រោងបានធ្វើចប់រួចរាល់ហើយ។ នាយកដ្ឋានពាក់ព័ន្ធជាច្រើនបានចាត់តាំងបុគ្គលិករបស់ខ្លួនអោយទទួលបន្ទុកអនុវត្តផ្នែកផ្សេងៗនៃគម្រោងៈ ផ្តល់ព័ត៌មានស្តីអំពីតួនាទីរបស់អាជ្ញាធរជាតិអប្សរា និងធ្វើការងារសម្របសម្រួលដោយបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលផ្នែកនេះ ដើម្បីបង្កើតទំនាក់ទំនងជាមួយអ្នកភូមិ។ យើងក៏មានគម្រោងបង្កើតកម្មវិធីបណ្តុះបណ្តាលអ្នកស្រុកអោយចេះទទួលភ្ញៀវទេសចរ ដែលមកទស្សនាសកម្មភាពដែលជាទំនៀមទំលាប់ប្រពៃណី និងការងារសិប្បកម្ម របស់អ្នកស្រុក។

ប្រកាសមួយត្រូវបានពង្រៀងនិងទទួលបានការយល់ព្រមពីនាយកដ្ឋានទាំងអស់។ ពង្រៀងប្រកាសនោះបានដាក់ជូនឧបនាយករដ្ឋមន្ត្រី ឯកឧត្តម សុខ អាន ចុះហត្ថលេខា។ ដោយរង់ចាំការអនុវត្តជាផ្លូវការ នាយកដ្ឋានទាំងអស់បានចាប់ផ្តើមប្រតិបត្តិការទៅតាមមុខងារដែលមានចែងនៅក្នុងប្រកាសនេះរួចហើយ។

# I. នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ

ទន្ទឹមនឹងមុខងារជំនួយផ្នែករដ្ឋបាលដល់នាយកដ្ឋានបច្ចេកទេសនានា នាយកដ្ឋាន រ .ប.ស ក៏ត្រូវគ្រប់គ្រងសកម្មភាព

ដែលជួយក្នុងដំណើរការអាជ្ញាធរជាតិអប្សរា ដូចជា មជ្ឈមណ្ឌលសេវាកម្ម និង ក្រុមគ្រប់គ្រងអគ្គិសនីនៅក្នុងតំបន់អង្គរ។

នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ មានការិយាល័យចំនួន៦ដូចខាងក្រោមៈ

១. ការិយាល័យរបៀប និងសរុប
២. ការិយាល័យពិធីការ និងមគ្គុទ្ទេសក៍
៣. ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល
៤. ការិយាល័យផែនការនិងសម្ភារៈ
៥. មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា ម.ស.អ
៦. អង្គភាពគ្រប់គ្រងអគ្គិសនី

កិច្ចការដែលស្ថិតនៅក្រោមបន្ទុករបស់ នាយកដ្ឋាន រ.ប.ស តម្រូវអោយនាយកដ្ឋាននេះជ្រើសបុគ្គលិកបន្ថែម បែងចែកការងារផ្សេងៗដល់បុគ្គលិក ហើយទទួលបានលទ្ធផលដូចខាងក្រោមៈ

## ១. ការិយាល័យរបៀប និងសរុប

ការិយាល័យនេះទទួលបន្ទុកខាងទទួល ឯកសារ លិខិតនានាទាំងក្នុងនិងក្រៅអាជ្ញាធរជាតិអប្សរា ព្រមទាំងឆ្លើយតបទៅនឹងលិខិតដែលពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន។ នៅឆ្នាំ២០០៩ ការិយាល័យបានឆ្លើយតបទៅលិខិតមកពីក្រៅចំនួន ១៤៨៦ច្បាប់ និងទទួលឯកសារខាងក្នុងនាយកដ្ឋានចំនួន ៥ ៩៩៤ច្បាប់ ព្រមទាំងបានរៀបចំលិខិតទៅស្ថាប័នផ្សេងៗ សរុបចំនួន ៥៦០ច្បាប់។ ម្យ៉ាងទៀត នាយកដ្ឋានទទួលបន្ទុករៀបចំកិច្ចប្រជុំការងារអាជ្ញាធរអប្សរា ទាំងនៅខាងក្នុងអប្សរា ទាំងជាមួយអាជ្ញាធរដែនដី ឬជាមួយដៃគូគម្រោងពិសេសផ្សេងៗ សរុបចំនួន ៤៥៩ លើក។

## ២. ការិយាល័យពិធីការ និងមគុទ្ទេសក៍

ការិយាល័យរៀបចំទទួលគណៈប្រតិភូជាតិនិងអន្តរជាតិ ដោយរៀបចំពិធីការសមស្របដើម្បីទទួលគណៈប្រតិភូដែលមកទស្សនារមណីយដ្ឋានអង្គរ។ ការិយាល័យត្រូវទទួលខាងផ្តល់មគ្គុទេសក៍ ដោយប្រើធនធានក្នុងអប្សរា ឬជួលសេវាមគ្គុទេសន៍ជំនាញពីខាងក្រៅ។ នៅឆ្នាំ២០០៩ ការិយាល័យបានរៀបចំទទួលគណៈប្រតិភូជាតិនិងអន្តរជាតិសរុបចំនួន ៦០លើក។ ការិយាល័យក៏ត្រូវរៀបចំពិធីបើកបិទការដ្ឋាន និងពិធីសម្ពោធសមិទ្ធផលនានា សហការជាមួយប្រទេស ឬស្ថាប័នរដ្ឋពាក់ព័ន្ធ។ ឆ្នាំ២០០៩ ការិយាល័យបានរៀបចំពិធីសរុប ១៥លើក។

## ៣. ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាល

ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ការិយាល័យបានរៀបចំជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យារយៈពេលខ្លី សរុបចំនួន២០៧នាក់ និងរៀបចំឯកសារសម្រាប់បុគ្គលិកឈប់ សរុបចំនួន ៧៦នាក់។ ការិយាល័យបានរៀបចំលិខិតបង្គាប់ការមន្ត្រីបុគ្គលិក អោយចូលរួមក្នុងកម្មវិធីសិក្ខាសាលា ដើម្បីស្វែងរកបទពិសោធន៍ ចំណេះដឹង និងផ្លាស់ប្តូរវប្បធម៌គ្នា សរុបចំនួន៥៥៩ច្បាប់។ ចំពោះបុគ្គលិកដែលបានចូលបំរើការរយៈពេលមួយឆ្នាំមកហើយ ការិយាល័យបានពិនិត្យអតីតភាពការងារមន្ត្រីបុគ្គលិក ដើម្បីវាយតម្លៃ និងផ្តល់ការលើកទឹកចិត្ត ដូចជាការតម្លើងថានៈនៅក្នុងនាយកដ្ឋានរបស់

ខ្លួនឬនៅក្នុងផ្នែកផ្សេងទៀតរបស់អាជ្ញាធរជាតិអប្សរា។ ម្យ៉ាងទៀត ការិយាល័យបានសហការរៀបចំវគ្គបណ្តុះបណ្តាលបុគ្គលិកថ្មីពីសារៈសំខាន់នៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ។ ការិយាល័យបានចូលរួមយ៉ាងសកម្ម និងបញ្ចប់ការរៀបចំសេចក្តីប្រកាសនៃការប្រព្រឹត្តទៅរបស់នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានអាជ្ញាធរជាតិអប្សរា ដើម្បីបង្កើនប្រសិទ្ធភាពការងារ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។

## ៤. ការិយាល័យផែនការនិងសម្ភារៈ

ការិយាល័យបានរៀបចំគម្រោងដ៏សំខាន់មួយ ពោលគឺគម្រោងបោះបង្គោលព្រំសីម៉ាកំណត់តំបន់ការពារឧទ្យានអង្គរដែលគម្រោងនេះមិនដែលបានអនុវត្តទាល់តែសោះតាំងពីចេញព្រះរាជក្រឹត្យ លេខ នស ០០១ ឆ្នាំ១៩៩៤ មក។ បន្ទាប់ពីទទួលសំណើពីនាយកដ្ឋាននិងអង្គភាពនានា ពាក់ព័ន្ធនឹងសម្ភារៈចាំបាច់សម្រាប់ការងាររបស់ពួកគេ ការិយាល័យត្រូវពិនិត្យ មុននឹងត្រៀមលិខិតអនុញ្ញាតអោយទិញ និងដាក់ជូនអគ្គនាយពិនិត្យសម្រេច។ សំណើខ្លះត្រូវស្នើយោបល់ពីប្រធានអាជ្ញាធរអប្សរាផ្ទាល់។ នៅឆ្នាំ២០០៩ ការិយាល័យបានទទួលនិងពិនិត្យសំណើជួសជុលគ្រឿងយន្ត សរុបចំនួន ២៤២ច្បាប់ សំណើសុំទូទាត់ថវិកា សរុបចំនួន ១ ៥១១ ច្បាប់ សំណើសុំទិញសម្ភារៈការិយាល័យ សរុបចំនួន ៨៦ច្បាប់ សំណើសុំឧបត្ថម្ភប្រេងសាំងចំនួន ២ ១២៦ ច្បាប់។

## ៥. មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា ម..ស.អ

មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរាត្រូវបានបង្កើត និងដាក់ឲ្យដំណើរការចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ ដែលមានគោលបំណងផ្តល់សេវាសារធារណៈជូនប្រជាពលរដ្ឋ ភ្ញៀវជាតិអន្តរជាតិ គណៈប្រតិភូផ្លូវការរដ្ឋដែលបានស្នើសុំសេវាផ្សេងៗតាមយន្តការច្រកចេញចូលតែមួយ ប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាព។ ក្នុងនោះមជ្ឈមណ្ឌលបានរៀបចំប្រកាសស្តីពីការបង្កើតមជ្ឈមណ្ឌល បទបញ្ជាផ្ទៃក្នុង បញ្ជីសម្រង់ប្រភេទសេវាកម្ម និងមានសេវាផ្នែកទ្រទ្រង់សម្រាប់ពិគ្រោះយោបល់ជូនដោយឥតបង់ថ្លៃ ដើម្បីជម្រុញឲ្យទទួលបានលទ្ធផលល្អស្របតាមអនុក្រឹត្យលេខ៥០ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា។ លទ្ធផលការងារទទួលបានចាប់ពីដើមថ្ងៃទី០១ ខែមករា ដល់ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ទទួលបានលទ្ធផលដូចតទៅ ៖

- បានផ្តល់យោបល់ជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិអន្តរជាតិលើការស្នើសុំសេវា និងការធ្វើអាជីវកម្មនានាក្នុងរមណីយដ្ឋាន ចំនួន ១៥៨០ ករណី
- បានទទួលពាក្យស្នើសុំសេវា សរុប ចំនួន ១៥៦០ ករណីមាន ៖
  - \+ ស្នើសុំសេវាសាងសង់ ចំនួន ៥៦១ ករណី
  - \+ ស្នើសុំសេវាទេសចរណ៍វប្បធម៌ ចំនួន ៧៩៦ ករណី
  - \+ ស្នើសុំសេវារដ្ឋបាលទូទៅ ចំនួន ២០៣ ករណី
- បានផ្តល់ចំលើយជូនអ្នកប្រើប្រាស់សេវាទាំងអស់ ចំនួន ១៦០៧ ករណីមាន ៖
  - \+ ផ្តល់ចំលើយលើសេវារដ្ឋបាលទូទៅ សរុប ចំនួន ២៤៨ ករណី (អនុញ្ញាតចំនួន២៣៩ និងមិនអនុញ្ញាត៩ករណី)
  - \+ បានទទួលពាក្យស្នើសុំសេវាទេសចរណ៍ វប្បធម៌ សរុប ចំនួន ៨៨០ ករណី

(អនុញ្ញាតចំនួន ៨៧២ ករណី និងមិនអនុញ្ញាតចំនួន ៨ករណី)

+ បានទទួលពាក្យស្នើសុំសាងសង់ សរុបចំនួន ៩៨១ ករណី

(អនុញ្ញាតចំនួន ១៥០ ករណី មិនអនុញ្ញាតចំនួន ២៨៦ករណី ចេញសេចក្តីជូនដំណឹង៤៥ករណី)

- ចំណូលសរុបរបស់មជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរអប្សរា សរុបចំនួន ១៦១ ០៧៥ ដុល្លារ ដោយចំណូលទាំងអស់នេះបានមកពីៈ

  + ការផ្តល់សេវាលើការស្នើសុំរៀបចំទទួលទានអាហារ និងសម្តែងសិល្បៈនៅរមណីយដ្ឋានអង្គរ ពីក្រុមហ៊ុននានា ចំនួន ៨៦ លើក

  + ការផ្តល់សេវាលើការសុំថតរូបភាពគ្រប់ប្រភេទនៅរមណីយដ្ឋានអង្គរ ចំនួន ៣៤ ករណី

  + ការផ្តល់សេវាលើការចេញប័ណ្ណសម្រាប់អ្នកស្រាវជ្រាវចំនួន ១១ករណី

### ៦. ក្រុមគ្រប់គ្រងអគ្គិសនី

អង្គភាពបានរៀបចំកិច្ចសន្យាជាមួយក្រុមហ៊ុនឯកជនដែលទទួលបន្ទុកខាងចែកចាយអគ្គិសនី។ ភារកិច្ចរបស់អាជ្ញាធរអប្សរាជាពិសេសគឺថែទាំនិងជួសជុលប្រព័ន្ធអគ្គិសនីនៅក្នុងឧទ្យានអង្គរ។ អង្គភាពបានៈ

- កៀបក្បាលសុងតំណរខ្សែភ្លើង ចំនួន ២៨៩ បង្គោល
- ចាក់ដីលុបខ្សែភ្លើងដែលផុសចេញបានចំនួន ១៣ កន្លែង
- ដូរអំពូលដែលខូចចេញ ចំនួន ១៩ អំពូល
- ជីកប្រឡាយរំដោះទឹកដើម្បីជួយសង្គ្រោះកាប៊ីន PTT 002 PTT 003
- តភ្ជាប់ខ្សែកាប LV បាន១២កន្លែង
- រៀបចំនិងជួសជុលប្រព័ន្ធបំភ្លឺភ្លើងនៅតំបន់រមណីយដ្ឋានអង្គរ និងរៀបចំបំភ្លឺភ្លើងនៅតាមផ្លូវ៦០ម៉ែត្រនៃដីបុរីទេសចរណ៍វប្បធម៌។

# II. នាយកដ្ឋានហិរញ្ញវត្ថុ និង គណនេយ្យ

សូមអានរបាយការណ៍ភ្ជាប់នៅក្នុងឧបសម្ពន្ធ ខាងចុងរបាយការណ៍នេះ។

# III. នាយកដ្ឋានផ្សព្វផ្សាយ

### III.1. រចនាសម្ព័ន្ធ និងក្របខ័ណ្ឌៈ

យោងតាមប្រកាស ដែលកំពុងស្ថិតនៅក្នុងរយៈពេលនៃការចុះហត្ថលេខាដោយប្រធានអាជ្ញាធរអប្សរា នាយកដ្ឋានផ្សព្វផ្សាយមាន ៤ការិយាល័យ។

**រចនាសម្ព័ន្ធៈ**

១. ការិយាល័យសម្របសម្រួល និងគាំទ្រសកម្មភាព

២. ការិយាល័យព្រឹត្តិបត្រ និងបោះពុម្ព
៣. ការិយាល័យឃោសនាចល័ត និងពិព័ណ៌ររូបភាព
៤. ការិយាល័យព័ត៌មាន

**ក្របខ័ណ្ឌ ៖**
មន្ត្រីរាជការ បុគ្គលិក នៃនាយកដ្ឋានផ្សព្វផ្សាយមានចំនួន ១៦នាក់ ក្នុងនោះមានបុគ្គលិករដ្ឋ និងមន្ត្រីជាប់កិច្ចសន្យា រួមមាន៖

- ប្រធាននាយកដ្ឋាន ០១រូប
- បុគ្គលិកផ្សព្វផ្សាយ ១៣រូប
- និងអ្នកបើកបរ ០២រូប។

### III.2 **លទ្ធផលការងារសំខាន់ៗប្រចាំឆ្នាំ ២០០៩ មាន ៖**
ការងារសំខាន់ៗរបស់នាយកដ្ឋានគឺការចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ការពារ ដើម្បីអោយពួកគេចូលរួមក្នុងកិច្ចការការពារបិតិកភណ្ឌ។ ជាករពិតណាស់ ប្រជាជនដែលរស់នៅក្នុងឧទ្យានកើតកូនកើតចៅ រួមនឹងប្រជាជនដែលមកពីខាងក្រៅ មកតាំងទីលំនៅថែមទៀត ធ្វើអោយប្រជាជនសរុបនៅក្នុងឧទ្យានមានចំនួនកាន់តែកើនឡើង។ ការងារផ្សព្វផ្សាយជួយពង្រឹងដល់កិច្ចការការពារទុកជាមុនចំពោះការបង្ក្រាបដែលធ្វើឡើងដោយ នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ។

១.ចុះផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋតាមមូលដ្ឋានដែលស្ថិតនៅតំបន់១ និងតំបន់២ បានចំនួន ៥៧ភូមិ ដែលមានប្រជាពលរដ្ឋចូលរួមស្តាប់ចំនួន ១០ ៨៣៨ នាក់ ក្រោមប្រធានបទ ៖
- ច្បាប់ការពារបេតិកភណ្ឌ
- ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារ
- ការជ្រើសរើសប្រជាពលរដ្ឋទើបរៀបការថ្មីៗ ឲ្យទៅរស់នៅភូមិធម្មជាតិរុនតាឯក

២. បោះពុម្ពព្រឹត្តិបត្រប្រចាំខែសម្រាប់ផ្សព្វផ្សាយទូទាំងប្រទេស បានចំនួន ៩៩ ៦០០ ក្បាល ក្នុងនោះមាន ៖
- ក្រសួង-ស្ថាប័ននានានៅរាជធានីភ្នំពេញចំនួន ២៦ ៤០០ ក្បាល
- អគ្គនាយកដ្ឋានអាជ្ញាធរអប្សរា និងមន្ទីរជុំវិញខេត្តសៀមរាបចំនួន ៣០ ៨៤០ ក្បាល
- ភូមិ-ឃុំក្នុងតំបន់១ និងតំបន់២ ចំនួន ២៩ ១៦០ ក្បាល
- ខេត្តចំនួន២២ផ្សេងទៀត ចំនួន ១៣ ២០០ ក្បាល

៣.- ផលិតកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ FM 100.5 MHz និងវិទ្យុបាយ័ន បានចំនួន ៧៧ កម្មវិធី ក្នុងន័យការងារអភិរក្ស និងអភិវឌ្ឍន៍ដោយចីរភាពតំបន់រមណីយដ្ឋានអង្គរ។

- ផលិតកម្មវិធីផ្សព្វផ្សាយតាមវិទ្យុទីស្តីការគណៈរដ្ឋមន្ត្រីប៉ុស្តិ៍ ១០១ បានចំនួន ៦៨ កម្មវិធី ក្នុងន័យការងារអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពតំបន់រមណីយដ្ឋានអង្គរ។

៤. បានផលិតប៉ាណូ និងដាក់តាមផ្លូវសាធារណៈស្តីពី សេចក្តីជូនដំណឹងផ្សេងៗរបស់អាជ្ញាធរអប្សរា ដែលពាក់ព័ន្ធការប្រើប្រាស់ដីធ្លីក្នុងតំបន់១ និងតំបន់២ និងការហាមរថយន្តផ្ទុកលើសចំនុះធ្វើចរាចរនៅលើកំណាត់ផ្លូវវាង មិត្តភាពកម្ពុជា-កូរ៉េ ចំនួន ២៧ ផ្ទាំង។

៥. ផ្សព្វផ្សាយអប់រំដល់យុវជនរាជធានី-ខេត្ត បានចំនួន ២វគ្គ ដែលមានអ្នកចូលរួមស្តាប់ ចំនួន ៤០០នាក់ ក្នុងឱកាសពួកគេធ្វើដំណើរទស្សនកិច្ចសិក្សានៅខេត្តសៀមរាប។

៦. រៀបចំពិព័រណ៍រូបថតនៅអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ស្តីពីសកម្មភាពរបស់អាជ្ញាធរអប្សរាប្រចាំខែនីមួយៗ ដើម្បីបង្ហាញដល់សាធារណជន បានចំនួន ១២ផ្ទាំង។

# IV. នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ

## IV.1- ស្ថានភាពទូទៅរបស់នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ៖

អនុក្រឹត្យ អនក/បក៥០ បានបង្កើតនាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ និងមានប្រកាសមួយដែលកំណត់រចនាសម្ព័ន្ធនិងដំណើការរបស់នាយកដ្ឋាននេះ។ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការចែកចេញជាបីការិយាល័យ និងមួយអង្គភាព គឺ ៖

- ការិយាល័យរបៀបនិងសរុប
- ការិយាល័យបុគ្គលិក និងសម្ភារៈ
- ការិយាល័យសហប្រតិបត្តិការនិងច្បាប់
- អង្គភាពប្រតិបត្តិការនិងអន្តរាគមន៍ ដោយបែងចែកកងកំលាំងចុះអន្តរាគមន៍ដល់គោលដៅចំនួន២៤ គោលដៅនៅទូទាំង ០៥ស្រុក/ក្រុង នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

## IV.2- ក្របខ័ណ្ឌ

មន្ត្រីរាជការ បុគ្គលិក និងកងកំលាំង នៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ មានចំនួនសរុបទាំងអស់ ចំនួន ១៣៦រូប ដោយចែកជា ៖

**២-១- មន្ត្រីថ្នាក់ដឹកនាំ**

អគ្គនាយករងទទួលបន្ទុកចំនួន០១រូប ប្រធាននាយកដ្ឋានស្តីទីចំនួន០១រូប អនុប្រធាននាយកដ្ឋានចំនួន០២រូប។

**២-២- មន្ត្រី និងបុគ្គលិក**

មន្ត្រី និងបុគ្គលិកសរុបទាំងអស់ចំនួន ០៨ រូប។

**២-៣- កងកំលាំងសហប្រតិបត្តិការ**

កងកំលាំងសហប្រតិបត្តិការរបស់នាយកដ្ឋានសរុបទាំងអស់មានចំនួន ១២៤ រូប។

**លទ្ធផលការងារចុះប្រតិបត្តិការរបស់កងកំលាំងនាយកដ្ឋាន**

ការងារចុះប្រតិបត្តិការទប់ស្កាត់សំណង់គ្មានច្បាប់ និងបទល្មើសផ្សេង ទូទាំង ០៥ ស្រុក/ក្រុង ប្រចាំឆ្នាំ២០០៩ គិតចាប់ពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៨ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ មានចំនួន ៩៧៩ ករណី ៖

- ចុះត្រួតពិនិត្យ និងបញ្ឈប់សកម្មភាពសាងសង់ និងករណីផ្សេងៗ ចំនួន ៤៩១ ករណី
- ចុះទប់ស្កាត់ការដ្ឋានបូមខ្សាច់ ចំនួន ២៣ កន្លែង
- ទប់ស្កាត់សកម្មភាពចាក់ដី ជីកដី និងដឹកដីលក់ ចំនួន ៥១ ករណី
- ទប់ស្កាត់សកម្មភាពវាតព្រៃយកដី ចំនួន ០៧ ករណី
- ចុះត្រួតពិនិត្យ និងអោយម្ចាស់រុះរើសំណង់ ចំនួន ២៣៣ ករណី
- ចុះរុះរើ និងដកហូតសម្ភារៈសំណង់ ចំនួន ១៩៨ ករណី
- ចុះត្រួតពិនិត្យ និងអោយម្ចាស់សំណង់ដឹកសម្ភារៈចេញ ចំនួន ២៦ ករណី
- សំណង់គ្មានច្បាប់អនុញ្ញាត កំពុងសាងសង់បន្តក្នុងឆមាសទី២ ឆ្នាំ២០០៩ និងរងចាំអនុសាសន៍ដើម្បីរុះរើរបស់ឯកឧត្តមអភិបាលខេត្ត ចំនួន ០២ ករណី
- សុំអន្តរាគមន៍ពីឯកឧត្តមអភិបាលខេត្តសៀមរាប ចំនួន ០៦ ករណី
- ដាក់ពាក្យបណ្តឹងសុំដីការក្សាការពារចូលតុលាការខេត្តសៀមរាប ចំនួន ០៨ ករណី
- ដាក់បណ្តឹងអង្គសេចក្តីចូលតុលាការខេត្ត ចំនួន ០១ ករណី
- ដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌចូលតុលាការខេត្ត ចំនួន ០៣ ករណី
- តុលាការចេញដីការក្សាការពារ ចំនួន ០៧ ករណី
- ទប់ស្កាត់រថយន្តធុនធំឆ្លងកាត់តំបន់រមណីយដ្ឋានអង្គរ និងរថយន្តផ្ទុកលើសទម្ងន់ ២០ តោន ឆ្លងកាត់ផ្លូវមិត្តភាពកម្ពុជា-កូរ៉េ ចំនួន ៤៤ ករណី

## IV.3- **ការវាយតម្លៃ និងសន្និដ្ឋាន**

### ៣-១- វាយកតម្លៃ និងសន្និដ្ឋាន

បទល្មើសសាងសង់សំណង់គ្មានច្បាប់អនុញ្ញាតនៅតែបន្តកើតឡើងនៅក្នុងតំបន់ការពារទី១ និងទី២។ ដោយមានការដឹកនាំបញ្ជាជាប្រចាំរបស់ថ្នាក់ដឹកនាំ កងកំលាំងបានចុះទប់ស្កាត់បទល្មើសដល់គោលដៅទាំងពេលថ្ងៃ និងពេលយប់ សហការជាមួយសមត្ថកិច្ច អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ចុះអប់រំណែនាំម្ចាស់សំណង់ ធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាពសាងសង់ រុះរើសំណង់ និងដកហូតសម្ភារៈសំណង់ដែលមិនគោរពតាមការណែនាំ ក៏ដូចជាកិច្ចសន្យាបញ្ឈប់ ទទួលបានលទ្ធផលគួរអោយកត់សំគាល់។

### ៣-២- លើកទិសដៅអនុវត្ត

- បន្តស្នើសុំអន្តរាគមន៍ទៅ ឯកឧត្តមអភិបាលខេត្ត ចំពោះសំណង់ខុសច្បាប់ដែលនៅតែជជែសបន្តការសាងសង់ និងរៀបចំពាក្យបណ្តឹងទៅសាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ។

- បន្តចុះប្រតិបត្តិការទប់ស្កាត់បទល្មើសទាំងពេលថ្ងៃ ទាំងពេលយប់ ដោយផ្អែកលើគោលការណ៍ ០៦ចំណុច

របស់អាជ្ញាធរអប្សរា និងអភិបាលខេត្តសៀមរាប ព្រមទាំងផែនការថ្មីៗថ្នាក់លើដាក់ជូន។

- ខិតខំបង្កើនកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ។

- គ្រប់គ្រងកងកំលាំង អោយមានវិន័យហ្មត់ចត់ និងខិតខំលើកកំពស់សមត្ថភាពតាមរយៈការរៀនសូត្របន្ថែម អំពីលិខិតបទដ្ឋាន ច្បាប់ សេចក្តីសម្រេច បទបញ្ជានានា ដែលពាក់ព័ន្ធដល់សកម្មភាពប្រតិបត្តិការ នៅក្នុងតំបន់រមណីយដ្ឋានអង្គរ។

- បន្តលើកវិធានការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើការទប់ស្កាត់ចំពោះបណ្តាសំណង់ខុសច្បាប់ ដែលនៅតែបន្តការសាងសង់។

- បន្តអនុវត្តន៍តាមព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច និងបទដ្ឋានច្បាប់នានា ជានាទប់ស្កាត់សំណង់គ្មានច្បាប់អនុញ្ញាត និងដោះស្រាយតាមនីតិវិធីច្បាប់ជាធរមាន ដើម្បីរួមចំណែកការពារ អភិរក្ស និងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានអង្គរប្រកបដោយចីរភាព។

# V. នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ

បន្ទាប់ពីការរៀបចំធនធានមនុស្សតាំងពីការបង្កើតនាយកដ្ឋាននេះនៅឆ្នាំ២០០៨រួចមក នាយកដ្ឋានបានបំពេញបេសកកម្មមួយចំនួនដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

ប្រតិបត្តិការសំខាន់ៗទាក់ទងនឹងការពិនិត្យសំណើសុំជួសជុលលំនៅដ្ឋាន។ ដោយហេតុថាសំណង់ថ្មីត្រូវហាមឃាត់ដាច់ខាតនៅក្នុងតំបន់ការពារ នាយកដ្ឋានបានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយនាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការដើម្បីបញ្ឈប់សំណង់ខុសច្បាប់។

ទន្ទឹមនឹងនោះ នាយកដ្ឋានក៏បានអនុវត្តគម្រោងពិសេសៗដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

សកម្មភាពការងារសំខាន់ៗដែលសំរេចបានមានដូចខាងក្រោម៖

### V.1 ការចុះពិនិត្យសំណង់

បុគ្គលិកជំនាញ បានចុះទៅពិនិត្យការស្នើសុំសាងសង់ និងពិនិត្យសំណង់សង់រួច របស់ប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងតំបន់ការពារទី១ និងទី២ និងរមណីយដ្ឋានផ្សេងទៀតនៃឧទ្យានអង្គរជាធម្មតា។

**ការទទួលពាក្យ និងការចេញច្បាប់សាងសង់**

ចាប់ពីថ្ងៃទី០១ ខែមករា រហូតដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ អាជ្ញាធរអប្សរាបានទទួលពាក្យសុំសាងសង់ និងលទ្ធផលចេញច្បាប់សម្រេចបានដែលមានក្នុងតារាងខាងក្រោមនេះ៖

| កាលបរិច្ឆេទ | ចំនួនពាក្យទទួល | ចំនួនលិខិតចេញ | | |
|---|---|---|---|---|
| | | អនុញ្ញាត | មិនអនុញ្ញាត | សរុប |
| មករា | ២៨ | ១២ | ១៦ | **២៨** |
| កុម្ភៈ | ៤០ | ១៤ | ២៦ | **៤០** |
| មីនា | ៤៩ | ២៦ | ២៣ | **៤៩** |
| មេសា | ៣៩ | ១០ | ២៩ | **៣៩** |
| ឧសភា | ៣៣ | ៩ | ២២ | **៣១** |
| មិថុនា | ៣៥ | ១១ | ២៣ | **៣៤** |
| កក្កដា | ៥៨ | ២១ | ៣៥ | **៥៦** |
| សីហា | ៦៨ | ១៥ | ៤២ | **៥៧** |
| កញ្ញា | ៥២ | ១៥ | ២៣ | **៣៨** |
| តុលា | ៨៧ | ១៤ | ១៧ | **៣១** |
| វិច្ឆិកា | ៧១ | ០ | ៦ | **៦** |
| ធ្នូ | ៣៤ | ០ | ០ | **០** |
| សរុប | **៥៩៤** | **១៤៧** | **២៦២** | **៤០៩** |

## V.2 **គម្រោងសំខាន់ៗដែលត្រូវធ្វើបន្ត**

**១- គម្រោងបារាយណ៍ខាងលិច និងខាងជើង៖** បានចាត់បញ្ជូនលោកទស្ស សុមនាថ, លោក ខៀវ ច័ន្ទ និងកញ្ញា មាស កល្យាណ ឲ្យចូលរួមធ្វើការងារក្នុងគម្រោងនេះជាមួយនាយកដ្ឋានគ្រប់គ្រងទឹក។

**២- គម្រោងរុនតាឯក ៖** ការសាងសង់អគារប្រចាំការចំនួន២ខ្នង កំពុងត្រៀមសាងសង់បន្ត និងបានរៀបចំបញ្ជីឈ្មោះប្រជាពលរដ្ឋ ៥០គ្រួសារ ដែលត្រូវជ្រើសរើសជាលើកដំបូង ឲ្យទៅរស់នៅភូមិរុនតាឯក។ បានបោះពុម្ពកូនសៀវភៅស្តីពីភូមិធម្មជាតិរុនតាឯក ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ដើម្បីផ្សព្វផ្សាយឲ្យមនុស្សទូទៅបានដឹងអំពីគោលដៅ និងគោលគំនិតក្នុងការអភិវឌ្ឍន៍តំបន់ភូមិធម្មជាតិរុនតាឯក។ បានដាក់ស្លាកសញ្ញាប្រាប់ទិសបង្ហាញទីតាំងគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯករួចហើយ។ ការសាងសង់ផ្ទះគម្រូ បានចាប់ផ្តើមនៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០០៩ និងដំណើរការបញ្ចប់រួចរាល់នៅក្នុងខែធ្នូ ឆ្នាំ២០០៩នេះ។ បានគូសប្លង់កំណត់ ដីឡូតិ៍ ជូនប្រជាពលរដ្ឋក្នុងទំហំ១៥ x ២៥ម៉ែត្រ ចំនួន២០៦ឡូតិ៍រួចហើយ។

**៣- គម្រោង Parvis បន្ទាយស្រី៖** មានការតំរូវឲ្យរៀបចំទីតាំងសម្រាប់ទស្សនាទេសភាពនៅមាត់ត្រពាំង និងរៀបចំសាងសង់តូបលក់ដូរ ព្រមទាំងតម្រូវធ្វើបន្តជាមួយស្លាកសញ្ញាខ្លះទៀត។ ការសាងសង់ខៀនសំរាប់តូបអ្នកលក់ដូរបានចប់សព្វគ្រប់ហើយ។ ការសង់រានទស្សនាធម្មជាតិ ចំនួន៥កន្លែង ក្រាលការ៉ូឡាតាមផ្លូវដើរជុំវិញ ព្រមទាំងដាំស្មៅ និងផ្កា សង់កន្លែងអង្គុយលំហែកាយនៅ (Parvis) ចំនួន២កន្លែង និងរោងដាក់សំរាមមួយកន្លែង បានលើកគម្រោងប៉ាន់តំលៃ ហើយបានដាក់សុំគោលការណ៍ទៅជូនអគ្គនាយកហើយ។

**៤- គម្រោងជួសជុលព្រះវិហារនៅវត្តប្រាសាទបាគង៖** អនុសារណៈលើកិច្ចព្រមព្រាងរវាងអាជ្ញាធរអប្សរា និងក្រុមហ៊ុន Holcim បានចុះហត្ថលេខារួចហើយក្នុងជំហានទី២។ លោក ឈឹម ផេត ជាអ្នកសម្របសម្រួលកិច្ចការបច្ចេកទេសរៀបចំឯកសារសំរាប់ដេញថ្លៃគម្រោងនេះចប់សព្វគ្រប់ហើយ។ ការដ្ឋានជួសជុលបានចាប់ដំណើរការពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ តទៅ ហើយបានចាត់លោក លឹម អួក លោក ខៀវ ច័ន្ទ លោក ហេង សុខា និងលោក ស៊ឹម ប៊ុនធឿន ជាអ្នកចុះពិនិត្យ និងតាមដាននូវគម្រោងនេះ។

**៥- គម្រោងសាងសង់ផ្ទះគម្រូ ៖** រោងជីកំប៉ុស្តត្រូវបានសាងសង់រួចរាល់ហើយ។ ការជីកស្រះចិញ្ចឹមត្រីក៏រួចស្រាច់បាច់ដែរ។ រៀបចំដាំផ្កា និងដំណាំបណ្ដើរៗដោយសហការជាមួយនាយកដ្ឋានគ្រប់គ្រងទឹក។ រីឯប្លង់ផ្ទះក៏បានធ្វើរួចស្រេច ហើយបញ្ជូនទៅអគ្គនាយកសុំគោលការណ៍អនុញ្ញាត។

**៦- គម្រោង Heritage Framework ៖** បានធ្វើកិច្ចសន្យាព្រមព្រៀងរួចហើយ រង់ចាំតែថ្ងៃចាប់ផ្ដើមដំណើរការ។

**៧- គម្រោងស្រះស្រង់៖** បានធ្វើរបាយការណ៍ផ្ញើទៅ UNESCO នៅក្រុងប៉ារីសរួចហើយ និងរៀបចំគម្រោង Parvis ជាបន្តបន្ទាប់។ បានបង្កើតក្រុមបច្ចេកទេសសំរាប់គម្រោងរៀបចំទស្សនកិច្ចនៅតំបន់ស្រះស្រង់។ កិច្ចសន្យាផ្តល់ប្រាក់បានធ្វើជាមួយ UNESCO រួចហើយ។ UNESCO ក៏បានប្រគល់ប្រាក់មកឲ្យអាជ្ញាធរអប្សរារួចហើយដែរ។ ការធ្វើកំណាយថ្មលំបុរាណខាងកើតប្រាសាទបាតជុំ បានចាប់ផ្ដើមពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩។ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានរៀបចំដំណើរការធ្វើកំណាយនៅចន្លោះស្រះស្រង់ និងបន្ទាយក្តី។ នាយកដ្ឋានគ្រប់គ្រងទឹក និងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌកំពុងរៀបចំឯកសារបច្ចេកទេសសំរាប់ដេញថ្លៃ។

**៨- គម្រោងអភិវឌ្ឍន៍ផ្តល់ដោយ New Zealand ៖** គម្រោងគម្រូនេះមានចំនួន៤ ដែលគម្រោង៣ពាក់ព័ន្ធនឹងនាយកដ្ឋានយើងខ្ញុំ និង១ទៀតទាក់ទងនឹងនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ។ បច្ចុប្បន្នយើងកំពុងបើកវគ្គបណ្តុះបណ្តាលពង្រឹង សមត្ថភាពបុគ្គលិកផ្នែកអភិវឌ្ឍន៍ជនបទ និងរៀបចំដីធ្លី។ បានចាត់បុគ្គលិកជាច្រើនរួបរួមទាំងបុគ្គលិកនាយកដ្ឋានផ្សេងដែលពាក់ព័ន្ធនឹងគម្រោងនេះ ឲ្យចុះធ្វើកម្មសិក្សាយកបទពិសោធន៍ពីសហគមគំរូនៅខេត្តបាត់ដំបង និងខេត្តកំពង់ឆ្នាំង ជាមួយក្រុមញូសេឡែន (NZAid)។ កិច្ចការនេះកំពុងអនុវត្តក្នុងភូមិស្រះស្រង់ខាងជើង និងភូមិរហាល។

**៩- គម្រោងសិក្សាផ្លូវបុរាណ៖** គម្រោងនេះ សហការជាមួយសកលវិទ្យាល័យសិល្បករបស់ប្រទេសថៃ ផ្លូវទៅអង្គរ-ភីម៉ៃ បានចប់ហើយ។ លោក អ៊ឹម សុខរិទ្ធី ត្រូវបានឲ្យទៅចូលរួម និងសហការជាមួយសកលវិទ្យាល័យនីហុង

ប្រទេសជប៉ុន ដើម្បីធ្វើការស្រាវជ្រាវផ្លូវបុរាណទៅប្រទេសឡាវក្នុងតំបន់ Wat Phu ចាប់ពីថ្ងៃទី២៣ ដល់២៧ ខែតុលា ឆ្នាំ២០០៩។

**១០- គម្រោងសាងសង់សារមន្ទីរកុលាលភាជន៍តានី៖** ការងារសាងសង់អគារបានសម្រេច១០០ភាគរយហើយ។ ទូកញ្ចក់សម្រាប់តាំងកុលាលភាជន៍បានធ្វើរួចហើយ និងបានទិញតុ ទូរការិយាល័យដាក់រួចរាល់ហើយដែរ។ គម្រោងសាងសង់ក្លោងទ្វារចូលសារមន្ទីរ ព្រមទាំងរៀបចំសួន បានដាក់ជូនអគ្គនាយករួចហើយដើម្បីសុំគោលការណ៍អនុញ្ញាត។

**១១- គម្រោងចុះស្រង់ស្ថិតិ និងទិន្នន័យក្បាលដី៖** បានចាត់មន្ត្រីបុគ្គលិកមួយចំនួន ចុះវាស់វែងទំហំក្បាលដី ស្រង់ទិន្នន័យក្បាលដី និងអង្កេតអគារនៅភូមិរហាល ស្រះស្រង់ត្បូង និងភូមិស្រះស្រង់ខាងជើង សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ បុគ្គលិកខ្លះ បានធ្វើការក្នុងគម្រោងនេះផង និងឲ្យទៅធ្វើខាងគម្រោង NZaid ផង។

### V.3 បញ្ហាសំខាន់ៗដែលកំពុងប្រឈមមុខ

- ប្រជាពលរដ្ឋពុំសូវមកដាក់ពាក្យសុំសាងសង់ទេ ប៉ុន្តែបើពួកគាត់មកដាក់ពាក្យសុំសាងសង់ភាគច្រើនពួកគាត់ចាប់ផ្តើមសាងសង់បណ្តើរៗតែម្តង។
- ពេលចុះទៅសាកសួររកផ្ទះប្រជាពលរដ្ឋ ដែលដាក់ពាក្យសុំសាងសង់ រដ្ឋអំណាចមូលដ្ឋានមិនសូវសហការជាមួយយើងទៀតទេ ព្រោះយើងឈប់ឲ្យពួកគាត់បញ្ជាក់លើពាក្យស្នើសុំសាងសង់ទៀតហើយ។ ចំពោះករណីនេះអាជ្ញាធរអប្សរាយើងគួរសើរើពិនិត្យឡើងវិញ។
- ការហូរចូលនៃអ្នកចំណូលថ្មីដែលបានទិញ និងលក់ដីក្នុងតំបន់ការពារ និងសាងសង់ផ្ទះអនាធិបតេយ្យចេះតែមានបន្ត។
- កិច្ចការចុះពិនិត្យសំណង់មានការលំបាកជាខ្លាំង តាំងពីនាយកដ្ឋានយើងខ្ញុំត្រូវបានគេដកហូតរថយន្តមួយគ្រឿង តាំងពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩មក ហើយទើបតែប្រគល់ឲ្យវិញថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។

### V.4 សំណូមពរ

- ប្រគល់ស្វ័យភាពខ្លះឲ្យទៅនាយកដ្ឋាន ខាងផ្នែកគណនេយ្យ ដើម្បីដោះស្រាយបញ្ហាដែលបន្ទាន់ ដូចជាការទិញសម្ភារៈតូចតាចដែលចាំបាច់ និងសំរាប់រើសកម្មករពេលធ្វើការក្នុងគម្រោងផ្សេងៗ។
- សូមដោះស្រាយបញ្ហាស្នើសុំផ្សេងៗដូចជាសំណើសុំថវិកា សម្ភារៈ និងជួសជុលឧបករណ៍ផ្សេងៗឲ្យបានឆាប់រហ័សបន្តិច។

# VI. នាយកដ្ឋានអភិវឌ្ឍន៍កសិកម្មនិងសហគមន៍

### VI.1 យុត្តិកម្ម

នៅក្នុងផ្ទៃដី ៤០ ១១៧ ហិកតានៃឧទ្យានអង្គរ មានដីស្រែ ១ ៩៥៦ ហិកតា ឬស្មើនឹង ៣៩ ភាគរយ នៃផ្ទៃដីសរុប ហើយស្រែគឺជាផ្នែកមួយនៃទេសភាពវប្បធម៌របស់ឧទ្យានអង្គរ។

សន្និសីទអន្តររដ្ឋាភិបាលទីក្រុងប៉ារីស៍ នាខែ វិច្ឆិកា ២០០៣ បានផ្តល់គោលដៅថ្មីដល់អាជ្ញាធរជាតិអប្សរា ពោលគឺត្រូវធានាការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃតំបន់សៀមរាបអង្គរ។
កសិកម្មគឺជាមុខរបរចម្បងមួយរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ការពារ។ ដូច្នេះ គេចាំបាច់ត្រូវជួយប្រជាជនទាំងនោះអោយធ្វើកសិកម្មដែលទទួលផល ប៉ុន្តែមាននិរន្តរភាព។

- ការអភិវឌ្ឍនឹងមិនមាននិរន្តរភាពទេប្រសិនបើផលិតផលកសិកម្មនៅសៀមរាបត្រូវបំពុលដោយជីគីមីនិងថ្នាំសម្លាប់សត្វល្អិត។ វានឹងប៉ះពាល់ដល់សុខភាពរបស់អ្នកទេសចរនិងប្រជាជន។
- ដោយសារសៀមរាបស្ថិននៅខាងលើបឹងទន្លេសាប សារជាតិគីមីដែលគេប្រើដើម្បីធ្វើកសិកម្មនឹងហូរតាមទឹកចូលទៅក្នុងទន្លេ ធ្វើអោយពុលត្រី ដែលជាម្ហូបអាហារសំខាន់ជាងគេរបស់ប្រជាជនខ្មែរ។

កសិកម្មធម្មជាតិគឺជាដំណោះស្រាយតែមួយគត់របស់អាជ្ញាធរជាតិអប្សរា។

គេដឹងថាប្រជាជនខេត្តសៀមរាបគឺជាប្រជាជនដែលក្រជាងគេនៅក្នុងប្រទេសកម្ពុជា។ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅក្នុងខេត្តនេះគឺជាបេសកកម្មមួយក្នុងចំណោមបេសកកម្មសំខាន់ៗជាច្រើនរបស់អាជ្ញាធរអប្សរា។ ប្រជាជន ៨០ ភាគរយជាកសិករ។ នាយកដ្ឋានត្រូវរិះរកមធ្យោបាយដើម្បីបង្កើនផលិតផលកសិកម្ម ដើម្បីធ្វើទៅបានគឺត្រូវបង្កើនទិន្នផល។

តើត្រូវបង្កើនទិន្នផលកសិកម្មយ៉ាងដូចម្តេចដោយមិនប្រើជីគីមី?

បទពិសោធន៍នៅតាមបណ្តាប្រទេសអភិវឌ្ឍន៍នានាបានបង្ហាញថា កសិកម្មធម្មជាតិត្រូវប្រទះនឹងការថយបរិមាណទិន្នផល។ បណ្តាប្រទេសទាំងនេះមិនទាន់រកឃើញដំណោះស្រាយបច្ចេកទេសសម្រាប់ពិភពលោកចំពោះបញ្ហានេះនៅឡើយទេ។ ដូច្នេះ នាយកដ្ឋានត្រូវប្រឈមមុខនឹងបញ្ហាមួយដ៏ធំ៖ បង្កើតបច្ចេកវិជ្ជាថ្មីអោយស្របទៅនឹងតម្រូវការរបស់ប្រទេស ដើម្បីបង្កើនទិន្នផលកសិកម្ម ដោយមិនធ្វើអោយប៉ះពាល់ដល់បរិស្ថាន។

ប្រជាជននៅអង្គរ ដែលជាអ្នកថែរក្សាវប្បធម៌ ប្រពៃណីរាប់ពាន់ឆ្នាំមកហើយនោះ គឺជាបេតិកភណ្ឌអរូបីមួយដែរ ដែលគេត្រូវការពារដូចជាប្រាង្គប្រាសាទដូច្នោះដែរ។ ការធ្វើអោយជីវភាពរបស់ពួកគេប្រសើរឡើងគឺជាកិច្ចការសំខាន់របស់អាជ្ញាធរជាតិអប្សរា។ ដៃគូអភិវឌ្ឍន៍សំខាន់គឺសហគមន៍កសិករ។ ការអោយពួកគេមានទំនួលខុសត្រូវលើសេចក្តីសម្រេចនានាគឺជាមធ្យោបាយមានប្រសិទ្ធិភាពដើម្បីឈានទៅសម្រេចបាននូវការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព។

### VI.2 **ការស្រាវជ្រាវកសិកម្ម**

នៅប្រទេសកម្ពុជា គេពុំឃើញមានការសិក្សាអោយបានស៊ីជម្រៅទៅលើកសិកម្មធម្មជាតិនោះឡើយ។ ក្រសួងកសិកម្មខ្មែរ ដែលគ្មានទាំងធនធានមនុស្ស គ្មានទាំងមធ្យោបាយហិរញ្ញវត្ថុ បានត្រឹមតែគាំទ្រការសិក្សា ស្រាវជ្រាវរបស់នាយកដ្ឋានប៉ុណ្ណោះ ដោយក្រសួងបានផ្តល់ដីមួយកន្លែងអោយនាយកដ្ឋាន នៅស្ថានីយកសិកម្ម ទឹក វិល។

នៅខែកុម្ភៈ ២០០៩ ឯកឧត្តមរដ្ឋមន្ត្រីកសិកម្មបានអញ្ជើញមកដោយខ្លួនលោកផ្ទាល់ដើម្បីស្តាប់ការបង្ហាញជូនរបស់នាយកដ្ឋានស្តីពីការស្រាវជ្រាវលើកសិកម្មធម្មជាតិ។

ប្រធានបទសំខាន់ៗនៃការស្រាវជ្រាវកសិកម្មមានដូចខាងក្រោម៖

- ជីកុំប៉ុស្ត៍
- KEM (Khmer Effective Micro Organisms)
- ការប្រើភក់បឹងទន្លេសាប
- ថ្នាំសម្លាប់សត្វល្អិតធម្មជាតិ

## ក. ជីកុំប៉ុស្ត៍

ការប្រើជីកុំប៉ុស្ត៍គឺជាគ្រឹះនៃកសិកម្មធម្មជាតិ។

នាយកដ្ឋានបានសិក្សាលើទំហំសមរម្យនៃគំនរជី ប្រភេទនៃធាតុផ្សំ និងដំណើរការធ្វើអោយលឿន ព្រមទាំងការបង្កើនគុណភាពផលិតផលសម្រេច។ យើងទទួលបានលទ្ធផលដូចខាងក្រោម៖

- ទំហំគំនរជី៖ 1,5m x 2m x 5m
- ធាតុផ្សំ៖ 50% ធាតុស្ងួត + 50% ធាតុស្រស់ + លាមកសត្វ (អាចមន៍គោ) + កំបោរ
- ដំណើរការធ្វើអោយលឿន និងបង្កើនគុណភាព៖ ប្រើKEM

## ខ. KEM (Khmer Effective Micro Organisms)

ទន្ទឹមនឹងមានលក្ខណៈធម្មជាតិ ជី EM ត្រូវបានគេស្គាល់នៅអាស៊ី និងនៅសហរដ្ឋអាមេរិក។ នាយកដ្ឋានបានបង្កើតជី EM ដោយខ្លួនឯងដោយប្រើវត្ថុធាតុដើមរបស់ខ្មែរ។ ដូច្នេះហើយបានជាជីនេះ មានឈ្មោះថា Khmer Effective Micro Organisms។

បទពិសោធន៍កសិកម្មដែលធ្វើនៅកន្លែងពិសោធន៍និងនៅមូលដ្ឋានផ្ទាល់បានបង្ហាញអំពីប្រសិទ្ធិភាពនៃ KEM ទៅលើបន្លែនិងស្រូវ។

គេក៏ទទួលបានលទ្ធផលល្អដែរលើផ្សិត សត្វស្លាប និងត្រី។

សូមរំលឹកថាការប្តូរពីកសិកម្មដោយប្រើជីគីមី ទៅកសិកម្មធម្មជាតិធ្វើអោយគេជួបប្រទះនឹងការចុះថយទិន្នផល។ ដោយសារការប្រើជីកុំប៉ុស្ត៍ និងជី KEM រួមគ្នា កសិករអាចរក្សាទិន្នផលអោយនៅបរិមាណដដែល ក្នុងរយៈពេលតែ ៤ ទៅ ៥ រដូវ ទិន្នផលអាចទទួលបានបរិមាណស្មើនឹងកសិកម្មប្រើជីគីមីដែរ ហើយថែមទាំងមានអត្ថប្រយោជន៍ច្រើនទៀតផង។ តាមពិត កសិកម្មធម្មជាតិធ្វើអោយដីកាន់តែមានជីវជាតិ ទិន្នផលក៏កាន់តែកើនបរិមាណ ចំណែកឯកកសិកម្មប្រើជីគីមីមានទំនោរផ្ទុយពីនេះទៅវិញ ពោលគឺធ្វើអោយដីនិងទឹកកាន់តែពុលខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ។

## គ. ភក់បឹងទន្លេសាប

ការប្រើជីកុំប៉ុស្តិ៍មិនគ្រប់គ្រាន់ដើម្បីបង្កើនគុណភាពដីដែលមានគុណភាពចុះអន់ថយនៅសៀមរាបទេ។ ភក់នៅទន្លេសាបគឺជាសារធាតុបន្ថែមមួយទៀតដែលមានតម្លៃកសិកម្មយ៉ាងខ្ពស់។ ភក់នេះគ្មានសារធាតុរ៉ែធ្ងន់ៗ សំបូរដោយជាតិដីឥដ្ឋនិងផូស្វ័រ។ បទពិសោធន៍នៅនឹងវាលស្រែផ្ទាល់បានបង្ហាញថា បើគេដាក់ភក់ទន្លេសាប ១០តោនក្នុងមួយហិកតា គេអាចបង្កើនទិន្នផលកសិកម្មបានរហូតដល់៥០% ចំពោះដីសំបូរដោយខ្សាច់នៅសៀមរាប។
ការប្រើវិធីនេះ គេជួបប្រទះនឹងបញ្ហាចំណាយ៖ គេត្រូវយកភក់ចេញពីទន្លេសាប ស្តុកទុក ចែកចាយដល់ប្រជាជន ទាំងនេះត្រូវចំណាយអស់ថវិកាច្រើន។ ដូច្នេះ គេត្រូវរិះរកវិធីកាត់បន្ថយចំណាយលើការដឹកជញ្ជូននិងចែកចាយ។
ម្យ៉ាងទៀត គេត្រូវធ្វើការសិក្សាលើផលប៉ះពាល់បរិស្ថានមុននឹងយកភក់ចេញពីបឹង។

### ឃ. SRI (System of Rice Intensification by natural means)

វិធីនេះត្រូវបានគេធ្វើនៅ Madagascar និងត្រូវបានអង្គការ CEDAC យកមកប្រើនៅកម្ពុជាមុនគេ។
គោលបំណងគឺធ្វើវាអោយត្រូវនឹងដីនិងអាកាសធាតុនៅសៀមរាប។
មើគ្មានជីគីមី វិធីនេះអាចជួយអោយកសិករបង្កើនទិន្នផលបានមួយជាពីរ។

## ង. ថ្នាំសម្លាប់សត្វល្អិតធម្មជាតិ

ជាមួយកសិកម្មធម្មជាតិ ពពួកប៉ារ៉ាស៊ីតថយចុះ ប៉ុន្តែក្នុងករណីខ្លះ គេចាំបាច់ត្រូវប្រឆាំង។
ថ្នាំសម្លាប់សត្វល្អិតធម្មជាតិដែលកសិករបានប្រើប្រាស់ ត្រូវបានអង្គការ CEDAC និងសាកលវិទ្យាល័យភូមិន្ទកសិកម្មចុះផ្សាយនៅក្នុងទស្សនាវដ្តីរបស់ខ្លួន។ ស្ថាប័នទាំងពីរនេះបានផ្អែកទៅលើការនិយាយប្រាប់របស់កសិករស្តីពីប្រសិទ្ធិភាពរបស់ថ្នាំនេះ។ នាយកដ្ឋាននាសម្រេចផលិតថ្នាំធម្មជាតិនេះជាង៣០ប្រភេទ ហើយយកទៅធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍និងនៅតាមកសិដ្ឋានផ្ទាល់។
**លទ្ធផល៖** ប្រសិទ្ធិភាពខ្សោយ ភាគច្រើនធ្វើអោយសត្វល្អិតគេចចេញ សកម្មភាពសម្លាប់សត្វល្អិតនៅមានកម្រិតខ្សោយ ថ្នាំសម្លាប់សត្វល្អិតធម្មជាតិមួយមុខគត់ដែលមានប្រសិទ្ធិភាព ហើយដែលយើងបានធ្វើតេស្តរួចហើយ គឺ ទឹកថ្នាំជក់ស្ងោ ប៉ុន្តែវាអាចសម្លាប់បានតែមមង់ប៉ុណ្ណោះ ហើយវាមានប្រសិទ្ធិភាពរយៈពេលតែ៧ថ្ងៃគត់។ សំណាងល្អ ការស្រាវជ្រាវស៊ីជម្រៅបន្ថែមទៀតបានជួយធ្វើអោយវាមានប្រសិទ្ធិភាពបានច្រើនខែ។ ដើម្បីកំចាត់ពងសត្វល្អិត គេបានរកឃើញផលិតផលមួយចំនួន ដែលងាយផលិតជាងរបៀបផលិតតាមបែបបុរាណ ប៉ុន្តែប្រសិទ្ធិភាពរបស់វានៅមានកម្រិតខ្សោយ។ រុក្ខជាតិបណ្តេញសត្វល្អិតមួយចំនួនកំពុងតែធ្វើការដកបទពិសោធន៍ Tagetes erecta, Oximum sanctum, cymbopogon nardus ឬ Neem (Azadirachta) ដែលគេស្គាល់យូរយារណាស់មកហើយនៅប្រទេសឥណ្ឌា។

### VI.3 ការផ្សព្វផ្សាយនិងចលនាប្រជាជន

នៅពេលដែលមានបច្ចេកទេសថ្មីមួយត្រូវគេទទួលស្គាល់ថាមានប្រសិទ្ធិភាព នាយកដ្ឋានចាប់ផ្តើមផ្តល់ព័ត៌មានជូនប្រជាជនភ្លាម។
ភ្នាក់ងារ១៧នាក់ទទួលបន្ទុកខាងផ្តល់ព័ត៌មាននៅតាមភូមិចំនួន២៧ ក្នុងចំណោមភូមិទាំង១១២ ដែលមាននៅក្នុង

ឧទ្យានអង្គរ។
ដំបូង យើងរើសកសិករគម្រូ (មានចំនួន ៧៩នាក់ ពីឆ្នាំ២០០៥ ដល់ ២០០៨) ដើម្បីអោយជួយផ្សព្វផ្សាយបច្ចេកទេសថ្មី ដូចជាការផលិតជីកុំប៉ុស្ត៍ SRI និង KEM (ចិញ្ចឹមសត្វស្លាប)។
បច្ចុប្បន្ននេះ ការបណ្តុះបណ្តាលបែរទៅរកសមាគមន៍កសិករទៅតាមគម្រូរបស់អង្គការ CEDAC។
ដើម្បីធ្វើទៅបាន ជំហ៊ានដែលត្រូវបំពេញមាន៖

- បង្កើតក្រុមសំចៃ
- ផ្តើមចេញពីក្រុមនេះ បង្កើតក្រុមបច្ចេកទេសតូចៗ៖ SRI ជីកំប៉ុស្ត៍ សត្វស្លាបនិងបន្លែ ។ល។
- ដោយអនុវត្តគោលការណ៍ទំនួលខុសត្រូវរបស់សហគន៍អ្នកស្រុក ក្រុមសំចៃចំនួន៣០ត្រូវបានបង្កើតឡើង។ ប្រាក់សំចៃសរុបមាន ៨២ ៧២២ ៨០០ រៀល ស្មើនឹង ១០ ៦៨០,៦ ដុល្លាអាមេរិក។ សមាជិកក្រុមទាំងអស់មាន៨០០ នាក់។ ប្រាក់សំចៃទាំងនេះបានធ្វើអោយពួកគេបង្កើតបានជាប្រព័ន្ធកំចីខ្នាតតូច ដែលមានតម្លៃការប្រាក់ទាប។
- រហូតមកដល់ថ្ងៃនេះ គេបានបង្កើត៖
  + ២៥ក្រុម ចិញ្ចឹមមាន់ ដោយប្រើ KEM មានសមាជិក ៣៣៦ នាក់
  + ២៧ក្រុម ដាំបន្លែធម្មជាតិ មានសមាជិក ២៣១ នាក់
  + ១០ក្រុម SRI មានសមាជិក ៦០ នាក់
  + ៧ក្រុម ជីកំប៉ុស្ត៍ មានសមាជិក ៥៩ នាក់

ចាប់ពីពេលនេះតទៅ ក្រុមតូចៗទាំងនេះ ជាអ្នកប្រាប់បច្ចេកទេសថ្មីដល់អ្នកផ្សេងជំនួសភ្នាក់ងាររបស់នាយកដ្ឋាន ដែលត្រូវធ្វើកិច្ចការផ្សេងទៀត ដូចជាបង្កើតសមាគមន៍កសិករ បង្កើតក្រុមសំចៃថ្មី និងការរៀបចំផលិតផលកសិកម្មដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

# VII. នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន

### VII. 1 រចនាសម្ព័ន្ធ ៖

នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន ចែកចេញជា៥ការិយាល័យគឺ៖ ការិយាល័យរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ការិយាល័យកិច្ចការព្រៃឈើ ការិយាល័យការពារបរិស្ថាន ការិយាល័យគ្រប់គ្រងទេសភាពវប្បធម៌ និងការិយាល័យដាំឈើ និងសួនរុក្ខជាតិ។

### VII. 2 ក្របខ័ណ្ឌ៖

មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារអភិរក្សព្រៃឈើ និងកម្មករ ក្រោមឱវាទនាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌ និងបរិស្ថាន មានសរុបចំនួន ២៩៨នាក់ក្នុងនោះមាន៖
១. ថ្នាក់ដឹកនាំនាយកដ្ឋាន............................................ ៖ ចំនួន ០៥ រូប
២. មន្ត្រី-បុគ្គលិក........................................................... ៖ ចំនួន ៣១ នាក់

៣. ភ្នាក់ងារអភិរក្សព្រៃឈើ និងកម្មករ........................ ៖ ចំនួន ២៥៧ នាក់ ដែលក្នុងនោះមាន៖

-ភ្នាក់ងារអភិរក្សព្រៃឈើ.............................................. ៖ ចំនួន ១២៩ នាក់

-កម្មករបើកបររថយន្ត.................................................. ៖ ចំនួន ០៤ នាក់

-កម្មករពោងជាងឈើតានៃ.......................................... ៖ ចំនួន ០៥ នាក់

-កម្មករនៅសួនគ្រឿងទេស........................................ ៖ ចំនួន ១៦ នាក់

-កម្មករនៅសួនមណ្ឌល៣.......................................... ៖ ចំនួន ៣៥ នាក់

-កម្មករនៅសួនបណ្ដុះកូនឈើ ៨ហិកតា.................. ៖ ចំនួន ០៨ នាក់

## VII.3 **សកម្មភាពការងារប្រចាំឆ្នាំ ២០០៩**

### ១. ការងាររដ្ឋបាលផែនការ និងសហប្រតិបត្តិការ

**ក. ការងាររដ្ឋបាលទូទៅ**

-បានចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ និងសិក្ខាសាលាចំនួន៥០លើក។

-បានទទួលលិខិតចូលចំនួន ១.២០៤ ច្បាប់

-បានចរាចរលិខិតចេញចំនួន ៥៧៦ ច្បាប់

**ខ. ការងារគ្រប់គ្រងបុគ្គលិក និងបណ្ដុះបណ្ដាល**

-បានផ្ទេរភារកិច្ចមន្ត្រី០១រូប ពីស្ថានីយ ៨ហិកតា ទៅគ្រប់គ្រងសួនបណ្ដុះកូនឈើប្រាសាទតាកែវ និងបានប្រគល់ភារកិច្ចមន្ត្រី ០១រូប ពីការិយាល័យដាំដើមឈើទៅគ្រប់គ្រងស្ថានីយ ៨ហិកតា។

-បានបញ្ជូនមន្ត្រីបុគ្គលិកចំនួន ២១នាក់ ដើម្បីរៀនសូត្រវគ្គព្យាបាលដើមឈើជាមួយក្រុមបច្ចេកទេសឥណ្ឌា រយៈពេល ០៤ថ្ងៃ និងវគ្គបណ្ដុះបណ្ដាលអ្នកប្រឹក្សាយោបល់ជក់បារីរយៈពេល២ថ្ងៃកន្លះ ដោយអង្គការ ADRA ចំនួន ០៥នាក់។

-បានទទួលពាក្យសុំចូលបំរើការថ្មីចំនួន ១៦នាក់ ក្នុងនេះសំរេចឲ្យចូលបំរើការងារចំនួន០៧នាក់ និងសំរេចជាគោលការណ៍ជ្រើសរើសចំនួន០៥នាក់។

-បានទទួលសេចក្ដីសំរេចសុំឈប់បំរើការងាររបស់បុគ្គលិកចំនួន ០៤រូប។

-បានទទួលសេចក្ដីសម្រេចបញ្ឈប់ពីការងាររបស់បុគ្គលិកចំនួន០១នាក់។

-បានរៀបចំទុកដាក់ឯកសារសំរាប់នាយកដ្ឋាននូវសំណុំលិខិតផ្ទាល់ខ្លួនរបស់មន្ត្រីបុគ្គលិកទាំងអស់។

-បានបំពេញទំរង់បែបបទសុំតម្លើងប្រាក់បន្ថែមជូនបុគ្គលិកចំនួន២៣នាក់ (មន្ត្រី-បុគ្គលិកបំពេញការងាររយៈពេល១ឆ្នាំ)។

**គ. ការងារផែនការ និងសហប្រតិបត្តិការ**

**ការងារផែនការ៖**

-បានធ្វើការបូកសរុបសកម្មភាព និងលទ្ធផលការងាររបស់នាយកដ្ឋានសំរាប់ឆ្នាំ២០០៩ និងទេសដៅការងារឆ្នាំ២០១០។

-បានរៀបចំគម្រោងអាទិភាពចំនួន០៥ ជូនអគ្គនាយកអាជ្ញាធរអប្សរាសំរាប់ស្នើសុំជំនួយអន្តរជាតិ។

-បានកសាងផែនការសកម្មភាពឆ្នាំ២០១០ និងចូលរួមកសាងផែនការយុទ្ធសាស្ត្រ០៥ឆ្នាំ (២០១១-២០១៥)។

**ការងារសហប្រតិបត្តិការ**

-បានជួបពិភាក្សាជាមួយឯកអគ្គរដ្ឋទូតហុងគ្រីក្នុងការសិក្សាគម្រោងចំនួន០៩ របស់គម្រោងកោះកេរ្តិ៍នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៩។

-បានទាក់ទងជាមួយស្ថានទូតជប៉ុន និងក្រុមហ៊ុនទេសចរណ៍ APEX អំពីការដាំដើមឈើអនុស្សាវរីយ៍របស់ លោក IWAO MATSUDA សមាជិកសភា និងជាអនុប្រធានសម្ព័ន្ធភាពអនុតំបន់មេគង្គជប៉ុន។

-បានទាក់ទងជាមួយហុងគ្រី ដើម្បីចរចាជាមួយនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរអំពីព្រំប្រទល់ស្រាវជ្រាវគម្រោងកោះកេរ្តិ៍។

-បានទាក់ទងជាមួយជប៉ុន និងនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរអំពីការដាំដើមឈើ។

-បានពិភាក្សាជាមួយជប៉ុនអំពីការដាំដើមឈើ១.០០០ដើម និងពិនិត្យដីដាំឈើនៅបេងមាលាជាមួយនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ។

-បានបានទាក់ទងជាមួយ NZAID អង្គការអន្តរជាតិចំនួន០២ដង អំពីការបង្កើតសហគមន៍អប់រំសុខភាព ការដាំដើមឈើ និងអប់រំផ្សព្វផ្សាយ។

-បានរៀបចំបទបង្ហាញ និង Slide ដើម្បីចូលរួមប្រជុំ ICC (១៥.០៦.២០០៩)។

-បានជួបពិភាក្សាជាមួយភាគីឥណ្ឌានៅប្រាសាទតាព្រហ្ម ដើម្បីបញ្ជូនមន្ត្រី-បុគ្គលិកចូលរួមរៀនវគ្គព្យាបាលដើមឈើ។

**២.ការងារកិច្ចការព្រៃឈើ**

**ការសិក្សាស្រាវជ្រាវ**

-បានចុះស្រង់ព័ត៌មានផ្ទៃដីឃុំគោកចកលើផ្ទៃដី ១៣.៥០០ហិកតា ក្នុងភូមិចំនួន០៥ ដែលមានប្រជាជនរស់នៅសរុបចំនួន៥.២៩០គ្រួសារ មានប្រជាជនសរុបចំនួន ២០.៦៩៧នាក់ ក្នុងនោះស្រីសរុបចំនួន ៨.៦៧៥នាក់។

-បានចុះស្រង់ស្ថិតិដីវិចវិលត្រូវដាំដើមឈើឡើងវិញចំនួន ២៣ហិកតា។

-បានចុះសិក្សាអំពីបរិមាណនិងឈ្មោះដើមឈើក្នុងតំបន់ឧទ្យានអង្គរសរុប៦.១០០ដើម ត្រូវជា៦០ប្រភេទដើមឈើ ក្នុងនោះបានត្រៀមដាក់ស្លាកឈ្មោះដើមឈើចំនួន២.៥០០ដើម ត្រូវជា៦០ប្រភេទដើមឈើ។

**ការងារសារពើភ័ណ្ឌព្រៃឈើ**

-បានចុះផ្ទៀងផ្ទាត់ចំណុចនិយាមកាក្នុងប្លុកទី៤ ក្នុងតំបន់១ និងស្រង់ទិន្នន័យដែលមានចំណុចនិយាមកាចំនួន១៨

-ផ្ទៃដីព្រៃឈើទំហំ ១០១,៣៩ ហិកតា

-ផ្ទៃដីលំនៅដ្ឋាន និងចំការទំហំ ២៤២,១ ហិកតា

-ផ្ទៃដីស្រែ និងផ្ទៃដីវិចវិលទំហំ ១៤៥,៧ ហិកតា

-ផ្ទៃដីបាឡុងទំហំ ៤,៩៦ ហិកតា

-បានធ្វើការបែងចែកតំបន់១ជា១១ប្លុក និងតំបន់២ជា៤ប្លុក

-បានចុះពិភាក្សាដីដាំឈើអនុស្សាវរីយ៍កម្ពុជា-ជប៉ុនលើផ្ទៃដីទំហំ ៤,៨០ហិកតា។

-បានចុះស្រង់ចំណុចនិយាមកាប្រាសាទចំនួន០៥កន្លែង ត្រៀមធ្វើសារពើភ័ណ្ឌក្នុងនោះមានប្រាសាទ ៖ ក្រោលគោ

តាសោម បន្ទាយក្ដី តាព្រហ្ម និងព្រះខ័ន។

**ការងារសុរុំឌ្ឍិកម្មព្រៃឈើ**

-បានលើកគម្រោងដីសំរាប់ធ្វើសុរុំឌ្ឍិកម្មព្រៃឈើចំនួន ៩១,៥០ហិកតា នៅឆ្នាំ២០០៩។

-បានចុះសិក្សាទីតាំងដីព្រៃឈើក្នុងប្លុក ៥-៧-៩-១០ និង១១ សំរាប់ធ្វើសុរុំឌ្ឍិកម្មព្រៃឈើ ១១៩.៧៥៧ហិកតា សំរាប់ឆ្នាំ២០១០។

-បានធ្វើការសិក្សាធ្វើសុរុំឌ្ឍិកម្មរយៈពេល៥ឆ្នាំមានចំនួន៩៤៨.១៧៦ហិកតា។

**ការងារធ្វើផ្លូវភ្លើងទប់ស្កាត់ និងការពារភ្លើងឆេះព្រៃ**

-បានអនុវត្តការធ្វើផ្លូវភ្លើងការពារភ្លើងឆេះព្រៃចំនួន១១ខ្សែ ប្រវែង៩,១៤៨ម៉ែត្រ ស្មើនឹង ៣៨.៦៣២ម៉ែត្រការ៉េ។

-បានចុះផ្ទៀងផ្ទាត់ផ្លូវភ្លើងចាស់ចំនួន០៦ខ្សែ ប្រវែង៤.៤០២ម៉ែត្រ និងផ្លូវភ្លើងថ្មីចំនួន១១ខ្សែប្រវែង១.៧០០ម សំរាប់ផែនការ២០១០។

-បានរៀបចំលើកប៉ាណូការពារភ្លើងឆេះព្រៃចំនួន២០ប៉ាណូ។

-បានចុះសិក្សាធ្វើផ្លូវភ្លើងក្នុងតំបន់១មានចំនួនសរុប៥០ខ្សែ។

**៣.ការងារគ្រប់គ្រងទេសភាពវប្បធម៌**

-បានកាត់ក្រីមែកឈើចំនួន ៤៨៦ដើម គិតជាមែកត្រូវជា២.៤៣០មែក តាមបណ្ដោយផ្លូវចាប់ពីកែងភូមិព្រះដាករហូតដល់សាលាស្រុកបន្ទាយស្រី។

-បានកាប់ដើមឈើដែលនឹងបង្កឲ្យមានបញ្ហាចំនួន១២៤ដើមនៅក្នុងតំបន់ឧទ្យានអង្គរ។

-បានចុះត្រួតពិនិត្យស្ថានភាពដើមឈើចំនួន៨៦៤ដើម ដែលនឹងបង្កឲ្យមានគ្រោះថ្នាក់នៅទីតាំង ៩កន្លែងក្នុងតំបន់អង្គរ។

-បានចូលរួមព្យាបាលជំងឺដើមឈើជាគំរូចំនួន៤ដើម ជាមួយអ្នកបច្ចេកទេសឥណ្ឌានៅប្រាសាទតាព្រហ្ម។

-បានសាងសង់ប៉ុស្ដិ៍យាមល្បាតចំនួន ១៤ប៉ុស្ដិ៍រួចរាល់ជាស្ថាពរ។

**៤.ការងារដាំឈើ និងសួនរុក្ខជាតិ**

-បានបណ្ដុះកូនឈើសរុប ៨៣.៣៤៧ដើម ក្នុងនោះបានដាំដោយនាយកដ្ឋានផ្ទាល់ចំនួន១០.១៣៩ដើម ចែកចាយជូនអង្គភាព ប្រជាជន អង្គការនានា និងវត្តអារាមចំនួន២១.៤៣០ដើម។

-កូនឈើនៅសល់ចំនួន ៥១.៧៧៨ដើម។

-បានបណ្ដុះកូនគ្រឿងទេសចំនួន ២.៧៦៨ដើម ស្មើនឹង៣៨មុខនៃកូនរុក្ខជាតិគ្រឿងទេស។

**៥.ការងារការពារបរិស្ថាន**

-បានចុះសិក្សាអំពីផលប៉ះពាល់បរិស្ថានក្នុងតំបន់១ ចំនួន១៦លើក។

-បានចុះអប់រំណែនាំដល់ប្រជាសហគមន៍ក្នុងតំបន់១ និង២ ចំនួន២៧លើក។

-បានសហការ និងត្រួតពិនិត្យតំបន់គោលដៅរបស់ក្រុមហ៊ុន HCC ចំនួន២២លើក។

-បានត្រួតពិនិត្យការបំពុលបរិស្ថានចំនួន ១៩លើក។

-បានចូលរួមចំណែកក្នុងការបង្ការរាល់សកម្មភាពល្មើសផ្សេងៗចំនួន ២៤លើក។
-បានចូលរួមបង្ក្រាបបទល្មើសបូមខ្សាច់ និងកាប់ដីចំនួន០៤លើក។

### VII.4 **ទិសដៅការងារឆ្នាំ២០១០**

**១.ការងារកិច្ចការព្រៃឈើ៖**

ក. ប្រមូលឯកសារ និងទិន្នន័យព្រៃឈើ និងការប្រើប្រាស់ដីរបស់ប្រជាជនក្នុងតំបន់អាជ្ញាធរអប្សរា។
ខ. រៀបចំធ្វើសារពើភ័ណ្ឌព្រៃឈើ និងចំណាត់ថ្នាក់ព្រៃឈើនៅក្នុងបរិវេណប្រាសាទ តំបន់១នៃឧទ្យានអង្គរ។
គ. ធ្វើសុវត្ថិកម្មព្រៃឈើនៅក្នុងតំបន់១ នៃឧទ្យានអង្គរចំនួន ៩១.៥ហិកតា។
ឃ. ធ្វើផ្លូវភ្លើងដើម្បីការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃនៅក្នុងតំបន់១ នៃឧទ្យានអង្គរចំនួន ១១ខ្សែ។

**២.ការងារគ្រប់គ្រងទេសភាពវប្បធម៌៖**

ក. លើកតម្លៃទេសភាពវប្បធម៌ និងធម្មជាតិដែលមានទំនាក់ទំនងនឹងប្រពៃណីប្រវត្តិសាស្ត្រខ្មែរនៅភូមិរហាល និងភូមិស្រះស្រង់ខាងជើងនៃសង្កាត់នគរធំក្នុងតំបន់ឧទ្យានអង្គរ។
ខ. ព្យាបាលជម្ងឺដើមឈើក្នុងបរិវេណប្រាសាទអង្គរធំ តាព្រហ្ម ព្រះខ័ន និងអង្គរវត្ត។
គ. ត្រួតពិនិត្យជាប្រចាំរាល់ដើមឈើដែលដុះនៅលើក្បែរប្រាសាទ និងនៅអមសងខាងផ្លូវ។
ឃ. កាត់ក្រីមែកឈើដុះនៅលើប្រាសាទ ក្បែរប្រាសាទ និងអមសងខាងផ្លូវក្នុងតំបន់ឧទ្យានអង្គរ។
ង. កែច្នៃឈើចាស់ៗក្នុងឃ្លាំងទៅជាឈើឡាំង ឈើអារ ដើម្បីរក្សាទុក និងប្រើប្រាស់តាមតំរូវការ។

**៣.ការងារដាំឈើ និងសួនរុក្ខជាតិ**

ក. រៀបចំសួនគ្រឿងទេសដោយដាំពូជគ្រឿងទេស៥៤ពូជសំរាប់បំរើការទស្សនារបស់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ។
ខ. ថ្នាលបណ្តុះកូនឈើនៅស្ថានីយ៨ហិកតា ចំនួន២៥.០០០ដើម។
គ. បណ្តុះកូនឈើនៅស្ថានីយមណ្ឌល៣ចំនួន២០.០០០ដើម និងផលិតជីកំប៉ុស្តិ៍ចំនួន១០០ម៉ែត្រគូប។
ឃ. បណ្តុះកូនឈើនៅប្រាសាទតាកែវចំនួន៤០.០០០ដើម។
ង. ត្រៀមដាំកូនឈើចំនួន៧.០០០ដើមលើផ្ទៃដី៧ហិកតា នៅចន្លោះព្រៃក្នុងតំបន់ត្រូវការពារ។

**៤.ការងារការពារបរិស្ថាន៖**

ក. សិក្សាអំពីផលប៉ះពាល់បរិស្ថាននៅក្នុងតំបន់ដែលត្រូវការពារ១ និង២។
ខ. អប់រំផ្សព្វផ្សាយចំណេះដឹងបរិស្ថានជូនដល់ប្រជាសហគមន៍ដែលរស់នៅតំបន់ត្រូវការពារ១ និង២។
គ. អប់រំផ្សព្វផ្សាយជូនដល់ភ្នាក់ងារអភិរក្សព្រៃឈើនៅតាមប៉ុស្តិ៍គោលដៅទាំង១៤។
ឃ. ត្រួតពិនិត្យ និងទប់ស្កាត់ជាបន្ទាន់រាល់សកម្មភាពទាំងឡាយណាដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន និងបទល្មើសធនធានធម្មជាតិនៅក្នុងតំបន់ដែលត្រូវការពារ១ និង២។

**៥.ការងាររដ្ឋបាល ផែនការ និងសហប្រតិបត្តិការ**

ក. ធ្វើឲ្យមានប្រសិទ្ធភាព និងសុវត្ថិភាពការងាររដ្ឋបាល។

ខ. កសាងផែនការ យុទ្ធសាស្ត្រ ផែនការរយៈពេលវែង មធ្យម រយៈពេលខ្លី។
គ. រៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សនិងគ្រប់គ្រងបុគ្គលិក។
ឃ. បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ និងស្វែងរកប្រភពជំនួយ។

### VII.5 ការវាយតម្លៃ និងសន្និដ្ឋានៈ

ដោយមានការចង្អុលណែនាំ ប្រកបដោយគតិបណ្ឌិតពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា និងក្រោមការដឹកនាំរបស់ឯកឧត្តមអគ្គនាយក អាជ្ញាធរអប្សរា មន្ត្រីបុគ្គលិកទាំងអស់ក្នុងនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយមនសិកាដែលលេចឡើងនូវលទ្ធផលការងារគួរឲ្យកត់សំគាល់ក្នុងឆ្នាំ២០០៩ ដូចដែលបានរៀបរាប់ខាងលើស្រាប់។

សំរាប់ឆ្នាំ២០១០ខាងមុខនេះ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានបានកសាងនូវទិសដៅការងារព្រមទាំងផែនការសកម្មភាពរបស់ខ្លួនបានច្បាស់លាស់ ដែលយើងខ្ញុំសង្ឃឹមថា ប្រជាជន មន្ត្រីរាជការដែលកំពុងរស់នៅនឹងប្រតិបត្តិការក្នុងឧទ្យានអង្គរពិតជាជួយការពារថែរក្សាព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានប្រកបដោយស្មារតីភ្ញាក់រលឹកខ្ពស់ពិសេសនឹងលះបង់នូវដីធ្លីដែលបានរំលោភបំពានយកធ្វើជាកម្មសិទ្ធិដោយខុសច្បាប់ ហើយមកចូលរួមដាំកូនឈើឡើងវិញដោយសហការយ៉ាងស្អិតរមួតជាមួយនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថានមិនខានឡើយ។

# VIII. នាយកដ្ឋានគ្រប់គ្រងទឹក

សកម្មភាពការងាររបស់នាយកដ្ឋានគ្រប់គ្រងទឹកនៅឆ្នាំ២០០៩ ពិតជាមមារញឹកយ៉ាងខ្លាំង។ ក្រៅពីគម្រោងពិសេសៗដែលកំពុងអនុវត្ត ដូចជាការអភិវឌ្ឍន៍ប្រកបដោយចិរភាពនៃបារាយខាងជើង និងបារាយទឹកថ្លា នាយកដ្ឋានត្រូវប្រឈមមុខនឹងទឹកជំនន់ដែលបង្កដោយព្យុះ កេតសាណា នៅដើមខែតុលា ឆ្នាំ២០០៩។

## ១. សកម្មភាពការងារសំខាន់ៗដែលកំពុងធ្វើ

ការងារកំពុងអនុវត្តនៅក្នុងនាយកដ្ឋានមានដូចជាៈ

-លទ្ធផលការងារផ្នែកទឹក និងបរិយាកាសដែលបានធ្វើមានៈ ប្រព័ន្ធទឹកបុរាណ ប្រព័ន្ធស្រោចស្រព ការវាស់ទឹកក្រោមដី ការបំពុលបរិយាកាស។

-សកម្មភាពការងារគម្រោងផ្សេងៗៈ គម្រោងបារាយណ៍ខាងជើង និងមជ្ឈមណ្ឌលលំនៅដ្ឋានខ្មែរ សួនគ្រឿងទេស គម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក គម្រោងបារាយណ៍ខាងលិច

### ១.១ សកម្មភាពការងារផ្នែកទឹក និងបរិយាកាស

#### ប្រព័ន្ធផ្លូវទឹកបុរាណ

-បន្តការងារថែទាំជួសជុលប្រឡាយដោយបិទរន្ធបាន៥កន្លែង និងថែទាំស្មៅដែលបានដាំរួចដើម្បីការពារកុំឲ្យបាក់ដីនៅខាងលិចប្រាសាទអង្គរវត្ត និងបានបង្ហូរទឹកចូលក្នុងកសិណាប្រាសាទអង្គរវត្ត។

-បន្តការងារថែទាំស្មៅដែលបានដាំការពារជើងទេរប្រឡាយបង្ហូរទឹកខាងលិចប្រាសាទអង្គរវត្ត និងធ្វើកិច្ចសហការជាមួយអាជ្ញាធរដែនដីដែលមានលោកមេភូមិគោកតាចាន់ក្នុងការទប់ស្កាត់ការកាប់បំផ្លាញប្រឡាយ និងធ្វើការអប់រំប្រជាពលរដ្ឋទាំងនោះ។

-សហការជាមួយមេឃុំនគរធំ ដើម្បីទប់ស្កាត់ការកាប់បំផ្លាញប្រឡាយបញ្ចូលទឹកក្នុងស្រះស្រង់(ប៉ែកខាងកើត) ដោយជនអនាធិបតេយ្យ។

-ចុះធ្វើការអប់រំប្រជាពលរដ្ឋក្នុងតំបន់ការពារតាមរយៈការបង្រៀនសិស្ស នៅវិទ្យាល័យសម្តេចឪ និងអនុវិទ្យាល័យអង្គរធំ អំពីសារសំខាន់នៃប្រព័ន្ធផ្លូវទឹក និងកាតព្វកិច្ចដែលប្រជាពលរដ្ឋត្រូវយល់ដឹង ដើម្បីជួយធ្វើការអភិរក្ស និងអភិវឌ្ឍន៍តំបន់ទេសចរណ៍របស់យើង។

-បន្តសិក្សាប្រព័ន្ធដោះទឹកតាមដងផ្លូវឡើងលើភ្នំបាខែង ដើម្បីការពារផ្លូវកុំឲ្យទឹកហូរច្រោះដាច់

-បានរៀបចំតំឡើងឧបករណ៍វាស់កំរិតកំពស់ទឹកស្វ័យប្រវត្តិចំនួន២ទីតាំងគឺ៖ នៅមាត់កសិណអង្គរវត្ត និងស្រះស្រង់ដើម្បីធ្វើការតាមដានកំរិតកំពស់ទឹកជាប្រចាំ។

-បានធ្វើការបញ្ចូលទឹកក្នុងត្រពាំងសេះ និងកសិណប្រាសាទអង្គរវត្ត ដើម្បីទប់ស្កាត់ការរីងស្ងួតក្នុងរដូវប្រាំង

-បានធ្វើការតាមដានត្រួតពិនិត្យបច្ចេកទេសសាងសង់សំណង់លូ៣ទីតាំង នៅខាងកើតស្រះស្រង់ ដែលសាងសង់រួចរាល់ដោយក្រុមហ៊ុន រ៉មធូហួន។

-បានបញ្ចប់ការងារជីកស្តារប្រឡាយមួយខ្សែប្រវែង១៨០០ម៉ែត្រ ខាងមុខប្រាសាទក្រវ៉ាន់ ដើម្បីបំពេញទឹកឲ្យកសិណប្រាសាទក្រវ៉ាន់ និងជួយដោះទឹកជំនន់ក្នុងតំបន់ដោយបានជួបពិភាក្សាជាមួយអាជ្ញាធរដែនដី លោកមេឃុំនគរធំ ដើម្បីធ្វើកិច្ចសហការ និងដោះស្រាយដីចំណីប្រឡាយដែលមានការពាក់ព័ន្ធនឹងប្រជាពលរដ្ឋ។

-ធ្វើការជួសជុលជើងទេរប្រឡាយបង្ហូរទឹកខាងលិចប្រាសាទអង្គរវត្ត ដែលហូរច្រោះដាច់ និងធ្វើការដាំដើមរំចេក ដើម្បីការពារខ្នងប្រឡាយ។

-ចុះសិក្សាទីតាំងសួនគ្រឿងទេសអាជ្ញាធរអប្សរា ដើម្បីរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក ដោយបានធ្វើការបោះបង្គោលកំណត់ទីតាំងស្រះ ប្រឡាយដែលត្រូវជី និងទីតាំងដែលត្រូវដាក់ស្ថានីយបូមយកទឹកពីស្ទឹងសៀមរាប

-ធ្វើការប៉ាន់ស្មានតម្លៃនៃការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកសួនគ្រឿងទេស

-ដាក់ម៉ាស៊ីនបូមទឹកចេញពីសួនគ្រឿងទេស ដែលជន់លិចដោយទឹកជំនន់ ដើម្បីអាចបន្តដំណើរការសាងសង់សួនគ្រឿងទេសបានលឿន។

-អនុវត្តការងារជីកប្រព័ន្ធទឹកក្នុងសួនគ្រឿងទេស នៅពេលនេះបានបញ្ចប់ជាស្ថាពរហើយ ដែលមានប្រវែងប្រមាណសរុប៨៤០ម និងបន្តអនុវត្តការងាររៀបចំកំរិតកំពស់ដីជុំវិញមាត់ខាងលើនៃប្រឡាយទឹកស្រះនិងអាងទទួលទឹក

-រៀបចំដំណើរការគម្រោងជីកប្រឡាយដោះទឹកជំនន់ចាប់ពីខាងជើងកែងផ្លូវ៦០ម ដល់ស្ទឹងសៀមរាបដែលមានប្រវែង១១០០ម

-ចុះធ្វើការសិក្សាពីលទ្ធភាព ដើម្បីបញ្ចូលទឹកក្នុងកសិណប្រាសាទចៅស្រីវិបុល

-សិក្សាទឹកដក់នៅសងខាងផ្លូវចាប់ពីខ្លោងទ្វារទន្លេធំ ដល់ប្រាសាទបាយ័ន ដើម្បីធ្វើការកែលំអសោភ័ណភាពទឹកអោយមានលក្ខណៈទ្រង់ទ្រាយល្អប្រសើរ ដែលរហូតដល់ពេលនេះបានប្រមូលទិន្នន័យរួច ដើម្បីគូសគំនូសកាត់ទទឹងដែលមានចំនួន៣៦មុខកាត់ទទឹង និងបន្តសិក្សាប្លង់លំអិត។

-ធ្វើការដោះទឹកដកចេញពីទីធ្លាសងខាងផ្លូវចូលប្រាសាទតាព្រហ្មប៉ែកខាងកើត ដើម្បីត្រៀមទទួលស្វាគមន៍គណៈប្រតិភូជាប្រធានាធិបតីនៃសាធារណៈរដ្ឋកូរ៉េ។

-ចុះធ្វើការសិក្សាវាស់កំរិតកំពស់ដីនៅទីតាំងខាងលិចក្លោងទ្វារតាកាវ ដែលទទួលរងនូវការបាក់តួផ្លូវកាលពីដើមខែតុលា ឆ្នាំ២០០៩ កន្លងទៅនេះ ដោយសារព្យុះកេតសាណា។

-ធ្វើការសង្គ្រោះទឹកជំនន់ចេញពីតំបន់អង្គរកាលពីដើមខែតុលា រួមមានៈ ធ្វើទំនប់ការពារទឹកជំនន់ពីស្ទឹងសៀមរាបកុំឲ្យហូរចូលកសិណាអង្គរវត្តដើម្បីបង្កើនល្បឿនដោះទឹកចេញ និងធ្វើការជីកស្តារប្រឡាយទឹក ដើម្បីដោះទឹកចេញពីកសិណាអង្គរវត្តជ្រុងខាងលិចឈាងខាងត្បូងប្រវែង៤០០ម។

-ធ្វើការជីកប្រឡាយទឹកដើម្បីដោះទឹកជំនន់កេតសាណាចេញពីកសិណាអង្គរវត្តជ្រុងខាងជើងដល់កសិណាអង្គរធំ

-ជីកប្រឡាយដោះទឹកជំនន់ចាប់ពីខាងជើសាលាSOS រហូតដល់ស្ទឹងសៀមរាបប្រវែង៧៥០ម ដើម្បីសង្គ្រោះសួនព្រៃឈើកាកបាទក្រហម។

## ១.២ ប្រព័ន្ធស្រោចស្រព

-ធ្វើការវាស់ធារទឹកនៅស្ពានបន្ទាយស្រី ស្ពានសាលាក្រវ៉ាន់ ស្ពានថ្មី ស្ពានអង្គរ ស្ពានពាក់ស្នែង ស្ពានក្រាំងក្រូចកោះអង្កាញ់ ស្ពានអន្លង់អាដូង ប្រឡាយភូមិគោកក្រើល ស្ពានប្រាសាទកែវ ស្ពានអាមេរិច ស្ពានភ្នំតូច អូត្រាំកងអូស្រែប្រាំង អូស្រះខ្វាវ អូជូនវេទ។

-គូសសំណង់ទ្វារទឹកត្រង់ចំណុចបង្ហូរទឹកចូលបារាយណ៍ខាងជើង

-បិទទំនប់នៅមុខសំណង់នៅប្រាសាទបន្ទាយស្រីចំនួន២កន្លែង

-ធ្វើឋានលេខានៅបារាយណ៍ខាងជើងចាប់ពីមុខប្រាសាទព្រះខ័នដល់ប្រាសាទនាគព័ន្ធ ទៅដល់ក្រាំងក្រូចតាមខ្នងទំនប់ចាស់ និងនៅប្រឡាយខ្មែរក្រហម

-ប៉ាន់ស្មានតម្លៃសំណង់លូជ្រុងនៅផ្លូវគ្រួសក្រហម និងសំណង់លូជ្រុង សំណង់លូមូលមានទ្វារទឹកនៅវត្តអង្គប្រមោល

-សិក្សាប្រព័ន្ធប្រឡាយស្រោចស្រពនៅជិតប្រាសាទក្រវ៉ាន់ ប្រវែង៥៨៥ម

-ជីកប្រឡាយពីកសិណាខាងជើងអង្គរវត្តឆ្ពោះទៅកសិណាអង្គរធំដែលមានប្រវែង១០២០ម

-ធ្វើឋានលេខានៅប្រាសាទនាគព័ន្ធ និងតាមដានកំពស់ទឹក ដើម្បីដឹងនូវស្ថេរភាពរបស់ប្រាសាទ

-ចុះសិក្សាប្រព័ន្ធប្រឡាយពីរខ្សែនៅក្បែរវត្តព្រះដាក់ប្រវែង២០០០ម ចំនួន០១ខ្សែ និង១ខ្សែទៀតភ្ជាប់ពីប្រឡាយមកពីទំនប់តានាវ មកដល់ផ្លូវវង់ធំចំងាយ១៥០០ម

-ធ្វើឋានលេខានៅប្រាសាទនាគព័ន្ធ និងតាមដានកំពស់ទឹក ដើម្បីដឹងនូវស្ថេរភាពរបស់ប្រាសាទ

-បន្តសិក្សាប្រព័ន្ធផ្លូវទឹកក្នុងគម្រោងបញ្ចូលទឹកបារាយណ៍ខាងជើង។

-បារាយណ៍ខាងជើងទទួលទឹកជំនន់កេសាណាកាលពីពេលកន្លងមក២,៩លានម៉ែត្រគូប សង្គ្រោះភូមិលាងដៃ,ភូមិក្លង់,ភូមិតាប្រុក,ភូមិដូនឪ,ស្ថិតក្នុងឃុំ លាងដៃ ស្រុកអង្គរធំ ទិសខាងជើងអោយរួចផុតពីគ្រោះមហន្តរាយ។

## ១.៣ ប្រព័ន្ធទឹកក្រោមដី

-ចុះបង្រៀនកម្មករពីរបៀបវាស់កំរិតកំពស់ទឹកអណ្តូងលូនៅភូមិតាឯក ភូមិស្រែចង្ហូតក និងភូមិអូរទទឹង ឃុំព្រះ

ដាក់

-យកសំណាកទឹកស្ទឹងសៀមរាបទៅមន្ទីរពិសោធន៍ក្រសួងបរិស្ថាន ដោយយកសំណាកទឹកចំនួន២ដង នៅ៣ទីតាំងគឺៈ ទំនប់បារាំង ស្ពានវត្តដំណាក់(ផ្សារចាស់) ស្ពានតាដូង(ភ្នំក្រោម) និងធ្វើការពិសោធន៍ចំនួន២ដង។

-ចុះវាស់ទឹកអណ្តូងក្រោមដីតាមបច្ចេកទេសរបស់អ្នកប្រឹក្សាជនជាតិឥណ្ឌានៅភូមិព្រះដាក់

-ចុះវាស់ទឹកអណ្តូងក្រោមដី នៅភូមិក្លង់ នៅប្រាសាទបាគង និងនៅតំបន់រុនតាឯក

-ចុះទៅភូមិត្រពាំងស្វាយ ភូមិដូនឪ ភូមិគោកគ្រៀល ឃុំលាងដៃ ភូមិត្រាចជ្រុំ និងភូមិបុស្សធំ ឃុំអំពិល ភូមិតាកុះ ស្រុកបន្ទាយស្រីរាប់អណ្តូងទឹកក្រោមដីបន្ថែម

-ចុះទៅជាមួយរដ្ឋាករទឹកខេត្តសៀមរាប ដើម្បីរកទីតាំងដាក់ស្ថានីយតាមដានបម្រែបម្រួលទឹកក្រោមដី

-ចុះពិនិត្យទីតាំងសំរាប់ស្ថានីយបម្រែបម្រួលទឹកក្រោមដី២កន្លែងដែលស្ថិតនៅៈ សាលាបឋមសិក្សាក្រវ៉ាន់ និងសាលាបឋមសិក្សាខ្នៀន។

### ១.៤ ការបំពុលបរិយាកាស

-នាយកដ្ឋានបានធ្វើការពិសោធន៍គុណភាពអាកាសធាតុបានចំនួន២លើក ដែលធ្វើឡើងនៅដំណាក់ព្រះអង្គចេកព្រះអង្គចម និងនៅក្នុងបរិវេណប្រាសាទអង្គរវត្ត និងនាយកដ្ឋានគ្រប់គ្រងទឹក(អាគារកូអ៊ិច) ដែលត្រូវចំណាយពេល១២ម៉ោងក្នុងមួយថ្ងៃ។

-នាយកដ្ឋានធ្វើការដាក់ឧបករណ៍ឧតុនិយមនៅទីតាំង៣កន្លែងគឺៈ នៅទីស្នាក់ការអាជ្ញាធរអប្សរាភ្នំពេញ នៅសួនគ្រឿងទេស និងនៅលើភ្នំគូលែន(វត្តព្រះក្រាល)។ ក្រុមការងារយកទិន្នន័យពីឧបករណ៍ចំនួន២កន្លែងៈ នៅសួនអាជ្ញាធរអប្សរា និងនៅលើភ្នំគូលែនតាមកាលបរិច្ឆេទដូចតទៅៈ នៅសួនអាជ្ញាធរអប្សរាធ្វើឡើងរៀងរាល់ដើមសប្តាហ៍ និងនៅភ្នំគូលែនរៀងរាល់ចុងខែ ដោយឡែកនៅទីស្នាក់ការអាជ្ញាធរអប្សរាភ្នំពេញមានកុំព្យូទ័រសំរាប់ផ្ទុកទិន្នន័យរួចជាស្រេច។

-ការងារតំឡើងឧបករណ៍តាមដានអាកាសធាតុរួចនៅៈ ស្ថានីយចៅស្រីវិបុល និងស្ថានីយវត្តស្លាតវជ័យ។

## ២. គម្រោង

### ២.១ បារាយណ៍ខាងជើង

| ល.រ | សកម្មភាព ការងារ | ស្ថានីយបណ្តុះរុក្ខជាតិ ការពារផ្លូវទឹកក្រាំងក្រូច | ស្ថានីយបណ្តុះរុក្ខជាតិ ផ្កាព្រៃ(ប្រាសាទព្រះខ័ន) | សួនរុក្ខជាតិផ្កាព្រៃ នៅបារាយណ៍ខាងជើង |
|---|---|---|---|---|
| ១ | បណ្តុះរុក្ខជាតិ/ផ្កា | -អង្គារដី,រលួសបាយ,ផ្កាចន្ទ | -ក្ងោក,រលួសបាយ,អង្គារដី | - |
| | | ផ្កាទួនស្រី សរុប១៩៥៣ដើម | ថ្កុល,ត្របែកព្រៃ,ក្ងោកតូច,អង្គារបុស្ស សរុប៤៨៥០ដើម | |
| ២ | ប្រមូលគ្រាប់ពូជ | -ត្របែព្រៃ,លឿងរាជ, រលួសបាយ,អង្គារដី,អង្គារបុស្ស, | -ត្របែកព្រៃ,លឿងរាជ,អង្គារដី, ក្ងោក,ថ្កុល,រលួសបាយ,អង្គារបុស្ស | - |

| | | | | |
|---|---|---|---|---|
| | | ក្ងោកតូច | សរុប៥០០គីឡូក្រាម | |
| ៣ | ការដាំ | - | - | -ដាំល្មៀងរាជ,គគីរ,ឈើទាល,កូនក្ងោក សរុប ៥១៧០ដើម |
| ៤ | ដាំស្មៅតាមជើងទេរស្រះ | - | -៣០៩៦មការ៉េ | - |
| ៥ | ការងារផ្សេងៗ | -ដាំដើមរំពាក់ជុំវិញកន្លែងតាមដានធាតុអាកាសនៅស្ថានីយបណ្តុះរុក្ខជាតិ ការពារផ្លូវទឹកបានចំនួន២៦៣៩គុម្ព<br>-ធ្វើផ្លូវរវាងថ្មីនៅចាប់ពីកន្លែងស្ថានីយតាមដានអាកាសធាតុមករោងយាមក្រាំងក្រូច<br>-ស្តារប្រឡាយបង្ហូរទឹកចូលបារាយណ៍ខាងជើងប្រវែង ១៧២ម<br>-ថែទាំ និងបោសសំអាតថ្នាលជាប្រចាំ | -ស្រោចស្រពកូនឈើដែលបានបណ្តុះ,ផ្លាស់ប្តូរថង់កូនឈើនិងប្តូរទីតាំង<br>-ឆ្ការព្រៃ និងគាស់គល់ដើមឈើដើម្បីដាក់ឧបករណ៍តាមដានធាតុអាកាសបានចំនួន ១២៥០ម៉ែត្រការ៉េ<br>-ដាំស្មៅសងខាងសៀគ្វីនៅកន្លែងហូរច្រោះបានប្រវែង១២០០ម។ | -ស្រោចស្រពកូនឈើដែលបានបណ្តុះ,ផ្លាស់ប្តូរថង់កូនឈើ និងប្តូរទីតាំង<br>-ជួសជុលរោងជ្រកទឹកភ្លៀងនៅជិតស្រះធំបានចំនួន១កន្លែង<br>-ចាក់ដីរៀបចំសៀគ្វីចំណុចពីស្រះធំឡើងទៅទំនប់ចំណុចទស្សនា<br>-ធ្វើការយាមល្បាតជាប្រចាំ |

**ការងារកំណាយសង្គ្រោះនៃបារាយណ៍ខាងជើង៖**

-ចុះអង្កេតនៅផ្នែកខាងជើងឈៀងខាងកើតនៃបារាយណ៍ខាងជើងតាមបណ្តោយមាត់ស្ទឹងសៀមរាប ដើម្បីតាមរកប្រព័ន្ធផ្លូវទឹក និងស្លាកស្នាមបុរាណវិទ្យាមួយចំនួនដែលទាក់ទងនឹងផ្លូវទឹកបុរាណ។ ក្រុមការងារបានចុះធ្វើការអង្កេតបន្តតាមបណ្តោយខ្នងទំនប់បារាយណ៍ផ្នែកខាងត្បូងនៃបារាយណ៍ជើង គឺតាមបណ្តោយប្រឡាយទឹករហូតដល់មាត់ស្ទឹងក្បែរទំនប់បារាំង

-ធ្វើការអង្កេតនៅប៉ែកខាងត្បូងនៃបារាយណ៍ខាងជើងតាមបណ្តោយស្ទឹងសៀមរាប ដើម្បីពិនិត្យមើលស្លាកស្នាមព្រមទាំងសិល្បៈផ្សេងៗ

-ចុះមើលការងារនៅកន្លែងធ្វើទ្វារទឹកសំរាប់បញ្ចូលទឹកទៅក្នុងបារាយណ៍ខាងជើង និងធ្វើកំណាយនៅត្រង់ទំនប់បារាយណ៍ខាងជើង ដោយធ្វើការបើករណ្តៅកំណាយសរុបទាំងអស់ចំនួន៧រណ្តៅ។

-ស្រង់ទិន្នន័យគូសស្រទាប់ដី វិភាគស្រទាប់ដី ដើម្បីចងក្រងជារបាយការណ៍នឹងទុកជាឯកសារ

-គ្រោងធ្វើការសិក្សា និងកំណាយបន្តនៅក្នុងបរិវេណបារាយណ៍ខាងជើង ពិសេសនៅជុំវិញប្រាសាទនាគព័ន្ធ

-ចុះអង្កេតនៅតាមទំនប់បុរាណ ដើម្បីជ្រើសរើសទីតាំងក្នុងការបើកការដ្ឋានសម្រាប់កំណាយនៅឆ្នាំ២០១០

-រៀបចំឯកសារសំរាប់បើកការដ្ឋាន ផែនទី និងស្នើសុំសម្ភារៈសំរាប់ប្រើប្រាស់ពេលកំណាយ។

**២.២ មជ្ឈមណ្ឌលលំនៅដ្ឋានខ្មែរ**

-ការងារដាំដុះ៖ ដាំល្ហុង ៣៣ដើមតាមព្រំ សណ្តែកទ្រើង២រង ពោត៣រង ត្រកួន២រង ប៉េងប៉ោះ៣រង ស្ពៃ៤រង ជីក្រហម២រង ជីនាងវង១រង សាឡាត់១រង ស្វាយ២ដើម ខ្នុរ៣ដើម ដាំSpinach ២រង Dill ១រង Esparagus ១រង ទៀបខ្មែរ ៩ដើម ម្រំ៦៣ដើម ម្រេច១គុម្ព និងធ្វើការដាំព្រលិតក្នុងស្រះ និងប្រឡាយចំនួន៨១គុម្ព ម្ទេសប្លោក១រង ម្រះព្រៅ១រង លៀន២រង Larosa ១រង សណ្តែកកួរ២រង ពោតបារាំង២រង Chicoree Frisee ២រង Chou de Bruxelles ១រង Laitue Pommee ១រង ម្ទេស១រង ផ្ទីរដូង១រង ជីរណា១រង ជីក្រសាំងទំហំ១រង ជីផ្កាល់ត្រី១រង ត្រសក់ស្រូវ១រង ស្ពៃចង្កឹះ១រង ដំឡូងមី១រង ដំឡូងជ្វា១រង។ និងដាំផ្កាស្បៃរឿង១២៨៥ដើម ផ្កាក្រចក៩៦១ដើម ផ្កាទ្រនិចឃ្មុំ៩៧៦ដើម ផ្កាឈូករ័ត្ន២៩៧ដើម សិរមាន់១០១៣ដើម ផ្កាទំហ៊ុំ៦៥១ដើម ផ្កាកង្ហារ៧១០ដើម ដើមជើងមាន់២០៤៨ដើម កន្ទុយមាន់២៤២ដើម រំដួលសុរិន្ទ ៦០ដើម ផ្កាកំពីងពួយ២៣ដើម ផ្កាម៉ោងដប់៦៨,៥មការ៉េ ផ្កាត្រចុក៣៧គុម្ព ផ្កាចិញ្ចៀន៥៤ដើម។

-ការងារធ្វើជីកំប៉ុស្ត៍៖ ក្រុមហ៊ុន HCC បានដឹកស្លឹកឈើចូលសំរាប់ធ្វើជី២២ឡាន និងយកពើកពីកសិណអង្គរ ១៥៨២បាវ សារាយសំរាប់ធ្វើជីចំនួន៣២រទេះ(ស្រះស្រង់)។ ដោយការរែងជីសរុបបានចំនួន១៧,៣៥មការ៉េ នឹងចែកទៅតាមការដ្ឋានក្រាំងក្រូច បារាយណ៍ខាងជើង និងធ្វើការគ្រលប់ជីជាប្រចាំ។

-ការងារធ្វើសំណង់លូខាងមុខលំនៅដ្ឋានខ្មែរប្រវែង១៦ម

-សំអាតស្តារបាតប្រឡាយប្រវែង៧៤,៨ម

-ដាំស្មៅតាមជំរាលប្រឡាយការពារហូរច្រោះ៣៥៦,១មការ៉េ

-ច្រកដីដាក់ថង់សំរាប់បណ្តុះបានចំនួន៧៥៧២ថង់

-ដាំស្មៅបារាំងអមមាត់ប្រឡាយខាងមុខបានចំនួន២៦២,៦៩មការ៉េ

-ធ្វើការថែទាំ និងបោសសំអាតទីធ្លាលំនៅដ្ឋានខ្មែរ។

# IX. នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ

ចាប់តាំងពីត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៨មក នាយកដ្ឋានអភិវឌ្ឍវប្បធម៌ សារមន្ទីរនិងបទដ្ឋានបេតិកភណ្ឌបានសម្រេចបេសកកម្មរបស់ខ្លួនបានមួយចំនួនធំទោះបីជាខ្វះបុគ្គលិកយ៉ាងណាក្តី។ បុគ្គលិកមួយចំនួនបានសម្រេចចិត្តនៅបម្រើការអោយនាយកដ្ឋានអភិវឌ្ឍទេសចរដដែល។

របាយការណ៍សកម្មភាព៦ខែដើមឆ្នាំ២០០៨បានផ្តោតទៅលើការរៀបចំផ្នែកផ្សេងៗ យោងទៅតាមតម្រូវការជាក់ស្តែងភ្លាមៗ។ រចនាសម្ព័ន្ធដែលត្រូវបានអនុម័តចំពោះនាយកដ្ឋាននេះមានដូចខាងក្រោម៖

១. ការិយាល័យសម្របសម្រួលនិងគាំទ្រសកម្មភាព

២. ការិយាល័យទំនាក់ទំនងសាធារណៈ

៣. ការិយាល័យរៀបចំនិងគ្រប់គ្រងផលិតផលវប្បធម៌

៤. ការិយាល័យបទដ្ឋានបេតិកភណ្ឌ

៥. ការិយាល័យអភិវឌ្ឍវប្បធម៌

៦. សារមន្ទីរព្រះនរោត្តមសីហានុ អង្គរ

## IX.1 **ការិយាល័យសម្របសម្រួលនិងគាំទ្រសកម្មភាព**

**ការងាររដ្ឋបាលៈ**

- ការិយាល័យសម្របសម្រួលទូទៅ ក្រោមការត្រួតពិនិត្យផ្ទាល់របស់នាយិការនិងអនុប្រធាន និងមានជំនួយការ៥រូប មានភារកិច្ចទទួលនិងឆ្លើយតបលិខិតផ្សេងៗទាក់ទងនឹងកិច្ចការរបស់នាយកដ្ឋាន ដោយសហការជាមួយការិយាល័យនៅភ្នំពេញ។
- ពាក្យសុំរៀបចំព្រឹត្តិការណ៍វប្បធម៌នៅពេលយប់ សុំថត ព្រមទាំមសុំចូលអង្គរដោយឥតគិតថ្លៃ ទាំងរយៈពេលវែងនិងរយៈ ពេលខ្លីរបស់អ្នកស្រាវជ្រាវ ដែលបញ្ជូនទៅដល់មជ្ឈមណ្ឌលសេវារបស់អាជ្ញាធរជាតិអប្សរា ត្រូវបានរៀបចំដើម្បីដាក់ជូនអគ្គនាយកពិនិត្យនិងចុះហត្ថលេខា ក្នុងនោះចំនួនអ្នកស្រាវជ្រាវរយៈពេលខ្លី(០១-០៣ខែ) ដែលបានចេញចូលតំបន់រមណីយដ្ឋានអង្គរមាន ចំនួន៥៨១រូប និងបានចេញជាកាតសំរាប់អ្នកស្រាវជ្រាវរយៈពេល០១ឆ្នាំ ចំនួន១៥៨រូប។
- គ្រប់គ្រងការងាររដ្ឋបាលរបស់នាយកដ្ឋានជាប្រចាំដូចជាៈ វត្តមានបុគ្គលិក ការប្រើប្រាស់សម្ភារៈ កត់ត្រាលិខិតចេញ-ចូល និងមធ្យោបាយធ្វើដំណើរការចាត់តាំង ។ល។

**ការងារសម្របសម្រួលៈ**

- នាយកដ្ឋានត្រូវសម្របសម្រួលទំនាក់ទំនងជាមួយនាយកដ្ឋានផ្សេងទៀតរបស់អាជ្ញាធរជាតិអប្សរា ដោយធានាផងដែរនូវទំនាក់ទំនងជាមួយសារមន្ទីរដែលគ្រប់គ្រងដោយនាយកដ្ឋាន។
- បុគ្គលិករដ្ឋបាលជួយនាយិការនាយកដ្ឋានក្នុងកិច្ចការរបស់ សេ អ៊ី សេ ដូចជាកិច្ចការរៀបចំការប្រជុំចតុភាគីនៃសម័យប្រជុំបច្ចេកទេសលើកទី១៨ តាមដានការអនុវត្តអនុសាសន៍របស់អ្នកជំនាញ អាដ ហុក ទាំងផ្នែកអភិរក្សក៏ដូចជាអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការអនុវត្តអនុសាសន៍សម័យប្រជុំពេញអង្គលើកទី១៦កាលពីខែធ្នូ២០០៩។

## IX.2 **ការិយាល័យទំនាក់ទំនងសាធារណៈ**

**ការអង្កេតសាធារណៈ**

- ភ្នាក់ងារអង្កេតសាធារណៈបានចុះទៅបំពេញការងារជាមួយក្រុមទទួលបន្ទុកវង់ទស្សនាវប្បធម៌ ដើម្បីចូលរួមការអនុវត្តសាកល្បងខ្សែទស្សនានៅប្រាសាទបន្ទាយស្រី ដែលនឹងត្រូវដាក់ឲ្យអនុវត្តដោយនាយកដ្ឋាន អភិវឌ្ឍន៍ទេសចរណ៍អង្គរ។ ទន្នន័យដែលទទួលបានពីការសាកល្បងនេះនឹងត្រូវវិភាគ ហើយកែសំរួលឡើងវិញ ដើម្បីសំរបឲ្យស៊ីគ្នាជាមួយនឹងខ្សែទស្សនាទូទៅនៃទីលានប្រាសាទបន្ទាយស្រី។
- ភ្នាក់ងារអង្កេតសាធារណៈចូលរួមបំពេញការងារវង់ទស្សនាប្រាសាទបាយ័ន និងប្រាសាទតាព្រហ្មតាមរយៈការរាប់ចំនួនភ្ញៀវ។

- ចូលរួមរាប់ចំនួនរថយន្ត នៅលើផ្លូវវាងពីទឹកវិលទៅចុងកៅស៊ូ សំរាប់នាយកដ្ឋាន ហិរញ្ញកិច្ច និងគណនេយ្យ
- ចូលរួមរាប់ចំនួនឡាន លើផ្លូវវាងចំនួន២ខ្សែ ផ្លូវវាងខាងកើតអង្គរ ពីស្ពាយធំទៅព្រះដាក់ និងផ្លូវវាងខាងលិចអង្គរ ពីសាលារៀនគ្រូសទៅបាឡាំងរបស់ក្រុមហ៊ុនសុខាអូតែល សំរាប់ការិយាល័យផ្លូវថ្នល់នៃនាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ។
- ត្រូវការបុគ្គលិកអង្កេតភៀវបន្ថែមសំរាប់គម្រោងការអភិវឌ្ឍន៍តំបន់ស្រះស្រង់ និងគម្រោងអភិវឌ្ឍន៍សហគមន៍ (NZaid) ហើយនិងចាប់ផ្តើមចូលរួមរៀបចំទីលានប្រាសាទតាព្រហ្ម។

## ការងារដែលសម្រេចបានជាមួយភ្នាក់ងារសាធារណៈ

- ចំនួនអ្នកទសចរនៅអង្គរកើនឡើងឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ អ្នកទេសចរអន្តរជាតិមួយចំនួនមិនយល់អំពីលក្ខណៈដ៍ពិសិដ្ឋនៃឧទ្យានអង្គរ បានស្លៀកពាក់មិនសមរម្យ។ នាយកដ្ឋានកំពុងរៀបចំសម្ភារៈផ្សព្វផ្សាយសាធារណៈ។ ក្រុមមួយនៃការិយាល័យបទដ្ឋានបិតិភណ្ឌនឹងទទួលបន្ទុកត្រួតពិនិត្យមើលនៅតាមប្រាសាទ។
- មានក្រុមមួយនឹងទទួលបន្ទុកពិនិត្យមើលអត្ថបទនិងសៀវភៅដែលចុះផ្សាយអំពីអរិយធម៌និងវប្បធម៌ខ្មែរ មើលបើមានកំហុស អោយគេកែឡើងវិញ (សៀវភៅមគ្គុទេសក៍ និងសៀវភៅផ្សេងៗទៀត)។

## ការងារសហប្រតិបត្តិការអន្តរជាតិ

- **ជាមួយប្រទេសបារាំង**

  + បំពេញប៉េសកកម្មធ្វើអត្តសញ្ញាណកម្មគម្រោងអាជ្ញាធរជាតិអប្សរា ដែលផ្តល់ថវិកាដោយភ្នាក់ងារអភិវឌ្ឍបារាំង

  + ប្រជុំអន្តរក្រសួងវាយតម្លៃកិច្ចសហប្រតិបត្តិការបារាំងខ្មែរ នៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិបារាំង លើគម្រោងទាំងអស់ដែលផ្តល់ប្រាក់ដោយប្រទេសបារាំង។

  + ប៉េសកកម្មធ្វើអត្តសញ្ញាណកម្មអ្នកជំនាញភ្នាក់ងារអភិវឌ្ឍបារាំងម្នាក់ ក្នុងគម្រោងអាជ្ញាធរអប្សរាដែលផ្តល់ប្រាក់ដោយ AFD និង FSP និង ការប្រជុំអន្តរក្រសួងវាយតម្លៃកិច្ចសហប្រតិបត្តិការបារាំងខ្មែរ នៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិបារាំង។

  + ទទួលនិងជូនគណប្រតិភូក្រុមហ៊ុន CVIPOL ដែលមានជំនាញខាងសុវត្ថិភាពស៊ីវិល និងជាស្ថាប័នមួយចំណុះអោយក្រសួងមហាផ្ទៃបារាំង។ ក្រុមហ៊ុន CIVIPOL ចង់ផ្តល់ជំនួយបច្ចេកទេសរបស់ខ្លួនដល់អាជ្ញាធរជាតិអប្សរា ក្នុងការអភិវឌ្ឍភូមិធម្មជាតិ រុន តាឯក និង សុវត្ថិភាពអ្នកទេសចរនៅក្នុងឧទ្យានអង្គរ និងតំបន់សៀមរាប។

- **ជាមួយប្រទេសផ្សេងទៀត**

  + ជូនគណៈប្រតិភូរបស់ UNDP ដែលមកពី New York

  + ជូនគណៈប្រតិភូ វិទ្យាស្ថាន SMITSONIAN របស់សហរដ្ឋអាមេរិក និងបង្ហាញជូននូវគម្រោងអភិរក្សនិងអភិវឌ្ឍវប្បធម៌របស់អាជ្ញាធរជាតិអប្សរា

  + រៀបចំប៉េសកកម្មអ្នកសារព័ត៌មានជនជាតិអ៊ីតាលីម្នាក់ របស់ទស្សនាវដ្តី ARCHEO (បុរាណវិទ្យា) ដើម្បីសរសេរអត្ថបទមួយស្តីពីអង្គរ និងទទួលគណៈប្រតិភូមកពីសាកលវិទ្យាល័យ Palerme ដែលមកវាយតម្លៃស្ថានភាពនៃរូប

ចម្លាក់នៅក្នុងអភិរក្សដ្ឋានអង្គរ ក្នុងគោលបំណងបង្កើតគម្រោងទ្វេរភាគីនៃកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ។

+ ទទួលនិងបង្ហាញជូននូវការងារអភិរក្សឧទ្យានអង្គរ ជូនដល់អភិរក្សករ មកពីសារមន្ទីរ Galouste Gulbenkian ប្រទេស Portugal។

+ ចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីទេសចរណ៍និងវប្បធម៌។

## IX.3 ការិយាល័យរៀបចំនិងគ្រប់គ្រងផលិតផលវប្បធម៌

នាយកដ្ឋានកំពុងរៀបចំជ្រើសរើសបុគ្គលិក ដើម្បីរៀបចំបង្កើតក្រុមទទួលបន្ទុករៀបចំនិងពិនិត្យផលិតផលវប្បធម៌ដែលត្រូវបានរៀបចំនិងលក់ដោយភ្នាក់ងារផ្សេងៗនៅក្នុងឧទ្យានអង្គរ។

- **ការគ្រប់គ្រងផលិតផលវប្បធម៌**

  + នៅជិតៗប្រាសាទនិងនៅកន្លែងលក់ដូរក្នុងប៉ាកវី បន្ទាយស្រី មានបុគ្គលិកមួយក្រុមផ្តល់ការណែនាំដល់អ្នកលក់អោយលក់ផលិតផលក្នុងស្រុក ដើម្បីជួយលើកតម្លៃវប្បធម៌ខ្មែរនៅក្នុងតំបន់អង្គរ ជាពិសេសចំពោះអ្នកទេសចរអន្តរជាតិ។

  + បុគ្គលិកមួយក្រុមទទួលបន្ទុកពិនិត្យមើលការប្រព្រឹត្តិទៅនៃការរៀបចំព្រឹត្តិការណ៍សិល្បៈ វប្បធម៌ នៅតាមប្រាង្គប្រាសាទនានា ដូចជា ប្រាសាទបាយ័ន ក្រវ៉ាន់ ធម្មនន បន្ទាយសម្រៃ វត្តអត់ទ្វារ។ល។

- **ការរៀបចំព្រឹត្តិការណ៍វប្បធម៌**

  + បុគ្គលិកមួយក្រុមនឹងចូលរួមរៀបចំព្រឹត្តិការណ៍វប្បធម៌ ដើម្បីជួយក្រុមហ៊ុនពិនិត្យរកទីកន្លែង ឬក្រុមហ៊ុនដែលបានទទួលការអនុញ្ញាតផ្លូវការ យើងជួយផ្តល់យោបល់លើគុណភាពទស្សនីយភាពវប្បធម៌ដល់ក្រុមហ៊ុនទាំងនោះ។

## IX.4 ការិយាល័យបទដ្ឋានបេតិកភណ្ឌ

ក្រុមមួយដែលមានបុគ្គលិក១៥រូបនឹងត្រូវបានបង្កើតឡើងដើម្បីអនុវត្តបទដ្ឋានបេតិកភណ្ឌនៅក្នុងឧទ្យានអង្គរ។

- អនុសញ្ញា សេចក្តីប្រកាស អនុសាសន៍ គឺជាគ្រឹះសម្រាប់ការបណ្តុះបណ្តាលភ្នាក់ងារនៃការិយាល័យនេះ ដែលទទួលបន្ទុកត្រួតពិនិត្យនៅតាមទីកន្លែងផ្ទាល់។
- ការិយាល័យបានចូលរួមក្នុងការរៀបចំបទបញ្ជាដើម្បីគ្រប់គ្រងឧទ្យានអង្គរះ

  + រៀបចំកិច្ចសន្យានៃការជួលទីតាំងជូនឯកឧត្តមអគ្គនាយកពិនិត្យ សំរេច និងរៀបចំក្រុមការងារចុះត្រួតពិនិត្យវប្បធម៌

  + បានបញ្ចប់កំណែផ្ទាំងព័ត៌មានចំនួន៣០ផ្ទាំង សំរាប់ការដាក់តាំងពិព័រណ៌នៅក្នុងមជ្ឈមណ្ឌលបកស្រាយព័ត៌មានប្រាសាទបន្ទាយស្រី ដែលពិនិត្យផ្ទាល់ដោយឯកឧត្តមអគ្គនាយកអាជ្ញាធរអប្សរា និងកំពុងរង់ចាំធ្វើការបោះពុម្ព។

  + កំពុងសិក្សាដើម្បីបង្ហាញពីគំរូស្លាកដែលមានលក្ខណៈស៊ីសង្វាក់គ្នាតែមួយនៅក្នុងរមណីយដ្ឋាន។

  + ចុះត្រួតពិនិត្យការថតរូបភាពដោយក្រុមចល័តនៅក្នុងរមណីយដ្ឋានអង្គរ។

  + ប្រជុំការងារនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បំពេញការងារជាមួយឯកឧត្តមអគ្គនាយក នាយកដ្ឋានរដ្ឋបាល

បុគ្គលិក និងសម្ភារៈ និងនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ លើអនុក្រឹត្យស្តីពីការការពារឈ្មោះ និងរូបភាពអង្គរ។

+ បានធ្វើការជ្រើសរើសបុគ្គលិកចំនួន១៥រូប សំរាប់ក្រុមការងារការពាររូបភាពតាមប្រាសាទ ដោយឆ្លងកាត់ការសម្ភាសន៍ពីប្រធាននាយកដ្ឋាន និងបានទទួលសេចក្តីសំរេចឲ្យចូលបំរើការងារចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១០តទៅ។

+ ច្បាប់ការពាររូបភាពត្រូវប្រជុំជាអន្តរវិស័យ ដើម្បីកំណត់ច្បាប់ការពាររូបភាពសំរាប់តែអាជ្ញាធរអប្សរាប្រើប្រាស់ជាមុនសិន។ ចំណែកច្បាប់ការពាររូបភាពប្រាសាទទូទាំងប្រទេសនឹងរៀបចំឡើងនៅពេលក្រោយ ក្រោមការណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន។

+ នាយកដ្ឋានបានសរសេរច្បាប់ការពាររូបភាព ប្រជុំអន្តរក្រសួង និងនាយកដ្ឋានពាក់ព័ន្ធរបស់អាជ្ញាធរអប្សរា។

+ ការងារអនុវត្តវិញ្ញាបនបត្រ ISO ១៤០០១ កំពុងបន្ត ដោយភ្នាក់ងារនាយកដ្ឋានដែលទទួលបន្ទុកតាមដានការគោរពបរិស្ថាន នៃសកម្មភាពផ្សេងៗ។

## IX.5 ការិយាល័យអភិវឌ្ឍវប្បធម៌

### ការងាររបស់សាស្ត្រាចារ្យ Sahai Sachchidanand

- ជួបរៀបចំសៀវភៅស្តីពីប្រាសាទព្រះវិហាររបស់លោកសាស្ត្រាចារ្យ Sahai Sachchidanand បានបញ្ចប់ការបោះពុម្ពនៅខែកញ្ញា និងបានដាក់បង្ហាញជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ពិនិត្យរួចរាល់។ គាំទ្រដល់ការសិក្សារបស់លោកសាស្ត្រាចារ្យ Sahai អំពីខ្សែទស្សនានៅប្រាសាទផ្សេងទៀតដែលនាំឲ្យមានការបង្កើតបានជា Le Grand Banteay Srei ដើម្បីផ្តល់តម្លៃដល់ហេដ្ឋារចនាសម្ព័ន្ធដែលមាននៅជុំវិញទីលានប្រាសាទដោយលោកសាស្ត្រាចារ្យកំពុងតែធ្វើការរៀបចំ ហើយនាយកដ្ឋានកំពុងតែរង់ចាំលទ្ធផលពីគាត់។

### ការរៀបចំទីលានប្រាសាទបន្ទាយស្រីៈ

- គ្រប់គ្រងការងាររៀបចំទីលានប្រាសាទបន្ទាយស្រី បានសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ប្រធានអាជ្ញាធរអប្សរា ឯកឧត្តមឯកអគ្គរដ្ឋទូតស្វីស និងដោយមានវត្តមានរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាប្រតិបត្តិរបស់អង្គការយូណេស្កូ។ បន្តឲ្យតំលៃបរិស្ថានរបស់ប្រាសាទ ជាពិសេសលើផែនការទេសភាព និងបន្តការងារតាមដានរាល់រចនាសម្ព័ន្ធនៅក្នុងទីលាន Parvis ទាំងមូលដោយធ្វើការជួសជុលបើមានការខូចខាត។
- បានធ្វើការជួសជុលសំណង់ដំបូលមណ្ឌលបកស្រាយព័ត៌មាន និងផ្លាកសញ្ញាព័ត៌មានមួយចំនួន នៅទីលានប្រាសាទបន្ទាយស្រីដែលបង្កមកពីខ្យល់ព្យុះបានធ្វើឲ្យដើមឈើធំមួយដើម ដែលស្ថិតនៅចំកណ្តាលទីលានប្រាសាទបន្ទាយស្រី បាក់ធ្លាក់មែកចុះមកបណ្តាលឲ្យខូចខាតដំបូល និងស្លាកសញ្ញាព័ត៌មាន។
- ចំណតរថយន្តនៅក្នុងទីលានប្រាសាទបន្ទាយស្រីបានបើកឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០០៩។
- គណៈប្រតិភូស្វីសបានចុះមកធ្វើទស្សនកិច្ចនៅទីលានប្រាសាទបន្ទាយស្រី។ រីឯតូបអ្នកលក់ដូរក៏បានផ្លាស់ប្តូរមកកាន់ទីលានតាំងថ្មីរួចរាល់ ហើយការគ្រប់គ្រងទីលានប្រាសាទបន្ទាយស្រីទាំងមូល អាចអនុវត្តទៅបាននៅពេលដែលនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍រៀបចំសៀវភៅបន្ទុកគ្រប់គ្រងរួចរាល់។

- បច្ចុប្បន្នសន្តិសុខ និងសណ្តាប់ធ្នាប់អ្នកលក់ដូរ បានរៀបចំឡើងដោយធ្វើការសហការជាមួយនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ។
- នាយកដ្ឋានក៏បានជ្រើសរើសកម្មករចំនួន១០រូប ក្នុងការសំអាត និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ដែលមាននៅក្នុងទីលានប្រាសាទបន្ទាយស្រី។
- បញ្ចប់ការងារសាងសង់ផ្លូវដើរចេញពីក្រោយប្រាសាទបន្ទាយស្រី មកកាន់ទីលានប្រាសាទបន្ទាយស្រី
- បានរៀបចំដាំកូនឈើបន្ថែម និងសួនផ្កា ដែលបានសុំពីសួនបារាយខាងជើង និងផ្ទះគំរូ
- បង្គន់អនាម័យដែលទទួលការសាងសង់ដោយក្រុមហ៊ុនសុខាអូតែល បានសាងសង់រួចរាល់ និងបើកឲ្យដំណើរការកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៩។
- បានចុះទៅវាស់ទីតាំងសាងសង់តូបថ្មីរបស់លោក ម៉ា គឹមមៀន ជាមួយនាយកដ្ឋានរៀបចំដែនដី និងនាយកដ្ឋានផ្សព្វផ្សាយ
- បានជួសជុលរួចរាល់នូវទីតាំងដែលខូចខាត នៅក្នុងចំណតរថយន្តនៅទីលានប្រាសាទបន្ទាយស្រី បណ្តាលមកពីខ្យល់ព្យុះកេតសានាបានបង្កឲ្យមានភ្លៀងធ្លាក់។
- ក្រោយពីថ្ងៃសម្ពោធ នាយកដ្ឋានបានបន្តការងារតទៅទៀត ដោយបានបើកឲ្យទស្សនានូវមជ្ឈមណ្ឌលបកស្រាយព័ត៌មាន និងបានដាក់បុគ្គលិកចំនួន០៤រូប ឲ្យបំពេញការងារជាអ្នកទទួលបដិសណ្ឋារកិច្ចភ្ញៀវ នៅក្នុងទីលានប្រាសាទបន្ទាយស្រី ដែលនឹងត្រូវបើកឲ្យភ្ញៀវទេសចរចូលទស្សនានៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១០។

## គម្រោងរៀបចំតំបន់ទេចរស្រះស្រង់៖

នាយកដ្ឋានទទួលបន្ទុករៀបចំហេដ្ឋារចនាសម្ព័ន្ធទេសចរនៅម្តុំស្រះស្រង់ ដូចជាភ្ជាប់ទំនាក់ទំនងបុរាណឡើងវិញ ពីស្រះស្រង់ទៅប្រាសាទបន្ទាយក្តី។ ថវិកាបានមកពីក្រុមហ៊ុន Jet Tours តាមរយៈអង្គការយូណេស្កូ និងគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា។ ការគ្រប់គ្រងគម្រោងត្រូវបានប្រគល់ជូននាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ។ យើងបានដាក់បង្គោល និងខ្សែរបានៅមុខប្រាសាទបន្ទាយក្តី និងស្រះស្រង់ក្នុងន័យលើកតំលៃទំនាក់ទំនងផ្លូវបុរាណរវាងរមណីយដ្ឋានទាំងពីរ ស្រះស្រង់និងប្រាសាទបន្ទាយក្តី បានសំរេច១០០ភាគរយ។

យើងបានជួសជុលកែលំអផ្លូវដីដើរទស្សនាជុំវិញស្រះស្រង់បានសំរេចចំនួន៩០ភាគរយរហូតមកដល់ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ការដ្ឋានបានផ្អាកជាបណ្តោះអាសន្ន ដោយសារត្រូវរង់ចាំការលុបអន្លង់កំណាយបុរាណវិទ្យារបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៅផ្នែកខាងលិចស្រះស្រង់រួចរាល់ជាមុនសិន។
បានរៀបចំការងារបច្ចេកទេស និងធ្វើការស្រាវជ្រាវព័ត៌មានប្រវត្តិភូមិ ដើម្បីរៀបចំស្លាកសញ្ញាផ្តល់ព័ត៌មានអំពីសៀគ្វី អំពីរុក្ខជាតិនៅតំបន់ស្រះស្រង់ អំពីភូមិរហាលស្រះស្រង់ខាងជើង អំពីដំណាំស្រូវ (ជំនួយដល់ការរៀបចំសៀគ្វី) ស្លាកសញ្ញាប្រាប់ទិស និងស្លាកសញ្ញាពីឈ្មោះដើមឈើ (សហការជាមួយនាយកដ្ឋានគ្រប់គ្រងទឹក)។

## ការរៀបចំផ្លូវនៅប្រាសាទតាព្រហ្ម៖

- បំពេញការងារជាប្រចាំជាមួយក្រុមការងារប្រទេសឥណ្ឌា (ASI) លើការរៀបចំផ្លូវចូលប្រាសាទ ដើម្បីសំរួលដល់ការ

កកស្ទះភ្ញៀវ និងដើម្បីលើកតំលៃកន្លែងដែលពុំសូវមានការទស្សនា ក្នុងគោលដៅលើកស្ទួយពីសារៈសំខាន់នៃវិស័យវប្បធម៌។ ដោយសារមានភ្លៀងធ្លាក់ច្រើនពេកការរៀបចំផ្លូវក៏ត្រូវបានពន្យាពេល។

- បង្គន់អនាម័យនៅខាងកើតត្រូវបានបើកឲ្យភ្ញៀវទេសចរប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០០៩។

## សិក្សានិងបង្កើតខ្សែទស្សនាវប្បធម៌ និងសង្គមវប្បធម៌៖

- បន្តសិក្សាលើការងាររៀបចំខ្សែទស្សនាវប្បធម៌នៅបារាយណ៍ខាងជើង និងបារាយណ៍ខាងលិច ដោយបានទទួលថវិការួមក្នុងការរៀបចំគម្រោង ជាមួយនាយកដ្ឋានគ្រប់គ្រងទឹក ដែលទទួលបានការឯកភាពពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន ជាប្រធានអាជ្ញាធរអប្សរា។
- ខ្សែទស្សនាវត្តអារាមនៅតាមដងស្ទឹងសៀមរាប៖ ការសិក្សាត្រូវបានពង្រឹងដោយលទ្ធផលស្រាវជ្រាវរបស់លោក Vittorio Roveda និងធ្វើការសហការជាមួយនាយកដ្ឋានអភិវឌ្ឍន៍បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប ដើម្បីចាប់ផ្តើមរៀបចំគម្រោងនេះ។
- បន្តការកែសំរួលខ្សែទស្សនាដែលបានរៀបចំរួច។
- រៀបចំក្រុមស្រាវជ្រាវសំរាប់រមណីយដ្ឋានប្រាសាទគោកចកនៅក្នុងខេត្តសៀមរាប ដើម្បីរៀបចំខ្សែទស្សនាប្រវត្តិសាស្ត្រ និងវប្បធម៌ក្រុង។
- បង្កើតក្រុមស្រាវជ្រាវដើម្បីសិក្សាខ្សែទស្សនានៅប្រាសាទបាយ័ន ដោយកំពុងតែធ្វើការកែសំរួល។
- គម្រោងទ្វេភាគីជាមួយប្រទេសញូវហ្សេឡេន៖ ក្រោយពីបានជ្រើសរើសទីប្រឹក្សាជាមួយប្រធានគម្រោងដំណាក់កាលទី១នៃការអនុវត្តសាកល្បងរយៈពេល០៦ខែ ជិតបញ្ចប់ និងរៀបចំសំរាប់គម្រោងដំណាក់កាលទី២។ នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌បានបញ្ជូនបុគ្គលិកឲ្យទៅបំពេញការងារផ្នែកបណ្តុះបណ្តាលប្រជាជន ដែលជាការបញ្ចូលសកម្មភាពពួកគេទៅក្នុងសេដ្ឋកិច្ចទេសចរណ៍។ នាយកដ្ឋានទើបនឹងទទួលបានរបាយការណ៍ដំណាក់កាលទី២ ហើយនាយកដ្ឋានកំពុងពិនិត្យនិងកែសំរួលជាមួយនាយកដ្ឋានពាក់ព័ន្ធ។
- ប្រជុំការងារ និងចុះពិនិត្យភូមិធម្មជាតិរន្ធតាឯក ជាមួយគណៈកម្មការនាំមុខ ដើម្បីសិក្សាការងារជាអាទិភាព និងចាប់ផ្តើមអនុវត្តគម្រោង។
- សិក្សាគម្រោងស្រះស្រង់ជាមួយលោកសាស្ត្រាចារ្យ Azedine Beschaouch លោក Michel Verrot និងលោក Philippe Delanghe នៃអង្គការយូណេស្កូប្រចាំភ្នំពេញ និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរៀបចំផែនការរៀបចំទីលានប្រាសាទ និងបង្កើតសកម្មភាពអាទិភាពដោយប្រើប្រាស់មូលនិធិរបស់ក្រុមហ៊ុន Jet Tours ដោយទទួលបានថវិកាសំរាប់ការអនុវត្តគម្រោង និងកំពុងតែអនុវត្តគម្រោង ព្រមទាំងបានរៀបចំរបាយការណ៍ដាក់ជូនអង្គការយូណេស្កូទីក្រុងប៉ារីសកាលពីខែកញ្ញា និងបន្តរៀបចំរបាយការណ៍សំរាប់ដំណាក់កាលទី២ទៅអង្គការ UNESCO ភ្នំពេញ និងទទួលបានថវិកាសំរាប់អនុវត្តគម្រោងដំណាក់កាលទី២នេះហើយ។
- បានចូលរួមប្រជុំពិភាក្សាស្តីពីការបើកឲ្យទស្សនាឡើងវិញ នូវរូតបាកាននៃប្រាសាទអង្គរវត្ត។
- បានចូលរួមប្រជុំពិភាក្សាពីបញ្ហាបញ្ចូលទឹកនៅប្រាសាទនាគព័ន្ធជាមួយលោកសាស្ត្រាចារ្យ Azedine BESCHAOUCH និងលោក Michel VERROT ដែលមានការប្តឹងតវ៉ាពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ។

## ការរៀបចំព្រឹត្តិការណ៍វប្បធម៌៖

– សិក្សាសំណើសុំថ្មីក្នុងការរៀបចំមហោស្រពវប្បធម៌នៅឆ្នាំ២០១០ របស់ក្រុមហ៊ុន RISE Entertainment និងផ្តល់ជាយោបល់ក្នុងការជ្រើសរើសទីតាំង និងការរៀបចំការធ្វើបទបង្ហាញគម្រោងនៅក្នុងកិច្ចប្រជុំ CIC ។ ក្រោយពីកិច្ចប្រជុំ CIC នៅដើមខែមិថុនា បានសំរេចឲ្យគម្រោងនេះត្រូវធ្វើការកែសំរួលជ្រើសរើសទីតាំងថ្មីក្រៅពីប្រាសាទបាយ័ន។ បន្ទាប់មក ក្រុមហ៊ុនក៏បានមកប្រជុំពិភាក្សាជាមួយនាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ ក្នុងការជ្រើសរើសទីតាំងថ្មីក្រោមការណែនាំដោយជំនាញការ Ad hoc ដោយទីតាំងថ្មីនៅលានជល់ដំរី។
– បានជួបរៀបចំការងារជាមួយជំនាញការមកពីអង្គការ UNESCO-Paris បានមកសិក្សាពីការបញ្ចាំងភ្លើងនៅប្រាសាទអង្គរវត្តតាមការចង់បានរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីឲ្យសមស្របតាមគណៈកម្មការបេតិកភណ្ឌពិភពលោក និងបានជួយចូលរួមរៀបចំការធ្វើបទបង្ហាញពីការបញ្ចាំងភ្លើងនៅក្នុងសម័យប្រជុំពេញអង្គលើកទី១៦ នៃ ICC កាលពីខែធ្នូ ឆ្នាំ ២០០៩។

### IX.6 **សារមន្ទីរព្រះនរោត្តមសីហនុ អង្គរ**

សារមន្ទីរព្រះនរោត្តមសីហនុអង្គរ ក៏ដូចជាក្រុមហ៊ុនសេវាទេសចរនៅសៀមរាបអង្គរដទៃទៀតដែរ គឺបានទទួលរងនូវការថយចុះនៃចំនួនអ្នកចូលទស្សនានៅឆ្នាំ២០០៩ ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក។
រយៈពេលពេញមួយឆ្នាំ២០០៩កន្លងទៅសារមន្ទីរមានភ្ញៀវចូលទស្សនាសរុបទាំងភ្ញៀវទិញសំបុត្រ និងភ្ញៀវមិនទិញសំបុត្រមានចំនួន **៣៣៣៥ នាក់** ៖

-ភ្ញៀវជាតិចំនួន **៩៣៧ នាក់** ក្នុងនោះមានភ្ញៀវឥតបង់ថ្លៃចំនួន **៣៨៦ នាក់**។

-ភ្ញៀវអន្តរជាតិចំនួន **២៣៩៨ នាក់** ក្នុងនោះមានភ្ញៀវឥតបង់ថ្លៃចំនួន **៦៧ នាក់**។

ចំនួនភ្ញៀវ និងប្រាក់ចំណូលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០០៩

| ខែ | ភ្ញៀវទិញសំបុត្រ | | ភ្ញៀវមិនទិញសំបុត្រ (មានលិខិតអនុញ្ញាត) | | ចំណូលប្រចាំខែ | |
|---|---|---|---|---|---|---|
| | បរទេស | ជនជាតិខ្មែរ | បរទេស | ជនជាតិខ្មែរ | បរទេស | ជនជាតិខ្មែរ |
| **មករា** | ៣៦៥នាក់ | ៥៦នាក់ | ០នាក់ | ២៦នាក់ | ១.០៩៥,០០ដុល្លារ | ៥៦.០០០,០០រៀល |
| **កុម្ភៈ** | ៤៧៤នាក់ | ៣៩នាក់ | ០នាក់ | ១៩៤នាក់ | ១.៤២២,០០ដុល្លារ | ៣៩.០០០,០០រៀល |
| **មីនា** | ៣២៣នាក់ | ៣៦នាក់ | ១០នាក់ | ២នាក់ | ៩៦៩,០០ដុល្លារ | ៣៦.០០០,០០រៀល |
| **មេសា** | ១២៧នាក់ | ២២នាក់ | ០នាក់ | ០នាក់ | ៣៨១,០០ដុល្លារ | ២២.០០០,០០រៀល |
| **ឧសភា** | ៥២នាក់ | ២០នាក់ | ០នាក់ | ១នាក់ | ១៥៦,០០ដុល្លារ | ២០.០០០,០០រៀល |

| | | | | | | |
|---|---|---|---|---|---|---|
| មិថុនា | ៣១នាក់ | ១៩២នាក់ | ០នាក់ | ១នាក់ | ៩៣,០០ដុល្លារ | ១៩២.០០០,០០រៀល |
| កក្កដា | ៦១នាក់ | ២៩នាក់ | ០នាក់ | ០នាក់ | ១៨៣,០០ដុល្លារ | ២៩.០០០,០០រៀល |
| សីហា | ១៩៦នាក់ | ៥៥នាក់ | ២៣នាក់ | ០នាក់ | ៥៨៨,០០ដុល្លារ | ៥៥.០០០,០០រៀល |
| កញ្ញា | ១៥១នាក់ | ៣៥នាក់ | ០នាក់ | ០នាក់ | ៤៥៣,០០ដុល្លារ | ៣៥.០០០,០០រៀល |
| តុលា | ៨២នាក់ | ១៥នាក់ | ៣នាក់ | ០នាក់ | ២៤៦,០០ដុល្លារ | ១៥.០០០,០០រៀល |
| វិច្ឆិកា | ២៦៧នាក់ | ៣៩នាក់ | ២នាក់ | ១៩០នាក់ | ៨០១,០០ដុល្លារ | ៣៩.០០០,០០រៀល |
| ធ្នូ | ២០២នាក់ | ១៣នាក់ | ២៩នាក់ | ២២នាក់ | ៦០៦,០០ដុល្លារ | ១៣.០០០,០០រៀល |
| សរុបប្រចាំឆ្នាំ២០០៩ | **២.៣៣១នាក់** | **៥៥១នាក់** | **៦៧នាក់** | **៣៨៦នាក់** | **៦.៩៩៣,០០ដុល្លារ** | **៥៥១.០០០,០០រៀល** |

## ការងារចុះបញ្ជី ស្រាវជ្រាវ និង អភិរក្ស

### ការងារចុះបញ្ជី

-វត្ថុបុរាណធ្វើអំពីថ្មភក់បានចំនួន ៥៨៨ដុំ នៃចំនួនសរុប ៨៧៩ ដុំ។

-កុលាលភាជន៍បានចំនួន ២៨៩ដុំ នៃចំនួនសរុប ១០៥កេស។

### ការងារអភិរក្សវត្ថុបុរាណ

-សហការជាមួយក្រុមអភិរក្សថ្មរបស់អាជ្ញាធរអប្សរា Stone Conservation Unit និង GACP ជួសជុលរូបចម្លាក់ថ្មភក់ដែលធ្វើកំណាយបានពីភ្នំគូលែន (ក្បាច់ជើងទម្រប្រាសាទ រូបព្រះនារាយណ៍ សរសេពេជ្រ ផ្តែរទ្វារ និងលាងសំអាតចម្លាក់តោ)។

-សហការជាមួយស្ថាប័នសូហ្វីយ៉ាជួសជុល និងសម្អាតចម្លាក់ចំនួន១០រូប ដែលនៅក្នុងឃ្លាំងសារមន្ទីរ ដើម្បីដាក់ជំនួសចម្លាក់ដែលត្រូវយកទៅតាំងពិព័រណ៍នៅប្រទេសជប៉ុន។

-សហការជាមួយអ្នកបច្ចេកទេសជួសជុលកុលាលភាជន៍ មកពីមន្ទីរពិសោធន៍ និងអភិរក្សកុលាលភាជន៍នៃមហាវិទ្យាល័យបុរាណវិទ្យា ដើម្បីជួសជុលកុលាលភាជន៍ដែលយកមកពីឡតានី ឡសរសើ ឡខ្នាពោធិ៍ និងឡអន្លង់ធំសម្រាប់ដាក់តាំងនៅសារមន្ទីរកុលាលភាជន៍ឡតានី។

-សហការជាមួយអ្នកបច្ចេកទេសមកពីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ ដើម្បីលាងសំអាតវត្ថុបុរាណដែលធ្វើកំណាយបានពីឡស្លដែកនៅភូមិខ្វារ។

-សំអាតកុលាលភាជន៍ និងជួសជុលទិកោ (Kendi) ចំនួន១ពាងចំនួន១ និងបំណែកមាត់ក្រឡចំនួន១ឡើងវិញដោយអ្នកបច្ចេកទេសជួសជុលកុលាលភាជន៍ មកពីមន្ទីរពិសោធន៍ និងអភិរក្សកុលាលភាជន៍នៃមហាវិទ្យាល័យបុរាណវិទ្យាសម្រាប់ដាក់តាំងនៅសារមន្ទីរកុលាលភាជន៍ឡតានី។

-បានលាងសំអាត និងជួសជុលសមុច្ច័យដែលមកពីភ្នំគូលែនមួយចំនួនថែមទៀត ដោយក្រុមអភិរក្សថ្ម (Stone

Conservation Unit) របស់អាជ្ញាធរអប្សរា។

## ការងារស្រាវជ្រាវ

-ប្រមូលឯកសារ និងរូបភាពដែលទាក់ទងនឹងព្រះពុទ្ធរូបពីសតវត្សទី១ ដល់សតវត្សទី១៣ ក្នុងបណ្ណាល័យសារមន្ទីរព្រះនរោត្តមសីហនុ_អង្គរ ដើម្បីប្រមូលព័ត៌មានដែលទាក់ទងប្រវត្តិពុទ្ធសាសនានៅកម្ពុជាសម័យបុរាណ។

-បញ្ចប់ការសិក្សាស្រាវជ្រាវប្រវត្តិព្រះពុទ្ធសាសនាតាមសិលាចារឹក ប៉ុន្តែកំពុងធ្វើការកែសម្រួលអត្ថន័យ។

## ការងារបណ្តុះបណ្តាល

- ពីថ្ងៃទី១៥ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ លោលសាស្ត្រាចារ្យ យូស៊ីហារ៉ូ ណាកាអូ មកពីស្ថាប័នសូហ្វីយ៉ា បានបង្រៀនដល់បុគ្គលិកសារមន្ទីរពីបច្ចេកទេសផ្តិតសិលាចារឹក។

-នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០០៩ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការថតរូបជាមួយលោក Robbie Flick (គ្រូបង្រៀនស្ម័គ្រចិត្តនៃសលា បង្រៀនកុមារអន្តរជាតិប្រចាំខេត្តសៀមរាប) ដែលរៀបចំដោយកញ្ញា Anne Marie Gan នៅសារមន្ទីរព្រះនរោត្តម សីហនុ_អង្គរ។

-ថ្ងៃទី២៨ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩ សារមន្ទីរបានបញ្ជូនបុគ្គលិកចំនួន២រូប ដើម្បីចូលរួមវគ្គបំប៉នជំនាញលើប្រធានបទ "គ្រប់គ្រងបុរាណវត្ថុ" នៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

-ថ្ងៃទី២០ រហូតដល់ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ សារមន្ទីរបានបញ្ជូនបុគ្គលិកបច្ចេកទេសចំនួន១នាក់ទៅចូលរួមជាសិក្ខាកាមក្នុងវគ្គ "ការប្រយុទ្ធ ប្រឆាំងទប់ស្កាត់នឹងអំពើចារកម្ម ចរាចរ និងការជួញដូរវត្ថុបុរាណខុសច្បាប់" ដែលរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងអង្គការយូណេស្កូនៅភ្នំពេញ។

## ការផ្សព្វផ្សាយ និងការអប់រំ

-សារមន្ទីរបានផ្សព្វផ្សាយ និងអប់រំដល់សិស្សានុសិស្ស និងនិស្សិត ចំនួន**៤០៥នាក់** មកពី សាលា **KTC**, សាលាបឋមសិក្សាសាមគ្គី_សាគូរ៉ាក្នុងតំបន់អង្គរ និងសាកលវិទ្យាល័យ USEA (University of South-east Asia) អំពីប្រវត្តិសាស្ត្រ និងវប្បធម៌សម័យអង្គរ។

-សារមន្ទីរបានចែកចាយក្រដាសផ្ទត់ចំនួន៣៤០ច្បាប់ ដល់ក្រុមហ៊ុនទេសចរណ៍នៅខេត្តសៀមរាបចំនួន១៧ក្រុមហ៊ុន និងចំនួន១០០ច្បាប់ដល់ស្ថាប័នសូហ្វីយ៉ា។

-រៀបចំផ្ទាំងព័ត៌មានផ្សព្វផ្សាយពីសារមន្ទីរព្រះនរោត្តមសីហនុ_អង្គរ ដើម្បីដាក់នៅបញ្ជរលក់សំបុត្ររបស់ក្រុមហ៊ុន សុខាអូតែល។

-រៀបចំព័ត៌មានផ្សព្វផ្សាយពីសារមន្ទីរព្រះនរោត្តមសីហនុ_អង្គរ នៅក្នុងព្រឹត្តិបត្រព័ត៌មានប្រចាំខែរបស់អាជ្ញាធរអប្សរា។

-រៀបចំដាក់ Poster ចំនួន៧ផ្ទាំងនៅសារមន្ទីរ ដើម្បីបង្ហាញអំពីសកម្មភាពអប់រំប្រជាជននៅតំបន់អង្គរ អំពីសារមន្ទីរ និងព្រះពុទ្ធបដិមាដែលរកឃើញនៅប្រាសាទបន្ទាយក្តី។

## ការងារបណ្ណាល័យ

-បណ្ណាល័យសារមន្ទីរមានសៀវភៅសរុបចំនួន **២៧៥១**ក្បាល

-សារមន្ទីរបានចុះបញ្ជីសៀវភៅតាមលំដាប់បែងចែកប្រភេទសៀវភៅធ្វើឡើងតាម (DEWEY DECIMAL CLASSIFICATION) បានចំនួន **៦៥៤** ក្បាល ក្នុងចំណោមសៀវភៅ **២៧៥១** ក្បាល។

## ការថែទាំសួនច្បារ

-ពីថ្ងៃទី១ ខែមីនា ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ ស្ថាប័នសូហ្វីយ៉ា បានបញ្ចប់ការកែលម្អសួននៅសារមន្ទីរ ដោយដាំដើមឈើបន្ថែមចំនួន១៥០ដើម និងដាំស្មៅនៅផ្ទៃកខាងមុខអគារលើផ្ទៃក្រឡា ៦៤៩,១ម៉ែត្រការ៉េ និងបានបំពាក់ប្រព័ន្ធស្រោចទឹកដោយប្រើអណ្តូងជីកថ្មីចំនួន៣។

-សារមន្ទីរបានដាំផ្កាបន្ថែមលើផ្ទៃសួនជុំវិញអគារលើផ្ទៃក្រឡា២៥២ម៉ែត្រការ៉េ។

-ថ្ងៃច័ន្ទ ទី១៧ ខែសីហា ឆ្នាំ២០០៩ មជ្ឈមណ្ឌលសូហ្វីយ៉ា សហការជាមួយសារមន្ទីរ បានធ្វើការចាក់ដីបំពេញចំនួន៣កន្លែង ក្នុងបរិវេណសារមន្ទីរ ដើម្បីការពារការហូរច្រោះទឹកភ្លៀង។

-កែលំអសោភ័ណភាពខាងក្នុងអគារសារមន្ទីរដោយរៀបចំដាក់ផ្កា។

-កែលំអដើមឈើនៅសួនខាងក្រៅសារមន្ទីរ ដោយដាក់ជីដើមឈើបានចំនួន២៨ដើម និងស្មៅទាំងអស់នៃផ្ទៃសួនខាងក្រៅទាំងមូល។

## កិច្ចសប្រតិបត្តិការអន្តរជាតិ

– ប្រជុំនៅទីក្រុង សេអ៊ូល តាមរយៈការអញ្ជើញរបស់ ICME (International Committee of Museums of Ethnography) ស្តីពីតួនាទី នៃសារមន្ទីរជាតិពិន្ទុវិទ្យា នៅក្នុងការសម្រុះសម្រួលនិងសន្តិភាព
– រៀបចំសំណុំឯកសារស្នើសុំអោយក្រុមហ៊ុន AEON នៃប្រទេសជប៉ុន ជួសជុលសារមន្ទីរព្រះនរោត្តមសីហនុអង្គរ ដែលបានផ្តល់ថវិការសាងសង់សារមន្ទីរនេះ។ អាជ្ញាធជាតិអប្សរាប្រហែលជាត្រូវជួសជុលបញ្ចប់ដោយខ្លួនឯង ព្រោះថាក្រុមហ៊ុន AEON បានជួសជុលតែពាក់កណ្តាលនៃផ្នែកដែលខូចខាតប៉ុណ្ណោះ។
– សហការជាមួយនាយកដ្ឋាន រៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋាននៅក្នុងឧទ្យានអង្គរ ដើម្បីរៀបចំប្លង់និងសង់ជើងសម្រាប់ដាក់រូបព្រះពុទ្ធ ផ្តល់ជូនដោយ លោកស្រី Sulata Sakar ជាសប្បុរសជនមិជនជាតិឥណ្ឌា។ ប្រធាននាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋាននៅក្នុងឧទ្យានអង្គរ បានជូនដំណឹងថា កំពុងរៀបចំសំណើសុំថវិកា ដើម្បីសុំការសម្រេច និងឯកភាពពីឯកឧត្តមឧបនាយករដ្ឋមន្រ្តី សុខ អាន។
– អ្នកជំនាញជនជាតិអ៊ីតាលីមួយក្រុម មកពីសាកលវិទ្យាល័យ Palerme (Sicile) ក្នុងគោលដៅបង្កើតសហប្រតិបត្តិការអ៊ីតាលី ខ្មែរ (ICCROM-ANA) ក្រោមការដឹកនាំផ្ទាល់របស់សាស្ត្រាចារ្យ Beschaouch និងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិអប្សរា បានពិនិត្យមើលជម្ងឺនៃរូបចម្លាក់នៅសារមន្ទីរជាតិភ្នំពេញ និងនិងរូបនៅក្នុងអភិរក្សដ្ឋានអង្គរ សៀមរាប។ អនុសញ្ញាសហប្រតិបត្តិការកំពុងដំណើរការរៀបចំ។

## សារមន្ទីរកុលាលភាជន៍តានីៈ

– ចុះបំពេញការងារ ពិនិត្យសារមន្ទីរ និងកុលាលភាជន៍នៅរមណីយដ្ឋានតានី ជាមួយនាយកដ្ឋានរៀបចំដែនដី និង

គ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ដើម្បីពិនិត្យការងារសាងសង់សារមន្ទីរ។

- បានជ្រើសរើសបុគ្គលិក និងកម្មករចំនួន០៩រូប សំរាប់បំពេញការងារនៅសារមន្ទីរកុលាលភាជន៍តានីនេះ
- ការសាងសង់សារមន្ទីរបានបញ្ចប់ ហើយបន្តរៀបចំជួសជុលកុលាលភាជន៍សំរាប់ការដាក់តាំងនៅក្នុងសារមន្ទីរ និងបានរៀបចំក្រដាសផ្ទាត់ស្តីពីសារមន្ទីរជាបីភាសា អង់គ្លេស ជប៉ុន ខ្មែរ និងបានបើកសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាព **ឯកឧត្តម ឧបនាយរដ្ឋមន្ត្រី សុខ អាន** នៅក្នុងពេលកិច្ចប្រជុំពេញអង្គលើកទី១៦នៃICC កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៩។

# X. នាយកដ្ឋានអភិវឌ្ឍន៍ បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប

តាំងពីសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល បង្វែរប៉េសកកម្មអតីតនាយកដ្ឋាននគរោបនីយកម្ម និងអភិវឌ្ឍក្រុងសៀមរាបទៅរកផ្នែកបេតិកភណ្ឌ នាយកដ្ឋាននេះត្រូវបានប្តូរឈ្មោះទៅជា នាយកដ្ឋានអភិវឌ្ឍន៍បេតិកភណ្ឌក្រុងក្នុងតំបន់សៀមរាប។ សកម្មភាពនិងគម្រោងសំខាន់ៗសម្រាប់ឆ្នាំ២០០៩ បានគិតដល់ការលើកតម្លៃបេតិកភណ្ឌក្រុង ជាពិសេសការងារសំអាតស្ទឹងសៀមរាប។

## X.1. ការងាររៀបចំក្រុង

### ក. ការពិនិត្យ និងផ្តល់យោបល់លើគម្រោងសាងសង់

- ពិនិត្យ និងផ្តល់យោបល់ពាក្យសាងសង់បង្គោលអង់តែនទូរស័ព្ទរបស់ក្រុមហ៊ុន អឹមផ្លាយហ្វូនចំនួន ៣១កន្លែង អង់តែន០១១ ចំនួន ២៣កន្លែង ព្រមទាំងអង់តែន០១៦ ចំនួន ០៨កន្លែង
- ពិនិត្យ និងផ្តល់យោបល់ពាក្យសាងសង់ស្ថានីយប្រេងឥន្ធនៈរបស់ លោកលឹម វ៉េង និងលោកស្រី ឡាំ ស៊ីម
- ពិនិត្យ និងផ្តល់យោបល់ពាក្យសុំសាងសង់បុរីណាហ្គាវ៉ា របស់ លោកស្រី អៀ ហ្គិចឡាង
- ពិនិត្យ និងផ្តល់យោបល់សុំសាងសង់អគារស្នាក់នៅ លោក សៀ សុផល និង លោកស្រី ស៊ុំ ថាវី
- ពិនិត្យ និងផ្តល់យោបល់សុំសាងសង់ និង ជួសជុលព្រះវិហារព្រះអង្គចេក ព្រះអង្គចម
- ពិនិត្យ និងផ្តល់យោបល់សុំសាងសង់ផ្លូវដីស១ខ្សែមានប្រវែង ៥៨០ម ទទឹង ៤ម របស់សង្កាត់ស្លក្រាមក្រុងសៀមរាប
- ពិនិត្យ និងផ្តល់យោបល់សុំសាងសង់សណ្ឋាគាររបស់ លោក មាស ច័ន្ទអេវីវណ្ណ និងអ្នកស្រី មាស ច័ន្ទធីតា

### ខ. ការតាក់តែងធ្វើលិខិតបទដ្ឋានច្បាប់

ដើម្បីចូលរួមធ្វើអោយមានសោភ័ណភាពទីក្រុងសៀមរាប នាយកដ្ឋានសហការជាមួយមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានខិតខំចងក្រងបទដ្ឋាននគរូបនីយកម្ម សំរាប់អនុវត្តន៍ចំពោះគ្រប់គម្រោងសាងសង់សំណង់ផ្សេងៗនៅសៀមរាប។

### គ. ការងាររៀបចំគម្រោង

ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍ក្រុងសៀមរាបឲ្យមានភាពរីកចំរើន នាយកដ្ឋានបានលើកគម្រោងជាច្រើនសម្រាប់ស្នើសុំថវិកាពីភ្នាក់ងារអន្តរជាតិដូចជា ៖

**១. គម្រោង AFD ដែលសហការផ្ទាល់ជាមួយអាជ្ញាធរខេត្ត**

- គម្រោងរៀបចំបង្ហូរទឹកភ្លៀង និងទឹកកខ្វក់ប៉ែកខាងកើតស្ទឹងដែលជាជំនួយថវិកាពីអង្គការ (AFD) មានទឹកប្រាក់ចំនួន ៤លាន អឺរ៉ូ ក្នុងនោះរួមមាន ៖
  - តម្លៃប្រហែល ១លាន អឺរ៉ូ សម្រាប់ទីប្រឹក្សាបច្ចេកទេស និងសិក្សាប្លង់មេ
  - តម្លៃប្រហែល ៣លាន អឺរ៉ូ សម្រាប់ការសាងសង់ប្រព័ន្ធប្រឡាយទឹក
- គម្រោងនេះបានសិក្សានូវលក្ខណៈបច្ចេកទេសរួចរាល់ និងរៀបចំជ្រើសរើសក្រុមហ៊ុនសាងសង់នៅដើមខែមេសា ឆ្នាំ២០១០ ការដ្ឋាននឹងចាប់ផ្តើមដំណើរការសាងសង់។ ចំពោះគម្រោងនេះគឺនាយកដ្ឋានបានជួយអាជ្ញាធរខេត្តទាំងស្រុងលើផ្នែកបច្ចេកទេស។

**២. គម្រោង AFD ដែលសហការផ្ទាល់ជាមួយអាជ្ញាធរអប្សរា**

២.១- គម្រោងកែលំអតាមដងស្ទឹងសៀមរាប ចំណាយថវិកាអស់ចំនួន ២៨០.៣៨០ អឺរ៉ូ លើការងារដូចជា ៖

- ដាំដើមឈើតាមដងផ្លូវក្នុងតំបន់ផ្សារចាស់ ចំណាយថវិកាអស់ ១៨.៤០៦ $

- ដាក់របាការពារស្មៅតាមដងស្ទឹងសៀមរាប ពីស្ពានអាងក្រពើដល់ស្ពាននាគមានប្រវែង៣.៤៧០ម ចំណាយថវិកាអស់ ៣៨.៥៩៩ $

- សាងសង់ស្ពានឈើសំរាប់ទេសចរណ៍ធ្វើដំណើរកំសាន្តឆ្លងស្ទឹងសៀមរាប ចំណាយថវិកាអស់ ៣៩.២១៣$

- ដាក់ផ្លាកសញ្ញាព័ត៌មានសម្រាប់បង្ហាញដល់ភ្ញៀវទេសចរតាមដងស្ទឹងសៀមរាបក្នុងក្រុងសៀមរាប ចំនួន៧កន្លែង ចំណាយថវិកាអស់ ២៨.៧៨៣$ ។

ចំពោះគម្រោងទាំងបួនខាងលើនេះ អាជ្ញាធរអប្សរាបានធ្វើការ ពិគ្រោះតម្លៃជាមួយក្រុមហ៊ុនដែលពាក់ព័ន្ធរួចរាល់ហើយ និងដំណើរការសាងសង់នៅដើមឆ្នាំ២០១០ ។

- កែលំអផ្លូវចូលវត្តស្ថិតតាមដងស្ទឹងសៀមរាប (វត្តពោធិ៍ល័ង្កា វត្តបូព៌ វត្តដំណាក់) ចំណាយអស់ថវិកាចំនួន ២៩៥.៥៦៩$ គម្រោងនេះបានដេញថ្លៃជាលក្ខណៈជាតិរួចរាល់ហើយ និងដំណើរការសាងសង់នៅដើមឆ្នាំ ២០១០។

២.២- គម្រោងលើតម្លៃនូវបេតិកភណ្ឌ និងវប្បធម៌ក្នុងក្រុងសៀមរាបចំណាយថវិកាអស់ចំនួន ៩៣.៣៣៣ អឺរ៉ូ លើការងារដូចខាងក្រោម ៖

- ការងារសិក្សាអំពីបេតិកភណ្ឌ វប្បធម៌ និងធម្មជាតិ គម្រោងនេះកំពុងជ្រើសរើសក្រុមហ៊ុនឲ្យមកសិក្សានៅខែកុម្ភៈ ឆ្នាំ២០១០។

**៣. គម្រោង A I M F និង SIAAP**

– គម្រោងស្តារប្រឡាយស្រោចស្រព្វឡើងវិញនៅខាងកើតក្រុងសៀមរាបមានប្រវែង៣.៧គម ចាប់ពីស្ពានសង្កាត់

សាលាកំរើករហូតដល់សង្កាត់ជ្រាវ ត្រង់ចំនុចសាលារៀនអនុវិទ្យាល័យជ្រាវ។ គម្រោងសាកល្បងស្ពារប្រឡាយមានប្រវែង ៧០០ម ចាប់ពីស្ពានជិតសាលាសង្កាត់ សាលាកំរើករហូតដល់ស្ពានសាមគ្គី។ គម្រោងនេះមានថវិកាសរុបចំនួន ១៣០.០០០អឺរ៉ូ ដែលជាជំនួយរបស់សមាគមន៍អន្តរជាតិនិយាយភាសាបារាំង A I M F និងអង្គការ SIAAP ក្នុងឆ្នាំ ២០០៩-២០១០។ គម្រោងនេះនាយកដ្ឋានបានរៀបចំបច្ចេកទេសរួចរាល់ហើយ និងចាប់ផ្តើមអនុវត្តន៍នៅដើមខែកុម្ភៈ ឆ្នាំ២០១០ ខាងមុខនេះ។

### ឃ. ការសំអាតតាមដងស្ទឹងសៀមរាប

– ការងារសំអាតស្ទឹងនាយកដ្ឋានមានកម្មករចំនួន ៣៥រូបធ្វើការសំអាត និងស្រោចទឹកស្មៅតាមមាត់ស្ទឹងជាប្រចាំ ហើយបែងចែកជាបី ក្រុមគឺ៖

- ក្រុមទីមួយមានកម្មករ ០៦រូប ធ្វើការសំអាតពីស្ពានថ្មព្រះរាជដំណាក់ដល់គល់ស្ពានវត្តពោធិ៍ល័ង្កា
- ក្រុមទីពីរមានកម្មករ ១២រូប ធ្វើការសំអាតពីគល់ស្ពានថ្មព្រះរាជដំណាក់ដល់គល់ស្ពានផ្សារចាស់
- ក្រុមទីបីមានកម្មករ ១៧រូប ធ្វើការសំអាតពីគល់ស្ពានផ្សារចាស់ដល់ស្ពានអាងក្រពើ

## II. **ការងារបុរីវប្បធម៌ និងទេសចរណ៍-អង្គរ**

### ក. ការងារសំអាតផ្លូវ

- ការងារសំអាតតាមផ្លូវដីបុរីវប្បធម៌ ទេសចរណ៍អង្គនាយកដ្ឋានមានកម្មករចំនួន ២៣រូប សំអាតផ្លូវបុរីវប្បធម៌ និងទេសចរណ៍-អង្គរ ដូចខាងក្រោម ៖

  - ធ្វើការបោសសំអាតថ្នល់ T1, T2, T3, T4 និង រង្វង់មូលមានចំនួន ០៩រូប

  ចំណែកឯកម្មករ ១៨រូបទៀតបានធ្វើការងារដូចខាងក្រោម ៖

  - កាប់ស្មៅនៅតាមដងប្រឡាយនៃផ្លូវ T1, T2, T3, T4
  - ជីកដី និងយកសំរាម ចេញពីចង្ហូរអមសងខាងផ្លូវថ្នល់ T1, T2, T4, T5 ដើម្បីឲ្យទឹកហូរ
  - ប្រមូលសំរាមនៅតាមដងផ្លូវ T5

### ខ. ការពិនិត្យតាមដានការជួសជុលផ្លូវ

- នាយកដ្ឋានបានតាមដានការរៀបចំដាក់របាដែកជ្រុងការពារយានយន្តឆ្លងកាត់ការីឡានៅកំណាត់ផ្លូវ T2.T5 និង Gabion ការពារទឹកហូរច្រោះក្បាលលូ និង ជួសជុលផ្លូវកៅស៊ូនៅបុរីវប្បធម៌ និងទេសចរណ៍អង្គរដែលអនុវត្តន៍ដោយក្រុមហ៊ុន KSDR។
- នាយកដ្ឋានបានតាមដានការជួសជុល ផ្លូវប្រេះ ផត ស្រុត និងសំបុកមាន់នៅកំណាត់ផ្លូវ T1.T2.T4 នៅបុរីវប្បធម៌ និងទេសចរណ៍អង្គរ ដែលអនុវត្តន៍ដោយក្រុមហ៊ុន ស្ពានគរធំ។

### គ. ការពិនិត្យតាមដានការដ្ឋានសាងសង់ទីស្នាក់ការអប្សរា

– អ្នកបច្ចេកទេសចំនួនពីររូបរបស់នាយកដ្ឋានបានតាមដានការសាងសង់ទីស្នាក់ការអាជ្ញាធរ អប្សរាដែលអនុវត្តន៍ការងារដោយក្រុមហ៊ុន Geting Teamwork Construction and Development Co.,Ltd ហើយរហូតមកដល់ ពេល

នេះក្រុមហ៊ុនសាងសង់បានសម្រេចការងារជាង ៣៣% នៃគ្រឿងបង្គុំសំណង់។

# XI. នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ

ការបែងចែកការងារនឹងមានលក្ខណៈច្បាស់លាស់នៅពេល ប្រធានអាជ្ញាធរជាតិអប្សរាចេញប្រកាសជាផ្លូវការ។ មុននឹងមានការចាត់តាំងជាផ្លូវការនេះ នាយកដ្ឋានបានចាត់វិធានការមួយចំនួន ដើម្បីអោយបុគ្គលិកអាចចុះអនុវត្តការងារបាន។

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរបច្ចុប្បន្នចែកចេញជា០៦ផ្នែកគឺៈ
១-ផ្នែករដ្ឋបាល និងបណ្តុះបណ្តាលទេសចរណ៍
២-ផ្នែកស្ថិតិ និងផែនការទេសចរណ៍
៣-ផ្នែកត្រួតពិនិត្យភ្ញៀវ និងវង់ទស្សនាចរណ៍
៤-ផ្នែកត្រួតពិនិត្យគុណភាព និងបទដ្ឋានទេសចរណ៍
៥-ផ្នែកវិនិយោគ អាជីវកម្ម សេវាកម្ម និងផ្សព្វផ្សាយទេសចរណ៍
៦-អង្គភាពដឹកជញ្ជូនទេសចរ។

មន្ត្រីរាជការ បុគ្គលិក ភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍នៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ មានចំនួនសរុប ៣៤៩នាក់ ក្នុងនោះរួមមានៈ

| | |
|---|---|
| ១-មន្ត្រីថ្នាក់ដឹកនាំៈ អគ្គនាយករង | ចំនួន ០១រូប និងអនុប្រធាននាយកដ្ឋានចំនួន០២រូប |
| ២-មន្ត្រី-បុគ្គលិក | ចំនួន ៣៩រូប |
| ៣-ភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ | ចំនួន ២៥៣រូប |
| ៤-បុគ្គលិកអង្គភាពដឹកជញ្ជូនទេសចរ | ចំនួន ៥៤រូប |

### XI.1 សម្ភាពរដ្ឋបាល

អគ្គនាយដ្ឋានចូលរួមប្រជុំផ្សេងៗ អគ្គនាយករងត្រូវបានចាត់តាំងអោយតំណាងអគ្គនាយកនៅក្នុងជំនួបផ្សេងៗ ដូចជាការប្រជុំនៅតាមក្រសួង ជាមួយអាជ្ញាធរខេត្ត និងស្ថាប័នជាតិនិងអន្តរជាតិ។

## ការងារប្រជុំផ្សេងៗ

### ការប្រជុំផ្ទៃក្នុងអាជ្ញាធរជាតិអប្សរា

– បានចូលរួមក្នុងកិច្ចប្រជុំពិភាក្សាស្តីអំពី គម្រោងវិនិយោគនៅភ្នំគូលែន ការងាររៀបចំកិច្ចសន្យា និងសៀវភៅបន្ទុកគ្រប់គ្រងអាជីវកម្មនៅទីលានប្រាសាទបន្ទាយស្រី និងបញ្ហាផ្សេងៗ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា នៅសាលប្រជុំ នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរាក្នុង អគារអង្គរ-គូនអ៊ិចនៅ

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩។

- បានចូលរួមប្រជុំពិភាក្សា ការងារបោះបង្គោលព្រំសីម៉ា កំណត់តំបន់ឧទ្យានអង្គរ សៀវភៅស្តីពីសមិទ្ធផលការងារអាជ្ញាធរអប្សរារយៈពេល១៨ឆ្នាំ កំរងសំនួរ-ចំលើយប្រជាពលរដ្ឋក្នុងតំបន់១ និងតំបន់២ បញ្ហាអនាម័យនៅតាមប្រាសាទនានា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា នៅសាលប្រជុំនៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរាក្នុងអគារអង្គរ-កូអ៊ិច នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩
- បានចូលរួមប្រជុំពិភាក្សាគម្រោង ស៊ូជីង នៅអគ្គនាយកដ្ឋានអាជ្ញាធរអប្សរានៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩
- បានចូលរួមប្រជុំពិភាក្សាស្តីពីការសាកល្បងបើកជូនភ្ញៀវទេសចរនានៅរូតបាកាន នៃប្រាសាទអង្គរវត្តនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា
- បានចូលរួមប្រជុំពិភាក្សាស្តីពីដំណើរការសាកល្បងបើកជូនភ្ញៀវទេសចរនានៅរូតបាកាន នៃប្រាសាទអង្គរវត្តនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **តាន់ សំប៊ុន** អគ្គនាយករងអាជ្ញាធរអប្សរា។
- បានចូលរួមប្រជុំពិភាក្សាស្តីអំពីគម្រោងសួនគ្រឿងទេស គម្រោងភូមិធម្មជាតិរុនតាឯក ការរំកិលរូបព្រះពុទ្ធបដិមានៅរូតបាកាននិងផ្សេងៗនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា
- អនុប្រធាននាយកដ្ឋានបានចូលរួមប្រជុំផ្ទៃក្នុងអាជ្ញាធរអប្សរា ជាមួយលោកសាស្ត្រាចារ្យ Beschaouch ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា ស្តីពីការរៀបចំរបាយការណ៍បញ្ជូនទៅ UNESCO។
- អនុប្រធាននាយកដ្ឋានបានចូលរួមប្រជុំតំណាងអោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** អគ្គនាយករងអាជ្ញាធរអប្សរា ស្តីពីគម្រោងរៀបចំបោះពុម្ពប័ណ្ណចូលទស្សនារមណីយដ្ឋានអង្គរសំរាប់ឆ្នាំ២០១០ ក្រោមអធិបតីភាព **ឯកឧត្តម បួន លឹមហេង** ។
- អនុប្រធាននាយកដ្ឋានបានដឹកនាំកិច្ចប្រជុំជាមួយប្រធានគ្រប់គ្រងភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ ដើម្បីពង្រឹងការងារនៅតាមប្រាសាទក្នុងការថែរក្សាសុវត្ថិភាព និងសណ្តាប់ធ្នាប់ដល់ការទស្សនារបស់ភ្ញៀវទេសចរ។

## ការប្រជុំថ្នាក់ជាតិនិងអន្តរជាតិ

- បានចូលរួមប្រជុំពិភាក្សាស្តីពីផែនការរៀបចំការពារសន្តិសុខ សម្រាប់ព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនគោលមិត្តភាពរវាងអគ្គទូតនៃបណ្តាប្រទេស អាស៊ាន+៣+ឥណ្ឌា+អូស្ត្រាលី និងការប្រកួតកីឡាវាយកូនគោលអាស៊ីលក្ខណៈអន្តរជាតិ Johnnie Walker Cambodian Open ២០០៩ នៅសាលប្រជុំសណ្ឋាគារ Sofitel Angkor Phokeethra Golf Spa&Resort នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៩។
- ចូលរួមជាតំណាងអាជ្ញាធរអប្សរា ក្នុងយុទ្ធនាការឃោសនាផ្សព្វផ្សាយទេសចរណ៍ ក្រោមប្រធានបទ " កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ "Cambodia Kingdom of Wonder" ចាប់ផ្តើមពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៩
- ចូលរួមជាសមាជិកក្នុងសិក្ខាសាលាជាតិ ស្តីពីការផ្សព្វផ្សាយទិសដៅយុទ្ធសាស្ត្រនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល និងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០០៩-២០១៣ ពិធីបិទសិក្ខាសាលាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងពិធីបើកសិក្ខាសាលា ក្រោមអធិបតីភាព ឯកឧត្តម សុខ អាន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលដែលបានប្រព្រឹត្តទៅ ពីថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំ២០០៩ នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់

- បានចូលរួមអបអរសាទរពិធីសម្ពោធទីលានប្រាសាទបន្ទាយស្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នាថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ នៅទីលានខាងមុខប្រាសាទបន្ទាយស្រី
- បានចូលរួមធ្វើជាមគ្គុទ្ទេសក៍ និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋកូរ៉េ មកទស្សនាកិច្ចនៅរមណីយដ្ឋានអង្គរនាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩
- បានចូលរួមជាគណៈអធិបតីក្នុងពិធីប្រកាសតែងតាំងអនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តសៀមរាប នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩ នៅសាលប្រជុំធំសាលាខេត្ត
- លោក ស្វាយ ពិសិដ្ឋ បានចូលរួមសិក្ខាសាលាស្តីពីការគ្រប់គ្រងទេសចរណ៍ក្នុងមហាអនុតំបន់មេគង្គនៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីថ្ងៃទី២៣ ខែវិច្ឆិកា ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៩។
- បានចូលរួមប្រជុំពេញអង្គលើកទី១៦ នៃគណៈកម្មការអន្តរជាតិសម្របសម្រួលកិច្ចគាំពារអង្គរ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រអង្គរ "ICC" ។

## X.2 **ត្រួតពិនិត្យសកម្មភាពការងារ**

- ចុះពិនិត្យលើការធ្វើអនាម័យរបស់ក្រុមហ៊ុន អេច ស៊ី ស៊ី នៅតាមរមណីយដ្ឋានសៀមរាប-អង្គរ ព្រមទាំងធ្វើការវាយតម្លៃលើការបោសសំអាតរបស់ក្រុមហ៊ុន និងធ្វើរបាយការណ៍បូកសរុបជូន ឯកឧត្តមអគ្គនាយកអាជ្ញាធរអប្សរា
- ចុះត្រួតពិនិត្យមើលសកម្មភាពការងាររបស់ក្រុមត្រួតពិនិត្យភ្ញៀវទេសចរ និងវង់ទស្សនាចរណ៍ ក្រុមស្ថិតិ និងផែនការទេសចរណ៍ និងក្រុមការងាររៀបចំ និងអនុវត្តវង់ទស្សនាចរថ្មីនៅក្នុងរមណីយដ្ឋានអង្គរ
- បានចុះពិនិត្យ និងតាមដានការរៀបចំ និងបោសសំអាតអនាម័យក្នុងបរិវេណប្រាសាទ ដើម្បីទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់ប្រធានាធិបតីប្រទេសកូរ៉េ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២២-២៣ ខែតុលា ឆ្នាំ២០០៩
- បានចុះពិនិត្យការងារចុះផ្ទៀងផ្ទាត់ទិន្នន័យតូបអ្នកលក់ដូរនៅប្រាសាទបន្ទាយស្រី ដើម្បីរៀបចំសៀវភៅបន្ទុក និងកិច្ចសន្យារវាងអ្នកលក់ដូរ និងអាជ្ញាធរអប្សរា ដែលបានអនុវត្តពីថ្ងៃទី០៧-១៣ ខែកុម្ភៈ ឆ្នាំ២០០៩
- ចុះពិនិត្យទីតាំងវិនិយោគរបស់ក្រុមហ៊ុន Sea Pac Investment Co.,Ltd នៅភូមិកំពុងភ្លុក ឃុំកំពុងភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាបនាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៩

  ចុះពិនិត្យមើលផ្លាកសញ្ញាផ្សេងៗ ស្លាកព័ត៌មានទេសចរណ៍តាមប្រាសាទនៅតំបន់រមណីយដ្ឋានអង្គរ និងលើកសំណើជូន ឯកឧត្តមអគ្គនាយកដើម្បីពិនិត្យ និងផ្តល់យោបល់ណែនាំ។
- បានចូលរួមធ្វើជាមគ្គុទ្ទេសក៍ជូនភ្ញៀវរបស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា ទស្សនកិច្ចនៅតាមប្រាសាទនានា ចំនួន ០១ថ្ងៃ នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩។
- បានចូលរួមធ្វើជាមគ្គុទ្ទេសក៍ និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ នៃសាធារណរដ្ឋកូរ៉េមកទស្សនកិច្ចនៅរមណីយដ្ឋានអង្គរនាថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩។

ការងារដែលបានអនុវត្ត

- បានចុះពិនិត្យ និងរៀបចំការងារចាំបាច់មួយចំនួននៅវត្តបាកាន និងការងាររៀបចំសៀគ្វីប្រាសាទអង្គរវត្ត
- បានចុះត្រួតពិនិត្យការគ្រប់គ្រងរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយកំប៉ុងជើងធូបនៅប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត
- ចុះតាមដានជាប្រចាំរាល់សកម្មភាពនៃការសាងសង់តូបលក់ដូររបស់អាជីវករនៅប្រាសាទបន្ទាយស្រី
- ដឹកនាំក្រុមការងារចុះអនុវត្តពិសោធន៍សាកល្បងវង់ទស្សនាប្រាសាទបន្ទាយស្រី និងចុះផ្ទៀងផ្ទាត់ទិន្នន័យតូបអ្នកលក់ដូរ ដើម្បីឈានទៅរៀបចំទីតាំងលក់ដូរថ្មីនៅប្រាសាទបន្ទាយស្រី
- បានដឹកនាំកិច្ចប្រជុំជាមួយលោកមេប៉ុស្តិ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ និងអ្នកលក់ដូរនៅប្រាសាទបន្ទាយស្រី ស្តីពីការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយ ដើម្បីត្រៀមលក្ខណៈទទួលបដិសណ្ឋារកិច្ចដំណើរទស្សនកិច្ចដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ក្នុងឱកាសសម្ពោធ Parvis នៅប្រាសាទបន្ទាយស្រី
- បានដឹកនាំកិច្ចប្រជុំជាមួយអាជីវករ អ្នកលក់ដូរចំនួន៦៨នាក់ លោកមេប៉ុស្តិ៍ មេភូមិបន្ទាយស្រី មេឃុំខ្នារសណ្តាយ និងលោកអភិបាលរងស្រុកបន្ទាយស្រី ស្តីពីការរៀបចំផ្ទេរតូបលក់ដូរពីទីតាំងចាស់ទៅទីតាំងថ្មីដែលរៀបចំឡើងដោយអាជ្ញាធរអប្សរា
- បានចូលរួមសិក្សាការងាររៀបចំគម្រោងសេវាកម្មរទេះសាឡីសំរាប់ភ្ញៀវទេសចរជិះទស្សនាកំសាន្តជុំវិញត្រពាំងនៅប្រាសាទបន្ទាយស្រី
- ដឹកនាំក្រុមការងារចុះពិនិត្យមើលជាប្រចាំ ការលក់ដូររបស់អាជីវករនៅ Parvis ថ្មី នៃប្រាសាទបន្ទាយស្រី និងពិនិត្យមើលការរុះរើតូបលក់ដូរចាស់នៅបរិវេណប្រាសាទបន្ទាយស្រី។

## XI.3- សកម្មភាពការងារតាមផ្នែក៖

### គ-១ ផ្នែករដ្ឋបាល និងបណ្តុះបណ្តាលទេសចរណ៍៖

#### គ-១-១ ការងាររដ្ឋបាលទូទៅ៖

- បានចូលរួមសហការជាមួយក្រុមការងារ ចុះធ្វើការតាមដានដំណើរការប្រព្រឹត្តទៅ នៃវង់ទស្សនាចរណ៍នៅប្រាសាទអង្គរវត្ត
- បានចូលរួមសហការជាមួយក្រុមការងារចុះអនុវត្តពិសោធន៍សាកល្បងវង់ទស្សនាចរណ៍នៅប្រាសាទបន្ទាយស្រី ពីថ្ងៃទី៣១ ខែមករា ដល់ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩
- បានចូលរួមសហការជាមួយក្រុមការងារចុះផ្ទៀងផ្ទាត់ទិន្នន័យតូបអ្នកលក់ដូរនៅប្រាសាទបន្ទាយស្រី ដើម្បីរៀបចំសៀវភៅបន្ទុក និងកិច្ចសន្យារវាងអ្នកលក់ដូរ និងអាជ្ញាធរអប្សរា ពីថ្ងៃទី០៧-១៣ ខែកុម្ភៈ ឆ្នាំ២០០៩
- បានចូលរួមសហការជាមួយក្រុមការងារ ចុះធ្វើការតាមដានដំណើរការប្រព្រឹត្តទៅ នៃវង់ទស្សនាចរណ៍នៅប្រាសាទអង្គរវត្ត
- បានធ្វើបទបង្ហាញស្តីពីការងាររបស់ផ្នែករដ្ឋបាល និងបណ្តុះបណ្តាលទេសចរណ៍ និងឆ្លើយសំនួរមួយចំនួនពាក់ព័ន្ធនឹងការងារជូនដល់ក្រុមនិស្សិតកម្មសិក្សាមកពីសាកលវិទ្យាល័យបៀលប្រាយ។

#### គ-១-២ ការងាររបៀប៖

- ទទួលឯកសារចូលបានចំនួន៩៩៧ច្បាប់ (គិតចាប់ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩)
- បញ្ជូនឯកសារចេញបានចំនួន៣៦៧ច្បាប់ (គិតចាប់ពីថ្ងៃទី២៦ ខែមេសា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩)
- បានរៀបចំលិខិតអនុញ្ញាតអោយ ចេញ-ចូល រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ (ចំនួន ៣៣១ លិខិត)
- បានរៀបចំលិខិតអនុញ្ញាតអោយរៀបចំពិធីផ្សេងៗ និងថតរូបភាពនៅក្នុងរមណីយដ្ឋានអង្គរ (រៀបចំពិធី និងសម្តែងសិល្បៈចំនួន២៦លិខិត និងលិខិតអនុញ្ញាតអោយថតរូបភាពចំនួន៥២លិខិត)។

**គ-២ ផ្នែកស្ថិតិ និងផែនការទេសចរណ៍៖**

**គ-២-១ ការងារត្រួតពិនិត្យបញ្ជរលក់ប័ណ្ណចូលទស្សនាប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ**

លទ្ធផលដែលទទួលបានក្នុងឆ្នាំ២០០៩ មានដូចខាងក្រោម៖

| ឆ្នាំ២០០៩ | ចំនួនភ្ញៀវ | ទឹកប្រាក់គិតជាដុល្លារ |
|---|---|---|
| មករា | ១០៧ ៣៣៩ នាក់ | ៣ ១៩៥ ០៨០ |
| កុម្ភៈ | ៩៥ ០០៦ នាក់ | ២ ៧៨៨ ០៦០ |
| មីនា | ៨៦ ៥៩៨ នាក់ | ២ ៥៩៥ ០៦០ |
| មេសា | ៦៦ ១៦៨ នាក់ | ១ ៨៨៧ ៧០០ |
| ឧសភា | ៥៦ ៩៨៩ នាក់ | ១ ៥៥៣ ០២០ |
| មិថុនា | ៤៣ ១៧៤ នាក់ | ១ ១៣៩ ៤៤០ |
| កក្កដា | ៦៥ ៣៦៥ នាក់ | ១ ៧៩៣ ៩០០ |
| សីហា | ៧៥ ៤៥៣ នាក់ | ២ ១៧៨ ៥៨០ |
| កញ្ញា | ៥២ ៩៨០ នាក់ | ១ ៥៣៥ ៤៤០ |
| តុលា | ៦៩ ៩៥៩ នាក់ | ២ ០៧៣ ៥៤០ |
| វិច្ឆិកា | ៩៤ ៧៥៦ នាក់ | ២ ៩០៤ ៩៤០ |
| ធ្នូ | ១០៣ ៩៦៣ នាក់ | ៣ ១៦៤ ៦៤០ |
| **សរុប** | **៩១៧ ៦៥០ នាក់** | **២៦ ៦៥៩ ៤០០ ដុល្លារ** |

**គ-២-២ ចំនួនភ្ញៀវទេសចរ ដែលចូលទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរ ដោយឥតបង់ថ្លៃ៖**

ចំនួនភ្ញៀវទេសចរ ជាគណៈប្រតិភូផ្លូវការរដ្ឋ ដែលអញ្ជើញមកតាមរយៈក្រសួង មន្ទីរ និងស្ថាប័ននានារបស់រដ្ឋ ព្រមទាំងអ្នកស្រាវជ្រាវ អ្នកជូសជុលប្រាសាទ នៅក្នុង៩ខែ ឆ្នាំ២០០៩ មានចំនួនដូចខាងក្រោម៖

| ឆ្នាំ ២០០៩ | ចំនួនគណៈប្រតិភូ | ចំនួនថ្ងៃ | ចំនួននាក់ថ្ងៃ |
|---|---|---|---|
| មករា | ២៧៧ នាក់ | ២១ ថ្ងៃ | ៥៥៦ ថ្ងៃ |
| កុម្ភៈ | ២៥៦ នាក់ | ២១ ថ្ងៃ | ៣១០ ថ្ងៃ |
| មីនា | ៣៥៦ នាក់ | ៣៦ ថ្ងៃ | ៥៧២ ថ្ងៃ |
| មេសា | ៣១៥ នាក់ | ២៥ ថ្ងៃ | ៣៩២ ថ្ងៃ |
| ឧសភា | ៥៧៣ នាក់ | ៣២ ថ្ងៃ | ៥៥៥ ថ្ងៃ |
| មិថុនា | ៥០៨ នាក់ | ៣៦ ថ្ងៃ | ៥៨១ ថ្ងៃ |
| កក្កដា | ៥៨០ នាក់ | ៣៩ ថ្ងៃ | ៥៥៩ ថ្ងៃ |
| សីហា | ៥៨២ នាក់ | ៣៥ ថ្ងៃ | ៦៦១ ថ្ងៃ |
| កញ្ញា | ៣៨០ នាក់ | ២៧ ថ្ងៃ | ៥០៧ ថ្ងៃ |
| តុលា | ៨២១ នាក់ | ៥៥ ថ្ងៃ | ១ ០៦៨ ថ្ងៃ |
| វិច្ឆិកា | ៨៥១ នាក់ | ៦០ ថ្ងៃ | ១ ២២៦ ថ្ងៃ |
| ធ្នូ | ២ ៥៨៣ នាក់ | ៦០ ថ្ងៃ | ២ ៨០០ ថ្ងៃ |
| **សរុប** | **៧ ៦៦១ នាក់** | **៤៤៥ ថ្ងៃ** | **៩ ៣៧៧ ថ្ងៃ** |

| ឆ្នាំ ២០០៩ | ចំនួនអ្នកស្រាវជ្រាវ | |
|---|---|---|
| មីនា | ៥៩ នាក់ | |
| មេសា | ៥០ នាក់ | |
| ឧសភា | ១១ នាក់ | |
| មិថុនា | ៩៧ នាក់ | |
| កក្កដា | ៣៤ នាក់ | |
| សីហា | ៥៨ នាក់ | |
| កញ្ញា | ៤៣ នាក់ | |
| តុលា | ៩០ នាក់ | |

| | | |
|---|---|---|
| វិច្ឆិកា | ៥៩ នាក់ | |
| ធ្នូ | ១៤២ នាក់ | |
| **សរុប** | **៦៣៣ នាក់** | |

**គ-២-៣ ការងារចុះស្រង់ស្ថិតិភ្ញៀវទេសចរ ក្នុងឆ្នាំ២០០៩**

| ការរាប់ភ្ញៀវ | ប្រាសាទអង្គរវត្ត | ប្រាសាទតាព្រហ្ម | ប្រាសាទបន្ទាយស្រី | ប្រាសាទប្រែរូប |
|---|---|---|---|---|
| **ចំនួនថ្ងៃ** | **14** | **7** | **7** | **7** |
| - ភ្ញៀវខ្មែរក្នុងមួយថ្ងៃៗ គិតជាមធ្យម | 1 010 | 174 | 131 | 25 |
| - ភ្ញៀវជប៉ុនក្នុងមួយថ្ងៃៗ គិតជាមធ្យម | 460 | 481 | 371 | 189 |
| - ភ្ញៀវចិនក្នុងមួយថ្ងៃៗ គិតជាមធ្យម | 470 | 600 | 518 | 260 |
| - ភ្ញៀវកូរ៉េក្នុងមួយថ្ងៃៗ គិតជាមធ្យម | 338 | 359 | 217 | 55 |
| - ភ្ញៀវអាស៊ីក្នុងមួយថ្ងៃៗ គិតជាមធ្យម | 362 | 554 | 221 | 56 |
| - ភ្ញៀវអឺរ៉ុបក្នុងមួយថ្ងៃៗ គិតជាមធ្យម | 1 477 | 1 021 | 819 | 367 |
| **សរុបចំនួនភ្ញៀវជាមធ្យម ក្នុងមួយថ្ងៃៗ /នាក់** | **4 116** | **3 189** | **2 277** | **952** |

- ប្រាសាទ **អង្គរវត្ត** ជាមធ្យមក្នុងមួយថ្ងៃៗ មានភ្ញៀវចូលទស្សនា ចំនួន ៖ **4 116** នាក់ ។
- ប្រាសាទ **តាព្រហ្ម** ជាមធ្យមក្នុងមួយថ្ងៃៗ មានភ្ញៀវចូលទស្សនា ចំនួន ៖ **3 189** នាក់ ។
- ប្រាសាទ **បន្ទាយស្រី** ជាមធ្យមក្នុងមួយថ្ងៃៗ មានភ្ញៀវចូលទស្សនា ចំនួន ៖ **2 277** នាក់ ។
- ប្រាសាទ **ប្រែរូប** ជាមធ្យមក្នុងមួយថ្ងៃៗ មានភ្ញៀវចូលទស្សនា ចំនួន ៖ **952** នាក់ ។

**គ-២-៤ ស្ថិតិភ្ញៀវទេសចរបរទេស ដែលបានទិញសំបុត្រចូលទស្សនាប្រាសាទ បេងមាលា និងកោះកែរ**

ទិន្នន័យភ្ញៀវទេសចរបរទេស ដែលបានទិញសំបុត្រ តាមខែក្នុងឆ្នាំ២០០៩ មានចំនួនដូចខាងក្រោម៖

| ចំនួនភ្ញៀវទេសចរបរទេស ដែលទិញសំបុត្រចូលទស្សនា ប្រាសាទបេងមាលា និងប្រាសាទកោះកែរ-ឆ្នាំ២០០៩ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ល.រ | ខែ | ប្រាសាទបេងមាលា | | ប្រាសាទកោះកែរ | | សរុបរួម | | ផ្សេងៗ |
| | | ភ្ញៀវទេសចរ | ទឹកប្រាក់ ($) | ភ្ញៀវទេសចរ | ទឹកប្រាក់ ($) | ភ្ញៀវទេសចរ | ទឹកប្រាក់ ($) | |
| ១ | កក្កដា | 3,600 | 18,000 | 188 | 1,880 | 3,788 | 19,880 | |
| ២ | សីហា | 5,858 | 29,290 | 365 | 3,650 | 6,223 | 32,940 | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | កញ្ញា | 5,135 | 25,675 | 199 | 1,990 | 5,334 | 27,665 | |
| ៤ | តុលា | 6,126 | 30,630 | 249 | 2,490 | 6,375 | 33,120 | |
| ៥ | វិច្ឆិកា | 6,413 | 32,065 | 451 | 4,510 | 6,864 | 36,575 | |
| ៦ | ធ្នូ | | | | | | | |
| សរុប | | **20,719** | **103,595** | **1,001** | **10,010** | **21,720** | **113,605** | |

*(ទិន្នន័យនេះ អង្គភាពទទួលបានពីក្រុមហ៊ុន **ខាំ សូមេធ កូអិលធីឌី** តាមរយៈរបាយការណ៍របស់ក្រុមហ៊ុន ហើយអង្គភាពក៏បានធ្វើការបូកសរុប ដោយធ្វើជារបាយការណ៍ខ្លីស្តីពីការលក់ប័ណ្ណចូលទស្សនានេះ។ បញ្ជាក់៖ អង្គភាពទើបតែទទួលបានទិន្នន័យស្តីពីការលក់សំបុត្រនេះ ពីខែកក្កដា ដល់ខែតុលា ឆ្នាំ២០០៩)។*

**គ-៣ ផ្នែកត្រួតពិនិត្យភ្ញៀវ និងវង់ទស្សនាចរណ៍៖**

**គ-៣-១ ការងារគ្រប់គ្រងភ្នាក់ងារសណ្តាប់ធ្នាប់តាមប្រាសាទ៖**

- បានចូលរួម និងចាត់ចែងភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ បោចស្មៅ និងបោសសំអាតជាប្រចាំនៅតាមទីលានប្រាសាទ។
- បានប្រជុំក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ ដើម្បីពង្រឹងសណ្តាប់ធ្នាប់ការងារ និងរបៀបរៀបរយនៅតាមប្រាសាទ
- បានរៀបចំ និងចាត់បញ្ជូនភ្នាក់ងារសណ្តាប់ធ្នាប់ ឲ្យចូលរួមរៀបចំសណ្តាប់ធ្នាប់ភ្ញៀវទេសចរនៅរាល់ការអនុញ្ញាតសម្តែងសិល្ប: និងទទួលទានអាហារពេលយប់នៅតាមទីលានប្រាសាទ
- បានចូលរួម និងចាត់ចែងភ្នាង់ងារសណ្តាប់ធ្នាប់ទេសចរណ៍ សហការជាមួយឆ្មាំអភិរក្សប្រាសាទ ធ្វើស្ពានសំរាប់ដើរឆ្លងក្នុងពេលទឹកលិចផ្លូវនៅប្រាសាទនាគព័ន្ធ ប្រាសាទតាព្រហ្ម
- បានចាត់ចែងភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ ចូលរួមសហការជាមួយឆ្មាំអភិរក្សប្រាសាទ និងកំលាំងសមត្ថកិច្ចតាមគោលដៅនីមួយៗនៅប្រាសាទជួយសង្គ្រោះ និងដឹកភ្ញៀវទេសចរដែលជួបគ្រោះថ្នាក់ផ្សេងៗនៅតាមប្រាសាទទៅកាន់មន្ទីរពេទ្យ ដូចជាការដួលធ្លាក់ពីលើកាំជណ្តើរមុខខាងកើតនៃប្រាសាទភិមានអាកាស ភ្ញៀវរអិលដួលរបួសនៅភ្នំបាខែង ភ្ញៀវបានធ្លាក់ពិបណ្ណាល័យខាងជើងនៃប្រាសាទបាយ័ន។ល។
- បានប្រជុំក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ ដើម្បីដាក់ផែនការការពារសន្តិសុខសណ្តាប់ធ្នាប់ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងបានធ្វើការពង្រឹងវិន័យបន្ថែមទៀតដល់ក្រុមភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍តាមគ្រប់គោលដៅ

**គ-៣-២ ការងារគ្រប់គ្រងសណ្តាប់ធ្នាប់ទីលានប្រាសាទ៖**

- បានចូលរួម និងចាត់ចែងភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍ សហការជាមួយឆ្មាំអភិរក្សប្រាសាទ ធ្វើស្ពានសំរាប់ដើរឆ្លងក្នុងពេលទឹកលិចផ្លូវនៅប្រាសាទនាគព័ន្ធ ប្រាសាទតាព្រហ្ម
- បានទប់ស្កាត់អ្នកធ្វើអាជីវកម្មថតរូបភ្ញៀវទេសចរដាក់ចាន ដោយគ្មានការអនុញ្ញាតជាផ្លូវការពីអាជ្ញាធរអប្សរា ដែល

បណ្តាលឲ្យមានការរំខានដល់ការទស្សនារបស់ភ្ញៀវទេសចរនៅប្រាសាទអង្គរវត្ត ភិមានអាកាស បន្ទាយស្រី និង បាគង

- បានចុះពិនិត្យជាប្រចាំ និងណែនាំដល់ភ្ញៀវទេសចរដែលស្លៀកពាក់ មិនសមរម្យ សក្តិសមទៅនឹងរមណីយដ្ឋាន ដែលជាទីកន្លែងសក្ការៈបូជា
- បានធ្វើការណែនាំអ្នកលក់ដូរវត្ថុអនុស្សាវរីយ៍នៅតាមប្រាសាទ ឲ្យរក្សារបៀបរៀបរយឲ្យបានល្អក្នុងការលក់ដូរ និង មិនអនុញ្ញាតឲ្យរត់ប្រដេញភ្ញៀវដើម្បីលក់របស់របរដែលនាំឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ
- បានទប់ស្កាត់ និងហាមឃាត់រាល់ការថតរូបភាព នៅក្នុងបរិវេណប្រាសាទ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរអប្សរា និងបានណែនាំឲ្យមកសុំការអនុញ្ញាតពីមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរអប្សរា
- បានទប់ស្កាត់ និងអប់រំចំពោះក្មេងៗដែលធ្វើសកម្មភាពសុំលុយភ្ញៀវនៅតាមប្រាសាទ ដូចជាតាមផ្លូវឡើងភ្នំបាខែង និងនៅតាមប្រាសាទមួយចំនួនទៀត
- បានទប់ស្កាត់ភ្ញៀវទេសចរដែលប្រើប្រាស់យានជំនិះជិះចូលទស្សនាដល់ក្នុងបរិវេណប្រាសាទ ដូចជានៅប្រាសាទ ភិមានអាកាសជាដើម ដែលភ្ញៀវទេសចរតែងតែជិះចូលជាប្រចាំ

**គ-៣-៣ ការងារគ្រប់គ្រងភ្ញៀវទេសចរៈ**

- បានធ្វើការហាមឃាត់ និងរាយការណ៍ជូននគរបាលការពារបេតិកភណ្ឌឲ្យចុះជួយធ្វើអន្តរាគមន៍កាលពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៩ នៅប្រាសាទបាភួន ករណីយមានជនជាតិចិនមួយរូបបានលើកដុំថ្មទំលាក់មកខាងក្រោមបែក ជាបួនបំនែក បន្ទាប់មកនគរបាលការពារបេតិកភណ្ឌ ក៏បាននាំខ្លួនភ្ញៀវទេសចរនោះទៅណែនាំ និងធ្វើកំណត់ហេតុ ដោះស្រាយ
- បានទប់ស្កាត់បានទាន់ពេលវេលា សកម្មភាពប្រថាប់រូបនៅប្រាសាទអង្គរវត្ត កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៩ ដោយភ្ញៀវជនជាតិអូស្ត្រាលីមួយរូប និងនៅប្រាសាទបន្ទាយស្រី កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០៩ ដោយភ្ញៀវ ជនជាតិចិនមួយរូប។

**គ-៤ ផ្នែកត្រួតពិនិត្យគុណភាព និងបទដ្ឋានទេសចរណ៍ៈ**

**គ-៤-១ ការងារដែលបានអនុវត្តៈ**

- ចុះត្រួតពិនិត្យការងារនៅប្រាសាទបន្ទាយស្រី និងកន្លែងលក់ដូរ
- ចូលរួមប្រជុំពិភាក្សាជាមួយ Private Sector ដើម្បីផ្សព្វផ្សាយអំពីការបើកសាកល្បងជូនភ្ញៀវទស្សនានៅរូតបាកាន
- បានចូលរួមធ្វើបទបង្ហាញជូនភ្ញៀវមកពី វៀតណាម ចិន និងថៃ នៅសណ្ឋាគារ Allson Angkor Paradise ស្តីអំពីការ គ្រប់គ្រងទេសចរណ៍នៅកម្ពុជា
- បានរៀបចំលិខិតស្នើសុំប៉ានល្អបទបញ្ញាអ្នកទស្សនា ដើម្បីដាក់តាមប្រាសាទសំខាន់ៗនៅក្នុងរមណីយដ្ឋានអង្គរ
- បានធ្វើបទបង្ហាញអំពីវិស័យទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជាជូនភ្ញៀវទេសចរជនជាតិជប៉ុនរបស់ក្រុមហ៊ុន PM Green
- បានធ្វើបទបង្ហាញស្តីពីដំណើរការសាកល្បងបើកជូនភ្ញៀវទស្សនារូតបាកាននៃប្រាសាទអង្គរវត្ត
- បានចូលរួមប្រជុំស្តីពីការរៀបចំទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់នៃសាធារណៈរដ្ឋកូរ៉េ និងចូលរួមទទួល

ដំណើរមកដល់របស់គណៈប្រតិភូ

- បានចូលរួមប្រជុំការងាររៀបចំកន្លែងលក់ដូរនៅទីលានប្រាសាទតាព្រហ្មផ្នែកខាងកើតជាបណ្តោះអាសន្ន និងចុះពិនិត្យមើលស្ថានភាពការលក់ដូរនៅប្រាសាទតាព្រហ្ម
- បានរៀបចំអត្ថបទសំរាប់ចុះព្រឹត្តិបត្រអាជ្ញាធរអប្សរា ស្តីអំពីការរៀបភ្ញៀវនៅប្រាសាទភ្នំបាខែង។

**គ-៤-២ ការងារត្រូវអនុវត្តបន្តៈ**

- ពិនិត្យ និងតាមដានការងាររៀបចំទីលានមុខប្រាសាទតាព្រហ្ម
- រៀបចំសរសេរអត្ថបទចុះក្នុងព្រឹត្តិប័ត្រប្រចាំខែអាជ្ញាធរអប្សរា
- រៀបចំការងារបើកអោយដំណើរការវង់ទស្សនាចរណ៍នៅជាន់បាកាន។

**គ-៥ ផ្នែកវិនិយោគ អាជីវកម្ម សេវាកម្ម និងផ្សព្វផ្សាយទេសចរណ៍ៈ**

**គ-៥-១ ការងារដែលបានបំពេញៈ**

- ចុះធ្វើការអប់រំបរិស្ថានដល់អ្នកលក់ដូរ និងភ្នាក់ងារសណ្តាប់ធ្នាប់ទេសចរណ៍
- បានចូលរួមសវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថានរបស់អាជ្ញាធរអប្សរា
- បានរៀបចំសេចក្តីព្រាង សន្ទរកថាជាភាសាអង់គ្លេស ជូនឯកឧត្តមអគ្គនាយក សំរាប់ចុះផ្សាយក្នុងទស្សនាវដ្តីប្រកួតកូនគោល Cambodia Open 2009 និងបានរៀបចំសេចក្តីព្រាងសន្ទរកថាជាភាសាខ្មែរ-អង់គ្លេស ជូន ឯកឧត្តមអគ្គនាយក សំរាប់សន្និសិទសារព័ត៌មានប្រកួតកូនគោល នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩ នៅមុខប្រាសាទអង្គរវត្ត។
- បានចុះស្រង់ទិន្នន័យ Secondary data និងរៀបចំបញ្ជីទទឹងអ្នកលក់ដូរនៅប្រាសាទបន្ទាយស្រី និងប្រាសាទតាព្រហ្ម
- បានរៀបចំលក្ខន្តិកៈកិច្ចសន្យាអ្នកលក់ដូរនៅប្រាសាទបន្ទាយស្រី។

**គ-៥-២ ការងារដែលត្រូវអនុវត្តបន្តៈ**

- បន្តរៀបចំឯកសាររបាយការណ៍ពាក់ព័ន្ធការងារគ្រប់គ្រងបរិស្ថានសំរាប់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ
- បន្តការតាមដាន និងពិនិត្យស្ថានភាពបង្គន់អនាម័យក្នុងរមណីយដ្ឋានអង្គរ
- បន្តរៀបចំឯកសាររបាយការណ៍ពាក់ព័ន្ធការងារគ្រប់គ្រងបរិស្ថានរបស់នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ
- រៀបចំការងារអប់រំបរិស្ថានដល់ភ្នាក់ងារសណ្តាប់ធ្នាប់ និងអ្នកលក់ដូរ
- ចងក្រងឯកសារពាក់ព័ន្ធនឹងទិន្នន័យអ្នកលក់ដូរ និងអាជីវកម្មនៅក្នុងរមណីយដ្ឋានអង្គរ
- រៀបចំលក្ខន្តិកៈ និងកំណត់ប្រភេទសំរាប់ទាក់ទាញការវិនិយោគ និងគម្រោងអាជីវកម្មនានា
- បន្តការរៀបចំបញ្ជូនព្រឹត្តិប័ត្រព័ត៌មានទេសចរណ៍ជូននាយកដ្ឋានផ្សព្វផ្សាយ ដើម្បីចុះក្នុងព្រឹត្តិប័ត្រប្រចាំខែអាជ្ញាធរអប្សរា
- បន្តសហការរៀបចំសេវាកម្មរទេះគោសាឡីនៅប្រាសាទបន្ទាយស្រី
- បន្តសហការជាតាមដានដំណើរការគ្រប់គ្រងទីលានប្រាសាទបន្ទាយស្រី។

**គ.៦ ការងារអង្គភាពរថយន្តអគ្គិសនី ៧មករា**

- **ការងារទូទៅ៖**

- បានរៀបចំដាក់ឲ្យដំណើរការកង់អាគុយ ក្នុងបរិវេណអតីតរាជធានីអង្គរ ចាប់ពីថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩
- បានរៀបចំធ្វើពោងសំរាប់សាក និងចតរថយន្តអគ្គិសនីឲ្យបានសមរម្យក្នុងអភិរក្សដ្ឋានអង្គរសំរាប់រដូវភ្លៀង

- **ការងារផ្សព្វផ្សាយ និងទីផ្សារ៖**

- បានរៀបចំផ្សព្វផ្សាយពីអាជីវកម្មក្នុងព្រឹត្តិប័ត្រផ្សព្វផ្សាយរបស់អាជ្ញាធរអប្សរា
- បានដាក់បដាផ្សព្វផ្សាយអំពីរថយន្តអគ្គិសនី ៧មករា ចំនួន៥គ្រឿង
- បានរៀបចំ និងចាក់ផ្សាយស្ប៉ុតសេវារថយន្តអគ្គិសនី ៧មករា ចំនួន០៣(បី)ស្ប៉ុត
- បានផ្សព្វផ្សាយពីសេវារថយន្តអគ្គិសនី ៧មករា ក្នុងទស្សនាវដ្ដីមគ្គុទ្ទេសក៍ទេសចរណ៍ CAN BY ចំនួន ០២លើក
- បានសហការជាមួយកាសែតរស្មីកម្ពុជា ដើម្បីផ្សព្វផ្សាយពីអត្ថប្រយោជន៍នៃរថយន្តអគ្គិសនី ៧មករា ក្នុងឧទ្យានអង្គរ
- បានរៀបចំអាវ និងមួកផ្សព្វផ្សាយ អង្គភាពរថយន្តអគ្គិសនី ៧មករា សំរាប់ទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ និងមគ្គុទ្ទេសក៍ទេសចរណ៍
- បានចុះទំនាក់ទំនងជាមួយក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ សាកលវិទ្យាល័យ សារមន្ទីរ និងបានដាក់ខិតប័ណ្ណផ្សព្វផ្សាយជាភាសាខ្មែរ និងជាភាសាអង់គ្លេស និងបានចែកចាយសៀវភៅព្រឹត្តិប័ត្រប្រចាំខែរបស់អាជ្ញាធរអប្សរា

- **លទ្ធផលអាជីវកម្ម ៩ខែ-២០០៩៖**

| ខែ - ឆ្នាំ | ចំណូល | ប្រភពចំណូល |
|---|---|---|
| មករា ២០០៩ | ២ ៧៣៩ ដុល្លារ | - ជួលរថយន្តប្រចាំខែ<br>- រថយន្តជួលប្រចាំថ្ងៃ<br>- ភ្ញៀវជិះរថយន្តដោយប្រើសំបុត្រ<br>- ភ្ញៀវជិះរថយន្តដោយប្រើ Voucher<br>- ជួលកង់អាគុយ |
| កុម្ភៈ ២០០៩ | ៣ ០០៨ ដុល្លារ | |
| មីនា ២០០៩ | ៣ ២៨៩ ដុល្លារ | |
| មេសា ២០០៩ | ៣ ៥២៣ ដុល្លារ | |
| ឧសភា ២០០៩ | ៣ ៣៨២.៥០ ដុល្លារ | |
| មិថុនា ២០០៩ | ២ ២៨៣ ដុល្លារ | |
| កក្កដា ២០០៩ | ២ ៦១៧.៥០ ដុល្លារ | |
| សីហា ២០០៩ | ២ ៧៨៦ ដុល្លារ | |
| កញ្ញា ២០០៩ | ២ ៩៥៥៤ ដុល្លារ | |
| តុលា ២០០៩ | ៣ ៦៥៦ ដុល្លារ | |

| | | |
|---|---|---|
| វិច្ឆិកា ២០០៩ | ៩ ៣៨៣.៥០ ដុល្លារ | |
| ធ្នូ ២០០៩ | ៩ ៦១៦ ដុល្លារ | |
| សរុបរួម | **៣៩ ២៣៧.៥ ដុល្លារ** | |

# XII. នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងគម្រោងអន្តរវិស័យ

ចាប់តាំងពីបង្កើតឡើងនៅឆ្នាំ២០០៨មក នាយកដ្ឋាននេះមានបុគ្គលិកបច្ចេកទេសដើម្បីអនុវត្តបេសកកម្មរបស់ខ្លួន។ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អាជ្ញាធរជាតិអប្សរាអោយនាយកដ្ឋានទាំងអស់មានសេវាដូចគ្នា ដូចជាការិយាល័យសម្របសម្រួលនិងទ្រទ្រង់សកម្មភាព នាយកដ្ឋាននេះ បានបង្កើតការិយាល័យបច្ចេកទេសពីរ។ ដូច្នេះ នាយកដ្ឋានមានការិយាល័យទាំងអស់ចំនួន៤ រួមទាំងមជ្ឈមណ្ឌលតំកល់ឯកសារអង្គរ។

សម្រាប់ឆ្នាំ២០០៩ សកម្មភាពនៃការិយាល័យនីមួយៗអាចសង្ខេបដូចខាងក្រោម៖

## ១-ការិយាល័យសម្របសម្រួល និងគាំទ្រសកម្មភាព៖

- រៀបចំគម្រោងចំណាយថវិកា និងសម្ភារៈការិយាល័យប្រចាំឆ្នាំ២០០៩
- ទទួលព្រឹត្តប័ត្រព័ត៌មាន **អាជ្ញាធរអប្សរា** ឆ្នាំទី៤ ចំនួន០៩លេខ ពីលេខ២៩ដល់លេខ៣៧ ប្រចាំខែកុម្ភៈ ដល់ខែវិច្ឆិកា ឆ្នាំ២០០៩ សរុបចំនួន២៧០ក្បាល និងធ្វើការចែកចាយទៅការិយាល័យនីមួយៗក្នុងនាយកដ្ឋាន
- មានបុគ្គលិកថ្មី២រូប៖ លោក ហេង ហ្សេរ៉ូនី និងលោក ជួន ប៊ុនណាត ផ្លាស់មកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ។ បុគ្គលិករបស់នាយកដ្ឋានសរុបមានចំនួន១៨រូប។
- រៀបចំ និងចុះលេខលិខិតចូលបានចំនួន១០៦០លិខិត និងលិខិតចេញបានចំនួន១៤០លិខិត
- រៀបចំការប្រជុំការងារផ្ទៃក្នុងនៃនាយកដ្ឋានចំនួន២លើក
- តាមដាន និងរៀបចំលិខិតស្នាមរបស់នាយកដ្ឋាន។

## ២-ការិយាល័យទ្រទ្រង់គម្រោងអន្តរវិស័យ៖

### សិក្សា និងគូរប្លង់៖

- សិក្សា និងបញ្ចប់ប្លង់អគារបដិសណ្ឋារកិច្ច និងCentre d'interpretation Parvis Angkor Vat

### ការងារសហការជាមួយស្ថាប័នផ្សេង៖

- កំពុងធ្វើការងារជាប្រធានក្រុមការងារបច្ចេកទេស និងចល័តនៃលេខាធិការដ្ឋាននៃក្រុមការងារពិសេសថ្នាក់ជាតិប្រាសាទព្រះវិហារ
- សហការជាមួយលោក Ahmed Bennys អ្នកជំនាញការអន្តរជាតិអំពីគម្រោងបំភ្លឺភ្លើងពេលរាត្រីនៅប្រាសាទអង្គរវត្ត

- សហការក្នុងក្របខ័ណ្ឌការងារបច្ចេកទេសជាមួយអាជ្ញាធរជាតិព្រះវិហារ ក្នុងការងារកំណាយស្រាវជ្រាវនៅប្រាសាទព្រះវិហារ
- សហការក្នុងក្របខ័ណ្ឌការងារនៃគម្រោងស្តារ និងលើកតម្លៃបារាយណ៍ខាងលិច។

**ចូលរួមអនុវត្តន៍ការងារះ**

- ចូលរួមក្នុងគណៈកម្មការដេញថ្លៃគម្រោងសាងសង់បង្គន់សាធារណៈក្នុងរមណីយដ្ឋានអង្គរ
- បញ្ចប់គម្រោងសាងសង់បង្គន់សាធារណៈនៅប្រាសាទតាព្រហ្ម និងបន្ទាយស្រីនៅដំណាច់ខែវិច្ឆិកា។ កំពុងបន្តពិនិត្យ និងតាមដានគម្រោងសាងសង់បង្គន់សាធារណៈនៅប្រាសាទបាគង។
- ចូលរួមដំណើរការជីកប្រឡាយរំដោះទឹកជំនន់ដែលជន់លិចសួនរុក្ខជាតិសម្តេចម៉ែ ដោយជីកពីផ្លូវទៅអង្គរខាងជើងសាលារៀន SOS ឆ្ពោះទៅស្ទឹងសៀមរាបត្រង់ចំណុចស្ពានរ៉ាករ៉ាក។
- ចូលរួមអនុវត្តន៍ការងារក្នុងគម្រោងសួនគ្រឿងទេសះ ការងារធ្វើបានលេខាកំណត់អ័ក្សផ្លូវ និងកំណត់ទីតាំងផ្សេងៗទៀត។ ធ្វើការឈូសឆាយពង្រាបដីបានចំនួន៧៦១៨មការ៉េ និងកំពុងបន្តលើកគម្រោងចាក់ដីបន្ថែមទៀត។
- ចូលរួមអនុវត្តន៍ការងារក្នុងគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯកះ ចុះធ្វើបានលេខាកំណត់ដីឡូត៍ប្រជាជនបានចំនួន៨០ឡូត៍ និងកំពុងបន្តធ្វើទៀត។
- ចូលរួមក្នុងការងារសាងសង់បញ្ចរលក់សំបុត្រនៅផ្លូវវាងខាងត្បូងក្រុងសៀមរាបះ សម្រេចបានការជីករណ្ដៅគ្រឹះ និងចាក់បេតុង ជើងតាងគ្រឹះរួចរាល់ជាស្ថាពរ និងកំពុងបន្តតំឡើងពុម្ពសសរ។

## ៣-ការិយាល័យផ្លូវថ្នល់ និងស្ពានះ

**ការងារសិក្សាគម្រោង ថែទាំផ្លូវ និងស្ពានះ**

- សិក្សាគម្រោងសាងសង់ផ្លូវដើរនៅទីលានប្រាសាទបន្ទាយស្រី និងស្ពានបេតុងប្រវែង៥ម ទទឹង៣,៥ម
- សិក្សាគម្រោងជួសជុលលុបក្រឡុកផ្លូវពីប្រដាក ដល់ប្រាសាទបន្ទាយស្រី
- សិក្សាផ្លូវដាច់ជាប់ផ្លូវជាតិលេខ១៧ ចូលទៅភូមិធម្មជាតិរុនតាឯក (កំពុងសិក្សា)
- លូដោះទឹក២កន្លែង (ផ្លូវក្លូម៉ែ១កន្លែង និងវង្សធំ១កន្លែង)
- ស្ពានប្រាសាទតាកែវ (កំពុងសិក្សា)
- ស្ពានតាអោង ស្ថិតក្នុងស្រុក សូទ្រនិគម (កំពុងសិក្សា)។

**ការងារចុះពិនិត្យ និងតាមដានគម្រោងកំពុងអនុវត្តះ**

- គម្រោងសាងសង់ស្ពានវាងខាងត្បូងក្រុងសៀមរាប
- គម្រោងនៅភូមិធម្មជាតិរុនតាឯក (កំពុងរៀបចំប្លង់គោល)
- គម្រោងសួនគ្រឿងទេស
- តាមដានការងារសាងសង់ស្ពានបន្ទាយស្រី
- តាមដានការងាររៀបចំទីលានចំណតរថយន្តខាងមុខប្រាសាទបន្ទាយស្រី

- តាមដានការងារជួសជុលផ្លូវជុំវិញកសិណអង្គរវត្ត
- តាមដានការងារជួសជុលផ្លូវពីប្រាសាទមេបុណ្យទៅស្ពានក្រាំងក្រូច
- តាមដានការងារជួសជុលជើងទេប្រឡាយ **T2** ។

**ការងារបានសំរេចរួច១០០%**

- ការងារជួសជុលផ្លូវ **T1** និងជាប់ផ្លូវជាតិលេខ៦ចំនួន៨៣២មការ៉េ
- ការងារជួសជុលក្រឡុកសំបុកមាន់ប្រភេទ MAKADAM ពីកែង **T3** រហូតដល់ផ្លូវចូលប្រាសាទតាព្រហ្មខាងកើតរួច
- ការងារជួសជុលក្រឡុកសំបុកមាន់ប្រើថ្ម M30 កំណាត់ផ្លូវកូម៉ៃ
- ការងារជួសជុលក្រឡុកពីមុខប្រាសាទអង្គរវត្តទៅព្រលានយន្តហោះ
- ការងារដាំស្មៅធ្វើសួនច្បារនៅកែង**T3** និងស្ពារប្រឡាយ
- ធ្វើផ្លូវលើខ្ទងលូផ្លូវចូលអង្គរវត្តខាងកើត។

**ការិយាល័យផ្លូវថ្នល់៖** មានកម្មករចំនួន៨នាក់ សំរាប់អនុវត្តការងារ។

## ៤-ការិយាល័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងគ្រប់គ្រងទិន្នន័យ៖

### ក. ការងារប្រមូល និងចុះយកទិន្នន័យ

- ចុះយកទិន្នន័យផ្លូវលេខ៦៧ចាប់ពីផ្លូវជាតិលេខ៦ដល់ក្បាលស្ពាន
- ចុះយកចំនុចទីតាំងដីរបស់ក្រុមហ៊ុនផលិតទឹកបរិសុទ្ធ KURALA WATER CO.,LTD ជាមួយនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ និងនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ។
- ទទួលទិន្នន័យតំបន់សំអាតមីនរួច និងតំបន់មានមីនក្នុងខេត្តសៀមរាប និងខេត្តព្រះវិហារដែលទទួលបានពីអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA)។
- ជួបពិភាក្សា និងសាកសួរព័ត៌មានអំពីទិន្នន័យនៃការប្រើប្រាស់ប្រព័ន្ធធ្វើផែនទីនៅការិយាល័យប្រព័ន្ធព័ត៌មានភូមិសាស្ត្រនៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ក្រុងភ្នំពេញ។

### ខ. ការងារកែសម្រួល និងបញ្ចូលទិន្នន័យ

- កែសម្រួលទិន្នន័យផ្លូវរបស់ JICA ឆ្នាំ២០០៥
- បញ្ចូលទិន្នន័យស្ពានថ្មីៗ ផ្លូវថ្មី (ផ្លូវ៦៧) ទិន្នន័យតំបន់សំអាតមីនរួច និងតំបន់មានមីនក្នុងខេត្តសៀមរាប និងខេត្តព្រះវិហារដែលទទួលបានពីអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) និងប្តូរ Projection ពីIndian_1960_UTM_Zone_48N ទៅជាWGS_1984_UTM_Zone 48N។

### គ. ការងាររៀបចំផែនទីតាមការស្នើសុំរបស់នាយកដ្ឋានផ្សេងៗ

**១-នាយកដ្ឋានផ្ទាល់ខ្លួន**

- ផែនទីគម្រោងផ្លូវថ្មីជុំវិញអង្គរ
- ផែនទីផ្លូវ និងតំបន់មានមីននៅស្រុកបន្ទាយស្រី និងអង្គរធំ

- ផែនទី ទីតាំងស្ពានតាអោង
- រៀបចំផែនទីរដ្ឋបាលខេត្តសៀមរាប ដោយបញ្ចូលសង្កាត់បីទៀតចូលក្នុងក្រុងសៀមរាប មានសង្កាត់ទឹកវិល សង្កាត់ក្របីរៀល សង្កាត់អំពិល។

**២-នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ**

- ផែនទីតំបន់រដ្ឋបាលថ្មី ត្រង់ចំណុចដីរបស់ក្រុមហ៊ុន J&R
- ផែនទីទីតាំងធ្វើអាជីវកម្មខ្សាច់បក និងធ្វើផ្លូវថ្មីនៅភូមិគោកចក
- ផែនទីទីតាំងភូមិសាស្ត្រ និងការប្រើប្រាស់ដីនៅភ្នំបូក
- ផែនទីស្នើសុំកាយដីរបស់ក្រុមហ៊ុនសាងសង់ ហ្វែនធីមរក នៅភូមិតាប៉ាង និងភូមិត្រាចជ្រុំ ឃុំអំពិល
- ផែនទីទីតាំងសំណង់ខុសច្បាប់ក្នុងតំបន់ការពារទី១ នៅស្រុកប្រាសាទបាគងរបស់អង្គការក្តីសង្ឃឹម
- ផែនទីស្នើសុំធ្វើប្រឡាយទឹកនៅឃុំរុនតាឯក
- ផែនទីសុំជីកស្រះនៅភូមិភ្នំក្រោម សង្កាត់សៀមរាប
- ផែនទីទីតាំងតំបន់ការពាររបស់អាជ្ញាធរអប្សរាទាំងអស់រួមមាន តំបន់ឧទ្យានកណ្តាល រលួស បន្ទាយស្រី វត្តអធ្វា បឹងមាលា ចៅស្រីវិបុល វត្តចេតិយ
- ផែនទីទួលបុរាណ CP467 គោកត្រពាំងចក និងប្រាសាទត្រពាំងល្ពៅ គោកតាគង់ គោកតាវាំង ប្រាសាទតាពន្លឺ ត្រពាំងគ្រួស និងត្រពាំងត្រាវដែលស្ថិតនៅក្នុងឃុំស្វាយដង្គុំ និងសាលាកន្សែង គោកចាន់ឬ គោកដើមចាន់ និងទួលត្រពាំងស្វាយក្នុងភូមិគ្រួស ត្រពាំងតាកួយ និងគោករកានៅភូមិភ្វាជ័យ គោកត្នោត គោកត្រពាំងពោធិ៍ គោកថ្វាន់ គោកឬស្សី គោកអកល្វាយ គោកដូនអន គោកក្តី នៅភូមិកន្ត្រក ទួលប្រាសាទ និងត្រពាំងបុរាណនៅភូមិគោកក្រសាំង ភូមិភ្វាជ័យ និងភូមិទ្រាំង ប្រាសាទត្រពាំងល្ពៅ ប្រឡាយបុរាណ នៅឃុំសាលាកន្សែង គោកគង់ គោកង៉ែត គោកបបាក់ គោកយាយច្រែង នៅភូមិគោកក្រសាំង ប្រាសាទវត្តព្រះឥន្ទ្រកោសីយ ទួលប្រាសាទអម្ពរភ្នំ នៅភូមិមណ្ឌលបី ទួលគោកពុទ្រា ទួលគោកង៉ែតនៅភូមិគោកក្រសាំង។

**៣-នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ**

- រៀបចំផែនទីតាំងកំណាយក្នុងគម្រោងស្រះស្រង់

**៤-នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តការ**

- ផែនទីទីតាំងបង្គោលតំបន់ការពារទី២របស់អាជ្ញាធរអប្សរាទាំងអស់រួមមានតំបន់ឧទ្យានកណ្តាល រលួស បន្ទាយស្រី

**៥-នាយកដ្ឋានរដ្ឋបាលបុគ្គលិក និងសម្ភារៈ**

- ផែនទីទីតាំងបង្គោលតំបន់ឧទ្យានអង្គរ
- ផែនទីតំបន់ការពារទី២របស់អាជ្ញាធរអប្សរាទាំងអស់រួមមាន តំបន់ឧទ្យានកណ្តាល រលួស បន្ទាយស្រី
- ផែនទីតំបន់ប្រាសាទបឹងមាលា

**៦-នាយកដ្ឋានអភិវឌ្ឍន៍វប្បធម៌ សារមន្ទីរ និងបទដ្ឋានបេតិកភណ្ឌ**

- ផែនទីទីតាំងបារាយណ៍ខាងលិច និងបញ្ចូលចំណុចដើម្បីធ្វើការវាស់វែង

**៧-នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន**

- ផែនទីទីតាំងបទល្មើសកាប់ដុត ទន្ទ្រានយកដី និងទីតាំងបូមខ្សាច់ចំនួន៣កន្លែងស្ថិតនៅភូមិរំចេក ឃុំរំចេក ស្រុកអង្គរធំ និងផែនទីទីតាំងបទល្មើសដីព្រៃត្រូវបានឈូសឆាយពីខាងត្បូងភ្នំបូក ក្នុងឃុំរុនតាឯក
- ផែនទីទីតាំងបូមខ្សាច់ស្ថិតនៅភូមិតាកុះ ឃុំរំចេក ស្រុកអង្គរធំ
- ផែនទីតំបន់ការពារទី១ និង២ និងមានចំណុចកូអរដោនេ
- ផែនទីទីតាំងភូមិខ្សាច់នៅបឹងត្រពាំងកកោះ ស្ថិតនៅភូមិរំចេកដើម្បីផ្ទៀងផ្ទាត់ក្នុងតំបន់ការពារ
- ផែនទីត្រពាំងសេះ

**៨-នាយកដ្ឋានអភិវឌ្ឍន៍កសិកម្ម និងសហគមន៍**

- រៀបចំផែនទីកំណត់ទីតាំងផ្ទះប្រជាជនដែលរស់នៅក្នុងតំបន់ការពារទី១ និងទី២ ចំនួន២៤ គ្រួសារដែលស្ថិតក្នុងស្រុកពួក ស្រុកសៀមរាប ស្រុកប្រាសាទបាគង

**៩-ស្ថាប័ននិងក្រុមហ៊ុនផ្សេងៗ**

- ផែនទីតំបន់ព្រំប្រទល់ដីសកលវិទ្យាល័យកម្ពុជា នៅឃុំខ្នារសណ្ដាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប
- រៀបចំផែនទីតំបន់អង្គរ និងក្រុងសៀមរាបតាមការស្នើសុំពីស្ថាប័នខាងក្រៅ
- ផ្ទៀងផ្ទាត់ផែនទីកំណត់តំបន់គម្រោងវិនិយោគ អនុលោមតាមគោលការណ៍សៀវភៅបន្ទុក របស់ក្រុមហ៊ុនវិនិយោគភ្នំគូលែនដើម្បីធ្វើការប្រជុំពិភាក្សាលើការកំណត់ព្រំប្រទល់តំបន់ការពារ។

**ឃ-ការងារជំរុញបរិស្ថានរបស់នាយកដ្ឋាន**

- ចូលរួមក្នុងការធ្វើបទបង្ហាញអំពី "សារសំខាន់ក្នុងការថែរក្សា និងការពារបរិស្ថានអង្គរប្រកបដោយចីរភាព" ដែលរៀបចំឡើងដោយអង្គភាពបរិស្ថានអង្គរ នៅថ្ងៃព្រហស្បតិ៍ ទី៨ ខែមករា ឆ្នាំ២០០៩។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩ ចូលរួមធ្វើសវនកម្មផ្ទៃក្រៅពីស្ថាប័ន JQA ប្រទេសជប៉ុន។
- ចូលរួមប្រជុំក្នុងការងារអ្នកជំរុញបរិស្ថាន និងរៀបចំកម្មវិធីបើកសវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រង បរិស្ថានរបស់អាជ្ញាធរអប្សរា ចាប់ពីថ្ងៃទី១៩ ខែតុលា ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩។
- រៀបចំតារាងតាមដានដំណើរការនៃកម្មវិធីអនុវត្តគោលដៅបរិស្ថានប្រចាំត្រីមាសទី៣ និងទី៤ លើកម្មវិធី៖
    + ជួសជុលនិងថែរក្សាផ្លូវថ្នល់និងស្ពាន
    + សង់ផ្លូវថ្នល់និងស្ពានថ្មី
- រៀបចំតារាងស្រង់ទិដ្ឋភាពបរិស្ថាន និងតារាងគោលបំណងនិងគោលដៅរបស់នាយកដ្ឋានប្រចាំឆ្នាំ២០១០។

**ង-សិក្ខាសាលា និងចូលរួមប្រជុំ**

- ចូលរួមប្រជុំក្នុងគម្រោង "អភិវឌ្ឍសហគមន៍ភូមិរហាល និងស្រះស្រង់ខាងជើង" ជាមួយនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ។

- ចូលរួមប្រជុំជាមួយ Nzaid អំពីរបាយការណ៍បញ្ចប់ជំហានទី១នៃកម្មវិធី "គ្រប់គ្រងធនធានធម្មជាតិក្នុងឧទ្យានដោយមានការចូលរួម និងការចិញ្ចឹមជីវិត"។

## ៥-មណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ៖

### ក-កិច្ចការទូទៅ៖

- ទទួលអ្នកអាន និងអ្នកស្រាវជ្រាវចំនួន៣២២នាក់
- ទទួលសៀវភៅ របាយការណ៍ ទស្សនាវដ្តី ដែលមួយចំនួនបានពីសប្បុរសជន អង្គការនានា ស្ថានទូតឥណ្ឌា និងសៀវភៅមួយចំនួនទៀតទិញដោយអាជ្ញាធរអប្សរា។ សរុបចំនួនឯកសារទាំងអស់មាន១៣៣ចំណងជើង (៣៨២ក្បាល) សូមមើលបញ្ជីខាងក្រោយ។
- ចុះបញ្ជីសៀវភៅ លេខកូដរៀបចំឯកសារ ធ្វើគម្រប និងបិទផ្លាកសៀវភៅ ព្រមទាំងរៀបចំសំណើសុំទិញសៀវភៅ
- រៀបចំសំណើសុំឯកសារពីស្ថានទូតឥណ្ឌា និងវិទ្យាស្ថានបោះពុម្ពផ្សាយនានា។
- ថតចម្លងឯកសារមួយចំនួន និងចងក្រងឯកសារថតចម្លងទាំងអស់នោះជាសៀវភៅ សំរាប់តម្កល់ទុកផ្សព្វផ្សាយក្នុងមណ្ឌលឯកសារ។
- បានទទួលគណៈប្រតិភូមកពីប្រទេសវៀតណាម។
- ចូលរួមប្រជុំក្នុងនាយកដ្ឋានចំនួន២លើក ជាមួយឯកឧត្តមអគ្គនាយករង ទទួលបន្ទុកនាយកដ្ឋានទ្រទ្រង់ បច្ចេកទេស និងគម្រោងអន្តរវិស័យ សមាសភាពចូលរួមមាន អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងបុគ្គលិកសរុបចំនួន១៨រូប។
- លោកស្រីនាយកមណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ បានចុះទៅទំនាក់ទំនងផ្ទាល់តាមបណ្ណាល័យនានានៅភ្នំពេញ និងសៀមរាប ដូចជាវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត វិទ្យាស្ថានវៃយំ បណ្ណាល័យពុទ្ធសាសនបណ្ឌិត បណ្ណាល័យជាតិ បណ្ណាល័យហ៊ុន សែន មហាវិទ្យាល័យបុរាណវិទ្យា EFEO CDRI

### គោលបំណង៖

- បង្កើតការប្រាស្រ័យទាក់ទងជិតស្និទ្ធជាមួយបណ្ណាល័យផ្សេងទៀត ដើម្បីស្វែងរកឯកសារសំខាន់ៗដែលមិនអាចរកបានលើទីផ្សារ
- ហាត់រៀនពីរបៀបរៀបចំបណ្ណាល័យ ដើម្បីជំរុញឲ្យមណ្ឌលអន្តរជាតិតម្កល់ឯកសារអង្គរ មានដំណើរការទៅមុខដោយរលូន។

### លទ្ធផល៖

- បានទទួលជា Soft Copy នូវបញ្ជីឯកសារ (កាតាឡុក) របស់បណ្ណាល័យពុទ្ធសាសនបណ្ឌិត។
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិតបានបង្កើត Website ដែលអាចបង្ហោះឯកសារខ្លះៗជាភាសាខ្មែរសំរាប់អ្នកស្រាវជ្រាវទាំងឡាយតាមរយៈ www.budinst.gov.kh
- បណ្ណាល័យទាំងនោះ (លើកលែងតែ EFEO) សុទ្ធសឹងតែមានកម្មវិធីដែលអាចប្រើភាសាខ្មែរបាន
- ចំពោះឯកសារដែលរកមិនបាននៅទីផ្សារ យើងអាចសុំឲ្យគេចម្លងឲ្យបានដោយផ្ទាល់ជាសាហ៊ុយទៅគេវិញ។
- ផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌ៖ បញ្ជីសៀវភៅចាស់ បញ្ជីថ្មី និងរាប់ចំនួនឯកសារទាំងអស់ដែលមានចុះនៅក្នុងបញ្ជី

សូមមើលបញ្ជីខាងក្រោយ។

**ខ-គម្រោងទៅមុខ៖**

- បន្តការទាក់ទងជាមួយបណ្ណាល័យសំខាន់ផ្សេងៗទៀត។
- រកមធ្យោបាយបង្កើតកម្មវិធី ដែលមានភាសាខ្មែរ សំរាប់មណ្ឌលតម្កល់ឯកសារអង្គរយើង។
- បានជួបពិភាក្សាជាមួយស្ថាប័ន EFEO ពីបច្ចេកទេសថែរក្សាក្រដាសផ្ដាមសិលាចារិក និងថតក្រដាសផ្ដាមទាំងនោះជាឌីជីថល
- បានជួបពិភាក្សាជាមួយក្រុម Nzaid ដើម្បីពិភាក្សាពីការចង់ប្ដូរកម្មវិធីគ្រប់គ្រងឯកសារ
- បានទំនាក់ទំនងជាមួយលោក ហ៊ី ហ៊ីន នៅ CDRI និងទំនាក់ទំនងជាមួយ Khmerdev ដើម្បីស្វែងយល់អំពី កម្មវិធីថ្មីសំរាប់យកមកប្រើប្រាស់នៅក្នុងបណ្ណាល័យ។

## លទ្ធផលនៃឯកសារដែលមាននៅក្នុងបញ្ជីរួចហើយ

| លេខ | ប្រភេទឯកសារ | ចំនួន | ផ្សេងៗ |
|---|---|---|---|
| ១ | សៀវភៅ របាយការណ៍ | ១៣០៣ក្បាល (សៀវភៅខ្លះមានច្រើនក្បាល) | បាត់៧៤ក្បាល |
| ២ | និក្ខេបបទនិស្សិត | ១៤៧ក្បាល (សៀវភៅខ្លះមានច្រើនក្បាល) | បាត់៤ក្បាល |
| ៣ | របាយការណ៍ស្រាវជ្រាវរបស់ក្រុមសិក្សាសង្គម | ៣២ក្បាល | |
| ៤ | ទស្សនាវដ្ដីជាតិនិងអន្តរជាតិ | ៣៤ចំណងជើង (សៀវភៅខ្លះមានច្រើនក្បាល) | |
| ៥ | កាសែតវីដេអូ | ១០កសែត | ខ្លះខូច |
| ៦ | CD | ៣០ | ខ្លះខូច |
| ៧ | DVD | ៥ | ខ្លះខូច |
| ៨ | Floppy Disks | ២៣ | ខ្លះខូច |
| ៩ | រូបថតរូបចម្លាក់នៅអភិរក្សដ្ឋានអង្គរ | ២៥០រូប | |
| ១០ | រូបតូចៗនៃប្លង់ប្រាសាទក្នុងឧទ្យានអង្គរ | ៣៧៨៤ សន្លឹក | |
| ១១ | របាយការណ៍កំណាយពីសម័យបារាំងដល់ឆ្នាំ ១៩៥៥ | ២៨ ដុំ | |

# XIII. នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ

អគ្គនាយករង=១នាក់ ប្រធាននាយកដ្ឋាន=១នាក់ អនុប្រធាននាយកដ្ឋាន=១នាក់ បុគ្គលិក=១៨នាក់ អ្នកបើកបរ=៧នាក់ កម្មករជំនាញ=១៥៣នាក់ កម្មករបោសសំអាតឧទ្យានអង្គរ=២៦៧នាក់ ឆ្មាំប្រាសាទ=២៨៧នាក់។

## XIII.1- **ការិយាល័យថែទាំប្រាសាទ ៖**

១- ការងារអភិរក្ស៖

**- ការងារប្រចាំ៖** បោសសំអាតអនាម័យ កាត់សំអាតកូនរុក្ខជាតិតូចៗដែលដុះលើប្រាសាទ រៀបចំសណ្តាប់ធ្នាប់ ការពារថែរក្សា ជួសជុលហេដ្ឋារចនាសម្ព័ន្ធប្រាសាទ នៅក្នុងតំបន់អង្គរ តំបន់រលួស តំបន់ប្រាសាទបន្ទាយស្រី និងស្ពានបុរាណផ្លូវជាតិលេខ៦ និងប្រាសាទនៅលើភ្នំគូលែន និងចូលរួមជំរុញការងារបរិស្ថានជុំវិញឲ្យសមស្របនិងរមណីយដ្ឋានវប្បធម៌-ប្រវត្តិសាស្ត្រ។

**- ការងារបានបញ្ចប់៖**

**- ការងារទល់ទ្រ៖** ហោជាងនិងផ្តែរជ្រុងខាងកើតនៃប្រាសាទបាលីល័យ។ ផ្តែរជ្រុងខាងត្បូងនៃប្រាសាទឃ្លាំងខាងត្បូង។ ផ្តែរក្លោងទ្វារ ផ្នែកខាងជើងនៃប្រាសាទឃ្លាំងខាងជើង។ តួទាំងបីនៃប្រាសាទភ្នំក្រោម។ ធ្នឹមបណ្ណាល័យខាងត្បូងនៃប្រាសាទភ្នំបាខែង។

**- ការជួសជុល៖** សសរផ្តោបប៉មជ្រុងអាគ្នេយ៍ ជ្រុងកែងនិរតី សសរពេជ្រនៅប្រាសាទព្រះគោ។ តួប្រាសាទទិសអាគ្នេយ៍នៃខឿនទី៣ និងទិសពាយ័ព្យនៃប្រាសាទភិមានអាកាស។ បណ្ណាល័យខាងជើង ខាងត្បូង គោបុរៈខាងលិច និងតួប្រាសាទខាងលិចនៃប្រាសាទវត្តអធ្វារ និងដាក់បង្គោលរបាការពារនៅចំណុចគ្រោះថ្នាក់៣ទីតាំង។ ដាក់បង្គោលរបា និងស្លាកសញ្ញា គ្រោះថ្នាក់នៅប្រាសាទភ្នំក្រោម។

**- ការងារផ្សេងៗ៖** គម្រោងធ្វើស្ពាននៅប្រាសាទតាព្រហ្ម។ សហការជាមួយនាយកដ្ឋានព្រៃឈើ កាប់លះមែកឈើនៅប្រាសាទព្រះខ័ន។

**- ការងារបន្ត៖** សិក្សាដើម្បីទល់ទ្រក្លោងទ្វារខាងលិចស្លាប ខាងត្បូងប្រាសាទវត្តអធ្វារ និងបណ្ណាល័យផ្នែកខាងជើងនៃវត្តអធ្វារ។ សិក្សាប្លង់ជណ្តើរប្រាសាទបន្ទាយសំរែ ដើម្បីបញ្ចៀសភាពគ្រោះថ្នាក់ដល់ភ្ញៀវ។

**- ស្ថានភាពប្រុងប្រយ័ត្ន៖** សត្វប្រចៀវចាប់ផ្តើមចូលមករស់នៅក្នុងតួកណ្តាលទាំងបីនៃប្រាសាទភ្នំក្រោម។ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៩ ថ្មដំបូលបណ្ណាល័យខាងត្បូងវត្តអធ្វារបានធ្លាក់ចំនួន៥ដុំ។ ប្រាសាទបាយ័នមានគ្រឿងដង្កំទល់ទ្រ៣កន្លែង ជញ្ជាំងខាងត្បូង១កន្លែង និងខាងកើត២កន្លែងត្រូវពុកផុយ អាចនឹងដួលនៅពេលខាងមុខ។ នៅបណ្ណាល័យខាងកើតតួខាងជើងនិងតួខាងត្បូង ថ្មបាយក្រៀមខាងលើញែកធ្លាក់ធ្វើឲ្យហោជាងថ្មភក់ខាងលើដែលសង្កត់លើជញ្ជាំងថ្មបាយក្រៀមនោះ ប្រេះបែកពាក់កណ្តាលធ្វើឲ្យបាត់លំនឹងទ្រហោជាង បណ្តាលឲ្យទ្រេតហោជាងផ្នែកខាងត្បូងមកលិច ស្ទើរតែធ្លាក់មកក្រោម និងគោបុរៈខាងលិចរលុះជញ្ជាំងរំកិលថ្មដំបូលបំរុងធ្លាក់ នៅប្រាសាទវត្តអធ្វារ។ សំណើអន្តរាគមន៍បញ្ឈប់ជាបន្ទាន់រាល់ការស្នើសុំ ឬជួសជុលសំណង់គ្រប់ប្រភេទនៅវត្តបន្ទាយក្តី។ ការកាប់ឈើនិងគាស់យកឥដ្ឋនៅប្រាសាទអ្នកតាភ្នំគូលែន។ ការរលំបាក់ផ្តែរនិងសសរផ្តោបនៅប្រាសាទបាគង។ ការរលុះថ្មតួប៉មប្រាសាទឥដ្ឋនៅលើភ្នំបាខែង។

## XIII.2- ការិយាល័យកិច្ចការវិស្វកម្មបេតិកភណ្ឌ

- ការងារបានបញ្ចប់៖

*ការងារទល់ទ្រ ៖* ចំនុចគ្រោះថ្នាក់២កន្លែងនៅស្រះស្រង់ និងធ្វើរបាំងទប់ទឹក។ ទីតាំងT ១៥ នៃប្រាសាទបាយ័ន១ចំនុច។ ក្លោងទ្វារតាការ មាន ៤ចំនុច។ ទីតាំងគ្រោះថ្នាក់មាន៥ចំនុចនៅប្រាសាទបន្ទាយក្តី។ ស្ថានភាពគ្រោះថ្នាក់ផ្នែកខាងក្នុងនៃប្រាសាទថ្មដាប់ភ្នំគូលែន។ ដោះដូរទ្រនល់ជញ្ជាំងនៅប្រាសាទបាទជុំ។ ទល់ទ្រសេះទ្រេតក្នុងកសិណា និងដាក់ខ្សែររបាំងការពារកន្លែងគ្រោះថ្នាក់នៅប្រាសាទនាគព័ន្ធ។ ទល់ទ្រជញ្ជាំងថ្មបាយក្រៀមនៅប្រាសាទនាគព័ន្ធ។

- **ការងារបន្ត៖** សិក្សាគម្រោងប្តូរទល់ទ្រនៅដំណាក់កាលទី២នៅប្រាសាទបន្ទាយក្តី។ ចុះពិនិត្យចំនុចគ្រោះថ្នាក់នៅប្រាសាទព្រះខ័ន្ធ។ ទល់ទ្រចំនុចT14 ដើម្បីធ្វើការសង្គ្រោះបន្ទាន់នៅប្រាសាទបាយ័ន។ ជួសជុលជ្រុងខាងជើងឈៀងខាងកើតនៃតួប្រាសាទបាតជុំ។ សិក្សាគម្រោងថៃវស្លាបច្រកចូលខាងលិចនៃប្រាសាទអង្គរវត្តមាន២ចំនុច។ ចុះពិនិត្យកន្លែងគ្រោះថ្នាក់នៅប្រាសាទបន្ទាយក្តីមាន១៧ចំនុច ដែលទល់ទ្រដោយអង្គការសូហ្វីយ៉ា និងមានកន្លែងថ្មី៥ចំនុចទៀតដែលគ្រោះថ្នាក់ធ្ងន់ធ្ងរ។ ចុះពិនិត្យតាមដានការបាក់ស្រុតថ្មបាយក្រៀមបណ្តាលមកពីទឹកបុករលុះដីនៅក្រោមថ្មនៅស្រះស្រង់។

## XIII.3- ការិយាល័យកិច្ចការបុរាណវិទ្យាក្នុងឧទ្យានអង្គរ

ក-ក្រុមកំណាយ៖

- **ការងារបានបញ្ចប់៖** កំណាយស្រាវជ្រាវនៅលើភ្នំគូលែន ជាមួយមូលនិធិបុរាណវិទ្យាដើម្បីអភិវឌ្ឍន៍ និងបញ្ចប់ផ្នែកស្រាវជ្រាវ ទល់ទ្រសេះប្រាសាទនាគព័ន្ធ និងដាក់ខ្សែរបាំងការពារកន្លែងគ្រោះថ្នាក់។ បញ្ចប់កំណាយលើកតោនៅប្រាសាទមេបុណ្យ។ ធ្វើការអង្កេតផ្នែកបុរាណវិទ្យា និងគូសផែនទីឋានលេខា និងសិក្សាវត្ថុសិល្បៈដែលមាននៅលើផ្ទៃខាងលើនៃទួល ចុះបញ្ជីរាល់វត្ថុបុរាណ និងវិភាគទិន្នន័យ នៅលើទួលខាងកើតក្លោងទ្វារខ្មោច។

- **ការងារបន្ត៖** ធ្វើកំណាយស្រាវជ្រាវនៅការដ្ឋានស្រះស្រង់។ ធ្វើការវិភាគលទ្ធផលដែលប្រមូលបានពីការធ្វើកំណាយនៅលើភ្នំគូលែន ស្ថានីយឡបាកោង និងកំពុងធ្វើការសិក្សាកុលាលភាជន៍ដែលបានមកពីក្លោងទ្វារទន្លេអុំ។ បន្តកំណាយសង្គ្រោះជាមួយ WMF នៅប្រាសាទភ្នំបាខែង ដើម្បីស្វែងរកថ្មនិងមើលគ្រឹះ ក្នុងគោលបំណងជួសជុល។

ខ-ក្រុមការងារចុះពិនិត្យពីផលប៉ះពាល់ផ្នែកបុរាណវិទ្យា៖

- ចុះពិនិត្យមើលផលប៉ះពាល់ផ្នែកបុរាណវិទ្យាមាន៥ករណី

- ធ្វើរបាយការណ៍ស្តីពីការកំណត់កូអរដោនេ ទួលប្រាសាទបុរាណ នៅសង្កាត់ស្វាយដង្គំ ក្រុងសៀមរាប

- ចុះពិនិត្យទីតាំង ស្នើសុំសាងសង់អគារ ផ្ទះ អគារសិក្សា បណ្ណាល័យ កុដិ សាលាឆ័ន ចំនួន៧៤ករណី ការស្តារស្រះលុបត្រពាំង ស្តារប្រឡាយ ជីកកាយ បកស្រទាប់ដី ចាក់ដី លូរកាត់ផ្លូវចំនួន២០ករណី និងជួសជុលផ្លូវមាន ចំនួន២៤ករណី។

គ-ក្រុមចុះបញ្ជីសារពើភណ្ឌ៖

-ការងារបានបញ្ចប់៖

- បានប្រគល់រូបបដិមា ចុះបញ្ជីរួច ចំនួន៧៧ដុំ ទៅសារមន្ទីរព្រះនរោត្តមសីហនុអង្គរ។

**-ការងារបន្ត៖** ចុះបញ្ជីនិងបញ្ចូលទិន្នន័យរូបនៅប្រាសាទបន្ទាយក្តីទៅក្នុង Data Base បានចំនួន២៦២រូប។ ឆ្លាក់និងជាប់ថ្មភក់ ដាក់ជើងទម្រ បង្កាន់ដៃនាគ ដើម្បីដូរស៊ីម៉ងត៍ចេញនៅប្រាសាទអង្គរវត្ត។

**-ការងារទូទៅ៖**

- ចុះបញ្ជីបេតិកភ័ណ្ឌ ដែលមាននៅលើខឿនព្រះវិហារព្រះពុទ្ធសាសនា នៅអង្គរធំ នៅទីតាំងក្លោងទ្វារខ្មោច។
- ចុះពិនិត្យសិលាចារឹកបុរាណមួយផ្ទាំង ដែលបានរលំកប់ដីនៅប្រាសាទត្រពាំងល្ពៅ។
- ចុះទៅយករូបគោលសីមា ចំនួន១ដុំនៅទួលគោកភ្នៅ ភូមិស្រះស្រង់ សង្កាត់នគរធំ ក្រុងសៀមរាប។
- ចុះយកបំណែកសិលាចារឹក១ផ្ទាំង នៅប្រាសាទបាគង នឹងបានប្រគល់ជូនសារមន្ទីរ ព្រះនរោត្តម សីហនុ អង្គរ។

**ឃ-ក្រុមកុលាលភាជន៍៖**

**-ការងារបានបញ្ចប់៖** ចុះបញ្ជីភាជន៍ដែលបានពីស្ថានីយឡថ្មល់ម្រេចភ្នំគូលែន។ បានប្រគល់ភាជន៍ចំនួន៨៧ប្រភេទឲ្យទៅសារមន្ទីរឡូតានី។

**-ការងារបន្ត៖** ចុះបញ្ជីភាជន៍បានពីស្ថានីយឡបង្កោង និងរៀបចំរបាយការណ៍។

## XIII.4- **ការិយាល័យកិច្ចការស្ថាបត្យកម្ម បេតិកភណ្ឌ**

**-ការងារបានបញ្ចប់៖** សិក្សាគម្រោងប្លង់ខ្ទះដាក់តាមភ្នំបាខែង។ រៀបចំគម្រោងប្លង់កូអ៊ិចនៃការិយាល័យអប្សរា។ ចូលរួមធ្វើប្លង់អំពីសួនច្បារអាជ្ញាធរអប្សរាជាមួយនាយកដ្ឋានព្រៃឈើ។ កែសំរួលប្លង់បង្គោលបេតិកភណ្ឌ។ គូសផ្លាកសញ្ញាអប្សរា (Logo) និងទង់អប្សរា។ សិក្សានិងគូសដងទង់ជាតិដាក់នៅទីធ្លាប្រាសាទបន្ទាយស្រី។ បង្គន់សាធារណៈនៅប្រាសាទបន្ទាយស្រី និងតាព្រហ្ម។

**-ការងារបន្ត៖** សិក្សាប្លង់សួនច្បារគ្រឿងទេស។ សិក្សាប្លង់បាញ់ទឹកលំអរសួនគ្រឿងទេស។ សិក្សាលំអិតប្លង់ទ្រើងសួនច្បារគ្រឿងទេស។ ត្រួតពិនិត្យការដ្ឋានសួនគ្រឿងទេស។ កែសំរួលបញ្ចូលប្លង់តូបលក់ដូរនៅទីលានប្រាសាទតាព្រហ្មខាងកើត។ កែសំរួលប្លង់ប្រឡាយទឹកតាមស្ថានភាពជាក់ស្តែងនៅក្នុងសួនគ្រឿងទេស។ ត្រួតពិនិត្យការដ្ឋានសាងសង់បង្គន់សាធារណៈនៅប្រាសាទបាគង។ ត្រួតពិនិត្យការដ្ឋានសាងសង់ក្តារក្រាល សំរាប់ភ្ញៀវទស្សនាទេសភាពនៅតាមផ្លូវឡើងភ្នំបាខែង។

## XIII.5- **ការិយាល័យ សម្របសម្រួល និងគាំទ្រសកម្មភាព៖**

**ក.ការងាររដ្ឋបាល៖** រៀបចំលិខិត

-ទទួលលិខិតចូលចំនួន ២២០១ ច្បាប់

-បញ្ជូនលិខិតចេញចំនួន ១០៣៤ ច្បាប់ ក្នុងនោះឆ្លើយតបការសុំយោបល់មានចំនួន ៧០ ករណី។

**ខ.ការងារសហការជាមួយស្ថាប័នអន្តរជាតិ៖** ការងារស្រាវជ្រាវនិងជួសជុលប្រាសាទ មានចំនួន៩ប្រទេសចែកចេញជា១៦ ស្ថាប័ន ២៤ការដ្ឋាន។

១-APSARA-GACP៖ ជួសជុលហោងជាង និងរូបទេពអប្សរានៅប្រាសាទអង្គរវត្ត លាងសំអាតរូបគោនិងជណ្តើរ

នៅប្រាសាទកោះកេរ្តិ៍ ធ្វើការអភិរក្សរូបចម្លាក់អប្សរានៅកំពូលកណ្តាលនៃប្រាសាទភ្នំបាខែង។

២-APSARA-CSA៖ បន្តសិក្សាលើក្បាច់ចំលាក់របស់ប្រាសាទ និងប្លង់ស្ថាបត្យកម្មថែវពេងទងទី១ ប្រាសាទតាកែវ។

៣-APSARA-WMF៖ **ប្រាសាទភ្នំបាខែង** ធ្វើកំណាយខាងកើតឈៀងខាងត្បូងនៃជាន់ផ្ទាល់ដីនៅភ្នំបាខែង គូសប្លង់នៅប្រាសាទតដ្ឋG5 ដើម្បីធ្វើការជួសជុល។ **ប្រាសាទព្រះខ័ន៖** តម្លើងរន្ទារដើម្បីជួសជុលរូបគ្រុឌលេខ៥៥ ទល់ទ្រសង្គ្រោះបន្ទាន់ដំបូលនៅពេងទងទី២។ **ប្រាសាទអង្គរវត្ត៖** ធ្វើការចល័តថ្ម ដើម្បីតម្លើងតំបូលពេងទងកូសមុទ្រទឹកដោះ។

៤-APSARA-ASI៖ បន្តជួសជុលស្ពានហាលខាងលិចនិងពេងទងខាងកើតនៅប្រាសាទតាព្រហ្ម។

៥-APSARA-JASA៖ ការជួសជុលនៅបណ្ណាល័យខាងត្បូងបានបញ្ចប់នៅត្រឹមឃឿនទី២ ហើយការងារនេះត្រូវផ្អាកមួយរយៈសិន ព្រោះថ្មនៅឃឿនទី៣កំពុងធ្វើការសាកល្បងនៅឡើយ។ បន្តការតាមដានពីផលប៉ះពាល់នៃបរិយាកាសរូបចម្លាក់នៃពេងទងខាងក្នុង នៃជញ្ជាំងខាងជើងស្លាបខាងកើត និងសិក្សាលំអិតស្តីពីវិធីសាស្ត្រព្យាបាល និងថៃរក្សាថ្ម។

៦-APSARA-NARA៖ ជួសជុលប្រាសាទតុប និងស្រាវជ្រាវឡបង្គោង។

៧-APSARA-DED៖ គម្រោងអភិរក្សថ្ម និងជួសជុលរូបចំលាក់ និងលិង្គនៅសារមន្ទីរព្រះនរោត្តមសីហានុអង្គរ។ នៅប្រាសាទភ្នំបាខែង ជួសជុលចំលាក់រូបអក្សរនិងចំលាក់លើហោជាងនៅប្រាសាទកណ្តាល។

៨-APSARA-FSP៖ បញ្ចប់កំណាយនៅអង្គរធំ។

៩-Fondation Archaeology & Development-Phnom Kulen៖ បញ្ចប់ការងារកំណាយនៅភ្នំគូលែន និងធ្វើរបាយការណ៍។

១០-APSARA-BSCP៖ គម្រោងរៀបចំ Parvis នៅបន្ទាយស្រី។

១១-APSARA-SOPHIA៖ គម្រោងស្រាវជ្រាវនៅប្រាសាទបន្ទាយក្តី។

### XIII.6-ការងារផ្សេងៗ

**ការអប់រំ៖**

-វគ្គបណ្តុះបណ្តាលជំនាញ 3D Scanning ពីអង្គការ JASA ដែលអនុវត្តន៍ ការងារនៅប្រាសាទអង្គរវត្ត។

-ចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាលជំនាញ ២ឆ្នាំ នៅប្រទេសជប៉ុន ១នាក់។

-ចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាលជំនាញ ៣ឆ្នាំ នៅប្រទេសឆែក ១នាក់។

-ចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាលជំនាញ ៣ឆ្នាំ នៅប្រទេសឥណ្ឌា ១នាក់។

-គ្រូពេទ្យអង្គការរ៉ាក់បានចុះពិនិត្យសុខភាពឆ្នាំកម្មករនៅតាមប្រាសាទ។

-ពន្យល់ណែនាំដល់ក្រុមក្មេង អំពីបរិស្ថានអនាម័យនៅជុំវិញកន្លែងពួកគាត់ប្រគុំ។

**សណ្តាប់ធ្នាប់ និងអនាម័យ៖**

-ភ្នាក់ងារបានសហការរាល់ការសំដែងនានា នៅតាមប្រាសាទ។

-ធ្វើការប្រជុំរួមរវាងឆ្មាំ ប្រធានក្រុមឆ្មាំ និងភ្នាក់ងារគ្រប់គ្រងប្រាសាទ ដើម្បីធ្វើការណែនាំនិងអប់រំ អំពីវិធានការផ្សេងៗ និងវិន័យឆ្មាំក្នុងពេលបំពេញការងារ។

-កំលាំងឆ្មាំបានធ្វើការណែនាំអប់រំអ្នកលក់ ឲ្យចូលរួមរក្សាអនាម័យ និងសណ្តាប់ធ្នាប់ក្នុងតំបន់ប្រាសាទ។

-សហការជាមួយក្រុមហ៊ុន HCC លើការងារប្រមូលកាកសំណល់កខ្វក់ចេញពីរមណីយដ្ឋានអង្គរ។

**សំណូមពរ៖**

-ត្រូវការធនធានមនុស្សជួយដោះស្រាយសម្ភារៈឲ្យទាន់ពេលវេលា អទិភាពសំរាប់ការងារជួសជុលប្រាសាទដែលមានសភាពទ្រុឌទ្រោម។

# XIV. នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ

របាយការណ៍សកម្មភាពរបស់នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរប្រចាំឆ្នាំ២០០៩ មានការងារសំខាន់ៗដូចជាការការពារបរិស្ថាន ការសាងសង់រចនាសម្ព័ន្ធតូចៗដែលជាតម្រូវការនៃការគ្រប់គ្រង ការថែទាំរមណីយដ្ឋានដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់នាយកដ្ឋាន។

ការងារប្រចាំថ្ងៃផ្តោតទៅលើការងារបច្ចេកទេសសំដៅទៅអភិរក្សនិងថែទាំប្រាង្គប្រាសាទ។

## ១-សកម្មភាពការងារសំខាន់ៗ៖

-ដាំកូនឈើនៅតាមរមណីយដ្ឋាននានាដែលស្ថិតនៅក្រៅឧទ្យានអង្គរបានចំនួន **៥ ៥៧០ដើម**។

-ប្រជុំនៅសាលាស្រុកស្វាយលើអំពីករណីប្រជាជនរុករានព្រៃយកដីធ្វើកម្មសិទ្ធ នៅក្នុងតំបន់រណ្តៅយក ថ្មភក់អូរថ្មដាប់ ។

-ចុះកំណត់ទំហំផ្ទៃដី និងរៀបចំបោះបង្គោលបរិវេណបុរាណដ្ឋានដែលត្រូវការពារ និងអភិរក្សនៅក្នុងបរិវេណ **ចំការកៅស៊ូក្រែក ស្រុកស្វាយលើ** ។

-ត្រួតពិនិត្យការជីកយកថ្មភក់របស់ក្រុមហ៊ុន **ជា រ៉ាវី** សំរាប់ផ្គត់ផ្គង់ការដ្ឋានប្រាសាទតាព្រហ្ម និងរោងជាងរបស់នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ។

-ចុះរុះរើរបងដីប្រជាជនចំនួន៥គ្រួសារ ដែលសង់ខុសច្បាប់នៅលើខ្នងបារាយណ៍ខាងកើត**ប្រាសាទបេងមាលា។**

-សាងសង់រោងឆ្មាំមួយខ្នងទំហំ ៥,០០ម X ៧,៥០ម នៅប្រាសាទគងភ្លុក។

-សាងសង់បង្គន់អនាម័យខ្នាតតូចសំរាប់បុរស-ស្ត្រី ទំហំ ៣ម X ៣ម ចំនួនពីរខ្នងនៅប្រាសាទបេងមាលា។

-ធ្វើរបងការពារកូនឈើបានប្រវែង ៣៥០ម នៅក្បែរកសិណាខាងលិចនៃប្រាសាទបេងមាលា។

-ជួសជុល និងថែទាំជណ្តើរ និងស្ពានជាប្រចាំ ដើម្បីសុវត្ថិភាពភ្ញៀវទេសចរ។

-បានទទួលរូបចម្លាក់ចំនួន២៧ដុំ ពីអធិការដ្ឋាននគរបាលស្រុកស្វាយលើ។

## ២-សកម្មភាពបច្ចេកទេសគ្រប់គ្រង និងអភិរក្សប្រាសាទ៖

-លាងសំអាត និងស្រង់ចំនួនឧបករណ៍ ដែលបានពីកំណាយនៅស្ថានីយ ឡស្លដែក ខ្វាវ។

-ស្រង់ទិន្នន័យចំនួនស្ថានីយបុរាណដែលស្ថិតនៅក្រៅឧទ្យានអង្គរតាមរយៈឯកសារផ្សេងៗ។

-សហការជាមួយអាជ្ញាធរភូមិ ដឹកនាំកម្មករចុះដាំកូនឈើតាមស្ពានបុរាណពី **បាគងដល់កំពង់ក្តី** បានចំនួន ៣១៣ដើម។

-សិក្សាស្រាវជ្រាវរកប្រព័ន្ធបង្ហូរទឹកបុរាណ ដើម្បីដំណើរការបង្ហូរទឹកដែលដក់ចេញពី **ប្រាសាទបេងមាលា** ដោយក្រុមបុរាណវិទ្យា។

-យកដីក្នុងបរិវេណ**ប្រាសាទស្រុត** (កោះកែរ)ចេញ ដើម្បីបង្ហាញអោយឃើញគ្រឹះ និងរៀបចំអោយមានសណ្តាប់ធ្នាប់នូវថ្មដែលដួលធ្លាក់។

-ចុះល្បាតព្រៃឈើនៅក្នុងឧទ្យានកោះកែរ និងប្រមូលដឹកឈើដែលជនល្មើសលួចអារបាន ១,៥មគូប។

-សង្គ្រោះបន្ទាន់នូវចំណុចដែលមានគ្រោះថ្នាក់ដោយធ្វើការទល់ទ្រនៅ ប្រាសាទធំ (កោះកែរ) បានចំនួន ៣កន្លែង និង ប្រាសាទស្រុត (កោះកែរ)ចំនួន១កន្លែង។

-ទល់ទ្រកន្លែងគ្រោះថ្នាក់បានចំនួន១៨ចំនុច នៅក្នុងប្រាសាទបេងមាលា។

-ធ្វើជណ្តើរឈើបាន២កន្លែង ដើម្បីសំរួលអោយភ្ញៀវទេសចរងាយស្រួលទស្សនានៅប្រាសាទធំ (កោះកែរ)។

-បន្តសិក្សា និងត្រួតពិនិត្យមើលចំណុចដែលត្រូវទល់ទ្រនៅក្នុងរមណីយដ្ឋានកោះកែរ។

-ចុះពិនិត្យស្ពានបុរាណតាមផ្លូវជាតិ ៦ពីបាគង ទៅស្ពានកំពង់ក្តី (ស្ពានព្រះទិស) ដើម្បីរកទីតាំងដាំដើមឈើសងខាងផ្លូវ និងធ្វើប៉ាណូពីប្រវត្តិស្ពានព្រះទិសដើម្បីបង្ហាញដល់ភ្ញៀវទេសចរ និងសាធារណៈជនបានយល់ដឹង។

-ជីកចង្អូរបង្ហូរទឹកភ្លៀងបានប្រវែង៧៥០ម ដែលមានទទឹងប្រវែង០,៥ម ក្នុងបរិវេណប្រាសាទបេងមាលា ដើម្បីដោះទឹកយកចេញអោយឆាប់ សំរួលដល់ការទស្សនារបស់ភ្ញៀវ និងសុវត្ថិភាពប្រាសាទ។

-ធ្វើរបងការពារកូនឈើបានប្រវែង៣៥០ម នៅក្បែរកសិណាខាងលិចនៃ ប្រាសាទបេងមាលា។

-ទប់ស្កាត់ការកាប់រំលំព្រៃឈើនៅផ្នែកខាងកើតឈាងខាងជើង និងនៅក្បែរការដ្ឋានជីកយកថ្មភក់ ត្រពាំងចារ។

-ធ្វើកំណាយស្រាវជ្រាវនៅស្ថានីយ ឡស្លដែក ក្នុងភូមិខ្វាវ ឃុំខ្វាវ ស្រុកជីក្រែង ខេត្តសៀមរាប ។

-លើកថ្មសំរួលផ្លូវទស្សនាដល់ភ្ញៀវទេសចរនៅ ប្រាសាទបេងមាលា ជាលទ្ធផលបានចំនួន៦០៩ដុំ។

-រៀបចំយកដីក្នុងបរិវេណ ប្រាសាទស្រុត ចេញ ដើម្បីបង្ហាញឲ្យឃើញគ្រឹះ និងរៀបចំឲ្យមានសណ្តាប់ធ្នាប់នូវថ្មដែលដួលធ្លាក់។

-ប្រមូលដឹកឈើដែលជនល្មើសបានអារ និងច្រៀកចេញពីក្នុងព្រៃយកមករក្សាទុកក្នុងឃ្លាំងអាជ្ញាធរអប្សរាបានចំនួន០,៥មគូប។

-កាប់ដើមឈើដែលមានគ្រោះថ្នាក់ដល់សុវត្ថិភាពប្រាសាទបានចំនួន២ដើម ដើមឈើដែលដួលរលំបានចំនួន ១ដើមនៅ ប្រាសាទធំ (កោះកែរ) និង២ដើមទៀតនៅប្រាសាទបេងមាលា។

-លះមែកឈើ និងកាប់យកចេញនូវដើមស្រឡៅ១ដើម ដែលដួលរលំដោយរន្ទះបាញ់មកលើច្រកចូលខាងត្បូងប្រាសាទបេងមាលា។

-ចុះចាប់ និងដកហូតរណាយន្តបាន៦គ្រឿង ដោយសហការជាមួយនគរបាលការពារបេតិកភណ្ឌដែលប្រចាំការនៅទីនោះ។

## ៣-ការងារសហការជាមួយស្ថាប័នអន្តរជាតិ៖

-សហការជាមួយស្ថាប័ន EFEO វិភាគទិន្នន័យបុរាណវិទ្យា ព្រមទាំងគូរបំណែក និងក្បាច់លើវត្ថុសិល្បៈដែលបានមកពីកំណាយ នៅឧទ្យានជាតិភ្នំគូលែន។

-សហការជាមួយស្ថាប័ន EFEO ធ្វើកំណាយស្រាវជ្រាវនៅការដ្ឋានផ្នូរដំរីស។

-សហការជាមួយក្រុមស្រាវជ្រាវជួសជុល និងអភិរក្សថ្ម (GACP) ជួសជុលជណ្តើរថ្ម រូបបដិមាតោ និងបដិមាដំរី នៅ **ប្រាសាទធំ កោះកែរ** ។

-សហការជាមួយក្រុមស្រាវជ្រាវ ហុងគ្រី (Royal Angkor Foundation) ស្រាវជ្រាវនៅ រមណីយដ្ឋានកោះកែរ ។

# របាយការណ៍ ចំណូល និង ថវិកា អាជ្ញាធរអប្សរា ឆ្នាំ ២០០៩

ឯកតា: ដុល្លារអាមេរិក

| ល.រ | អត្ថន័យចំណូល | ឆ្នាំ ២០០៩ | | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | ផែនការឆ្នាំ | សមតុល្យ ដើមឆ្នាំ | ចលនាក្នុងខែមករាដល់ខែធ្នូ | | | សមតុល្យ ចុងខែធ្នូ | |
| | | | | អនុវត្តបាន | ធៀបនឹងផែនការឆ្នាំ | បានបង់ | | |
| | | (A) | (B) | (C) | (D = C/A) % | (E) | (F = B + C - E) | |
| **សរុបចំណូលរួម ( I + II )** | | | | **$ 29,374,539.33** | | **$ 16,126,319.44** | **$ 1,951,646.21** | |
| I. **សរុបចំណូលមិនមែនសារពើពន្ធ (១+២+៣+៤)** | | **$ 36,590,000.00** | **$ 1,647,495.31** | **$ 16,430,470.34** | **44.90%** | **$ 16,126,319.44** | **$ 1,951,646.21** | |
| **1** | **តំបន់ប្រាសាទអង្គរ** | | ***$ 1,636,083.72*** | ***$ 15,985,702.71*** | | ***$ 15,683,610.44*** | ***$ 1,938,175.99*** | |
| | .ការលក់ប័ណ្ណចូលទស្សនា | | $ 1,633,535.90 | $ 15,753,155.77 | | $ 15,451,577.21 | $ 1,935,114.46 | |
| | .អាជីវកម្ម"ការកំសាន្តអង្គរ-បាល់ឡុង" | | $ 2,547.82 | $ 19,063.42 | | $ 18,549.71 | $ 3,061.53 | |
| | .ការលក់ប័ណ្ណចូលទស្សនាសារមន្ទីរព្រះនរោត្តមសីហនុ | | $ - | $ 8,608.02 | | $ 8,608.02 | $ - | |
| | .ការដាក់ជួលរថយន្តអគ្គិសនី៧មករា | | $ - | $ 29,992.50 | | $ 29,992.50 | $ - | |
| | .ការដាក់ជួលកង់អាគុយ | | $ - | $ 131.00 | | $ 131.00 | $ - | |
| | .អាជីវកម្មដាក់ជួលឯកសណ្ឋានខ្មែរយុគសម័យបុរាណ ជូនភ្ញៀវថតរូប | | $ - | | | | $ - | មានការឃើតយ៉ាវបង់ |
| | .ពីកិច្ចសន្យាអាជីវកម្មលើខ្នងដំរី | | $ - | $ 4,500.00 | | $ 4,500.00 | $ - | |
| | .ពីកិច្ចសន្យាអាជីវកម្មរទេះសេះ | | $ - | $ 25,245.00 | | $ 25,245.00 | $ - | |
| | .ចំណូលផ្សេងៗ | | $ - | $ 145,007.00 | | $ 145,007.00 | $ - | |
| **2** | **តំបន់ប្រាសាទបេងមាលា** | | ***$ 9,410.23*** | ***$ 102,298.64*** | | ***$ 100,526.00*** | ***$ 11,182.87*** | |
| | .ការលក់ប័ណ្ណចូលទស្សនា | | $ 9,410.23 | $ 102,298.64 | | $ 100,526.00 | $ 11,182.87 | |
| **3** | **តំបន់ប្រាសាទកោះកែរ** | | ***$ 2,001.36*** | ***$ 13,579.99*** | | ***$ 13,294.00*** | ***$ 2,287.35*** | |
| | .ការលក់ប័ណ្ណចូលទស្សនា | | $ 2,001.36 | $ 13,579.99 | | $ 13,294.00 | $ 2,287.35 | |
| **4** | **ការជួលទ្រព្យសម្បត្តិ** | | ***$ -*** | ***$ 328,889.00*** | | ***$ 328,889.00*** | ***$ -*** | |
| | .ពីកិច្ចសន្យាជួលដី ២៣ហិកតា | | $ - | | | | $ - | ដោះស្រាយដីពុំទាន់គ្រប់ |
| | .ពីកិច្ចសន្យាជួលដី ០៨ហិកតា | | $ - | $ 328,889.00 | | $ 328,889.00 | $ - | |
| II. **សរុបចំណូលសំរាប់ចំណាយ (៦+៧+៨)** | | | | **$ 13,272,957.99** | | | | |
| **5** | **ថវិការដ្ឋផ្តល់** | | | **$ 7,020,005.21** | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **6** | **ជំនួយផ្សេងៗ** | | | **$ 219,349.91** | | | | |
| | UNESCO | | | $ 184,000.00 | | | | |
| | DED | | | $ 6,880.00 | | | | |
| | ផ្តល់ដោយ IDRC-CRDI សំរាប់ជួលកុងស៊ុលតង់ រៀបចំគំរោងអភិវឌ្ឍន៏រុនតាឯក | | | $ 1,159.91 | | | | |
| | គំរោងអភិវឌ្ឍន៏ស្រះស្រង់ | | | $ 27,310.00 | | | | |
| **7** | **ថវិកាមូលនិធិអភិរក្សនិងអភិវឌ្ឍន៏** | | | **$ 5,633,713.87** | | | | |
| **8** | **ថវិកាបដិភាគរដ្ឋាភិបាលខ្មែរក្រវ៉ាត់បៃតង** | | | **$ 71,000.00** | | | | |

បានឃើញ និង ឯកភាព

**អគ្គនាយក អាជ្ញាធរអប្សរា**

នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ

សៀមរាប,ថ្ងៃទី ខែ ឆ្នាំ ២០១០

**អ្នកធ្វើតារាង**

**ប៊ុន ណារិទ្ធ**

**ច៉ាន់ ដានី**

**ប៊ុន សុជាតា**

ទីស្តីការគណៈរដ្ឋមន្ត្រី

អាជ្ញាធរអប្សរា

# របាយការណ៍ចំណាយថវិកាឆ្នាំ២០០៩

# របស់អាជ្ញាធរអប្សរា

ការអធិប្បាយឥណទាន និង សារប័ព្ចថវិកា

ឯកតា : ដុល្លារអាមេរិក

| ជំពូក | គណនី | អនុគណនី | | ចំណាត់ថ្នាក់ចំណាយ | សរុប៦ខែ | ខែកក្កដា | ខែសីហា | ខែកញ្ញា | ខែតុលា | វិច្ឆិកា | ធ្នូ | សរុប១២ខែ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុបចំណាយរួម (១+២+៣+៤+៥+៦) | | | | | 7,818,703.30 | 741,773.28 | 1,795,029.83 | 864,894.42 | 835,503.51 | 224,375.87 | 708,437.15 | 12,988,717.36 | |
| សរុបចំណាយរួម (១+២+៣+៤) | | | | | 4,034,261.05 | 741,773.28 | 1,795,029.83 | 659,534.43 | 604,499.86 | 224,375.87 | 708,437.15 | 8,767,911.47 | |
| ១. ចំណាយដំណើរការរដ្ឋបាល | | | | | 1,132,041.66 | 203,998.32 | 284,464.69 | 126,924.69 | 255,634.55 | 66,592.34 | 200,079.03 | 2,269,735.28 | |
| | | 2181 | | សំភារៈឧបករណ៍ដឹកជញ្ជូន | 38,000.00 | | 92,750.00 | | | | | 130,750.00 | |
| | | 2182 | | សំភារៈឧបករណ៍ការិយាល័យ | 7,116.00 | 1,262.00 | 500.00 | 1,972.00 | | 1,399.00 | 830.00 | 13,079.00 | |
| | | 2183 | | សំភារៈពតិមានវិទ្យា-ទូរគមនាគមន៏ និង ហ្វូតូកូពី | 5,028.00 | 12,525.00 | 408.00 | 8,034.00 | | | 905.00 | 26,900.00 | |
| | | 2184 | | សង្ហារឹម | 19,854.45 | | | 3,404.00 | 5,297.00 | 1,580.00 | 300.00 | 30,435.45 | |
| | | 2185 | | ឧបករណ៏ ផ្នែកអគ្គិសនី | 3,590.00 | | 1,840.00 | 1,410.00 | 413.30 | | 245.00 | 7,498.30 | |
| | | 2186 | | គ្រឿងម៉ាស៊ីន-សំភារៈប្រើប្រាស់ | - | | | | 8,793.00 | 440.00 | | 9,233.00 | |
| | | 6011 | | សំភារៈផ្គត់ផ្គង់ សំអាត និង អនាម័យ | 8,478.03 | 388.80 | 1,092.14 | | 715.73 | 374.40 | 376.00 | 11,425.10 | |
| | | 6015 | | ប្រេងឥន្ធនៈ និង ប្រេងរំអិល | 253,590.72 | 108,036.20 | | | 100,129.06 | | | 461,755.98 | |
| | | 6021 | | សំភារៈការិយាល័យ និង ការបោះពុម្ព | 52,242.13 | 10,131.48 | 16,879.67 | 7,136.75 | 6,601.72 | 9,137.26 | 948.54 | 103,077.55 | |
| | | 6022 | | សៀវភៅមើល និង ឯកសារ | - | | | 214.50 | | | 32.00 | 246.50 | |
| | | 6023 | | សំភារៈកំព្យូទ័រ-ហ្វូតូកូពី និង អគ្គិសនី | 18,504.65 | 201.00 | 59,869.29 | 1,440.25 | 655.00 | 1,606.00 | 1,512.50 | 83,788.69 | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 6042 | | ឯកសណ្ឋានសន្តិសុខ-អ្នកបើកបរ និង កម្មករ | 572.00 | 4,495.47 | 8,998.80 | 13,566.61 | 13,183.13 | | | 40,816.01 | |
| | | 6043 | | ឯកសណ្ឋាន-សំភារៈ-ជំរកឆ្នាំ | 43,718.32 | 140.00 | 248.97 | 1,315.00 | 461.53 | 2,255.68 | 334.00 | 48,473.50 | |
| | | 6053 | | សំភារៈប្រើប្រាស់ | 1,298.75 | 282.00 | | | | 80.00 | | 1,660.75 | |
| | | 6061 | | អគ្គិសនី | 118,592.67 | 1,340.55 | 758.90 | 1,763.50 | 67,676.99 | 661.83 | 27,670.64 | 218,465.08 | |
| | | 6062 | | ទឹក | 206.96 | 86.22 | 66.65 | | | 58.12 | 135.15 | 553.10 | |
| | | 6068 | | ផ្សេងៗ | 324.00 | | | 14.00 | | | 31.00 | 369.00 | |
| | | 6082 | | សំភារៈរោងជាង-សំភារៈប្រើប្រាស់ | 1,947.17 | 146.00 | 393.90 | | | 138.00 | 3,540.35 | 6,165.42 | |
| | | 6121 | | ការជួលផ្សេងៗ ( ជួលស្នាក់ការ និង មធ្យោបាយ) | 165,896.23 | 2,995.00 | 33,476.00 | 1,770.00 | 18,318.00 | 3,200.00 | 11,314.00 | 236,969.23 | |
| | | 6156 | | ការថែទាំ និង ជួសជុលមធ្យោយបាយដឹកជញ្ជូន | 5,187.52 | 472.00 | 12,346.12 | 17,422.36 | 933.78 | 14,780.50 | 3,534.00 | 54,676.28 | |
| | | 6157 | | ការថែទាំជួសជុលសំភារៈឧបករណ៍ការិ-<br>សំភារៈពត៌មានវិទ្យា | 5,848.78 | 61.00 | 538.00 | 292.00 | 1,306.39 | 797.50 | 561.00 | 9,404.67 | |
| | | 6159 | | ជួសជុលគ្រឿងម៉ាស៊ីន | - | | | 405.40 | | | 563.10 | 968.50 | |
| | | 6161 | | ពន្ធផ្លូវយានយន្ត-ផ្លាកលេខ និង ធានារ៉ាប់រង | 1,161.69 | | 201.50 | | 291.84 | 2,720.04 | 989.00 | 5,364.07 | |
| | | 6181 | | សំភារៈ និង ទំនិញ | 505.00 | | | | | | | 505.00 | |
| | | 6211 | | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | 1,530.00 | 382.50 | | 382.50 | 382.50 | 382.50 | 382.50 | 3,442.50 | |
| | | 6212 | | ភ្នាក់ងារអន្តរជាតិជាប់កិច្ចសន្យា | 102,405.99 | 5,300.00 | 15,005.68 | 31,431.50 | 4,984.00 | 2,500.00 | 84,753.92 | 246,381.09 | |
| | | 6221 | | សោហ៊ុយទទួលភ្ញៀវជាតិ | 45,307.21 | 6,531.68 | 9,217.12 | 1,730.00 | 7,756.46 | 2,747.10 | 10,165.46 | 83,455.03 | |
| | | 6222 | | សោហ៊ុយទទួលភ្ញៀវបរទេស | 304.30 | 133.55 | | 224.40 | 493.40 | | 1,066.50 | 2,222.15 | |
| | | 6223 | | ប្រជុំ សិក្ខាសាលា និង សន្និសីទ | 9,420.35 | 16,238.25 | 2,624.05 | 2,293.33 | 441.45 | 383.48 | 7,010.43 | 38,411.34 | |
| | | 6224 | | សោហ៊ុយពិធីបុណ្យ ( បុណ្យជាតិ-បុណ្យផ្សេងៗ) | 77,859.27 | 313.50 | 370.00 | 9,924.00 | | 1,685.44 | 8,368.34 | 98,520.55 | |
| | | 6225 | | ចំណាយសំរាប់ទិញវត្ថុអនុស្សាវរីយ៍<br>ក្នុង និងក្រៅប្រទេស | 2,156.60 | 146.00 | 201.00 | | 227.00 | | 146.78 | 2,877.38 | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 6226 | | ចំណាយតាំងពិពិរណ៍ក្នុង និងក្រៅប្រទេស | | | | | | | 405.50 | 405.50 | |
| | <u>*623*</u> | | | <u>*សោហ៊ុយជាវសារពត៌មាន និង ឯកសារ*</u> | 247.24 | 91.72 | 46.60 | 545.24 | 2,425.10 | 421.37 | 55.76 | 3,833.03 | |
| | | 6242 | | សោហ៊ុយបេសកកម្មក្នុងប្រទេស | 113,904.42 | 27,513.45 | 20,247.39 | 16,058.14 | 9,341.65 | 16,786.69 | 27,983.59 | 231,835.33 | |
| | | 6252 | | សោហ៊ុយបេសកកម្ម ក្រៅប្រទេស | 1,262.87 | 1,959.98 | 175.00 | 368.00 | 493.00 | 175.00 | 2,127.66 | 6,561.51 | |
| | | 6262 | | សោហ៊ុយទូរគមនាគមន៏ | 9,761.36 | 892.01 | 2,783.27 | 1,468.97 | 1,495.94 | 1,577.50 | 2,290.56 | 20,269.61 | |
| | | 6263 | | សោហ៊ុយសេវាអ៊ីមែល-អ៊ិនធឺណែត | 14,535.09 | 1,282.96 | 2,826.64 | 1,838.24 | 2,536.74 | 554.93 | 1,500.75 | 25,075.35 | |
| | | 6271 | | សោហ៊ុយធនាគារក្នុងការផ្ទេរប្រាក់ | 1,683.89 | 650.00 | 600.00 | 500.00 | 280.84 | 150.00 | | 3,864.73 | |
| **២. ប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភផ្សេងៗ** | | | | | **1,306,035.28** | **324,409.35** | **119,160.21** | **358,079.44** | **216,684.20** | **123,603.62** | **425,126.17** | <u>2,873,098.27</u> | - |
| | | 6421 | | បៀវត្សមូលដ្ឋាន | 548,384.87 | 223,564.07 | 3,933.21 | 227,680.99 | 121,855.23 | 3,104.45 | 235,789.48 | 1,364,312.30 | |
| | | 6423 | | ប្រាក់បំណាច់ម៉ោងបន្ថែម | 18,662.87 | 7,990.21 | 7,019.36 | 5,596.73 | 5,836.77 | 6,739.48 | 20,288.46 | 72,133.88 | |
| | | 6441 | | បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ | 183,998.97 | 28,340.87 | 42,338.52 | 30,188.72 | 34,569.74 | 33,736.16 | 51,855.66 | 405,028.64 | |
| | | 6445 | | ឧបត្ថម្ភកម្មករសំអាតប្រាសាទ | 83,589.72 | 16,279.41 | 11,614.55 | 17,015.97 | 8,204.80 | 10,004.83 | 23,804.90 | 170,514.18 | |
| | | 6446 | | ឧបត្ថម្ភឆ្មាំប្រាសាទ | 150,432.97 | 25,777.85 | 24,983.36 | 32,592.03 | 18,240.66 | 27,241.71 | 40,394.86 | 319,663.44 | |
| | | 6514 | | ឧបត្ថម្ភប៉ូលីសបេតិកភ័ណ្ឌ | 32,682.65 | 5,770.00 | 7,758.64 | 9,940.00 | 1,910.00 | 5,840.00 | 13,383.72 | 77,285.01 | |
| | | 6515 | | ឧបត្ថម្ភប៉ូលីសទេសចរណ៍ | 6,600.00 | 1,310.00 | 1,300.00 | 2,640.00 | | 1,290.00 | 2,809.05 | 15,949.05 | |
| | | 6516 | | ឧបត្ថម្ភស្ថាប័ន | 200,000.00 | | | | | | | 200,000.00 | |
| | | 6517 | | ឧបត្ថម្ភផ្សេងៗ-អំណោយ | 34,720.73 | 4,911.94 | 7,458.88 | 7,760.00 | 1,332.00 | 2,320.99 | 6,940.04 | 65,444.58 | |
| | | 6518 | | ឧបត្ថម្ភក្រុមអន្តរាគមន៏ និង ពន្លត់អគ្គីភ័យ | 44,582.50 | 9,905.00 | 11,223.69 | 24,315.00 | 24,175.00 | 32,556.00 | 28,950.00 | 175,707.19 | |
| | | 6519 | | ឧបត្ថម្ភពេទ្យសង្គ្រោះបន្ទាន់នៅតំបន់ រមណីយដ្ឋានអង្គរ | 2,380.00 | 560.00 | 1,530.00 | 350.00 | 560.00 | 770.00 | 910.00 | 7,060.00 | |
| **៣. ចំណាយការងារអភិរក្ស និង អភិវឌ្ឍន៍** | | | | | **1,547,684.11** | **213,365.61** | **491,404.93** | **174,530.30** | **132,181.11** | **34,179.91** | **83,231.95** | <u>2,676,577.92</u> | - |
| | | 2113 | | ដីធ្លីបុរីវប្បធមិ | 348,201.25 | | 282,880.00 | 65,321.25 | 8,000.00 | | | 704,402.50 | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 2114 | | ដីធ្លីរុនតាឯក | - | | | | | | | - | |
| | | 2123 | | ការងាររៀបចំដីធ្លីបុរីវប្បធម៌ | 13,556.00 | 2,765.00 | 2,400.00 | 2,350.00 | 1,575.00 | | 3,525.00 | 26,171.00 | |
| | | 2124 | | ការងាររៀបចំដីធ្លីរុនតាឯក | 20,080.00 | 680.00 | 8,420.00 | 6,372.54 | 490.00 | 790.00 | 750.00 | 37,582.54 | |
| | | 2131 | | សំណង់-អគារ | - | | | | | | | - | |
| | | 2134 | | សំណង់-ប្រព័ន្ធអគ្គិសនីបំភ្លឺសាធារណៈ | - | | | | | | | - | |
| | | 6016 | | សំភារៈសំអាត និង ថែទាំប្រាសាទ | 1,103.75 | 372.00 | | | 647.00 | 4,045.70 | 630.63 | 6,799.08 | |
| | | 6017 | | សេវាអនាម័យតំបន់ប្រាសាទអង្គរ | 249,823.39 | 4,424.05 | 93,745.85 | 4,447.44 | 71,064.29 | | | 423,505.02 | |
| | | 6081 | | ផ្លាកសញ្ញាសំគាល់ | 9,395.90 | 3,844.79 | 2,099.40 | 3,642.00 | 620.00 | 950.00 | 1,109.80 | 21,661.89 | |
| | | 6141 | | ការងារបណ្ដុះបណ្ដាល | 10.00 | | | | | | | 10.00 | |
| | | 6151 | | ការថែទាំ គ្រប់គ្រង ឧទ្យានព្រៃឈើតំបន់អង្គរ | 61,021.61 | 4,852.77 | 1,362.21 | 750.00 | 10,918.25 | 752.55 | 2,941.71 | 82,599.10 | |
| | | 6152 | | ការថែទាំ ជួសជុលអគារ និង ប្រាសាទ | 273,511.35 | 18,567.50 | 38,977.35 | 45,161.88 | 8,136.23 | 19,718.24 | 41,067.41 | 445,139.96 | |
| | | 6153 | | ការថែទាំ និង ជួសជុលផ្លូវ-ផ្លូវលំ-ស្ពាននិងលូ | 77,275.15 | 2,358.00 | | | 300.00 | 450.00 | 965.00 | 81,348.15 | |
| | | 6154 | | ការថែទាំបណ្ដាញផ្សេងៗ | 26.93 | | | | | | | 26.93 | |
| | | 6171 | | សិក្សា-ស្រាវជ្រាវ | 2,000.00 | | | | | | | 2,000.00 | |
| | | 6172 | | ការប្រមូលទិន្នន័យសំណង់បេតិកភណ្ឌ ក្នុងតំបន់សៀមរាប | 1,153.08 | | 2,930.17 | | | | 1,301.46 | 5,384.71 | |
| | | 6173 | | ការងារសិក្សាប្រព័ន្ធទឹកបុរាណ និង អាកាសធាតុ | 55,157.89 | 52,833.02 | 5,991.36 | 35,082.91 | 6,604.45 | 381.63 | 17.00 | 156,068.26 | |
| | | 6174 | | ការងារសាងសង់មជ្ឈមណ្ឌលលំនៅដ្ឋាន និង ផ្ទះគំរូ | 200.00 | | | | | | | 200.00 | |
| | | 6175 | | ស្រាវជ្រាវវប្បធម៌សម័យអង្គរឡបុរាណ-កុសាលភាជន៍ | - | | | | | | 24,240.00 | 24,240.00 | |
| | | 6227 | | ការឃោសនា និង ផ្សព្វផ្សាយពត៌មានសាធារណៈ | 58,959.03 | 14,047.73 | 1,212.30 | 1,930.00 | 4,049.00 | 1,230.87 | 4,914.62 | 86,343.55 | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 6281 | | ការងារគ្រប់គ្រងប្រជាសាស្ត្រ និង អភិវឌ្ឍន៍តំបន់អង្គរ | 6,399.50 | 343.30 | 1,461.75 | | 18,185.49 | 766.35 | 45.07 | 27,201.46 | |
| | | 6282 | | ការងារគ្រប់គ្រងរៀបចំ ហេដ្ឋារចនាសម្ព័ន្ធភ្ញៀវទេសចរណ៍ | 6,387.98 | 642.50 | 46,785.97 | | | 981.16 | | 54,797.61 | |
| | | 6283 | | ការងារសហការទ្វេភាគី (ជួសជុលថែទាំប្រាសាទ) | - | | | | | | | - | |
| | | 6284 | | ការងារអភិរក្ស-អភិវឌ្ឍន៍ក្រុងសៀមរាប | 356,053.38 | 102,636.82 | | 4,828.98 | 405.00 | 1,984.50 | | 465,908.68 | |
| | | 6286 | | ការងារគ្រប់គ្រងរថយន្តអគ្គិសនី និង កង់អាគុយ | 6,255.87 | 4,698.13 | 3,138.57 | 4,643.30 | 1,186.40 | 2,128.91 | 1,724.25 | 23,775.43 | |
| | 093 | | | ការងារកំណាយសង្គ្រោះ | 936.30 | 300.00 | | | | | | 1,236.30 | |
| | | 6561 | | វិភាគទានដល់អង្គការអន្តរជាតិនានា | 175.75 | | | | | | | 175.75 | |
| **៤. ចំណាយថ្លៃសាងសង់ស្នាក់ការអាជ្ញាធរអប្សរា** | | | | | **48,500.00** | **-** | **900,000.00** | **-** | **-** | **-** | **-** | 948,500.00 | - |
| | | | 2187 | សាងសង់អគារស្នាក់ការ | 48,500.00 | | 900,000.00 | | | | | 948,500.00 | |
| **៥. ចំណាយប្រាក់មូលនិធិអភិរក្សនិងអភិវឌ្ឍន៍** | | | | | **3,736,931.33** | | | **205,359.99** | **231,003.65** | | | 4,173,294.97 | |
| **៦. ថវិកាបដិភាគរបស់រដ្ឋាភិបាលគាំពារកែលំអស្ទឹងសៀមរាប** | | | | | **47,510.92** | | | | | | | 47,510.92 | |

បានឃើញ និង ឯកភាព

**អគ្គនាយកអាជ្ញាធរអប្សរា**

**ប៊ុន ណារិទ្ធ**

បានឃើញ និង ឯកភាព

**ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និង គណនេយ្យ**

**ខ៉ាន់ ដានី**

សៀមរាប, ថ្ងៃទី ខែ ឆ្នាំ២០១០

**អ្នកធ្វើតារាង**

**ប៊ុន សុជាតា**